

ឯកសារគម្ពីព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ១ ដល់ ភាគ៥០
គឺជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងបុត្រធីតា,
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស ។ និងទុកក្នុង
គេហទំព័រ៥000ឆ្នាំ សម្រាប់ជាធម្មទាន ។

កែសម្រួលតាមកុំព្យូទ័រ តម្រូវឧបករណ៍អានអេឡិត្រូនិច
ដោយខ្ញុំព្រះករុណា ខ្ញុំបាទ ស្រុង-ចាន់ណា ៕

www.5000-years.org

ព្រះ
ត្រៃបិដកបាលី
នឹង
សេចក្ដីប្រែជាភាសាខ្មែរ
វិនយបិដក បរិវារ
ទុតិយភាគ
១៣

ខន្ធកបុច្ឆា ឯកុត្តរិកៈ ឧបោសថាទិបុច្ឆាវិសជ្ជនា

អត្ថវសេបករណៈ គាថាសង្គណិកៈ

នឹងអធិករណភេទ ជាដើម

បោះពុម្ពលើកទី ២

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥០១

ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ដល់ស្មារតីស្ងួត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។

ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។

ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានស្ងួត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete collection of " TRIPITAKA " to the Cambodian Buddhists on behalf of the Japanese Buddhist community.

អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្ដានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្ដីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្ដេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

អ្នកតំណាងចាត់ការ Rev. Muchaku Seikyo

ប្រធានការិយាល័យ Rev. Sinohara Eiichi

អ្នកចាត់ការ Rev. Matunaga Zendo Rev. Arima Jitsujo Rev. Ito Yoshimichi
Rev. Watai Keiichi Rev. Sugiya Yoshizumi Rev. Sigeta Shincyo
Rev. Maeda Risyo Rev. Nakajima Kyoshi Mr. Ei Rokusuke

『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表	無着　成恭	世話人	松永　然道	有馬　実成
事務局長	篠原　鋭一		伊藤　佳通	渡井　奎一
			杉谷　義純	茂田　真澄
			前田　利勝	中島　教之
			永　六輔	

Acknowledgment

My dear Cambodian friends and respected members of the Cambodian Buddhist community.

It gives me a great pleasure to learn that the translation of the " Pali Tripitaka " into Cambodian by the " Tripitaka Commission " of the Buddhist Institute, Phnom Penh has been successfully achieved. The project to translate the Tripitaka was launched in 1930 and took 39 years to complete the whole work only in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but is also an important milestone in the history of publication in Cambodia.

Revival and prosperity of Buddhism in Cambodia is the ardent desire of the Japanese Buddhist Community. It is with this spirit that we have completed this important project and want to present the complete work to the Cambodian Buddhist community. It is a present not only to the Buddhist community in Cambodia but also to the Cambodian people and all the peace loving people in the world.

Cambodia experienced the greatest tragedies of modern times and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount this grief and anger, and to forgive and start working again for world peace.

This great work is a symbol of Japanese Buddhist communities resolve to work with our Cambodian brothers and sisters toward world peace and a testimony to the friendship between the people.

Join hands in prayer...
July 1994

TRIPITAKA PUBLISHING SUPPORT COMMITTEE
Project Manager: Rev. Seikyo Muchaku
Secretary General: Rev. Eiichi Sinohara
Management Team:
Rev. Zendo Matunaga   Rev. Jitsujo Arima   Rev. Yoshimichi Ito
Rev. Keiichi Watai   Rev. Yoshizumi Sugiya   Rev. Shincyo Sigeta
Rev. Risyo Maeda   Rev. Kyoshi Nakajima   Mr. Rokusuke Ei

វិនយបិដក បរិវារៈ

ទុតិយភាគ

១៣

ខន្ធកបុច្ឆា ឯកុត្តរិកៈ ឧបោសថាទិបុច្ឆាវិសជ្ជនា

អត្ថវសេ បករណៈ គាថាសង្គណិកៈ

នឹង អធិករណភេទ ជាដើម

ព. ស. ២៥០១

ខន្ធកបុច្ឆា

(១) ឧបសម្បន្នំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ

សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

ឧបសម្បន្នំ វិស្សជ្ជិសំ សនិទានំ សនិទ្ទេសំ

សមុក្កដ្ឋបទានំ ទ្វេ អាបត្តិយោ ។

(២) ឧបោសថំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ

សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

ឧបោសថំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ

សមុក្កដ្ឋបទានំ តិស្សោ អាបត្តិយោ ។

(៣) វស្សូបនាយិកំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ

សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

វស្សូបនាយិកំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ

សមុក្កដ្ឋបទានំ ឯកា អាបត្តិ ។

ខន្ធកបញ្ហា

(១) ខ្ញុំនឹងសួរឧបសម្បទាខន្ធក: ដែលប្រកបដោយនិទាន (ហេតុដែលទ្រង់បញ្ញត្តសិក្ខាបទ) ប្រកបដោយនិទ្ទេស (សំដែងអំពីបុគ្គលជាដើម) អាបត្តិរបស់បទឧក្រិដ្ឋ[១] មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយឧបសម្បទាខន្ធក: ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន ២ ។

(២) ខ្ញុំនឹងសួរឧបោសថក្ខន្ធក: ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយឧបោសថក្ខន្ធក: ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន ៣ ។

(៣) ខ្ញុំនឹងសួរវស្សូបនាយិកក្ខន្ធក: ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយវស្សូបនាយិកក្ខន្ធក: ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន ១ ។

---

១ បទដែលព្រះអង្គទ្រង់ហាមមិនឲ្យភិក្ខុឲ្យឧបសម្បទាដល់បុគ្គលមានអាយុមិនគ្រប់ ២០ ឆ្នាំជាដើម ។

(៤) បវារណំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ ស-
មុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

បវារណំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋ-
បទានំ តិស្សោ អាបត្តិយោ ។

(៥) ចម្មសញ្ញុត្តំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ
សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

ចម្មសញ្ញុត្តំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ ស-
មុក្កដ្ឋបទានំ តិស្សោ អាបត្តិយោ ។

(៦) ភេសជ្ជំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ ស-
មុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

ភេសជ្ជំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្ក-
ដ្ឋបទានំ តិស្សោ អាបត្តិយោ ។

(៧) កឋិនកំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ ស-
មុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

កឋិនកំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ ស-
មុក្កដ្ឋបទានំ នត្ថិ តត្ថ អាបត្តិ ។

វិនយបិដក បរិវារ

(៤) ខ្ញុំនឹងសួរបវារណាខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទៗក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយបវារណាខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទៗក្រិដ្ឋ មាន ៣ ។

(៥) ខ្ញុំនឹងសួរចម្មក្ខន្ធកៈ (ចម្មក្ខន្ធកៈ) ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទៗក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយចម្មក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទៗក្រិដ្ឋ មាន ៣ ។

(៦) ខ្ញុំនឹងសួរភេសជ្ជក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទៗក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយភេសជ្ជក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទៗក្រិដ្ឋ មាន ៣ ។

(៧) ខ្ញុំនឹងសួរកឋិនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទៗក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយកឋិនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស ឯអាបត្តិរបស់បទៗក្រិដ្ឋ មិនមានក្នុងកឋិនក្ខន្ធកៈនោះទេ ។

(៨) ចីវរសញ្ញុត្តំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

ចីវរសញ្ញុត្តំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ ស-មុក្កដ្ឋបទានំ តិស្សោ អាបត្តិយោ ។

(៩) ចម្បេយ្យកំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

ចម្បេយ្យកំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ ស-មុក្កដ្ឋបទានំ ឯកា អាបត្តិ ។

(១០) កោសម្ពកំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

កោសម្ពកំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ ស-មុក្កដ្ឋបទានំ ឯកា អាបត្តិ ។

(១១) កម្មក្ខន្ធកំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

កម្មក្ខន្ធកំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ ស-មុក្កដ្ឋបទានំ ឯកា អាបត្តិ ។

ខន្ធកបុច្ឆា បុច្ឆាវិសជ្ជនាអំពីចីវរសញ្ញត្តជាដើម

(៨) ខ្ញុំនឹងសួរចីវរសញ្ញត្ត (ចីវរក្ខន្ធកៈ) ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ១ៗក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយចីវរសញ្ញត្ត ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ១ៗក្រិដ្ឋ មាន ៣ ។

(៩) ខ្ញុំនឹងសួរចម្មក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ១ៗក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយចម្មក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ១ៗក្រិដ្ឋ មាន ១ ។

(១០) ខ្ញុំនឹងសួរកោសម្ពិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ១ៗក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយកោសម្ពិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ១ៗក្រិដ្ឋ មាន ១ ។

(១១) ខ្ញុំនឹងសួរកម្មក្ខន្ធកៈដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ១ៗក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយកម្មក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ១ៗក្រិដ្ឋ មាន ១ ។

(១២) បារិវាសិកំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

បារិវាសិកំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ ឯកា អាបត្តិ ។

(១៣) សមុច្ចយំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

សមុច្ចយំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ ឯកា អាបត្តិ ។

(១៤) សមថំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

សមថំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ ទ្វេ អាបត្តិយោ ។

(១៥) ខុទ្ទកវត្ថុកំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

ខុទ្ទកវត្ថុកំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ តិស្សោ អាបត្តិយោ ។

(១២) ខ្ញុំនឹងសួរបរិវាសិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយបរិវាសិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន ១ ។

(១៣) ខ្ញុំនឹងសួរសមុច្ចយក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយសមុច្ចយក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន ១ ។

(១៤) ខ្ញុំនឹងសួរសមថក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយសមថក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន ៤ ។

(១៥) ខ្ញុំនឹងសួរខុទ្ទកវត្ថុក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយខុទ្ទកវត្ថុក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន ៣ ។

(១៦) សេនាសនំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

សេនាសនំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ តិស្សោ អាបត្តិយោ ។

(១៧) សង្ឃភេទំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

សង្ឃភេទំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ ទ្វេ អាបត្តិយោ ។

(១៨) សមាចារំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

សមាចារំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ ឯកា អាបត្តិ ។

(១៩) ឋបនំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

ឋបនំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ ឯកា អាបត្តិ ។

(១៦) ខ្ញុំនឹងសួរសេនាសនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ៖ក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយសេនាសនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ៖ក្រិដ្ឋ មាន ៣ ។

(១៧) ខ្ញុំនឹងសួរសង្ឃភេទក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ៖ក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយសង្ឃភេទក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ៖ក្រិដ្ឋ មាន ២ ។

(១៨) ខ្ញុំនឹងសួរសមាចារ (វត្តក្ខន្ធកៈ) ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ៖ក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយសមាចារ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ៖ក្រិដ្ឋ មាន ១ ។

(១៩) ខ្ញុំនឹងសួរឋាតិមោក្ខដ្ឋបនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ៖ក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយបាតិមោក្ខដ្ឋបនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទ៖ក្រិដ្ឋ មាន ១ ។

[២០] ភិក្ខុនីឱវគ្គកំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

ភិក្ខុនីឱវគ្គកំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ ទ្វេ អាបត្តិយោ ។

[២១] បញ្ចសតិកំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

បញ្ចសតិកំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ នត្ថិ តត្ថ(១) អាបត្តិ ។

[២២] សត្តសតិកំ បុច្ឆិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ កតិ អាបត្តិយោ ។

សត្តសតិកំ វិស្សជ្ជិស្សំ សនិទានំ សនិទ្ទេសំ សមុក្កដ្ឋបទានំ នត្ថិ តត្ថ(២) អាបត្តីតិ ។

ខន្ធកបុច្ឆា(៣) និដ្ឋិតា បឋមា ។

តស្សុទ្ទានំ

[២៣] ឧបសម្បទុបោសថំ(៤)

វស្សូបនា បវារណា(៥)

១-២ ឱ. ម. ន កតមា ។ ៣ ឱ. ខន្ធកបុច្ឆាវារំ ។ ៤ ឱ. ម. ឧបសម្បទូបោសថោ ។ ៥ ឱ. ម. វស្សូបនាយិកបវារណា ។

(៦០) ខ្ញុំនឹងសួរភិក្ខុនីខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទទុក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយភិក្ខុនីខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទទុក្រិដ្ឋ មាន ២ ។

(៦១) ខ្ញុំនឹងសួរបញ្ចសតិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទទុក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយបញ្ចសតិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទទុក្រិដ្ឋ មិនមានក្នុងបញ្ចសតិកក្ខន្ធកៈនោះទេ ។

(៦២) ខ្ញុំនឹងសួរសត្តសតិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទទុក្រិដ្ឋ មានប៉ុន្មាន ។

ខ្ញុំនឹងឆ្លើយសត្តសតិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទទុក្រិដ្ឋ មិនមានក្នុងសត្តសតិកក្ខន្ធកៈនោះទេ ។

ចប់ ខន្ធកបុច្ឆា ទី ១ ។

ឧទ្ទាន គឺ បញ្ជីរឿងនៃពាក្យសួរអំពីខន្ធកៈនោះ

(៦៣) (ខន្ធកៈ ២២ គឺ) ឧបសម្បទាខន្ធកៈ ១ ឧបោសថក្ខន្ធកៈ ១ វស្សូបនាយិកក្ខន្ធកៈ ១ បវារណាខន្ធកៈ ១

ខន្ធកបុញ្ញ ឧទ្ទានគាថា

ចម្មភេសជ្ជកឋិនា
ចីវរំ ចម្បេយ្យកេន ច
កោសម្ពក្ខន្ធកំ កម្មំ
បារិវាសិកសមុច្ចយា
សមថា ខុទ្ទកា សេនា
សង្ឃភេទសមាចារា[១] ។
ឋបនំ ភិក្ខុនីនញ្ច
បញ្ចសត្តសតេន ចាតិ ។

---

១ ឱ. ម. សង្ឃភេទ សមាចារោ ។

ខន្ធកបញ្ហា ឧទ្ទានគាថា

ចម្មក្ខន្ធក: ១ ភេសជ្ជក្ខន្ធក: ១ កឋិនក្ខន្ធក: ១ ចីវរក្ខន្ធក: ១ ចម្បេយ្យក្ខន្ធកៈ ១ កោសម្ពិកក្ខន្ធក: ១ កម្មក្ខន្ធកៈ ១ បារិវាសិកក្ខន្ធក: ១ សមុច្ចយក្ខន្ធក: ១ សមថក្ខន្ធកៈ ១ ខុទ្ទកវត្ថុក្ខន្ធកៈ ១ សេនាសនក្ខន្ធក: ១ សង្ឃភេទក្ខន្ធក: ១ សមាចារ គឺវត្តក្ខន្ធក: ១ ៗ បាតិមោក្ខដ្ឋបនក្ខន្ធក: ១ ភិក្ខុនីខន្ធក: ១ បញ្ចសតិកក្ខន្ធក: ១ សត្តសតិកក្ខន្ធក: ១ ៗ

ឯកុត្តរិកំ

(២៤) អាបត្តិករា ធម្មា ជានិតព្វា ។ អនាបត្តិករា ធម្មា ជានិតព្វា ។ អាបត្តិ ជានិតព្វា ។ អនាបត្តិ ជានិតព្វា ។ លហុកា អាបត្តិ ជានិតព្វា ។ គរុកា អាបត្តិ ជានិតព្វា ។ សាវសេសា អាបត្តិ ជានិតព្វា ។ អនវសេសា អាបត្តិ ជានិតព្វា ។ ទុដ្ឋុល្លា អាបត្តិ ជានិតព្វា ។ អទុដ្ឋុល្លា អាបត្តិ ជានិតព្វា ។ សប្បដិកម្មា អាបត្តិ ជានតិព្វា ។ អប្បដិកម្មា អាបត្តិ ជានិតព្វា ។ ទេសនាគាមិនី អាបត្តិ ជានិតព្វា ។ អទេសនាគាមិនី អាបត្តិ ជានិតព្វា ។ អន្តរាយិកា អាបត្តិ ជានិតព្វា ។

ឯកុត្តរិកៈ

(៤៤) ភិក្ខុត្រូវស្គាល់ធម៌ ដែលធ្វើឲ្យមានអាបត្តិ(១) ។ ភិក្ខុត្រូវស្គាល់ធម៌ដែលធ្វើមិនឲ្យមានអាបត្តិ(២) ។ ភិក្ខុត្រូវស្គាល់អាបត្តិ(៣) ។ ភិក្ខុត្រូវស្គាល់អនាបត្តិ(៤) ។ ភិក្ខុត្រូវស្គាល់លហុកាបត្តិ(អាបត្តិស្រាល) ។ ភិក្ខុត្រូវស្គាល់គរុកាបត្តិ (អាបត្តិធ្ងន់) ។ ភិក្ខុត្រូវស្គាល់សាវសេសាបត្តិ (លើកតែអាបត្តិបារាជិកចេញ) ។ ភិក្ខុត្រូវស្គាល់អនវសេសាបត្តិ (អាបត្តិបារាជិក) ។ ភិក្ខុត្រូវស្គាល់ទុដ្ឋុល្លាបត្តិ គឺ អាបត្តិ ២ កងខាងដើម ។ ភិក្ខុត្រូវស្គាល់អទុដ្ឋុល្លាបត្តិ គឺអាបត្តិ ៥ កងខាងចុង ។ ភិក្ខុត្រូវស្គាល់អាបត្តិសំដែងចេញបាន ។ ភិក្ខុត្រូវស្គាល់អាបត្តិសំដែងចេញមិនបាន ។ ភិក្ខុត្រូវស្គាល់អាបត្តិដែលជាទេសនាគាមិនី ។ ភិក្ខុត្រូវស្គាល់អាបត្តិដែលមិនមែនជាទេសនាគាមិនី ។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលធ្វើនូវសេចក្តីអន្តរាយ(៥) ។

---

១ អដ្ឋកថា ថា សមុដ្ឋាននៃអាបត្តិ ៦ ហៅថា ធម៌ធ្វើឲ្យមានអាបត្តិ ព្រោះភិក្ខុដែលត្រូវអាបត្តិនោះ ដោយសមុដ្ឋាន ៦ នេះឯង ។ ២ សមថៈទាំង ៧ ហៅថា ធម៌ធ្វើមិនឲ្យមានអាបត្តិ ។ ៣ គឺត្រូវស្គាល់អាបត្តិដែលមានក្នុងសិក្ខាបទនោះៗ នឹងក្នុងវិភង្គ ។ ៤ គឺត្រូវស្គាល់អនាបត្តិដោយន័យថា បើភិក្ខុមិនត្រេកអរក៏មិនមានអាបត្តិ ដូច្នេះជាដើម ។ ៥ អាបត្តិណាដែលភិក្ខុក្លែងកន្លងហើយ តែងធ្វើសេចក្តីអន្តរាយដល់ឋានសួគ៌នឹងព្រះនិព្វាន អាបត្តិនោះឈ្មោះថា ធ្វើសេចក្តីអន្តរាយ ។

ឯកុត្តរិកំ ឯកកំ

អនន្តរាយិកា អាបត្តិ ជានិតព្វា ។ សាវជ្ជបញ្ញត្តិ អាបត្តិ ជានិតព្វា ។ អនវជ្ជបញ្ញត្តិ អាបត្តិ ជានិតព្វា ។ កិរិយតោ សមុដ្ឋិតា អាបត្តិ ជានិតព្វា ។ អកិរិយតោ សមុដ្ឋិតា អាបត្តិ ជានិតព្វា ។ កិរិយាកិរិយតោ សមុដ្ឋិតា អាបត្តិ ជានិតព្វា ។ បុព្វាបត្តិ ជានិតព្វា ។ អបរាបត្តិ ជានិតព្វា ។ បុព្វាបត្តីនំ អន្តរាបត្តិ ជានិតព្វា ។ អបរាបត្តីនំ អន្តរាបត្តិ ជានិតព្វា ។ ទេសិតា គណនុបគា អាបត្តិ ជានិតព្វា ។ ទេសិតា ន គណ-

ឯកុត្តរិកៈ ឯកកៈ (ពួកមួយ ៗ)

ភិក្ខុត្រូវស្គាល់អាបត្តិ ដែលមិនធ្វើនូវសេចក្តីអន្តរាយ[១] ។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលជាសាវជ្ជបញ្ញត្តិ[២] ។ ភិក្ខុត្រូវស្គាល់អាបត្តិដែលជាអនវជ្ជបញ្ញត្តិ[៣] ។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលតាំងឡើងអំពីការធ្វើ (ដូចយ៉ាងបារាជិកាបត្តិ) ។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលតាំងឡើងអំពីការមិនធ្វើ (ដូចជាភិក្ខុត្រូវអាបត្តិព្រោះមិនអធិដ្ឋានចីវរ) ។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលតាំងឡើងអំពីការធ្វើនឹងការមិនធ្វើ (ដូចក្នុងកុដិការសិក្ខាបទ) ។ ភិក្ខុត្រូវស្គាល់អាបត្តិខាងដើម គឺអាបត្តិដែលភិក្ខុត្រូវមុន ។ ភិក្ខុត្រូវស្គាល់អាបត្តិខាងចុង គឺអាបត្តិដែលត្រូវបន្ទាប់គ្នាមក ។ ភិក្ខុត្រូវស្គាល់អាបត្តិជាចន្លោះនៃអាបត្តិខាងដើម[៤] ។ ភិក្ខុត្រូវស្គាល់អាបត្តិជាចន្លោះនៃអាបត្តិខាងចុង[៥] ។ ភិក្ខុត្រូវស្គាល់អាបត្តិដែលខ្លួនសំដែងហើយ ជាអាបត្តិគួរដល់កិរិយារាប់ គឺជាក់ធុរៈចេញបាន ។ ភិក្ខុត្រូវស្គាល់អាបត្តិ

---

១ អាបត្តិដែលជាបណ្ណត្តិវជ្ជៈ បើភិក្ខុកន្លងដោយមិនដឹង ក៏មិនធ្វើសេចក្តីអន្តរាយដល់សួគ៌និងព្រះនិព្វានឡើយ ។ ២ សាវជ្ជបញ្ញត្តិ គឺអាបត្តិដែលជាលោកវជ្ជៈ ។ ៣ អនវជ្ជបញ្ញត្តិ គឺអាបត្តិជាបណ្ណត្តិវជ្ជៈ ។ ៤ អាបត្តិជាចន្លោះនៃមូលវិសុទ្ធិ គឺបរិសុទ្ធ ព្រោះមូលាយ-បដិកស្សនៈ ។ ៥ អាបត្តិជាចន្លោះនៃអគ្ឃវិសុទ្ធិ គឺបរិសុទ្ធព្រោះបានទទួលអគ្ឃសមោធាន តែក្នុងអដ្ឋកថា កុរុន្ទី ពន្យល់ថា អាបត្តិជាចន្លោះនៃអាបត្តិខាងដើមនោះ គឺអាបត្តិដែលភិក្ខុត្រូវក្នុងបរិវាស ឯអាបត្តិជាចន្លោះនៃអាបត្តិខាងចុងនោះ គឺភិក្ខុត្រូវក្នុងវេលាប្រព្រឹត្តមានត្ត ។

នូបគា អាបត្តិ ជានិតព្វា ។ បញ្ញត្តិ ជានិតព្វា ។ អនុបញ្ញត្តិ ជានិតព្វា ។ អនុប្បន្នបញ្ញត្តិ ជានិតព្វា ។ សព្វត្ថបញ្ញត្តិ ជានិតព្វា ។ បទេសបញ្ញត្តិ ជានិតព្វា ។ សាធារណបញ្ញត្តិ ជានិតព្វា ។ អសាធារណបញ្ញត្តិ ជានិតព្វា ។ ឯកតោបញ្ញត្តិ ជានិតព្វា ។ ឧភតោបញ្ញត្តិ ជានិតព្វា ។ ថុល្លវជ្ជា អាបត្តិ ជានិតព្វា ។ អថុល្លវជ្ជា អាបត្តិ ជានិតព្វា ។ គិហិបដិសញ្ញុត្តា អាបត្តិ ជានិតព្វា ។ ន គិហិបដិសញ្ញុត្តា អាបត្តិ ជានិតព្វា ។ និយតា អាបត្តិ ជានិតព្វា ។ អនិយតា អាបត្តិ ជានិតព្វា ។ អាទិករោ បុគ្គលោ ជានិតព្វោ ។ អនាទិករោ បុគ្គលោ ជានិតព្វោ ។ អធិច្ចាបត្តិកោ បុគ្គលោ ជានិតព្វោ ។ អភិណ្ហាបត្តិកោ បុគ្គលោ ជានិតព្វោ ។ ចោទកោ បុគ្គលោ ជានិតព្វោ ។ ចុទិតកោ បុគ្គលោ ជានិតព្វោ ។ អធម្មចោទកោ បុគ្គលោ ជានិតព្វោ ។ អធម្មចុទិតកោ បុគ្គលោ ជានិតព្វោ ។

ដែលខ្លួនសំដែងហើយ តែមិនគួរដល់កិរិយាកប់(ដាក់ធុរៈចេញបាន) ។ ភិក្ខុត្រូវស្គាល់បញ្ញត្តិ ។ ភិក្ខុត្រូវស្គាល់អនុប្បញ្ញត្តិ ។ ភិក្ខុត្រូវស្គាល់អនុប្បន្នប្បញ្ញត្តិ ។ ភិក្ខុត្រូវស្គាល់សព្វត្ថប្បញ្ញត្តិ ។ ភិក្ខុត្រូវស្គាល់បទេសប្បញ្ញត្តិ ។ ភិក្ខុត្រូវស្គាល់សាធារណប្បញ្ញត្តិ ។ ភិក្ខុត្រូវស្គាល់អសាធារណប្បញ្ញត្តិ ។ ភិក្ខុត្រូវស្គាល់ឯកតោបញ្ញត្តិ ។ ភិក្ខុត្រូវស្គាល់ឧភតោបញ្ញត្តិ ។ ភិក្ខុត្រូវស្គាល់អាបត្តិមានទោសធ្ងន់ ។ ភិក្ខុត្រូវស្គាល់អាបត្តិមិនមានទោសធ្ងន់ ។ ភិក្ខុត្រូវស្គាល់អាបត្តិដែលបដិសំយុត្តដោយគ្រហស្ថ ។ ភិក្ខុត្រូវស្គាល់អាបត្តិដែលមិនបដិសំយុត្តដោយគ្រហស្ថ ។ ភិក្ខុត្រូវស្គាល់អាបត្តិដែលទៀង គឺអនន្តរិយកម្ម ៥ ។ ភិក្ខុត្រូវស្គាល់អាបត្តិដែលមិនទៀង គឺក្រៅអំពីអនន្តរិយកម្ម ។ ភិក្ខុត្រូវស្គាល់បុគ្គល ដែលធ្វើខុសខាងដើមបញ្ញត្តិ (អាទិកម្មិកបុគ្គល) ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលមិនធ្វើខុសខាងដើមបញ្ញត្តិ (អនុប្បញ្ញត្តិការកបុគ្គល) ។ ភិក្ខុត្រូវស្គាល់បុគ្គលអ្នកត្រូវអាបត្តិមិនបានជានិច្ច (ត្រូវអាបត្តិម្ដង ១) ។ ភិក្ខុត្រូវស្គាល់បុគ្គលអ្នកត្រូវអាបត្តិរឿយ ៗ (ត្រូវជានិច្ច) ។ ភិក្ខុត្រូវស្គាល់បុគ្គលអ្នកចោទ ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលគេចោទ ។ ភិក្ខុត្រូវស្គាល់បុគ្គលអ្នកចោទមិនត្រូវតាមធម៌ ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលគេចោទមិនត្រូវតាមធម៌ ។

ធម្មចោទកោ បុគ្គលោ ជានិតព្វោ ។ ធម្មចុទិតកោ បុគ្គលោ ជានិតព្វោ ។ និយតោ បុគ្គលោ ជានិតព្វោ ។ អនិយតោ បុគ្គលោ ជានិតព្វោ ។ ភព្វាបត្តិកោ បុគ្គលោ ជានិតព្វោ ។ អភព្វាបត្តិកោ បុគ្គលោ ជានិតព្វោ ។ ឧក្ខិត្តកោ បុគ្គលោ ជានិតព្វោ ។ អនុក្ខិត្តកោ បុគ្គលោ ជានិតព្វោ ។ នាសិតកោ បុគ្គលោ ជានិតព្វោ ។ អនាសិតកោ បុគ្គលោ ជានិតព្វោ ។ សមានសំវាសកោ បុគ្គលោ ជានិតព្វោ ។ នានាសំវាសកោ បុគ្គលោ ជានិតព្វោ ។ ឋបនំ ជានិតព្វន្តិ ។

ឯកកំ និដ្ឋិតំ ។

តស្សុទ្ទានំ

(២៥) ការា អាបត្តិ លហុកា

សាវសេសា ច ទុដ្ឋុល្លា

បដិកម្មទេសនា ច

ឯកុត្តរិកៈ ឧទ្ទានគាថា

ភិក្ខុត្រូវស្គាល់បុគ្គលអ្នកចោទត្រូវតាមធម៌ ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលគេចោទត្រូវតាមធម៌ ។ ភិក្ខុត្រូវស្គាល់និយតបុគ្គល (ដែលប្រកបដោយមិច្ឆត្តនិយតធម៌ ឬសម្មត្តនិយតធម៌) ។ ភិក្ខុត្រូវស្គាល់អនិយតបុគ្គល ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលគួរដល់អាបត្តិ គឺពួកសាវ័ក ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលមិនគួរដល់អាបត្តិ គឺព្រះពុទ្ធនឹងព្រះបច្ចេកពុទ្ធ ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលសង្ឃធ្វើឧក្ខេបនីយកម្ម ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលសង្ឃមិនបានធ្វើឧក្ខេបនីយកម្ម ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលសង្ឃឲ្យវិនាសចេញហើយ ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលសង្ឃមិនបានឲ្យវិនាសចេញ ។ ភិក្ខុត្រូវស្គាល់បុគ្គលមានសំវាសស្មើគ្នា ។ ភិក្ខុត្រូវស្គាល់បុគ្គលមានសំវាសផ្សេងៗគ្នា ។ ភិក្ខុត្រូវស្គាល់វិធីបញ្ឈប់បាតិមោក្ខ ។

ចប់ ឯកកៈ (ពួកមួយៗ) ។

ឧទ្ទាន គឺបញ្ជីរឿងនៃឯកកៈ (ពួកមួយ ៗ) នោះដូច្នេះ

[២៥] ហេតុដែលធ្វើឲ្យមានអាបត្តិ ១ លហុកាបត្តិ ១ សា-
វសេសាបត្តិ ១ ទុដ្ឋុល្លាបត្តិ ១ អាបត្តិដែលគួរសំដែងចេញ
បាន ១ អាបត្តិដែលជាទេសនាគាមិនី ១ អាបត្តិដែលធ្វើ

អន្តភវជ្ជកិរិយា(១)

កិរិយាកិរិយា(២) បុញ្ញា

អន្តភ គណានុបគា

បញ្ញត្តានុប្បន្នា(៣) សព្វា

សាធារណា ច ឯកតោ

ទុដ្ឋុល្លា តិហិ និយតា ច

អាទិអទិច្ចចោទកោ

អធម្មធម្មនិយតោ

អកញ្ញោក្ខិត្តជាសកោ ។

សមានំ បឋមនញ្ចេវ

ឧទ្ទានំ ឯកតោ(៤) ឥទន្តិ ។

[២៦] អត្ថាបត្តិ សញ្ញាវិមោក្ខា អត្ថាបត្តិ ន សញ្ញាវិមោក្ខា ។ អត្ថាបត្តិ លទ្ធសមាបត្តិកស្ស អត្ថាបត្តិ ន លទ្ធសមាបត្តិកស្ស ។ អត្ថាបត្តិ សទ្ធម្មប្បដិសញ្ញុត្តា អត្ថាបត្តិ អសទ្ធម្មប្បដិសញ្ញុត្តា ។

---

១ ខ. ម. អន្តភវជ្ជកិរិយំ ។ ២ ខ. កិរិយាកិរិយបុញ្ញា ។ ម. កិរិយាកិរិយំ បុញ្ញា ។
៣ ខ. បញ្ញត្តិ អនានុប្បន្នា ។ ៤ ខ. ម. ឯកកេ ។

សេចក្តីអន្តរាយ ១ អាបត្តិដែលជាសាវជ្ជបញ្ញត្តិ ១ អាបត្តិដែលតាំងឡើងអំពីការធ្វើ ១ អាបត្តិដែលតាំងឡើងអំពីការធ្វើនិងការមិនធ្វើ ១ អាបត្តិខាងដើម ១ អាបត្តិជាចន្លោះ ១ អាបត្តិគួរដល់កិរិយាកប់ ១ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នបញ្ញត្តិ ១ សព្វត្ថបញ្ញត្តិ ១ សាធារណបញ្ញត្តិ ១ អសាធារណបញ្ញត្តិ ១ ឯកតោបញ្ញត្តិ ១ ទុដ្ឋុល្លាបត្តិ ១ អាបត្តិដែលបដិសំយុត្តដោយគ្រហស្ថ ១ អាបត្តិទៀង ១ អាទិកម្មិកបុគ្គល ១ បុគ្គលអ្នកត្រូវអាបត្តិមិនជានិច្ច ១ បុគ្គលអ្នកចោទ ១ បុគ្គលអ្នកចោទមិនតាមធម៌ ១ ចោទតាមធម៌ ១ និយតបុគ្គល ១ បុគ្គលមិនគួរដល់អាបត្តិ ១ បុគ្គលដែលសង្ឃធ្វើឧក្ខេបនីយកម្ម ១ បុគ្គលដែលសង្ឃឲ្យវិនាស ១ បុគ្គលមានសំវាសស្មើគ្នា ១ វិធីបញ្ឈប់បាតិមោក្ខ ១ នេះជាឧទ្ទានក្នុងពួកមួយ ៗ ។

(២៦) អាបត្តិជាសញ្ញាវិមោក្ខ (សចិត្តកៈ) ក៏មាន អាបត្តិជានោសញ្ញាវិមោក្ខ (អចិត្តកៈ) ក៏មាន ។ អាបត្តិត្រូវដល់ភិក្ខុដែលបានសមាបត្តិក៏មាន អាបត្តិត្រូវដល់ភិក្ខុដែលមិនបានសមាបត្តិក៏មាន ។ អាបត្តិដែលប្រកបនឹងព្រះសទ្ធម្មក៏មាន អាបត្តិដែលប្រកបនឹងអសទ្ធម្មក៏មាន ។

ឯកុត្តរិកំ ទុកំ សបរិក្ខារប្បដិសញ្ញុត្តទុកា

អត្ថាបត្តិ សបរិក្ខារប្បដិសញ្ញុត្តា អត្ថាបត្តិ បរបរិក្ខារប្ប-
ដិសញ្ញុត្តា ។ អត្ថាបត្តិ សបុគ្គលប្បដិសញ្ញុត្តា អត្ថាបត្តិ
បរបុគ្គលប្បដិសញ្ញុត្តា ។ អត្ថិ សច្ចំ ភណន្តោ គរុកំ
អាបត្តឹ អាបជ្ជតិ អត្ថិ មុសា ភណន្តោ លហុកំ អា-
បត្តឹ អាបជ្ជតិ ។ អត្ថិ មុសា ភណន្តោ គរុកំ អាបត្តឹ
អាបជ្ជតិ អត្ថិ សច្ចំ ភណន្តោ លហុកំ អាបត្តឹ អា-
បជ្ជតិ ។ អត្ថាបត្តិ ភូមិគតោ អាបជ្ជតិ នោ វេហាសគ-
តោ អត្ថាបត្តិ វេហាសគតោ អាបជ្ជតិ នោ ភូមិគតោ ។
អត្ថាបត្តិ និក្ខមន្តោ អាបជ្ជតិ នោ បវិសន្តោ អត្ថាបត្តិ
បវិសន្តោ អាបជ្ជតិ នោ និក្ខមន្តោ ។ អត្ថាបត្តិ អា-
ទិយន្តោ អាបជ្ជតិ អត្ថាបត្តិ អនាទិយន្តោ អាបជ្ជតិ ។
អត្ថាបត្តិ សមាទិយន្តោ អាបជ្ជតិ អត្ថាបត្តិ ន សមា-
ទិយន្តោ អាបជ្ជតិ ។ អត្ថាបត្តិ ករោន្តោ អាបជ្ជតិ
អត្ថាបត្តិ ន ករោន្តោ អាបជ្ជតិ ។ អត្ថាបត្តិ ទេន្តោ
អាបជ្ជតិ អត្ថាបត្តិ ន ទេន្តោ អាបជ្ជតិ ។ អត្ថាបត្តិ
បដិគ្គណ្ហន្តោ អាបជ្ជតិ អត្ថាបត្តិ ន បដិគ្គណ្ហន្តោ
អាបជ្ជតិ ។ អត្ថាបត្តិ បរិភោគេន អាបជ្ជតិ អត្ថាបត្តិ

ឯកុត្តរិកៈ ទុកៈ (ពួកពីរ) អាបត្តិដែលប្រកបនឹងគ្រឿងបរិក្ខារជាដើម

អាបត្តិដែលប្រកបនឹងគ្រឿងបរិក្ខាររបស់ខ្លួនក៏មាន អាបត្តិដែលប្រកបនឹងគ្រឿងបរិក្ខាររបស់បុគ្គលដទៃក៏មាន ។ អាបត្តិដែលប្រកបនឹងបុគ្គលគឺខ្លួនឯងក៏មាន ។ អាបត្តិដែលប្រកបនឹងបុគ្គល គឺអ្នកដទៃក៏មាន ។ ភិក្ខុនិយាយពាក្យសច្ចៈត្រូវគរុកាបត្តិក៏មាន ភិក្ខុនិយាយពាក្យមុសាត្រូវលហុកាបត្តិក៏មាន ។ ភិក្ខុនិយាយពាក្យមុសាត្រូវគរុកាបត្តិក៏មាន ។ ភិក្ខុនិយាយពាក្យសច្ចៈត្រូវលហុកាបត្តិក៏មាន ។ ភិក្ខុនៅលើផែនដីត្រូវអាបត្តិក៏មាន នៅលើអាកាសមិនត្រូវអាបត្តិក៏មាន នៅលើអាកាសត្រូវអាបត្តិ នៅលើផែនដីមិនត្រូវអាបត្តិក៏មាន ។ ភិក្ខុដើរចេញទៅត្រូវអាបត្តិ ដើរចូលមកមិនត្រូវអាបត្តិក៏មាន ដើរចូលមកត្រូវអាបត្តិ ដើរចេញទៅមិនត្រូវអាបត្តិក៏មាន ។ ភិក្ខុកាន់យកត្រូវអាបត្តិក៏មាន មិនកាន់យកត្រូវអាបត្តិក៏មាន ។ ភិក្ខុសមាទាន (វត្ត) ត្រូវអាបត្តិក៏មាន មិនសមាទាន (វត្ត) ត្រូវអាបត្តិក៏មាន ។ ភិក្ខុធ្វើត្រូវអាបត្តិក៏មាន មិនធ្វើត្រូវអាបត្តិក៏មាន ។ ភិក្ខុឲ្យត្រូវអាបត្តិក៏មាន មិនឲ្យត្រូវអាបត្តិក៏មាន ។ ភិក្ខុទទួលត្រូវអាបត្តិក៏មាន មិនទទួលត្រូវអាបត្តិក៏មាន ។ ភិក្ខុត្រូវអាបត្តិព្រោះបរិភោគក៏មាន ត្រូវ

ន បរិភោគេន អាបជ្ជតិ ។ អត្ថាបត្តិ រត្តឹ អាបជ្ជតិ នោ ទិវា អត្ថាបត្តិ ទិវា អាបជ្ជតិ នោ រត្តឹ ។ អត្ថាបត្តិ អរុណុគ្គេ អាបជ្ជតិ អត្ថាបត្តិ ន អរុណុគ្គេ អាបជ្ជតិ ។ អត្ថាបត្តិ ឆិន្ទន្តោ អាបជ្ជតិ អត្ថាបត្តិ ន ឆិន្ទន្តោ អាបជ្ជតិ ។ អត្ថាបត្តិ ឆាទេន្តោ អាបជ្ជតិ អត្ថាបត្តិ ន ឆាទេន្តោ អាបជ្ជតិ ។ អត្ថាបត្តិ ធារេន្តោ អាបជ្ជតិ អត្ថាបត្តិ ន ធារេន្តោ អាបជ្ជតិ ។

[២៧] ទ្វេ ឧបោសថា ចាតុទ្ទសិកោ ច បណ្ណរសិកោ ច(១) ។ ទ្វេ បវារណា ចាតុទ្ទសិកា ច បណ្ណរសិកា ច ។ ទ្វេ កម្មានិ អបលោកនកម្មំ ញត្តិកម្មំ ។ អបរានិបិ ទ្វេ កម្មានិ ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ។ ទ្វេ កម្មវត្ថូនិ អបលោកនកម្មស្ស វត្ថុ ញត្តិកម្មស្ស វត្ថុ ។ អបរានិបិ ទ្វេ កម្មវត្ថូនិ ញត្តិទុតិយកម្មស្ស វត្ថុ ញត្តិចតុត្ថកម្មស្ស វត្ថុ ។ ទ្វេ កម្មទោសា អបលោកនកម្មស្ស ទោសោ ញត្តិកម្មស្ស ទោសោ ។ អបរេបិ ទ្វេ កម្មទោសា ញត្តិទុតិយកម្មស្ស ទោសោ ញត្តិចតុត្ថកម្មស្ស ទោសោ ។

១ ចាតុទ្ទសិយោ ច បណ្ណរសិយោ ចាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

អាបត្តិព្រោះមិនបរិភោគក៏មាន ។ ភិក្ខុត្រូវអាបត្តិតែក្នុងវេលាយប់ មិនត្រូវអាបត្តិក្នុងវេលាថ្ងៃក៏មាន ត្រូវអាបត្តិតែក្នុងវេលាថ្ងៃ មិនត្រូវក្នុងវេលាយប់ក៏មាន ភិក្ខុត្រូវអាបត្តិក្នុងពេលអរុណរះក៏មាន ត្រូវអាបត្តិក្នុងពេលអរុណមិនទាន់រះក៏មាន ។ ភិក្ខុកាត់ត្រូវអាបត្តិក៏មាន មិនកាត់ត្រូវអាបត្តិក៏មាន ។ ភិក្ខុបិទបាំងត្រូវអាបត្តិក៏មាន មិនបិទបាំងត្រូវអាបត្តិក៏មាន ។ ភិក្ខុទ្រទ្រង់ត្រូវអាបត្តិក៏មាន មិនទ្រទ្រង់ត្រូវអាបត្តិក៏មាន ។

(២៧) ឧបោសថមាន ២ យ៉ាង គឺ ចាតុទ្ទសីឧបោសថ១ បណ្ណរសីឧបោសថ១ ។ បវារណាមាន ២ យ៉ាង គឺ ចាតុទ្ទសីបវារណា ១ បណ្ណរសីបវារណា ១ ។ កម្មមាន ២ យ៉ាង គឺ អបលោកនកម្ម ១ ញត្តិកម្ម១ ។ កម្មមាន ២ យ៉ាងដទៃទៀត គឺ ញត្តិទុតិយកម្ម ១ ញត្តិចតុត្ថកម្ម១ ។ ទីកើតនៃកម្មមាន ២ យ៉ាង គឺ ទីកើតនៃអបលោកនកម្ម ១ ទីកើតនៃញត្តិកម្ម១ ។ ទីកើតនៃកម្មមាន២ យ៉ាងដទៃទៀត គឺទីកើតនៃញត្តិទុតិយកម្ម១ ទីកើតនៃញត្តិចតុត្ថកម្ម១ ។ ទោសរបស់កម្មមាន ២ យ៉ាង គឺទោសនៃអបលោកនកម្ម ១ ទោសនៃញត្តិកម្ម១ ។ ទោសរបស់កម្មមាន ២ យ៉ាងដទៃទៀត គឺ ទោសនៃញត្តិទុតិយកម្ម ១ ទោសនៃញត្តិចតុត្ថកម្ម១ ។

ទេ្វ កម្មសម្បត្តិយោ អបលោកនកម្មស្ស សម្បត្តិ ញត្តិកម្មស្ស សម្បត្តិ ។ អបរាបិ ទេ្វ កម្មសម្បត្តិយោ ញត្តិទុតិយកម្មស្ស សម្បត្តិ ញត្តិចតុត្ថកម្មស្ស សម្បត្តិ ។ ទេ្វ នានាសំវាសកភូមិយោ អត្តនា វា អត្តានំ នានាសំវាសកំ ករោតិ សមគ្គោ វា នំ សង្ឃោ ឧក្ខិបតិ អទស្សនេ វា អប្បដិកម្មេ វា អប្បដិនិស្សគ្គេ វា ។ ទេ្វ សមានសំវាសកភូមិយោ អត្តនា វា អត្តានំ សមានសំវាសកំ ករោតិ សមគ្គោ វា នំ សង្ឃោ ឧក្ខិត្តំ ឱសារេតិ អទស្សនេ វា អប្បដិកម្មេ វា អប្បដិនិស្សគ្គេ វា ។

(២៨) ទេ្វ បារាជិកា ភិក្ខូនញ្ច ភិក្ខុនីនញ្ច ។ ទេ្វ សង្ឃាទិសេសា ទេ្វ ថុល្លច្ចយា ទេ្វ បាចិត្តិយា ទេ្វ បាដិទេសនីយា ទេ្វ ទុក្កដា ទេ្វ ទុព្ភាសិតា ភិក្ខូនញ្ច ភិក្ខុនីនញ្ច សត្ត អាបត្តិយោ សត្ត អាបត្តិក្ខន្ធា ។ ទ្វីហាការេហិ សង្ឃោ ភិជ្ជតិ កម្មេន វា សលាកគ្គាហេន វា ។

សម្បត្តិរបស់កម្មមាន ២ យ៉ាង គឺ សម្បត្តិនៃអបលោកនកម្ម ១ សម្បត្តិនៃញត្តិកម្ម ១ ។ សម្បត្តិរបស់កម្មមាន ២ យ៉ាងដទៃទៀត គឺ សម្បត្តិនៃញត្តិទុតិយកម្ម ១ សម្បត្តិនៃញត្តិចតុត្ថកម្ម ១ ។ ភូមិនៃភិក្ខុមានសំវាសផ្សេង ៗ គ្នាមាន ២ យ៉ាង គឺ ភិក្ខុធ្វើខ្លួនឲ្យមានសំវាសផ្សេងគ្នា ដោយខ្លួនឯង១ សង្ឃព្រមព្រៀងគ្នាលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ (ទិដ្ឋិអាក្រក់) ក្តី ១ ។ ភូមិនៃភិក្ខុមានសំវាសស្មើគ្នាមាន ២ យ៉ាង គឺ ភិក្ខុធ្វើខ្លួនឲ្យមានសំវាសស្មើគ្នា ដោយខ្លួនឯង ១ សង្ឃព្រមព្រៀងគ្នាសូត្រឱសារណកម្ម ចំពោះភិក្ខុដែលសង្ឃលើកវត្តហើយនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ (ទិដ្ឋិអាក្រក់) ក្តី ១ ។

[២៨] បារាជិកមាន ២ យ៉ាងគឺ បារាជិករបស់ពួកភិក្ខុ ១ បារាជិករបស់ពួកភិក្ខុនី ១ ។ សង្ឃាទិសេសមាន ២ ថុល្លច្ច័យមាន ២ បាចិត្តិយៈមាន ២ បាដិទេសនីយៈមាន ២ ទុក្កដមាន ២ ទុព្ភាសិតមាន ២ គឺរបស់ភិក្ខុ ១ របស់ភិក្ខុនី ១ រួមជាអាបត្តិ ៧ គឺ កងនៃអាបត្តិទាំង ៧ ។ សង្ឃបែកធ្លាយ ដោយអាការ ២ គឺ ដោយកម្ម ១ ដោយការចាប់ស្លាក ១ ។

[២៩] ទ្វេ បុគ្គលា ន ឧបសម្បាទេតព្វា អទ្ធានហីនោ អង្គហីនោ ។ អបរេបិ ទ្វេ បុគ្គលា ន ឧបសម្បាទេតព្វា វត្ថុវិបន្នោ ករណទុក្កដកោ ។ អបរេបិ ទ្វេ បុគ្គលា ន ឧបសម្បាទេតព្វា អបរិបូរោ បរិបូរោ(១) នោ ច យាចតិ ។ ទ្វិន្នំ បុគ្គលានំ និស្សាយ ន វត្ថព្វំ អលជ្ជិស្ស ច ពាលស្ស ច ។ ទ្វិន្នំ បុគ្គលានំ ន និស្សយោ ទាតព្វោ(២) អលជ្ជិស្ស ច លជ្ជិនោ ច ន យាចតិ ។ ទ្វិន្នំ បុគ្គលានំ និស្សយោ ទាតព្វោ ពាលស្ស ច លជ្ជិស្ស ច យាចតិ ។ ទ្វេ បុគ្គលា អភព្វា អាបត្តឹ អាបជ្ជិតុំ ពុទ្ធា ច បច្ចេកពុទ្ធា ច ។ ទ្វេ បុគ្គលា ភព្វា អាបត្តឹ អាបជ្ជិតុំ ភិក្ខូ ច ភិក្ខុនិយោ ច ។ ទ្វេ បុគ្គលា អភព្វា សញ្ចិច្ច អាបត្តឹ អាបជ្ជិតុំ ភិក្ខូ ច ភិក្ខុនិយោ ច អរិយបុគ្គលា ។ ទ្វេ បុគ្គលា ភព្វា សញ្ចិច្ច អាបត្តឹ អាបជ្ជិតុំ ភិក្ខូ ច ភិក្ខុនិយោ ច បុថុជ្ជនា ។ ទ្វេ បុគ្គលា អភព្វា សញ្ចិច្ច សាតិសារំ វត្ថុំ អជ្ឈាចរិតុំ ភិក្ខូ ច ភិក្ខុនិយោ ច អរិយបុគ្គលា ។ ទ្វេ បុគ្គលា ភព្វា សញ្ចិច្ច សាតិសារំ វត្ថុំ អជ្ឈាចរិតុំ ភិក្ខូ ច ភិក្ខុនិយោ ច បុថុជ្ជនា ។

---

១ ឱ. ម· សបរិបូរោ ។ ២ ឱ. ម. និស្សយោ ន ទាតព្វោ ។

(២៩) បុគ្គលដែលភិក្ខុមិនត្រូវឲ្យឧបសម្បទា មាន ២ ពួក គឺ បុគ្គលសាបសូន្យតាកាល ១ បុគ្គលសាបសូន្យតាអវយវៈ ១ ។ បុគ្គលដែលភិក្ខុមិនត្រូវឲ្យឧបសម្បទា មាន ២ ពួកដទៃទៀត គឺ បុគ្គលជាវត្ថុវិបត្តិ ១ បុគ្គលធ្លាប់ធ្វើអំពើអាក្រក់ ១ ។ បុគ្គលដែលភិក្ខុមិនត្រូវឲ្យឧបសម្បទា មាន ២ ពួកដទៃទៀត គឺ បុគ្គលមាន(បរិក្ខារ)មិនគ្រប់គ្រាន់ ១ បុគ្គលមាន(បរិក្ខារ)គ្រប់គ្រាន់ហើយ តែមិនសូម(ឧបសម្បទា) ១ ។ ភិក្ខុមិនត្រូវនៅអាស្រ័យនឹងបុគ្គល ២ ពួក គឺ បុគ្គលជាអលជ្ជី ១ បុគ្គលពាល ១ ។ ភិក្ខុមិនត្រូវឲ្យនិស្ស័យដល់បុគ្គល ២ ពួក គឺ បុគ្គលជាអលជ្ជី ១ បុគ្គលជាលជ្ជី តែមិនបានសូម ១ ។ ភិក្ខុត្រូវឲ្យនិស្ស័យដល់បុគ្គល ២ ពួក គឺ បុគ្គលល្ងង់ ១ បុគ្គលជាលជ្ជីហើយបានសូម ១ ។ បុគ្គលដែលមិនគួរត្រូវអាបត្តិមាន ២ គឺ ព្រះពុទ្ធ ១ ព្រះបច្ចេកពុទ្ធ ១ ។ បុគ្គលដែលគួរនឹងត្រូវអាបត្តិមាន ២ គឺ ភិក្ខុ ១ ភិក្ខុនី ១ ។ បុគ្គលមិនគួរនឹងត្រូវអាបត្តិ ព្រោះក្លែងមាន ២ គឺ ភិក្ខុ ១ ភិក្ខុនី ១ ដែលជាអរិយបុគ្គល ។ បុគ្គលដែលគួរនឹងត្រូវអាបត្តិ ព្រោះក្លែងមាន ២ គឺ ភិក្ខុ ១ ភិក្ខុនី ១ ដែលជាបុថុជ្ជន ។ បុគ្គលមិនគួរនឹងប្រព្រឹត្តកន្លងវត្ថុ ដែលប្រកបដោយទោសយ៉ាងធំ ព្រោះក្លែងមាន ២ គឺ ភិក្ខុ ១ ភិក្ខុនី ១ ដែលជាព្រះអរិយបុគ្គល ។ បុគ្គលគួរនឹងប្រព្រឹត្តកន្លងនូវវត្ថុ ដែលប្រកបដោយទោសយ៉ាងធំ ព្រោះក្លែងមាន ២ គឺ ភិក្ខុ ១ ភិក្ខុនី ១ ដែលជាបុថុជ្ជន ។

ឯកុត្តរិកំ ទុកំ ទ្វេ បដិក្កោសនាទយោ

(៣០) ទ្វេ បដិក្កោសនា កាយេន វា បដិក្កោសតិ វាចាយ វា បដិក្កោសតិ ។ ទ្វេ និស្សារណា អត្ថិ បុគ្គលោ អប្បត្តោ និស្សារណំ តញ្ចេ សង្ឃោ និស្សារេតិ ឯកច្ចោ សុនិស្សារិតោ ឯកច្ចោ ទុន្និស្សារិតោ ។ ទ្វេ ឱសារណា អត្ថិ បុគ្គលោ អប្បត្តោ ឱសារណំ តញ្ចេ សង្ឃោ ឱសារេតិ ឯកច្ចោ សោសារិតោ ឯកច្ចោ ទោសារិតោ ។ ទ្វេ បដិញ្ញា កាយេន វា បដិជានាតិ វាចាយ វា បដិជានាតិ ។ ទ្វេ បដិគ្គហា កាយេន វា បដិគ្គណ្ហាតិ កាយបដិពទ្ធេន វា បដិគ្គណ្ហាតិ ។ ទ្វេ បដិក្ខេបា កាយេន វា បដិក្ខិបតិ វាចាយ វា បដិក្ខិបតិ ។ ទ្វេ ឧបឃាតិកា សិក្ខូបឃាតិកា ច ភោគូបឃាតិកា ច ។ ទ្វេ ចោទនា កាយេន វា ចោទេតិ វាចាយ វា ចោទេតិ ។

ឯកុត្តរិកៈ ទុកៈ ការហាមឃាត់មានពីរយ៉ាងជាដើម

(៣០) ការហាមឃាត់មាន ២ យ៉ាង គឺ ហាមឃាត់ដោយកាយ ១ ហាមឃាត់ដោយវាចា ១ ។ ការសូត្រនិស្សារណកម្មមាន ២ យ៉ាង គឺបុគ្គលមិនដល់និស្សារណកម្មនៅឡើយ តែបើសង្ឃសូត្រនិស្សារណកម្មចំពោះបុគ្គលនោះ បុគ្គលពួកខ្លះឈ្មោះថាសង្ឃសូត្រនិស្សារណកម្មហើយដោយល្អ ១ បុគ្គលពួកខ្លះឈ្មោះថាសង្ឃសូត្រនិស្សារណកម្មដោយអាក្រក់ ១ ។ ការសូត្រឱសារណកម្មមាន ២ យ៉ាង គឺ បុគ្គលមិនទាន់ដល់ឱសារណកម្មនៅឡើយ តែបើសង្ឃសូត្រឱសារណកម្ម ចំពោះបុគ្គលនោះ បុគ្គលពួកខ្លះឈ្មោះថាសង្ឃសូត្រឱសារណកម្មហើយដោយល្អ ១ បុគ្គលខ្លះឈ្មោះថាសង្ឃសូត្រឱសារណកម្មហើយដោយអាក្រក់ ១ ។ ការប្តេជ្ញាមាន ២ យ៉ាង គឺ ប្តេជ្ញាដោយកាយ ១ ប្តេជ្ញាដោយវាចា ១ ។ ការទទួលមាន ២ យ៉ាង គឺ ទទួលដោយកាយ ១ ទទួលដោយវត្ថុដែលជាប់នឹងកាយ ១ ។ ការឃាត់មាន ២ យ៉ាង គឺ ឃាត់ដោយកាយ ១ ឃាត់ដោយវាចា ១ ។ ការបៀតបៀនមាន ២ យ៉ាង គឺ បៀតបៀនសិក្ខា១ បៀតបៀនគ្រឿងបរិភោគ (ជារបស់សង្ឃ ឬបុគ្គល) ១ ។ ការចោទមាន ២ យ៉ាង គឺ ចោទដោយកាយ ១ ចោទដោយវាចា ១ ។

(៣១) ទ្វេ កឋិនស្ស បលិពោធា អាវាសបលិពោធោ ច ចីវរបលិពោធោ ច ។ ទ្វេ កឋិនស្ស អបលិពោធា អាវាសាបលិពោធោ ច ចីវរាបលិពោធោ ច ។ ទ្វេ ចីវរានិ គហបតិកញ្ច បំសុកូលិកញ្ច ។ ទ្វេ បត្តា អយោបត្តោ ច មត្តិកាបត្តោ ច ។ ទ្វេ មណ្ឌលានិ តិបុមយញ្ច សីសមយញ្ច[១] ។ ទ្វេ បត្តស្ស អធិដ្ឋានា កាយេន វា អធិដ្ឋេតិ វាចាយ វា អធិដ្ឋេតិ ។ ទ្វេ ចីវរស្ស អធិដ្ឋានា កាយេន វា អធិដ្ឋេតិ វាចាយ វា អធិដ្ឋេតិ ។ ទ្វេ វិកប្បនា សម្មុខាវិកប្បនា ច បរម្មុខាវិកប្បនា ច ។ ទ្វេ វិនយា ភិក្ខូនញ្ច ភិក្ខុនីនញ្ច ។ ទ្វេ វេនយិកា បញ្ញត្តញ្ច បញ្ញត្តានុលោមញ្ច ។ ទ្វេ វិនយស្ស សល្លេខា អកប្បិយេ សេតុឃាតោ កប្បិយេ មត្តការិតា ។

(៣២) ទ្វីហាការេហិ អាបត្តិំ អាបជ្ជតិ កាយេន វា អាបជ្ជតិ វាចាយ វា អាបជ្ជតិ ។ ទ្វីហាការេហិ

១ ឱ. ម. តិបុមយំ សីសមយំ ។

[៣១] បលិពោធនៃកឋិនមាន ២ យ៉ាង គឺ អាវាសបលិពោធ ១ ចីវរបលិពោធ ១ ។ ការមិនមានបលិពោធនៃកឋិនមាន ២ យ៉ាង គឺ មិនមានបលិពោធនឹងអាវាស ១ មិនមានបលិពោធនឹងចីវរ ១ ។ ចីវរមាន ២ យ៉ាង គឺ គហបតីចីវរ ១ បំសុកូលចីវរ ១ ។ បាត្រមាន ២ យ៉ាង គឺ បាត្រដែក ១ បាត្រដី ១ ។ មណ្ឌលគឺជើងបាត្រមាន ២ យ៉ាង គឺ ជើងបាត្រដែលគេធ្វើដោយសំណប៉ាហាំង ១ ធ្វើដោយសំណកក់ ១ ។ ការអធិដ្ឋានបាត្រមាន ២ យ៉ាង គឺ អធិដ្ឋានដោយកាយ ១ អធិដ្ឋានដោយវាចា ១ ។ ការអធិដ្ឋានចីវរមាន ២ យ៉ាង គឺ អធិដ្ឋានដោយកាយ ១ អធិដ្ឋានដោយវាចា ១ ។ ការវិកប្បមាន ២ យ៉ាង គឺ វិកប្បក្នុងទីចំពោះមុខ ១ វិកប្បក្នុងទីកំបាំងមុខ ១ ។ វិន័យមាន ២ យ៉ាង គឺ វិន័យរបស់ពួកភិក្ខុ ១ របស់ពួកភិក្ខុនី ១ ។ អត្ថរបស់វិន័យមាន ២ យ៉ាង គឺ បញ្ញត្ត ១ បញ្ញត្តានុលោម (គឺ មហាបទេស ៤) ១ ។ សេចក្ដីផ្សេងនៃវិន័យមាន ២ យ៉ាង គឺ សម្រាប់នូវបច្ច័យក្នុងអកប្បិយវត្ថុ ១ ការធ្វើនូវប្រមាណក្នុងកប្បិយវត្ថុ ១ ។

[៣២] ភិក្ខុត្រូវអាបត្តិដោយអាការ ២ យ៉ាង គឺ ត្រូវដោយកាយ ១ ត្រូវដោយវាចា ១ ។ ភិក្ខុចេញចាកអាបត្តិដោយអាការ ២ យ៉ាង គឺចេញ

អាបត្តិយោ វុដ្ឋាតិ កាយេន វា វុដ្ឋាតិ វាចាយ វា វុដ្ឋាតិ ។ ទ្វេ បរិវាសា បដិច្ឆន្នបរិវាសោ ច អប្បដិច្ឆន្នបរិវាសោ ច ។ អបរេបិ ទ្វេ បរិវាសា សុទ្ធន្តបរិវាសោ ច សមោធានបរិវាសោ ច ។ ទ្វេ មានត្តា បដិច្ឆន្នមានត្តញ្ច អប្បដិច្ឆន្នមានត្តញ្ច (១) ។ អបរេបិ ទ្វេ មានត្តា បក្ខមានត្តញ្ច សមោធានមានត្តញ្ច ។ ទ្វិន្នំ បុគ្គលានំ រត្តិច្ឆេទោ បារិវាសិកស្ស ច មានត្តចារិកស្ស ច ។

[៣៣] ទ្វេ អនាទរិយានិ បុគ្គលានាទរិយញ្ច ធម្មានាទរិយញ្ច ។ ទ្វេ លោណានិ ជាតិមយញ្ច ខារិមយញ្ច (២) ។ អបរានិបិ ទ្វេ លោណានិ សាមុទ្ទញ្ច កាឡលោណញ្ច ។ អបរានិបិ ទ្វេ លោណានិ សិន្ធវញ្ច ឧព្ភិទញ្ច ។ អបរានិបិ ទ្វេ លោណានិ រោមកញ្ច បក្កាលកញ្ច ។ ទ្វេ បរិភោគា អព្ភន្តរបរិភោគោ ច

---

១ ឱ. ម. បដិច្ឆន្នមានត្តំ អប្បដិច្ឆន្នមានត្តំ ។ ២ ឱ. ម. ការិមយញ្ច ។

ចាកដោយកាយ ១ ចេញចាកដោយវាចា ១ ។ បរិវាសមាន ២ យ៉ាង គឺ បដិច្ឆន្នបរិវាស ១ អប្បដិច្ឆន្នបរិវាស ១ ។ បរិវាសមាន ២ យ៉ាងដទៃទៀត គឺ សុទ្ធន្តបរិវាស ១ សមោធានបរិវាស ១ ។ មានត្តមាន ២ យ៉ាង គឺ បដិច្ឆន្នមានត្ត ១ អប្បដិច្ឆន្នមានត្ត ១ ។ មានត្តមាន ២ យ៉ាងដទៃទៀត គឺ បក្ខមានត្ត ១ សមោធានមានត្ត ១ ។ ការដាច់រាត្រីរបស់បុគ្គល ២ ពួក គឺ ភិក្ខុកំពុងនៅបរិវាស ១ ភិក្ខុកំពុងប្រព្រឹត្តមានត្ត ១ ។

(៣៣) ការមិនអើពើមាន ២ យ៉ាង គឺ មិនអើពើនឹងបុគ្គល ១ មិនអើពើនឹងធម៌ ១ ។ អំបិលមាន ២ បែប គឺ អំបិលកើតឯង ១ អំបិលកើតអំពីជាតិដីប្រៃ ១ ។ អំបិលមាន ២ យ៉ាងដទៃទៀត គឺអំបិលកើតពីទឹកសមុទ្រ ១ អំបិលខ្មៅ ១ ។ អំបិលមាន ២ យ៉ាងដទៃទៀត គឺអំបិលសិន្ធវៈ (អំបិលមានសម្បុរសដុះលើភ្នំ) ១ អំបិលឧព្ភិទៈ (អំបិលដុះជាពន្លក ៗ ឡើងពីផែនដី) ១ ។ អំបិល ២ យ៉ាងដទៃទៀត គឺ អំបិលឈ្មោះរោមកៈ (អំបិលកើតក្នុងរោមជនបទ) ១ អំបិលឈ្មោះបក្កលកៈ (អំបិលកើតពីទឹកក្បួងដែលធ្វើអំពីស្រូវដំណើប) ១ ។ បរិភោគមាន ២ គឺ អព្ភន្តរបរិភោគ

ពាហិរបរិក្ខារោ ច ។ ទ្វេ អក្កោសា ហីនោ ច អក្កោសោ ឧក្កដ្ឋោ ច អក្កោសោ ។ ទ្វីហាការេហិ បេសុញ្ញំ ហោតិ បិយកម្យស្ស វា ភេទាធិប្បាយស្ស វា ។ ទ្វីហាការេហិ គណភោជនំ បសវតិ និមន្តនតោ វា វិញ្ញត្តិតោ វា ។ ទ្វេ វស្សូបនាយិកា បុរិមិកា ច បច្ឆិមិកា ច ។ ទ្វេ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ ទ្វេ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ[១] ។

[៣៤] ទ្វេ បុគ្គលា ពាលា យោ ច អនាគតំ ភារំ វហតិ យោ ច អាគតំ ភារំ ន វហតិ ។ ទ្វេ បុគ្គលា បណ្ឌិតា យោ ច អនាគតំ ភារំ ន វហតិ យោ ច អាគតំ ភារំ វហតិ ។ អបរេបិ ទ្វេ បុគ្គលា ពាលា យោ ច អកប្បិយេ កប្បិយសញ្ញី យោ ច កប្បិយេ អកប្បិយសញ្ញី ។ ទ្វេ បុគ្គលា បណ្ឌិតា យោ ច អកប្បិយេ អកប្បិយសញ្ញី យោ ច កប្បិយេ កប្បិយសញ្ញី ។ អបរេបិ ទ្វេ បុគ្គលា ពាលា យោ ច

១ ទ្វេ បាតិមោក្ខដ្ឋបនានិ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ធម្មិកានិ បាតិមោក្ខដ្ឋបនានីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

(បរិភោគលេបចូលទៅ) ១ អាហារបរិភោគ (ប្រើប្រាស់ខាងក្រៅ) ១ ។ ការដេរមាន ២ យ៉ាង គឺ ដេរយ៉ាងថោកទាប ១ ដេរយ៉ាងឧក្រិដ្ឋ ១ ។ ការញុះញង់កើតដោយអាការ ២ យ៉ាង គឺ ប៉ងដើម្បីឲ្យគេស្រឡាញ់ខ្លួន ១ ប៉ងដើម្បីបំបែកគ្នា ១ ។ ភិក្ខុទទួលគណភោជនបានដោយអាការ ២ យ៉ាង គឺ ដោយគេនិមន្ត ១ ដោយការសូមគេ ១ ។ ការចូលវស្សាមាន ២ យ៉ាង គឺ បុរិមិកាវស្សា ១ បច្ឆិមិកាវស្សា ១ ។ ការឃាត់ហាមបាតិមោក្ខ ដែលមិនប្រកបដោយធម៌មាន ២ យ៉ាង ។ ការឃាត់ហាមបាតិមោក្ខដែលប្រកបដោយធម៌មាន ២ យ៉ាង ។

(៣៤) បុគ្គលពាលមាន ២ ពួក គឺបុគ្គលដែលនាំភារៈ (កិច្ចមានអាពធនាធម៌ជាដើម) មិនទាន់មានមក ១ បុគ្គលដែលមិននាំភារៈដែលមានមកហើយ ១ ។ បុគ្គលជាបណ្ឌិតមាន ២ ពួក គឺ បុគ្គលដែលមិននាំភារៈមិនទាន់មកដល់ ១ បុគ្គលដែលនាំភារៈមានមកហើយ ១ ។ បុគ្គលពាលមាន ២ ពួកដទៃទៀត គឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអកប្បិយវត្ថុ ថាជាកប្បិយវត្ថុ ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងកប្បិយវត្ថុ ថាជាអកប្បិយ-វត្ថុ ១ ។ បុគ្គលជាបណ្ឌិតមាន ២ ពួក គឺ បុគ្គលមានសេចក្ដីសំគាល់ ក្នុងអកប្បិយវត្ថុ ថាជាអកប្បិយវត្ថុ ១ បុគ្គលមានសេចក្ដីសំគាល់ ក្នុងកប្បិយ-វត្ថុ ថាជាកប្បិយវត្ថុ ១ ។ បុគ្គលពាលមាន ២ ពួកដទៃទៀត គឺ បុគ្គល

អនាបត្តិយា អាបត្តិសញ្ញី យោ ច អាបត្តិយា អនា-បត្តិសញ្ញី ។ ទ្វេ បុគ្គលា បណ្ឌិតា យោ ច អាបត្តិយា អាបត្តិសញ្ញី យោ ច អនាបត្តិយា អនាបត្តិសញ្ញី ។ អបរេបិ ទ្វេ បុគ្គលា ពាលា យោ ច អធម្មេ ធម្មសញ្ញី យោ ច ធម្មេ អធម្មសញ្ញី ។ ទ្វេ បុគ្គលា បណ្ឌិតា យោ ច អធម្មេ អធម្មសញ្ញី យោ ច ធម្មេ ធម្មសញ្ញី ។ អបរេបិ ទ្វេ បុគ្គលា ពាលា យោ ច អវិនយេ វិនយ-សញ្ញី យោ ច វិនយេ អវិនយសញ្ញី ។ ទ្វេ បុគ្គលា បណ្ឌិតា យោ ច អវិនយេ អវិនយសញ្ញី យោ ច វិនយេ វិនយសញ្ញី ។

(១៩) ទ្វិន្នំ បុគ្គលានំ អាសវា វឌ្ឍន្តិ យោ ច ន កុក្កុច្ចាយិតព្វំ កុក្កុច្ចាយតិ យោ ច កុក្កុច្ចាយិតព្វំ ន កុក្កុច្ចាយតិ ។ ទ្វិន្នំ បុគ្គលានំ អាសវា ន វឌ្ឍន្តិ យោ ច ន កុក្កុច្ចាយិតព្វំ ន កុក្កុច្ចាយតិ យោ ច

មានសេចក្តីសំគាល់ក្នុងអនាបត្តិ ថាជាអាបត្តិ ១ បុគ្គលមានសេចក្តីសំគាល់ក្នុងអាបត្តិ ថាជាអនាបត្តិ ១ ។ បុគ្គលជាបណ្ឌិតមាន ២ ពួក គឺបុគ្គលមានសេចក្តីសំគាល់ក្នុងអាបត្តិ ថាជាអាបត្តិ ១ បុគ្គលមានសេចក្តីសំគាល់ក្នុងអនាបត្តិ ថាជាអនាបត្តិ ១ ។ បុគ្គលពាលមាន ២ ពួកដទៃទៀត គឺបុគ្គលមានសេចក្តីសំគាល់ ក្នុងសភាវៈមិនមែនធម៌ ថាជាធម៌ ១ មានសេចក្តីសំគាល់ ក្នុងសភាវៈជាធម៌ ថាមិនមែនធម៌ ១ ។ បុគ្គលជាបណ្ឌិតមាន ២ ពួកគឺបុគ្គលមានសេចក្តីសំគាល់ក្នុងសភាវៈមិនមែនធម៌ ថាមិនមែនជាធម៌ ១ បុគ្គលមានសេចក្តីសំគាល់ក្នុងសភាវៈជាធម៌ ថាជាធម៌ ១ ។ បុគ្គលពាលមាន ២ ពួកដទៃទៀត គឺ បុគ្គលមានសេចក្តីសំគាល់ក្នុងសភាវៈមិនមែនវិន័យថាជាវិន័យ ១ បុគ្គលមានសេចក្តីសំគាល់ក្នុងសភាវៈជាវិន័យ ថាមិនមែនវិន័យ ១ ។ បុគ្គលជាបណ្ឌិតមាន ២ ពួក គឺ បុគ្គលមានសេចក្តីសំគាល់ក្នុងសភាវៈមិនមែនជាវិន័យ ថាមិនមែនជាវិន័យ ១ បុគ្គលមានសេចក្តីសំគាល់ ក្នុងសភាវៈជាវិន័យ ថាជាវិន័យ ១ ។

[៣៥] អាសវៈទាំងឡាយតែងចំរើនដល់បុគ្គល ២ ពួក គឺ បុគ្គលដែលសង្ស័យចំពោះហេតុដែលមិនគួរសង្ស័យ ១ បុគ្គលដែលមិនសង្ស័យចំពោះហេតុដែលគួរសង្ស័យ ១ ។ អាសវៈទាំងឡាយរមែងមិនចំរើនដល់បុគ្គល ២ ពួក គឺ បុគ្គលដែលមិនសង្ស័យចំពោះហេតុដែលមិនគួរសង្ស័យ ១

ការុញ្ញតាយិទំ ការុញ្ញតាយតិ ។ អបរេសម្បិ ទ្វិន្នំ
បុគ្គលានំ អាបត្តិ វឌ្ឍតិ យោ ច អកប្បិយេ កប្បិ-
យសញ្ញី យោ ច កប្បិយេ អកប្បិយសញ្ញី ។ ទ្វិន្នំ
បុគ្គលានំ អាបត្តិ ន វឌ្ឍតិ យោ ច អកប្បិយេ អកប្បិ-
យសញ្ញី យោ ច កប្បិយេ កប្បិយសញ្ញី ។ អបរេ-
សម្បិ ទ្វិន្នំ បុគ្គលានំ អាបត្តិ វឌ្ឍតិ យោ ច អនាបត្តិ-
យា អាបត្តិសញ្ញី យោ ច អាបត្តិយា អនាបត្តិសញ្ញី ។
ទ្វិន្នំ បុគ្គលានំ អាបត្តិ ន វឌ្ឍតិ យោ ច អនាបត្តិយា
អនាបត្តិសញ្ញី យោ ច អាបត្តិយា អាបត្តិសញ្ញី ។ អប-
រេសម្បិ ទ្វិន្នំ បុគ្គលានំ អាបត្តិ វឌ្ឍតិ យោ ច អធម្មេ
ធម្មសញ្ញី យោ ច ធម្មេ អធម្មសញ្ញី ។ ទ្វិន្នំ បុគ្គលានំ
អាបត្តិ ន វឌ្ឍតិ យោ ច អធម្មេ អធម្មសញ្ញី យោ
ច ធម្មេ ធម្មសញ្ញី ។ អបរេសម្បិ ទ្វិន្នំ បុគ្គលានំ
អាបត្តិ វឌ្ឍតិ យោ ច អវិនយេ វិនយសញ្ញី យោ ច
វិនយេ អវិនយសញ្ញី ។ ទ្វិន្នំ បុគ្គលានំ អាបត្តិ ន

សង្ស័យចំពោះហេតុដែលគួរសង្ស័យ ១ ។ អាសវៈទាំងឡាយតែងចំរើនដល់បុគ្គល ២ ពួកដទៃទៀត គឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអកប្បិយវត្ថុ ថាជាកប្បិយវត្ថុ ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងកប្បិយវត្ថុថាជាអកប្បិយវត្ថុ ១ ។ អាសវៈទាំងឡាយរមែងមិនចំរើនដល់បុគ្គល ២ ពួក គឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអកប្បិយវត្ថុ ថាជាអកប្បិយវត្ថុ ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងកប្បិយវត្ថុ ថាជាកប្បិយវត្ថុ ១ ។ អាសវៈទាំងឡាយរមែងចំរើនដល់បុគ្គល ២ ពួកដទៃទៀត គឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអនាបត្តិ ថាជាអាបត្តិ ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងអាបត្តិថាជាអនាបត្តិ ១ ។ អាសវៈទាំងឡាយរមែងមិនចំរើនដល់បុគ្គល ២ ពួក គឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអនាបត្តិថាជាអនាបត្តិ ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងអាបត្តិ ថាជាអាបត្តិ ១ ។ អាសវៈទាំងឡាយរមែងចំរើនដល់បុគ្គល ២ ពួកដទៃទៀត គឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនធម៌ ថាជាធម៌ ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈជាធម៌ ថាមិនមែនជាធម៌ ១ ។ អាសវៈទាំងឡាយរមែងមិនចំរើនដល់បុគ្គល ២ ពួក គឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនធម៌ ថាមិនមែនជាធម៌ ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈជាធម៌ ថាជាធម៌ ១ ។ អាសវៈទាំងឡាយរមែងចំរើនដល់បុគ្គល ២ ពួកដទៃទៀត គឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនវិន័យ ថាជាវិន័យ ១ បុគ្គល

ឯកុត្តរិកំ ទុកំ ឧទ្ទានគាថា

វឌ្ឍម្ហិ យោ ច អវិនយេ អវិនយសញ្ញី យោ ច វិនយេ វិនយសញ្ញី ។

ទុកំ និដ្ឋិតំ (១) ។

តស្សុទ្ទានំ

(១៦) សញ្ញា លទ្ធា ច សទ្ធម្មា

បរិក្ខារា ច បុគ្គលា

សង្ឃំ ភូមិ និក្ខមន្តោ

អាទិយន្តោ សមាទិយំ

ការោន្តោ ទេន្តោ គណ្ហន្តោ

បរិភោគេន វត្តិ ច

អរុណា និដ្ឋំ ឆាទេន្តោ

ធារេន្តោ ច ឧបោសថា

បវារណា កម្មាបរា

---

១ ឱ. ម. ទុកា និដ្ឋិតា ។

មានសេចក្តីសំគាល់ក្នុងសភាវៈជាវិន័យ ថាមិនមែនជាវិន័យ ១ ។ អាសវៈទាំងឡាយ រមែងមិនចំរើនដល់បុគ្គលពីរពួក គឺ បុគ្គលមានសេចក្តីសំគាល់ក្នុងសភាវៈមិនមែនវិន័យ ថាមិនមែនវិន័យ ១ បុគ្គលមានសេចក្តីសំគាល់ក្នុងសភាវៈជាវិន័យ ថាជាវិន័យ ១ ។

ចប់ ទុកៈ (ពួកពីរ ៗ) ។

ឧទ្ទានគឺបញ្ជីរឿងនៃទុកៈ (ពួកពីរ ៗ) នោះ ដូច្នេះ

(៣៦)អាបត្តិជាសញ្ញាវិមោក្ខ១ អាបត្តិនៃភិក្ខុដែលបានសមាបត្តិ ១ អាបត្តិប្រកបដោយព្រះសទ្ធម្ម ១ អាបត្តិប្រកបដោយបរិក្ខារ១ អាបត្តិប្រកបដោយបុគ្គល ១ ភិក្ខុនិយាយពាក្យសច្ចៈត្រូវអាបត្តិ១ ភិក្ខុនៅលើផែនដីត្រូវអាបត្តិ ១ ភិក្ខុចេញទៅត្រូវអាបត្តិ១ ភិក្ខុកាន់យកត្រូវអាបត្តិ ១ ភិក្ខុសមាទានត្រូវអាបត្តិ១ ភិក្ខុដើរត្រូវអាបត្តិ ១ ភិក្ខុកាលឲ្យត្រូវអាបត្តិ ១ ភិក្ខុកាលទទួលត្រូវអាបត្តិ ១ ភិក្ខុត្រូវអាបត្តិព្រោះបរិភោគ ១ ត្រូវអាបត្តិក្នុងវេលាយប់ ១ ត្រូវអាបត្តិក្នុងវេលាអរុណរះ ១ ភិក្ខុកាត់ត្រូវអាបត្តិ១ ភិក្ខុបិទបាំងត្រូវអាបត្តិ ១ ភិក្ខុទ្រទ្រង់ត្រូវអាបត្តិ ១ ឧបោសថ ១ បវារណា ១ កម្ម ១ កម្មដទៃទៀត ១

វិនយបិដកេ បរិវារោ

វត្ថុ អបរា ទោសា ច
អបរា ទ្វេ ច សម្បត្តិ
នានា សមានមេវ ច
បារាជិ សង្ឃា ថុល្លច្ចំ[១]
បាចិត្តិ បាដិទេសនី
ទុក្កដា ភាសិតញ្ចេវ[២]
សត្ត អាបត្តិក្ខន្ធកា[៣]
ភិជ្ជតិ ឧបសម្បទា
តថេវ អបរេ ទុវេ
ន វត្តព្វំ ន ទាតព្វំ
អកព្វាកព្វមេវ ច
សញ្ចិច្ច សាតិសារក ច
បដិក្កោសា និស្សារណា
ឱសារណា បដិញ្ញា ច
បដិគ្គហោ បដិក្ខិបា
ឧបយាតិ ហោនណា ច

---

១ ឱ. ថុល្លច្ចយំ ។ ២ ឱ. ទុព្ភាសិតា ចេវ ។ ៣ ឱ. ម. សត្ត អាបត្តិក្ខន្ធា ច ។

វត្ថុនៃកម្ម ១ វត្ថុនៃកម្មដទៃទៀត ១ ទោសនៃកម្ម ១ ទោសនៃកម្មដទៃទៀត ១ សម្បត្តិនៃកម្ម ២ យ៉ាង ១ ភូមិនៃភិក្ខុមានសំវាសផ្សេងៗគ្នា១ ភូមិនៃភិក្ខុមានសំវាសស្មើគ្នា ១ បារាជិក ១ សង្ឃាទិសេស ១ ថុល្លច្ច័យ ១ បាចិត្តិយៈ ១ បាដិទេសនីយៈ១ ទុក្កដ១ ទុព្ភាសិត១ រួមជាកងនៃអាបត្តិ៧ សង្ឃបែកគ្នា១ ភិក្ខុមិនត្រូវឲ្យឧបសម្បទា១ មិនត្រូវឲ្យឧបសម្បទាចំពោះបុគ្គលពីរពួកដទៃទៀត១ ភិក្ខុមិនត្រូវអាស្រ័យនៅ ១ មិនត្រូវឲ្យនិស្ស័យ១ បុគ្គលមិនគួរនឹងត្រូវអាបត្តិ១ បុគ្គលគួរត្រូវអាបត្តិព្រោះកែង១ បុគ្គលគួរនឹងត្រូវអាបត្តិព្រោះប្រព្រឹត្តកន្លងវត្ថុដែលប្រកបដោយទោសយ៉ាងធំ ១ ការហាមឃាត់ ១ ការសូត្រនិស្សារណកម្ម ១ ការសូត្រឱសារណកម្ម ១ ការប្តេជ្ញា១ ការទទួល១ ការឃាត់១ ការបៀតបៀន១ ការចោទ១

ឯកុត្តរិកំ ទុកំ ឧទ្ទានគាថា

កបិតា ច ទុវេ តថា
ចីវរ បត្តមណ្ឌលា
អធិដ្ឋានា តថា ទុវេ(១)
វិកប្បនា ច វិនយា
វេនយិកា សល្លេក្ខកា(២)
អាបជ្ជតិ ច វុដ្ឋាតិ
បរិភាសាបរេ ទុវេ(៣)
ទ្វេ មានត្តា អបរេ ច
រត្តិច្ឆេទោ អនាទរិ
ទ្វេ លោណា តយោ អបរេ
បរិភោគា អក្កោសនា(៤)
បេសុញ្ញំ ច គណា វស្សំ(៥)
ឋបនា អារកប្បិយា
អនាបត្តិ អធម្មា(៦) ច
វិនយេ អាសវេ តថាតិ ។

១ ឱ. ម. តថេវ ទ្វេ ។ ២ ឱ. វេនយិកា ច សល្លេខា ។ ៣ ឱ. ម. អបរេ ទ្វេ ។ ៤ ឱ. ម. បរិភោគក្កោសេន ច ។ ៥ ឱ.ម. វស្សំ ។ ម. បេសុញ្ញោ ច គណា វស្សំ ។ ៦ ឱ. ម. អធម្មធម្មា ។

បលិពោធនៃកឋិន ២ យ៉ាង១ មិនមានបលិពោធនៃកឋិន ២ យ៉ាងដូចគ្នា១ ចីវរ១ បាត្រនឹងជើងទ្របាត្រ១ ការអធិដ្ឋានបាត្រ ២ យ៉ាង១ ការអធិដ្ឋានចីវរ ២ យ៉ាងដូចគ្នា១ ការវិកប្ប ១ វិន័យ ១ អត្ថនៃវិន័យ ១ សេចក្ដីផ្ទុយផង (នៃវិន័យ)១ កិច្ចត្រូវអាបត្តិ (ដោយអាការ ២ យ៉ាង)១ ចេញចាកអាបត្តិ (ដោយអាការ ២ យ៉ាង)១ បរិវាស ២ យ៉ាង ១ បរិវាស ២ យ៉ាងដទៃទៀត១ មានត្ត ២ យ៉ាង១ មានត្ត ២ យ៉ាងដទៃទៀត ១ ការដាច់រាត្រី ១ សេចក្ដីមិនអើពើ ១ អំបិល ២ យ៉ាងមាន ៣ ពួកតទៅទៀត១ ការបរិភោគ ១ ការដេរ១ បេសុញ្ញវាទ១ ការទទួលគណភោជន១ ការចូលវស្សា១ ការបញ្ចប់នូវបាតិមោក្ខ១ បុគ្គលពាលនាំការៈ១ កប្បិយវត្ថុ១ អនាបត្តិ១ អធម្មកម្ម១ វិនយកម្ម១ អាសវៈទាំងឡាយ ១ ។

(៣៧) អត្ថាបត្តិ តិដ្ឋន្តេ ភគវតិ អាបជ្ជតិ នោ បរិនិព្វុតេ អត្ថាបត្តិ បរិនិព្វុតេ ភគវតិ អាបជ្ជតិ នោ តិដ្ឋន្តេ អត្ថាបត្តិ តិដ្ឋន្តេបិ ភគវតិ អាបជ្ជតិ បរិនិព្វុតេបិ ។ អត្ថាបត្តិ កាលេ អាបជ្ជតិ នោ វិកាលេ អត្ថាបត្តិ វិកាលេ អាបជ្ជតិ នោ កាលេ អត្ថាបត្តិ កាលេ ចេវ អាបជ្ជតិ វិកាលេ ច ។ អត្ថាបត្តិ រត្តឹ អាបជ្ជតិ នោ ទិវា អត្ថាបត្តិ ទិវា អាបជ្ជតិ នោ រត្តឹ អត្ថាបត្តិ រត្តិញ្ចេវ អាបជ្ជតិ ទិវា ច ។ អត្ថាបត្តិ ទសវស្សោ អាបជ្ជតិ នោ ឩនទសវស្សោ អត្ថាបត្តិ ឩនទសវស្សោ អាបជ្ជតិ នោ ទសវស្សោ អត្ថាបត្តិ ទសវស្សោ ចេវ អាបជ្ជតិ ឩនទសវស្សោ ច ។ អត្ថាបត្តិ បញ្ចវស្សោ អាបជ្ជតិ នោ ឩនបញ្ចវស្សោ អត្ថាបត្តិ ឩនបញ្ចវស្សោ អាបជ្ជតិ នោ បញ្ចវស្សោ អត្ថាបត្តិ បញ្ចវស្សោ ចេវ អាបជ្ជតិ ឩនបញ្ចវស្សោ ច ។ អត្ថាបត្តិ កុសលចិត្តោ អាបជ្ជតិ នោ អកុសលចិត្តោ អត្ថាបត្តិ អកុសល-

(៣៧) ភិក្ខុត្រូវអាបត្តិតែក្នុងកាលដែលព្រះមានព្រះភាគគង់នៅ កាលដែលព្រះអង្គបរិនិព្វានហើយមិនត្រូវក៏មាន ភិក្ខុត្រូវអាបត្តិតែក្នុងកាលដែលព្រះមានព្រះភាគបរិនិព្វានហើយ កាលដែលព្រះអង្គគង់នៅឡើយ មិនត្រូវក៏មាន ភិក្ខុត្រូវអាបត្តិទាំងក្នុងកាលដែលព្រះអង្គគង់នៅ ទាំងក្នុងកាលដែលព្រះអង្គបរិនិព្វានហើយក៏មាន ។ ភិក្ខុត្រូវអាបត្តិតែក្នុងកាល មិនត្រូវក្នុងវិកាលក៏មាន ភិក្ខុត្រូវអាបត្តិតែក្នុងវិកាល មិនត្រូវក្នុងកាលក៏មាន ភិក្ខុត្រូវអាបត្តិទាំងក្នុងកាល ទាំងក្នុងវិកាលក៏មាន ។ ភិក្ខុត្រូវអាបត្តិតែក្នុងវេលាយប់ មិនត្រូវក្នុងវេលាថ្ងៃក៏មាន ត្រូវអាបត្តិតែក្នុងវេលាថ្ងៃ មិនត្រូវក្នុងវេលាយប់ក៏មាន ត្រូវអាបត្តិទាំងវេលាយប់ ទាំងវេលាថ្ងៃក៏មាន ។ ភិក្ខុមានវស្សា ១០ ត្រូវអាបត្តិ មានវស្សាខ្វះពី ១០ មិនត្រូវអាបត្តិក៏មាន ភិក្ខុមានវស្សាខ្វះពី ១០ ត្រូវអាបត្តិ មានវស្សា ១០ មិនត្រូវអាបត្តិក៏មាន ទាំងភិក្ខុមានវស្សា ១០ ទាំងភិក្ខុមានវស្សាខ្វះពី ១០ ត្រូវអាបត្តិក៏មាន ។ ភិក្ខុមានវស្សា ៥ ត្រូវអាបត្តិ មានវស្សាខ្វះពី ៥ មិនត្រូវអាបត្តិក៏មាន ភិក្ខុមានវស្សាខ្វះពី ៥ ត្រូវអាបត្តិ មានវស្សាគ្រប់ ៥ មិនត្រូវអាបត្តិក៏មាន ទាំងភិក្ខុមានវស្សា ៥ ទាំងភិក្ខុមានវស្សាខ្វះពី ៥ ត្រូវអាបត្តិក៏មាន ។ ភិក្ខុមានចិត្តជាកុសលត្រូវអាបត្តិ មានចិត្តជា

ចិត្តោ អាបជ្ជតិ ហោ កុសលចិត្តោ អត្ថាបត្តិ អព្យាកតចិត្តោ អាបជ្ជតិ ។ អត្ថាបត្តិ សុខវេទនាសមង្គី អាបជ្ជតិ អត្ថាបត្តិ ទុក្ខវេទនាសមង្គី អាបជ្ជតិ អត្ថាបត្តិ អទុក្ខមសុខវេទនាសមង្គី អាបជ្ជតិ ។

(៣៨) តីណិ ចោទនាវត្ថូនិ ទិដ្ឋេន សុតេន បរិសង្កាយ ។ តយោ សលាកគ្គាហា គុឡ្ហកោ វិវដកោ សកណ្ណជប្បកោ ។ តយោ បដិក្ខេបា មហិច្ឆតា អសន្តុដ្ឋតា អសល្លេខតា ។ តយោ អនុញ្ញាតា អប្បិច្ឆតា សន្តុដ្ឋតា សល្លេខតា ។ អបរេបិ តយោ បដិក្ខេបា មហិច្ឆតា អសន្តុដ្ឋតា អមត្តញ្ញុតា ។ តយោ អនុញ្ញាតា អប្បិច្ឆតា សន្តុដ្ឋតា មត្តញ្ញុតា ។ តិស្សោ បញ្ញត្តិយោ បញ្ញត្តិ អនុបញ្ញត្តិ អនុប្បន្នបញ្ញត្តិ ។ អបរាបិ តិស្សោ បញ្ញត្តិយោ សព្វត្ថបញ្ញត្តិ បទេសបញ្ញត្តិ សាធារណបញ្ញត្តិ ។ អបរាបិ តិស្សោ បញ្ញត្តិយោ អសាធារណបញ្ញត្តិ ឯកតោបញ្ញត្តិ ឧភតោបញ្ញត្តិ ។

អកុសលមិនត្រូវអាបត្តិក៏មាន ភិក្ខុមានចិត្តជាអកុសលត្រូវអាបត្តិ មានចិត្តជាកុសល មិនត្រូវអាបត្តិក៏មាន ភិក្ខុមានចិត្តជាអព្យាក្រឹតត្រូវអាបត្តិក៏មាន ។ ភិក្ខុមានចិត្តប្រកបដោយសុខវេទនាត្រូវអាបត្តិក៏មាន មានចិត្តប្រកបដោយទុក្ខវេទនាត្រូវអាបត្តិក៏មាន មានចិត្តប្រកបដោយអទុក្ខមសុខវេទនា ត្រូវអាបត្តិក៏មាន ។

[៣៨] ចោទនាវត្ថុ (វត្ថុជាគ្រឿងចោទ) មាន ៣ យ៉ាង គឺ ដោយឃើញ ១ ឮ ១ រង្កៀស ១ ។ ការចាប់ស្លាកមាន ៣ យ៉ាង គឺ គូឡ្ហកៈ (ស្លាកបិទ)១ វិវដ្តកៈ (ស្លាកបើក)១ សកណ្ណជប្បកៈ (ការខ្សឹបផិតត្រចៀកជាស្លាក)១ ។ បំរាមមាន ៣ យ៉ាង គឺ សេចក្តីប្រាថ្នាធំ ១ សេចក្តីមិនសន្តោស ១ សេចក្តីមិនផូរផង់ចិត្ត ១ ។ អនុញ្ញាតមាន ៣ យ៉ាង គឺ សេចក្តីប្រាថ្នាតិច១ សេចក្តីសន្តោស១ សេចក្តីផូរផង់ចិត្ត១ ។ បំរាមមាន ៣ យ៉ាងដទៃទៀត គឺសេចក្តីប្រាថ្នាធំ១ សេចក្តីមិនសន្តោស ១ សេចក្តីមិនដឹងប្រមាណ១ ។ អនុញ្ញាតមាន ៣ យ៉ាង គឺ សេចក្តីប្រាថ្នាតិច១ សេចក្តីសន្តោស១ សេចក្តីដឹងប្រមាណ១ ។ បញ្ញត្តិមាន ៣ យ៉ាង គឺ បញ្ញត្តិ១ អនុប្បញ្ញត្តិ១ អនុប្បន្នបញ្ញត្តិ១ ។ បញ្ញត្តិមាន ៣ យ៉ាងដទៃទៀត គឺ សព្វត្ថបញ្ញត្តិ១ បទេសបញ្ញត្តិ១ សាធារណបញ្ញត្តិ១ ។ បញ្ញត្តិមាន ៣ យ៉ាងដោយដទៃទៀត គឺ អសាធារណបញ្ញត្តិ១ ឯកតោបញ្ញត្តិ១ ឧភតោបញ្ញត្តិ ១ ។

(៣៩) អត្ថាបត្តិ ពាលោ អាបជ្ជតិ នោ បណ្ឌិតោ អត្ថាបត្តិ បណ្ឌិតោ អាបជ្ជតិ នោ ពាលោ អត្ថាបត្តិ ពាលោ ចេវ អាបជ្ជតិ បណ្ឌិតោ ច ។ អត្ថាបត្តិ កាឡេ អាបជ្ជតិ នោ ជុណ្ហេ អត្ថាបត្តិ ជុណ្ហេ អាបជ្ជតិ នោ កាឡេ អត្ថាបត្តិ កាឡេ ចេវ អាបជ្ជតិ ជុណ្ហេ ច ។ អត្ថិ កាឡេ កប្បតិ នោ ជុណ្ហេ អត្ថិ ជុណ្ហេ កប្បតិ នោ កាឡេ អត្ថិ កាឡេ ចេវ កប្បតិ ជុណ្ហេ ច ។ អត្ថាបត្តិ ហេមន្តេ អាបជ្ជតិ នោ ច គិម្ហេ នោ ច វស្សេ អត្ថាបត្តិ គិម្ហេ អាបជ្ជតិ នោ ច ហេមន្តេ នោ ច វស្សេ អត្ថាបត្តិ វស្សេ អាបជ្ជតិ នោ ច គិម្ហេ នោ ច ហេមន្តេ ។ អត្ថាបត្តិ សង្ឃេ អាបជ្ជតិ នោ គណេ នោ បុគ្គលេ អត្ថាបត្តិ គណេ អាបជ្ជតិ នោ សង្ឃេ នោ បុគ្គលេ អត្ថាបត្តិ បុគ្គលេ អាបជ្ជតិ នោ សង្ឃេ នោ គណេ ។ អត្ថិ សង្ឃស្ស កប្បតិ ន គណស្ស ន បុគ្គលស្ស អត្ថិ គណស្ស កប្បតិ ន សង្ឃស្ស ន បុគ្គលស្ស អត្ថិ បុគ្គលស្ស កប្បតិ ន សង្ឃស្ស ន គណស្ស ។

(៣៩) ភិក្ខុពាលត្រូវអាបត្តិ ភិក្ខុបណ្ឌិតមិនត្រូវអាបត្តិក៏មាន ភិក្ខុបណ្ឌិតត្រូវអាបត្តិ ភិក្ខុពាលមិនត្រូវអាបត្តិក៏មាន ភិក្ខុពាលក្តី បណ្ឌិតក្តី ត្រូវអាបត្តិក៏មាន ។ ភិក្ខុត្រូវអាបត្តិក្នុងកាឡបក្ខ (រនោច) មិនត្រូវក្នុងជុណ្ហបក្ខ (ខ្នើត) ក៏មាន ភិក្ខុត្រូវអាបត្តិក្នុងជុណ្ហបក្ខ មិនត្រូវក្នុងកាឡបក្ខក៏មាន ភិក្ខុត្រូវអាបត្តិទាំងក្នុងកាឡបក្ខ ទាំងក្នុងជុណ្ហបក្ខក៏មាន ។ សេចក្តីអនុញ្ញាតគួរតែក្នុងកាឡបក្ខ មិនគួរក្នុងជុណ្ហបក្ខក៏មាន គួរតែក្នុងជុណ្ហបក្ខ មិនគួរក្នុងកាឡបក្ខក៏មាន គួរទាំងក្នុងកាឡបក្ខ ទាំងជុណ្ហបក្ខក៏មាន ។ ភិក្ខុត្រូវអាបត្តិតែក្នុងហេមន្តរដូវ មិនត្រូវក្នុងគិម្ហរដូវ ទាំងមិនត្រូវអាបត្តិក្នុងវស្សានរដូវក៏មាន ត្រូវអាបត្តិក្នុងគិម្ហរដូវ មិនត្រូវអាបត្តិ ក្នុងហេមន្តរដូវ មិនត្រូវអាបត្តិក្នុងវស្សានរដូវផងក៏មាន ត្រូវអាបត្តិក្នុងវស្សានរដូវ មិនត្រូវអាបត្តិក្នុងគិម្ហរដូវផង មិនត្រូវអាបត្តិក្នុងហេមន្តរដូវផងក៏មាន ។ សង្ឃត្រូវអាបត្តិ គណៈមិនត្រូវអាបត្តិ បុគ្គលមិនត្រូវអាបត្តិក៏មាន គណៈត្រូវអាបត្តិ សង្ឃមិនត្រូវអាបត្តិ បុគ្គលមិនត្រូវអាបត្តិក៏មាន បុគ្គលត្រូវអាបត្តិ សង្ឃមិនត្រូវអាបត្តិ គណៈមិនត្រូវអាបត្តិក៏មាន ។ សេចក្តីអនុញ្ញាតគួរដល់សង្ឃ មិនគួរដល់គណៈ មិនគួរដល់បុគ្គលក៏មាន គួរដល់គណៈ មិនគួរដល់សង្ឃ មិនគួរដល់បុគ្គលក៏មាន គួរដល់បុគ្គល មិនគួរដល់សង្ឃ មិនគួរដល់គណៈក៏មាន ។

ឯកុត្តរិកំ តិកំ តិស្សោ ឆាទនាទយោ

[៦០] តិស្សោ ឆាទនា វត្ថុំ ឆាទេតិ នោ អាបត្តិំ អាបត្តិំ ឆាទេតិ នោ វត្ថុំ វត្ថុញ្ចេវ ឆាទេតិ អាបត្តិញ្ច ។ តិស្សោ បដិច្ឆាទិយោ ជន្តាឃរបដិច្ឆាទិ ឧទកបដិច្ឆាទិ វត្ថបដិច្ឆាទិ ។ តីណិ បដិច្ឆន្នានិ វហន្តិ នោ វិវដានិ មាតុគាមោ បដិច្ឆន្នោ វហតិ នោ វិវដោ ព្រាហ្មណានំ មន្តា បដិច្ឆន្នា វហន្តិ នោ វិវដា មិច្ឆាទិដ្ឋិ បដិច្ឆន្នា វហតិ នោ វិវដា ។ តីណិ វិវដានិ វិរោចន្តិ នោ បដិច្ឆន្នានិ ចន្ទមណ្ឌលំ វិវដំ វិរោចតិ នោ បដិច្ឆន្នំ សុរិយមណ្ឌលំ វិវដំ វិរោចតិ នោ បដិច្ឆន្នំ តថាគតប្ប-វេទិតោ ធម្មវិនយោ វិវដោ វិរោចតិ នោ បដិច្ឆន្នោ ។ តយោ សេនាសនគ្គាហា បុរិមកោ បច្ឆិមកោ អន្ត-រាមុត្តកោ ។

[៦១] អត្ថាបត្តិ គិលានោ អាបជ្ជតិ នោ អគិលា-នោ អត្ថាបត្តិ អគិលានោ អាបជ្ជតិ នោ គិលានោ-អត្ថាបត្តិ គិលានោ ចេវ អាបជ្ជតិ អគិលានោ ច ។

ឯកុត្តរិកៈ តិកៈ ការបិទបាំងមាន ៣ យ៉ាងជាដើម

(៤០) ការបិទបាំងមាន ៣ យ៉ាងគឺ ភិក្ខុបិទបាំងវត្ថុ មិនបិទបាំងអាបត្តិ១ បិទបាំងអាបត្តិ មិនបិទបាំងវត្ថុ១ បិទបាំងទាំងវត្ថុ ទាំងអាបត្តិ១ ។ គ្រឿងបិទបាំងមាន៣ យ៉ាងគឺ គ្រឿងបិទបាំងគឺផ្ទះជាទីរក្សាកាយ ១ គ្រឿងបិទបាំងគឺទឹក១ គ្រឿងបិទបាំងគឺសម្ពត់ ១ ។ វត្ថុ ៣ យ៉ាងដែលបិទបាំងទុកទើបប្រព្រឹត្តទៅស្រួល តែបើកឡើងប្រព្រឹត្តទៅមិនស្រួល គឺ មាតុគ្រាមមានវត្ថុបិទបាំងទើបប្រព្រឹត្តទៅស្រួល តែមិនមានវត្ថុបិទបាំងប្រព្រឹត្តទៅមិនស្រួល ១ មន្តរបស់ពួកព្រាហ្មណ៍បិទបាំងទុកទើបប្រព្រឹត្តទៅស្រួល បើកឡើងប្រព្រឹត្តទៅមិនស្រួល ១ មិច្ឆាទិដ្ឋិបិទបាំងទុកទើបប្រព្រឹត្តទៅស្រួល តែបើកឡើងប្រព្រឹត្តទៅមិនស្រួល១ ។ វត្ថុ៣ យ៉ាងបើកបញ្ចេញទើបរុងរឿង បិទទុកមិនរុងរឿងឡើយ គឺ មណ្ឌលព្រះចន្ទបើកឡើងទើបរុងរឿង តែបិទបាំងទុកមិនរុងរឿង១ មណ្ឌលព្រះអាទិត្យបើកឡើងទើបរុងរឿង តែបិទបាំងទុកមិនរុងរឿង ១ ធម្មវិន័យដែលតថាគតសំដែងហើយបើកឡើងទើបរុងរឿង បិទបាំងទុកមិនរុងរឿង ១ ។ ការកាន់យកសេនាសនៈមាន ៣ យ៉ាងគឺ បុរិមកៈ១ បច្ឆិមកៈ១ អន្តរាមុត្តកៈ១ ។

(៤១) ភិក្ខុឈឺត្រូវអាបត្តិ ភិក្ខុឥតឈឺមិនត្រូវអាបត្តិក៏មាន ភិក្ខុមិនឈឺត្រូវអាបត្តិ ភិក្ខុឈឺមិនត្រូវអាបត្តិក៏មាន ទាំងភិក្ខុឈឺ ទាំងភិក្ខុមិនឈឺត្រូវអាបត្តិក៏មាន ។

(៤២) តីណិ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ តីណិ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ តយោ បរិវាសា បដិច្ឆន្នបរិវាសោ អប្បដិច្ឆន្នបរិវាសោ សុទ្ធន្តបរិវាសោ ។ តយោ មានត្តា បដិច្ឆន្នមានត្តំ អប្បដិច្ឆន្នមានត្តំ បក្ខមានត្តំ ។ តយោ បារិវាសិកស្ស ភិក្ខុនោ រត្តិច្ឆេទា សហវាសោ វិប្បវាសោ អនារោចនា ។

(៤៣) អត្ថាបត្តិ អន្តោ អាបជ្ជតិ នោ ពហិ អត្ថាបត្តិ ពហិ អាបជ្ជតិ នោ អន្តោ អត្ថាបត្តិ អន្តោ ចេវ អាបជ្ជតិ ពហិ ច ។ អត្ថាបត្តិ អន្តោសីមាយ អាបជ្ជតិ នោ ពហិសីមាយ អត្ថាបត្តិ ពហិសីមាយ អាបជ្ជតិ នោ អន្តោសីមាយ អត្ថាបត្តិ អន្តោសីមាយ ចេវ អាបជ្ជតិ ពហិសីមាយ ច ។

(៤៤) តីហាការេហិ អាបត្តឹ អាបជ្ជតិ កាយេន អាបជ្ជតិ វាចាយ អាបជ្ជតិ កាយេន វាចាយ អាបជ្ជតិ ។ អបរេហិបិ តីហាការេហិ អាបត្តឹ អាបជ្ជតិ សង្ឃមជ្ឈេ គណមជ្ឈេ បុគ្គលស្ស សន្តិកេ ។ តីហាការេហិ អាបត្តិយា វុដ្ឋាតិ កាយេន វុដ្ឋាតិ វាចាយ វុដ្ឋាតិ កាយេន

[៤២] ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ មាន ៣ យ៉ាង ៗ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌មាន ៣ យ៉ាង ៗ បរិវាសមាន ៣ យ៉ាងគឺ បដិច្ឆន្នបរិវាស ១ អប្បដិច្ឆន្នបរិវាស ១ សុទ្ធន្តបរិវាស ១ ៗ មានត្តមាន៣យ៉ាងគឺ បដិច្ឆន្នមានត្ត១ អប្បដិច្ឆន្នមានត្ត១ បក្ខមានត្ត ១ ៗ ការដាច់រាត្រីរបស់ភិក្ខុដែលនៅបរិវាសមាន ៣ យ៉ាង គឺ ការនៅរួម១ ការមិននៅរួម ១ ការមិនបានប្រាប់ ១ ៗ

[៤៣] ភិក្ខុនៅខាងក្នុងត្រូវអាបត្តិ នៅខាងក្រៅមិនត្រូវក៏មាន នៅខាងក្រៅត្រូវអាបត្តិ នៅខាងក្នុងមិនត្រូវក៏មាន ត្រូវអាបត្តិទាំងខាងក្នុងទាំងខាងក្រៅក៏មាន ៗ ភិក្ខុនៅខាងក្នុងសីមាត្រូវអាបត្តិ នៅខាងក្រៅសីមាមិនត្រូវអាបត្តិក៏មាន នៅខាងក្រៅសីមាត្រូវអាបត្តិ នៅខាងក្នុងសីមា មិនត្រូវអាបត្តិក៏មាន ត្រូវអាបត្តិ ទាំងខាងក្នុងសីមាទាំងខាងក្រៅសីមាក៏មាន ៗ

[៤៤] ភិក្ខុត្រូវអាបត្តិដោយអាការ ៣ យ៉ាង គឺ ត្រូវដោយកាយ១ ត្រូវដោយវាចា ១ ត្រូវដោយកាយនឹងវាចា ១ ៗ ភិក្ខុត្រូវអាបត្តិដោយអាការ ៣ យ៉ាងដទៃទៀត គឺត្រូវក្នុងកណ្តាលសង្ឃ ១ ត្រូវក្នុងកណ្តាលគណៈ១ ត្រូវក្នុងសំណាក់នៃបុគ្គល១ ៗ ភិក្ខុចេញចាកអាបត្តិដោយអាការ ៣ យ៉ាង គឺ ចេញចាកដោយកាយ១ ចេញចាកដោយវាចា ១ ចេញចាក

ភាសាយ វុដ្ឋាតិ ។ អបរេហិបិ តីហាការេហិ អាបត្តិយា
វុដ្ឋាតិ សង្ឃមជ្ឈេ គណមជ្ឈេ បុគ្គលស្ស សន្តិកេ ។
តីណិ អធម្មិកានិ អមូឡ្ហវិនយស្ស ទានានិ ។ តីណិ
ធម្មិកានិ អមូឡ្ហវិនយស្ស ទានានិ ។

(៤៨) តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អា-
កង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ភណ្ឌនការ-
កោ ហោតិ កលហការកោ វិវាទការកោ ភស្សកា-
រកោ សង្ឃេ អធិករណការកោ ពាលោ ហោតិ
អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ
វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ។ តីហង្គេហិ
សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ
និយស្សកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ ។បេ។
សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ
អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ
អននុលោមិកេហិ គិហិសំសគ្គេហិ ។ តីហង្គេហិ ស-
មន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនី-
យកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ ។បេ។ សង្ឃេ

ដោយកាយនិងវាចា ១ ។ ភិក្ខុចេញចាកអាបត្តិដោយអាការ ៣ យ៉ាង ដទៃទៀត គឺ ចេញចាកក្នុងកណ្ដាលសង្ឃ ១ ក្នុងកណ្ដាលគណៈ ១ ក្នុងសំណាក់នៃបុគ្គល ១ ។ ការឲ្យអមូឡ្ហវិន័យ មិនប្រកបដោយធម៌ មាន ៣ យ៉ាង ។ ការឲ្យអមូឡ្ហវិន័យប្រកបដោយធម៌ មាន ៣ យ៉ាង ។

(៤៨) កាលបើសង្ឃប្រាថ្នា គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកបង្កហេតុ បង្កជំលោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ ១ ជាមនុស្សល្ងង់មិនឈ្លាសវៃ ច្រើនដោយអាបត្តិមិនមានការកំណត់អាបត្តិ ១ ជាបុគ្គលនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ១ ។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើនិយស្សកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុអ្នកបង្កហេតុ ។ បេ ។ បង្កអធិករណ៍ក្នុងសង្ឃ ១ ជាមនុស្សល្ងង់មិនឈ្លាសវៃ ច្រើនដោយអាបត្តិមិនមានការកំណត់អាបត្តិ ១ ជាអ្នកនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ១ ។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុអ្នកបង្កហេតុ ។ បេ ។ ជា

អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ កុលទូសកោ ហោតិ បាបសមាចារោ[១] ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ ។ បេ ។ សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហី[២] អក្កោសតិ បរិភាសតិ ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ ។ បេ ។ សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តឹ បស្សិតុំ ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ ។ បេ ។ សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ

---

១ ឥតោ បរំ ឱរោបិយបោត្ថកេ ជាបសមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ជាតិ ជាលិ ទិស្សតិ ។ ២ ឱ. គិហី ។

អ្នកបង្កអធិករណ៍ក្នុងសង្ឃ ១ ជាមនុស្សល្ងង់មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ ១ ជាអ្នកប្រទុស្តត្រកូល ជាអ្នកមានមារយាទអាក្រក់ ១ ។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបដិសារណីយកម្ម ដល់ភិក្ខុប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកបង្កហេតុ ។ បេ ។ អ្នកបង្កអធិក-រណ៍ក្នុងសង្ឃ ១ ជាមនុស្សល្ងង់មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ ១ ជេរគម្រាមគ្រហស្ថ ១ ។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ព្រោះមិនឃើញអាបត្តិ គឺភិក្ខុជាអ្នកបង្កហេតុ ។ បេ ។ ជាអ្នកបង្កអធិករណ៍ក្នុងសង្ឃ ១ ជាមនុស្សល្ងង់មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ ១ ត្រូវអាបត្តិហើយមិនប្រាថ្នាដើម្បីឃើញអាបត្តិ ១ ។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ព្រោះមិនសំដែងអាបត្តិ គឺ ភិក្ខុជាអ្នកបង្កហេតុ ។ បេ ។ ជាអ្នកបង្កអធិករណ៍ក្នុងសង្ឃ ១ ជាមនុស្សល្ងង់មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ ១

អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តឹ បដិកាតុំ ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ ។ បេ ។ សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ ន ឥច្ឆតិ បាបិកំ ទិដ្ឋឹ បដិនិស្សជ្ជិតុំ ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ អាគាឡ្ហាយ ចេតេយ្យ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ កម្មំ កាតព្វំ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ អបរេហិបិ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ កម្មំ កាតព្វំ អធិសីលេ សីលវិបន្នោ ហោតិ អជ្ឈាចារេ

ត្រូវអាបត្តិហើយ មិនប្រាថ្នាដើម្បីសំដែងអាបត្តិចេញ ១ ។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកបង្កហេតុ ។ បេ ។ ជាអ្នកបង្កអធិករណ៍ក្នុងសង្ឃ ១ ជាមនុស្សល្ងង់មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ ១ មិនប្រាថ្នានឹងលះបង់ទិដ្ឋិអាក្រក់ចេញ ១ ។ កាលបើសង្ឃប្រាថ្នា គប្បីលៃលក ដើម្បីសេចក្តីមាំមួន[1] ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកបង្កហេតុ បង្កជំលោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ ១ ជាមនុស្សល្ងង់មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ ១ ជាអ្នកនៅច្រឡូកច្រឡំដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ១ ។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកឥតមានខ្មាស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺ ភិក្ខុជាអ្នកមានសីលវិបត្តិក្នុងអធិសីល ១ មានអាចារវិបត្តិក្នុងអជ្ឈាចារ ១

---

១ អដ្ឋកថាពន្យល់ថា បើសង្ឃត្រូវការក៏គប្បីធ្វើឧក្ខេបនីយកម្មបន្ថែមដល់ភិក្ខុនៃសង្ឃបាន ដាក់កម្មមានតជ្ជនីយកម្មជាដើមហើយ មិនបំពេញវត្ត (តាមអាជ្ញាសង្ឃ) ។

អាចារវិបន្នោ ហោតិ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ។ អបរេហិបិ តីហាការេហិ សមន្នាគតស្ស ភិក្ខុនោ កម្មំ កាតព្វំ កាយិកេន ទវេន សមន្នាគតោ ហោតិ វាចសិកេន ទវេន សមន្នាគតោ ហោតិ កាយិកវាចសិកេន ទវេន សមន្នាគតោ ហោតិ ។ អបរេហិបិ តីហាការេហិ សមន្នាគតស្ស ភិក្ខុនោ កម្មំ កាតព្វំ កាយិកេន អនាចារេន សមន្នាគតោ ហោតិ វាចសិកេន អនាចារេន សមន្នាគតោ ហោតិ កាយិកវាចសិកេន អនាចារេន សមន្នាគតោ ហោតិ ។ អបរេហិបិ តីហាការេហិ សមន្នាគតស្ស ភិក្ខុនោ កម្មំ កាតព្វំ កាយិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ វាចសិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ កាយិកវាចសិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ ។ អបរេហិបិ តីហាការេហិ សមន្នាគតស្ស ភិក្ខុនោ កម្មំ កាតព្វំ កាយិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ វាចសិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ

មានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិ ១ ។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដោយឡែកទៀត គឺ ភិក្ខុជាអ្នកប្រកបខាងល្បែងដោយកាយ ១ ជាអ្នកប្រកបខាងល្បែង ដោយវាចា ១ ជាអ្នកប្រកបខាងល្បែង ដោយកាយនឹងវាចា ១ ។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដោយឡែកទៀត គឺ ភិក្ខុជាអ្នកប្រកបដោយមារយាទមិនមានសណ្ដាប់ធ្នាប់ដោយកាយ ១ ជាអ្នកប្រកបដោយមារយាទ មិនមានសណ្ដាប់ធ្នាប់ដោយវាចា ១ ជាអ្នកប្រកបដោយមារយាទ មិនមានសណ្ដាប់ធ្នាប់ដោយកាយនឹងវាចា ១ ។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដោយឡែកទៀត គឺ ភិក្ខុជាអ្នកប្រកបដោយការបៀតបៀនដោយកាយ ១ ជាអ្នកប្រកបដោយការបៀតបៀនដោយវាចា ១ ជាអ្នកប្រកបដោយការបៀតបៀនដោយកាយនឹងវាចា ១ ។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដោយឡែកទៀត គឺ ភិក្ខុជាអ្នកប្រកបដោយមិច្ឆាជីវៈដោយកាយ ១ ជាអ្នកប្រកបដោយមិច្ឆាជីវៈដោយវាចា ១ ជាអ្នកប្រកបដោយ

ឯកុត្តរិកេ តិកំ ឧបសម្បទាបនាទីនិ

កាយិកវាចសិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ ។ អបរេហិបិ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ កម្មំ កាតព្វំ អាបត្តឹ អាបន្នោ កម្មកតោ ឧបសម្បាទេតិ និស្សយំ ទេតិ សាមណេរំ ឧបដ្ឋាបេតិ ។ អបរេហិបិ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ កម្មំ កាតព្វំ យាយ អាបត្តិយា សង្ឃេន កម្មំ កតំ ហោតិ តំ អាបត្តឹ អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ ។ អបរេហិបិ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ កម្មំ កាតព្វំ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ សង្ឃមជ្ឈេ ឧបោសថំ ឋបេន្តស្ស អលំ ភិក្ខុ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន ឧបោសថោ កាតព្វោ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ សង្ឃមជ្ឈេ បវារណំ ឋបេន្តស្ស អលំ ភិក្ខុ មា ភណ្ឌនំ មា កលហំ

មិច្ឆាជីវៈដោយកាយនិងវាចា ១ ។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកប
ដោយអង្គ ៣ ដោយឡែកទៀត គឺ ភិក្ខុត្រូវអាបត្តិហើយ សង្ឃបានធ្វើកម្ម
ហើយនៅតែឲ្យឧបសម្បទា (ដល់កុលបុត្រ)១ ឲ្យនិស្ស័យ (ដល់កុលបុត្រ)១
ឲ្យសាមណេរបម្រើខ្លួន ១ ។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយ
អង្គ ៣ ដោយឡែកទៀត គឺ កម្មដែលសង្ឃធ្វើហើយដោយអាបត្តិណា
ភិក្ខុត្រូវអាបត្តិដដែលនោះ១ ឬត្រូវអាបត្តិដទៃប្រហែលគ្នានឹងអាបត្តិនោះ ១
ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះទៅទៀត ១ ។ សង្ឃគប្បីធ្វើកម្មដល់ភិក្ខុ
ដែលប្រកបដោយអង្គ ៣ ដោយឡែកទៀត គឺ ភិក្ខុពោលតិះដៀលព្រះ
ពុទ្ធ១ ពោលតិះដៀលព្រះធម៌ ១ ពោលតិះដៀលព្រះសង្ឃ ១ ។ កាល
បើមានភិក្ខុប្រកបដោយអង្គ ៣ គឺ ភិក្ខុមិនមានអៀនខ្មាស ១ ភិក្ខុពាល ១
មិនមែនជាបកតត្ត ១ មកបញ្ឈប់នូវឧបោសថ ក្នុងកណ្ដាលជំនុំសង្ឃ ។
ត្រូវហាមប្រាមដោយពាក្យថា ម្នាលភិក្ខុ មិនគួរទេ កុំបង្កហេតុ កុំឈ្លោះ
កុំប្រកាន់ផ្សេងគ្នា កុំទាស់ទែងគ្នាដូច្នេះរួចហើយសឹមធ្វើឧបោសថ ។ កាល
បើភិក្ខុប្រកបដោយអង្គ ៣ គឺ ភិក្ខុដែលមិនមានអៀនខ្មាស ១ ភិក្ខុពាល ១
មិនមែនជាបកតត្ត ១ មកបញ្ឈប់បវារណាក្នុងកណ្ដាលជំនុំសង្ឃ ។ ត្រូវ
ហាមប្រាមដោយពាក្យថា ម្នាលភិក្ខុ មិនគួរទេ អ្នកកុំបង្កហេតុ កុំឈ្លោះ

មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន បវារេតព្វំ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ន កាចិ សង្ឃសម្មុតិ ទាតព្វា អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃោ ន វោហរិតព្វោ[១] អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតោ ភិក្ខុ ន កិស្មិញ្ចិ បច្ចេកដ្ឋានេ ឋបេតព្វោ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ និស្សាយ ន វត្ថព្វំ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ និស្សយោ ន ទាតព្វោ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសំ[២] ការាបេន្តស្ស នាលំ ឱកាសកម្មំ កាតុំ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ សវចនីយំ នាទាតព្វំ

១ ឱ. ម. សង្ឃេ ន វោហរិតព្វំ ។ ២ ឱ. ម. ឱកាសកម្មំ ។

គ្នា កុំប្រកាន់ផ្សេងគ្នា កុំទាស់ទែងគ្នា ដូច្នេះរួចហើយសឹមបវារណា ។ សង្ឃសម្មតិណាមួយ សង្ឃមិនត្រូវឲ្យដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកមិនមានទោស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។ ភិក្ខុប្រកបដោយអង្គ៣ មិនត្រូវស្តីពោលកេសង្ឃ គឺ ភិក្ខុជាអ្នកមិនមានទោស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត១ ។ ភិក្ខុដែលប្រកបដោយអង្គ ៣ សង្ឃមិនត្រូវដំកល់ទុកក្នុងតំណែងផ្សេងណាមួយ គឺ ភិក្ខុជាអ្នកមិនមានទោស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។ ភិក្ខុមិនត្រូវអាស្រ័យនៅនឹងភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកមិនមានទោស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត១ ។ ភិក្ខុមិនត្រូវឲ្យនិស្ស័យដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកមិនមានទោស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។ ភិក្ខុមិនត្រូវធ្វើឱកាសកម្មដល់ភិក្ខុ ដែលមកសូមឱកាស ដែលប្រកបដោយអង្គ៣ គឺ ភិក្ខុជាអ្នកមិនមានទោស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត១ ។ ភិក្ខុមិនត្រូវជឿស្តាប់ពាក្យរបស់ភិក្ខុដែលប្រកបដោយអង្គ ៣

អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ វិនយោ ន បុច្ឆិតព្វោ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតេន ភិក្ខុនា វិនយោ ន បុច្ឆិតព្វោ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ វិនយោ ន វិស្សជ្ជេតព្វោ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តិហង្គេហិ សមន្នាគតេន ភិក្ខុនា វិនយោ ន វិស្សជ្ជេតព្វោ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អនុយោគោ ន ទាតព្វោ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ វិនយោ ន សាកច្ឆិតព្វោ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។ តីហង្គេហិ សមន្នាគតេន ភិក្ខុនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ។

ឯកត្តិក តិកៈ មានភិក្ខុមិនមានខ្មាសជាដើម

គឺ ភិក្ខុជាអ្នកមិនមានខ្មាស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។ ភិក្ខុមិនត្រូវសួរវិន័យចំពោះភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៣ មិនត្រូវសួរវិន័យ (នឹងភិក្ខុណាមួយ) គឺ ភិក្ខុជាអ្នកមិនមានខ្មាស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។ ភិក្ខុមិនត្រូវដោះស្រាយវិន័យចំពោះភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៣ មិនត្រូវដោះស្រាយវិន័យនឹងភិក្ខុណាមួយ គឺ ភិក្ខុជាអ្នកមិនមានខ្មាស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។ ភិក្ខុមិនត្រូវឲ្យការសាកសួរដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស ១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត ១ ។ ភិក្ខុមិនត្រូវសាកច្ឆាវិន័យជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។ ភិក្ខុដែលប្រកបដោយអង្គ៣ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន គឺ ភិក្ខុជាអ្នកមិនមានខ្មាស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ ។

[៦២] តយោ ឧបោសថា ចាតុទ្ទសិកោ បណ្ណរសិកោ សាមគ្គីឧបោសថោ ។ អបរេបិ តយោ ឧបោសថា សង្ឃេ ឧបោសថោ គណេ ឧបោសថោ បុគ្គលេ ឧបោសថោ ។ អបរេបិ តយោ ឧបោសថា សុត្តុទ្ទេសោ (១) បារិសុទ្ធិឧបោសថោ អធិដ្ឋានឧបោសថោ ។ តិស្សោ បវារណា ចាតុទ្ទសិកា បណ្ណរសិកា សាមគ្គីបវារណា ។ អបរាបិ តិស្សោ បវារណា សង្ឃេ បវារណា គណេ បវារណា បុគ្គលេ បវារណា ។ អបរាបិ តិស្សោ បវារណា តេវាចិកា បវារណា ទ្វេវាចិកា បវារណា សមានវស្សិកា បវារណា ។ តយោ អាបាយិកា នេរយិកា ឥទមប្បហាយ យោ ច អព្រហ្មចារី ព្រហ្មចារីបដិញ្ញោ យោ ច សុទ្ធំ ព្រហ្មចារឹ សុទ្ធំ ព្រហ្មចរិយំ (២) ចរន្តំ អមូលកេន អព្រហ្មចរិយេន អនុទ្ធំសេតិ យោ ចាយំ ឯវំវាទី ឯវំទិដ្ឋិ នត្ថិ កាមេសុ ទោសោតិ សោ កាមេសុ បាតព្យតំ អាបជ្ជតិ ។ តីណិ អកុសលមូលានិ លោភោ អកុសលមូលំ ទោសោ

---

១ ឱ. ម. សុត្តុទ្ទេសោ ឧបោសថោ ។ ២ ឱ. ម. អសុទ្ធព្រហ្មចារី បរិសុទ្ធព្រហ្មចរិយំ ។

[៤៦] ឧបោសថមាន ៣ យ៉ាង គឺ ចាតុទ្ទសីឧបោសថ ១ បណ្ណរសីឧបោសថ១ សាមគ្គីឧបោសថ ១ ។ ឧបោសថមាន ៣ យ៉ាងដទៃទៀត គឺ សង្ឃឧបោសថ ១ គណឧបោសថ ១ បុគ្គលឧបោសថ ១ ។ ឧបោសថមាន៣យ៉ាងដទៃទៀត គឺសុត្តុទ្ទេសឧបោសថ ១ បារិសុទ្ធិឧបោសថ១ អធិដ្ឋានឧបោសថ ១ ។ បវារណាមាន ៣ យ៉ាង គឺ ចាតុទ្ទសីបវារណា១ បណ្ណរសីបវារណា ១ សាមគ្គីបវារណា ១ ។ បវារណាមាន ៣ យ៉ាងដទៃទៀត គឺ សង្ឃប្បវារណា ១ គណប្បវារណា ១ បុគ្គលប្បវារណា ១ បវារណាមាន ៣ យ៉ាង ដោយឡែកទៀត គឺ តេវាចិកាបវារណា ១ ទ្វេវាចិកាបវារណា ១ សមានវស្សិកាបវារណា ១ ។ បុគ្គលឈមមុខទៅកាន់អបាយ ទៅកាន់នរក មាន ៣ ពួក គឺ បុគ្គលមិនមែនជាអ្នកប្រព្រឹត្តព្រហ្មចារ្យ តែប្តេជ្ញាថាជាអ្នកប្រព្រឹត្តព្រហ្មចារ្យ ១ បុគ្គលចោទព្រហ្មចារីបុគ្គលដ៏បរិសុទ្ធ ដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ ដោយអព្រហ្មចរិយធម៌មិនមានមូល ១ បុគ្គលណាមួយមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទោសក្នុងកាមគុណមិនមានដូច្នេះ បុគ្គលនោះតែងដល់នូវការសេពគប់នូវកាមទាំងឡាយ ១ ព្រោះមិនលះលទ្ធិនេះចេញ ។ មូលនៃអកុសលមាន ៣ យ៉ាង គឺ[១] លោភៈជាមូលនៃអកុសល ១ ទោសៈ

---

១ អដ្ឋកថា សំដៅយកព្រះខីណាស្រព ។

ឯកុត្តរិកេ តិកំ តីណិ កុសលមូលាទីនិ

អកុសលមូលំ មោហោ អកុសលមូលំ ។ តីណិ កុសលមូលានិ អលោភោ កុសលមូលំ អទោសោ កុសលមូលំ អមោហោ កុសលមូលំ ។ តីណិ ទុច្ចរិតានិ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ។ តីណិ សុចរិតានិ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ ។ តយោ អត្ថវសេ បដិច្ច ភគវតា កុលេសុ តិកភោជនំ បញ្ញត្តំ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ មា បាបិច្ឆា បក្ខំ និស្សាយ សង្ឃំ ភិន្ទេយ្យុំ កុលានុទ្ទយតាយ ច ។ តីហិ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ បាបិច្ឆតា បាបមិត្តតា ឱរមត្តកេន វិសេសាធិគមេន អន្តរា វោសានំ អាបាទិ ។ តិស្សោ សម្មុតិយោ ទណ្ឌសម្មុតិ សិក្កាសម្មុតិ ទណ្ឌសិក្កាសម្មុតិ ។ តិស្សោ បាទុកា ធុវដ្ឋានិយា អសង្កមនីយា វច្ចបាទុកា បស្សាវបាទុកា

ជាមូលនៃអកុសល ១ មោហៈជាមូលនៃអកុសល ១ ។ មូលនៃកុសល មាន ៣ យ៉ាង គឺ អលោភៈជាមូលនៃកុសល១ អទោសៈជាមូលនៃកុសល១ អមោហៈជាមូលនៃកុសល ១ ។ ទុច្ចរិតមាន ៣ យ៉ាង គឺ កាយទុច្ចរិត១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។ សុចរិតមាន ៣ យ៉ាង គឺ កាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តតិកភោជនសិក្ខាបទក្នុងត្រកូលទាំងឡាយ ព្រោះអាស្រ័យ អំណាចប្រយោជន៍ ៣ យ៉ាង គឺ ដើម្បីផ្ចាញ់ផ្ចាល់បុគ្គលឥតខ្មាស ១ ដើម្បីនៅសប្បាយដល់ភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ដោយទ្រង់ត្រិះរិះថា ភិក្ខុប្រាថ្នាលាមកទាំងឡាយកុំទំលាយសង្ឃព្រោះអាស្រ័យពួក ១ ដើម្បីអនុគ្រោះដល់ត្រកូល ១ ។ ទេវទត្តត្រូវអសទ្ធម្ម ៣ ប្រការ គ្របសង្កត់រួបរិតចិត្តហើយក៏ទៅកាន់អបាយ ទៅកាន់នរក តាំងនៅអស់កល្ប កែខ្លួនលែងបាន (អសទ្ធម្ម ៣ ប្រការនោះគឺ) សេចក្តីប្រាថ្នាលាមក ១ មានមិត្រលាមក ១ ទេវទត្តនោះ បានសម្រេចគុណវិសេសត្រឹមជាន់ទាប តែដល់នូវសេចក្តីសាបសូន្យក្នុងចន្លោះវិញ ១ ។ សម្មតិមាន ៣ យ៉ាង គឺ ទណ្ឌសម្មតិ ១ សិក្ខាសម្មតិ ១ ទណ្ឌសិក្ខាសម្មតិ ១ ។ ទ្រនាប់ជើងដែលសម្រាប់ដំកល់ទុកជានិច្ច មិនត្រូវធ្វើឲ្យឃ្លាតចាកកន្លែងមាន ៣ គឺ ទ្រនាប់សម្រាប់បន្ទោបង់វច្ចៈ ១ ទ្រនាប់សម្រាប់បន្ទោបង់បស្សាវៈ ១

អាចមនបាទុកា ។ តិស្សោ បាទឃំសនិយោ សក្ខរ
កថលា សមុទ្ទផេណកាតិ[1] ។

តិកំ និដ្ឋិតំ[2] ។

តស្សុទ្ទានំ

(៤៧) តិដ្ឋន្តេ កាលេ វត្ថុំ ច
ទស បញ្ហ ច កុសលា[3]
វេទនា ចោទនាវត្ថុ
សលាកា ទ្វេ បដិក្ខិតា
បញ្ញត្តិ អបរេ ទ្វេ ច
ពាលោ កាលេ ច កប្បតិ
ហោមន្តេ សង្ឃោ សង្ឃស្ស
ឆាទនា ច បដិច្ឆទិ[4]
បដិច្ឆន្នា វិវដ្ឋា ច
សេនាសនគិលាយនា

១ ឱ. ម. សមុទ្ទផេណកោតិ ។ ២ ឱ. តិកា និដ្ឋិតា ។ ៣ ឱ. ម. ទស បញ្ហ កុស-លេន ។ ៤ ឱ. ម. បដិច្ឆាទិ ។

ទ្រនាប់សម្រាប់ជំរះអាចម៍ ១ ។ ទ្រនាប់សម្រាប់ជូតជើង មាន ៣ គឺ ទ្រនាប់ថ្ម ១ ទ្រនាប់ក្បឿង ១ ទ្រនាប់អណ្ដាតសមុទ្រ ១ ។

ចប់តិកៈ (ពួកបីៗ) ។

ឧទ្ទាន គឺបញ្ជីរឿងនៃតិកៈ (ពួកបី ៗ) នោះដូច្នេះ

(៨៧) ភិក្ខុត្រូវអាបត្តិក្នុងកាលដែលព្រះមានព្រះភាគគង់ព្រះជន្មនៅ ១ ភិក្ខុត្រូវអាបត្តិក្នុងកាលគួរ ១ ក្នុងរាត្រី ១ ភិក្ខុមានវស្សា ១០ ត្រូវអាបត្តិ ១ មានវស្សា ៥ ក៏ត្រូវអាបត្តិ ១ មានកុសលចិត្តក៏ត្រូវអាបត្តិ ១ ប្រកបដោយវេទនាត្រូវអាបត្តិ ១ ចោទនវត្ថុ ១ ការចាប់ស្លាក ១ ការឃាត់មានពីរលើក ១ បញ្ញត្តិ ១ បញ្ញត្តិពីរលើកដទៃទៀត ១ ភិក្ខុពាលត្រូវអាបត្តិក៏មាន ១ ភិក្ខុត្រូវអាបត្តិក្នុងកាឡប័ក្ខ ១ ការចូលវស្សាគួរក្នុងកាឡប័ក្ខ ១ ភិក្ខុត្រូវអាបត្តិក្នុងហេមន្តរដូវក៏មាន ១ សង្ឃត្រូវអាបត្តិ ១ ឧបោសថនិងបវារណាគួរដល់សង្ឃ ១ ការបិទបាំង ១ គ្រឿងបិទបាំង ១ វត្ថុដែលបិទបាំងទុក ១ វត្ថុដែលបើកឡើង ១ ការកាន់យកសេនាសនៈ ១ ភិក្ខុឈឺត្រូវ

ឯកុត្តរិកំ តិកំ ឧទ្ទានគាថា

ជាតិមោក្ខបរិវាសា(១)
មានត្តា ជារិវសិកា
អដ្ដោ អដ្ដោ ច សីមាយ
អាបត្តិ បុណាបរេ
វុដ្ឋាតិ អបរេ ចេវ
អមូឡ្ហវិនយា ទុវេ
តជ្ជនិយោ និយស្សា ច
បព្វាជបដិសារណី(២)
អទស្សនាបដិក្កម្មេ
អនិស្សគ្គេ ច ទិដ្ឋិយា
អាគាឡ្ហកម្មានិសីសេ
ឧវាណាជារយាតិកា
អាជីវបច្ចា តានិសិកា
អវណ្ណុទោសវេទន ច
បវារណា សម្មុតិ ច
វោហារបច្ចេកោន(៣) ច
ន វត្តព្វំ ន នាតព្វំ

១ ឱ. ម. ជាតិមោក្ខំ បរិវាសំ ។ ២ ឱ. បព្វាជនីយបដិសារណី ។ ៣ ឱ. វោហា-របច្ចេកេន ។

អាបត្តិ ១ បញ្ឈប់បាតិមោក្ខ ១ បរិវាស ១ មានត្ត ១ ភិក្ខុកំពុងនៅបរិវាស ១ ភិក្ខុនៅខាងក្នុងត្រូវអាបត្តិ ១ ភិក្ខុត្រូវអាបត្តិខាងក្នុងសីមា ១ ភិក្ខុត្រូវអាបត្តិដោយអាការ ៣ ដទៃទៀត ១ ភិក្ខុចេញចាកអាបត្តិដោយអាការ ៣ ដទៃទៀត ១ ការឲ្យអមូឡ្ហវិន័យ ២ យ៉ាង ១ សង្ឃធ្វើតជ្ជនីយកម្ម១ និយស្សកម្ម១ បព្វាជនីយកម្ម១ បដិសារណីយកម្ម១ សង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ១ ព្រោះមិនសំដែងអាបត្តិ១ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ១ សង្ឃលៃលកដើម្បីសេចក្តីមាំមួន ១ សង្ឃគប្បីធ្វើកម្មដល់ភិក្ខុ ១ អធិសីល ១ ល្បែង ១ ភិក្ខុមានមារយាទមិនមានសណ្តាប់ធ្នាប់១ ការបៀតបៀន១ មិច្ឆាជីវៈ១ ភិក្ខុត្រូវអាបត្តិហើយនៅតែឲ្យឧបសម្បទា ១ ភិក្ខុត្រូវអាបត្តិប្រហែលនឹងអាបត្តិមុននោះ ១ ភិក្ខុតិះដៀលព្រះរតនត្រ័យ ១ ហាមឧបោសថ ១ ហាមបវារណា ១ សង្ឃសម្មតិ ១ ភិក្ខុល្ងង់មិនគប្បីស្តីរកសង្ឃ ១ សង្ឃមិនត្រូវដំកល់ភិក្ខុល្ងង់ទុកក្នុងតំណែងផ្សេងណាមួយ ១ មិនត្រូវឲ្យនិស្ស័យ ១

ខែមបិនគេ បរិភេក

ឱកាសំ ច ការេ តថា
ច ការេ សវចនីយំ
ច បុច្ឆិតព្វកា ទុវេ
ច វិស្សជ្ជេ ទុវេ ចេវ
អនុយោគម្បិ ទោ ទទេ
សាកច្ឆា ឧបសម្បទា
និស្សយ សាមណេរ[១] ច
ឧភោសជតិកា តីណិ
បរិណាតិកា តយោ
អាចយិកា អកុសលា
កុសលា ចរិតេន[២] ច
តិកាភោជនសទ្ធម្មេ
សម្មតិ ធានុក្កេន ច
ធានយំសនិកា ចេវ
ឧទ្ទានំ តិកាតោ ឥទន្តិ ។

---

១ ឱ. ម. សាមណេភ ប ។ ២ ឱ. ម. បរិតា ទុវេ ។

វិនយបិដក បរិវារៈ

មិនត្រូវបើកឱកាសឲ្យ១ មិនត្រូវជឿស្តាប់ពាក្យ១ មិនត្រូវសួរវិន័យមានពីរលើក ១ មិនត្រូវឆ្លើយវិន័យមានពីរលើក ១ មិនត្រូវឲ្យការសាកសួរ ១ មិនត្រូវសាកច្ឆាវិន័យ ១ មិនត្រូវឲ្យឧបសម្បទា ១ មិនត្រូវឲ្យនិស្ស័យ ១ មិនត្រូវឲ្យសាមណេរបំរើខ្លួន ១ ឧបោសថមាន ៣ យ៉ាង ១ បវារណាមាន ៣ យ៉ាង ១ ជន ៣ ពួកទៅកាន់អបាយ ១ អកុសលមូល ១ កុសលមូល ១ ទុច្ចរិតនឹងសុចរិត ១ តិកភោជនសិក្ខាបទ ១ ទេវទត្តត្រូវអសទ្ធម្មគ្របសង្កត់ ១ សម្មតិ ១ ទ្រនាប់ជើង ១ ទ្រនាប់សម្រាប់ជូតជើង ១ ពាក្យដែលពោលមកនេះ ជាឧទ្ទានក្នុងតិកបទ ។

ឯកុត្តរិកំ ចតុក្កំ អាបត្តិអាបជ្ជនវុដ្ឋានាទយោ

[៤៨] អត្ថាបត្តិ សកវាចាយ អាបជ្ជតិ បរវាចាយ វុដ្ឋាតិ អត្ថាបត្តិ បរវាចាយ អាបជ្ជតិ សកវាចាយ វុដ្ឋាតិ អត្ថាបត្តិ សកវាចាយ អាបជ្ជតិ សកវាចាយ វុដ្ឋាតិ អត្ថាបត្តិ បរវាចាយ អាបជ្ជតិ បរវាចាយ វុដ្ឋាតិ ។ អត្ថាបត្តិ កាយេន អាបជ្ជតិ វាចាយ វុដ្ឋាតិ អត្ថាបត្តិ វាចាយ អាបជ្ជតិ កាយេន វុដ្ឋាតិ អត្ថាបត្តិ កាយេន អាបជ្ជតិ កាយេន វុដ្ឋាតិ អត្ថាបត្តិ វាចាយ អាបជ្ជតិ វាចាយ វុដ្ឋាតិ ។ អត្ថាបត្តិ បសុត្តោ អាបជ្ជតិ បដិពុទ្ធោ វុដ្ឋាតិ អត្ថាបត្តិ បដិពុទ្ធោ អាបជ្ជតិ បសុត្តោ វុដ្ឋាតិ អត្ថាបត្តិ បសុត្តោ អាបជ្ជតិ បសុត្តោ វុដ្ឋាតិ អត្ថាបត្តិ បដិពុទ្ធោ អាបជ្ជតិ បដិពុទ្ធោ វុដ្ឋាតិ ។ អត្ថាបត្តិ អចិត្តកោ អាបជ្ជតិ សចិត្តកោ វុដ្ឋាតិ អត្ថាបត្តិ សចិត្តកោ អាបជ្ជតិ អចិត្តកោ វុដ្ឋាតិ អត្ថាបត្តិ អចិត្តកោ អាបជ្ជតិ អចិត្តកោ វុដ្ឋាតិ អត្ថាបត្តិ សចិត្តកោ អាបជ្ជតិ សចិត្តកោ វុដ្ឋាតិ ។ អត្ថាបត្តិ អាបជ្ជន្តោ ទេសេតិ ទេសេន្តោ អាបជ្ជតិ អត្ថាបត្តិ អាបជ្ជន្តោ វុដ្ឋាតិ

ឯកុត្តរិកៈ ចតុក្កៈ ការត្រូវនិងការចេញចាកអាបត្តិជាដើម

(៤៨) ភិក្ខុត្រូវអាបត្តិដោយវាចារបស់ខ្លួន ចេញចាកអាបត្តិដោយវាចារបស់អ្នកដទៃក៏មាន ភិក្ខុត្រូវអាបត្តិដោយវាចារបស់អ្នកដទៃ ចេញចាកអាបត្តិដោយវាចារបស់ខ្លួនក៏មាន ត្រូវអាបត្តិដោយវាចារបស់ខ្លួន ចេញចាកអាបត្តិដោយវាចារបស់ខ្លួនក៏មាន ត្រូវអាបត្តិដោយវាចារបស់អ្នកដទៃ ចេញចាកអាបត្តិដោយវាចារបស់អ្នកដទៃក៏មាន ។ ភិក្ខុត្រូវអាបត្តិដោយកាយ ចេញចាកអាបត្តិដោយវាចាក៏មាន ត្រូវអាបត្តិដោយវាចា ចេញចាកអាបត្តិដោយកាយក៏មាន ត្រូវអាបត្តិដោយកាយ ចេញចាកអាបត្តិដោយកាយក៏មាន ត្រូវអាបត្តិដោយវាចា ចេញចាកអាបត្តិដោយវាចាក៏មាន ។ ភិក្ខុដេកលក់ត្រូវអាបត្តិ ភ្ញាក់ឡើងចេញចាកអាបត្តិក៏មាន ភ្ញាក់ឡើងត្រូវអាបត្តិ ដេកលក់ទៅវិញចេញចាកអាបត្តិក៏មាន ដេកលក់ត្រូវអាបត្តិ ដេកលក់ចេញចាកអាបត្តិក៏មាន ភ្ញាក់ឡើងត្រូវអាបត្តិ ភ្ញាក់ឡើងចេញចាកអាបត្តិក៏មាន ។ ភិក្ខុមិនមានចិត្តត្រូវអាបត្តិ ប្រកបដោយចិត្តចេញចាកអាបត្តិក៏មាន ភិក្ខុប្រកបដោយចិត្តត្រូវអាបត្តិ មិនមានចិត្តចេញចាកអាបត្តិក៏មាន ភិក្ខុមិនមានចិត្តត្រូវអាបត្តិ មិនមានចិត្តចេញចាកអាបត្តិក៏មាន ភិក្ខុប្រកបដោយចិត្តត្រូវអាបត្តិ ប្រកបដោយចិត្តចេញចាកអាបត្តិក៏មាន ។ ភិក្ខុត្រូវអាបត្តិហើយសំដែង កំពុងតែសំដែងត្រូវអាបត្តិទៀតក៏មាន ភិក្ខុត្រូវអាបត្តិហើយចេញចាកអាបត្តិ កំពុងចេញចាកអាបត្តិ ត្រូវអាបត្តិ

វុដ្ឋហន្តោ អាបជ្ជតិ ។ អត្ថាបត្តិ កម្មេន អាបជ្ជតិ អកម្មេន វុដ្ឋាតិ អត្ថាបត្តិ អកម្មេន អាបជ្ជតិ កម្មេន វុដ្ឋាតិ អត្ថាបត្តិ កម្មេន អាបជ្ជតិ កម្មេន វុដ្ឋាតិ អត្ថាបត្តិ អកម្មេន អាបជ្ជតិ អកម្មេន វុដ្ឋាតិ ។

(៤៩) ចត្តារោ អនរិយវោហារា អទិដ្ឋេ ទិដ្ឋវាទិតា អស្សុតេ សុតវាទិតា អមុតេ មុតវាទិតា អវិញ្ញាតេ វិញ្ញាតវាទិតា ។ ចត្តារោ អរិយវោហារា អទិដ្ឋេ អទិដ្ឋវាទិតា អស្សុតេ អស្សុតវាទិតា អមុតេ អមុតវាទិតា អវិញ្ញាតេ អវិញ្ញាតវាទិតា ។ អបរេបិ ចត្តារោ អនរិយវោហារា ទិដ្ឋេ អទិដ្ឋវាទិតា សុតេ អស្សុតវាទិតា មុតេ អមុតវាទិតា វិញ្ញាតេ អវិញ្ញាតវាទិតា ។ ចត្តារោ អរិយ-

ទៀតក៏មាន ។ ភិក្ខុត្រូវអាបត្តិដោយកម្ម ចេញចាកអាបត្តិដោយមិនមែនកម្មក៏មាន ភិក្ខុត្រូវអាបត្តិដោយមិនមែនកម្ម ចេញចាកអាបត្តិដោយកម្មក៏មាន ភិក្ខុត្រូវអាបត្តិដោយកម្ម ចេញចាកអាបត្តិដោយកម្មក៏មាន ភិក្ខុត្រូវអាបត្តិដោយមិនមែនកម្ម ចេញចាកអាបត្តិដោយមិនមែនកម្មក៏មាន ។

[៨៩] អនរិយវោហារ (វោហារមិនប្រសើរ) មាន ៨ គឺ ការពោលថាបានឃើញក្នុងហេតុដែលខ្លួនមិនបានឃើញ ១ ការពោលថាបានឮក្នុងហេតុដែលខ្លួនមិនបានឮ ១ ការពោលថាបានពាល់ត្រូវក្នុងហេតុដែលខ្លួនមិនបានពាល់ត្រូវ ១ ការពោលថាដឹងច្បាស់ក្នុងហេតុដែលខ្លួនមិនដឹងច្បាស់ ១ ។ អរិយវោហារ (វោហារដ៏ប្រសើរ) មាន ៨ គឺ ការពោលថាមិនបានឃើញក្នុងហេតុដែលខ្លួនមិនបានឃើញ ១ ការពោលថាមិនបានឮក្នុងហេតុដែលខ្លួនមិនបានឮ ១ ការពោលថាមិនបានពាល់ត្រូវក្នុងហេតុដែលខ្លួនមិនបានពាល់ត្រូវ ១ ការពោលថាមិនបានដឹងច្បាស់ក្នុងហេតុដែលខ្លួនមិនបានដឹងច្បាស់ ១ ។ អនរិយវោហារមាន ៨ ដទៃទៀត គឺ ការពោលថាមិនបានឃើញក្នុងហេតុដែលខ្លួនបានឃើញ ១ ការពោលថាមិនបានឮក្នុងហេតុដែលខ្លួនបានឮ ១ ការពោលថាមិនបានពាល់ត្រូវក្នុងហេតុដែលខ្លួនពាល់ត្រូវ ១ ការពោលថាមិនបានដឹងច្បាស់ក្នុងហេតុដែលខ្លួនដឹងច្បាស់ ១ ។ អរិយវោហារមាន ៨ គឺ ការពោលថា

វោហារា ទិដ្ឋេ ទិដ្ឋវាទិតា សុតេ សុតវាទិតា មុតេ មុតវាទិតា វិញ្ញាតេ វិញ្ញាតវាទិតា ចត្តារោ បារាជិកា ភិក្ខូនំ ភិក្ខុនីហិ សាធារណា ។ ចត្តារោ បារាជិកា ភិក្ខុនីនំ ភិក្ខូហិ អសាធារណា ។ ចត្តារោ បរិក្ខារា អត្ថិ បរិក្ខារោ រក្ខិតព្វោ គោបេតព្វោ មមាយិតព្វោ បរិភុញ្ជិតព្វោ អត្ថិ បរិក្ខារោ រក្ខិតព្វោ គោបេតព្វោ ន មមាយិតព្វោ បរិភុញ្ជិតព្វោ អត្ថិ បរិក្ខារោ រក្ខិតព្វោ គោបេតព្វោ ន មមាយិតព្វោ ន បរិភុញ្ជិតព្វោ អត្ថិ បរិក្ខារោ ន រក្ខិតព្វោ ន គោបេតព្វោ ន មមាយិតព្វោ ន បរិភុញ្ជិតព្វោ ។

(៨០) អត្ថាបត្តិ សម្មុខា អាបជ្ជតិ បរម្មុខា វុដ្ឋាតិ អត្ថាបត្តិ បរម្មុខា អាបជ្ជតិ សម្មុខា វុដ្ឋាតិ អត្ថាបត្តិ សម្មុខា អាបជ្ជតិ សម្មុខា វុដ្ឋាតិ អត្ថាបត្តិ បរម្មុខា អាបជ្ជតិ បរម្មុខា វុដ្ឋាតិ ។ អត្ថាបត្តិ អជានន្តោ អាបជ្ជតិ ជានន្តោ វុដ្ឋាតិ អត្ថាបត្តិ ជានន្តោ អាបជ្ជតិ

បានឃើញក្នុងហេតុដែលខ្លួនបានឃើញ ១ ការពោលថាបានឮក្នុងហេតុដែលខ្លួនបានឮ១ ការពោលថាបានពាល់ត្រូវក្នុងហេតុដែលខ្លួនបានពាល់ត្រូវ ១ ការពោលថាបានដឹងច្បាស់ក្នុងហេតុដែលខ្លួនបានដឹងច្បាស់ ១ ។ បារាជិកាបត្តិទាំង ៤ របស់ភិក្ខុ សាធារណ៍ទៅដល់ពួកភិក្ខុនីផង ។ បារាជិកាបត្តិទាំង ៤ របស់ភិក្ខុនី មិនបានសាធារណ៍ទៅដល់ពួកភិក្ខុផងទេ ។ បរិក្ខារ ៤ គឺបរិក្ខារដែលភិក្ខុគួររក្សា គួរគ្រប់គ្រង គួរប្រកាន់ថាជារបស់អាត្មាអញ គួរប្រើប្រាស់ក៏មាន បរិក្ខារដែលភិក្ខុគួររក្សា គួរគ្រប់គ្រង មិនគួរប្រកាន់ថាជារបស់អាត្មាអញ តែគួរប្រើប្រាស់ក៏មាន បរិក្ខារដែលភិក្ខុគួររក្សា គួរគ្រប់គ្រង តែមិនគួរប្រកាន់ថាជារបស់អាត្មាអញ មិនគួរប្រើប្រាស់ក៏មាន បរិក្ខារដែលភិក្ខុមិនគួររក្សា មិនគួរគ្រប់គ្រង មិនគួរប្រកាន់ថាជារបស់អាត្មាអញ មិនគួរប្រើប្រាស់ក៏មាន ។

(៩០) ភិក្ខុត្រូវអាបត្តិក្នុងទីចំពោះមុខ ចេញចាកអាបត្តិក្នុងទីកំបាំងមុខក៏មាន ត្រូវអាបត្តិក្នុងទីកំបាំងមុខ ចេញចាកអាបត្តិក្នុងទីចំពោះមុខក៏មាន ត្រូវអាបត្តិក្នុងទីចំពោះមុខ ចេញចាកអាបត្តិក្នុងទីចំពោះមុខក៏មាន ត្រូវអាបត្តិក្នុងទីកំបាំងមុខ ចេញចាកអាបត្តិក្នុងទីកំបាំងមុខក៏មាន ។ ភិក្ខុកាលមិនដឹងត្រូវអាបត្តិ កាលដឹងចេញចាកអាបត្តិក៏មាន កាលដឹងត្រូវអាបត្តិ

អជានន្តោ វុដ្ឋាតិ អត្ថាបត្តិ ជានន្តោ អាបជ្ជតិ ជានន្តោ វុដ្ឋាតិ អត្ថាបត្តិ អជានន្តោ អាបជ្ជតិ អជានន្តោ វុដ្ឋាតិ ។

(៤១) ចតូហាការេហិ អាបត្តិំ អាបជ្ជតិ កាយេន អាបជ្ជតិ វាចាយ អាបជ្ជតិ កាយេន វាចាយ អាបជ្ជតិ កម្មវាចាយ អាបជ្ជតិ ។ អបរេហិបិ ចតូហាការេហិ អាបត្តិំ អាបជ្ជតិ សង្ឃមជ្ឈេ គណមជ្ឈេ បុគ្គលស្ស សន្តិកេ លិង្គបាតុភាវេន ។ ចតូហាការេហិ អាបត្តិយា វុដ្ឋាតិ កាយេន វុដ្ឋាតិ វាចាយ វុដ្ឋាតិ កាយេន វាចាយ វុដ្ឋាតិ កម្មវាចាយ វុដ្ឋាតិ ។ អបរេហិបិ ចតូហាការេហិ អាបត្តិយា វុដ្ឋាតិ សង្ឃមជ្ឈេ គណមជ្ឈេ បុគ្គលស្ស សន្តិកេ លិង្គបាតុភាវេន ។ សហ បដិលាភេន បុរិមំ ជហាតិ[១] បច្ឆិមេ បតិដ្ឋាតិ វិញ្ញត្តិយោ បដិប្បស្សម្ភន្តិ បណ្ណត្តិយោ និរុជ្ឈន្តិ ។ សហ បដិលាភេន បច្ឆិមំ ជហាតិ បុរិមេ បតិដ្ឋាតិ វិញ្ញត្តិយោ បដិប្បស្សម្ភន្តិ បណ្ណត្តិយោ និរុជ្ឈន្តិ ។ ចតស្សោ ហោនជា សីលវិបត្តិយោ ហោន្តិ អាចារវិបត្តិយា ហោន្តិ

---

១ ឱ. ម. ជិហតិ ។

កាលមិនដឹងចេញចាកអាបត្តិក៏មាន កាលដឹងត្រូវអាបត្តិ កាលដឹងចេញចាកអាបត្តិក៏មាន កាលមិនដឹងត្រូវអាបត្តិ កាលមិនដឹងចេញចាកអាបត្តិក៏មាន ។

(៨១) ភិក្ខុត្រូវអាបត្តិដោយអាការ ៤ យ៉ាង គឺ ត្រូវដោយកាយ ១ ដោយវាចា ១ ដោយកាយនឹងវាចា ១ ដោយកម្មវាចា ១ ។ ភិក្ខុត្រូវអាបត្តិដោយអាការ ៤ យ៉ាងដទៃទៀត គឺ ត្រូវក្នុងកណ្តាលជំនុំសង្ឃ ១ ក្នុងកណ្តាលគណៈ ១ ក្នុងសំណាក់នៃបុគ្គល ១ ដោយភ្លាយភេទ ១ ។ ភិក្ខុចេញចាកអាបត្តិដោយអាការ ៤ យ៉ាង គឺ ចេញចាកដោយកាយ ១ ចេញចាកដោយវាចា ១ ចេញចាកដោយកាយនឹងវាចា ១ ចេញចាកដោយកម្មវាចា ១ ។ ភិក្ខុចេញចាកអាបត្តិដោយអាការ ៤ យ៉ាងដទៃទៀត គឺ ចេញចាកអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ១ ក្នុងកណ្តាលគណៈ ១ ក្នុងសំណាក់នៃបុគ្គល ១ ដោយភ្លាយភេទ ១ ។ ភិក្ខុលះបង់បុរិមភេទ (ភេទប្រុស) ព្រមទាំងការបានចំពោះភេទ (ថ្មី) ឋិតនៅក្នុងបច្ឆិមភេទ (ភេទស្រី) វិញ្ញត្តិទាំងឡាយក៏ស្ងប់រម្ងាប់ទៅ បណ្ណត្តិទាំងឡាយក៏រលត់បាត់ទៅ ។ ភិក្ខុនីលះបង់បច្ឆិមភេទព្រមទាំងការបានចំពោះភេទ (ថ្មី) ឋិតនៅក្នុងបុរិមភេទវិញ វិញ្ញត្តិទាំងឡាយក៏ស្ងប់រម្ងាប់បាត់ទៅ បណ្ណត្តិទាំងឡាយក៏រលត់ទៅ ។ ការទោសមាន ៤ យ៉ាង គឺ ទោសដោយសីលវិបត្តិ ១ ទោសដោយអាចារវិបត្តិ ១

ទិដ្ឋិវិបត្តិយា ចោទេតិ អាជីវវិបត្តិយា ចោទេតិ ។ ចត្តារោ បរិវាសា បដិច្ឆន្នបរិវាសោ អប្បដិច្ឆន្នបរិវាសោ សុទ្ធន្តបរិវាសោ សមោធានបរិវាសោ ។ ចត្តារោ មានត្តា បដិច្ឆន្នមានត្តំ អប្បដិច្ឆន្នមានត្តំ បក្ខមានត្តំ សមោធានមានត្តំ ។ ចត្តារោ មានត្តចារិកស្ស ភិក្ខុនោ រត្តិច្ឆេទា សហវាសោ វិប្បវាសោ អនារោចនា ឩនេ គណេ ចរតិ ។ ចត្តារោ សាមុក្កំសា ។ ចត្តារោ បដិគ្គហិតបរិភោគា យាវកាលិកំ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ។ ចត្តារិ មហាវិកដានិ គូថំ មុត្តំ ឆារិកា មត្តិកា ។ ចត្តារិ កម្មានិ អបលោកនកម្មំ ញត្តិកម្មំ ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ។ អបរានិបិ ចត្តារិ កម្មានិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មេន សមគ្គកម្មំ ។ ចតស្សោ វិបត្តិយោ សីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ អាជីវវិបត្តិ ។ ចត្តារិ អធិករណានិ វិវាទាធិករណំ អនុវាទាធិករណំ អាបត្តាធិករណំ កិច្ចាធិករណំ ។ ចត្តារោ បរិសទូសនា ភិក្ខុ ទុស្សីលោ បាបធម្មោ បរិសទូសនោ

ទោសដោយទិដ្ឋិវិបត្តិ ១ ទោសដោយអាជីវវិបត្តិ ១ ។ បរិវាសមាន ៤ យ៉ាង គឺ បដិច្ឆន្នបរិវាស ១ អប្បដិច្ឆន្នបរិវាស ១ សុទ្ធន្តបរិវាស ១ សមោធានបរិវាស ១ ។ មានត្តមាន៤យ៉ាង គឺ បដិច្ឆន្នមានត្ត ១ អប្បដិច្ឆន្នមានត្ត ១ បក្ខមានត្ត ១ សមោធានមានត្ត ១ ។ ការដែលដាច់រាត្រីរបស់ភិក្ខុអ្នកប្រព្រឹត្តមានត្តមាន ៤ យ៉ាងគឺ ការនៅរួម ១ ការមិននៅរួម ១ ការមិនប្រាប់ ១ ប្រព្រឹត្តវត្តក្នុងទីមិនគ្រប់គណៈសង្ឃ ១ ។ គ្រឿងអាង (មហាបទេស) មាន ៤ ។ គ្រឿងបរិភោគដែលភិក្ខុទទួលប្រគេនមាន ៤ គឺយាវកាលិក ១ យាមកាលិក ១ សត្តាហកាលិក ១ យាវជីវិក ១ ។ ថ្នាំមហាវិកដមាន ៤ គឺ គូថៈ ១ មូត្រ ១ ផេះ ១ ដី ១ ។ កម្មមាន ៤ គឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ ញត្តិចតុត្ថកម្ម ១ ។ កម្ម ៤ យ៉ាងដទៃទៀត គឺ កម្មជាពួកមិនប្រកបដោយធម៌ ១ កម្មព្រមព្រៀងគ្នាមិនប្រកបដោយធម៌ ១ កម្មជាពួកតែប្រកបដោយធម៌ ១ កម្មព្រមព្រៀងគ្នាទាំងប្រកបដោយធម៌ ១ ។ វិបត្តិមាន ៤ គឺ សីលវិបត្តិ ១ អាចារវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ អាជីវវិបត្តិ ១ ។ អធិករណ៍មាន ៤ គឺ វិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ ។ អ្នកញុំាងបរិសទ្យឲ្យអាក្រក់មាន ៤ គឺ ភិក្ខុទ្រុស្តសីលមានធម៌ដ៏លាមក ធាត់ជាអ្នកញុំាងបរិសទ្យឲ្យអាក្រក់ ១

ភិក្ខុនី ទុស្សីលា បាបធម្មា បរិសទូសនា ឧបាសកោ ទុស្សីលោ បាបធម្មោ បរិសទូសនោ ឧបាសិកា ទុស្សីលា បាបធម្មា បរិសទូសនា ។ ចត្តារោ បរិសសោភណា ភិក្ខុ សីលវា កល្យាណធម្មោ បរិសសោភណោ ភិក្ខុនី សីលវតី កល្យាណធម្មា បរិសសោភណា ឧបាសកោ សីលវា កល្យាណធម្មោ បរិសសោភណោ ឧបាសិកា សីលវតី កល្យាណធម្មា បរិសសោភណា ។

(៤២) អត្ថាបត្តិ អាគន្តុកោ អាបជ្ជតិ នោ អាវាសិកោ អត្ថាបត្តិ អាវាសិកោ អាបជ្ជតិ នោ អាគន្តុកោ អត្ថាបត្តិ អាគន្តុកោ ចេវ អាបជ្ជតិ អាវាសិកោ ច អត្ថាបត្តិ នេវ អាគន្តុកោ អាបជ្ជតិ នោ អាវាសិកោ ។ អត្ថាបត្តិ គមិកោ អាបជ្ជតិ នោ អាវាសិកោ អត្ថាបត្តិ អាវាសិកោ អាបជ្ជតិ នោ គមិកោ អត្ថាបត្តិ គមិកោ ចេវ អាបជ្ជតិ អាវាសិកោ ច អត្ថាបត្តិ នេវ គមិកោ អាបជ្ជតិ នោ អាវាសិកោ ។

ភិក្ខុនីទ្រុស្តសីលមានធម៌ដ៏លាមក តាំងជាអ្នកញ៉ាំងបរិស័ទឲ្យអាក្រក់ ១ ឧបាសកទ្រុស្តសីល មានធម៌ដ៏លាមក តាំងជាអ្នកញ៉ាំងបរិស័ទឲ្យអាក្រក់១ ឧបាសិកាទ្រុស្តសីលមានធម៌ដ៏លាមក តាំងជាអ្នកញ៉ាំងបរិស័ទឲ្យអាក្រក់ ១ ។ អ្នកញ៉ាំងបរិស័ទឲ្យល្អមាន ៤ គឺ ភិក្ខុមានសីលមានធម៌ល្អ តាំងជាអ្នកញ៉ាំងបរិស័ទឲ្យល្អ ១ ភិក្ខុនីមានសីលមានធម៌ល្អ តាំងជាអ្នកញ៉ាំងបរិស័ទឲ្យល្អ ១ ឧបាសកមានសីលមានធម៌ល្អ តាំងជាអ្នកញ៉ាំងបរិស័ទឲ្យល្អ ១ ឧបាសិកាមានសីលមានធម៌ល្អ តាំងជាអ្នកញ៉ាំងបរិស័ទឲ្យល្អ ១ ។

(៨២) អាគន្តុកភិក្ខុត្រូវអាបត្តិ អាវាសិកភិក្ខុមិនត្រូវអាបត្តិក៏មាន អាវាសិកភិក្ខុត្រូវអាបត្តិ អាគន្តុកភិក្ខុមិនត្រូវអាបត្តិក៏មាន ទាំងអាគន្តុកភិក្ខុ ទាំងអាវាសិកភិក្ខុត្រូវអាបត្តិក៏មាន ទាំងអាគន្តុកភិក្ខុ ទាំងអាវាសិកភិក្ខុមិនត្រូវអាបត្តិក៏មាន ។ គមិកភិក្ខុត្រូវអាបត្តិ អាវាសិកភិក្ខុមិនត្រូវអាបត្តិក៏មាន អាវាសិកភិក្ខុត្រូវអាបត្តិ គមិកភិក្ខុមិនត្រូវអាបត្តិក៏មាន ទាំងគមិកភិក្ខុ ទាំងអាវាសិកភិក្ខុត្រូវអាបត្តិក៏មាន ទាំងគមិកភិក្ខុ ទាំងអាវាសិកភិក្ខុមិនត្រូវអាបត្តិក៏មាន ។

ឯកុត្តរិកំ ចតុក្កំ វត្ថុនានត្តាទយោ

[៤៧] អត្ថិ វត្ថុនានត្តតា នោ អាបត្តិនានត្តតា អត្ថាបត្តិនានត្តតា នោ វត្ថុនានត្តតា អត្ថិ វត្ថុនានត្តតា ចេវ អាបត្តិនានត្តតា ច អត្ថិ នេវ វត្ថុនានត្តតា នោ អាបត្តិនានត្តតា ។ អត្ថិ វត្ថុសភាគតា នោ អាបត្តិសភាគតា អត្ថិ អាបត្តិសភាគតា នោ វត្ថុសភាគតា អត្ថិ វត្ថុសភាគតា ចេវ អាបត្តិសភាគតា ច អត្ថិ នេវ វត្ថុសភាគតា នោ អាបត្តិសភាគតា ។

[៤៨] អត្ថាបត្តិ ឧបជ្ឈាយោ អាបជ្ជតិ នោ សទ្ធិវិហារិកោ អត្ថាបត្តិ សទ្ធិវិហារិកោ អាបជ្ជតិ នោ ឧបជ្ឈាយោ អត្ថាបត្តិ ឧបជ្ឈាយោ ចេវ អាបជ្ជតិ សទ្ធិវិហារិកោ ច អត្ថាបត្តិ នេវ ឧបជ្ឈាយោ អាបជ្ជតិ នោ សទ្ធិវិហារិកោ ។ អត្ថាបត្តិ អាចរិយោ អាបជ្ជតិ នោ អន្តេវាសិកោ អត្ថាបត្តិ អន្តេវាសិកោ អាបជ្ជតិ នោ អាចរិយោ អត្ថាបត្តិ អាចរិយោ ចេវ អាបជ្ជតិ អន្តេវាសិកោ ច អត្ថាបត្តិ នេវ អាចរិយោ អាបជ្ជតិ នោ អន្តេវាសិកោ ។

ឯកុត្តរិកៈ ចតុក្កៈ សេចក្ដីផ្សេងគ្នាដោយវត្ថុជាដើម

(៤៣) សេចក្ដីផ្សេងគ្នាដោយវត្ថុ តែមិនផ្សេងគ្នាដោយអាបត្តិក៏មាន ផ្សេងគ្នាដោយអាបត្តិ តែមិនផ្សេងគ្នាដោយវត្ថុក៏មាន ផ្សេងគ្នាដោយវត្ថុផង ផ្សេងគ្នាដោយអាបត្តិផងក៏មាន មិនផ្សេងគ្នាដោយវត្ថុ មិនផ្សេងគ្នាដោយអាបត្តិក៏មាន ។ សភាវៈមានចំណែកស្មើគ្នាដោយវត្ថុ តែមិនមានចំណែកស្មើគ្នាដោយអាបត្តិក៏មាន មានចំណែកស្មើគ្នាដោយអាបត្តិ តែមិនមានចំណែកស្មើគ្នាដោយវត្ថុក៏មាន មានចំណែកស្មើគ្នាដោយវត្ថុ មានចំណែកស្មើគ្នាដោយអាបត្តិក៏មាន មិនមានចំណែកស្មើគ្នាដោយវត្ថុ មិនមានចំណែកស្មើគ្នាដោយអាបត្តិក៏មាន ។

(៤៤) ឧបជ្ឈាយ៍ត្រូវអាបត្តិ សទ្ធិវិហារិកមិនត្រូវអាបត្តិក៏មាន សទ្ធិវិហារិកត្រូវអាបត្តិ ឧបជ្ឈាយ៍មិនត្រូវអាបត្តិក៏មាន ទាំងឧបជ្ឈាយ៍ ទាំងសទ្ធិវិហារិកត្រូវអាបត្តិក៏មាន ទាំងឧបជ្ឈាយ៍ ទាំងសទ្ធិវិហារិក មិនត្រូវអាបត្តិក៏មាន ។ អាចារ្យត្រូវអាបត្តិ អន្តេវាសិកមិនត្រូវអាបត្តិក៏មាន អន្តេវាសិកត្រូវអាបត្តិ អាចារ្យមិនត្រូវអាបត្តិក៏មាន ទាំងអាចារ្យ ទាំងអន្តេវាសិកត្រូវអាបត្តិក៏មាន ទាំងអាចារ្យ ទាំងអន្តេវាសិកមិនត្រូវអាបត្តិក៏មាន ។

[៥៥] ចត្តារោ បច្ចយា អនាបត្តិ វស្សច្ឆេទស្ស សង្ឃោ វា ភិន្នោ ហោតិ សង្ឃំ វា ភិន្ទិតុកាមា ហោន្តិ ជីវិតន្តរាយោ វា ហោតិ ព្រហ្មចរិយន្តរាយោ វា ហោតិ ។ ចត្តារិ វចីទុច្ចរិតានិ មុសាវាទោ បិសុណាវាចា ផរុសវាចា សម្ផប្បលាបោ ។ ចត្តារិ វចីសុចរិតានិ សច្ចវាចា អបិសុណាវាចា សណ្ហាវាចា មត្តភាសា (១) ។

[៥៦] អត្ថិ អាទិយន្តោ គរុកំ អាបត្តឹ អាបជ្ជតិ បយោជេន្តោ លហុកំ អត្ថិ អាទិយន្តោ លហុកំ អាបត្តឹ អាបជ្ជតិ បយោជេន្តោ គរុកំ អត្ថិ អាទិយន្តោបិ បយោជេន្តោបិ គរុកំ អាបត្តឹ អាបជ្ជតិ អត្ថិ អាទិយន្តោបិ បយោជេន្តោបិ លហុកំ អាបត្តឹ អាបជ្ជតិ ។ អត្ថិ បុគ្គលោ អភិវាទនារហោ នោ បច្ចុដ្ឋានារហោ អត្ថិ បុគ្គលោ បច្ចុដ្ឋានារហោ នោ អភិវាទនារហោ អត្ថិ បុគ្គលោ អភិវាទនារហោ ចេវ បច្ចុដ្ឋានារហោ ច អត្ថិ បុគ្គលោ នេវ អភិវាទនារហោ នោ បច្ចុដ្ឋានារហោ ។ អត្ថិ បុគ្គលោ អាសនារហោ នោ អភិវាទនារហោ អត្ថិ បុគ្គលោ អភិវាទនារហោ នោ អាសនារហោ អត្ថិ បុគ្គលោ

១ ឱ. ម. មន្តភាសា ។

(៩៥) ហេតុនៃការដាច់វស្សាតែមិនត្រូវអាបត្តិមាន ៤ យ៉ាង គឺ សង្ឃបែកគ្នា ១ ភិក្ខុទាំងឡាយប្រាថ្នាបំលាយសង្ឃ ១ មានអន្តរាយដល់ជីវិត ១ មានអន្តរាយដល់ព្រហ្មចារ្យ ១ ។ វចីទុច្ចរិតមាន ៤ យ៉ាង គឺ មុសាវាទ ១ បិសុណាវាទ ១ ផរុសវាទ ១ សម្ផប្បលាបៈ ១ ។ វចីសុចរិតមាន ៤ យ៉ាងគឺ សច្ចវាចា (និយាយពាក្យពិត) ១ អបិសុណាវាចា (មិននិយាយពាក្យស៊កសៀត) ១ សណ្ហវាចា (និយាយពាក្យពីរោះ) ១ មត្តភាសា (និយាយពាក្យគួរដល់ប្រមាណ) ១ ។

(៩៦) ភិក្ខុកាន់យកទ្រព្យគេដោយខ្លួនឯង ត្រូវគរុកាបត្តិ ប្រើគេឲ្យកាន់យក ត្រូវលហុកាបត្តិក៏មាន កាន់យកទ្រព្យគេដោយខ្លួនឯង ត្រូវលហុកាបត្តិ ប្រើគេឲ្យកាន់យក ត្រូវគរុកាបត្តិក៏មាន កាន់យកទ្រព្យគេដោយខ្លួនឯងក្តី ប្រើគេឲ្យកាន់យកក្តី ត្រូវគរុកាបត្តិក៏មាន កាន់យកទ្រព្យគេដោយខ្លួនឯងក្តី ប្រើគេឲ្យកាន់យកក្តី ត្រូវលហុកាបត្តិក៏មាន ។ បុគ្គលគួរដល់ការអភិវាទ មិនគួរដល់ការក្រោកទទួលក៏មាន បុគ្គលគួរដល់ការក្រោកទទួល មិនគួរដល់ការអភិវាទក៏មាន បុគ្គលគួរដល់ការអភិវាទផង គួរដល់ការក្រោកទទួលផងក៏មាន បុគ្គលមិនគួរដល់ការអភិវាទ មិនគួរដល់ការក្រោកទទួលក៏មាន ។ បុគ្គលគួរដល់អាសនៈ មិនគួរដល់ការអភិវាទក៏មាន បុគ្គលគួរដល់ការអភិវាទ មិនគួរដល់អាសនៈក៏មាន បុគ្គល

អាមិសគរុកោ ចេវ សទ្ធម្មគរុកោ ច អត្ថិ បុគ្គលោ នេវ អាមិសគរុកោ នោ សទ្ធម្មគរុកោ ។

(៥៧) អត្ថាបត្តិ កាលេ អាបជ្ជតិ នោ វិកាលេ អត្ថាបត្តិ វិកាលេ អាបជ្ជតិ នោ កាលេ អត្ថាបត្តិ កាលេ ចេវ អាបជ្ជតិ វិកាលេ ច អត្ថាបត្តិ នេវ កាលេ អាបជ្ជតិ នោ វិកាលេ ។ អត្ថិ បដិគ្គហិតំ កាលេ កប្បតិ នោ វិកាលេ អត្ថិ បដិគ្គហិតំ វិកាលេ កប្បតិ នោ កាលេ អត្ថិ បដិគ្គហិតំ កាលេ ចេវ កប្បតិ វិកាលេ ច អត្ថិ បដិគ្គហិតំ នេវ កាលេ កប្បតិ នោ វិកាលេ ។ អត្ថាបត្តិ បច្ចន្តិមេសុ ជនបទេសុ អាបជ្ជតិ នោ មជ្ឈិមេសុ អត្ថាបត្តិ មជ្ឈិមេសុ ជនបទេសុ អាបជ្ជតិ នោ បច្ចន្តិមេសុ អត្ថាបត្តិ បច្ចន្តិមេសុ ចេវ ជនបទេសុ អាបជ្ជតិ មជ្ឈិមេសុ ច អត្ថាបត្តិ នេវ បច្ចន្តិមេសុ ជនបទេសុ អាបជ្ជតិ នោ មជ្ឈិមេសុ ។ អត្ថិ បច្ចន្តិមេសុ ជនបទេសុ កប្បតិ នោ មជ្ឈិមេសុ អត្ថិ មជ្ឈិមេសុ ជនបទេសុ កប្បតិ នោ បច្ចន្តិមេសុ អត្ថិ បច្ចន្តិមេសុ ចេវ ជនបទេសុ កប្បតិ មជ្ឈិមេសុ ច អត្ថិ

គួរដល់អាសនៈផង គួរដល់ការអភិវាទផងក៏មាន បុគ្គលមិនគួរដល់អាសនៈ មិនគួរដល់ការអភិវាទក៏មាន ។

(៥៧) ភិក្ខុត្រូវអាបត្តិតែក្នុងកាល មិនត្រូវក្នុងវិកាលក៏មាន ត្រូវអាបត្តិតែក្នុងវិកាល មិនត្រូវក្នុងកាលក៏មាន ត្រូវអាបត្តិទាំងក្នុងកាល ទាំងក្នុងវិកាលក៏មាន មិនត្រូវអាបត្តិទាំងក្នុងកាល ទាំងក្នុងវិកាលក៏មាន ។ វត្ថុដែលភិក្ខុទទួលប្រគេនហើយ គួរតែក្នុងកាល មិនគួរក្នុងវិកាលក៏មាន វត្ថុដែលភិក្ខុទទួលប្រគេនហើយ គួរក្នុងវិកាល មិនគួរក្នុងកាលក៏មាន វត្ថុដែលភិក្ខុទទួលប្រគេនហើយ គួរក្នុងកាលផង គួរក្នុងវិកាលផងក៏មាន វត្ថុដែលភិក្ខុទទួលប្រគេនហើយ មិនគួរក្នុងកាល មិនគួរក្នុងវិកាលក៏មាន ។ ភិក្ខុត្រូវអាបត្តិតែក្នុងបច្ចន្តិមជនបទ មិនត្រូវក្នុងមជ្ឈិមជនបទក៏មាន ត្រូវអាបត្តិតែក្នុងមជ្ឈិមជនបទ មិនត្រូវក្នុងបច្ចន្តិមជនបទក៏មាន ត្រូវអាបត្តិទាំងក្នុងបច្ចន្តិមជនបទ ទាំងក្នុងមជ្ឈិមជនបទក៏មាន មិនត្រូវអាបត្តិទាំងក្នុងបច្ចន្តិមជនបទ ទាំងក្នុងមជ្ឈិមជនបទក៏មាន ។ វត្ថុគួរតែក្នុងបច្ចន្តិមជនបទ មិនគួរក្នុងមជ្ឈិមជនបទក៏មាន គួរតែក្នុងមជ្ឈិមជនបទ មិនគួរក្នុងបច្ចន្តិមជនបទក៏មាន គួរទាំងក្នុងបច្ចន្តិមជនបទ ទាំងក្នុងមជ្ឈិមជនបទក៏មាន

នេវ បច្ចន្តិមេសុ ជនបទេសុ កប្បតិ នោ មជ្ឈិមេសុ ។ អត្ថាបត្តិ អន្តោ អាបជ្ជតិ នោ ពហិ អត្ថាបត្តិ ពហិ អាបជ្ជតិ នោ អន្តោ អត្ថាបត្តិ អន្តោ ចេវ អាបជ្ជតិ ពហិ ច អត្ថាបត្តិ នេវ អន្តោ អាបជ្ជតិ នោ ពហិ ។ អត្ថាបត្តិ អន្តោសីមាយ អាបជ្ជតិ នោ ពហិសីមាយ អត្ថាបត្តិ ពហិសីមាយ អាបជ្ជតិ នោ អន្តោសីមាយ អត្ថាបត្តិ អន្តោសីមាយ ចេវ អាបជ្ជតិ ពហិសីមាយ ច អត្ថាបត្តិ នេវ អន្តោសីមាយ អាបជ្ជតិ នោ ពហិសីមាយ ។ អត្ថាបត្តិ គាមេ អាបជ្ជតិ នោ អរញ្ញេ អត្ថាបត្តិ អរញ្ញេ អាបជ្ជតិ នោ គាមេ អត្ថាបត្តិ គាមេ ចេវ អាបជ្ជតិ អរញ្ញេ ច អត្ថាបត្តិ នេវ គាមេ អាបជ្ជតិ នោ អរញ្ញេ ។

(៩៨) ចតស្សោ ចោទនា វត្ថុសន្ទស្សនា អាបត្តិសន្ទស្សនា សំវាសប្បដិក្ខេបោ សាមីចិប្បដិក្ខេបោ ។ ចត្តារោ បុព្វកិច្ចា[១] ។ ចត្តារោ បត្តកល្លា ។ ចត្តារិ អនញ្ញបាចិត្តិយានិ ។ ចតស្សោ ភិក្ខុសម្មុតិយោ ។ ចត្តារិ អគតិគមនានិ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ

១ បុព្វករណានិ កត្ថចិ បោត្ថកេ ទិស្សតិ ។

មិនគួរទាំងក្នុងបច្ចន្តិមជនបទ មិនគួរទាំងក្នុងមជ្ឈិមជនបទក៏មាន ។ ភិក្ខុនៅខាងក្នុងត្រូវអាបត្តិ នៅខាងក្រៅមិនត្រូវអាបត្តិក៏មាន នៅខាងក្រៅត្រូវអាបត្តិ នៅខាងក្នុងមិនត្រូវអាបត្តិក៏មាន នៅខាងក្នុងក៏ត្រូវអាបត្តិ នៅខាងក្រៅក៏ត្រូវអាបត្តិក៏មាន នៅខាងក្នុងក៏មិនត្រូវអាបត្តិ នៅខាងក្រៅក៏មិនត្រូវអាបត្តិក៏មាន ។ ភិក្ខុនៅខាងក្នុងសីមាត្រូវអាបត្តិ នៅខាក្រៅសីមាមិនត្រូវអាបត្តិក៏មាន នៅខាងក្រៅសីមាត្រូវអាបត្តិ នៅខាងក្នុងសីមាមិនត្រូវអាបត្តិក៏មាន នៅខាងក្នុងសីមាក៏ត្រូវអាបត្តិ នៅខាងក្រៅសីមាក៏ត្រូវអាបត្តិក៏មាន នៅខាងក្នុងសីមាក៏មិនត្រូវអាបត្តិ នៅខាងក្រៅសីមាក៏មិនត្រូវអាបត្តិក៏មាន ។ ភិក្ខុនៅក្នុងស្រុកត្រូវអាបត្តិ នៅក្នុងព្រៃមិនត្រូវអាបត្តិក៏មាន នៅក្នុងព្រៃត្រូវអាបត្តិ នៅក្នុងស្រុកមិនត្រូវអាបត្តិក៏មាន នៅក្នុងស្រុកក៏ត្រូវអាបត្តិ នៅក្នុងព្រៃក៏ត្រូវអាបត្តិក៏មាន នៅក្នុងស្រុកក៏មិនត្រូវអាបត្តិ នៅក្នុងព្រៃក៏មិនត្រូវអាបត្តិក៏មាន ។

(៩៨) ការចោទមាន ៤ យ៉ាង គឺបង្អួលចំពោះវត្ថុ ១ បង្អួលចំពោះអាបត្តិ ១ ឃាត់សំវាស ១ ឃាត់សាមីចិកម្ម ១ ។ បុព្វកិច្ចមាន ៤ ។ កម្មមានកាលដ៏គួរមាន ៤ ។ អនញ្ញបាចិត្តិយៈមាន ៤ ។ ភិក្ខុសម្មតិមាន ៤ ។ ការលុះអគតិមាន ៤ គឺ លុះទៅខាងឆន្ទាគតិ ១ លុះទៅខាងទោសាគតិ ១

ឯកុត្តរិកំ ចតុក្កំ ចតុនាគតិគមនាទីនិ

មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ។ ចត្តារិ នាគ
តិគមនានិ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន
មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ។ ចតូហង្គេហិ
សមន្នាគតោ អលជ្ជី ភិក្ខុ សង្ឃំ ភិន្ទតិ ឆន្ទាគតឹ
គច្ឆន្តោ ទោសាគតឹ គច្ឆន្តោ មោហាគតឹ គច្ឆន្តោ
ភយាគតឹ គច្ឆន្តោ ។ ចតូហង្គេហិ សមន្នាគតោ បេ-
សលោ ភិក្ខុ ភិន្នំ សង្ឃំ សមគ្គំ ករោតិ ន ឆន្ទាគតឹ
គច្ឆន្តោ ន ទោសាគតឹ គច្ឆន្តោ ន មោហាគតឹ គច្ឆ-
ន្តោ ន ភយាគតឹ គច្ឆន្តោ ។ ចតូហង្គេហិ សមន្នា-
គតស្ស ភិក្ខុនោ វិនយោ ន បុច្ឆិតព្វោ ឆន្ទាគតឹ
គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយា-
គតឹ គច្ឆតិ ។ ចតូហង្គេហិ សមន្នាគតេន ភិក្ខុនា
វិនយោ ន បុច្ឆិតព្វោ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ
មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ។ ចតូហង្គេហិ
សមន្នាគតស្ស ភិក្ខុនោ វិនយោ ន វិស្សជ្ជេតព្វោ
ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ

លុះទៅតាមមោហាគតិ ១ លុះទៅតាមភយាគតិ ១ ។ ការមិនលុះអគតិមាន ៤ គឺ មិនលុះទៅតាមឆន្ទាគតិ ១ មិនលុះទៅតាមទោសាគតិ ១ មិនលុះទៅតាមមោហាគតិ ១ មិនលុះទៅតាមភយាគតិ ១ ។ អលជ្ជីភិក្ខុដែលប្រកបដោយអង្គ ៤ គឺ លុះទៅតាមឆន្ទាគតិ ១ លុះទៅតាមទោសាគតិ ១ លុះទៅតាមមោហាគតិ ១ លុះទៅតាមភយាគតិ ១ រមែងទំលាយនូវសង្ឃ ។ ភិក្ខុមានសីលជាទីស្រឡាញ់ប្រកបដោយអង្គ ៤ គឺ មិនលុះទៅតាមឆន្ទាគតិ ១ មិនលុះទៅតាមទោសាគតិ ១ មិនលុះទៅតាមមោហាគតិ១ មិនលុះទៅតាមភយាគតិ ១ រមែងធ្វើសង្ឃដែលបែកគ្នាហើយ ឲ្យព្រមព្រៀងគ្នាវិញ ។ ភិក្ខុមិនគួរសួរវិន័យចំពោះភិក្ខុដែលប្រកបដោយអង្គ ៤ គឺ ភិក្ខុលុះទៅតាមឆន្ទាគតិ ១ លុះទៅតាមទោសាគតិ ១ លុះទៅតាមមោហាគតិ ១ លុះទៅតាមភយាគតិ ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៤ គឺ ភិក្ខុលុះទៅតាមឆន្ទាគតិ ១ លុះទៅតាមទោសាគតិ ១ លុះទៅតាមមោហាគតិ ១ លុះទៅតាមភយាគតិ ១ ក៏មិនគួរសួរវិន័យឡើយ ។ ភិក្ខុមិនគួរដោះស្រាយវិន័យចំពោះភិក្ខុដែលប្រកបដោយអង្គ ៤ គឺ ភិក្ខុលុះទៅតាមឆន្ទាគតិ ១ លុះទៅតាមទោសាគតិ ១ លុះទៅតាមមោហាគតិ ១ លុះទៅតាម

ភយាគតឹ គច្ឆតិ ។ ចតូហង្គេហិ សមន្នាគតេន ភិក្ខុនា វិនយោ ន វិស្សជ្ជេតព្វោ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ។ ចតូហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អនុយោគោ ន ទាតព្វោ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ។ ចតូហង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ វិនយោ ន សាកច្ឆិតព្វោ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ។

(៥៩) អត្ថាបត្តិ គិលានោ អាបជ្ជតិ នោ អគិលានោ អត្ថាបត្តិ អគិលានោ អាបជ្ជតិ នោ គិលានោ អត្ថាបត្តិ គិលានោ ចេវ អាបជ្ជតិ អគិលានោ ច អត្ថាបត្តិ នេវ គិលានោ អាបជ្ជតិ នោ អគិលានោ ។

(៦០) ចត្តារិ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ ចត្តារិ ធម្មិកានិ បាតិមោក្ខដ្ឋបនានីតិ ។

ចតុក្កំ និដ្ឋិតំ ។

ភយាគតិ ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៤ គឺ ភិក្ខុលុះទៅខាងឆន្ទាគតិ ១ លុះទៅខាងទោសាគតិ ១ លុះទៅខាងមោហាគតិ ១ លុះទៅខាងភយាគតិ ១ ក៏មិនត្រូវដោះស្រាយវិន័យ ។ ភិក្ខុមិនត្រូវឲ្យការសាកសួរ ចំពោះភិក្ខុដែលប្រកបដោយអង្គ ៤ គឺ ភិក្ខុលុះទៅខាងឆន្ទាគតិ ១ លុះទៅខាងទោសាគតិ ១ លុះទៅខាងមោហាគតិ ១ លុះទៅខាងភយាគតិ ១ ។ ភិក្ខុមិនត្រូវសាកច្ឆាវិន័យជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ ៤ គឺ ភិក្ខុលុះទៅខាងឆន្ទាគតិ ១ លុះទៅខាងទោសាគតិ ១ លុះទៅខាងមោហាគតិ ១ លុះទៅខាងភយាគតិ ១ ។

(៥៩) ភិក្ខុឈឺត្រូវអាបត្តិ មិនឈឺមិនត្រូវអាបត្តិក៏មាន មិនឈឺត្រូវអាបត្តិ ឈឺមិនត្រូវអាបត្តិក៏មាន ឈឺត្រូវអាបត្តិ មិនឈឺក៏ត្រូវអាបត្តិក៏មាន ឈឺមិនត្រូវអាបត្តិ មិនឈឺមិនត្រូវអាបត្តិក៏មាន ។

(៦០) ការបញ្ឈប់នូវបាតិមោក្ខមិនប្រកបដោយធម៌មាន ៤ យ៉ាង ។ ការបញ្ឈប់នូវបាតិមោក្ខប្រកបដោយធម៌ មាន ៤ យ៉ាង ។

ចប់ ចតុក្កៈ (ពួកបួន) ។

ឯកុត្តរិកំ ចតុក្កំ ឧទ្ទានគាថា

តស្សុទ្ទានំ

[៦១] សកវាចាយ កាយេន
បសុត្តោ ច អចិត្តកោ
អាបជ្ជន្តោ ច កម្មេន
វោហារា ចតុរោ តថា
ភិក្ខូនំ ភិក្ខុនីនញ្ច
បរិក្ខារោ ច សម្មុខា
អជានកាយេ មជ្ឈេ ច
វុដ្ឋាតិ ទុវិធោ[១] តថា
បដិលាភា[២] ច ទោសតា
បរិវាសា ច វុច្ចតិ
មានត្តចារិកា ចាបិ
សមុក្កំសា បដិគ្គហា[៣]
មហាវិកដកម្មានិ
បុន កម្មវិបត្តិយោ
អធិករណោ ទុស្សីលា ច

---

១ ឱ. ម. ទុរិតា ។ ២ ឱ. ម. បដិលាភេន ។ ៣ ឱ. ម. បដិគ្គហំ ។

ឯកុត្តរិកៈ ចតុក្កៈ ឧទ្ទានគាថា

ឧទ្ទាន គឺបញ្ជីរឿងនៃចតុក្កៈ (ពួកបួន ៗ) នោះដូច្នេះ

(៦១) ភិក្ខុត្រូវអាបត្តិដោយវាចារបស់ខ្លួន ១ ដោយកាយ ១ ដេកលក់ត្រូវអាបត្តិ ១ មិនមានចិត្តក៏ត្រូវអាបត្តិ ១ ត្រូវអាបត្តិកំពុងសំដែងអាបត្តិ ១ ត្រូវអាបត្តិដោយកម្ម ១ អនរិយវោហារមាន ៤ យ៉ាង ១ អរិយវោហារមាន ៤ យ៉ាង ដូចគ្នា ១ បារាជិក ៤ របស់ភិក្ខុ ទូទៅទាំងពួកភិក្ខុ ទាំងពួកភិក្ខុនី ១ ភិក្ខុគួររក្សាបរិក្ខារទុក ១ នៅក្នុងទីចំពោះមុខត្រូវអាបត្តិ ១ ភិក្ខុមិនដឹងត្រូវអាបត្តិ ១ ត្រូវអាបត្តិដោយកាយ ១ ត្រូវអាបត្តិក្នុងកណ្ដាលជំនុំសង្ឃ ១ ចេញចាកអាបត្តិដោយអាការ ៤ យ៉ាង មាន ២ លើក ១ លះបង់បុរិមភេទព្រមទាំងការបានភេទថ្មី ១ ការភេទ ១ បរិវាស ១ ភិក្ខុប្រព្រឹត្តមានត្ត ១ គ្រឿងអាង ១ គ្រឿងបរិភោគដែលភិក្ខុទទួលប្រគេន ១ ថ្នាំមហាវិកដ ១ កម្ម ៤ យ៉ាងដទៃទៀត ១ វិបត្តិ ១ អធិករណ៍ ១ បុគ្គលអ្នកញុំាង

សោតឃានាគន្ធេកេន ច
គមិកោ វុត្តនាជត្តា
សកាគុបជ្ឈយេន(១) ច
អាចរិយោ បច្ចយោ វា
ទុច្ចរិតំ សុចារិតំ(២)
អាទិយន្តោ បុគ្គលោ ច
អរហា អាសនេន ច
កាលេ ច កប្បតិ ចេវ
បច្ចន្តិមេសុ(៣) កប្បតិ
អន្តោ អន្តោ ច សីមាយ
គាមេ ច ភោជនាយ ច
បុព្វកិច្ចំ បត្តកល្លំ
អនញ្ញកា ច សម្មុតិ(៤)
អគតិ នាគតិ ចេវ
អលជ្ជិ បេសលេន ច

---

១ ឱ. ម. សភាគុបជ្ឈាយេន ។ ២ ឱ. សុចរិតំ ។ ៣ ឱ. ម. បច្ចន្តិមេ ច ។
៤ ឱ. ម. អនញ្ញា សម្មុតិយា ច ។

វិនយបិដក បរិវារៈ

បរិសទ្យឲ្យរាក្រក់ ១ ភិក្ខុញុំាងបរិសទ្យឲ្យល្អ ១ អាគន្តុកភិក្ខុត្រូវអាបត្តិ ១ គមិកភិក្ខុត្រូវអាបត្តិ ១ សភាវៈផ្សេងគ្នាដោយវត្ថុ ១ សភាវៈស្មើគ្នាដោយវត្ថុ ១ ឧបជ្ឈាយ៍ត្រូវអាបត្តិ ១ អាចារ្យត្រូវអាបត្តិ ១ ហេតុនៃការដាច់វស្សាតែមិនត្រូវអាបត្តិ ១ ទុច្ចរិត ១ សុចរិត ១ ភិក្ខុកាន់យកទ្រព្យគេត្រូវអាបត្តិ ១ បុគ្គលគួរដល់ការអភិវាទ ១ បុគ្គលគួរដល់អាសនៈ ១ វត្ថុដែលភិក្ខុទទួលប្រគេនគួរក្នុងកាល ១ ភិក្ខុត្រូវអាបត្តិតែក្នុងបច្ចន្តិមជនបទ ១ វត្ថុដែលគួរតែក្នុងបច្ចន្តិមជនបទ ១ ត្រូវអាបត្តិតែក្នុងខាងក្នុង ១ ត្រូវអាបត្តិតែក្នុងសីមា ១ ត្រូវអាបត្តិតែក្នុងស្រុក ១ ការចោទ ១ បុព្វកិច្ច ១ កម្មមានកាលដ៏គួរ ១ អនញ្ញាបាចិត្តិយៈ ១ សម្មតិ ១ អគតិ ១ មិនគួរដល់នូវអគតិ ១ អលជ្ជីភិក្ខុ ១ ភិក្ខុមានសីលជាទីស្រឡាញ់ ១

ឯកុត្តរិកំ បញ្ចកំ បញ្ចបញ្ចទយោ

បុច្ឆិតញ្ច ទុវេ ចេវ
វិស្សជ្ជេយ្យ តថា ទុវេ
អនុយោគោ ច សាកច្ឆា
គិលានោ ឋបនេន ចាតិ ។

(៦២) បញ្ច អាបត្តិយោ ។ បញ្ច អាបត្តិក្ខន្ធា ។ បញ្ច វិនីតវត្ថូនិ ។ បញ្ច កម្មានិ អនន្តរិកានិ ។ បញ្ច បុគ្គលា និយតា ។ បញ្ច ឆេទនកា អាបត្តិយោ ។ បញ្ចហាការេហិ អាបត្តឹ អាបជ្ជតិ ។ បញ្ចាបត្តិយោ មុសាវាទបច្ចយា ។ បញ្ចហាការេហិ កម្មំ ន ឧបេតិ សយំ វា កម្មំ ន ករោតិ បរំ វា នាជ្ឈេសតិ ឆន្ទំ វា បារិសុទ្ធឹ វា ន ទេតិ កាយិរមាចេ កម្មេ បដិក្កោសតិ កតេ វា បន កម្មេ អធម្មទិដ្ឋិ ហោតិ ។ បញ្ចហាការេហិ កម្មំ ឧបេតិ សយំ វា កម្មំ ករោតិ បរំ វា អជ្ឈេសតិ ឆន្ទំ វា បារិសុទ្ធឹ វា ទេតិ កាយិរមាចេ កម្មេ នប្បដិក្កោសតិ កតេ វា បន កម្មេ ធម្មទិដ្ឋិ ហោតិ ។ បញ្ច

ឯកុត្តរិកៈ បញ្ចកៈ អាបត្តិមាន ៥ យ៉ាងជាដើម

ភិក្ខុមិនគួរសួរវិន័យចំពោះភិក្ខុ ២ ពួក ១ មិនគួរដោះស្រាយវិន័យចំពោះភិក្ខុ ២ ពួកដូចគ្នា ១ ភិក្ខុមិនត្រូវឲ្យការសាកសួរ ១ មិនត្រូវសាកច្ឆា ១ ភិក្ខុឈឺត្រូវអាបត្តិ ១ ការបញ្ឈប់បាតិមោក្ខ ១ ។

[៦២] អាបត្តិមាន ៥ យ៉ាង ។ កងនៃអាបត្តិមាន ៥ យ៉ាង ។ វិនីតវត្ថុ (វត្ថុដែលព្រះមានព្រះភាគបានជម្រះហើយ) មាន ៥ យ៉ាង ។ អនន្តរិកកម្ម (កម្មដែលឲ្យផលក្នុងអត្តភាពជាបន្ទាប់) មាន ៥ យ៉ាង ។ និយតបុគ្គល (បុគ្គលដែលទៀង) មាន ៥ពួក ។ ឆេទនកាបត្តិ (អាបត្តិដែលមានការកាត់ជាវិន័យកម្ម) មាន ៥យ៉ាង ។ ភិក្ខុត្រូវអាបត្តិដោយអាការ ៥យ៉ាង ។ អាបត្តិ ៥ យ៉ាង មានមុសាវាទជាបច្ច័យ ។ ភិក្ខុមិនគួរដល់សង្ឃកម្មដោយអាការ ៥ យ៉ាង គឺមិនធ្វើកម្មដោយខ្លួនឯង១ មិនអារាធនាភិក្ខុឯទៀត ១ មិនឲ្យឆន្ទៈ ១ មិនឲ្យបារិសុទ្ធិ ១ ហាមឃាត់កម្មដែលសង្ឃកំពុងធ្វើ ឬមានសេចក្តីយល់ឃើញថាមិនត្រូវតាមធម៌ក្នុងកម្មដែលសង្ឃបានធ្វើរួចហើយ ១ ។ ភិក្ខុគួរដល់កម្មដោយអាការ ៥ យ៉ាង គឺភិក្ខុធ្វើកម្មដោយខ្លួនឯង ១ អារាធនាភិក្ខុឯទៀត ១ ឲ្យឆន្ទៈ ១ ឲ្យបារិសុទ្ធិ ១ មិនហាមឃាត់កម្មដែលសង្ឃកំពុងធ្វើ ឬមានសេចក្តីយល់ឃើញថាត្រូវតាមធម៌ក្នុងកម្មដែលសង្ឃបានធ្វើរួចហើយ ១ ។ ធម៌ ៥ យ៉ាងតែងសម្រេច

បិណ្ឌបាតិកស្ស ភិក្ខុនោ កប្បតិ អនាមន្តចារោ គណភោជនំ បរម្បរភោជនំ អនធិដ្ឋានំ អវិកប្បនា ។ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧស្សង្កិតបរិសង្កិតោ(១) ហោតិ បាបភិក្ខុបិ អកុប្បធម្មោបិ វេសិយាគោចរោ វា ហោតិ វិធវាគោចរោ វា ហោតិ ថុល្លកុមារីគោចរោ វា ហោតិ បណ្ឌកគោចរោ វា ហោតិ ភិក្ខុនីគោចរោ វា ហោតិ ។ បញ្ច តេលានិ តិលតេលំ សាសបតេលំ មធុកតេលំ ឯរណ្ឌកតេលំ វសាតេលំ ។ បញ្ច វសានិ អច្ឆវសំ មច្ឆវសំ សុសុកាវសំ សូករវសំ គទ្រភវសំ ។ បញ្ច ព្យសនានិ ញាតិព្យសនំ ភោគព្យសនំ រោគព្យសនំ សីលព្យសនំ ទិដ្ឋិព្យសនំ ។ បញ្ច សម្បទា ញាតិសម្បទា ភោគសម្បទា អរោគសម្បទា សីលសម្បទា ទិដ្ឋិសម្បទា ។ បញ្ច និស្សយប្បដិប្បស្សទ្ធិយោ ឧបជ្ឈាយម្ហា ឧបជ្ឈាយោ បក្កន្តោ វា ហោតិ វិព្ភន្តោ វា កាលកតោ វា បក្ខសង្កន្តោ វា អាណត្តិយេវ បញ្ចមី ។ បញ្ច បុគ្គលា ន ឧបសម្បាទេតព្វា អទ្ធានហី-

១ សង្កិតបរិសង្កិតោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ដល់ភិក្ខុជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ គឺត្រាច់ទៅក្នុងត្រកូលដោយមិនបាច់លាភិក្ខុផងគ្នា ១ ឆាន់គណភោជនបាន ១ ឆាន់បរម្បរភោជនបាន ១ មិនអធិដ្ឋានចីវរក៏បាន ១ មិនវិកប្បចីវរក៏បាន ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៥ ទុកជាភិក្ខុបាប ឬជាភិក្ខុមានធម៌មិនបានកម្រើក ក៏គួរឲ្យគេរង្កៀសសង្ស័យបាន គឺការត្រាច់ទៅក្នុងលំនៅស្រីផ្កាមាស ១ ការត្រាច់ទៅក្នុងលំនៅស្រីមេម៉ាយ ១ ការត្រាច់ទៅក្នុងលំនៅស្រីក្រមុំចាស់ ១ ការត្រាច់ទៅក្នុងលំនៅមនុស្សខ្ទើយ ១ ការត្រាច់ទៅក្នុងលំនៅភិក្ខុនី ១ ។ ប្រេងមាន ៥ យ៉ាង គឺប្រេងល្ង ១ ប្រេងស្ពៃ ១ ប្រេងស្រគំ ១ ប្រេងល្ហុងខ្វៃ ១ ប្រេងខ្លាញ់ ១ ។ ខ្លាញ់មាន ៥ យ៉ាងគឺ ខ្លាញ់ខ្លាឃ្មុំ ១ ខ្លាញ់ត្រី ១ ខ្លាញ់ឆ្លាម ១ ខ្លាញ់ជ្រូក ១ ខ្លាញ់លា ១ ។ សេចក្ដីវិនាសមាន ៥ យ៉ាង គឺវិនាសញាតិ ១ វិនាសភោគៈ ១ វិនាសព្រោះរោគ ១ វិនាសសីល ១ វិនាសព្រោះទិដ្ឋិ ១ ។ សេចក្ដីបរិបូណ៌មាន ៥ យ៉ាង គឺ បរិបូណ៌ដោយញាតិ ១ បរិបូណ៌ដោយភោគៈ ១ បរិបូណ៌ដោយសេចក្ដីមិនមានរោគ ១ បរិបូណ៌ដោយសីល ១ បរិបូណ៌ដោយទិដ្ឋិ ១ ។ ការរម្ងាប់និស្ស័យចាកឧបជ្ឈាយ៍មាន ៥ យ៉ាង គឺឧបជ្ឈាយ៍ចៀសចេញទៅ ១ សឹកចេញទៅ ១ ស្លាប់ទៅ ១ ទៅចូលពួក (តិរ្ថិយ) ១ ឧបជ្ឈាយ៍បណ្ដេញចាកនិស្ស័យ ១ ជាគំរប់ ៥ ។ បុគ្គលដែលមិនគួរឲ្យឧបសម្បទា មាន ៥ ពួកគឺបុគ្គលខ្វះខាត

នោ អត្ថីហីនោ វត្ថុវិបន្នោ ការណាទុក្កដកោ អបរិបុ-
រោ ។ បញ្ច បំសុកូលានិ សោសានិកំ អាបណិកំ[១]
ឧន្ទុរក្ខាយិតំ ឧបចិកក្ខាយិតំ[២] អគ្គិឌឌ្ឍំ ។ អប-
រានិបិ បញ្ច បំសុកូលានិ គោខាយិតំ អជក្ខាយិតំ[៣]
ថូបចីវរំ អភិសេកិកំ គតប្បដិយាគតំ ។ បញ្ច អវ-
ហារា ថេយ្យាវហារោ បសយ្ហាវហារោ បរិកប្បាវហារោ
បដិច្ឆន្នាវហារោ កុសាវហារោ ។ បញ្ច មហាចោរា
សន្តោ សំវិជ្ជមានា លោកស្មឹ ។ បញ្ច អវិស្សជ្ជ-
នីយានិ ។ បញ្ច អវេភង្គិយានិ ។ បញ្ចាបត្តិយោ កា-
យតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ ។ បញ្ចា-
បត្តិយោ កាយតោ ច វាចតោ ច សមុដ្ឋហន្តិ
ន ចិត្តតោ ។ បញ្ចាបត្តិយោ ទេសនាគាមិនិ-
យោ ។ បញ្ច សង្ឃា ។ បញ្ច បាតិមោក្ខុទ្ទេសា ។

---

១ ឱ. ម. ឋាបណិកំ ។ ២ ម. ឧន្ទុរក្ខាយិកំ ឧបចិកក្ខាយិកំ ។ ៣ ម. គោខាយិកំ
អជក្ខាយិកំ ។

កាល (មានឆ្នាំមិនគ្រប់ម្ភៃ) ១ បុគ្គលខូចខាតអវយវៈ (បានដាច់ដៃជាដើម) ១ បុគ្គលជាវិត្តិវិបត្តិ (មានខ្វាក់ជាដើម) ១ បុគ្គលធ្វើអពើរោគក្រក់បានដល់អកតញ្ញុបុគ្គល ៨យ៉ាង (មានថេយ្យសំវាសជាដើម) ១ បុគ្គលមានបាត្រនឹងចីវរមិនគ្រប់ ១ ។ សំពត់បំសុកូលមាន ៥ យ៉ាង គឺសំពត់ដែលធ្លាក់ចុះក្នុងព្រៃស្មសាន ១ សំពត់ដែលធ្លាក់ចុះទៀបពនផ្សារ ១ សំពត់ដែលកណ្ដុរកាត់ ១ សំពត់ដែលកណ្ដៀរកោរ ១ សំពត់ដែលភ្លើងឆេះ ១ ។ សំពត់បំសុកូលមាន៥ យ៉ាងដទៃទៀត គឺសំពត់ដែលគោទំពាស៊ី ១ សំ-ពត់ដែលពពែទំពាស៊ី ១ សំពត់ដែលគេរុំដំបូកធ្វើពលិកម្ម ១ សំពត់ដែលគេបោលគ្រវែងកន្លែងអភិសេកស្ដេច ១ សំពត់ដែលគេទៅកាន់ព្រៃស្មសានលុះត្រឡប់មកវិញហើយគេផ្លាស់បោល ១ ។ ការលួចមាន ៥ យ៉ាង គឺលួចដោយបញ្ឆោត ១ លួចដោយគំហែង ១ លួចដោយកំណត់ទ្រព្យនឹងទីកន្លែង ១ លួចដោយបំបិទបំបាំង ១ លួចដោយផ្លាស់ប្ដូរស្លាក ១ ។ មហា-ចោរ ៥ ពួក រមែងមាននៅក្នុងលោក ។ វត្ថុដែលភិក្ខុមិនគួរលះបង់មាន ៥ ពួក ។ វត្ថុដែលភិក្ខុមិនគួរចែកមាន ៥ ពួក ។ អាបត្តិ ៥ យ៉ាងតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចានឹងចិត្ត ។ អាបត្តិ ៥ យ៉ាងតាំងឡើងអំពីកាយនឹងវាចា មិនបានតាំងឡើងអំពីចិត្ត ។ អាបត្តិ ៥ កងជាទេសនាគាមិនី ។ សង្ឃមាន ៥ ពួក ។ បាតិមោក្ខុទ្ទេសមាន ៥ យ៉ាង ។

សព្វបច្ចន្តិមេសុ ជនបទេសុ វិនយធរបញ្ចមេន គណេន ឧបសម្បាទេតព្វំ ។ បញ្ចានិសំសា កឋិនត្ថារេ ។ បញ្ច កម្មានិ ។ យាវតតិយកេ បញ្ច អាបត្តិយោ ។ បញ្ចហាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ បារាជិកស្ស ។ បញ្ចហាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ ថុល្លច្ចយស្ស ។ បញ្ចហាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ ទុក្កដស្ស ។ បញ្ច អកប្បិយានិ ន បរិភុញ្ជិតព្វានិ អទិន្នញ្ច ហោតិ អវិទិតញ្ច ហោតិ អកប្បិយញ្ច ហោតិ អប្បដិគ្គហិតញ្ច ហោតិ អកតាតិរិត្តញ្ច ហោតិ ។ បញ្ច កប្បិយានិ បរិភុញ្ជិតព្វានិ ទិន្នញ្ច ហោតិ វិទិតញ្ច ហោតិ កប្បិយញ្ច ហោតិ បដិគ្គហិតញ្ច ហោតិ កតាតិរិត្តញ្ច ហោតិ ។ បញ្ច ទានានិ អបុញ្ញានិ បុញ្ញសម្មតានិ លោកស្ស[១] មជ្ជទានំ សមជ្ជទានំ ឥត្ថីទានំ ឧសភទានំ ចិត្តកម្មទានំ ។ បញ្ច ឧប្បន្នា ទុប្បដិវិនោទិយា ឧប្បន្នោ រាគោ ទុប្បដិវិនោទិយោ ឧប្បន្នោ

១ ម. លោកស្មឹ ។

គណៈសង្ឃមានវិនយធរជាគំរប់ ៥ គួរឲ្យឧបសម្បទាក្នុងបច្ចន្តិមជនបទទាំងពួង ៗ អានិសង្សក្នុងការក្រាលកឋិនមាន ៥ យ៉ាង ៗ កម្មមាន ៥ យ៉ាង ៗ អាបត្តិ ៥ យ៉ាងត្រូវក្នុងខណៈ ដែលសង្ឃសូត្រសមនុភាសនកម្មជាគំរប់ ៣ ដងចប់ ៗ ភិក្ខុកាន់យកទ្រព្យដែលគេមិនបានឲ្យដោយអាការ ៥ យ៉ាង ត្រូវអាបត្តិបារាជិក ៗ ភិក្ខុកាន់យកទ្រព្យដែលគេមិនបានឲ្យដោយអាការ ៥ យ៉ាងត្រូវអាបត្តិថុល្លច្ច័យ ៗ ភិក្ខុកាន់យកទ្រព្យដែលគេមិនបានឲ្យដោយអាការ ៥ យ៉ាងត្រូវអាបត្តិទុក្កដ ៗ របស់ដែលជាអកប្បិយៈមាន ៥ យ៉ាងភិក្ខុមិនគួរឆាន់ គឺរបស់ដែលគេមិនបានឲ្យ ១ របស់ដែលភិក្ខុមិនស្គាល់ជាក់លាក់ ១ របស់ដែលមិនគួរ ១ របស់ដែលមិនបានទទួលប្រគេន ១ របស់ដែលភិក្ខុមិនបានធ្វើវិនយកម្ម ១ ៗ របស់ដែលជាកប្បិយៈមាន ៥ យ៉ាង ភិក្ខុគួរឆាន់ គឺរបស់ដែលគេបានឲ្យ ១ របស់ដែលភិក្ខុស្គាល់ជាក់លាក់ ១ របស់ដែលគួរ ១ របស់ដែលបានទទួលប្រគេន ១ របស់ដែលភិក្ខុបានធ្វើវិនយកម្ម ១ ៗ ទាន ៥ យ៉ាងមិនមែនជាបុណ្យទេ តែសត្វលោកសន្មតថាជាបុណ្យ គឺឲ្យទឹកស្រវឹង ១ ឲ្យមហោស្រព ១ ឲ្យស្រី (ដល់បុរស) ១ ឲ្យគោឈ្មោល (ដល់គោញី) ១ ឲ្យរូបគំនូរ (ដែលប្រកបដោយមេថុន) ១ ៗ សភាវៈ ៥ យ៉ាងដែលកើតឡើងហើយ មិនងាយនឹងបន្ទោបង់បេញបាន គឺ រាគៈកើតឡើងហើយ មិនងាយនឹងបន្ទោបង់បេញបាន ១

ទោសោ ឧប្បដិវិនោទិយោ ឧប្បន្នោ មោហោ ឧប្បដិវិនោទិយោ ឧប្បន្នំ បដិភាណំ ឧប្បដិវិនោទិយំ ឧប្បន្នំ គមិយចិត្តំ ឧប្បដិវិនោទិយំ ។ បញ្ចានិសំសា សម្មជ្ជនិយា សកចិត្តំ បសីទតិ បរចិត្តំ បសីទតិ ទេវតា អត្តមនា ហោន្តិ បាសាទិកសំវត្តនិយំ កម្មំ ឧបចិនតិ[១] កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ អបរេបិ បញ្ចានិសំសា សម្មជ្ជនិយា សកចិត្តំ បសីទតិ បរចិត្តំ បសីទតិ ទេវតា អត្តមនា ហោន្តិ សត្ថុសាសនំ កតំ ហោតិ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ ។

(៦៣) បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ ពាលោតេ្វវ សង្ខំ គច្ឆតិ អត្តនោ ភាសបរិយន្តំ ន ឧគ្គណ្ហាតិ បរស្ស ភាសបរិយន្តំ ន ឧគ្គណ្ហាតិ អត្តនោ ភាសបរិយន្តំ អនុគ្គហេត្វា បរស្ស ភាសបរិយន្តំ អនុគ្គហេត្វា អធម្មេន ការេតិ អប្បដិញ្ញាយ ។ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោតេ្វវ សង្ខំ

---

១ កម្មំ ឧបចិនន្តិ កត្ថចិ បាឋកេ ទិស្សតិ ។

ទោសៈកើតឡើងហើយ មិនងាយនឹងបន្ទោបង់ចេញបាន ១ មោហៈកើតឡើងហើយ មិនងាយនឹងបន្ទោបង់ចេញបាន១ បដិភាណ(សេចក្តីឈ្លាស) កើតឡើងហើយ មិនងាយនឹងបន្ទោបង់ចេញបាន ១ ចិត្តរបស់បុគ្គលដែលប្រាថ្នានឹងដើរចេញទៅកើតឡើងហើយ មិនងាយនឹងបន្ទោបង់ចេញបាន១ ។ អានិសង្សការបោសមាន ៥ យ៉ាង គឺចិត្តរបស់ខ្លួនក៏ជ្រះថ្លា ១ ចិត្តរបស់អ្នកដទៃក៏ជ្រះថ្លា ១ ពួកទេវតាតែងពេញចិត្ត ១ អ្នកបោសរមែងសន្សំនូវការដែលប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លា ១ លុះដល់បែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ ក៏រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ១ ។ អានិសង្សការបោសមាន៥ យ៉ាងដទៃទៀត គឺចិត្តរបស់ខ្លួនជ្រះថ្លា ១ ចិត្តរបស់អ្នកដទៃក៏ជ្រះថ្លា ១ ពួកទេវតាតែងពេញចិត្ត១ ឈ្មោះថាធ្វើតាមសាសនារបស់ព្រះសាស្តា ១ ប្រជុំជនជាខាងក្រោយនឹងយកគតម្រាប់តាម ១ ។

(៦៣) វិន័យធរដែលប្រកបដោយអង្គ ៥ ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនរៀនទីកំណត់ភាសារបស់ខ្លួន ១ មិនរៀនទីកំណត់ភាសារបស់ជាតិដទៃ ១ លុះមិនរៀនទីកំណត់ភាសារបស់ខ្លួនហើយក៏កាត់សេចក្តីដោយមិនត្រូវតាមធម៌ ១ លុះមិនរៀនទីកំណត់ភាសារបស់ជាតិដទៃហើយ ក៏កាត់សេចក្តីដោយមិនត្រូវតាមធម៌ ១ កាត់សេចក្តីមិនត្រូវតាមពាក្យប្តេជ្ញា ១ ។ វិន័យធរដែលប្រកបដោយអង្គ ៥ ដល់នូវការរាប់ថា

គច្ឆតិ អត្ថោ កាសបរិយន្តំ ឧក្កណ្ឋតិ បរស្ស កាស-
បរិយន្តំ ឧក្កណ្ឋតិ អត្ថោ កាសបរិយន្តំ ឧក្កហេត្វា
បរស្ស កាសបរិយន្តំ ឧក្កហេត្វា ធម្មេន ការេតិ ប-
ដិញ្ញាយ ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតោ វិន-
យធរោ ពាលោត្វេវ សង្ខំ គច្ឆតិ អាបត្តឹ ន ជានាតិ
អាបត្តិយា មូលំ ន ជានាតិ អាបត្តិសមុទយំ ន
ជានាតិ អាបត្តិនិរោធំ ន ជានាតិ អាបត្តិនិរោធគាមិនឹ
បដិបទំ ន ជានាតិ ។ បញ្ចហង្គេហិ សមន្នាគតោ
វិនយធរោ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ អាបត្តឹ ជានាតិ
អាបត្តិយា មូលំ ជានាតិ អាបត្តិសមុទយំ ជានាតិ
អាបត្តិនិរោធំ ជានាតិ អាបត្តិនិរោធគាមិនឹ បដិបទំ
ជានាតិ ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតោ
វិនយធរោ ពាលោត្វេវ សង្ខំ គច្ឆតិ អធិករណំ ន
ជានាតិ អធិករណស្ស មូលំ ន ជានាតិ អធិករណ-
សមុទយំ ន ជានាតិ អធិករណនិរោធំ ន ជានាតិ
អធិករណនិរោធគាមិនឹ បដិបទំ ន ជានាតិ ។ បញ្ច-
ហង្គេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោត្វេវ សង្ខំ

ជាបណ្ឌិត គឺរៀនទីកំណត់កាសារបស់ខ្លួន ១ រៀនទីកំណត់កាសារបស់ជាតិដទៃ ១ លុះរៀនទីកំណត់កាសារបស់ខ្លួនហើយ ទើបកាត់សេចក្តីដោយត្រូវតាមធម៌ ១ លុះរៀនទីកំណត់កាសារបស់ជាតិដទៃហើយ ទើបកាត់សេចក្តីដោយត្រូវតាមធម៌ ១ កាត់សេចក្តីត្រូវតាមពាក្យប្តូជា ១ ៗ វិនយធរប្រកបដោយអង្គ ៥ ដទៃទៀត ដល់នៅការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អាបត្តិ ១ មិនស្គាល់មូលរបស់អាបត្តិ ១ មិនស្គាល់ហេតុដែលកើតអាបត្តិ ១ មិនស្គាល់សេចក្តីរលត់អាបត្តិ ១ មិនស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់អាបត្តិ ១ ៗ វិនយធរដែលប្រកបដោយអង្គ ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់អាបត្តិ ១ ស្គាល់មូលរបស់អាបត្តិ ១ ស្គាល់ហេតុដែលកើតអាបត្តិ ១ ស្គាល់សេចក្តីរលត់អាបត្តិ ១ ស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់អាបត្តិ ១ ៗ វិន័យធរប្រកបដោយអង្គ ៥ ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អធិករណ៍ ១ មិនស្គាល់មូលរបស់អធិករណ៍ ១ មិនស្គាល់ហេតុដែលកើតអធិករណ៍ ១ មិនស្គាល់សេចក្តីរលត់អធិករណ៍ ១ មិនស្គាល់បដិបទា ឲ្យដល់ទៅសេចក្តីរលត់អធិករណ៍ ១ ៗ វិន័យធរប្រកបដោយអង្គ ៥ ដល់នូវការរាប់ថាជាបណ្ឌិត

ឯកត្តរិកំ បញ្ចកំ វិនយធរស្ស បញ្ចង្គានិ

គច្ឆតិ អធិករណំ ជានាតិ អធិករណស្ស មូលំ ជានាតិ អធិករណសមុទយំ ជានាតិ អធិករណនិរោធំ ជានាតិ អធិករណនិរោធគាមិនឹ បដិបទំ ជានាតិ ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ ពាលោត្វេវ សង្ខំ គច្ឆតិ វត្ថុំ ន ជានាតិ និទានំ ន ជានាតិ បញ្ញត្តឹ ន ជានាតិ អនុប្បញ្ញត្តឹ ន ជានាតិ អនុសន្ធិវចនបថំ ន ជានាតិ ។ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ វត្ថុំ ជានាតិ និទានំ ជានាតិ បញ្ញត្តឹ ជានាតិ អនុប្បញ្ញត្តឹ ជានាតិ អនុសន្ធិវចនបថំ ជានាតិ ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ ពាលោត្វេវ សង្ខំ គច្ឆតិ ញត្តឹ ន ជានាតិ ញត្តិយា ករណំ ន ជានាតិ ន បុព្វកុសលោ ហោតិ ន អបរកុសលោ ហោតិ អកាលញ្ញូ ច ហោតិ ។ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ ញត្តឹ ជានាតិ ញត្តិយា ករណំ ជានាតិ

ឯកុត្តរិកៈ បញ្ចកៈ អង្គ ៥ របស់វិន័យធរ

គឺស្គាល់អធិករណ៍ ១ ស្គាល់មូលរបស់អធិករណ៍ ១ ស្គាល់ហេតុដែលកើតអធិករណ៍ ១ ស្គាល់សេចក្តីរលត់អធិករណ៍ ១ ស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់អធិករណ៍ ១ ។ វិន័យធរដែលប្រកបដោយអង្គ ៥ ដទៃទៀត ដល់នូវការពោលថាជាបុគ្គលពាល គឺមិនស្គាល់វត្ថុ ១ មិនស្គាល់និទាន ១ មិនស្គាល់បញ្ញត្តិ ១ មិនស្គាល់អនុប្បញ្ញត្តិ ១ មិនស្គាល់គន្លងនៃពាក្យដែលតគ្នា ១ ។ វិន័យធរដែលប្រកបដោយអង្គ ៥ ដល់នូវការពោលថាជាបណ្ឌិត គឺស្គាល់វត្ថុ ១ ស្គាល់និទាន ១ ស្គាល់បញ្ញត្តិ ១ ស្គាល់អនុប្បញ្ញត្តិ ១ ស្គាល់គន្លងនៃពាក្យដែលតគ្នា ១ ។ វិន័យធរដែលប្រកបដោយអង្គ ៥ ដទៃទៀត ដល់នូវការពោលថាជាបុគ្គលពាល គឺមិនស្គាល់ញត្តិ ១ មិនស្គាល់កិរិយាធ្វើញត្តិ ១ មិនឈ្លាសក្នុងកិច្ចខាងដើម ១ មិនឈ្លាសក្នុងកិច្ចខាងចុង ១ មិនស្គាល់កាលគួរ ១ ។ វិន័យធរដែលប្រកបដោយអង្គ ៥ ដល់នូវការពោលថាជាបណ្ឌិត គឺស្គាល់ញត្តិ ១ ស្គាល់កិរិយាធ្វើញត្តិ ១

បុព្វកុសលោ ហោតិ អបរកុសលោ ហោតិ កាលញ្ញូ ច ហោតិ ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ ពាលោត្វេវ សង្ខំ គច្ឆតិ អាបត្តានាបត្តឹ ន ជានាតិ លហុកគរុកំ អាបត្តឹ ន ជានាតិ សាវសេសានវសេសំ អាបត្តឹ ន ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ន ជានាតិ អាចរិយបរម្បរា ខោ បនស្ស ន សុគ្គហិតា ហោតិ ន សុមនសិកតា ន សូបធារិតា ។ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ អាបត្តានាបត្តឹ ជានាតិ លហុកគរុកំ អាបត្តឹ ជានាតិ សាវសេសានវសេសំ អាបត្តឹ ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ជានាតិ អាចរិយបរម្បរា ខោ បនស្ស សុគ្គហិតា ហោតិ សុមនសិកតា សូបធារិតា ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ ពាលោត្វេវ សង្ខំ គច្ឆតិ អាបត្តានាបត្តឹ ន ជានាតិ លហុកគរុកំ អាបត្តឹ ន ជានាតិ សាវសេសានវសេសំ អាបត្តឹ ន ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ន ជានាតិ

ឈ្លាសក្នុងកិច្ចខាងដើម ១ ឈ្លាសក្នុងកិច្ចខាងចុង ១ ស្គាល់កាលគួរ ១ ។ វិន័យធរដែលប្រកបដោយអង្គ ៥ ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អាបត្តិនិងអនាបត្តិ ១ មិនស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ មិនស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ មិនស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១ វិន័យធរនោះមិនរៀនគំណអាចារ្យ ហើយនិងមិនយកចិត្តទុកដាក់មិនពិចារណាដោយល្អ ១ ។ វិន័យធរដែលប្រកបដោយអង្គ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់អាបត្តិនិងអនាបត្តិ ១ ស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ ស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ ស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១ វិន័យធរនោះបានរៀនគំណអាចារ្យ ហើយនិងយកចិត្តទុកដាក់ពិចារណាដោយល្អ ១ ។ វិន័យធរដែលប្រកបដោយអង្គ៥ ដទៃទៀតដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អាបត្តិនិងអនាបត្តិ ១ មិនស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ មិនស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ មិនស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១

ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ន ស្វាគតានិ[១] ហោន្តិ ន សុវិភត្តានិ ន សុប្បវត្តីនិ ន សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ ។ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ អាបត្តានាបត្តឹ ជានាតិ លហុកគរុកំ អាបត្តឹ ជានាតិ សាវសេសានវសេសំ អាបត្តឹ ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ជានាតិ ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ ពាលោត្វេវ សង្ខំ គច្ឆតិ អាបត្តានាបត្តឹ ន ជានាតិ លហុកគរុកំ អាបត្តឹ ន ជានាតិ សាវសេសានវសេសំ អាបត្តឹ ន ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ន ជានាតិ អធិករណោ ច ន វិនិច្ឆយកុសលោ ហោតិ ។ បញ្ចហង្គេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ អាបត្តានាបត្តឹ ជានាតិ លហុកគរុកំ អាបត្តឹ ជានាតិ សាវសេសានវសេសំ អាបត្តឹ ជានាតិ

---

១ ឱ. ម. បាតិមោក្ខានិ ន វិត្ថារេន ស្វាគតានិ ។

ឯកុត្តរិកៈ បញ្ចកៈ អង្គ ៥ របស់វិន័យធរ

វិន័យធរនោះមិនបានចេះចាំបាតិមោក្ខ ទាំងពីរយ៉ាងដោយពិស្តារ មិនចេះចែកបទភាជនៈដោយប្រពៃ មិនបានចាំស្ទាត់រត់មាត់ដោយប្រពៃ មិនចេះកាត់សេចក្តីដោយប្រពៃតាមសូត្រៈគឺខន្ធកៈនិងបរិវារៈតាមអនុព្យញ្ជនៈគឺអក្ខរៈនិងបទ ១ ។ វិន័យធរដែលប្រកបដោយអង្គ ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់អាបត្តិនិងអនាបត្តិ ១ ស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ ស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ ស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១ វិន័យធរនោះបានចេះចាំបាតិមោក្ខ ទាំងពីរយ៉ាងដោយពិស្តារ ចេះចែកបទភាជនៈដោយប្រពៃ បានចាំស្ទាត់រត់មាត់ដោយប្រពៃ ចេះកាត់សេចក្តីដោយប្រពៃតាមសូត្រៈ តាមអនុព្យញ្ជនៈ ១ ។ វិន័យធរដែលប្រកបដោយអង្គ ៥ ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អាបត្តិនិងអនាបត្តិ ១ មិនស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ មិនស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ មិនស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១ ជាអ្នកមិនឈ្លាសក្នុងការកាត់សេចក្តីក្នុងអធិករណ៍ ១ ។ វិន័យធរដែលប្រកបដោយអង្គ ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់អាបត្តិនិងអនាបត្តិ ១ ស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ ស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១

ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ជានាតិ អធិករណេ ច វិនិច្ឆយ-កុសលោ ហោតិ ។

(៦៤) បញ្ច អារញ្ញកា មន្ទត្តា មោមូហត្តា អារញ្ញកោ ហោតិ បាបិច្ឆោ ឥច្ឆាបកតោ អារញ្ញកោ ហោតិ ឧម្មាទា ចិត្តក្ខេបា អារញ្ញកោ ហោតិ វណ្ណិតោ[១] ពុទ្ធេហិ ពុទ្ធសាវកេហីតិ អារញ្ញកោ ហោតិ អបិច អប្បិច្ឆញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមដ្ឋិតញ្ញេវ និស្សាយ អារញ្ញកោ ហោតិ ។ បញ្ច បិណ្ឌបាតិកា ។ បញ្ច បំសុកូលិកា ។ បញ្ច រុក្ខមូលិកា ។ បញ្ច សោសានិកា ។ បញ្ច អព្ភោកាសិកា ។ បញ្ច តេចីវរិកា ។ បញ្ច សបទានចារិកា ។ បញ្ច នេសជ្ជិកា ។

---

១ ឱ. ម. វណ្ណិតំ ។

ស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១ ជាអ្នកឈ្លាសក្នុងការកាត់សេចក្តី ក្នុងអធិករណ៍ ១ ។

(៦៤) ភិក្ខុអ្នកប្រព្រឹត្តអារញ្ញកធុតង្គ (ភិក្ខុអ្នកនៅក្នុងព្រៃជាវត្ត) មាន ៥ ពួក គឺ ភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គ ដោយសេចក្តីល្ងង់សេចក្តីវង្វេង ១ ភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គ មានសេចក្តីប្រាថ្នាលាមកជ្រុលជ្រប់ ដោយសេចក្តីប្រាថ្នា ១ ភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គ ព្រោះសេចក្តីឆ្កួតនិងអណ្តែតអណ្តូងចិត្ត ១ ភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គដោយគិតថា ភិក្ខុអ្នកប្រព្រឹត្តអារញ្ញកធុតង្គ ព្រះពុទ្ធនិងពុទ្ធសាវកតែងសរសើរ ១ ម្យ៉ាងទៀត ភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិចផង អាស្រ័យសេចក្តីសន្តោសផង អាស្រ័យការជុសខាត់ចិត្តផង អាស្រ័យសេចក្តីស្ងាត់កាយស្ងាត់ចិត្តផង អាស្រ័យសេចក្តីប្រតិបត្តិដែលមានប្រយោជន៍ផង ១ ។ ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តបំសុកូលិកធុតង្គ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្ត រុក្ខមូលិកធុតង្គ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តសោសានិកធុតង្គ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តអព្ភោកាសិកធុតង្គ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តតេចីវរិកធុតង្គ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តសបទានចារិកធុតង្គ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តនេសជ្ជិកធុតង្គ មាន ៥ ពួក

ឯកុត្តរិកំ បញ្ចកំ នានិស្សិតានិស្សិតស្ស បញ្ចង្គានិ

បញ្ច យថាសន្ថតិកា ។ បញ្ច ឯកាសនិកា ។ បញ្ច ខលុបច្ឆាភត្តិកា ។ បញ្ច បត្តបិណ្ឌិកា មន្ទត្តា មោមូហត្តា បត្តបិណ្ឌិកោ ហោតិ បាបិច្ឆោ ឥច្ឆាបកតោ បត្តបិណ្ឌិកោ ហោតិ ឧម្មាទា ចិត្តក្ខេបា បត្តបិណ្ឌិកោ ហោតិ វណ្ណិតំ ពុទ្ធេហិ ពុទ្ធសាវកេហីតិ បត្តបិណ្ឌិកោ ហោតិ អបិច អប្បិច្ឆញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមត្ថិតញ្ញេវ និស្សាយ បត្តបិណ្ឌិកោ ហោតិ ។

(៦៨) បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា នានិស្សិតេន វត្ថព្វំ ឧបោសថំ ន ជានាតិ ឧបោសថកម្មំ ន ជានាតិ បាតិមោក្ខំ ន ជានាតិ បាតិមោក្ខុទ្ទេសំ ន ជានាតិ ឩនបញ្ចវស្សោ ហោតិ ។ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា អនិស្សិតេន វត្ថព្វំ ឧបោសថំ ជានាតិ ឧបោសថកម្មំ ជានាតិ បាតិមោក្ខំ ជានាតិ បាតិមោក្ខុទ្ទេសំ ជានាតិ បញ្ចវស្សោ វា ហោតិ អតិរេ

ភិក្ខុអ្នកប្រព្រឹត្តយថាសន្ថតិកង្គ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តឯកាសនិកង្គ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តខលុបច្ឆាភត្តិកង្គ មាន៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកង្គ មាន ៥ ពួក គឺភិក្ខុប្រព្រឹត្តបិណ្ឌបាតិកង្គ ដោយសេចក្ដីល្ងង់សេចក្ដីវង្វេង ១ ភិក្ខុប្រព្រឹត្តបិណ្ឌបាតិកង្គមានសេចក្ដីប្រាថ្នាលាមកជ្រុលជ្រប់ដោយសេចក្ដីប្រាថ្នា ១ ភិក្ខុប្រព្រឹត្តបិណ្ឌបាតិកង្គ ព្រោះសេចក្ដីឆ្កួតសេចក្ដីអណ្ដែតអណ្ដូងចិត្ត ១ ភិក្ខុប្រព្រឹត្តបិណ្ឌបាតិកង្គដោយគិតថា ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកង្គ ព្រះពុទ្ធនិងពុទ្ធសាវកតែងសរសើរ ១ ម្យ៉ាងទៀត ភិក្ខុប្រព្រឹត្តបិណ្ឌបាតិកង្គ ព្រោះអាស្រ័យសេចក្ដីប្រាថ្នាតិចផង អាស្រ័យសេចក្ដីសន្តោសផង អាស្រ័យការជុសខាត់ចិត្តផង អាស្រ័យសេចក្ដីស្ងាត់កាយស្ងាត់ចិត្តផង អាស្រ័យសេចក្ដីប្រតិបត្តិដែលមានប្រយោជន៍ផង ១ ។

(៦៥) ភិក្ខុដែលប្រកបដោយអង្គ ៥ មិនត្រូវនៅដោយឥតនិស្ស័យទេ គឺ ភិក្ខុមិនស្គាល់ឧបោសថ (ថ្ងៃឧបោសថ) ១ មិនស្គាល់ឧបោសថកម្ម ១ មិនចេះបាតិមោក្ខ ១ មិនចេះឧទ្ទេសរបស់បាតិមោក្ខ ១ មានវស្សាមិនគ្រប់ប្រាំ ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺភិក្ខុស្គាល់ឧបោសថ ១ ស្គាល់ឧបោសថកម្ម ១ ចេះបាតិមោក្ខ ១ ចេះឧទ្ទេសរបស់បាតិមោក្ខ ១ មានវស្សាគ្រប់ប្រាំ ឬមាន

កបញ្ចវស្សោ វា ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា នានិស្សិតេន វត្ថព្វំ បវារណំ ន ជានាតិ បវារណាកម្មំ ន ជានាតិ បាតិមោក្ខំ ន ជានាតិ បាតិមោក្ខុទ្ទេសំ ន ជានាតិ ឩនបញ្ចវស្សោ ហោតិ ។ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា អនិស្សិតេន វត្ថព្វំ បវារណំ ជានាតិ បវារណាកម្មំ ជានាតិ បាតិមោក្ខំ ជានាតិ បាតិមោក្ខុទ្ទេសំ ជានាតិ បញ្ចវស្សោ វា ហោតិ អតិរេកបញ្ចវស្សោ វា ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា នានិស្សិតេន វត្ថព្វំ អាបត្តានាបត្តឹ ន ជានាតិ លហុកគរុកំ អាបត្តឹ ន ជានាតិ សាវសេសានវសេសំ អាបត្តឹ ន ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ន ជានាតិ ឩនបញ្ចវស្សោ ហោតិ ។ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា អនិស្សិតេន វត្ថព្វំ អាបត្តានាបត្តឹ ជានាតិ លហុកគរុកំ អាបត្តឹ ជានាតិ សាវសេសានវសេសំ អាបត្តឹ ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ជានាតិ បញ្ចវស្សោ វា ហោតិ អតិរេកបញ្ចវស្សោ វា ។ បញ្ចហង្គេហិ

វស្សាលើសអំពីប្រាំឡើងទៅ ១ ។ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនៅដោយឥតនិស្ស័យដែរ គឺភិក្ខុមិនស្គាល់បវារណា (ថ្ងៃបវារ-ណា) ១ មិនស្គាល់បវារណាកម្ម ១ មិនចេះបាតិមោក្ខ ១ មិនចេះឧទ្ទេសរបស់បាតិមោក្ខ ១ មានវស្សាមិនគ្រប់ប្រាំ ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺភិក្ខុស្គាល់បវារណា ១ ស្គាល់បវារណាកម្ម ១ ចេះបាតិមោក្ខ ១ ចេះឧទ្ទេសរបស់បាតិមោក្ខ ១ មានវស្សាគ្រប់ប្រាំ ឬមានវស្សាលើសអំពីប្រាំឡើងទៅ ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនត្រូវនៅដោយឥតនិស្ស័យដែរ គឺភិក្ខុមិនស្គាល់អាបត្តិនឹងអនាបត្តិ ១ មិនស្គាល់លហុកាបត្តិនឹងគរុកាបត្តិ ១ មិនស្គាល់សាវសេសាបត្តិ នឹងអនវសេសាបត្តិ ១ មិនស្គាល់ទុដ្ឋុល្លាបត្តិនឹងអទុដ្ឋុល្លាបត្តិ ១ មានវស្សាមិនគ្រប់ប្រាំ ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺភិក្ខុស្គាល់អាបត្តិនឹងអនាបត្តិ ១ ស្គាល់លហុកាបត្តិនឹងគរុកាបត្តិ ១ ស្គាល់សាវសេសាបត្តិ នឹងអនវសេ-សាបត្តិ ១ ស្គាល់ទុដ្ឋុល្លាបត្តិនឹងអទុដ្ឋុល្លាបត្តិ ១ មានវស្សាគ្រប់ប្រាំ ឬមានវស្សាលើសអំពីប្រាំឡើងទៅ ១ ។ ភិក្ខុនីដែលប្រកបដោយអង្គ ៥

ឯកុត្តរិកំ បញ្ចកំ អនិស្សិតានិស្សិតាយ បញ្ចង្គានិ

សមន្នាគតាយ ភិក្ខុនិយា នានិស្សិតាយ វត្ថព្វំ ឧបោសថំ ន ជានាតិ ឧបោសថកម្មំ ន ជានាតិ បាតិមោក្ខំ ន ជានាតិ បាតិមោក្ខុទ្ទេសំ ន ជានាតិ ឩនបញ្ចវស្សា ហោតិ ។ បញ្ចហង្គេហិ សមន្នាគតាយ ភិក្ខុនិយា អនិស្សិតាយ វត្ថព្វំ ឧបោសថំ ជានាតិ ឧបោសថកម្មំ ជានាតិ បាតិមោក្ខំ ជានាតិ បាតិមោក្ខុទ្ទេសំ ជានាតិ បញ្ចវស្សា វា ហោតិ អតិរេកបញ្ចវស្សា វា ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតាយ ភិក្ខុនិយា នានិស្សិតាយ វត្ថព្វំ បវារណំ ន ជានាតិ បវារណាកម្មំ ន ជានាតិ បាតិមោក្ខំ ន ជានាតិ បាតិមោក្ខុទ្ទេសំ ន ជានាតិ ឩនបញ្ចវស្សា ហោតិ ។ បញ្ចហង្គេហិ សមន្នាគតាយ ភិក្ខុនិយា អនិស្សិតាយ វត្ថព្វំ បវារណំ ជានាតិ បវារណាកម្មំ ជានាតិ បាតិមោក្ខំ ជានាតិ បាតិមោក្ខុទ្ទេសំ ជានាតិ បញ្ចវស្សា វា ហោតិ អតិរេកបញ្ចវស្សា វា ។ អបរេហិបិ បញ្ចហង្គេហិ សមន្នាគតាយ ភិក្ខុនិយា នានិស្សិតាយ វត្ថព្វំ អាបត្តានាបត្តិំ ន ជានាតិ លហុកគរុកំ អាបត្តិំ ន ជានាតិ សាវសេសានាវសេសំ អាបត្តិំ ន ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តិំ ន ជានាតិ

មិនត្រូវនៅដោយឥតនិស្ស័យ ៦ គឺភិក្ខុមិនស្គាល់ឧបោសថ ១ មិនស្គាល់ឧបោសថកម្ម ១ មិនចេះបាតិមោក្ខ ១ មិនចេះឧទ្ទេសរបស់បាតិមោក្ខ ១ មានវស្សាមិនគ្រប់ប្រាំ ១ ៗ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺ ភិក្ខុស្គាល់ឧបោសថ ១ ស្គាល់ឧបោសថកម្ម ១ ចេះបាតិមោក្ខ ១ ចេះឧទ្ទេសរបស់បាតិមោក្ខ ១ មានវស្សាគ្រប់ប្រាំ ឬ មានវស្សាលើសអំពីប្រាំឡើងទៅ ១ ៗ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនត្រូវនៅដោយឥតនិស្ស័យដែរ គឺ ភិក្ខុមិនស្គាល់បវារណា ១ មិនស្គាល់បវារណាកម្ម ១ មិនចេះបាតិមោក្ខ ១ មិនចេះឧទ្ទេសរបស់បាតិមោក្ខ ១ មានវស្សាមិនគ្រប់ប្រាំ ១ ៗ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺភិក្ខុស្គាល់បវារណា ១ ស្គាល់បវារណាកម្ម ១ ចេះបាតិមោក្ខ ១ ចេះឧទ្ទេសរបស់បាតិមោក្ខ ១ មានវស្សាគ្រប់ប្រាំ ឬមានវស្សាលើសអំពីប្រាំឡើងទៅ ១ ៗ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនត្រូវនៅដោយឥតនិស្ស័យដែរ គឺ ភិក្ខុមិនស្គាល់អាបត្តិនិងអនាបត្តិ ១ មិនស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ មិនស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ មិនស្គាល់ទុដ្ឋុល្លាបត្តិនិង

ឩនបញ្ចវស្សា ហោតិ ។ បញ្ចហង្គេហិ សមន្នាគតាយ ភិក្ខុនិយា អនិស្សិតាយ វត្ថព្វំ អាបត្តានាបត្តឹ ជានាតិ លហុកគរុកំ អាបត្តឹ ជានាតិ សាវសេសានាវសេសំ អាបត្តឹ ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ជានាតិ បញ្ចវស្សា វា ហោតិ អតិរេកបញ្ចវស្សា វា ។

(៦៦) បញ្ច អាទីនវា អបាសាទិកេ អត្តាបិ អត្តានំ ឧបវទតិ អនុវិច្ចបិ វិញ្ញូ គរហន្តិ បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ សម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ បញ្ចានិសំសា បាសាទិកេ អត្តាបិ អត្តានំ ន ឧបវទតិ អនុវិច្ចបិ វិញ្ញូ បសំសន្តិ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អសម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ អបរេបិ បញ្ច អាទីនវា អបាសាទិកេ

អទុដ្ឋុល្លាបត្តិ ១ មានវស្សាមិនគ្រប់ប្រាំ ១ ។ ភិក្ខុនីដែលប្រកបដោយអង្គ ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺភិក្ខុនីស្គាល់អាបត្តិនិងអនាបត្តិ ១ ស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ ស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ ស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១ មានវស្សាគ្រប់ប្រាំ ឬមានវស្សាលើសអំពីប្រាំឡើងទៅ ១ ។

(៦៦) អំពើមិនជាទីញ៉ាំងសេចក្ដីជ្រះថ្លាឲ្យកើត រមែងមានទោស ៥ យ៉ាង គឺខ្លួនឯងតិះដៀលខ្លួនឯង ១ អ្នកប្រាជ្ញសង្កេតមើលហើយតែងតិះដៀល ១ កិត្តិស័ព្ទអាក្រក់ រមែងផ្សាយទៅ ១ បុគ្គលនោះមានសេចក្ដីវង្វេងធ្វើមរណកាល ១ លុះរំលាយកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ១ ។ អំពើដែលញ៉ាំងសេចក្ដីជ្រះថ្លាឲ្យកើត រមែងមានអានិសង្ស ៥ គឺខ្លួនឯងតិះដៀលខ្លួនឯងមិនបាន ១ អ្នកប្រាជ្ញសង្កេតហើយតែងសរសើរ ១ កិត្តិស័ព្ទល្អ រមែងផ្សាយទៅ ១ បុគ្គលនោះមិនមានសេចក្ដីវង្វេងធ្វើមរណកាល ១ លុះរំលាយកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ អំពើមិនជាទីញ៉ាំងសេចក្ដីជ្រះថ្លាឲ្យកើត រមែងមានទោស ៥ យ៉ាងដទៃ

ឯកុត្តរិកំ បញ្ចកំ បញ្ចានិសំសា បញ្ចាទីនវា

អប្បសន្នា នប្បសីទន្តិ បសន្នានំ ឯកច្ចានំ អញ្ញថត្តំ ហោតិ សត្ថុសាសនំ អកតំ ហោតិ បច្ឆិមា ជនតា ទិដ្ឋានុគតិំ អាបជ្ជតិ ចិត្តមស្ស នប្បសីទតិ ។ បញ្ចានិសំសា បាសាទិកេ អប្បសន្នា បសីទន្តិ បសន្នានំ ភិយ្យោភាវាយ ហោតិ សត្ថុសាសនំ កតំ ហោតិ បច្ឆិមា ជនតា ទិដ្ឋានុគតិំ អាបជ្ជតិ ចិត្តមស្ស បសីទតិ ។ បញ្ច អាទីនវា កុលូបកេ អនាមន្តចារេ អាបជ្ជតិ រហោនិសជ្ជាយ អាបជ្ជតិ បដិច្ឆន្នេ អាសនេ អាបជ្ជតិ មាតុគាមស្ស ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេន្តោ អាបជ្ជតិ កាមសង្កប្បពហុលោ ច វិហរតិ ។ បញ្ច អាទីនវា កុលូបកស្ស ភិក្ខុនោ អតិវេលំ កុលេសុ សំសដ្ឋស្ស វិហរតោ មាតុគាមស្ស អភិណ្ហទស្សនំ ទស្សនេ សតិ សំសគ្គោ សំសគ្គេ សតិ វិស្សាសោ វិស្សាសេ សតិ

ទៀត គឺពួកជនដែលមិនទាន់ជ្រះថ្លាក៏ខានជ្រះថ្លា ១ ជនពួកខ្លះដែលជ្រះថ្លាស្រាប់ហើយ ក៏បែរជាបាត់ជ្រះថ្លាទៅវិញ ១ ឈ្មោះថាមិនធ្វើតាមពាក្យប្រដៅរបស់ព្រះសាស្ដា ១ ប្រជុំជនជាខាងក្រោយ រមែងយកតម្រាប់តាម ១ ចិត្តរបស់បុគ្គលនោះក៏មិនជ្រះថ្លា ១ ៗ អំពើដែលញ៉ាំងសេចក្ដីជ្រះថ្លាឲ្យកើតរមែងមានអានិសង្ស ៥ យ៉ាង គឺពួកជនដែលមិនទាន់ជ្រះថ្លាក៏ជ្រះថ្លាឡើង ១ ពួកជនដែលជ្រះថ្លាស្រាប់ហើយ ក៏រឹតតែជ្រះថ្លាឡើង ១ ឈ្មោះថាធ្វើតាមពាក្យប្រដៅរបស់ព្រះសាស្ដា ១ ប្រជុំជនជាខាងក្រោយរមែងយកតម្រាប់តាម ១ ចិត្តរបស់បុគ្គលនោះក៏ជ្រះថ្លា ១ ៗ ភិក្ខុអ្នកទៅកាន់ត្រកូលរមែងមានទោស ៥ យ៉ាង គឺត្រូវអាបត្តិព្រោះមិនបានប្រាប់ភិក្ខុដែលមាននៅក្នុងអាវាសហើយត្រេចទៅ ១ ត្រូវអាបត្តិព្រោះអង្គុយក្នុងទីស្ងាត់ ១ ត្រូវអាបត្តិក្នុងអាសនៈដែលកំបាំង ១ សំដែងធម៌ដល់មាតុគ្រាមលើសជាងប្រាំ ប្រាំមួយម៉ាត់ឡើងទៅត្រូវអាបត្តិ ១ មានសេចក្ដីត្រិះរិះជាច្រើនក្នុងកាមគុណ ១ ៗ ភិក្ខុអ្នកចូលទៅកាន់ត្រកូលនៅប្រឡូកប្រឡំក្នុងត្រកូលហួសវេលា រមែងមានទោស ៥ យ៉ាង គឺក្រឡេកមើលមាតុគ្រាមរឿយៗ ១ កាលបើមើលហើយនឹងមានសេចក្ដីជាប់ជំពាក់ ១ កាលបើមានសេចក្ដីជាប់ជំពាក់ហើយនឹងកើតសេចក្ដីស្និទ្ធស្នាល ១ កាល

ឱតារោ(១) ឱតិណ្ណោ ចិត្តស្សេតំ ភិក្ខុនោ ឆាទិកាត្ថំ អន-ភិរតោ វា ព្រហ្មចរិយំ ចរិស្សតិ អញ្ញតរំ វា សំកិលិដ្ឋំ អាបត្តឹ អាបជ្ជិស្សតិ សិក្ខំ វា បច្ចក្ខាយ ហីនា-យាវត្តិស្សតិ ។

(៦៧) បញ្ច ពីជជាតានិ មូលពីជំ ខន្ធពីជំ ផឡុ-ពីជំ អគ្គពីជំ ពីជពីជញ្ញេវ បញ្ចមំ ។ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតព្វំ អគ្គិបរិចិតំ សត្ថបរិចិតំ នខបរិចិតំ អពីជំ និព្វដ្ដពីជញ្ញេវ បញ្ចមំ ។

(៦៨) បញ្ច វិសុទ្ធិយោ និទានំ ឧទ្ទិសិត្វា អវសេសំ សុតេន សាវេតព្វំ អយំ បឋមា វិសុទ្ធិ និទានំ ឧទ្ទិសិ-ត្វា ចត្តារិ បារាជិកានិ ឧទ្ទិសិត្វា អវសេសំ សុតេន សាវេតព្វំ អយំ ទុតិយា វិសុទ្ធិ និទានំ ឧទ្ទិសិត្វា ចត្តា-រិ បារាជិកានិ ឧទ្ទិសិត្វា តេរស សង្ឃាទិសេសេ ឧទ្ទិ-សិត្វា អវសេសំ សុតេន សាវេតព្វំ អយំ តតិយា

១ ឱតារោតិ កិលេសានំ អន្តោ ឱតរណន្តិ អដ្ឋកថា ។

បើមានសេចក្តីស្និទ្ធស្នាលហើយ ទឹងកើតមានរាគៈ គ្របសង្កត់ចិត្ត ១ ទោសជាតនេះតែងកើតមាន បំពោះតែភិក្ខុដែលមានចិត្ត ត្រូវរាគៈគ្របសង្កត់ហើយ គឺភិក្ខុនោះទឹងប្រព្រឹត្តព្រហ្មចរិយធម៌ទាំងសេចក្តីអផ្សុក ឬនឹងត្រូវអាបត្តិដែលសៅហ្មងឯណានីមួយ ឬនឹងពោលលាសិក្ខាត្រឡប់មកកាន់ភេទគ្រហស្ថវិញ ១ ។

(៦៣) ពូជមាន ៥ យ៉ាង គឺពូជឬសឬមើម ១ ពូជដើម ១ ពូជថ្នាំង ១ ពូជត្រួយឬចុង ១ រួមពូជគ្រាប់ ១ ផង ជាគំរប់ ៥ ។ ផ្លែឈើដែលភិក្ខុគួរឆាន់បានដោយសមណកប្បមាន ៥ យ៉ាង គឺផ្លែឈើដែលគេសម្រេចដោយភ្លើង ១ គេសម្រេចដោយសស្ត្រា ១ គេសម្រេចដោយក្រចក ១ ផ្លែឈើដែលគ្មានគ្រាប់ ១ ផ្លែឈើដែលគេយកគ្រាប់ចេញ ១ ជាគំរប់ ៥ ។

(៦៤) វិសុទ្ធិមាន ៥ គឺសំដែងនូវនិទានហើយសូត្រនូវឧទ្ទេសដែលសល់អំពីនិទាននោះដោយសុតបទ នេះជាវិសុទ្ធិទី ១ សំដែងនូវនិទានរួចសំដែងនូវបារាជិកទាំង ៤ ហើយសូត្រនូវឧទ្ទេសដែលសល់អំពីបារាជិកនោះដោយសុតបទ នេះជាវិសុទ្ធិទី ២ សំដែងនូវនិទានហើយសំដែងនូវបារាជិកទាំង ៤ រួចសំដែងនូវសង្ឃាទិសេសទាំង ១៣ ហើយសូត្រនូវឧទ្ទេសដែលសល់អំពីសង្ឃាទិសេសនោះដោយសុតបទ នេះជាវិសុទ្ធិទី៣

វិសុទ្ធិ និទានំ ឧទ្ទិសិត្វា ចត្តារិ បារាជិកានិ ឧទ្ទិសិត្វា តេរស សង្ឃាទិសេសេ ឧទ្ទិសិត្វា ទ្វេ អនិយតេ ឧទ្ទិសិត្វា អវសេសំ សុតេន សាវេតព្វំ អយំ ចតុត្ថា វិសុទ្ធិ ។ វិត្ថារេនេវ បញ្ចមី ។ អបរាបិ បញ្ច វិសុទ្ធិយោ សុត្តុទ្ទេសោ បារិសុទ្ធិឧបោសថោ អធិដ្ឋានុបោសថោ សាមគ្គីឧបោសថោ បវារណាយេវ បញ្ចមា[1] ។

[៦៩] បញ្ចានិសំសា វិនយធរេ អត្តនោ សីលក្ខន្ធោ សុគុត្តោ ហោតិ សុរក្ខិតោ កុក្កុច្ចបកតានំ បដិសរណំ ហោតិ វិសារទោ សង្ឃមជ្ឈេ វោហរតិ បច្ចត្ថិកេ សហធម្មេន សុនិគ្គហិតំ និគ្គណ្ហាតិ សទ្ធម្មដ្ឋិតិយា បដិបន្នោ ហោតិ ។ បញ្ច អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ បញ្ច ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

បញ្ចកំ និដ្ឋិតំ ។

---

១ ឧ. ម. អធិដ្ឋានុបោសថោ បវារណា សាមគ្គីឧបោសថោ យេវ បញ្ចមោ ។

សំដែងនូវនិទានហើយសំដែងនូវបារាជិកទាំង ៤ សំដែងនូវសង្ឃាទិសេស ទាំង ១៣ រួបសំដែងអនិយតទាំង ២ ហើយសូត្រនូវទោសដែលសល់ អំពីអនិយតនោះដោយសុតបទ នេះជាវិសុទ្ធិទី ៤ ។ (ការសំដែង)ដោយ ពិស្តារ ចាត់ជាវិសុទ្ធិទី ៥ ។ វិសុទ្ធិ៥ យ៉ាងដទៃទៀត គឺឧបោសថដែល ភិក្ខុធ្វើដោយសំដែងបាតិមោក្ខ ១ ឧបោសថដែលភិក្ខុធ្វើដោយប្រាប់បា-រិសុទ្ធិ ១ ឧបោសថដែលភិក្ខុធ្វើដោយអធិដ្ឋាន ១ ឧបោសថដែលភិក្ខុធ្វើ ដោយសេចក្ដីព្រមព្រៀងគ្នា ១ បវារណា ១ ជាគំរប់ ៥ ។

(៩) ភិក្ខុអ្នកទ្រទ្រង់វិន័យ តែងបានអានិសង្ស ៥ ប្រការ គឺសី-លក្ខន្ធរបស់ខ្លួន ឈ្មោះថាភិក្ខុនោះបានគ្រប់គ្រងរក្សាដោយល្អ ១ ភិក្ខុនោះ តែងជាទីពឹងនៃពួកភិក្ខុដែលមានសេចក្ដីសង្ស័យជាប្រក្រតី ១ ភិក្ខុនោះ ជាអ្នកក្លៀវក្លានិយាយក្នុងកណ្ដាលជំនុំសង្ឃ ១ ភិក្ខុនោះរមែងសង្កត់សង្កិន ដោយល្អនូវពួកសត្រូវដោយសហធម៌ គឺសិក្ខាបទដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តទុក ១ ភិក្ខុនោះឈ្មោះថាជាអ្នកប្រតិបត្តិដើម្បីញុំាងព្រះសទ្ធម្ម ឲ្យតាំងនៅមាំ ១ ។ ការបញ្ឈប់បាតិមោក្ខដែលមិនប្រកបដោយធម៌មាន ៥ ប្រការ ។ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌មាន ៥ ប្រការ ។

ចប់ បញ្ចកៈ (ពួក ៥ ។) ។

តស្សុទ្ទានំ

(៧០) អាបត្តិ អាបត្តិក្ខន្ធា
វិនីតានិ តថេវ ច
បុគ្គលា ឆេឡសា ចេវ
អាបជ្ជតិ ច បច្ចយា
ន ឧបេតិ ឧបេតិ ច
កប្បន្តិស្សក្តិ តេល ច[១]
វសព្យសនសម្បទា[២]
បស្សន្ធិ បុគ្គលេន ច
សោភានិ កោធាយិតញ្ច
ថេយ្យំ ចោរោ ច វុច្ចតិ
អវិស្សជ្ជិ អវេភង្គិ
កាយតោ កាយវាចតោ
ទេសនា សង្ឃឧទ្ទេសា[៣]
បច្ចត្ថិ កឋិនេន ច
កម្មានិ យាវតតិយំ

---

១ ឧ. ម. គេលញ្ញ ។ ២ ឧ. វសំព្យសនំ សម្បទា ។ ម. វសំព្យសនា សម្បទា ។
៣ ឧ. ម. សង្ឃំ ឧទ្ទេសំ ។

ឧទ្ទាន គឺបញ្ជីរឿងនៃបញ្ចកៈ (ពួកប្រាំ ៗ) នោះដូច្នេះ

[៧០] និយាយអំពីអាបត្តិ ១ កងនៃអាបត្តិ ១ វិនីតវត្ថុ ១ អានន្តរិកកម្ម ១ និយតបុគ្គល ១ អាបត្តិមានកិរិយាកាត់ជាវិនយកម្ម ១ ភិក្ខុត្រូវអាបត្តិ ១ អាបត្តិមានមុសាវាទជាបច្ច័យ ១ ភិក្ខុមិនគួរដល់កម្ម ១ ភិក្ខុដែលគួរដល់កម្ម ១ ធម៌ ៥ យ៉ាងតែងសម្រេចដល់ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត ១ ភិក្ខុដែលគួរឲ្យគេរង្កៀសសង្ស័យ ១ ប្រេង ១ ខ្លាញ់ ១ សេចក្តីវិនាស ១ សម្បទា ១ រម្ងាប់ចាកនិស្ស័យ ១ បុគ្គល ១ សំពត់បំសុកូលឈ្មោះសោសានិក ១ សំពត់បំសុកូលឈ្មោះគោខាយិ ១ ការលួច ១ មហាចោរ ១ វត្ថុដែលភិក្ខុមិនគួរលះបង់ ១ វត្ថុដែលភិក្ខុមិនគួរបែក ១ អាបត្តិតាំងឡើងអំពីកាយ ១ អាបត្តិតាំងឡើងអំពីកាយនឹងវាចា ១ អាបត្តិជាទេសនាគាមិនី ១ សង្ឃ ១ ឧទ្ទេសរបស់បាតិមោក្ខ ១ ឲ្យឧបសម្បទាក្នុងបច្ចន្តប្រទេស ១ អានិសង្សកឋិន ១ សង្ឃកម្ម ១ អាបត្តិជាយាវតតិយកា ១

ឯកុត្តរិកំ បញ្ចកំ ឧទ្ទានគាថា

ឆាភជិតថុល្លទុក្កដំ(១)
អកប្បិយំ កប្បិយញ្ច
អបុញ្ញា ទុរិតោទិយា(២)
សម្មដ្ឋី អបរេ ច
កាសំ អាបត្តិមេវ ច
អធិករណំ វត្ថុំ(៣) ញត្តិ
អាបត្តិ ឧភយាធិ ច
លហុកដួមកា ឃរេ
កណ្ហាសុក្កា វិជានថ
អរញ្ញំ(៤) បិណ្ឌបាតញ្ច
បំសុក្កូសុសានិកា(៥)
អព្ភោកាសោ(៦) ចីវរញ្ច
សបទានោ និសជ្ជិកោ
សន្ថតិខលុបច្ឆាបិ
បត្តបិណ្ឌិកមេវ ច

---

១ ម. ឋាភជិថុល្លទុក្កដំ ។ ២ ឱ. ម. ទុរិតោទយា ។ ៣ ម. វត្ថុ ។ ៤ ម. អរញ្ញ ។
៥ ឱ. ម. បំសុក្កូសោសានិកា ។ ៦ ឱ. អពោកាសេ ។

ឯកុត្តរិកៈ បញ្ចកៈ ឧទ្ទានគាថា

លួចត្រូវអាបត្តិបារាជិក ១ លួចត្រូវអាបត្តិថុល្លច្ច័យ ១ លួចត្រូវអាបត្តិទុក្កដ ១ វត្ថុមិនគួរធាន់ ១ វត្ថុគួរធាន់ ១ ទានមិនមែនជាបុណ្យ ១ ធម៌មិនងាយនឹងបន្ទោបង់បាន ១ អានិសង្សបោស ១ អានិសង្សបោសដទៃទៀត ១ វិន័យធរមិនរៀននឹងរៀនទីកំណត់ភាសា ១ មិនស្គាល់នឹងស្គាល់អាបត្តិ ១ មិនស្គាល់នឹងស្គាល់អធិករណ៍ ១ មិនស្គាល់នឹងស្គាល់វត្ថុ ១ មិនស្គាល់នឹងស្គាល់ញត្តិ ១ មិនស្គាល់នឹងស្គាល់អាបត្តិ ១ មិនចេះនឹងចេះបាតិមោក្ខទាំងពីរ ១ ស្គាល់លហុកាបត្តិនឹងគរុកាបត្តិ ១ ជាគំរប់ ៨ អ្នកទាំងឡាយចូរដឹងនូវធម៌ (ដែលជាអង្គរបស់វិន័យធរ) ទាំង ៨ នេះ ថាជាធម៌ខ្មៅនឹងស (អាក្រក់នឹងល្អ ឬមិនចេះនឹងចេះ) រឿងភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គ ១ បិណ្ឌបាតិកធុតង្គ ១ បំសុកូលិកធុតង្គ ១ រុក្ខមូលិកធុតង្គ ១ សោសានិកធុតង្គ ១ អព្ភោកាសិកធុតង្គ ១ តេចីវរិកធុតង្គ ១ សបទានចារិកធុតង្គ ១ នេសជ្ជិកធុតង្គ ១ យថាសន្ថតិកធុតង្គ ១ ខលុបច្ឆាភត្តិកធុតង្គ ១ បត្តបិណ្ឌិកធុតង្គ ១

ឧបោសថំ បវារណំ

អាបត្តានាបត្តិបិ ច

កណ្ហាសុក្កបទា ឯតេ

ភិក្ខុនីនំបិ តេ តថា

អធាសាទិកធាសាទិ

តថេវ អបរេ ទុវេ

កុលុបកោ អតិវេលំ

ពីជំ សមណកប្បិ ច

វិសុទ្ធិ អបរេ ចេវ

វិនយោធម្មិកានិ[1] ច

ធម្មិកា ច តថា វុត្តា

និដ្ឋិតា សុទ្ធិបញ្ចកាតិ[2] ។

(៧១) ឆ អគារវា ។ ឆ គារវា ។ ឆ វិនីតវត្ថូនិ ។ ឆ សាមីចិយោ ។ ឆ អាបត្តិសមុដ្ឋានា ។ ឆ ឆេទនកា អាបត្តិយោ ។ ឆហាការេហិ អាបត្តឹ អាបជ្ជតិ ។ ឆ

---

១ ឧ. ម. វិនយាធម្មិកេន ច ។ ២ ឧ. សុភបញ្ចកាតិ ។

ទុព្ភាសិត ១ បវារណា ១ អាបត្តិនិងអនាបត្តិ ១ ធម៌ទាំងនេះ មានបំណែកខ្មៅនិងស (អាក្រក់និងល្អ) ធម៌ទាំងអម្បាលនោះ មានដល់ភិក្ខុនីដូចជាភិក្ខុដែរ រឿងទោសនៃអំពើមិនជាទីញ៉ាំង សេចក្តីជ្រះថ្លាឲ្យកើត ១ អានិសង្សនៃអំពើដែលញ៉ាំងសេចក្តី ជ្រះថ្លាឲ្យកើត ១ ទោសនិងអានិសង្សនៃអំពើទាំងពីរដទៃទៀត ១ ធម៌ទាំងនេះមានបំណែកខ្មៅនិងសដូចគ្នាដែរ រឿងទោសដែល មានក្នុងភិក្ខុអ្នកចូលទៅកាន់ត្រកូល ១ ទោសភិក្ខុដែលនៅប្រឡូកប្រឡំក្នុងត្រកូលហួសវេលា ១ អំពីពូជ ១ ផ្លែឈើដែល ភិក្ខុគួរឆាន់បានដោយសមណកប្ប ១ វិសុទ្ធិ ១ វិសុទ្ធិដទៃ ទៀត ១ អានិសង្សនៃភិក្ខុអ្នកទ្រទ្រង់វិន័យ ១ បញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ១ បញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ១ ធម៌ទាំងនេះព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ថាមានបំណែក ខ្មៅនិងសដូចគ្នា ចប់បញ្ចកសុទ្ធិ តែប៉ុណ្ណោះ ។

(៧១) អគារវៈមាន ៦ យ៉ាង ។ គារវៈមាន ៦ យ៉ាង ។ វិនីតវត្ថុមាន ៦ យ៉ាង ។ សិក្ខាបទដែលមានពាក្យថាប្រព្រឹត្តដោយសមគួរមាន ៦ ។ សមុដ្ឋាននៃអាបត្តិមាន ៦ យ៉ាង ។ អាបត្តិដែលមានកិរិយាកាត់ជាវិនយកម្ម មាន ៦ ។ ភិក្ខុត្រូវអាបត្តិដោយអាការ ៦ យ៉ាង ។ ភិក្ខុអ្នកទ្រទ្រង់វិន័យ

អានិសំសា វិនយធរេ ។ ឆ បរមានិ ។ ឆារត្តំ តិចីវរេន វិប្បវសិតព្វំ ។ ឆ ចីវរានិ ។ ឆ រជនានិ ។ ឆ អាបត្តិយោ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ ឆ អាបត្តិយោ វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ ។ ឆ អាបត្តិយោ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ឆ កម្មានិ ។ ឆ វិវាទមូលានិ ។ ឆ អនុវាទមូលានិ ។ ឆ សារាណីយា ធម្មា[1] ។ ទីឃសោ ឆ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ឆ វិទត្ថិយោ ។ ឆ និស្សយប្បដិប្បស្សទ្ធិយោ អាចរិយម្ហា ។ ឆ នហានេ អនុប្បញ្ញត្តិយោ ។ វិប្បកតចីវរំ អាទាយ បក្កមតិ ។ វិប្បកតចីវរំ សមាទាយ បក្កមតិ ។

(៧២) ឆហង្គេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ និស្សយោ ទាតព្វោ សាមណេរោ ឧបដ្ឋាបេតព្វោ អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន សមាធិក្ខន្ធេន សមន្នាគតោ ហោតិ

១ ឥទំ បាឋទ្វយំ អតិរេកំ វិយ ទិស្សតិ ឧទ្ទានេ អនាគតត្តា ។ ឧភោបិយោត្តកេបិ ន ទិស្សតិ ។

តែងបានអានិសង្ស ៦ ប្រការ ។ សិក្ខាបទដែលមានទីកំណត់មាន ៦ ។ ភិក្ខុគួរនៅប្រាសចាកត្រៃចីវរបានត្រឹម ៦ រាត្រី ។ ចីវរមាន ៦ យ៉ាង ។ ទឹកជ្រលក់មាន ៦ យ៉ាង ។ អាបត្តិ ៦ យ៉ាងតាំងឡើងតែអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចា ។ អាបត្តិ ៦ យ៉ាងតាំងឡើងតែអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយ ។ អាបត្តិ ៦ យ៉ាងតាំងឡើងអំពីកាយវាចានឹងចិត្ត ។ សង្ឃកម្មមាន ៦ យ៉ាង ។ វិវាទមូល(ដើមហេតុវិវាទ)មាន ៦ យ៉ាង ។ អនុវាទមូល(ដើមហេតុនៃការចោទប្រកាន់)មាន ៦ យ៉ាង ។ សារាណីយធម៌មាន ៦ យ៉ាង ។ បណ្ណាយ ៦ ចំអាម ទទឹង ៦ ចំអាម ដោយចំអាមព្រះសុគត ។ ការរម្ងាប់និស្ស័យចាកអាចារ្យមាន ៦ យ៉ាង ។ អនុប្បញ្ញត្តិក្នុងនហានសិក្ខាបទមាន ៦ លើក ។ ភិក្ខុកាន់យកចីវរដែលធ្វើមិនទាន់ស្រេចហើយចៀសចេញទៅ ។ ភិក្ខុប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចហើយចៀសចេញទៅ ។

(៧២) ភិក្ខុប្រកបដោយអង្គ ៦ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុប្រកបដោយកងសីលជារបស់អសេក្ខ-បុគ្គល ១ ប្រកបដោយកងសមាធិជារបស់អសេក្ខបុគ្គល ១ ប្រកបដោយ

អសេក្ខេន បញ្ញាក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ទសវស្សោ វា ហោតិ អតិរេកទសវស្សោ វា ។ អបរេហិបិ ឆហង្គេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ និស្សយោ ទាតព្វោ សាមណេរោ ឧបដ្ឋាបេតព្វោ អត្តនា អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ បរំ អសេក្ខេ សីលក្ខន្ធេ សមាទបេតា អត្តនា អសេក្ខេន សមាធិក្ខន្ធេន សមន្នាគតោ ហោតិ បរំ អសេក្ខេ សមាធិក្ខន្ធេ សមាទបេតា អត្តនា អសេក្ខេន បញ្ញាក្ខន្ធេន សមន្នាគតោ ហោតិ បរំ អសេក្ខេ បញ្ញាក្ខន្ធេ សមាទបេតា អត្តនា អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតោ ហោតិ បរំ អសេក្ខេ វិមុត្តិក្ខន្ធេ សមាទបេតា អត្តនា អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ បរំ អសេក្ខេ វិមុត្តិញាណទស្សនក្ខន្ធេ សមាទបេតា ទសវស្សោ វា ហោតិ អតិរេកទសវស្សោ វា ។ អបរេហិបិ ឆហង្គេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ និស្សយោ ទាតព្វោ

កងបញ្ញាជារបស់អសេក្ខបុគ្គល ១ ប្រកបដោយកងវិមុត្តិជារបស់អសេក្ខបុគ្គល ១ ប្រកបដោយកងវិមុត្តិញាណទស្សនៈ (បច្ចវេក្ខណញ្ញាណ)ជារបស់អសេក្ខបុគ្គល ១ មានវស្សា ១០ ឬមានវស្សាលើសអំពី ១០ ឡើងទៅ ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៦ ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺប្រកបដោយកងសីលជារបស់អសេក្ខបុគ្គលដោយខ្លួនឯង ទាំងដឹកនាំអ្នកដទៃ (ឲ្យប្រកប) ក្នុងកងសីលជារបស់អសេក្ខបុគ្គល ១ ប្រកបដោយកងសមាធិជារបស់អសេក្ខបុគ្គលដោយខ្លួនឯង ទាំងដឹកនាំអ្នកដទៃក្នុងកងសមាធិជារបស់អសេក្ខបុគ្គល ១ ប្រកបដោយកងបញ្ញាជារបស់អសេក្ខបុគ្គលដោយខ្លួនឯង ទាំងដឹកនាំអ្នកដទៃក្នុងកងបញ្ញាជារបស់អសេក្ខបុគ្គល ១ ប្រកបដោយកងវិមុត្តិជារបស់អសេក្ខបុគ្គលដោយខ្លួនឯង ទាំងដឹកនាំអ្នកដទៃក្នុងកងវិមុត្តិជារបស់អសេក្ខបុគ្គល ១ ប្រកបដោយកងវិមុត្តិញាណទស្សនៈជារបស់អសេក្ខបុគ្គលដោយខ្លួនឯង ទាំងដឹកនាំអ្នកដទៃក្នុងកងវិមុត្តិញាណទស្សនៈ ជារបស់អសេក្ខបុគ្គល ១ មានវស្សា ១០ ឬមានវស្សាលើសអំពី ១០ ឡើងទៅ ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៦ ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ

សាមណេរោ ឧបដ្ឋាបេតព្វោ សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ អារទ្ធវីរិយោ ហោតិ ឧបដ្ឋិតស្សតិ ហោតិ ទសវស្សោ វា ហោតិ អតិរេកទសវស្សោ វា ។ អបរេហិបិ ឆហង្គេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ និស្សយោ ទាតព្វោ សាមណេរោ ឧបដ្ឋាបេតព្វោ ន អធិសីលេ សីលវិបន្នោ ហោតិ ន អជ្ឈាចារេ អាចារវិបន្នោ ហោតិ ន អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ពហុស្សុតោ ហោតិ បញ្ញវា ហោតិ ទសវស្សោ វា ហោតិ អតិរេកទសវស្សោ វា ។ អបរេហិបិ ឆហង្គេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ និស្សយោ ទាតព្វោ សាមណេរោ ឧបដ្ឋាបេតព្វោ បដិពលោ ហោតិ អន្តេវាសឹ វា សទ្ធិវិហារឹ វា គិលានំ ឧបដ្ឋាតុំ វា ឧបដ្ឋាបេតុំ វា ឧប្បន្នំ អនភិរតឹ វូបកាសេតុំ វា វូបកាសាបេតុំ វា ឧប្បន្នំ កុក្កុច្ចំ ធម្មតោ វិនោទេតុំ វា វិនោទាបេតុំ វា អាបត្តឹ ជានាតិ អាបត្តិយា វុដ្ឋានំ ជានាតិ ទសវស្សោ វា ហោតិ អតិរេកទសវស្សោ វា ។ អបរេហិបិ ឆហង្គេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ និស្សយោ ទាតព្វោ

ឯកុត្តរិកៈ ឆក្កៈ អង្គ ៦ របស់ឧបជ្ឈាយ៍

គួរឲ្យសាមណេរបម្រើខ្លួនបាន គឺជាភិក្ខុមានសេចក្ដីជឿត្រូវ ១ មានសេចក្ដីខ្មាសបាប ១ មានសេចក្ដីក្រែងខ្លាចបាប ១ ប្រារព្ធសេចក្ដីព្យាយាម ១ មានសតិខ្ជាប់ខ្លួន ១ មានវស្សា ១០ ឬមានវស្សាលើសអំពី ១០ ឡើងទៅ ១ ៗ ភិក្ខុដែលប្រកបដោយអង្គ ៦ ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុមិនវិបត្តិចាកសីលក្នុងអធិសីល ១ មិនវិបត្តិចាកមារយាទក្នុងអជ្ឈាចារៈ ១ មិនវិបត្តិចាកទិដ្ឋិក្នុងអតិទិដ្ឋិ ១ ជាអ្នកចេះដឹងច្រើន ១ មានប្រាជ្ញា ១ មានវស្សា ១០ ឬមានវស្សាលើសអំពី ១០ ឡើងទៅ ១ ៗ ភិក្ខុដែលប្រកបដោយអង្គ ៦ ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុជាអ្នកអាចនឹងបម្រើ ឬប្រើគេឲ្យបម្រើនូវអន្តេវាសិកក្ដី សទ្ធិវិហារិកក្ដីដែលមានជម្ងឺ ១ អាចនឹងបំបាត់ឬប្រើគេឲ្យបំបាត់នូវសេចក្ដីអផ្សុកដែលកើតឡើង ១ អាចនឹងបន្ទោបង់ឬប្រើគេឲ្យបន្ទោបង់តាមធម៌នូវសេចក្ដីសង្ស័យដែលកើតឡើង ១ ស្គាល់អាបត្តិ ១ ស្គាល់ការចេញចាកអាបត្តិ ១ មានវស្សា ១០ ឬមានវស្សាច្រើនជាង ១០ ឡើងទៅ ១ ៗ ភិក្ខុដែលប្រកបដោយអង្គ ៦ ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យ

សាមណេរោ ឧបដ្ឋាបេតព្វោ បដិពលោ ហោតិ អន្តេវាសឹ វា សទ្ធិវិហារឹ វា អភិសមាចារិកាយ សិក្ខាយ សិក្ខាបេតុំ អាទិព្រហ្មចរិយកាយ សិក្ខាយ វិនេតុំ អភិធម្មេ វិនេតុំ អភិវិនយេ វិនេតុំ ឧប្បន្នំ ទិដ្ឋិគតំ ធម្មតោ វិវេចេតុំ ទសវស្សោ វា ហោតិ អតិរេកទសវស្សោ វា ។ អបរេហិបិ ឆហង្គេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ និស្សយោ ទាតព្វោ សាមណេរោ ឧបដ្ឋាបេតព្វោ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ ទសវស្សោ វា ហោតិ អតិរេកទសវស្សោ វា ។

(៧៣) ឆ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ ឆ ធម្មិកានិ បាតិមោក្ខដ្ឋបនានីតិ ។

សាមណេរបម្រើខ្លួនបាន គឺភិក្ខុជាអ្នកអាចឲ្យអន្តេវាសិក ឬសទ្ធិវិហារិកសិក្សាក្នុងអភិសមាចារិកាសិក្ខាបាន ១ អាចទូន្មានក្នុងអាទិព្រហ្មចរិយកាសិក្ខា ១ អាចទូន្មានក្នុងអភិធម្ម ១ អាចទូន្មានក្នុងអភិវិន័យ ១ អាចដោះតាមធម៌នូវទិដ្ឋិខុសដែលកើតឡើង ១ មានវស្សា ១០ ឬមានវស្សាច្រើនជាង ១០ ឡើងទៅ ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៦ ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ភិក្ខុនោះចេះបាតិមោក្ខទាំងពីរដោយពិស្តារ ចេះចែកបទភាជនៈដោយប្រពៃ ចាំស្ទាត់រត់មាត់ដោយប្រពៃ កាត់សេចក្តីដោយប្រពៃ តាមសុត្តៈ គឺខន្ធកៈនិងបរិវារៈ តាមអនុព្យញ្ជនៈ គឺអក្ខរៈនិងបទ ១ មានវស្សា ១០ ឬមានវស្សាច្រើនជាង ១០ ឡើងទៅ ១ ។

(៧៣) ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌មាន ៦ ។ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌មាន ៦ ។

ចប់ ឆកៈ (ពួកប្រាំមួយៗ) ។

ឯកុត្តរិកំ ឆក្កំ ឧទ្ទានគាថា

តស្សុទ្ទានំ

(៧៤) អគារវា គារវា ច
វិនីតា សាមិចីបិ ច
សមុដ្ឋានា ចេតនា ចេវ
អកាវានិសំសេន ច
បរមានិ ច ឆារត្តំ
ចីវរំ រជនានិ ច[១]
កាយតោ ចិត្តតោ ចាបិ
វាចតោ ចិត្តតោបិ ច[២]
កាយវាចាចិត្តតោ ច
កម្មវិវាទមេវ ច
អនុវាទា ទីឃសោ ច
តិរិយំ និស្សយេន ច
អនុប្បញ្ញត្តិ អាទាយ
សមាទាយ តថេវ ច
អសេខេ សមាទបេតា

១-២ ឱ. ឆ ។

ឯកុត្តរិកៈ ឆក្កៈ ឧទ្ទានគាថា

ឧទ្ទាន គឺបញ្ជីរឿងនៃឆក្កៈនោះដូច្នោះ

[៧៨] និយាយអំពីអគារវៈ ១ គារវៈ ១ វិនីតវត្ថុ ១ សិក្ខាបទដែលមានពាក្យថាប្រព្រឹត្តដោយសមគួរ ១ សមុដ្ឋាននៃអាបត្តិ ១ អាបត្តិមានកិរិយាគាត់ជាវិនយកម្ម ១ អាការដែលត្រូវអាបត្តិ ១ អានិសង្ស ១ សិក្ខាបទដែលមានទីកំណត់ ១ នៅប្រាសចាកត្រៃចីវរ ៦ រាត្រី ១ ចីវរ ១ ទឹកជ្រលក់ ១ អាបត្តិតាំងឡើងតែអំពីកាយនឹងចិត្ត ១ អាបត្តិតាំងឡើងតែអំពីវាចានឹងចិត្ត ១ អាបត្តិតាំងឡើងអំពីកាយនឹងវាចានឹងចិត្ត ១ សង្ឃកម្ម ១ វិវាទមូល ១ អនុវាទមូល ១ ប្រមាណបណ្តាយនឹងប្រមាណទទឹង ១ ការរម្ងាប់ចាកនិស្ស័យ ១ អនុប្បញ្ញត្តិ ១ ភិក្ខុកាន់យកចីវរដែលធ្វើមិនទាន់ស្រេចហើយចៀសចេញទៅ ១ ភិក្ខុប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចហើយចៀសចេញទៅ ១ ភិក្ខុដឹកនាំអ្នកដទៃក្នុងសីលជារបស់អសេក្ខបុគ្គលជាដើម ១ ភិក្ខុមានសេចក្តីជឿត្រូវ ១

សេក្ខា អធិសីលេន ច

តិលាឆាតិសមាចារិ

អាបត្តាធម្មធម្មិកាតិ ។

(៧៩) សត្ត អាបត្តិយោ ។ សត្ត អាបត្តិក្ខន្ធា ។ សត្ត វិនីតវត្ថូនិ ។ សត្ត សាមីចិយោ ។ សត្ត អធម្មិកា បដិញ្ញាតករណា ។ សត្ត ធម្មិកា បដិញ្ញាតករណា ។ សត្តន្នំ អនាបត្តិ សត្តាហករណីយេន គន្តុំ ។ សត្តានិសំសា វិនយធរេ ។ សត្ត បរមានិ ។ សត្ត អរុណុគ្គមនេ និស្សគ្គិយំ ហោតិ ។ សត្ត សមថា ។ សត្ត កម្មានិ ។ សត្ត អាមកធញ្ញានិ ។ តិរិយំ សត្តន្តរា ។ សត្ត គណភោជនេ អនុប្បញ្ញត្តិយោ ។ ភេសជ្ជានិ បដិគ្គហេត្វា សត្តាហបរមំ សន្និធិការកំ បរិភុញ្ជិតព្វានិ ។ កតចីវរំ អាទាយ បក្កមតិ ។ កតចីវរំ

ភិក្ខុប្រកបដោយអធិសីល ១ ភិក្ខុអាចបម្រើកូនសិស្សដែលមានជម្ងឺបាន ១ ភិក្ខុអាចបង្រៀនកូនសិស្សក្នុងអភិសមាចារិកា-សិក្ខា ១ ភិក្ខុស្គាល់អាបត្តិ ១ បញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ១ បញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ១ ។

(៧៤) អាបត្តិមាន ៧ យ៉ាង ។ កងនៃអាបត្តិមាន ៧ ។ វិនីតវត្ថុមាន ៧ យ៉ាង ។ សិក្ខាបទដែលមាន ពាក្យថាប្រព្រឹត្តដោយសមគួរមាន ៧ ។ សមថៈឈ្មោះបដិញ្ញាតករណៈ មិនប្រកបដោយធម៌មាន ៧ យ៉ាង ។ សមថៈឈ្មោះបដិញ្ញាតករណៈប្រកបដោយធម៌មាន ៧ យ៉ាង ។ ភិក្ខុទៅដោយសត្តាហកិច្ចមិនត្រូវអាបត្តិ ព្រោះអាស្រ័យបុគ្គល ៧ ពួក ។ ភិក្ខុអ្នកទ្រទ្រង់វិន័យតែងបានអានិសង្ស ៧ យ៉ាង ។ សិក្ខាបទដែលមានទីកំណត់មាន ៧ យ៉ាង ។ វត្ថុដែលជានិស្សគ្គិយៈក្នុងខណៈអរុណរះឡើងមាន ៧ យ៉ាង ។ សមថៈមាន ៧ យ៉ាង ។ សង្ឃកម្មមាន ៧ យ៉ាង ។ ស្រូវស្រស់មាន ៧ ប្រការ ។ ខ្នាតទទឹងក្នុង ៧ ចំអាម (ត្រូវវាស់ខាងក្នុងជញ្ជាំង) ។ អនុប្បញ្ញត្តិក្នុងគណភោជនសិក្ខាបទមាន ៧ លើក ។ ភេសជ្ជៈ (ដែលជាសត្តាហកាលិក) ភិក្ខុត្រូវទទួលសន្សំទុកឆាន់បានតែត្រឹម ៧ ថ្ងៃ ។ ភិក្ខុកាន់យកចីវរដែលធ្វើស្រេចហើយចៀសចេញទៅ ។ ភិក្ខុប្រមូលយកចីវរ

សមាទាយ បក្កមតិ ។ ភិក្ខុស្ស ន ហោតិ អាបត្តិ ទដ្ឋព្វា ។ ភិក្ខុស្ស ហោតិ អាបត្តិ ទដ្ឋព្វា ។ ភិក្ខុស្ស ហោតិ អាបត្តិ បដិកាតព្វា ។ សត្ត អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ សត្ត ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(៧៦) សត្តហង្គេហិ សមន្នាគតោ ភិក្ខុ វិនយធរោ ហោតិ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អបរេហិបិ សត្តហង្គេហិ

ដែលធ្វើស្រេចហើយចៀសចេញទៅ ។ អាបត្តិដែលមិនមានដល់ភិក្ខុបណ្ឌិតគប្បីឃើញ ។ អាបត្តិដែលមានដល់ភិក្ខុ គឺបណ្ឌិតគប្បីឃើញ ។ អាបត្តិដែលមានដល់ភិក្ខុ បណ្ឌិតគប្បីរម្ងាប់ចេញ ។ ការបញ្ញប់បាតិមោក្ខដែលមិនប្រកបដោយធម៌មាន ៧ យ៉ាង ។ ការបញ្ញប់បាតិមោក្ខដែលប្រកបដោយធម៌មាន ៧ យ៉ាង ។

(៧៦) ភិក្ខុដែលប្រកបដោយអង្គ៧ បានឈ្មោះថាជាវិន័យធរ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកមានសីលនឹងសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនឹងគោចរៈ ឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច ហើយសមាទានសិក្សាក្នុងសិក្ខាបទ ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈានទាំឲ្យនៅជាសុខ ក្នុងបច្ចុប្បន្ន ១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈហើយដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) ក្នុងបច្ចុប្បន្ន ១ ។ ភិក្ខុដែលប្រកបដោយអង្គ ៧ ដទៃទៀត បាន

សមន្នាគតោ ភិក្ខុ វិនយធរោ ហោតិ អាបត្តិំ ជានាតិ អនាបត្តិំ ជានាតិ លហុកំ អាបត្តិំ ជានាតិ គរុកំ អាបត្តិំ ជានាតិ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ ៖ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អបរេហិបិ សត្តហាការេហិ សមន្នាគតោ ភិក្ខុ វិនយធរោ ហោតិ អាបត្តិំ ជានាតិ អនាបត្តិំ ជានាតិ លហុកំ អាបត្តិំ ជានាតិ គរុកំ អាបត្តិំ ជានាតិ ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ

ឈ្មោះថាជាវិនយធរ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ធម៌ដែលពីរោះខាងដើម ពីរោះកណ្ដាល ពីរោះខាងចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធគ្រប់គ្រាន់ទាំងអស់ ធម៌ដែលមានសភាពដូច្នោះ ភិក្ខុនោះបានចេះដឹងច្រើន បានទ្រទ្រង់ បានចាំស្ទាត់រត់មាត់ បានចូលចិត្តច្បាស់លាស់ បានយល់ជ្រាលជ្រៅដោយទិដ្ឋិ គឺបញ្ញា ១ ជាអ្នកបានដូចសេចក្ដីប្រាថ្នា បានដោយមិនលំបាក បានដោយធំទូលាយ នូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈានទាំងឡាយនៅជាសុខក្នុងបច្ចុប្បន្ន ១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) ក្នុងបច្ចុប្បន្ន ១ ៗ ភិក្ខុដែលប្រកបដោយអង្គ៧ដទៃទៀត បានឈ្មោះថាជាវិនយធរ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ភិក្ខុនោះចេះចាំបាតិមោក្ខទាំងពីរដោយពិស្ដារ ចេះចែកបទភាជនៈដោយប្រពៃ ចាំស្ទាត់រត់មាត់ដោយប្រពៃ ចេះកាត់សេចក្ដីដោយប្រពៃតាមសុត្តៈគឺខន្ធកៈនិងបរិវារៈ តាមអនុព្យញ្ជនៈគឺអក្ខរៈនិងបទ១

ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ
និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាស-
វានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ
ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។
អបរេហិបិ សត្តហង្គេហិ សមន្នាគតោ ភិក្ខុ វិនយធរោ
ហោតិ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ
ជានាតិ គរុកំ អាបត្តឹ ជានាតិ អនេកវិហិតំ បុព្វេនិ-
វាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិ-
យោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ
ជាតិយោ ។ បេ ។ ទសបិ ជាតិយោ វីសម្បិ ជាតិយោ
តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ
ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតស-
ហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ
អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំ-
គោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី
ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ
តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ

ជាអ្នកបានដូចសេចក្ដីប្រាថ្នា បានដោយមិនលំបាក បានដោយដ៏ទូលាយ នូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខក្នុងបច្ចុប្បន្ន ១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន១ ។ ភិក្ខុដែលប្រកបដោយអង្គ ៧ ដទៃទៀត បានឈ្មោះថាជាវិន័យធរ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ រលឹកឃើញនូវចំណែកខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនមានច្រើនប្រការ គឺរលឹកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ។ បេ ។ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១០០០០០ (១ សែន) ជាតិខ្លះ សំវដ្តកប្បជាច្រើនខ្លះ វិវដ្តកប្បជាច្រើនខ្លះ សំវដ្តវិវដ្តកប្បជាច្រើនខ្លះ ថាអាត្មាអញកើតក្នុងទីឯណោះ មានឈ្មោះយ៉ាងនោះ មានគោត្រយ៉ាងនោះ មានសម្បុរយ៉ាងនោះ មានអាហារយ៉ាងនោះ ទទួលសុខទុក្ខយ៉ាងនោះ មានអាយុកំណត់ប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកទីនោះហើយទៅកើតក្នុងទីឯណោះទៀត ដែលអាត្មាអញបានកើតក្នុងទីនោះ មានឈ្មោះយ៉ាងនោះ មានគោត្រយ៉ាងនោះ មានសម្បុរយ៉ាងនោះ មានអាហារយ៉ាងនោះ

ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន

ទទួលសុខទុក្ខយ៉ាងនោះ មានកាយុកំណត់ប៉ុណ្ណោះ លុះកាលតាមញ្ញច្យុត ចាកទីនោះហើយទើបបានមកកើតក្នុងទីនេះ ភិក្ខុនោះរលឹកនូវចំណែកខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនមានច្រើនប្រការ ព្រមទាំងអាការព្រម ទាំងឧទ្ទេសដោយប្រការដូច្នេះ ១ ភិក្ខុនោះមានចក្ខុទិព្វដ៏បរិសុទ្ធកន្លងហួស ចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុតដែលកើត ជាសត្វ ថោកទាបខ្លះ ឧត្តមខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អ ខ្លះ មានគតិអាក្រក់ខ្លះ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ ខ្លួនថា អើហ្ន៎ សត្វពួកនេះប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គល ជាអ្នកយល់ខុស ប្រកាន់ស៊ប់នូវអំពើតាមសេចក្តីយល់ខុស សត្វពួកនោះលុះមានរាងកាយ បែកធ្លាយទៅ ខាងមុខអំពីសេចក្តីស្លាប់ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ម្យ៉ាងទៀតថា អើហ្ន៎ សត្វពួកនេះ ប្រកប ដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលព្រះអរិយបុគ្គល ជាអ្នកយល់ត្រូវ ប្រកាន់ស៊ប់នូវកម្ម តាមសេចក្តីយល់ត្រូវ សត្វពួកនោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខអំពីសេចក្តីស្លាប់ រមែងទៅកើតក្នុងសុគតិ នឹងឋានសួគ៌ទេវលោក ភិក្ខុនោះមានចក្ខុទិព្វ ដ៏បរិសុទ្ធ កន្លងហួសចក្ខុ របស់មនុស្សធម្មតា

ឯកុត្តរិកំ សត្តកំ វិនយធរស្ស សត្តង្គានិ

សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ សត្តហង្គេហិ សមន្នាគតោ វិនយធរោ សោភតិ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អបរេហិបិ សត្តហង្គេហិ សមន្នាគតោ វិនយធរោ សោភតិ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា

ឯកុត្តរិកៈ សតកៈ អង្គ ៧ របស់ភិក្ខុវិន័យធរ

បានឃើញពួកសត្វដែលច្យុតដែលកើត ជាសត្វថោកទាបខ្លះ ឧត្តមខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ ១ បានធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) ក្នុងបច្ចុប្បន្ន ១ វិន័យធរដែលប្រកបដោយអង្គ ៧ រមែងល្អ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកមានសីល ១ ។ បេ ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខក្នុងបច្ចុប្បន្ន ១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន ១ ។ វិន័យធរដែលប្រកបដោយអង្គ ៧ ដទៃទៀតរមែងល្អ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកចេះចាំច្រើន ។ បេ ។ បានយល់ជ្រាលជ្រៅ

ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អបរេហិបិ សត្តហង្គេហិ សមន្នាគតោ វិនយធរោ សោភតិ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អបរេហិបិ សត្តហង្គេហិ

ដោយទិដ្ឋិគឺបញ្ញា ១ ជាអ្នកបានដូចសេចក្តីប្រថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខក្នុងបច្ចុប្បន្ន ១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤)ក្នុងបច្ចុប្បន្ន១ៗ វិន័យធរប្រកបដោយអង្គ ៧ ដទៃទៀត ក៏រមែងល្អ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ភិក្ខុនោះចេះចាំបាតិមោក្ខទាំងពីរដោយពិស្តារ ចេះវែកញែកបទភាជនៈដោយប្រពៃ ចាំស្ទាត់រត់មាត់ដោយប្រពៃ ចេះកាត់សេចក្តីដោយប្រពៃ តាមសុត្តៈគឺខន្ធកៈនិងបរិវារៈ តាមអនុព្យញ្ជនៈគឺអក្ខរៈនិងបទ១ ជាអ្នកបានដូចសេចក្តីប្រថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខក្នុងបច្ចុប្បន្ន១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន ១ ។ វិន័យធរដែលប្រកបដោយអង្គ ៧ ដទៃទៀត

ឯកុត្តរិកំ សត្តកំ សត្ត អសទ្ធម្មា សត្ត សទ្ធម្មា

សមន្នាគតោ វិនយធរោ សោភតិ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ បេ ។ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ បេ ។ អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។

(៧៧) សត្ត អសទ្ធម្មា អស្សទ្ធោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ អប្បស្សុតោ ហោតិ កុសីតោ ហោតិ មុដ្ឋស្សតិ ហោតិ ទុប្បញ្ញោ ហោតិ ។ សត្ត សទ្ធម្មា សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ ពហុស្សុតោ ហោតិ អារទ្ធវិរិយោ ហោតិ ឧបដ្ឋិតស្សតិ ហោតិ បញ្ញវា ហោតីតិ ។

សត្តកំ និដ្ឋិតំ ។

វេមនល្អ គឺស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ ១ រលឹកឃើញនូវបំណែកខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនមានច្រើនប្រការ ១ ។បេ។ មានចក្ខុទិព្វដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញពួកសត្វដែលច្យុតដែលកើត ជាសត្វថោកទាបខ្លះ ឧត្តមខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួន ១ ។ បេ ។ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន ១ ។

(៧៧) អសទ្ធម្មមាន ៧ យ៉ាង គឺបុគ្គលមិនមានសទ្ធា១ មិនខ្មាសបាប ១ មិនស្ញែងនឹងបាប ១ ចេះដឹងតិច ១ ខ្ជិលច្រអូស ភ្លេចស្មារតី ១ ឥតប្រាជ្ញា១ ។ ព្រះសទ្ធម្មមាន ៧ យ៉ាង គឺបុគ្គលមានសទ្ធា ១ ខ្មាសបាប១ ស្ញែងនឹងបាប ១ ចេះដឹងច្រើន ១ ប្រារព្ធព្យាយាម ១ មានស្មារតីខ្ជាប់ខ្ជួន១ មានប្រាជ្ញា១ ។

ចប់ សត្តកៈ (ពួកប្រាំពីរៗ) ។

តស្សុទ្ទានំ

[៧៨] អាបត្តិ អាបត្តិក្ខន្ធា
វិនីតា សាមិចីបិ ច
អធម្មិកា ធម្មិកា ច
អនាបត្តិ ច សត្តហំ
អានិសំសា បរមានិ
អរុណាសមជេន ច
កម្មា អាមកធញ្ញា ច
តិរិយំ គណភោជនេ
សត្តាហបរមាទាយ
សមាទាយ តថេវ ច
ន ហោតិ ហោតិ ហោតិ ច
អធម្មធម្មិកានិ[1] ច
ចត្តារោ វិនយធរា
ចតុភិក្ខ ច សោភណោ
សត្ត ចេវ អសទ្ធម្មា
សត្ត សទ្ធម្មទេសិតាតិ[2] ។

១ ឱ. ម. អធម្មា ធម្មិកានិ ច ។ ២ សទ្ធម្មា ទេសិតាតិបិ ។

វិនយបិដក បរិវារៈ

ឧទ្ទាន គឺបញ្ជីរឿងនៃសត្តកៈ (ពួកប្រាំពីរៗ) នោះដូច្នេះ

(៧៨) និយាយអំពីអាបត្តិ ១ កងនៃអាបត្តិ ១ វិនីតវត្ថុ ១ សិក្ខាបទមានពាក្យថាប្រព្រឹត្តដោយសមគួរ ១ បដិញ្ញាតករណៈមិនប្រកបដោយធម៌ ១ បដិញ្ញាតករណៈប្រកបដោយធម៌ ១ ទៅដោយសត្តាហកិច្ចមិនមានអាបត្តិ ១ អានិសង្សវិន័យធរ ១ សិក្ខាបទដែលមានទីកំណត់ ១ វត្ថុជានិស្សគ្គិយៈក្នុងខណៈដែលអរុណរះឡើង ១ សមថៈ ១ កម្ម ១ ស្រាវស្រស់ ១ ខ្នាតទទឹងក្នុង ១ អនុប្បញ្ញត្តិក្នុងគណភោជនសិក្ខាបទ ១ ភេសជ្ជៈភិក្ខុគួរទទួលទុកឆាន់បានកំណត់៧ថ្ងៃ១ ភិក្ខុកាន់យកចីវរដែលសម្រេចហើយចៀសចេញទៅ១ ភិក្ខុប្រមូលយកចីវរដែលសម្រេចហើយចៀសចេញទៅ១ អាបត្តិមិនមានដល់ភិក្ខុ១ អាបត្តិមានដល់ភិក្ខុ១ អាបត្តិដែលមានដល់ភិក្ខុបណ្ឌិតគប្បីរម្ងាប់ចេញ១ បញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ១ បញ្ឈប់បាតិមោក្ខប្រកបដោយធម៌១ ភិក្ខុដែលបានឈ្មោះថាជាវិន័យធរ ៤ ពួក១ ភិក្ខុ៤ពួកដែលល្អ១ អសទ្ធម្ម ៧ ប្រការ១ ព្រះសទ្ធម្ម ៧ ប្រការ ដែលព្រះមានព្រះភាគទ្រង់ទេសនាហើយ ១ ។

ឯកុត្តរិកំ អដ្ឋកំ អដ្ឋានិសំសាទយោ

(៧៩) អដ្ឋានិសំសេ សម្បស្សមានេន ន សោ ភិក្ខុ អាបត្តិយា អទស្សនេ ឧក្ខិបិតព្វោ ។ អដ្ឋានិសំសេ សម្បស្សមានេន បរេសំបិ សទ្ធាយ សា អាបត្តិ ទេសេតព្វា ។ អដ្ឋ យាវតតិយកា ។ អដ្ឋហាការេហិ កុលានិ ទូសេតិ ។ អដ្ឋ មាតិកា ចីវរស្ស ឧប្បាទាយ ។ អដ្ឋ មាតិកា កឋិនស្ស ឧព្ភារាយ ។ អដ្ឋ បានានិ ។ អដ្ឋហិ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ អដ្ឋ លោកធម្មា ។ អដ្ឋ គរុធម្មា ។ អដ្ឋ បាដិទេសនីយា ។ អដ្ឋង្គិកោ មុសាវាទោ ។ អដ្ឋ ឧបោសថង្គានិ ។ អដ្ឋ ទូតេយ្យង្គានិ ។ អដ្ឋ តិត្ថិយវត្តានិ ។ អដ្ឋ អច្ឆរិយា អព្ភុតា ធម្មា មហាសមុទ្ទេ ។ អដ្ឋ អច្ឆរិយា អព្ភុតា ធម្មា ឥមស្មឹ ធម្មវិនយេ ។ អដ្ឋ អនតិរិត្តា ។ អដ្ឋ អតិរិត្តា ។ អដ្ឋមេ អរុណុគ្គមនេ និស្សគ្គិយំ ហោតិ ។ អដ្ឋ បារាជិកា ។ អដ្ឋមំ វត្ថុំ បរិបូរេន្តី នាសេតព្វា ។ អដ្ឋមំ វត្ថុំ បរិបូរេន្តិយា ទេសិតាបិ អទេសិតាបិ(១) ហោតិ ។

---

១ ឱ. ម. ទេសិតំបិ អទេសិតំបិ ។

(៧៩) កាលបើភិក្ខុបានឃើញច្បាស់នូវអានិសង្ស ៨ ប្រការហើយ មិនត្រូវលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិឡើយ ។ កាលបើភិក្ខុបានឃើញនូវអានិសង្ស ៨ ប្រការហើយ ត្រូវសំដែងអាបត្តិនោះចេញដោយសេចក្តីជឿពាក្យភិក្ខុឯទៀត ។ សិក្ខាបទជាយាវតតិយកាមាន ៨ ។ ភិក្ខុទ្រុស្តត្រកូលដោយប្រការ ៨ យ៉ាង ។ មាតិកា ៨ យ៉ាងនាំឲ្យកើតបំ-វរ ។ មាតិកា ៨ យ៉ាងនាំឲ្យដោះកឋិន ។ ទឹកបានមាន ៨ យ៉ាង ។ ទេវទត្តត្រូវអសទ្ធម្ម ៨ ប្រការគ្របសង្កត់ហើយ មានចិត្តគឺអសទ្ធម្មរួបរឹតហើយ ក៏ធ្លាក់ទៅក្នុងទីមិនចំរើន ធ្លាក់ទៅនរក តាំងនៅអស់ ១ កប្ប រកអ្នកណាកែមិនកើត ។ លោកធម៌មាន ៨ ប្រការ ។ គរុធម៌មាន ៨ ប្រការ ។ បាដិទេសនីយសិក្ខាបទមាន ៨ ។ មុសាវាទប្រកបដោយអង្គ ៨ ។ អង្គរបស់ឧបោសថមាន ៨ ។ អង្គរបស់ភិក្ខុដែលជាទូត (អ្នកទទួលបម្រើ) មាន ៨ ។ វត្តរបស់ពួកតិរ្ថិយមាន ៨ ។ ធម៌ជាអស្ចារ្យចំឡែកក្នុងមហា-សមុទ្រមាន ៨ ។ ធម៌ជាអស្ចារ្យចំឡែកក្នុងធម៌វិន័យនេះមាន ៨ ។ អនតិ-រិត្តភោជនមាន ៨ ។ អតិរិត្តភោជនមាន ៨ ។ វត្ថុដែលជានិស្សគ្គិយៈក្នុងខណៈអរុណរះឡើងជាគំរប់ ៨ ។ បារាជិកសិក្ខាបទមាន ៨ ។ ភិក្ខុនីធ្វើវត្ថុទី៨ ឲ្យពេញ សង្ឃត្រូវឲ្យវិនាស ។ អាបត្តិដែលភិក្ខុនីធ្វើវត្ថុទី ៨ ឲ្យពេញ សំដែងចេញបានក៏មាន សំដែងចេញមិនបានក៏មាន ។

អដ្ឋវាចិកា ឧបសម្បទា ។ អដ្ឋន្នំ បច្ចុដ្ឋាតព្វំ ។ អដ្ឋន្នំ អាសនំ ទាតព្វំ ។ ឧបាសិកា អដ្ឋ វរានិ យាចិ ។ អដ្ឋហង្គេហិ សមន្នាគតោ ភិក្ខុ ភិក្ខុនោវាទកោ សម្មន្និតព្វោ ។ អដ្ឋានិសំសា វិនយធរេ ។ អដ្ឋ បរមានិ ។ តស្សបាបិយសិកាកម្មកតេន ភិក្ខុនា អដ្ឋសុ ធម្មេសុ សម្មាវត្តិតព្វំ ។ អដ្ឋ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ អដ្ឋ អធម្មិកានិ បាតិមោក្ខដ្ឋបនានីតិ ។

អដ្ឋកំ និដ្ឋិតំ ។

តស្សុទ្ទានំ

(៨០) ន សោ ភិក្ខុ បរេសម្បិ

យោវទតិយទូសនា[១] ។

មាតិកា កាបិន្ភុក

ធាធា អភិក្កេន ច

លោកធម្មា តរុធម្មា

បាដិទេសនិយា មុសា

ឧបោសថា ច ទូតដ្ឋា

---

១ ឱ. យោវទតិយំ ទូសនា ។

ឧបសម្បទាប្រកបដោយកម្មវាចា ៨ លើក ៗ ត្រូវក្រោកទៅទទួលបុគ្គល ៨ ពួក ៗ ត្រូវឲ្យអាសនៈដល់បុគ្គល ៨ ពួក ៗ ឧបាសិកាបានសូមពរទាំង ៨ ប្រការ ៗ ភិក្ខុប្រកបដោយអង្គ ៨ សង្ឃគួរសន្មតឲ្យជាអ្នកប្រដៅភិក្ខុនី ៗ អានិសង្សវិន័យធរមាន ៨ ៗ សិក្ខាបទដែលមានទីកំណត់មាន ៨ ៗ ភិក្ខុដែលសង្ឃធ្វើតស្សបាបិយសិកាកម្មហើយ គួរប្រព្រឹត្តដោយប្រពៃ ក្នុងធម៌ទាំង៨ ប្រការ ៗ ការបញ្ឈប់បាតិមោក្ខដែលមិនប្រកបដោយធម៌មាន ៨ ៗ ការបញ្ឈប់បាតិមោក្ខដែលប្រកបដោយធម៌មាន ៨ ៗ

ចប់ អដ្ឋកៈ (ពួកប្រាំបី) ។

ឧទ្ទាន គឺបញ្ជីរឿងនៃអដ្ឋកៈ (ពួកប្រាំបី) នោះដូច្នេះ

(៨០) និយាយអំពីភិក្ខុមិនត្រូវលើកវត្តភិក្ខុនោះ ១ ភិក្ខុគួរសំដែងអាបត្តិដោយជឿពាក្យភិក្ខុឯទៀត ១ សិក្ខាបទជាយាវតតិយកា ១ ភិក្ខុទ្រុស្តត្រកូល ១ ៗ មាតិកានាំឲ្យកើតបវារ ១ មាតិកានាំឲ្យដោះកឋិន ១ ទឹកបាន ១ ទេវទត្តត្រូវអសទ្ធម្មគ្របសង្កត់ ១ លោកធម៌ ១ គរុធម៌ ១ បាដិទេសនីយសិក្ខាបទ ១ មុសាវាទ ១ ឧបោសថ ១ អង្គរបស់ភិក្ខុជាទូត ១

ឯកុត្តរិកំ នវកំ នវាឃាតវត្ថុអាទីនិ

អិត្តិកា សមុដ្ឋិបិ ច
អត្រុតា អនតិរិត្តំ
អតិរិត្តំ និស្សគ្គិយំ
ចាភជិតកជ្ជមំ វត្ថុំ
អទេសិត្វូបសម្បទា
បច្ចុដ្ឋានាសនញ្ចេវ
វំ ទ្វិភនភោន ច
អានិសំសា បរមានិ
អដ្ឋធម្មេសុ វត្តនា
អធម្មិកា ធម្មិកា ច
អដ្ឋកា សុប្បកាសិតាតិ ។

[៨១] នវ អាឃាតវត្ថូនិ ។ នវ អាឃាតប្បដិវិនយា ។ នវ វិនីតវត្ថូនិ ។ នវ បឋមាបត្តិកា ។ នវហិ សង្ឃោ ភិជ្ជតិ ។ នវ បណីតភោជនានិ ។ នវមំសេហិ ទុក្កដំ ។ នវ បាតិមោក្ខុទ្ទេសា ។ នវ បរមានិ ។ នវ តណ្ហាមូលកា ធម្មា ។ នវវិធមានា ។ នវ ចីវរានិ

វត្តិរ័យ១ ធម៌ឯអស្ចារ្យចំឡែកក្នុងមហាសមុទ្ទ១ អនតិរិត្តភោជនៈ១ អតិរិត្តភោជន១ និស្សគ្គិយវត្ថុ១ បារាជិកសិក្ខាបទ១ ភិក្ខុនីធ្វើវត្ថុទី ៨ ឲ្យពេញ ១ អាបត្តិដែលភិក្ខុនីសំដែងមិនបាន១ ឧបសម្បទា១ ការក្រោកទទួល១ ឲ្យអាសនៈ១ ឧបាសិកាសូមពរ១ ភិក្ខុដែលសង្ឃគួរសន្មតឲ្យប្រដៅភិក្ខុនី ១ អានិសង្សវិន័យធរ ១ សិក្ខាបទដែលមានទីណាត់ ១ ភិក្ខុគួរប្រព្រឹត្តក្នុងធម៌ ៨ ប្រការ ១ បញ្ញប់បាតិមោក្ខមិនប្រកបដោយធម៌១ បញ្ញប់បាតិមោក្ខប្រកបដោយធម៌១ ពួកធម៌ប្រាំបី ៗ (នេះ) ព្រះសម្ពុទ្ធទ្រង់សំដែងទុកមកដោយល្អហើយ ។

[៨១] អាឃាតវត្ថុ គឺវត្ថុជាទីកើតនៃគំនុំមាន ៩ ។ ធម៌សម្រាប់កំចាត់នូវគំនុំមាន ៩ ។ វិនីតវត្ថុមាន ៩ ។ អាបត្តិជាបឋមាបត្តិកា (ដែលត្រូវជាដំបូង)មាន ៩ ។ សង្ឃបែកគ្នាដោយធម៌ ៩ ប្រការ ។ ភោជនឧត្តមមាន ៩ យ៉ាង ។ ភិក្ខុត្រូវទុក្កដព្រោះឆាន់សាច់ ៩ យ៉ាង ។ ឧទ្ទេសរបស់បាតិមោក្ខមាន ៩ ។ សិក្ខាបទដែលមានទីកំណត់មាន ៩ ។ ធម៌ដែលមានតណ្ហាជាមូលមាន ៩ ។ មានះមាន ៩ ប្រការ ។ ចីវរ ៩ ប្រការ

អធិដ្ឋាតព្វានិ ។ ទ្វេ ចីវរានិ ន វិកប្បេតព្វានិ ។ ទីយសោ ទ្វេ វិនត្តិយោ សុត្តវិនត្តិយោ ។ ទ្វេ អធម្មិកានិ ទានានិ ។ ទ្វេ អធម្មិកា បដិគ្គហា ។ ទ្វេ អធម្មិកា បរិភោគា ។ តីណិ ធម្មិកានិ ទានានិ ។ តយោ ធម្មិកា បដិគ្គហា ។ តយោ ធម្មិកា បរិភោគា ។ ទ្វេ អធម្មិកា សញ្ញត្តិយោ ។ ទ្វេ ធម្មិកា សញ្ញត្តិយោ ។ អធម្មកម្មេ ទ្វេ ទ្វេកានិ ។ ធម្មកម្មេ ទ្វេ ទ្វេកានិ ។ ទ្វេ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ ទ្វេ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

ទុកំ និដ្ឋិតំ ។

តស្សុទ្ទានំ

[៨២] អាយាតវត្ថុវិនយា[១]
វិធីតា បឋមេន ច
ភិជ្ជិត ច បណីតញ្ច
មំសុទ្ទសបរមានិ ច

១ ឱ. អាយាគតវត្ថូនិ វិនយា ។

ភិក្ខុគួរអធិដ្ឋាន ១ ចីវរ ៩ ប្រការ ភិក្ខុមិនគួរវិកប្ប ១ បណ្ដោយ (ចីវរព្រះសុគត) ៩ ចំអាម ដោយចំអាមព្រះសុគត ១ ទានដែលមិនប្រកបដោយធម៌មាន ៩ យ៉ាង ១ ការទទួលដែលមិនប្រកបដោយធម៌មាន ៩ យ៉ាង ១ បរិភោគដែលមិនប្រកបដោយធម៌មាន ៩ យ៉ាង ១ ទានដែលប្រកបដោយធម៌មាន ៣ យ៉ាង ១ ការទទួលដែលប្រកបដោយធម៌មាន ៣ យ៉ាង ១ បរិភោគដែលប្រកបដោយធម៌មាន ៣ យ៉ាង ១ ការពន្យល់ ឬបញ្ជាក់ដែលមិនប្រកបដោយធម៌មាន៩ យ៉ាង ១ ការពន្យល់ ឬបញ្ជាក់ដែលប្រកបដោយធម៌មាន ៩ យ៉ាង ១ នវកៈមាន ២ ក្នុងកម្មដែលមិនប្រកបដោយធម៌ ១ នវកៈមាន ២ ក្នុងកម្មដែលប្រកបដោយធម៌ ១ ការបញ្ចប់ធាតុមោក្ខដែលមិនប្រកបដោយធម៌មាន ៩ ១ ការបញ្ចប់ធាតុមោក្ខដែលប្រកបដោយធម៌មាន ៩ ១

ចប់ នវកៈ (ពួកប្រាំបួន ១) ។

ឧទ្ទាន គឺបញ្ជីរឿងនៃនវកៈ (ពួកប្រាំបួនៗ) នោះដូច្នេះ

[៨២] និយាយអំពីវត្ថុជាទីកើតគំនុំ ១ ធម៌សម្រាប់កំចាត់គំនុំ ១ វិនីតវត្ថុ ១ អាបត្តិជាបឋមាបត្តិកា ១ សង្ឃភេទកា ១ ភោជនទុក្ខ ១ ភិក្ខុត្រូវទុកដាក់ព្រោះធានសាប ១ ទោស-របស់ធាតុមោក្ខ ១ សិក្ខាបទដែលមានទីកំណត់ ១ ធម៌ដែល

តណ្ហា មានា អភិជ្ឈា ធា
វិកាប្យេ ច វិនត្តិយោ
ចារា បដិគ្គហា កោតា
តិវិធា បុន ធម្មិកា
អធម្មធម្មសញ្ញត្តិ[(១)]
ទុវេ ទ្វេ នវកានិ ច
ទាតិមោក្ខុទ្ទេសនានិ
អធម្មធម្មិកានិ ចាតិ[(២)] ។

(៨៣) ទស អាឃាតវត្ថូនិ ។ ទស អាឃាតប្បដិវិនយា ។ ទសវីធិតវត្ថូនិ ។ ទសវត្ថុកា មិច្ឆាទិដ្ឋិ ។ ទសវត្ថុកា សម្មាទិដ្ឋិ ។ ទស អន្តគ្គាហិកា ទិដ្ឋិ ។ ទស មិច្ឆត្តា ។ ទស សម្មត្តា ។ ទស អកុសលកម្មបថា ។ ទស កុសលកម្មបថា ។ ទស អធម្មិកា សលាកគ្គាហា ។ ទស ធម្មិកា សលាកគ្គាហា ។ សាមណេរានំ ទស សិក្ខាបទានិ ។ ទសហង្គេហិ សមន្នាគតោ សាមណេរោ នាសេតព្វោ ។

១ ឱ. អធម្មំ ធម្មសញ្ញត្តិ ។ ម. អធម្មធម្មបញ្ញត្តិ ។ ២ ឱ. ឃាតិមោក្ខុទ្ទេសនានិ ច អធម្មិកា ធម្មិកានិ ចាតិ ។

ឯកុត្តរិកៈ ទសកៈ វត្ថុជាទីកើតគំនុំទាំង ១០ ជាដើម

មានតណ្ហាជាមូល ១ មានះ ១ អធិដ្ឋាន ១ វិកប្ប ១ បំអាមព្រះសុគត ១ ទាន ១ ការទទួល ១ ការបរិភោគ ១ ទាននឹងការទទួលនឹងការបរិភោគ ដែលប្រកបដោយធម៌មាន ៣ ប្រការ ១ ពន្យល់ឬបញ្ជាក់មិនប្រកបដោយធម៌ ១ ពន្យល់ឬបញ្ជាក់ប្រកបដោយធម៌ ១ នវកៈពីរពួក ២ ដង ១ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ១ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ១ ។

(៨៣) វត្ថុជាទីកើតគំនុំមាន ១០ ។ ធម៌សម្រាប់កំចាត់នូវគំនុំមាន ១០ ។ វិនីតវត្ថុមាន ១០ ។ មិច្ឆាទិដ្ឋិមានវត្ថុ ១០ ។ សម្មាទិដ្ឋិមានវត្ថុ ១០ ។ ទិដ្ឋិឈ្មោះអន្តគ្គាហិកាមាន ១០ ។ មិច្ឆត្តធម៌មាន ១០ ។ សម្មត្តធម៌មាន ១០ ។ អកុសលកម្មបថមាន ១០ ។ កុសលកម្មបថមាន ១០ ។ ការចាប់ស្លាកដែលមិនប្រកបដោយធម៌មាន ១០ ។ ការចាប់ស្លាកដែលប្រកបដោយធម៌មាន ១០ ។ សិក្ខាបទរបស់សាមណេរមាន ១០ ។ សាមណេរប្រកបដោយអង្គ ១០ គួរឲ្យវិនាស ។

(៨៤) ឆហាការេហិ សមន្នាគតោ វិនយធរោ ពាលោត្វេវ សង្ខ្យំ គច្ឆតិ អត្តនោ ភាសបរិយន្តំ ន ឧគ្គណ្ហាតិ បរស្ស ភាសបរិយន្តំ ន ឧគ្គណ្ហាតិ អត្តនោ ភាសបរិយន្តំ អនុគ្គហេត្វា បរស្ស ភាសបរិយន្តំ អនុគ្គហេត្វា អធម្មេន ការេតិ អប្បដិញ្ញាយ អាបត្តឹ ន ជានាតិ អាបត្តិយា មូលំ ន ជានាតិ អាបត្តិសមុទយំ ន ជានាតិ អាបត្តិនិរោធំ ន ជានាតិ អាបត្តិនិរោធគាមិនឹ បដិបទំ ន ជានាតិ ។ ឆហាការេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោត្វេវ សង្ខ្យំ គច្ឆតិ អត្តនោ ភាសបរិយន្តំ ឧគ្គណ្ហាតិ បរស្ស ភាសបរិយន្តំ ឧគ្គណ្ហាតិ អត្តនោ ភាសបរិយន្តំ ឧគ្គហេត្វា បរស្ស ភាសបរិយន្តំ ឧគ្គហេត្វា ធម្មេន ការេតិ បដិញ្ញាយ អាបត្តឹ ជានាតិ អាបត្តិយា មូលំ ជានាតិ អាបត្តិសមុទយំ ជានាតិ អាបត្តិនិរោធំ ជានាតិ អាបត្តិនិរោធគាមិនឹ បដិបទំ ជានាតិ ។ អបរេហិបិ ឆហាការេហិ សមន្នាគតោ វិនយធរោ ពាលោត្វេវ

(៨៤) វិន័យធរដែលប្រកបដោយអង្គ ១០ ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនរៀនទីកំណត់ភាសារបស់ខ្លួន ១ មិនរៀនទីកំណត់ភាសារបស់ជាតិដទៃ ១ លុះមិនរៀនទីកំណត់ភាសារបស់ខ្លួនហើយកាត់សេចក្តីមិនត្រូវតាមធម៌ ១ លុះមិនរៀនទីកំណត់ភាសារបស់ជាតិដទៃហើយកាត់សេចក្តីមិនត្រូវតាមធម៌ ១ កាត់សេចក្តីមិនត្រូវតាមពាក្យប្តេជ្ញា ១ មិនស្គាល់អាបត្តិ ១ មិនស្គាល់មូលនៃអាបត្តិ ១ មិនស្គាល់ហេតុឲ្យកើតអាបត្តិ ១ មិនស្គាល់សេចក្តីរលត់នៃអាបត្តិ ១ មិនស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់នៃអាបត្តិ ១ ។ វិន័យធរដែលប្រកបដោយអង្គ ១០ ដល់នូវការរាប់ថាជាបណ្ឌិត គឺរៀនទីកំណត់ភាសារបស់ខ្លួន ១ រៀនទីកំណត់ភាសារបស់ជាតិដទៃ ១ លុះរៀនទីកំណត់ភាសារបស់ខ្លួនហើយកាត់សេចក្តីត្រូវតាមធម៌ ១ លុះរៀនទីកំណត់ភាសារបស់ជាតិដទៃហើយកាត់សេចក្តីត្រូវតាមធម៌ ១ កាត់សេចក្តីត្រូវតាមពាក្យប្តេជ្ញា ១ ស្គាល់អាបត្តិ ១ ស្គាល់មូលនៃអាបត្តិ ១ ស្គាល់ហេតុឲ្យកើតអាបត្តិ ១ ស្គាល់សេចក្តីរលត់នៃអាបត្តិ ១ ស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់នៃអាបត្តិ ១ ។ វិន័យធរដែលប្រកបដោយអង្គ ១០ ដទៃទៀត ក៏ដល់នូវការរាប់ថាជាបុគ្គលពាល

ឯកុត្តរិកំ ទសកំ វិនយធរស្ស ទសង្គានិ

សង្ខំ គច្ឆតិ អធិករណំ ន ជានាតិ អធិករណស្ស មូលំ ន ជានាតិ អធិករណសមុទយំ ន ជានាតិ អធិករណនិរោធំ ន ជានាតិ អធិករណនិរោធគាមិនឹ បដិបទំ ន ជានាតិ វត្ថុំ ន ជានាតិ និទានំ ន ជានាតិ បញ្ញត្តឹ ន ជានាតិ អនុប្បញ្ញត្តឹ ន ជានាតិ អនុសន្ធិវចនបថំ ន ជានាតិ ។ ទសហង្គេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ អធិករណំ ជានាតិ អធិករណស្ស មូលំ ជានាតិ អធិករណសមុទយំ ជានាតិ អធិករណនិរោធំ ជានាតិ អធិករណនិរោធគាមិនឹ បដិបទំ ជានាតិ វត្ថុំ ជានាតិ និទានំ ជានាតិ បញ្ញត្តឹ ជានាតិ អនុប្បញ្ញត្តឹ ជានាតិ អនុសន្ធិវចនបថំ ជានាតិ ។ អបរេហិបិ ទសហង្គេហិ សមន្នាគតោ វិនយធរោ ពាលោត្វេវ សង្ខំ គច្ឆតិ ញត្តឹ ន ជានាតិ ញត្តិយា ករណំ ន ជានាតិ ន បុព្វកុសលោ ហោតិ ន អបរកុសលោ ហោតិ អកាលញ្ញូ ច ហោតិ អាបត្តានាបត្តឹ ន ជានាតិ លហុកគរុកំ អាបត្តឹ ន ជានាតិ

ឯកុត្តរិកៈ ទសកៈ អង្គ ១០ របស់វិន័យធរ

គឺមិនស្គាល់អធិករណ៍ ១ មិនស្គាល់មូលនៃអធិករណ៍ ១ មិនស្គាល់ហេតុឲ្យកើតអធិករណ៍ ១ មិនស្គាល់សេចក្តីរលត់នៃអធិករណ៍ ១ មិនស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់នៃអធិករណ៍ ១ មិនស្គាល់វត្ថុ ១ មិនស្គាល់និទាន ១ មិនស្គាល់បញ្ញត្តិ ១ មិនស្គាល់អនុប្បញ្ញត្តិ ១ មិនស្គាល់គន្លងពាក្យដែលជាប់តគ្នា ១ ។ វិន័យធរដែលប្រកបដោយអង្គ ១០ ដល់នូវការរាប់ថាជាបណ្ឌិតគឺស្គាល់អធិករណ៍ ១ ស្គាល់មូលនៃអធិករណ៍ ១ ស្គាល់ហេតុឲ្យកើតអធិករណ៍ ១ ស្គាល់សេចក្តីរលត់អធិករណ៍ ១ ស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់អធិករណ៍ ១ ស្គាល់វត្ថុ ១ ស្គាល់និទាន ១ ស្គាល់បញ្ញត្តិ ១ ស្គាល់អនុប្បញ្ញត្តិ ១ ស្គាល់គន្លងពាក្យដែលជាប់តគ្នា ១ ។ វិន័យធរដែលប្រកបដោយអង្គ ១០ ដទៃទៀតក៏ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់ញត្តិ ១ មិនស្គាល់ការធ្វើញត្តិ ១ មិនឈ្លាសក្នុងកិច្ចខាងដើម ១ មិនឈ្លាសក្នុងកិច្ចខាងចុង ១ មិនស្គាល់កាល ១ មិនស្គាល់អាបត្តិនិងអនាបត្តិ ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ ១

សាវសេសានវសេសំ អាបត្តឹ ន ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ន ជានាតិ អាចរិយបរម្បរា ខោ បនស្ស ន សុគ្គហិតា ហោតិ ន សុមនសិកតា ន សូបធារិតា ។ ទសហង្គេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោតេ្វវ សង្ខំ គច្ឆតិ ញត្តឹ ជានាតិ ញត្តិយា ករណំ ជានាតិ បុព្វកុសលោ ហោតិ អបរកុសលោ ហោតិ កា-លញ្ញូ ច ហោតិ អាបត្តានាបត្តឹ ជានាតិ លហុកគរុកំ អាបត្តឹ ជានាតិ សាវសេសានវសេសំ អាបត្តឹ ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ជានាតិ អាចរិយបរម្បរា ខោ បនស្ស សុគ្គហិតា ហោតិ សុមនសិកតា សូបធារិ-តា ។ អបរេហិបិ ទសហង្គេហិ សមន្នាគតោ វិនយធរោ ពាលោតេ្វវ សង្ខំ គច្ឆតិ អាបត្តានាបត្តឹ ន ជានាតិ លហុកគរុកំ អាបត្តឹ ន ជានាតិ សាវសេសានវ-សេសំ អាបត្តឹ ន ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ន ជានាតិ ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ន ស្វាគតានិ ហោន្តិ ន សុវិភត្តានិ ន សុប្បវត្តីនិ ន សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ

វិនយបិដក បរិវារៈ

មិនស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ មិនស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១ វិន័យធរនោះមិនរៀនតំណអាចារ្យ តាំងមិនយកចិត្តទុកដាក់មិនពិចារណាដោយល្អ ១ ។ វិន័យធរដែលប្រកបដោយអង្គ ១០ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់ញត្តិ ១ ស្គាល់ការធ្វើញត្តិ ១ ឈ្លាសក្នុងកិច្ចខាងដើម ១ ឈ្លាសក្នុងកិច្ចខាងចុង ១ ស្គាល់កាល ១ ស្គាល់អាបត្តិនិងអនាបត្តិ ១ ស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ ស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ ស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ ១ វិន័យធរនោះបានរៀនតំណអាចារ្យតាំងបានយកចិត្តទុកដាក់ បានពិចារណាដោយល្អ ១ ។ វិន័យធរដែលប្រកបដោយអង្គ ១០ ដទៃទៀត គឺដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អាបត្តិនិងអនាបត្តិ ១ មិនស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ មិនស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ មិនស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១ វិន័យធរនោះមិនចេះចាំបាតិមោក្ខទាំងពីរដោយពិស្តារ មិនចេះចែកបទភាជនៈដោយប្រពៃ មិនបានចាំស្ទាត់រត់មាត់ដោយប្រពៃ មិនចេះកាត់សេចក្តីដោយប្រពៃ តាមសុត្តៈគឺខន្ធកៈនិងបរិវារៈ តាមអនុព្យញ្ជនៈគឺអក្ខរៈនិងបទ ១

អាបត្តានាបត្តឹ ន ជានាតិ លហុកគរុកំ អាបត្តឹ ន ជានាតិ សាវសេសានវសេសំ អាបត្តឹ ន ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ន ជានាតិ អធិករណេ ច ន វិនិច្ឆយកុសលោ ហោតិ ។ ទសហង្គេហិ សមន្នាគតោ វិនយធរោ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ អាបត្តានាបត្តឹ ជានាតិ លហុកគរុកំ អាបត្តឹ ជានាតិ សាវសេសានវសេសំ អាបត្តឹ ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ជានាតិ ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ អាបត្តានាបត្តឹ ជានាតិ លហុកគរុកំ អាបត្តឹ ជានាតិ សាវសេសានវសេសំ អាបត្តឹ ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ជានាតិ អធិករណេ ច វិនិច្ឆយកុសលោ ហោតិ ។

(៨៥) ទសហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ ទស អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ ទស អាទីនវា រាជន្តេបុរប្បវេសនេ ។ ទស ទានវត្ថូនិ ។ ទស រតនានិ ។

មិនស្គាល់អាបត្តិនឹងអនាបត្តិ ១ មិនស្គាល់លហុកាបត្តិនឹងគរុកាបត្តិ ១ មិនស្គាល់សាវសេសាបត្តិនឹងអនវសេសាបត្តិ ១ មិនស្គាល់ទុដ្ឋុល្លាបត្តិនឹងអទុដ្ឋុល្លាបត្តិ ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ ១ ៗ វិន័យធរប្រកបដោយអង្គ១០ ដល់នូវការរាប់អានថាជាបណ្ឌិត គឺស្គាល់អាបត្តិនឹងអនាបត្តិ១ ស្គាល់លហុកាបត្តិនឹងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិនឹងអនវសេសាបត្តិ ១ ស្គាល់ទុដ្ឋុល្លាបត្តិនឹងអទុដ្ឋុល្លាបត្តិ ១ វិន័យធរនោះចេះចាំបាតិមោក្ខទាំងពីរដោយពិស្តារ ចេះចែកបទភាជនៈដោយប្រពៃ ចាំស្ទាត់រត់មាត់ដោយប្រពៃ ចេះកាត់សេចក្តីដោយប្រពៃ តាមសុត្តៈ តាមអនុព្យញ្ជនៈ ១ ស្គាល់អាបត្តិនឹងអនាបត្តិ ១ ស្គាល់លហុកាបត្តិនឹងគរុកាបត្តិ ១ ស្គាល់សាវសេសាបត្តិនឹងអនវសេសាបត្តិ ១ ស្គាល់ទុដ្ឋុល្លាបត្តិនឹងអទុដ្ឋុល្លាបត្តិ ១ ឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ ១ ៗ

(៨៩) ភិក្ខុប្រកបដោយអង្គ ១១ សង្ឃគួរសន្មតដោយឧព្វាហិកាកម្ម [១] ៗ ព្រះតថាគតអាស្រ័យអំណាចប្រយោជន៍ទាំង ១០ ទើបបញ្ញត្តសិក្ខាបទដល់សាវ័កទាំងឡាយ ៗ ទោសក្នុងការចូលទៅក្នុងព្រះរាជវាំងមាន ១០ យ៉ាង ៗ ទានវត្ថុមាន ១០ យ៉ាង ៗ រតនៈមាន ១០យ៉ាងៗ

---

១ ឧព្វាហិកាកម្មនេះ លោកបានពោលទុកក្នុងសមថក្ខន្ធកៈរួចហើយ ។

ទសវគ្គោ ភិក្ខុសង្ឃោ ។ ទសវគ្គេន គណេន ឧបសម្បាទេតព្វំ ។ ទស បំសុកូលានិ ។ ទស ចីវរធារណានិ(១) ។ ទសាហបរមំ អតិរេកចីវរំ ធារេតព្វំ ។ ទស សុក្កានិ ។ ទស ឥត្ថិយោ ។ ទស ភរិយាយោ ។ វេសាលិយំ(២) ទស វត្ថូនិ ទីបេន្តិ ។ ទស បុគ្គលា អវន្ទិយា ។ ទស អក្កោសវត្ថូនិ ។ ទសហាការេហិ បេសុញ្ញំ ឧបសំហរតិ ។ ទស សេនាសនានិ ។ ទស វរានិ យាចិំសុ ។ ទស អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ ទស ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ ទសានិសំសា យាគុយា ។ ទស មំសា អកប្បិយា ។ ទស បរមានិ ។ ទសវស្សេន ភិក្ខុនា ព្យត្តេន បដិពលេន បព្វាជេតព្វំ ឧបសម្បាទេតព្វំ និស្សយោ ទាតព្វោ សាមណេរោ ឧបដ្ឋាបេតព្វោ ។ ទសវស្សាយ ភិក្ខុនិយា ព្យត្តាយ បដិពលាយ បព្វាជេតព្វំ ឧបសម្បាទេតព្វំ និស្សយោ ទាតព្វោ

១ ខ. ម. ចីវរធារណា ។ ២ ខ. ម. វេសាលិយា ។

ភិក្ខុសង្ឃមានពួក ១០ ។ គណៈសង្ឃពួក ១០ គួរឲ្យឧបសម្បទាបាន ។ សំពត់បំសុកូលមាន ១០ យ៉ាង ។ ការទ្រទ្រង់ចីវរមាន ១០ យ៉ាង ។ អតិរេកចីវរ ភិក្ខុត្រូវប្រើប្រាស់បាន កំណត់ត្រឹម ១០ ថ្ងៃ ។ ទឹកសុក្កៈមាន ១០ យ៉ាង ។ ស្រីមាន ១០ ពួក ។ ភរិយាមាន ១០ ពួក ។ វជ្ជីបុត្តកភិក្ខុទាំងឡាយសំដែងវត្ថុទាំង ១០ ប្រការ ក្នុងក្រុងវេសាលី ។ អវន្ទិយបុគ្គលមាន ១០ ពួក ។ អក្កោសវត្ថុមាន ១០ យ៉ាង ។ ភិក្ខុនាំពាក្យញុះញង់ដោយអាការ ១០ ។ សេនាសនៈមាន ១០ យ៉ាង ។ ជនទាំងឡាយបានសូមពរទាំង ១០ ។ ការបញ្ឈប់បាតិមោក្ខដែលមិនប្រកបដោយធម៌មាន ១០ ។ ការបញ្ឈប់បាតិមោក្ខដែលប្រកបដោយធម៌មាន ១០ ។ អានិសង្សបបរមាន ១០ យ៉ាង ។ សាច់ដែលភិក្ខុមិនគួរឆាន់មាន ១០ យ៉ាង ។ សិក្ខាបទដែលមានទីកំណត់មាន ១០ ។ ភិក្ខុមានវស្សាគ្រប់ ១០ ដែលឈ្លាសប្រតិពលទើបគួរឲ្យបព្វជ្ជា គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួន ។ ភិក្ខុនីមានវស្សាគ្រប់ ១០ ដែលឈ្លាសប្រតិពលទើបគួរឲ្យបព្វជ្ជា គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ

សាមណេរី ឧបដ្ឋាបេតព្វា ។ ទសវស្សាយ ភិក្ខុនិយា ព្យត្តាយ បដិពលាយ វុដ្ឋាបនសម្មតិ សាធិតព្វា ។ ទសវស្សាយ គិហិគតាយ សិក្ខា ទាតព្វាតិ ។

ខន្ធកំ និដ្ឋិតំ ។

តស្សុទ្ទានំ

[៨៦] អាយាតវិនយោ(១) វត្តុ
មិច្ឆា សម្មា ច អជ្ឈត្តា
មិច្ឆត្តា ចេវ សម្មត្តា
អកុសលា កុសលាបិ ច
សលាកាធម្មធម្មា ច
សាមណោក ច ធាសធា
កាសាវិការណោទ្ទេវ
ញត្តិ លហុកមេវ ច
លហុកា គរុកា ឃតេ

---

១ ឱ. ម. អាយាគំ វិនយំ ។

គួរឲ្យសាមណេរីបម្រើខ្លួនបាន ។ ភិក្ខុនីដែលឈ្មោះប្រតិពល មានវស្សាគ្រប់ ១០ ទើបគួរត្រេកអរនឹងការសន្មតិឲ្យបំបួសគេបាន ។ ភិក្ខុនីគប្បីឲ្យសិក្ខា[១] ដល់ស្រីគិហិគតា[២] មានវស្សាគ្រប់ ១០ ។

ចប់ ទសកៈ (ពួកដប់ៗ) ។

ឧទ្ទាន គឺបញ្ជីរឿងនៃទសកៈ (ពួកដប់ ៗ) នោះដូច្នេះ

(៨៦) និយាយអំពីវត្ថុជាទីកើតគំនុំ ១ ធម៌សម្រាប់កំចាត់គំនុំ ១ វិនីតវត្ថុ ១ មិច្ឆាទិដ្ឋិ ១ សម្មាទិដ្ឋិ ១ អន្តគ្គាហិកាទិដ្ឋិ ១ មិច្ឆត្តធម៌ ១ សម្មត្តធម៌ ១ អកុសលកម្មបថ ១ កុសលកម្មបថ ១ ការចាប់ស្លាកមិនប្រកបដោយធម៌ ១ ការចាប់ស្លាកប្រកបដោយធម៌ ១ សិក្ខាបទរបស់សាមណេរ ១ សាមណេរដែលគួរឲ្យវិនាស ១ ទីកំណត់កាសា ១ អធិករណ៍ ១ ញត្តិ ១ លហុកាបត្តិ ១ លហុកាបត្តិម្យ៉ាងទៀត ១ គរុកាបត្តិ ១ អ្នកទាំងឡាយ ចូរដឹងធម៌ទាំងអម្បាលនេះ ថាជាធម៌

---

១ សិក្ខាក្នុងទីនេះសំដៅយកធម៌ ៦ ប្រការដែលសាមណេរីត្រូវសិក្សាអស់ ២ ឆ្នាំទៅទៀត ។

២ ស្រីដែលល្មមមានប្ដីហើយទើបចូលបួសជាសាមណេរីបាន ។

កណ្ហា សុក្កា វិជាន ច
ឧញ្ញាហិកា ច សិក្ខា ច
អន្តេបុភ ច វត្ថូនិ
រតនំ ទសវគ្គោ ច
តថេវ ឧបសម្បទា
បំសុកូលធារណា ច
ទសាហា សុក្កឥត្ថិយោ
ករិយា ទស វត្ថូនិ
អវន្ទិយក្កោសេន ច
បេសុញ្ញញ្ញេវ(១) សេនា ច
វភដិ ច អធម្មិកា
ធម្មិកា យាគុ មំសា ច
បរមា ភិក្ខុ ភិក្ខុនី
វុដ្ឋាបនា គិហិគតា
ទសកា សុប្បកាសិតាតិ ។

---

១ ឱ. បេសុញ្ញ ។ ម. បេសុញ្ញ ចេវ សេនាទិ ។

មានបំណែកខ្មៅ នឹងស ភិក្ខុដែលសង្ឃត្រូវសន្មតដោយឧព្វា-ហិកាកម្ម ១ ព្រះតថាគតទ្រង់បញ្ញត្តសិក្ខាបទ ១ ទោសក្នុងការចូលទៅក្នុងព្រះរាជវាំង ១ ទានវត្ថុ ១ រតនៈ ១ សង្ឃពួកដប់ ១ ការឲ្យឧបសម្បទាដោយសង្ឃពួក ១០ ដូចគ្នា ១ សំពត់បំសុ-កូល ១ ការប្រើប្រាស់ចីវរ ១ អតិរេកចីវរ គួរប្រើប្រាស់បានត្រឹមតែកំណត់ ១០ ថ្ងៃ ១ ទឹកសុក្កៈ ១០ យ៉ាង ១ ស្រី ១០ ពួក ១ ភរិយា ១០ ពួក ១ វត្ថុ ១០ យ៉ាង ១ អវន្ទិយបុគ្គល ១ អក្កោសវត្ថុ ១ ភិក្ខុនាំការញុះញង់ ១ សេនាសនៈ ១ ការសូមពរ ១ ការបញ្ឈប់បាតិមោក្ខដែលមិនប្រកបដោយធម៌ ១ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ១ អានិសង្សបបរ ១ សាច់មិនគួរឆាន់ ១ សិក្ខាបទដែលមានទីកំណត់ ១ ភិក្ខុដែលគួរឲ្យបព្វជ្ជាជាដើម ១ ភិក្ខុនីដែលគួរឲ្យបព្វជ្ជាជាដើម ១ ភិក្ខុនីគួរត្រេកអរនឹងការសន្តិបព្វជ្ជា ១ ស្រីគិហិគតា ១ ធម៌ពួកដប់ៗនេះព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងហើយ ដោយប្រពៃ ។

(៨៧) ឯកាទស បុគ្គលា អនុបសម្បន្នា ន ឧបសម្បាទេតព្វា ឧបសម្បន្នា នាសេតព្វា ។ ឯកាទស បាទុកា អកប្បិយា ។ ឯកាទស បត្តា អកប្បិយា ។ ឯកាទស ចីវរានិ អកប្បិយានិ ។ ឯកាទស យាវតតិយកា ។ ភិក្ខុនីនំ ឯកាទស អន្តរាយិកា ធម្មា បុច្ឆិតព្វា ។ ឯកាទស ចីវរានិ អធិដ្ឋាតព្វានិ ។ ឯកាទស ចីវរានិ ន វិកប្បេតព្វានិ ។ ឯកាទសេ អរុណុគ្គមនេ និស្សគ្គិយំ ហោតិ ។ ឯកាទស គណ្ឋិកា កប្បិយា ។ ឯកាទស វីធា កប្បិយា ។ ឯកាទស បថវិយោ អកប្បិយា ។ ឯកាទស បថវិយោ កប្បិយា ។ ឯកាទស និស្សយប្បដិប្បស្សទ្ធិយោ ។ ឯកាទស បុគ្គលា អវន្ទិយា ។ ឯកាទស បរមានិ ។ ឯកាទស វរានិ យាចិសុ ។ ឯកាទស សីមាទោសា ។ អក្កោសកបរិភាសកេ បុគ្គលេ ឯកាទស អាទីនវា បាដិកង្ខា ។ មេត្តាយ ចេតោវិមុត្តិយា អាសេវិតាយ ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ ឯកាទសានិសំសា

(៨៧) បុគ្គល ១១ ពួក បើនៅជាអនុបសម្បន្ននៅឡើយ ភិក្ខុមិនត្រូវឲ្យឧបសម្បទា ទុកជាបានឧបសម្បទារួចហើយ ភិក្ខុត្រូវឲ្យវិនាសចេញ ។ ទ្រនាប់ជើងដែលភិក្ខុមិនគួរប្រើប្រាស់ មាន ១១ យ៉ាង ។ បាត្រដែលភិក្ខុមិនគួរប្រើប្រាស់ មាន ១១ យ៉ាង ។ ចីវរដែលភិក្ខុមិនគួរប្រើប្រាស់ មាន ១១ យ៉ាង ។ អាបត្តិជាយាវតតិយកា មាន ១១ ។ អន្តរាយិកធម៌ ១១ ប្រការរបស់ពួកភិក្ខុនី ភិក្ខុត្រូវសួរ ។ ចីវរដែលភិក្ខុគួរអធិដ្ឋាន មាន ១១ យ៉ាង ។ ចីវរដែលភិក្ខុមិនគួរវិកប្ប មាន ១១ យ៉ាង ។ វត្ថុដែលជានិស្សគ្គិយៈ ក្នុងពេលអរុណរះឡើងជាគំរប់ ១១ ។ ឡេវក្ដុំដែលជាកប្បិយៈ (គួរប្រើប្រាស់បាន) មាន ១១យ៉ាង ។ ក្រវិលក្ដុំដែលជាកប្បិយៈមាន ១១ យ៉ាង ។ ផែនដីជាអកប្បិយៈ (ភិក្ខុមិនគួរជីក) មាន ១១ យ៉ាង ។ ផែនដីជាកប្បិយៈមាន ១១យ៉ាង ។ សេចក្តីរម្ងាប់ហាកនិស្ស័យ មាន ១១ ប្រការ ។ អវន្ទិយបុគ្គល មាន ១១ ពួក ។ សិក្ខាបទមានទីកំណត់មាន ១១ ។ ពួកជនបានសូមពរ ១១ ប្រការ ។ ទោសរបស់សីមា មាន ១១ ប្រការ ។ ទោស ១១ ប្រការ រមែងកើតប្រាកដដល់បុគ្គលជាអ្នកជេរទឹងជាអ្នកគម្រាម ។ មេត្តាចេតោវិមុត្តិដែលបុគ្គលធ្វើឲ្យថ្កឹកហើយ ចំរើនហើយ ធ្វើឲ្យក្រាស់ក្រែលហើយ ធ្វើឲ្យដូចជាយានជំនិះហើយ ធ្វើឲ្យជាទីនៅហើយ ឲ្យតាំងនៅញឹកញយហើយ សន្សំទុកមិនឲ្យបាត់ប្រារព្ធដោយល្អហើយ នឹងមានអានិសង្ស ១១ ប្រការ

បាដិកង្ខា សុខំ សុបតិ សុខំ បដិពុជ្ឈតិ ន បាបកំ សុបិនំ បស្សតិ មនុស្សានំ បិយោ ហោតិ អមនុស្សានំ បិយោ ហោតិ ទេវតា រក្ខន្តិ នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ តុវដំ ចិត្តំ សមាធិយតិ មុខវណ្ណោ វិប្បសីទតិ អសម្មូឡ្ហោ កាលំ ករោតិ ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ មេត្តាយ ចេតោវិមុត្តិយា អាសេវិតាយ ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ ឥមេ ឯកាទសានិសំសា បាដិកង្ខាតិ ។

ឯកាទសកំ និដ្ឋិតំ ។

តស្សុទ្ទានំ

(៨៨) នាសេតព្វា បាទុកា ច
បត្តា ច ចីវរានិ ច
តតិយា បុច្ឆិតព្វា ច
អធិដ្ឋានវិកប្បនា

ជាពិតប្រាកដ គឺបុគ្គលនោះដេកលក់ជាសុខ ១ ភ្ញាក់ឡើងជាសុខ ១ មិនយល់សុបិនអាក្រក់ ១ ជាទីស្រឡាញ់របស់ពួកមនុស្ស ១ ជាទីស្រឡាញ់របស់ពួកអមនុស្ស ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី ក៏មិនប៉ះពាល់ដល់បុគ្គលនោះ ១ ចិត្តបុគ្គលនោះ រមែងចូលកាន់សមាធិដោយរួសរាន់ ១ បុគ្គលនោះមានពណ៌សម្បុរមុខស្រស់បស់ ១ បុគ្គលនោះមិនបានវង្វេង ធ្វើមរណកាល ១ កាលបើមិនទាន់បានត្រាស់ដឹងនូវគុណធម៌ជាន់ខ្ពស់ទេ ជាអ្នកបានទៅកើតក្នុងព្រហ្មលោក ១ មេត្តាចេតោវិមុត្តិដែលបុគ្គលធ្វើឲ្យច្រើនហើយ ចំរើនហើយ ធ្វើឲ្យកាស់ក្រែលហើយ ធ្វើឲ្យដូចជាយានជំនិះហើយ ធ្វើឲ្យជាទីនៅហើយ ឲ្យតាំងនៅញឹកញយហើយ សន្សំទុកមិនឲ្យបាត់ ប្រារព្ធដោយល្អហើយ អានិសង្ស ១១ ប្រការនេះនឹងកើតប្រាកដ ។

ចប់ ឯកាទសកៈ (ពួកដប់មួយ ៗ) ។

ឧទ្ទាន គឺ បញ្ជីរឿងនៃឯកាទសកៈ (ពួកដប់មួយៗ) នោះដូច្នេះ

(៨៨) និយាយអំពីឧបសម្បទដែលសង្ឃគួរឲ្យវិនាស ១ ទ្រនាប់ជើង ១ បាត្រ ១ ចីវរ ១ អាបត្តិ ជាយាវតតិយកា ១ អន្តរាយិកធម៌ដែលវិន័យធរត្រូវសួរ ១ ចីវរគួរអធិដ្ឋាន ១ ចីវរ

ឯកុត្តរិកំ ឯកាទសកំ ឧទ្ទានគាថា

អរុណា តណ្ហិកា វីជា
អកប្បិយា ច កប្បិយំ
និស្សយោវឌ្ឍិយោ ចេវ
បរមានិ វភនិ ច
សីមាឃោសា ច អក្កោសា
មេត្តាយេកាទសា កតាតិ ។

ឯកុត្តរិកំ និដ្ឋិតំ ។

តស្សុទ្ទានំ

(៨៩) ឯកកា ច ទុកា ចេវ
តិកា ច ចតុបញ្ចកា
ឆសត្តដ្ឋនវកា ច
ទសឯកាទសានិ ច
ហិតាយ សព្វសត្តានំ
ញាតធម្មេន តាទិនា
ឯកុត្តរិកា វិមលា
មហាវិរេន ទេសិតាតិ ។

ឯកុត្តរិកៈ ឯកាទសកៈ ឧទ្ទានគាថា

គួរវិកប្ប ១ វត្ថុជានិស្សគ្គិយៈក្នុងវេលាអរុណរះឡើង ១ ទៀវត្ថុ ១ ក្រវិលក្ខុ ១ ដីជាអកប្បិយៈ ១ ដីជាកប្បិយៈ ១ សេចក្តីម្ចាប់ពាកនិស្ស័យ ១ អវន្ទិយបុគ្គល ១ សិក្ខាបទដែលមានទីកំណត់ ១ ការសូមពរ ១ ទោសរបស់សីមា ១ ការជេរ ១ អានិសង្សមេត្តាមាន ១១ ប្រការ ១ ។

ចប់ ឯកុត្តរិកៈ (ការស្រង់យកសេចក្តីតាំងពីពួកមួយៗ ឡើងទៅ) ។

ឧទ្ទាននៃឯកុត្តរិកៈនោះដូច្នេះ

[៨៩] ពួកធម៌មួយ ១ ពួកធម៌ពីរ ១ ពួកធម៌បី ១ ពួកធម៌បួន ១ ពួកធម៌ប្រាំ ១ ពួកធម៌ប្រាំមួយ ១ ពួកធម៌ប្រាំពីរ ១ ពួកធម៌ប្រាំបី ១ ពួកធម៌ប្រាំបួន ១ ពួកធម៌ដប់ ១ ពួកធម៌ដប់មួយ ១ ឈ្មោះថា ឯកុត្តរិកៈ ជារបស់ប្រាសចាកមន្ទិល ដែលព្រះពុទ្ធជាតាទិបុគ្គលទ្រង់ត្រាស់ដឹងនូវធម៌ ទ្រង់ប្រកបដោយសេចក្តីព្យាយាមច្រើន ទ្រង់សំដែងទុកមក ដើម្បីប្រយោជន៍ ដល់សព្វសត្វទាំងឡាយ ។

ឧបោសថាទិបុច្ឆាវិស្សជ្ជនា

[៩០] ឧបោសថកម្មស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។ បវារណាកម្មស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។ តជ្ជនីយកម្មស្ស ។ បេ ។ និយស្សកម្មស្ស ។ បេ ។ បព្វាជនីយកម្មស្ស ។ បេ ។ បដិសារណីយកម្មស្ស ។ បេ ។ ឧក្ខេបនីយកម្មស្ស ។ បេ ។ បរិវាសទានស្ស ។ បេ ។ មូលាយ បដិកស្សនាយ ។ បេ ។ មានត្តទានស្ស ។ បេ ។ អព្ភានស្ស ។ បេ ។ ឧបសម្បទាកម្មស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិយា កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។ និយស្សកម្មស្ស បដិប្បស្សទ្ធិយា ។ បេ ។ បព្វាជនីយកម្មស្ស បដិប្បស្សទ្ធិយា ។ បេ ។ បដិសារណីយកម្មស្ស បដិប្បស្សទ្ធិយា ។ បេ ។ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិយា កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។ សតិវិនយស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។ បេ ។ អមូឡ្ហវិនយស្ស ។ បេ ។ តស្សបាបិយសិ-

បុច្ឆាវិសជ្ជនាអំពីឧបោសថកម្មជាដើម

(៩០) ឧបោសថកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាទីបំផុត ។ បវារណាកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាទីបំផុត ។ តជ្ជនីយកម្ម ។ បេ ។ និយស្សកម្ម ។ បេ ។ បព្វាជនីយកម្ម ។ បេ ។ បដិសារណីយកម្ម ។ បេ ។ ឧក្ខេបនីយកម្ម ។ បេ ។ បរិវាសទាន (ការឲ្យបរិវាស) ។ បេ ។ មូលាយបដិកស្សនា ។ បេ ។ មានត្តទាន ។ បេ ។ អព្ភាន ។ បេ ។ ឧបសម្បទាកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាទីបំផុត ។ ការរម្ងាប់តជ្ជនីយកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាទីបំផុត ។ ការរម្ងាប់និយស្សកម្ម ។ បេ ។ ការរម្ងាប់បព្វាជនីយកម្ម ។ បេ ។ ការរម្ងាប់បដិសារណីយកម្ម ។ បេ ។ ការរម្ងាប់ឧក្ខេបនីយកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាទីបំផុត ។ សតិវិន័យ មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាទីបំផុត ។ បេ ។ អមូឡ្ហវិន័យ ។ បេ ។ តស្សបាបិយសិកា

កាយ ។ បេ ។ តិណវត្ថារកស្ស ។ បេ ។ ភិក្ខុនោវាទក-សម្មុតិយា ។ បេ ។ តិចីវរេន អវិប្បវាសសម្មុតិយា ។ បេ ។ សន្ថតសម្មុតិយា ។ បេ ។ រូបិយឆឌ្ឌកសម្មុតិយា ។ បេ ។ សាដិយគ្គាហាបកសម្មុតិយា ។ បេ ។ បត្តគ្គា-ហាបកសម្មុតិយា ។ បេ ។ ទណ្ឌសម្មុតិយា ។ បេ ។ សិក្កាសម្មុតិយា ។ បេ ។ ទណ្ឌសិក្កាសម្មុតិយា កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។

(៩១) ឧបោសថកម្មស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានន្តិ ។ ឧបោសថកម្មស្ស សាមគ្គី អាទិ កិរិយា មជ្ឈេ និដ្ឋានំ បរិយោសានំ ។ បវារណាកម្មស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានន្តិ ។ បវារណា-កម្មស្ស សាមគ្គី អាទិ កិរិយា មជ្ឈេ និដ្ឋានំ បរិយោ-សានំ ។ តជ្ជនីយកម្មស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានន្តិ ។ តជ្ជនីយកម្មស្ស វត្ថុ ច បុគ្គលោ ច អាទិ ញត្តិ មជ្ឈេ កម្មវាចា បរិយោសានំ ។ និយស្ស-កម្មស្ស ។ បេ ។ បព្វាជនីយកម្មស្ស បដិសារណីយ-កម្មស្ស ឧក្ខេបនីយកម្មស្ស បរិវាសទានស្ស មូលាយ

ៗ បេ ៗ តិណវត្ថារកៈ ៗ បេ ៗ ការសន្មតិភិក្ខុឲ្យជាអ្នកប្រដៅភិក្ខុនី ៗ បេ ៗ ការសន្មតិភិក្ខុឲ្យទៅប្រាសចាកត្រៃចីវរ ៗ បេ ៗ ការសន្មតិសន្ថត ៗ បេ ៗ ការសន្មតិភិក្ខុឲ្យជាអ្នកចោលរូបិយៈ ៗ បេ ៗ ការសន្មតិភិក្ខុឲ្យជាអ្នកប្រគល់សាដក ៗ បេ ៗ ការសន្មតិភិក្ខុឲ្យជាអ្នកប្រគល់បាត្រ ៗ បេ ៗ ការសន្មតិឈើច្រត់ ៗ បេ ៗ ការសន្មតិសង្រែក ៗបេៗ ការសន្មតិឈើច្រត់នឹងសង្រែក មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត ៗ

[៩១] សួរថា ឧបោសថកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត ៗ ឆ្លើយថា ឧបោសថកម្ម មានសេចក្តីព្រមព្រៀងជាខាងដើម មានការធ្វើជាកណ្តាល មានការចប់ជាទីបំផុត ៗ បវារណាកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត ៗ បវារណាកម្ម មានសេចក្តីព្រមព្រៀងជាខាងដើម មានការធ្វើជាកណ្តាល មានការចប់ជាទីបំផុត ៗ តជ្ជនីយកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត ៗ តជ្ជនីយកម្ម មានវត្ថុនឹងបុគ្គលជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត ៗ និយស្សកម្ម ៗ បេ ៗ បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេបនីយកម្ម បរិវាសទាន មូលាយ–

បដិកស្សនាយ មានត្តចារស្ស អព្ភានស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានន្តិ ។ អព្ភានស្ស វត្ថុ ច បុគ្គលោ ច អាទិ ញត្តិ មជ្ឈេ កម្មវាចា បរិយោសានំ ។ ឧបសម្បទាកម្មស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានន្តិ ។ ឧបសម្បទាកម្មស្ស បុគ្គលោ អាទិ ញត្តិ មជ្ឈេ កម្មវាចា បរិយោសានំ ។ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិយា កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានន្តិ ។ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិយា សម្មាវត្តនា អាទិ ញត្តិ មជ្ឈេ កម្មវាចា បរិយោសានំ ។ និយស្សកម្មស្ស ។ បេ ។ បព្វាជនីយកម្មស្ស បដិសារណីយកម្មស្ស ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិយា កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានន្តិ ។ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិយា សម្មាវត្តនា អាទិ ញត្តិ មជ្ឈេ កម្មវាចា បរិយោសានំ ។ សតិវិនយស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានន្តិ ។ សតិវិនយស្ស វត្ថុ ច បុគ្គលោ ច អាទិ ញត្តិ មជ្ឈេ កម្មវាចា បរិយោសានំ ។ អមូឡ្ហវិនយស្ស ។ បេ ។ តស្សបាបិយសិកាយ តិណវត្ថារកស្ស

ប្បដិកស្សនា មានត្តមាន អព្ភាន មានសីមាជាខាងដើម មានសីមាជាកណ្តាល មានសីមាជាទីបំផុត ។ អព្ភាន មានវត្ថុនិងបុគ្គលជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត ។ ឧបសម្បទាកម្ម មានសីមាជាខាងដើម មានសីមាជាកណ្តាល មានសីមាជាទីបំផុត ។ ឧបសម្បទាកម្ម មានបុគ្គលជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត ។ ការរំងាប់តជ្ជនីយកម្ម មានសីមាជាខាងដើម មានសីមាជាកណ្តាល មានសីមាជាទីបំផុត ។ ការរំងាប់តជ្ជ-នីយកម្ម មានការប្រព្រឹត្តិវត្តដោយល្អជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត ។ ការរំងាប់និយស្សកម្ម ។ បេ ។ បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេបនីយកម្ម មានសីមាជាខាងដើម មានសីមាជាកណ្តាល មានសីមាជាទីបំផុត ។ ការរំងាប់ឧក្ខេបនីយកម្ម មានការប្រព្រឹត្តិវត្តដោយល្អ ជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត ។ សតិវិន័យ មានសីមាជាខាងដើម មានសីមាជាកណ្តាល មានសីមាជាទីបំផុត ។ សតិវិន័យមាន វត្ថុនិងបុគ្គលជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត ។ អមូឡ្ហវិន័យ ។ បេ ។ តស្សបាបិយសិកា តិណវត្ថារកៈ ការសន្មតិ

ឧបោសថាទិបុច្ឆាវិសជ្ជនា ភិក្ខុនោវាទកសម្មតិអាទីនិ

ភិក្ខុនោវាទកសម្មតិយា តិចីវរេន អវិប្បវាសសម្មតិយា សន្ថតសម្មតិយា រូបិយឆឌ្ឌកសម្មតិយា សាដិយគ្គាហាបកសម្មតិយា បត្តគ្គាហាបកសម្មតិយា ទណ្ឌសម្មតិយា សិក្កាសម្មតិយា ទណ្ឌសិក្កាសម្មតិយា កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានន្តិ ។ ទណ្ឌសិក្កាសម្មតិយា វត្ថុ ច បុគ្គលោ ច អាទិ ញត្តិ មជ្ឈេ កម្មវាចា បរិយោសានំ ។

បុច្ឆាវិសជ្ជនាអំពីឧបោសថជាដើម ការសន្មតិភិក្ខុឲ្យជាអ្នកប្រដៅភិក្ខុនីជាដើម

ភិក្ខុឲ្យជាអ្នកប្រដៅភិក្ខុនី ការសន្មតភិក្ខុឲ្យនៅប្រាសចាកត្រៃចីវរ ការសន្មតិសន្ថត ការសន្មតិភិក្ខុឲ្យជាអ្នកពោលរូបិយៈ ការសន្មតិភិក្ខុឲ្យជាអ្នកប្រគល់សាដក ការសន្មតិភិក្ខុឲ្យជាអ្នកប្រគល់បាត្រ ការសន្មតិឈើច្រត់ ការសន្មតិសាជ្រែក ការសន្មតិឈើច្រត់នឹងសាជ្រែក មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាទីបំផុត ។ ការសន្មតិឈើច្រត់នឹងសាជ្រែកមានវត្ថុនឹងបុគ្គលជាខាងដើម មានញត្តិជាកណ្ដាល មានកម្មវាចាជាទីបំផុត ។

អត្ថវសប្បករណំ

(៩២) ទស អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។

(៩៣) យំ សង្ឃសុដ្ឋុ តំ សង្ឃផាសុ យំ សង្ឃផាសុ តំ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ យំ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ តំ បេសលានំ ភិក្ខូនំ ផាសុវិហារាយ

បករណៈសំដែងអំពីអំណាចប្រយោជន៍

(៩២) ព្រះតថាគតទ្រង់បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយព្រោះអាស្រ័យអំណាចប្រយោជន៍១០ យ៉ាង ។ គឺ ដើម្បីសេចក្ដីល្អដល់សង្ឃ១ ដើម្បីនៅសប្បាយដល់សង្ឃ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលមិនមានសេចក្ដីអៀនខ្មាស ១ ដើម្បីនៅជាសុខស្រួល ដល់ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង១ ដើម្បីតាំងតល់នៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ។

(៩៣) អំណាចប្រយោជន៍ណាដែលជាសេចក្ដីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា សប្បាយដល់សង្ឃ អំណាចប្រយោជន៍ណាសប្បាយដល់សង្ឃ អំណាចប្រយោជនោះ ឈ្មោះថា(ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្ដីអៀនខ្មាស អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្ដីអៀនខ្មាស អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួល ដល់ភិក្ខុទាំងឡាយ ដែល

យំ បេសលានំ ភិក្ខូនំ ផាសុវិហារាយ តំ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ យំ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ តំ សម្បរាយិកានំ អាសវានំ បដិឃាតាយ យំ សម្បរាយិកានំ អាសវានំ បដិឃាតាយ តំ អប្បសន្នានំ បសាទាយ យំ អប្បសន្នានំ បសាទាយ តំ បសន្នានំ ភិយ្យោភាវាយ យំ បសន្នានំ ភិយ្យោភាវាយ តំ សទ្ធម្មដ្ឋិតិយា យំ សទ្ធម្មដ្ឋិតិយា តំ វិនយានុគ្គហាយ ។

មានសីលជាទីស្រឡាញ់ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីកពាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីពាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីតម្កល់នៅមាំនៃព្រះសទ្ធម្ម អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីតម្កល់នៅមាំនៃព្រះសទ្ធម្ម អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ ។

[៩៤] យំ សង្ឃសុដ្ឋុ តំ សង្ឃផាសុ យំ សង្ឃសុដ្ឋុ តំ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ យំ សង្ឃសុដ្ឋុ តំ បេសលានំ ភិក្ខូនំ ផាសុវិហារាយ យំ សង្ឃសុដ្ឋុ តំ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ យំ សង្ឃសុដ្ឋុ តំ សម្បរាយិកានំ អាសវានំ បដិឃាតាយ យំ សង្ឃសុដ្ឋុ តំ អប្បសន្នានំ បសាទាយ យំ សង្ឃសុដ្ឋុ តំ បសន្នានំ ភិយ្យោភាវាយ

(៩៨) អំណាចប្រយោជន៍ណា ដែលជាសេចក្ដីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថាសប្បាយដល់សង្ឃ អំណាចប្រយោជន៍ណា ដែលជាសេចក្ដីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្ដីអៀនខ្មាស អំណាចប្រយោជន៍ណា ដែលជាសេចក្ដីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ អំណាចប្រយោជន៍ណា ដែលជាសេចក្ដីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីពាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន អំណាចប្រយោជន៍ណា ដែលជាសេចក្ដីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក អំណាចប្រយោជន៍ណា ដែលជាសេចក្ដីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង អំណាចប្រយោជន៍ណា ដែលជាសេចក្ដីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង

យំ សង្ឃសុដ្ឋុ តំ សទ្ធម្មដ្ឋិតិយា យំ សង្ឃសុដ្ឋុ តំ វិនយានុគ្គហាយ ។

(៩៥) យំ សង្ឃផាសុ តំ ទុម្មង្កូនំ បុគ្គលានំ និគ្គ-ហាយ យំ សង្ឃផាសុ តំ បេសលានំ ភិក្ខូនំ ផាសុវិហា-រាយ យំ សង្ឃផាសុ តំ ទិដ្ឋធម្មិកានំ អាសវានំ សំវ-រាយ យំ សង្ឃផាសុ តំ សម្បរាយិកានំ អាសវានំ បដិ-ឃាតាយ យំ សង្ឃផាសុ តំ អប្បសន្នានំ បសាទាយ

អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីតំកល់នៅមាំនៃព្រះសទ្ធម្ម អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ ។

(៩៥) អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្តីអៀនខ្មាស អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីការពាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញ៉ាំងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង អំណាចប្រយោជន៍ណា

យំ សង្ឃផាសុ តំ បសន្នានំ ភិយ្យោភាវាយ យំ សង្ឃផាសុ តំ សទ្ធម្មដ្ឋិតិយា យំ សង្ឃផាសុ តំ វិនយានុគ្គហាយ យំ សង្ឃផាសុ តំ សង្ឃសុដ្ឋុ ។

(៩២) យំ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ ។បេ។ យំ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ។បេ។ យំ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ ។បេ។ យំ សម្បរាយិកានំ អាសវានំ បដិឃាតាយ ។បេ។ យំ

ដែលជាសេចក្ដីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញ៉ាំងបុគ្គលទាំងឡាយ ដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង អំណាចប្រយោជន៍ណា ដែលជាសេចក្ដីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីតាំងនៅមាំនៃព្រះសទ្ធម្ម អំណាចប្រយោជន៍ណា ដែលជាសេចក្ដីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍ណា ដែលជាសេចក្ដីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថាជាសេចក្ដីល្អដល់សង្ឃ ។

[៩៦] អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្ដីអៀនខ្មាស ។ បេ ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ។ បេ ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីពាំងនូវអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន ។ បេ ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ។ បេ ។ អំណាចប្រយោជន៍ណា

អប្បសន្នានំ បសាទាយ ។ បេ ។ យំ បសន្នានំ

ភិយ្យោភាវាយ ។ បេ ។ យំ សទ្ធម្មដ្ឋិតិយា ។ បេ ។ យំ

វិនយានុគ្គហាយ តំ សង្ឃសុដ្ឋុ យំ វិនយានុគ្គហាយ តំ

សង្ឃផាសុ យំ វិនយានុគ្គហាយ តំ ទុម្មង្កូនំ បុគ្គ-

លានំ និគ្គហាយ យំ វិនយានុគ្គហាយ តំ បេសលានំ

ភិក្ខូនំ ផាសុវិហារាយ យំ វិនយានុគ្គហាយ តំ ទិដ្ឋ-

ធម្មិកានំ អាសវានំ សំវរាយ យំ វិនយានុគ្គហាយ តំ

(ប្រព្រឹត្តទៅ) ដើម្បីញុំាងជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ។ បេ ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីញុំាងជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើង ។ បេ ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីតំកល់នៅមាំនៃព្រះសទ្ធម្ម ។ បេ ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា ជាសេចក្ដីល្អដល់សង្ឃ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា ជាសេចក្ដីសប្បាយដល់សង្ឃ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្ដីអៀនខ្មាស អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីកាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ)

សម្បរាយិកានំ អាសវានំ បដិឃាតាយ យំ វិនយានុគ្គ-
ហាយ តំ អប្បសន្នានំ បសាទាយ យំ វិនយានុគ្គហាយ
តំ បសន្នានំ ភិយ្យោភាវាយ យំ វិនយានុគ្គហាយ តំ
សទ្ធម្មដ្ឋិតិយា ។

[៩៧] អត្ថសតំ ធម្មសតំ ទ្វេ ច និរុត្តិសតានិ
ចត្តារិ ញាណសតានិ អត្ថវសេ បករណេតិ ។

អត្ថវសេបករណំ និដ្ឋិតំ ។

មហាវគ្គំ និដ្ឋិតំ ។

ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងជនទាំងឡាយ ដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីតំកល់នៅមាំនៃព្រះសទ្ធម្ម ។

[៩៧] ក្នុងបករណៈសំដែងអំណាចប្រយោជន៍ (នេះ) បណ្ឌិតត្រូវដឹងថាមានអត្ថ ១ រយ ធម៌ ១ រយ និរុត្តិ ២ រយ និងញាណ ៤ រយ ។

ចប់ បករណៈ អំពីអំណាចប្រយោជន៍ ។

ចប់ មហាវគ្គ (ពួកធំ) ។

អត្ថវសេបករណំ មហាវគ្គំ ឧទ្ទានគាថា

តស្សុទ្ទានំ

(៩៨) បឋមំ អដ្ឋ ឧបជ្ឈាយ

បច្ចយេសុ ឧបជ្ជ ច

ភិក្ខូនំ សោឡសា ឯតេ

ភិក្ខុនីនញ្ច សោឡស

បេយ្យាលអន្តភេទា

ឯកុត្តរិកមេវ ច

បវារណាត្ថវសិកា

មហាវគ្គស្ស សង្គហោតិ ។

បករណៈ អំពីអំណាចប្រយោជន៍ មហាវគ្គ ឧទ្ទានគាថា

ឧទ្ទានគឺបញ្ជីរឿងនៃបករណៈអំពីអំណាចប្រយោជន៍នោះដូច្នេះ (៩៨)មុនដម្បូងនិយាយអំពីបុព្វាក្នុងការៈ ៨ យ៉ាង ១ តមកទៀត និយាយអំពីវិសជ្ជនាក្នុងការៈ ៨ យ៉ាង ក្នុងបច្ច័យទាំងឡាយ១ និយាយអំពីការៈ ១៦ របស់ភិក្ខុទាំងឡាយ ១ និយាយអំពីការៈ ១៦ របស់ភិក្ខុនីទាំងឡាយ ១ និយាយអំពីប្រភេទជាបន្ទោះនៃបេយ្យាលៈ ១ និយាយអំពីការស្រង់សេចក្ដីមួយៗ ឡើងទៅ១ និយាយអំពីបវារណា ១ និយាយអំពីអំណាចប្រយោជន៍ ១ និយាយអំពីការប្រមូលសេចក្ដីដែលជាពួកធំ ៗ ១ ។

គាថាសង្គណិកំ

(៩៩) ឯកំសំ ចីវរំ កត្វា
បគ្គណ្ហិត្វាន អញ្ជលិំ
អាសីសមានរូបោ(១)វ
កិស្ស ត្វំ ឥធមាគតោ(២) ។
ទ្វីសុ វិនយេសុ បញ្ញត្តា
ឧទ្ទេសំ អាគច្ឆន្តិ ឧបោសថេសុ
កតិ តេ សិក្ខាបទា ហោន្តិ
កតីសុ ឋានេសុ បញ្ញត្តា ។
ភទ្ទកោ តេ ឧម្មង្គោ
យោនិសោ បរិបុច្ឆសិ
តគ្ឃ តេ អហមក្ខិស្សំ
យថាបិ កុសលោ តថា ។
ទ្វីសុ វិនយេសុ បញ្ញត្តា(៣)
ឧទ្ទេសំ អាគច្ឆន្តិ ឧបោសថេសុ
អឌ្ឍុឌ្ឍសតានិ តេ ហោន្តិ
សត្តសុ ឋានេសុ បញ្ញត្តា ។

---

១ ម. អាសិសមានរូបោ វ ។ ២-៣ ម. យេ បញ្ញត្តា ។

គាថាសង្គណិកៈ[១]

[៩៩] ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សួរព្រះឧបាលិត្ថេរដ៏មានអាយុថា អ្នកធ្វើចីវរទៀងស្មាម្ខាង រួចប្រណម្យអញ្ជលី ធ្វើហាក់ដូចជាមានបំណង (អ្វីមួយ) មកក្នុងទីនេះដើម្បីអ្វី ។ ព្រះឧបាលិត្ថេរ ក្រាបបង្គំទូលសួរថា សិក្ខាបទទាំងឡាយណាដែលព្រះអង្គបានបញ្ញត្តទុកក្នុងវិន័យទាំងពីរ តែងមកកាន់ឧទ្ទេសរាល់ៗថ្ងៃឧបោសថ សិក្ខាបទទាំងនោះមានប៉ុន្មាន ទ្រង់បញ្ញត្តក្នុងនគរណាខ្លះ ។ ព្រះអង្គទ្រង់ត្រាស់តបថា អ្នកមានប្រាជ្ញាមោះមុតល្អហើយ អ្នកសួរដោយឧបាយ ព្រោះហេតុនោះ តថាគតនឹងប្រាប់អ្នក តាមទំនងដែលតថាគតជាអ្នកឈ្លាសវៃ ។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្តទុកក្នុងវិន័យទាំងពីរ តែងមកកាន់ឧទ្ទេសរាល់ៗថ្ងៃឧបោសថ សិក្ខាបទនោះ មាន ៣៥០ សិក្ខាបទ តថាគតបញ្ញត្តក្នុងនគរទាំង៧ ។

---

១ អដ្ឋកថា ហៅថា បឋមគាថាសង្គណិកៈ (គាថាឆ្លូកឆ្លាស់ជាដំបូង) ។

គាថាសង្គណិកំ បញ្ហាព្យាករណំ

(១០០) កតមេសុ សត្តសុ នគរេសុ បញ្ញត្តា ។
ឥង្ឃ មេ ត្វំ[១] ព្យាករណំ ។
តវ[២] វចនបថំ និសាមយិត្វា
បដិបជ្ជេម ហិតាយ នោ សិយា ។
វេសាលិយា រាជគហេ
សាវត្ថិយា ច អាឡវិយា
កោសម្ពិយា ច សក្កេសុ
ភគ្គេសុ ចេវ បញ្ញត្តា ។

(១០១) កតិ វេសាលិយា បញ្ញត្តា
កតិ រាជគហេ កតា
សាវត្ថិយា កតិ ហោន្តិ[៣]
កតិ អាឡវិយា កតា
កតិ កោសម្ពិយា បញ្ញត្តា
កតិ សក្កេសុ វុច្ចន្តិ
កតិ ភគ្គេសុ បញ្ញត្តា
តំ មេ អក្ខាហិ បុច្ឆិតោ ។

---

១ ឱ. ម. តំ ។ ២ ឱ. ម. តំ ។ ៣ បញ្ញត្តា ។

(១០០) ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា សិក្ខាបទដែលទ្រង់បញ្ញត្តក្នុងនគរទាំង ៧ នោះតើ នគរណាខ្លះ ។ សូមព្រះអង្គដោះស្រាយនូវប្រស្នានោះ របស់ខ្ញុំព្រះអង្គ យើងខ្ញុំទាំងឡាយនឹងពិចារណា នូវគន្លងពាក្យរបស់ព្រះអង្គ ហើយប្រតិបត្តិតាម ការប្រតិបត្តិតាមនោះនឹងជាប្រយោជន៍ដល់យើងខ្ញុំទាំងឡាយ ។ ឯសិក្ខាបទទាំងឡាយ ដែលតថាគតបញ្ញត្ត (ក្នុងនគរទាំង ៧ នោះ) គឺ នគរវេសាលី ១ រាជគ្រឹះ ១ សាវត្ថី ១ អាឡវី ១ កោសម្ពី ១ ដែនសក្កៈ ១ ដែនភគ្គៈ ១ ។

(១០១) ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា សិក្ខាបទប៉ុន្មានដែលទ្រង់បញ្ញត្ត ក្នុងនគរវេសាលី សិក្ខាបទប៉ុន្មានដែលទ្រង់បញ្ញត្ត ក្នុងនគររាជគ្រឹះ សិក្ខាបទប៉ុន្មានដែលទ្រង់បញ្ញត្ត ក្នុងនគរសាវត្ថី សិក្ខាបទប៉ុន្មានដែលទ្រង់បញ្ញត្ត ក្នុងនគរអាឡវី សិក្ខាបទប៉ុន្មានដែលទ្រង់បញ្ញត្ត ក្នុងនគរកោសម្ពី សិក្ខាបទប៉ុន្មានដែលទ្រង់បញ្ញត្ត ក្នុងដែនសក្កៈ សិក្ខាបទប៉ុន្មានដែលទ្រង់បញ្ញត្ត ក្នុងភគ្គជនបទ ខ្ញុំព្រះអង្គសួរនូវសេចក្ដីណា សូមទ្រង់ព្រះមេត្តាប្រោសប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ។

ទស វេសាលិយា បញ្ញត្តា
ឯកវីសា[១] រាជគហេ កតា
ឆឩនតីណិ សតានិ
សព្វេ សាវត្ថិយា កតា
ឆ អាឡវិយា បញ្ញត្តា
អដ្ឋ កោសម្ពិយា កតា
អដ្ឋ សក្កេសុ វុច្ចន្តិ
តយោ ភគ្គេសុ បញ្ញត្តា ។
យេ វេសាលិយា បញ្ញត្តា
តេ សុណោហិ យថាតថំ[២] ។
មេថុនំ វិគ្គហុត្តរិ[៣]
អតិរេកញ្ច កាឡកំ
ភូតំ បរម្បរភត្តំ
ទន្តបោណេន អចេលកោ
ភិក្ខុនីសុ ច អក្កោសោ
ទសេតេ វេសាលិយា កតា ។
យេ រាជគហេ បញ្ញត្តា

---

១ ឱ. ឯកវីសំ ។ ម. ឯកវីសេ ។ ២ ឱ. ម. យថាតថំ ។ ៣ ឱ. មេថុនវិគ្គហុត្តរិ ។ ម. មេថុនវិគ្គហំ ឧត្តរិធម្មោ ។

ព្រះអង្គទ្រង់ត្រាស់ថា តថាគតបញ្ញត្តសិក្ខាបទ ១០ ក្នុងនគរវេសាលី តថាគតបញ្ញត្តសិក្ខាបទ ២១ ក្នុងនគររាជគ្រឹះ តថាគតបញ្ញត្តសិក្ខាបទទាំងអស់ ២៩៤ ក្នុងនគរសាវត្ថី តថាគតបញ្ញត្តសិក្ខាបទ ៦ ក្នុងនគរអាឡវី តថាគតបញ្ញត្តសិក្ខាបទ ៨ ក្នុងនគរកោសម្ពី តថាគតបញ្ញត្តសិក្ខាបទ ៨ ក្នុងដែនសក្កៈ តថាគតបញ្ញត្តសិក្ខាបទ ៣ ក្នុងដែនភគ្គៈ ។ សិក្ខាបទទាំងឡាយណាដែលតថាគតបញ្ញត្ត ក្នុងនគរវេសាលី អ្នកចូរប្រុងស្តាប់សិក្ខាបទទាំងនោះដូចសំដែងតទៅនេះ ។ មេថុនធម្មសិក្ខាបទ ១ មនុស្សវិគ្គហសិក្ខាបទ ១ ឧត្តរិមនុស្សធម្មសិក្ខាបទ ១ អតិរេកសិក្ខាបទ[១] ១ កាឡកសិក្ខាបទ ១ ភូតគាមសិក្ខាបទ ១ បរម្បរភត្តសិក្ខាបទ ១ ទន្តពោណសិក្ខាបទ ១ អចេលកសិក្ខាបទ ១ ភិក្ខុនីសុអក្កោសកសិក្ខាបទ ១ ទាំង ១០ សិក្ខាបទនេះ តថាគតបញ្ញត្ត ក្នុងនគរវេសាលី ។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្ត ក្នុងនគររាជគ្រឹះ អ្នកចូរប្រុង

---

១ បឋមកឋិនសិក្ខាបទ ។

គាថាសង្គណិកំ បញ្ហាព្យាករណំ

តេ សុណោហិ យថាតថំ ។

អតិដ្ឋានំ ភជតោ

ទ្វេ ច អនុទ្ធំសនា

ទ្វេបិ ច ភេទា អន្តរវាសកំ

រូបិយំ សុត្តំ ឧជ្ឈាបនកេន ច

ទាចិតបិណ្ឌំ គណភោជនំ វិកាលេ

ចារិត្តំ ន្ហានំ ឩនវីស

ចីវរំ ទត្វា វោសាសន្តី

ឯតេ ភជតោ កាតា ។

តិរក្ខចរិយោ តត្ថេវ(១)

ឆន្ទានេន ឯកវីសតិ ។

យេ សាវត្ថិយា បញ្ញត្តា

តេ សុណោហិ យថាតថំ ។

ទាភជិកាដិ ចត្តារិ

---

១ ឱ. តហើ ។

ស្តាប់សិក្ខាបទទាំងនោះដូចសំដែងតទៅនេះ ។ អទិន្នាទានសិក្ខាបទ ១ (សញ្ចាបិកសិក្ខាបទ[១] ១) អនុទ្ធំសនសិក្ខាបទទាំងពីរ ភេទសិក្ខាបទទាំងពីរ អន្តរាសកសិក្ខាបទ[២] ១ រូបិយសិក្ខាបទ ១ សុត្តវិញ្ញត្តិសិក្ខាបទ ១ ឧជ្ឈាបនកសិក្ខាបទ ១ បាចិតបិណ្ឌសិក្ខាបទ[៣] ១ គណភោជនសិក្ខាបទ ១ វិកាលភោជនសិក្ខាបទ ១ ចារិត្តសិក្ខាបទ ១ នហានសិក្ខាបទ ១ ឧនវីសសិក្ខាបទ ១ ចីវរទានសិក្ខាបទ[៤] ១ ហេសាសន្តិសិក្ខាបទ[៥] ១ សិក្ខាបទទាំងនេះ តថាគតបញ្ញត្ត ក្នុងនគររាជគ្រឹះ ។ គិរគ្គសិក្ខាបទ ១ ចារិកសិក្ខាបទ ១ ឆន្ទទានសិក្ខាបទ[៦] ១ (សិក្ខាបទទាំងនេះរួមពីលើមកត្រូវជា) ២១ សិក្ខាបទ តថាគតបញ្ញត្ត ក្នុងក្រុងរាជគ្រឹះនោះដែរ ។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្ត ក្នុងក្រុងសាវត្ថី អ្នកចូលប្រុងស្តាប់សិក្ខាបទទាំងនោះដូចសំដែងតទៅនេះ ។ បារាជិកសិក្ខាបទ ៤

---

១ ក្នុងទីនេះមានកំណត់ថា សិក្ខាបទដែលទ្រង់បញ្ញត្តក្នុងក្រុងរាជគ្រឹះ ២១ សិក្ខាបទ តែបានរាប់តាមបាលីទៅឃើញតែ ២០ សិក្ខាបទ លះពិនិត្យមើលក្នុងមហាវិភង្គឃើញថា សញ្ចាបិកសិក្ខាបទនេះ ក៏ទ្រង់បញ្ញត្តក្នុងក្រុងរាជគ្រឹះដែរ ។ ២ ចីវរប្បដិគ្គហណសិក្ខាបទ ។ ៣ បរិបាចនសិក្ខាបទ ។ ៤ វិយ្យធម្មសិក្ខាបទ ។ ៥ កុលេសុនិមន្តិតសិក្ខាបទ ។ ៦ បីសិក្ខាបទខាងចុងនេះ ជាសិក្ខាបទភិក្ខុនី ។

សង្ឃាទិសេសា ភវន្តិ សោឡស
អនិយតា ទ្វេ(១) ហោន្តិ
និស្សគ្គិយា ចតុត្តឹសតិ(២)
ឆប្បញ្ញាសសតញ្ចេវ
ខុទ្ទកានិ បវុច្ចរេ(៣)
ទស គារយ្ហា ទ្វេសត្តតិ សេខិយា(៤) ។
ឆឩនតីណិ សតានិ សព្វេ សាវត្ថិយា កតា ។
យេ អាឡវិយា បញ្ញត្តា
តេ សុណោហិ យថាតថំ ។
កុដិកោសិយសេយ្យា ច
ខណនេ គច្ឆ ទេវតេ
សប្បាណកញ្ច សិញ្ចន្តិ
ឆ ឯតេ អាឡវិយា កតា ។
យេ កោសម្ពិយា បញ្ញត្តា
តេ សុណោហិ យថាតថំ ។

១ ម. អនិយតា ច ទ្វេ ហោន្តិ ។ ២ ចតុវីសតីតិ ឱ. ម. ពោត្ថកេ ទិស្សតិ ។ ចតុត្តឹសតីតិ កត្ថចិ ពោត្ថកេ ទិស្សតិ ។ យុត្តតរមេវេតំ ។ មហាវិភង្គេ បន សព្វេសំ សិក្ខាបទានំ បមាណំ អម្ហេហិ វិចិនិតំ ។ តស្មា ហិ ចតុត្តឹសប្បមាណានិ និស្សគ្គិយសិក្ខាបទានិ សាវត្ថិយំ បញ្ញត្តានិ ហោន្តិ ។ ៣ ឱ. ម. បវុច្ចន្តិ ។ ៤ ម. ទសយេវ ច គារយ្ហា ទ្វេសត្តតិ ច សេខិយា ។

សង្ឃាទិសេសសិក្ខាបទ ១៦ អនិយតសិក្ខាបទ ២ និស្សគ្គិយ-
សិក្ខាបទ ៣៤[1] សិក្ខាបទ ១៥៦ ដែលតថាគតហៅថាខុទ្ទក-
សិក្ខាបទ គារយ្ហសិក្ខាបទ ១០ នឹងសេខិយវត្ត ៧២ ។ រួមទាំង
អស់ត្រូវជាសិក្ខាបទ ២៩៤ ដែលតថាគតបញ្ញត្ត ក្នុងនគរសា-
វត្ថី ។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្ត ក្នុងនគរ
អាឡវី ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅ
នេះ ។ កុដិការសិក្ខាបទ ១ កោសិយសិក្ខាបទ ១ បឋមសហ-
សេយ្យសិក្ខាបទ ១ បឋវីខណនសិក្ខាបទ ១ ភូតគាមសិក្ខាបទ ១
សប្បាណកសិក្ខាបទ ១ សិក្ខាបទទាំង ៦ នេះ តថាគតបញ្ញត្តក្នុង
នគរអាឡវី ។ សិក្ខាបទណា ដែលតថាគតបញ្ញត្តក្នុងនគរកោ-
សម្ពី ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ ។

---

១ ឃើញក្នុងគម្ពីរឱរុបនឹងគម្ពីរភូមាថា ២៤ ។ ឃើញក្នុងគម្ពីរ (ស៊ីករិត) ខុះថា ៣៤ ។ ពាក្យថា ៣៤ នេះគួរជាង ។ ដ្បិតចំនួនសិក្ខាបទទាំងអស់ក្នុងមហាវិភង្គ យើងបានជ្រើសរើសរួចហើយ ។ សេចក្តីពិតថា ក្នុងមហាវិភង្គនោះ មាននិស្សគ្គិយសិក្ខាបទចំនួន ៣៤ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី ។

គាថាសង្គណិកំ បញ្ហាព្យាករណំ

មហាវិហារេ នោវចស្សំ
អញ្ញំ ទ្វារំ សុភយ ច
អនាគរិយំ សហាជម្មោ ច
បយោភាគេន អដ្ឋមំ ។
យេ សក្កេសុ បញ្ញត្តា
តេ សុណោហិ យថាកថំ ។
ឃឧ្យកលោមានិ បត្តោ ច
ឱភតោបិ ច[1] កេសជ្ជំ
សូចិ អារញ្ញកោ ចេវ
ជ ឃតេ កាបិលវត្ថុវេ[2] ។
ឧទកេ សុទ្ធិយា ឱភេរ
ភិក្ខុនីសុ បវុត្តិ ។
យេ កត្តេសុ បញ្ញត្តា
តេ សុណោហិ យថាកថំ ។
សមាទហិត្វា វិសិព្វេន្តិ
សាមិសេន សសិត្ថកំ ។
ភាភធិកានិ ចត្តារិ

---

១ ឱ. ម. ឱភតោ ចេវ ។ ២ កាបិលវត្ថុកេតិ កត្ថចិ ពោត្ថកេ ទិស្សតិ ។

មហល្លកសិក្ខាបទ [១] ១ ទុព្វចជាតិកសិក្ខាបទ ១ អញ្ញវាទក-
សិក្ខាបទ ១ មហល្លកសិក្ខាបទ [២] ១ សុរាបានសិក្ខាបទ ១
អនាទរិយសិក្ខាបទ ១ សហធម្មិកសិក្ខាបទ ១ សុរុសុរុការក-
សិក្ខាបទ ១ ជាគំរប់ ៨ ។ សិក្ខាបទទាំងឡាយណា
ដែលតថាគតបញ្ញត្ត ក្នុងដែនសក្កៈ ចូរអ្នកប្រុងស្តាប់សិក្ខាបទ
ទាំងនោះ ដូចសំដែងតទៅនេះ ។ ឯឡកលោមធោវន
សិក្ខាបទ ១ បត្តសិក្ខាបទ [៣] ១ ឱវាទសិក្ខាបទ [៤] ១ ភេសជ្ជ-
សិក្ខាបទ [៥] ១ សូបិយសិក្ខាបទ ១ អារញ្ញកសេនាសន-
សិក្ខាបទ ១ ទាំង ៦ សិក្ខាបទនេះ តថាគតបញ្ញត្ត ក្នុងក្រុង
កបិលពស្តុ ។ ឧទកសុទ្ធិយសិក្ខាបទនឹងឱវាទុបសង្កមន-
សិក្ខាបទ ក្នុងភិក្ខុនីវិភង្គ ក៏តថាគតបញ្ញត្ត (ក្នុងដែនសក្កៈ
ដែរ) ។ សិក្ខាបទទាំងឡាយណា [៥] ដែលតថាគតបញ្ញត្ត
ក្នុងដែនភគ្គៈ ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែង
តទៅនេះ ។ ជោតិសមាទហនវិសិព្វនសិក្ខាបទ ១ សាមិ-
សសិក្ខាបទ ១ សសិត្ថកសិក្ខាបទ ១ ។ បាកដិកសិក្ខាបទ ៤

---

១ ក្នុងតេរសកណ្ឌ (សង្ឃាទិសេស) ។ ២ ក្នុងបាចិត្តិយកណ្ឌ (ភូតគាមវគ្គ) ។ ៣ ឩន-បញ្ចពន្ធនសិក្ខាបទ ។ ៤ ភិក្ខុនូបស្សយសិក្ខាបទ ។ ៥ មហានាមសិក្ខាបទ ។

សង្ឃាទិសេសានិ ចត្តារិ សត្ត

និស្សគ្គិយានិ អដ្ឋ

ទ្វត្តឹសានិ ច ខុទ្ទកា(១)

ទ្វេ គារយ្ហា ឯកោ សេខោ ឆបញ្ញាស

ឆសុ នគរេសុ បញ្ញត្តា

ពុទ្ធេនាទិច្ចពន្ធុនា

ឆឡូនតីណិ សតានិ

សព្វេ សាវត្ថិយា កតា

គោតមេន យសស្សិនា(២) ។

(១០២) យន្តំ អបុច្ឆិម្ហា អកិត្តយី នោ(៣)

តន្តំ(៤) ព្យាកតំ អនញ្ញថា ។

អញ្ញត្តំ បុច្ឆាម(៥) តទិង្ឃ ព្រូហិ ។

គរុកំ លហុកំ ចាបិ

សាវសេស អនវសេសំ

ទុដ្ឋុល្លញ្ច អទុដ្ឋុល្លំ

---

១ ឱ. ម. ទ្វត្តឹស ខុទ្ទកា ។ ២ ឱ. ម. ការុណិកេន ពុទ្ធេន គោតមេន យសស្សិ-
នា ។ ៣ ប. យន្តំ បុច្ឆិម្ហ អកិត្តយិនោ ។ ៤ ម. តំ តំ ។ ៥ ឱ. ម. បុច្ឆាមិ ។

សង្ឃាទិសេសសិក្ខាបទ ១៧ និស្សគ្គិយសិក្ខាបទ ១៨ ខុទ្ទកសិក្ខាបទ ៣២ បាដិទេសនីយសិក្ខាបទ ២ សេខិយសិក្ខាបទ ៣ ទាំង ៥៦ សិក្ខាបទ (នេះ) ព្រះពុទ្ធដែលជាអាទិច្ចពន្ធុ ទ្រង់បញ្ញត្ត ក្នុងនគរទាំង ៦ សិក្ខាបទទាំងអស់មាន ២៩៤ ព្រះគោតមដ៏មានយសទ្រង់បញ្ញត្ត ក្នុងនគរសាវត្ថី ។

[១០២] ខ្ញុំព្រះអង្គបានសួរហើយនូវប្រស្នាណា ព្រះអង្គក៏បានសំដែងហើយដល់ខ្ញុំព្រះអង្គ (១ទៀត) ពាក្យណាដែលខ្ញុំព្រះអង្គ បានទូលសួរហើយ ព្រះអង្គក៏បានព្យាករពាក្យនោះដោយមិនមានលើសខ្វះ ។ ខ្ញុំព្រះអង្គសូមសួរនូវប្រស្នាដោយឡែកទៀត សូមទ្រង់សំដែងនូវប្រស្នានោះមក ។ សូមសួរថា គរុកាបត្តិក្តី លហុកាបត្តិក្តី សាវសេសាបត្តិក្តី អនវសេសាបត្តិក្តី ទុដ្ឋុល្លាបត្តិក្តី អទុដ្ឋុល្លាបត្តិក្តី ភិក្ខុទាំងឡាយ

គាថាសង្គណិកំ យាវតតិយកាទិព្យាករណំ

យេ ច យាវតតិយកា

សាធារណាំ អសាធារណាំ

វិបត្តិយោ ច យេហិ សមថេហិ សម្មន្តិ

សព្វានិ បេតានិ វិយាករោហិ ។

ហន្ទ វាក្យំ សុណោម តេ ។

ឯកត្តឹសា យេ គរុកា

អដ្ឋេត្ថ អនវសេសា

យេ គរុកា តេ ទុដ្ឋុល្លា

យេ ទុដ្ឋុល្លា សា សីលវិបត្តិ ។

បារាជិកំ សង្ឃាទិសេសោ

សីលវិបត្តីតិ វុច្ចតិ ។

ថុល្លច្ចយំ បាចិត្តិយំ

បាដិទេសនីយំ ទុក្កដំ

ទុព្ភាសិតំ យោចាយំ

អក្កោសតិ ហស្សាធិប្បាយោ ។

អយំ សា អាចារវិបត្តិសម្មតា ។

ដែលត្រូវអាបត្តិជា យាវតតិយកាក្តី (សិក្ខាបទ) ដែលជាសាធារណបញ្ញត្តិក្តី ជាអសាធារណបញ្ញត្តិក្តី វិបត្តិទាំងឡាយតែងរម្ងាប់ ដោយសមថៈទាំងឡាយណាក្តី សូមព្រះអង្គព្យាករនូវពាក្យទាំងឡាយមានអាបត្តិជាដើមនេះ ។ ហ៎ យើងទាំងឡាយនឹងស្តាប់នូវព្រះពុទ្ធដីការបស់ព្រះអង្គ ។ អាបត្តិទាំងឡាយ ដែលចាត់ជាគរុកាបត្តិមាន ៣១[(១)] អាបត្តិទាំងឡាយ ដែលចាត់ជាអនវសេសាបត្តិមាន ៨ មកក្នុងទីនេះ អាបត្តិទាំងឡាយណា ជាគរុកាបត្តិក្តី អាបត្តិទាំងនោះ ហៅថា ទុដ្ឋុល្លាបត្តិ អាបត្តិទាំងឡាយណា ជាទុដ្ឋុល្លាបត្តិ អាបត្តិទាំងនោះហៅថា សីលវិបត្តិ ។ បារាជិកាបត្តិនឹងសង្ឃាទិសេសាបត្តិ ព្រះសម្មាសម្ពុទ្ធទ្រង់ហៅថា សីលវិបត្តិ ។ ថុល្លច្ចយាបត្តិ បាចិត្តិយាបត្តិ បាដិទេសនីយាបត្តិ ទុក្កដាបត្តិ នឹងទុព្ភាសិតាបត្តិ ដូចយ៉ាងភិក្ខុណា មានសេចក្តីប៉ុនប៉ងនឹងសើចលេងហើយដេរ ។ អាបត្តិទាំងនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថាជាអាចារវិបត្តិ ។

---

១ រាប់យកបារាជិកាបត្តិរបស់ភិក្ខុ ៤ របស់ភិក្ខុនី ៤ ទាំងរាប់សង្ឃាទិសេសាបត្តិរបស់ភិក្ខុ ១៣ របស់ភិក្ខុនី ១០ មកបូកផ្សំគ្នា ត្រូវជាគរុកាបត្តិមាន ៣១ ។

(១០៣) វិបន្នទិដ្ឋី គណ្ហន្តិ
អសទ្ធម្មេហិ បុរក្ខតា
អព្ភាចិក្ខន្តិ សម្ពុទ្ធំ
ទុប្បញ្ញា មោហបារុតា
អយំ សា ទិដ្ឋិវិបត្តិសម្មតា ។

(១០៤) អាជីវហេតុ អាជីវការណា បាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបតិ អាជីវហេតុ អាជីវការណា សញ្ចរិត្តំ សមាបជ្ជតិ អាជីវហេតុ អាជីវការណា យោ តេ វិហារេ វសតិ សោ ភិក្ខុ អរហាតិ ភណតិ អាជីវហេតុ អាជីវការណា ភិក្ខុ បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាជីវហេតុ អាជីវការណា ភិក្ខុនី បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាជីវហេតុ អាជីវការណា ភិក្ខុ សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ ។ អយំ សា អាជីវវិបត្តិសម្មតា ។

(១០៣) ភិក្ខុទាំងឡាយ ដែលអសទ្ធម្មបរិត ជាអ្នកអាប់ប្រាជ្ញា ដែលមោហៈបិទបាំង ប្រកាន់ទិដ្ឋិខុស តែងពោលបង្កាច់នូវព្រះសម្មាសម្ពុទ្ធនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ជាទិដ្ឋិវិបត្តិ ។

(១០៤) ភិក្ខុមានសេចក្តីប្រាថ្នាអាក្រក់ លុះក្នុងអំណាចសេចក្តីប្រាថ្នា ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន (ក្នុងខ្លួន) ដែលមិនពិត ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ជាភិក្ខុប្រព្រឹត្តិនិយាយដឹកនាំបុរសឲ្យស្ត្រី ដឹកនាំស្ត្រីឲ្យបុរស ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអា-ជីវៈ ភិក្ខុពោលថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះឯងជាព្រះអរហន្ត ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ភិក្ខុសូមបណីតភោជនទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួនមកបរិភោគ ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ភិក្ខុនីសូមបណីតភោជនទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួនយកមកបរិភោគ ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ភិក្ខុដែលមិនមានជម្ងឺ សូមសម្លក្តី បាយក្តី ដើម្បីប្រយោជន៍ដល់ខ្លួនយកមកបរិភោគ ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ។ នេះព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថាជា អាជីវវិបត្តិ ។

[១០៩] ឯកាទស យាវតតិយកា

តេ សុណោហិ យថាកមំ

ឧក្ខិត្តានុវត្តិកា

អដ្ឋ យាវតតិយកា

អរិដ្ឋោ ចណ្ឌកាលី ច

ឥមេ តេ យាវតតិយកា ។

[១១០] កតិ ឆេទនកានិ កតិ ភេទនកានិ កតិ ឧទ្ទាលនកានិ កតិ អនញ្ញាចិត្តិយានិ កតិ ភិក្ខុសម្មុតិយោ កតិ សាមីចិយោ កតិ បរមានិ

កតិ ជានន្តិ បញ្ញត្តា

ពុទ្ធេនាទិច្ចពន្ធុនា ។

[១០៥] បុគ្គល ១១ រូប (ត្រូវអាបត្តិក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្ម) ចប់ ជាគំរប់ ៣ ដង ចូរអ្នកប្រុងស្តាប់នូវសេចក្តីនៃបុគ្គលទាំងនោះ ដូចសំដែងតទៅនេះ គឺ ឧក្ខិត្តានុវត្តិកភិក្ខុមួយពួក ភិក្ខុ ដែលត្រូវអាបត្តិក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្ម) ចប់ ជាគំរប់ ៣ ដង ៨ រូប អរិដ្ឋភិក្ខុមួយរូប ចណ្ឌកាលីភិក្ខុនីមួយរូប បុគ្គលទាំងប៉ុណ្ណេះ (ត្រូវអាបត្តិក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្ម) ចប់ ជាគំរប់ ៣ ដង ។

(១០៦) សួរថា ព្រះពុទ្ធដែលជាអាទិច្ចពន្ធុ ទ្រង់បញ្ញត្តថា សិក្ខាបទដែលមានកិរិយាកាត់ចេញជាវិនយកម្ម មានប៉ុន្មាន សិក្ខាបទដែលមានកិរិយាបំបែកចេញជាវិនយកម្ម មានប៉ុន្មាន សិក្ខាបទដែលមានកិរិយាកកាយចេញជាវិនយកម្ម មានប៉ុន្មាន អនញ្ញបាចិត្តិយសិក្ខាបទ គឺបាចិត្តិយៈដែលមានពាក្យថាមិនមែនហេតុដទៃ មានប៉ុន្មាន សិក្ខាបទដែលនិយាយពីការសន្មតិភិក្ខុ មានប៉ុន្មាន សិក្ខាបទដែលនិយាយពីសាមីចិកម្ម មានប៉ុន្មាន សិក្ខាបទដែលនិយាយពីកំណត់ មានប៉ុន្មាន

សិក្ខាបទដែលមានពាក្យថាដឹង មានប៉ុន្មាន ។

ឆ ឆេទនកានិ ឯកំ ភេទនកំ ឯកំ ឧទ្ទាលនកំ ចត្តារិ អនញ្ញបាចិត្តិយានិ ចតស្សោ ភិក្ខុសម្មតិយោ សត្តសាមីចិយោ ចុទ្ទស បរមានិ

សោឡស ជានន្តិ បញ្ញត្តា
ពុទ្ធេនាទិច្ចពន្ធុនា ។

(១០៧) វីសំ ទ្វេ សតានិ ភិក្ខូនំ សិក្ខាបទានិ ឧទ្ទេសំ អាគច្ឆន្តិ ឧបោសថេសុ តីណិ សតានិ ចត្តារិ ភិក្ខុនីនំ សិក្ខាបទានិ ឧទ្ទេសំ អាគច្ឆន្តិ ឧបោសថេសុ ។

ឆ ចត្តាឡីស(១) ភិក្ខូនំ
ភិក្ខុនីហិ អសាធារណា
សតំ តិំសា ច ភិក្ខុនីនំ
ភិក្ខូហិ អសាធារណា
សតំ សត្តតិ ឆ ចេវ
ឧភិន្នំ អសាធារណា
សតំ សត្តតិ ចត្តារិ
ឧភិន្នំ សមសិក្ខាតា ។

---

មានហេតុជាសមុដ្ឋាន ។ សតិវិន័យ ។ បេ ។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា និងតិណវត្ថារកៈ មានហេតុជាគ្រឿងប្រគល់ឲ្យនូវផល មានហេតុជាហេតុឲ្យកើតឡើង មានហេតុជាកំណើត មានហេតុជាដែន មានហេតុជាអង្គ មានហេតុជាសមុដ្ឋាន ។ សម្មុខាវិន័យ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន ។ សតិវិន័យ ។ បេ ។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា និងតិណវត្ថារកៈ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន ។ សម្មុខាវិន័យ មានបច្ច័យជាគ្រឿងប្រគល់ឲ្យនូវផល មានបច្ច័យជាហេតុឲ្យកើតឡើង មានបច្ច័យជាកំណើត មានបច្ច័យជាដែន មានបច្ច័យជាអង្គ មានបច្ច័យជាសមុដ្ឋាន ។ សតិវិន័យ ។បេ។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា និងតិណវត្ថារកៈ មានបច្ច័យជាគ្រឿងប្រគល់ឲ្យនូវផល មានបច្ច័យជាហេតុឲ្យកើតឡើង មានបច្ច័យជាកំណើត មានបច្ច័យជាដែន មានបច្ច័យជាអង្គ មានបច្ច័យជាសមុដ្ឋាន ។

[១៤៥] សត្តន្នំ សមថានំ កតិ មូលានិ កតិ សមុដ្ឋានា ។ សត្តន្នំ សមថានំ ឆត្តឹស មូលានិ ឆត្តឹស សមុដ្ឋានា ។ សត្តន្នំ សមថានំ កតមានិ ឆត្តឹស មូលានិ ។ សម្មុខាវិនយស្ស ចត្តារិ មូលានិ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។ សតិវិនយស្ស ចត្តារិ មូលានិ ។ អមូឡ្ហវិនយស្ស ចត្តារិ មូលានិ ។ បដិញ្ញាតករណស្ស ទ្វេ មូលានិ យោ ច ទេសេតិ យស្ស ច ទេសេតិ ។ យេភុយ្យសិកាយ ចត្តារិ មូលានិ តស្សបាបិយសិកាយ ចត្តារិ មូលានិ ។ តិណវត្ថារកស្ស ចត្តារិ មូលានិ សង្ឃសម្មុខតា ធម្មសម្មុខតា វិនយសម្មុខតា បុគ្គលសម្មុខតា ។ សត្តន្នំ សមថានំ ឥមានិ ឆត្តឹស មូលានិ ។ សត្តន្នំ សមថានំ កតមេ ឆត្តឹស សមុដ្ឋានា ។ សតិវិនយស្ស កម្មស្ស កិរិយា ករណំ ឧបគមនំ អជ្ឈុបគមនំ អធិវាសនា អប្បដិក្កោសនា ។ អមូឡ្ហវិនយស្ស កម្មស្ស ។ បេ ។ បដិញ្ញាតករណស្ស កម្មស្ស ។ បេ ។ យេភុយ្យសិកាយ កម្មស្ស ។ បេ ។

[១៤៩] សមថៈទាំង ៧ មានមូលប៉ុន្មាន មានសមុដ្ឋានប៉ុន្មាន ។ សមថៈទាំង ៧ មានមូល ២៦ មានសមុដ្ឋាន ៣៦ ។ សមថៈទាំង ៧ មានមូល ២៦ (នោះ) ដូចម្តេច ។ សម្មុខាវិន័យមានមូល ៤ គឺចំពោះមុខសង្ឃ ១ ចំពោះមុខធម៌ ១ ចំពោះមុខវិន័យ ១ ចំពោះមុខបុគ្គល ១ ។ សតិវិន័យមានមូល ៤ ។ អមូឡ្ហវិន័យមានមូល ៤ ។ បដិញ្ញាតករណៈមានមូល ២ គឺ បុគ្គលណាសំដែង ១ សំដែងចំពោះបុគ្គលណា ១ ។ យេភុយ្យសិកាមានមូល ៤ តស្សបាបិយសិកាមានមូល ៤ ។ តិណវត្ថារកៈមានមូល ៤ គឺ ចំពោះមុខសង្ឃ ១ ចំពោះមុខធម៌ ១ ចំពោះមុខវិន័យ ១ ចំពោះមុខបុគ្គល ១ ។ នេះជាមូល ២៦ របស់សមថៈទាំង ៧ ។ សមថៈទាំង[១] ៧ មានសមុដ្ឋាន ៣៦ (នោះ) ដូចម្តេចខ្លះ ។ ការធ្វើញត្តិ ការបញ្ញប់ញត្តិ ការចូលទៅធ្វើដោយខ្លួនឯង ការបង្គាប់ឲ្យគេចូលទៅធ្វើ ការទទួលបង្គាប់ ការមិនហាមឃាត់នូវសង្ឃកម្ម គឺ សតិវិន័យ ។ នូវសង្ឃកម្ម គឺ អមូឡ្ហវិន័យ ។ បេ ។ នូវសង្ឃកម្ម គឺបដិញ្ញាតករណៈ ។ បេ ។ នូវសង្ឃកម្ម គឺ យេភុយ្យសិកា ។ បេ ។

---

១ អដ្ឋកថាពន្យល់ថា ត្រង់ពាក្យបុច្ឆាអំពីសមុដ្ឋាន ដែលលោកពោលថា សមថៈទាំង ៧ មានសមុដ្ឋាន ៣៦ នោះតើដូចម្តេច ដូច្នេះ ក៏មែនពិតហើយ តែបានជាលោកចែកតែសមថៈ៦ ក្នុងសមថៈ មួយ ៗ មានសមុដ្ឋានប្រាំមួយៗ ដូច្នេះវិញ ព្រោះសម្មុខាវិន័យមិនមានសមុដ្ឋានទេ ដោយមិនបានសង្គ្រោះចូលក្នុងកម្ម ។

តស្សបាបិយសិកាយ កម្មស្ស ។ បេ ។ តិណវត្ថារកស្ស កម្មស្ស កិរិយា ករណំ ឧបគមនំ អជ្ឈុបគមនំ អធិវាសនា អប្បដិក្កោសនា ។ សត្តន្នំ សមថានំ ឥមេ ឆត្តឹស សមុដ្ឋានា ។

(១៥២) សម្មុខាវិនយោតិ វា សតិវិនយោតិ វា ឥមេ ធម្មា នានត្ថា នានាព្យញ្ជនា ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានំ ។ សម្មុខាវិនយោតិ វា អមូឡ្ហវិនយោតិ វា ។ បេ ។ សម្មុខាវិនយោតិ វា បដិញ្ញាតករណន្តិ វា សម្មុខាវិនយោតិ វា យេភុយ្យសិកាតិ វា សម្មុខាវិនយោតិ វា តស្សបាបិយសិកាតិ វា សម្មុខាវិនយោតិ វា តិណវត្ថារកោតិ វា ឥមេ ធម្មា នានត្ថា នានាព្យញ្ជនា ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានំ ។ សម្មុខាវិនយោតិ វា សតិវិនយោតិ វា ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ។ សម្មុខាវិនយោតិ វា អមូឡ្ហវិនយោតិ វា ។ បេ ។ សម្មុខាវិនយោតិ វា បដិញ្ញាតករណន្តិ វា សម្មុខាវិនយោតិ វា យេភុយ្យសិកាតិ វា សម្មុខាវិន-

នូវសង្ឃកម្ម គឺតស្សបាបិយសិកា ។ បេ ។ ការធ្វើញត្តិ ការបញ្ចប់ញត្តិ ការចូលទៅធ្វើដោយខ្លួនឯង ការបង្គាប់ឲ្យគេចូលទៅធ្វើ ការទទួលបង្គាប់ ការមិនហាមឃាត់ នូវសង្ឃកម្ម គឺតិណវត្ថារកៈ ។ នេះជាសមុដ្ឋាន ៣៦ របស់សមថៈ ៧ ។

[១៨៦] សម្មុខាវិន័យនឹងសតិវិន័យ ធម៌ទាំងនេះមានអត្ថផ្សេង ៗ គ្នា មានព្យញ្ជនៈផ្សេង ៗ គ្នា ឬក៏មានអត្ថជាមួយគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះទេ ។ សម្មុខាវិន័យនឹងអមូឡ្ហវិន័យ ។ បេ ។ សម្មុខាវិន័យនឹងបដិញ្ញាតករណៈ សម្មុខាវិន័យនឹងយេភុយ្យសិកា សម្មុខាវិន័យនឹងតស្សបាបិយសិកា សម្មុខាវិន័យនឹងតិណវត្ថារកៈ ធម៌ទាំងនេះមានអត្ថផ្សេង ៗ គ្នា មានព្យញ្ជនៈផ្សេង ៗ គ្នា ឬក៏មានអត្ថជាមួយគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះទេ ។ សម្មុខាវិន័យ នឹងសតិវិន័យ ធម៌ទាំងនេះមានអត្ថក៏ផ្សេងគ្នា មានព្យញ្ជនៈក៏ផ្សេងគ្នាដែរ ។ សម្មុខាវិន័យនឹងអមូឡ្ហវិន័យ ។ បេ ។ សម្មុខាវិន័យនឹងបដិញ្ញាតករណៈ សម្មុខាវិន័យនឹងយេភុយ្យសិកា សម្មុខាវិន័យ

យេន ច តស្សបាបិយសិកាយ ច សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ។

(១៤៧) វិវាទោ វិវាទាធិករណំ វិវាទោ នោ អធិករណំ អធិករណំ នោ វិវាទោ អធិករណញ្ចេវ វិវាទោ ច សិយា វិវាទោ វិវាទាធិករណំ សិយា វិវាទោ នោ អធិករណំ សិយា អធិករណំ នោ វិវាទោ សិយា អធិករណញ្ចេវ វិវាទោ ច ។ តត្ថ កតមោ វិវាទោ វិវាទាធិករណំ ។ ឥធ ភិក្ខូ វិវទន្តិ ធម្មោតិ វា អធម្មោតិ វា ។ បេ ។ ទុដ្ឋុល្លា អាបត្តីតិ វា អទុដ្ឋុល្លា អាបត្តីតិ វា យំ តត្ថ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ នានាវាទោ អញ្ញថាវាទោ វិបច្ចតាយ (១) វោហារោ មេធគំ (២) អយំ វិវាទោ វិវាទាធិករណំ ។ តត្ថ កតមោ វិវាទោ នោ អធិករណំ ។ មាតាបិ បុត្តេន វិវទតិ បុត្តោបិ មាតរា វិវទតិ បិតាបិ បុត្តេន វិវទតិ បុត្តោបិ បិតរា វិវទតិ ភាតាបិ ភាតរា វិវទតិ ភាតាបិ ភគិនិយា វិវទតិ ភគិនីបិ ភាតរា វិវទតិ សហាយោបិ សហាយេន វិវទតិ អយំ

១ ម. វិបច្ចយតាយ ។ ២ ម. មេធគំ ។

ទិន្នតស្សបាបិយសិកា សម្មុខាវិនយ ទិន្នតិណវត្ថារកៈ ធម៌ទាំងនេះមានអត្ថផ្សេង ៗ គ្នា មានព្យញ្ជនៈក៏ផ្សេង ៗ គ្នាដែរ ។

(១៨៧) វិវាទ ចាត់ជាវិវាទាធិករណ៍ វិវាទ មិនចាត់ជាអធិករណ៍ អធិករណ៍មិនចាត់ជាវិវាទ ចាត់ជាអធិករណ៍ផង ជាវិវាទផង វិវាទ ចាត់ជាវិវាទាធិករណ៍ក៏មាន វិវាទ មិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍មិនចាត់ជាវិវាទក៏មាន ចាត់ជាអធិករណ៍ផង វិវាទផងក៏មាន ។ បណ្ដាធម៌ទាំងនោះ វិវាទដូចម្ដេច ដែលចាត់ជាវិវាទាធិករណ៍ ។ ភិក្ខុទាំងឡាយក្នុងសាសនានេះ ជជែកគ្នា ថាសភាវៈនេះជាធម៌ក្ដី មិនមែនជាធម៌ក្ដី ។បេ។ ជាទុដ្ឋុល្លាបត្តិក្ដី ជាអទុដ្ឋុល្លាបត្តិក្ដី សេចក្ដីប្រកួតប្រកាន់ ជម្លោះ សេចក្ដីប្រកាន់ខុស សេចក្ដីជជែក ការនិយាយបែកផ្សេងពីគ្នា ការនិយាយផ្ដេសផ្ដាស ការនិយាយដើម្បីឲ្យគេព្រួយចិត្ត សេចក្ដីប្រកែកប្រណាំងណា ក្នុងសភាវៈទាំងនោះ វិវាទនេះចាត់ជាវិវាទាធិករណ៍ ។ បណ្ដាធម៌ទាំងនោះ វិវាទដូចម្ដេច ដែលមិនចាត់ជាអធិករណ៍ ។ មាតាទាស់ទែងនឹងបុត្តក្ដី បុត្តទាស់ទែងនឹងមាតាក្ដី បិតាទាស់ទែងនឹងបុត្តក្ដី បុត្តទាស់ទែងនឹងបិតាក្ដី បងប្អូនប្រុសទាស់ទែងនឹងបងប្អូនប្រុសក្ដី បងប្អូនប្រុសទាស់ទែងនឹងបងប្អូនស្រីក្ដី បងប្អូនស្រីទាស់ទែងនឹងបងប្អូនប្រុសក្ដី សំឡាញ់ទាស់ទែងនឹងសំឡាញ់ផងគ្នាក្ដី

អធិករណភេទំ អនុវាទាធិករណំ

វិវាទោ នោ អធិករណំ ។ តត្ថ កតមំ អធិករណំ នោ វិវាទោ ។ អនុវាទាធិករណំ អាបត្តាធិករណំ កិច្ចាធិករណំ ឥទំ អធិករណំ នោ វិវាទោ ។ តត្ថ កតមំ អធិករណញ្ចេវ វិវាទោ ច ។ វិវាទាធិករណំ អធិករណញ្ចេវ វិវាទោ ច ។

(១៦៨) អនុវាទោ អនុវាទាធិករណំ អនុវាទោ នោ អធិករណំ អធិករណំ នោ អនុវាទោ អធិករណញ្ចេវ អនុវាទោ ច សិយា អនុវាទោ អនុវាទាធិករណំ សិយា អនុវាទោ នោ អធិករណំ សិយា អធិករណំ នោ អនុវាទោ សិយា អធិករណញ្ចេវ អនុវាទោ ច ។ តត្ថ កតមោ អនុវាទោ អនុវាទាធិករណំ ។ ឥធ ភិក្ខូ ភិក្ខុំ អនុវទន្តិ សីលវិបត្តិយា វា អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អាជីវវិបត្តិយា វា យោ តត្ថ អនុវាទោ អនុវទនា អនុល្លបនា អនុភណនា អនុសម្បវង្កតា អព្ភុស្សហនតា អនុពលប្បទានំ អយំ អនុវាទោ អនុវាទាធិករណំ ។ តត្ថ កតមោ អនុវាទោ នោ អធិករណំ ។ មាតាបិ បុត្តំ អនុវទតិ បុត្តោបិ មាតរំ

វិវាទនេះ មិនចាត់ជាអធិករណ៍ទេ ។ បណ្ដាធម៌ទាំងនោះ អធិករណ៍ដូចម្ដេច ដែលមិនចាត់ជាវិវាទ ។ អនុវាទាធិករណ៍ អាបត្តាធិករណ៍ កិច្ចាធិករណ៍ អធិករណ៍នេះ មិនចាត់ជាវិវាទទេ ។ បណ្ដាធម៌ទាំងនោះ អធិករណ៍ដូចម្ដេច ដែលចាត់ជាអធិករណ៍ផង ជាវិវាទផង ។ វិវាទាធិករណ៍ ចាត់ជាអធិករណ៍ផង ជាវិវាទផង ។

(១៨៨) ការចោទ ចាត់ជាអនុវាទាធិករណ៍ ការចោទ មិនចាត់ជាអធិករណ៍ អធិករណ៍មិនចាត់ជាការចោទ ចាត់ជាអធិករណ៍ផង ជាការចោទផង ការចោទចាត់ជាអនុវាទាធិករណ៍ក៏មាន ការចោទមិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍មិនចាត់ជាការចោទក៏មាន ចាត់ជាអធិករណ៍ផង ជាការចោទផងក៏មាន ។ បណ្ដាធម៌ទាំងនោះ ការចោទដូចម្ដេច ដែលចាត់ជាអនុវាទាធិករណ៍ ។ ភិក្ខុទាំងឡាយក្នុងសាសនានេះ ចោទភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី ការចោទ សេចក្ដីប្រកាន់ ការពោលដដែល ការពោលតព៉ ការពោលបន្ទាប់ ការទំពោលបង្ខូច ការបន្ថែមកម្លាំងណា ក្នុងវិបត្តិទាំងនោះ ការចោទនេះ ចាត់ជាអនុវាទាធិករណ៍ ។ បណ្ដាធម៌ទាំងនោះ ការចោទដូចម្ដេច ដែលមិនចាត់ជាអធិករណ៍ ។ មាតាចោទបុត្តក្តី បុត្តចោទ

អនុវទតិ បិតាបិ បុត្តំ អនុវទតិ បុត្តោបិ បិតរំ អនុវទតិ ភាតាបិ ភាតរំ អនុវទតិ ភាតាបិ ភគិនិំ អនុវទតិ ភគិនីបិ ភាតរំ អនុវទតិ សហាយោបិ សហាយំ អនុវទតិ អយំ អនុវាទោ នោ អធិករណំ ។ តត្ថ កតមំ អធិករណំ នោ អនុវាទោ ។ អាបត្តាធិករណំ កិច្ចាធិករណំ វិវាទាធិករណំ ឥទំ អធិករណំ នោ អនុវាទោ ។ តត្ថ កតមំ អធិករណញ្ចេវ អនុវាទោ ច ។ អនុវាទាធិករណំ អធិករណញ្ចេវ អនុវាទោ ច ។

(១៤៩) អាបត្តិ អាបត្តាធិករណំ អាបត្តិ នោ អធិករណំ អធិករណំ នោ អាបត្តិ អធិករណញ្ចេវ អាបត្តិ ច សិយា អាបត្តិ អាបត្តាធិករណំ សិយា អាបត្តិ នោ អធិករណំ សិយា អធិករណំ នោ អាបត្តិ សិយា អធិករណញ្ចេវ អាបត្តិ ច ។ តត្ថ កតមា អាបត្តិ អាបត្តាធិករណំ ។ បញ្ចបិ អាបត្តិក្ខន្ធា អាបត្តាធិករណំ សត្តបិ អាបត្តិក្ខន្ធា អាបត្តាធិករណំ អយំ អាបត្តិ អាបត្តាធិករណំ ។ តត្ថ កតមា អាបត្តិ នោ អធិករណំ ។ សោតាបត្តិ សមាបត្តិ

មាតាក្តី បិតាចោទបុត្តក្តី បុត្តចោទបិតាក្តី បងប្អូនប្រុសចោទបងប្អូនប្រុសផងគ្នាក្តី បងប្អូនប្រុសចោទបងប្អូនស្រីក្តី បងប្អូនស្រីចោទបងប្អូនប្រុសក្តី សំឡាញ់ចោទសំឡាញ់ផងគ្នាក្តី ការចោទនេះ មិនចាត់ជាអធិករណ៍ ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលមិនចាត់ជាការចោទ ។ អាបត្តាធិករណ៍ កិច្ចាធិករណ៍ និងវិវាទាធិករណ៍ អធិករណ៍នេះ មិនចាត់ជាការចោទទេ ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលចាត់ជាអធិករណ៍ផង ជាការចោទផង ។ អនុវាទាធិករណ៍ ចាត់ជាអធិករណ៍ផង ជាការចោទផង ។

[១៨៩] អាបត្តិ ចាត់ជាអាបត្តាធិករណ៍ អាបត្តិ មិនចាត់ជាអធិករណ៍ អធិករណ៍មិនចាត់ជាអាបត្តិ ចាត់ជាអធិករណ៍ផង ជាអាបត្តិផង អាបត្តិ ចាត់ជាអាបត្តាធិករណ៍ក៏មាន អាបត្តិមិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍មិនចាត់ជាអាបត្តិក៏មាន ចាត់ជាអធិករណ៍ផង ជាអាបត្តិផងក៏មាន ។ បណ្តាធម៌ទាំងនោះ អាបត្តិដូចម្តេច ដែលចាត់ជាអាបត្តាធិករណ៍ ។ កងនៃអាបត្តិទាំង ៥ ក៏ចាត់ជាអាបត្តាធិករណ៍ កងនៃអាបត្តិទាំង ៧ ក៏ចាត់ជាអាបត្តាធិករណ៍ អាបត្តិទាំងនេះ ទើបចាត់ជាអាបត្តាធិករណ៍ ។ បណ្តាធម៌ទាំងនោះ អាបត្តិដូចម្តេច ដែលមិនចាត់ជាអធិករណ៍ ។ សោតាបត្តិនិងសមាបត្តិ

អយំ អាបត្តិ នោ អធិករណំ ។ តត្ថ កតមំ អធិករណំ នោ អាបត្តិ ។ កិច្ចាធិករណំ វិវាទាធិករណំ អនុវាទាធិករណំ ឥទំ អធិករណំ នោ អាបត្តិ ។ តត្ថ កតមំ អធិករណញ្ចេវ អាបត្តិ ច ។ អាបត្តាធិករណំ អធិករណញ្ចេវ អាបត្តិ ច ។

(១៥០) កិច្ចំ កិច្ចាធិករណំ កិច្ចំ នោ អធិករណំ អធិករណំ នោ កិច្ចំ កិច្ចញ្ចេវ អធិករណញ្ច[(១)] សិយា កិច្ចំ កិច្ចាធិករណំ សិយា កិច្ចំ នោ អធិករណំ សិយា អធិករណំ នោ កិច្ចំ សិយា អធិករណញ្ចេវ កិច្ចញ្ច ។ តត្ថ កតមំ កិច្ចំ កិច្ចាធិករណំ ។ យា សង្ឃស្ស កិច្ចយតា ករណីយតា អបលោកនកម្មំ ញត្តិកម្មំ ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ឥទំ កិច្ចំ កិច្ចាធិករណំ ។ តត្ថ កតមំ កិច្ចំ នោ អធិករណំ អាចរិយកិច្ចំ ឧបជ្ឈាយកិច្ចំ សមានុបជ្ឈាយកិច្ចំ សមានាចរិយកិច្ចំ ឥទំ កិច្ចំ នោ អធិករណំ ។ តត្ថ កតមំ អធិករណំ នោ កិច្ចំ ។ វិវាទាធិករណំ

---

១ ម· អធិករណញ្ចេវ កិច្ចញ្ច ។

អាបត្តិ(១) នេះ មិនចាត់ជាអធិករណ៍ទេ ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលមិនចាត់ជាអាបត្តិ ។ កិច្ចាធិករណ៍ វិវាទាធិករណ៍ និងអនុវាទាធិករណ៍ អធិករណ៍នេះ មិនចាត់ជាអាបត្តិទេ ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលចាត់ជាអធិករណ៍ផង ជាអាបត្តិផង ។ អាបត្តាធិករណ៍ ចាត់ជាអធិករណ៍ផង ជាអាបត្តិផង ។

(១៩០) កិច្ច ចាត់ជាកិច្ចាធិករណ៍ កិច្ច មិនចាត់ជាអធិករណ៍ អធិករណ៍មិនចាត់ជាកិច្ច ចាត់ជាកិច្ចផង ជាអធិករណ៍ផង កិច្ចចាត់ជាកិច្ចាធិករណ៍ក៏មាន កិច្ចមិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍មិនចាត់ជាកិច្ចក៏មាន ចាត់ជាអធិករណ៍ផង ជាកិច្ចផងក៏មាន ។ បណ្តាធម៌ទាំងនោះ កិច្ចដូចម្តេច ដែលចាត់ជាកិច្ចាធិករណ៍ ។ កិច្ចរបស់សង្ឃ ឬកម្មដែលសង្ឃត្រូវធ្វើណា គឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ ញត្តិចតុត្ថកម្ម ១ កិច្ចនេះ ទើបចាត់ជាកិច្ចាធិករណ៍បាន ។ បណ្តាធម៌ទាំងនោះ កិច្ចដូចម្តេច ដែលមិនចាត់ជាអធិករណ៍ ។ កិច្ចដែលអន្តេវាសិកត្រូវធ្វើដល់អាចារ្យ កិច្ចដែលសទ្ធិវិហារិកត្រូវធ្វើដល់ឧបជ្ឈាយ៍ កិច្ចដែលភិក្ខុត្រូវធ្វើដល់ភិក្ខុដែលមានឧបជ្ឈាយ៍ស្មើគ្នា កិច្ចដែលភិក្ខុត្រូវធ្វើដល់ភិក្ខុដែលមានអាចារ្យស្មើគ្នា កិច្ចនេះ មិនចាត់ជាអធិករណ៍ទេ ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលមិនចាត់ជាកិច្ច ។ វិវាទាធិករណ៍

---

១ ប្រែថា កិរិយាដល់ មិនប្រែថា កិរិយាត្រូវនូវអាបត្តិ ដូចក្នុងសិក្ខាបទនោះទេ ។

អនុវាទាធិករណំ អាបត្តាធិករណំ ឥទំ អធិករណំ នោ កិច្ចំ ។ តត្ថ កតមំ អធិករណញ្ច កិច្ចញ្ច ។ កិច្ចាធិករណំ អធិករណញ្ចេវ កិច្ចញ្ចាតិ ។

អធិករណភេទំ និដ្ឋិតំ ។

តស្សុទ្ទានំ

(១៨១) អធិករណំ ឧក្កោដា
អាការា បុគ្គលេន ច
និទានហេតុបច្ចយា
មូលំ សមុដ្ឋានេន ច
អាបត្តិ ហោតិ យត្ថ ច
សំសដ្ឋា និទានេន ច[1]
ហេតុបច្ចយមូលានិ
សមុដ្ឋានេន ព្យញ្ជនា
វិភាគោ អធិករណម្ហិ
ភេទាធិករណេ ឥមម្ហិ ។

---

១ បកភិតិ កត្ថចិ ឃោត្តកេ ទិស្សតិ ។

អនុវាទាធិករណ៍ នឹងអាបត្តាធិករណ៍ អធិករណ៍នេះ មិនចាត់ជាកិច្ចទេ ។ បណ្ដាធម៌ទាំងនោះ កិច្ចដូចម្ដេច ដែលចាត់ជាអធិករណ៍ផង ជាកិច្ចផង ។ កិច្ចាធិករណ៍ ចាត់ជាអធិករណ៍ផង ជាកិច្ចផង ។

ចប់ អធិករណភេទ ។

ខ្ទានគឺបញ្ហាស្រៀវនៃអធិករណ៍ភេទនោះដូច្នេះ

(១៩១) និយាយអំពីការសើរើអធិករណ៍ ១ ភិក្ខុបាននូវការសើរើដោយអាការ ១០ យ៉ាង ១ បុគ្គលគឺ ភិក្ខុដែលប្រកបដោយអង្គ ៤ ទើបសើរើអធិករណ៍បាន ១ និទាន ហេតុ បច្ច័យ មូល នឹងសមុដ្ឋាន (នៃអធិករណ៍) ១ អធិករណ៍ដែលចាត់ជាអាបត្តិ នឹងអនាបត្តិ ១ សមថៈទាំង ៧ មានសតិ-វិន័យជាដើម កើតក្នុងទីណា ១ សមថៈទាំង ៧ មានសម្មុខា-វិន័យជាដើម លាយប្រឡូកគ្នាឬមិនប្រឡូកគ្នា ១ និទាន ហេតុ បច្ច័យ មូល នឹងសមុដ្ឋាន (នៃសមថៈទាំង ៧ ប្រការ) ១ សមថៈទាំង ៧ ប្រការ មានអត្ថនឹងព្យញ្ជនៈ (ផ្សេង ៗ គ្នា) ១ ធម៌ទាំងឡាយមានវិវាទជាដើម ដែលចាត់ជាអធិករណ៍ នឹងមិនចាត់ជាអធិករណ៍ ១ នេះជាខ្ទានក្នុងអធិករណភេទ ។

អបរំ គាថាសង្គណិកំ

(១៩២) ចោទនា កិមត្ថាយ
សារណា កិស្ស ការណា
សង្ឃោ កិមត្ថាយ
មតិកម្មំ បន កិស្ស ការណា ។
ចោទនា សារណត្ថាយ
និគ្គហត្ថាយ សារណា
សង្ឃោ បរិគ្គហត្ថាយ(១)
មតិកម្មំ បន បាដិយេក្កំ ។
មា ខោ តុរិតោ អភណិ
មា ខោ ចណ្ឌិកតោ ភណិ(២)
មា ខោ បដិឃំ ជនយិ
សចេ អនុវិជ្ជកោ តុវំ
មា ខោ សហសា អភណិ
កថំ វិគ្គាហិកំ អនត្ថសញ្ហិតំ

---

១ ម. បរិគ្គហត្ថាយ ។ ២ ម. អភណិ ។

គាថាសង្គណិកៈ ជាតំណាមក[១]

(១៥២) សួរថា ការចោទដើម្បីប្រយោជន៍អ្វី ការរំលឹកទោសដើម្បីហេតុអ្វី ប្រជុំសង្ឃដើម្បីប្រយោជន៍អ្វី ម្យ៉ាងទៀត មតិកម្ម គឺការរៀនមន្តដើម្បីហេតុអ្វី ។ ឆ្លើយថា ការចោទ ដើម្បីរំលឹកទោស ការរំលឹកទោស ដើម្បីទឹងសង្កត់សង្កិន (បុគ្គលនោះឲ្យរាងចាល) ប្រជុំសង្ឃដើម្បីពិនិត្យរកនូវការវិនិច្ឆ័យ ឯមតិកម្ម គឺការរៀនមន្តផ្សេងៗគ្នា (ដើម្បីឲ្យចូលចិត្តនូវការកាត់សេចក្ដី) ។ បើលោកធ្វើជាវិន័យធរត្រូវកុំនិយាយរួសរាន់ពេក កុំនិយាយទាំងកំណាច កុំធ្វើសេចក្ដីថ្នាំងថ្នាក់ចិត្តឲ្យកើតឡើង (ចំពោះអ្នកដែលត្រូវចោទ ឬអ្នកដែលចោទ) កុំនិយាយពាក្យសង្កត់សង្កិនឥតប្រយោជន៍ ដោយ

១ អដ្ឋកថា ហៅថា ទុតិយគាថាសង្គណិកៈ គាថាផ្ទួកផ្ទាល់ទី ២ ។

សុត្តេ វិនយេ អនុលោមេ
បញ្ញត្តេ អនុលោមិកេ
អនុយោគវត្តំ និសាមយ (១)
កុសលេន ពុទ្ធិមតា កតំ
សុវុត្តំ សិក្ខាបទានុលោមិកំ
គតឹ ន នាសេន្តោ សម្បរាយិកំ ។
ហិតេសី អនុយុញ្ជស្សុ
កាលេនត្ថុបសញ្ហិតំ
ចុទិតស្ស ច ចោទកស្ស ច
សហសា វោហារំ មា បណេសិ ។
ចោទកោ អាហ អាបន្នោតិ
ចុទិតកោ អាហ អនាបន្នោតិ
ឧភោ អនុក្ខិបន្តោ
បដិញ្ញានុសន្ធិតេន ការយេ ។
បដិញ្ញា លជ្ជីសុ វុត្តា (២)
អលជ្ជីសុ ឃតំ (៣) ន វិជ្ជតិ

---

១ និសាមេថាតិ កត្ថចិ ពោត្ថកេ ទិស្សតិ ។ និសាមេថាតិយេវ អដ្ឋកថាយំ ។
២ ឱ. ម. កតា ។ ៣ ឱ. ម. ឯវំ ។

ួសកាន់ត្រូវ លោកពិចារណានូវវត្ថុដែលគួរប្រព្រឹត្តតាមដោយអនុ-លោមរបស់សិក្ខាបទដែលព្រះសម្ពុទ្ធ ជាអ្នកប្រាជ្ញឆ្លៀវឆ្លាស ទ្រង់ធ្វើ គឺបាននាំមកតាក់តែងទុក ទ្រង់ពោលទុកមកដោយល្អ ក្នុងសុត្តៈ គឺឧភតោវិភង្គ ក្នុងវិន័យ គឺខន្ធកៈ ក្នុងអនុលោម គឺបរិវារៈ ក្នុងបញ្ញត្តិ គឺវិនយបិដកទាំងអស់ ក្នុងអនុលោមិកៈ គឺមហាបទេស ៤ ហើយមិនបានញ៉ាំងគតិរបស់ខ្លួន ដែលប្រព្រឹត្តទៅក្នុងបរលោក មិនឲ្យវិនាសបាន ។ លោកកាលស្វែងរកនូវប្រយោជន៍ គប្បីប្រកបតាមធម្មជាត ដែលប្រកបដោយប្រយោជន៍តាមកាលដ៏គួរ លោកកុំអាលជឿសំដី របស់អ្នកជាប់ចោទនឹងអ្នកចោទ ដោយរហ័សឡើយ ។ (បើ) អ្នកចោទនិយាយថា លោកត្រូវអាបត្តិហើយ លោកអ្នកជាប់ចោទប្រកែកថា ខ្ញុំមិនត្រូវអាបត្តិទេ (វិន័យធរ) កុំអាលលើកលែងបុគ្គលទាំង ២ (នោះ) គប្បីវិនិច្ឆ័យតាមដំ-ណាពាក្យដែលប្តេជ្ញា ។ ពាក្យប្តេជ្ញា (ណា) ដែលវិន័យធរពោលចំពោះពួកបុគ្គលដែលមានសេចក្តីខ្មាស ពាក្យប្តេជ្ញានុ៎ះមិនមានក្នុងពួកបុគ្គល ដែលឥតសេចក្តីខ្មាសទេ (ព្រោះថា)

អបរំ គាថាសង្គណិកំ អលជ្ជិអាទិបុច្ឆាវិសជ្ជនា

ពហុម្បិ អលជ្ជី កាលេសយ្យ
វត្តានុសន្ធិតេន ការយេ ។

(១៩៣) អលជ្ជី កីទិសោ ហោតិ
បដិញ្ញា យស្ស ន រូហតិ
ឯតញ្ច(១) តាហំ បុច្ឆាមិ
កីទិសោ វុច្ចតិ អលជ្ជិបុគ្គលោ ។
សញ្ចិច្ច អាបត្តឹ អាបជ្ជតិ
អាបត្តឹ បរិគូហតិ
អគតិគមនញ្ច គច្ឆតិ
ឯទិសោ វុច្ចតិ អលជ្ជិបុគ្គលោ ។

(១៩៤) សច្ចំ អហម្បិ ជានាមិ
ឯទិសោ អលជ្ជិបុគ្គលោ
អញ្ញញ្ច តាហំ បុច្ឆាមិ
កីទិសោ វុច្ចតិ លជ្ជិបុគ្គលោ ។
សញ្ចិច្ច អាបត្តឹ នាបជ្ជតិ
អាបត្តឹ ន បរិគូហតិ

---

១. ម. ឯវញ្ច ។

គាថាសង្គណិកៈជាគំណមក បញ្ហាវិសជ្ជនាអំពីអលជ្ជីបុគ្គលជាដើម

បុគ្គលដែលឥតសេចក្ដីខ្មាស សូម្បីពោលពាក្យច្រើនក្ដី (វិន័យធរ) គប្បីវិនិច្ឆ័យតាមពាក្យប្ដេជ្ញាដែលជាប់មកជាមួយនឹងវត្ថុប្រតិបត្តិរបស់បុគ្គលនោះ ។

(១៨៣) សួរថា អលជ្ជីបុគ្គលតើដូចម្ដេច សេចក្ដីប្ដេជ្ញាមិនលូតលាស់ដល់បុគ្គលណា ខ្ញុំសួរចំពោះបុគ្គលនុ៎ះ ដូច្នេះថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគត្រាស់ហៅថា អលជ្ជីបុគ្គល ។ ឆ្លើយថា បុគ្គលមានចិត្តក្លែងត្រូវអាបត្តិ រួចបិទបាំងអាបត្តិទុកក្ដី លុះតាមអំណាចអគតិក្ដី បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហៅថា អលជ្ជីបុគ្គល ។

(១៨៤) ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះហៅថា អលជ្ជីបុគ្គល ប៉ុន្តែខ្ញុំសូមសួរតបុគ្គលដទៃទៀតនឹងអ្នកថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគត្រាស់ហៅថា លជ្ជីបុគ្គល ។ ឆ្លើយថា បុគ្គលមិនក្លែងឲ្យត្រូវអាបត្តិ មិនបានបិទបាំងអាបត្តិ

អគតិគមនំ ន គច្ឆតិ
ឯទិសោ វុច្ចតិ លជ្ជីបុគ្គលោ ។

(១៥៥) សច្ចំ អហម្បិ ជានាមិ
ឯទិសោ វុច្ចតិ លជ្ជីបុគ្គលោ
អញ្ញញ្ច តាហំ បុច្ឆាមិ
កីទិសោ វុច្ចតិ អធម្មចោទកោ ។
អកាលេន ចោទេតិ អភូតេន
ផរុសេន អនត្ថសញ្ហិតេន
ទោសន្តរោ ចោទេតិ នោ មេត្តចិត្តោ
ឯទិសោ វុច្ចតិ អធម្មចោទកោ ។

(១៥៦) សច្ចំ អហម្បិ ជានាមិ
ឯទិសោ វុច្ចតិ អធម្មចោទកោ
អញ្ញញ្ច តាហំ បុច្ឆាមិ
កីទិសោ វុច្ចតិ ធម្មចោទកោ ។
កាលេន ចោទេតិ ភូតេន
សណ្ហេន អត្ថសញ្ហិតេន

មិនលុះអំណាចអគតិ បុគ្គលយ៉ាងនេះ ដែលព្រះមានព្រះភាគត្រាស់ហៅថា លជ្ជីបុគ្គល ។

(១៩៥) ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះហៅថា លជ្ជីបុគ្គល ប៉ុន្តែខ្ញុំសូមសួររកបុគ្គលដទៃទៀតនឹងអ្នកថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទមិនត្រូវតាមធម៌ ។ ឆ្លើយថា បុគ្គលដែលចោទដោយមិនត្រូវតាមកាល ១ ដោយពាក្យមិនពិត ១ ដោយពាក្យគ្រោះ ១ ដោយពាក្យមិនប្រកបដោយប្រយោជន៍ ១ ចោទដោយសេចក្ដីស្អប់ មិនចោទដោយមេត្តាចិត្ត ១ បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទមិនប្រកបដោយធម៌ ។

(១៩៦) ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទមិនប្រកបដោយធម៌ ប៉ុន្តែខ្ញុំសូមសួររកបុគ្គលដទៃទៀតនឹងអ្នកថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទត្រូវតាមធម៌ ។ ឆ្លើយថា បុគ្គលដែលចោទត្រូវតាមកាល ១ ដោយពាក្យពិត ១ ដោយពាក្យផ្អែមល្ហែម ១ ដោយពាក្យប្រកបដោយប្រយោជន៍ ១

អបរំ គាថាសង្គណិកំ ធម្មចោទកាទិបញ្ហាវិសជ្ជនា

មេត្តចិត្តោ ចោទេតិ នោ ទោសន្តរោ
ឯទិសោ វុច្ចតិ ធម្មចោទកោ ។

(១៤៧) សច្ចំ អហម្បិ ជានាមិ
ឯទិសោ វុច្ចតិ ធម្មចោទកោ
អញ្ញញ្ច តាហំ បុច្ឆាមិ
កីទិសោ វុច្ចតិ ពាលចោទកោ ។
បុព្វាបរំ ន ជានាតិ បុព្វាបរស្ស អកោវិទោ
អនុសន្ធិវចនបថំ ន ជានាតិ
អនុសន្ធិវចនបថស្ស អកោវិទោ
ឯទិសោ វុច្ចតិ ពាលចោទកោ ។

(១៤៨) សច្ចំ អហម្បិ ជានាមិ
ឯទិសោ វុច្ចតិ ពាលចោទកោ
អញ្ញញ្ច តាហំ បុច្ឆាមិ
កីទិសោ វុច្ចតិ បណ្ឌិតចោទកោ ។
បុព្វាបរំបិ ជានាតិ បុព្វាបរស្ស កោវិទោ
អនុសន្ធិវចនបថំ ជានាតិ

គាថាសង្គណិកៈជាតំណមក បុច្ឆាវិសជ្ជនាអំពីបុគ្គលអ្នកចោទត្រូវតាមធម៌ជាដើម

ចោទដោយមេត្តាចិត្ត មិនចោទដោយស្អប់ ១ បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទត្រូវតាមធម៌ ។

(១៩៧) ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទត្រូវតាមធម៌ ប៉ុន្តែខ្ញុំសូមសួរកបុគ្គលដទៃទៀតនឹងអ្នកថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទជាបុគ្គលពាល ។ ឆ្លើយថា បុគ្គលមិនដឹងពាក្យខាងដើមនឹងពាក្យខាងចុង មិនយល់ដល់ពាក្យខាងដើមនឹងពាក្យខាងចុង មិនដឹងគន្លងពាក្យតគ្នា មិនយល់ដល់គន្លងពាក្យតគ្នា បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទជាបុគ្គលពាល ។

(១៩៨) ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះ ដែលព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទជាបុគ្គលពាល ប៉ុន្តែខ្ញុំសូមសួរកបុគ្គលដទៃទៀតនឹងអ្នកថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទជាបណ្ឌិត ។ ឆ្លើយថា បុគ្គលដែលដឹងពាក្យខាងដើម នឹងពាក្យខាងចុង យល់ដល់ពាក្យខាងដើមនឹងពាក្យខាងចុង ដឹងគន្លងពាក្យតគ្នា

អនុសន្ធិវចនបថស្ស កោវិទោ
ឃដិសោ វុច្ចតិ បណ្ឌិតេហេវ កោ ៗ

(១៥៩) សច្ចំ អហម្បិ ជានាមិ
ឃដិសោ វុច្ចតិ បណ្ឌិតេហេវ កោ
អញ្ញញ្ច តាហំ បុច្ឆាមិ
ចោទនា កិន្តិ វុច្ចតិ ៗ
សីលវិបត្តិយា ចោទេតិ
អថោ អាចារទិដ្ឋិយា
អាជីវេនបិ ចោទេតិ
ចោទនា កេន វុច្ចតិ ៗ

អបរំ គាថាសង្គណិកំ និដ្ឋិតំ ៗ

យល់ផល់តទួនពាក្យតគ្នា បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទជាបណ្ឌិត ។

(១៤៩) ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះ ដែលព្រះមានព្រះភាគត្រាស់ហៅថា អ្នកចោទជាបណ្ឌិត ប៉ុន្តែខ្ញុំសូមសួររកហេតុដទៃទៀតនឹងអ្នកថា ដូចម្ដេចដែលព្រះមានព្រះភាគត្រាស់ហៅថា ការចោទ ។ ហើយថា បុគ្គលចោទដោយសីលវិបត្តិ ពុំនោះសោត ដោយអាចារវិបត្តិ ទិដ្ឋិវិបត្តិ ចោទដោយអាជីវិបត្តិ ការចោទដោយសីលវិបត្តិជាដើមនោះ ព្រះមានព្រះភាគត្រាស់ហៅថា ការចោទ ។

ចប់ គាថាសង្គណិកៈ (គាថាដូកឆ្លាស់គ្នា) ជាតំណមក ។

ចោទនាកណ្ឌំ

(១៦០) អនុវិជ្ជកេន ចោទកោ បុច្ឆិតព្វោ យំ ខោ ត្វំ អាវុសោ ឥមំ ភិក្ខុំ ចោទេសិ កិម្ហិ នំ ចោទេសិ សីលវិបត្តិយា ចោទេសិ អាចារវិបត្តិយា ចោទេសិ ទិដ្ឋិវិបត្តិយា ចោទេសីតិ ។ សោ ចេ ឯវំ វទេយ្យ សីលវិបត្តិយា វា ចោទេមិ អាចារវិបត្តិយា វា ចោទេមិ ទិដ្ឋិវិបត្តិយា វា ចោទេមីតិ ។ សោ ឯវមស្ស វចនីយោ ជានាតិ បនាយស្មា សីលវិបត្តឹ ជានាតិ អាចារវិបត្តឹ ជានាតិ ទិដ្ឋិវិបត្តិន្តិ ។ សោ ចេ ឯវំ វទេយ្យ ជានាមិ ខោ អហំ អាវុសោ សីលវិបត្តឹ ជានាមិ អាចារវិបត្តឹ ជានាមិ ទិដ្ឋិវិបត្តិន្តិ ។ សោ ឯវមស្ស វចនីយោ កតមា បនាវុសោ សីលវិបត្តិ កតមា អាចារវិបត្តិ កតមា ទិដ្ឋិវិបត្តីតិ ។ សោ ចេ ឯវំ វទេយ្យ ចត្តារិ បារាជិកានិ តេរសសង្ឃាទិសេសា អយំ សីលវិបត្តិ ថុល្លច្ចយំ បាចិត្តិយំ បាដិទេសនីយំ ទុក្កដំ ទុព្ភាសិតំ អយំ អាចារវិបត្តិ

ចោទនាកណ្ឌ

(១៦០) វិន័យធរត្រូវសួរភិក្ខុអ្នកចោទថា ម្នាលអាវុសោ លោកចោទភិក្ខុនេះដោយហេតុណា លោកចោទភិក្ខុនោះ ព្រោះទោសអ្វី លោកចោទដោយសីលវិបត្តិ ដោយអាចារវិបត្តិ ឬចោទដោយទិដ្ឋិវិបត្តិ ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ខ្ញុំចោទដោយសីលវិបត្តិក្តី ខ្ញុំចោទដោយអាចារវិបត្តិក្តី ខ្ញុំចោទដោយទិដ្ឋិវិបត្តិក្តី ។ ត្រូវវិន័យធរសួរភិក្ខុនោះយ៉ាងនេះថា លោកមានអាយុស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរឬទេ ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរ ។ ត្រូវវិន័យធរសួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ ចុះដូចម្តេចហៅថា សីលវិបត្តិ ដូចម្តេចហៅថា អាចារវិបត្តិ ដូចម្តេចហៅថា ទិដ្ឋិវិបត្តិ ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា បារាជិក ៤ និងសង្ឃាទិសេស ១៣ នេះហៅថា សីលវិបត្តិ ថុល្លច្ច័យ បាចិត្តិយៈ បាដិទេសនីយៈ ទុក្កដ និងទុព្ភាសិត នេះហៅថា អាចារវិបត្តិ

មិច្ឆាទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ អយំ ទិដ្ឋិវិបត្តិ ។ សោ ឯវមស្ស វចនីយោ យំ ខោ ត្វំ អាវុសោ ឥមំ ភិក្ខុំ ចោទេសិ ទិដ្ឋេន ចោទេសិ សុតេន ចោទេសិ បរិសង្កាយ ចោទេសីតិ ។ សោ ចេ ឯវំ វទេយ្យ ទិដ្ឋេន វា ចោទេមិ សុតេន វា ចោទេមិ បរិសង្កាយ វា ចោទេមីតិ ។ សោ ឯវមស្ស វចនីយោ យំ ខោ ត្វំ អាវុសោ ឥមំ ភិក្ខុំ ទិដ្ឋេន ចោទេសិ កិន្តេ ទិដ្ឋំ កិន្តិ តេ ទិដ្ឋំ កទា តេ ទិដ្ឋំ កត្ថ តេ ទិដ្ឋំ បារាជិកំ អជ្ឈាបន្នោ ទិដ្ឋោ សង្ឃាទិសេសំ អជ្ឈាបន្នោ ទិដ្ឋោ ថុល្លច្ចយំ អជ្ឈាបន្នោ ទិដ្ឋោ បាចិត្តិយំ អជ្ឈាបន្នោ ទិដ្ឋោ បាដិទេសនីយំ អជ្ឈាបន្នោ ទិដ្ឋោ ទុក្កដំ អជ្ឈាបន្នោ ទិដ្ឋោ កត្ថ ច ត្វំ អហោសិ កត្ថ ចាយំ ភិក្ខុ អហោសិ កិញ្ច ត្វំ ករោសិ កិញ្ចាយំ ភិក្ខុ ករោតីតិ ។ សោ ចេ ឯវំ វទេយ្យ ន ខោ អហំ អាវុសោ ឥមំ ភិក្ខុំ ទិដ្ឋេន ចោទេមិ អបិច សុតេន ចោទេមីតិ ។ សោ ឯវមស្ស វចនីយោ យំ ខោ ត្វំ អាវុសោ ឥមំ ភិក្ខុំ សុតេន ចោទេ-

មិច្ឆាទិដ្ឋិ នឹងអន្តគ្គាហិកាទិដ្ឋិ នេះហៅថា ទិដ្ឋិវិបត្តិ ។ ត្រូវវិន័យធរ សួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ លោកចោទភិក្ខុនេះ ដោយហេតុណា លោកចោទដោយឃើញ ដោយឮ ឬក៏ចោទដោយ រង្កៀសទេ ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ខ្ញុំចោទដោយ ឃើញក្តី ចោទដោយឮក្តី ចោទដោយរង្កៀសក្តី ។ ត្រូវវិន័យធរ សួរភិក្ខុ អ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ លោកចោទភិក្ខុនេះដោយឃើញ ហេតុណា លោកបានឃើញទោសដូចម្តេច លោកបានឃើញហេតុដូច ម្តេច លោកបានឃើញពីកាលណា លោកបានឃើញក្នុងទីណា កាល ភិក្ខុនោះត្រូវអាបត្តិបារាជិក លោកបានឃើញដែរឬ កាលត្រូវអាបត្តិសង្ឃា- ទិសេស លោកបានឃើញដែរឬ កាលត្រូវអាបត្តិថុល្លច្ច័យ លោកបាន ឃើញដែរឬ កាលត្រូវអាបត្តិបាចិត្តិយៈ លោកបានឃើញដែរឬ កាលត្រូវ អាបត្តិបាដិទេសនីយៈ លោកបានឃើញដែរឬ កាលត្រូវអាបត្តិទុក្កដ លោក បានឃើញដែរឬ មួយៈទៀត លោកនៅក្នុងទីណា ភិក្ខុនេះនៅក្នុងទីណា ចំណែកខាងលោកកំពុងធ្វើអ្វី ឯភិក្ខុនេះកំពុងធ្វើអ្វី ។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនបានចោទភិក្ខុនោះដោយការ ឃើញទេ ខ្ញុំចោទដោយគ្រាន់តែបានឮ ។ ត្រូវវិន័យធរសួរភិក្ខុអ្នក ចោទនោះយ៉ាងនេះថា ម្នាលអាវុសោ លោកចោទភិក្ខុនេះដោយបានឮ

សំ កិន្តេ សុតំ កិន្តិ តេ សុតំ កទា តេ សុតំ កត្ថ តេ សុតំ បារាជិកំ អជ្ឈាបន្នោតិ សុតំ សង្ឃាទិសេសំ អជ្ឈាបន្នោតិ សុតំ ថុល្លច្ចយំ អជ្ឈាបន្នោតិ សុតំ បាចិត្តិយំ អជ្ឈាបន្នោតិ សុតំ បាដិទេសនីយំ អជ្ឈាបន្នោតិ សុតំ ទុក្កដំ អជ្ឈាបន្នោតិ សុតំ ទុព្ភាសិតំ អជ្ឈាបន្នោតិ សុតំ ភិក្ខុស្ស សុតំ ភិក្ខុនិយា សុតំ សិក្ខមានាយ សុតំ សាមណេរស្ស សុតំ សាមណេរិយា សុតំ ឧបាសកស្ស សុតំ ឧបាសិកាយ សុតំ រាជូនំ សុតំ រាជមហាមត្តានំ សុតំ តិត្ថិយានំ សុតំ តិត្ថិយសាវកានំ សុតន្តិ ។ សោ ចេ ឯវំ វទេយ្យ ន ខោ អហំ អាវុសោ ឥមំ ភិក្ខុំ សុតេន ចោទេមិ អបិច បរិសង្កាយ ចោទេមីតិ ។ សោ ឯវមស្ស វចនីយោ យំ ខោ ត្វំ អាវុសោ ឥមំ ភិក្ខុំ បរិសង្កាយ ចោទេសិ កឹ បរិសង្កសិ កិន្តិ បរិសង្កសិ កទា បរិសង្កសិ កត្ថ បរិសង្កសិ បារាជិកំ អជ្ឈាបន្នោតិ បរិសង្កសិ សង្ឃាទិសេសំ អជ្ឈាបន្នោតិ

ចោទនាកណ្ឌ ការសាកសួររបស់ភិក្ខុជាវិន័យធរ

ដោយហេតុណា លោកបានឮដូចម្តេច លោកបានឮហេតុដូចម្តេច លោកបានឮក្នុងកាលណា លោកបានឮក្នុងទីណា លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិបារាជិក លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេស លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិថុល្លច្ច័យ លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិបាចិត្តិយៈ លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិបាដិទេសនីយៈ លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិទុក្កដ លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិទុព្ភាសិត លោកបានឮពាក្យភិក្ខុ លោកបានឮពាក្យភិក្ខុនី លោកបានឮពាក្យសិក្ខមានា លោកបានឮពាក្យសាមណេរ លោកបានឮពាក្យសាមណេរី លោកបានឮពាក្យឧបាសក លោកបានឮពាក្យឧបាសិកា លោកបានឮពាក្យពួកស្តេច លោកបានឮពាក្យពួករាជមហាមាត្រ លោកបានឮពាក្យពួកតិត្ថិយ លោកបានឮពាក្យពួកសាវ័កតិត្ថិយឬ ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនបានចោទភិក្ខុនេះដោយបានឮទេ ខ្ញុំចោទដោយត្រឹមតែសេចក្តីរង្កៀស ។ ត្រូវវិន័យធរសួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ លោកចោទភិក្ខុនេះដោយសេចក្តីរង្កៀសដោយហេតុណា លោករង្កៀសដូចម្តេច លោករង្កៀសអំពីហេតុអ្វី លោករង្កៀសក្នុងកាលណា លោករង្កៀសក្នុងទីណា លោករង្កៀសថា ភិក្ខុនេះត្រូវអាបត្តិបារាជិក លោករង្កៀសថា ភិក្ខុនេះត្រូវអាបត្តិសង្ឃា-

បរិសុទ្ធសិ ថុល្លច្ចយំ អជ្ឈាបន្នោតិ បរិសុទ្ធសិ បាចិត្តិយំ អជ្ឈាបន្នោតិ បរិសុទ្ធសិ បាដិទេសនីយំ អជ្ឈាបន្នោតិ បរិសុទ្ធសិ ទុក្កដំ អជ្ឈាបន្នោតិ បរិសុទ្ធសិ ទុព្ភាសិតំ អជ្ឈាបន្នោតិ បរិសុទ្ធសិ ភិក្ខុស្ស សុត្វា បរិសុទ្ធសិ ភិក្ខុនិយា សុត្វា បរិសុទ្ធសិ សិក្ខមានាយ សុត្វា បរិសុទ្ធសិ សាមណេរស្ស សុត្វា បរិសុទ្ធសិ សាមណេរិយា សុត្វា បរិសុទ្ធសិ ឧបាសកស្ស សុត្វា បរិសុទ្ធសិ ឧបាសិកាយ សុត្វា បរិសុទ្ធសិ រាជូនំ សុត្វា បរិសុទ្ធសិ រាជមហាមត្តានំ សុត្វា បរិសុទ្ធសិ តិត្ថិយានំ សុត្វា បរិសុទ្ធសិ តិត្ថិយសាវកានំ សុត្វា បរិសុទ្ធសីតិ ។

[៣៦៣] ឆិទ្ទំ ឆិទ្ទេន សមេតិ

ឆិទ្ទេន សំសន្ទតេ ឆិទ្ទំ

ឆិទ្ទំ បដិច្ច ន ឧបេតិ

អសុទ្ធបរិសុទ្ធិតោ

វិសេស លោករន្ទៀសថា ភិក្ខុនេះត្រូវអាបត្តិថុល្លច្ច័យ លោករន្ទៀសថា ភិក្ខុនេះត្រូវអាបត្តិបាចិត្តិយៈ លោករន្ទៀសថា ភិក្ខុនេះត្រូវអាបត្តិបាដិទេសនីយៈ លោករន្ទៀសថា ភិក្ខុនេះត្រូវអាបត្តិទុក្កដ លោករន្ទៀសថា ភិក្ខុនេះត្រូវអាបត្តិទុព្ភាសិត លោករន្ទៀសព្រោះពាក្យភិក្ខុ លោករន្ទៀសព្រោះពាក្យភិក្ខុនី លោករន្ទៀសព្រោះពាក្យសិក្ខមានា លោករន្ទៀសព្រោះពាក្យសាមណេរ លោករន្ទៀសព្រោះពាក្យសាមណេរី លោករន្ទៀសព្រោះពាក្យឧបាសក លោករន្ទៀសព្រោះពាក្យឧបាសិកា លោករន្ទៀសព្រោះពាក្យពួកស្តេច លោករន្ទៀសព្រោះពាក្យពួកពលមហាមាត្រ លោករន្ទៀសព្រោះពាក្យពួកតិរ្ថិយ លោករន្ទៀសព្រោះពាក្យពួកសាវ័កតិរ្ថិយ ។

(១៦១) ហេតុដែលអ្នកចោទបានឃើញ សមតាមហេតុដែលឃើញមែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានឃើញ តាមហេតុដែលបានឃើញ (បើ) ភិក្ខុអ្នកជាប់ចោទមិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យហេតុដែលអ្នកចោទបានឃើញនោះទេ ឈ្មោះថា អ្នកចោទមានសេចក្តីរន្ទៀសមិនបរិសុទ្ធ គឺរន្ទៀ ដោយមិនមានមូល

ហោះនាកណ្ដាំ អនុរិដ្ឋកស្ស បដិបត្តិ

សោ បុគ្គលោ បដិញ្ញាយ
កាតព្វោ តេនុបោសថោ ៗ
សុតំ សុតេន សមេតិ
សុតេន សំសន្ទេត សុតំ
សុតំ បដិច្ច ច ឧបេតិ
អសុទ្ធបរិសង្កិតោ
សោ បុគ្គលោ បដិញ្ញាយ
កាតព្វោ តេនុបោសថោ ៗ
មុតំ មុតេន សមេតិ
មុតេន សំសន្ទេត មុតំ
មុតំ បដិច្ច ច ឧបេតិ
អសុទ្ធបរិសង្កិតោ
សោ បុគ្គលោ បដិញ្ញាយ
កាតព្វោ តេនុបោសថោតិ ៗ

វិន័យធរគប្បីវិនិច្ឆ័យ តាមពាក្យប្តេជ្ញា របស់ភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើឧបោសថជាមួយនឹងភិក្ខុនោះចុះ ។ ហេតុដែលអ្នកចោទបានឮ សមតាមហេតុដែលបានឮមែន វិន័យធរគប្បីប្រៀបធៀបនូវហេតុ ដែលអ្នកចោទបានឮ តាមហេតុដែលបានឮ (បើ) ភិក្ខុអ្នកជាប់ចោទនោះមិនទាន់ដល់(បារាជិក) ព្រោះអាស្រ័យហេតុដែលអ្នកចោទបានឮទេ ឈ្មោះថាអ្នកចោទមានសេចក្តីរង្កៀសមិនបរិសុទ្ធ វិន័យធរគប្បីវិនិច្ឆ័យ តាមពាក្យប្តេជ្ញារបស់ភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើឧបោសថជាមួយនឹងភិក្ខុនោះចុះ ។ ហេតុដែលអ្នកចោទបានប៉ះពាល់ សមតាមហេតុដែលបានប៉ះពាល់មែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលបានប៉ះពាល់ តាមហេតុដែលបានប៉ះពាល់ (បើ) ភិក្ខុអ្នកជាប់ចោទនោះ មិនទាន់ដល់(បារាជិក) ព្រោះអាស្រ័យហេតុដែលអ្នកចោទបានប៉ះពាល់ទេ ឈ្មោះថាអ្នកចោទមានសេចក្តីរង្កៀសមិនបរិសុទ្ធ វិន័យធរគប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញា របស់ភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើឧបោសថជាមួយនឹងភិក្ខុនោះចុះ ។

(១៦៤) ចោទនាយ កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។ ចោទនាយ ឱកាសកម្មំ អាទិ កិរិយា មជ្ឈេ សមថោ បរិយោសានំ ។ ចោទនាយ កតិ មូលានិ កតិ វត្ថូនិ កតិ ភូមិយោ កតីហាការេហិ ចោទេតិ ។ ចោទនាយ ទ្វេ មូលានិ តីណិ វត្ថូនិ បញ្ច ភូមិយោ ទ្វីហាការេហិ ចោទេតិ ។ ចោទនាយ កតមានិ ទ្វេ មូលានិ ។ សមូលិកា វា អមូលិកា វា ចោទនាយ ឥមានិ ទ្វេ មូលានិ ។ ចោទនាយ កតមានិ តីណិ វត្ថូនិ ។ ទិដ្ឋេន សុតេន បរិសង្កាយ ចោទនាយ ឥមានិ តីណិ វត្ថូនិ ។ ចោទនាយ កតមា បញ្ច ភូមិយោ ។ កាលេន វក្ខាមិ នោ អកាលេន ភូតេន វក្ខាមិ នោ អភូតេន សណ្ហេន វក្ខាមិ នោ ផរុសេន អត្ថសញ្ហិតេន វក្ខាមិ នោ អនត្ថសញ្ហិតេន មេត្តចិត្តោ វក្ខាមិ នោ ទោសន្តរោ ចោទនាយ ឥមា បញ្ច ភូមិយោ ។ កតមេហិ ទ្វីហាការេហិ ចោទេតិ ។ កាយេន វា ចោទេតិ វាចាយ វា ចោទេតិ ឥមេហិ ទ្វីហាការេហិ ចោទេតិ ។

(១៦៤) សួរថា ការចោទមានអ្វីជាខាងដើម អ្វីជាកណ្តាល អ្វីជាទីបំផុត ។ ឆ្លើយថា ការចោទមានឱកាសកម្មគឺសូមឱកាសជាខាងដើម មានកិរិយាគឺអធិករណ៍ដែលវិន័យធរត្រូវធ្វើជាកណ្តាល មានសមថៈគឺសេចក្តីរម្ងាប់ជាទីបំផុត ។ សួរថា ការចោទមានមូលប៉ុន្មាន មានវត្ថុប៉ុន្មាន មានភូមិប៉ុន្មាន បុគ្គលចោទដោយអាការប៉ុន្មាន ។ ឆ្លើយថា ការចោទមានមូល ២ មានវត្ថុ ៣ មានភូមិ ៥ បុគ្គលចោទដោយអាការ ២ ។ សួរថា ការចោទមានមូល ២ គឺអ្វីខ្លះ ។ ឆ្លើយថា ការចោទមានមូល ២ នេះ គឺ ចោទដោយមានមូល ១ ចោទដោយមិនមានមូល ១ ។ សួរថា ការចោទមានវត្ថុ ៣ គឺអ្វីខ្លះ ។ ឆ្លើយថា ការចោទមានវត្ថុ ៣ នេះគឺ ដោយបានឃើញ ១ ដោយបានឮ ១ ដោយបានរង្កៀស ១ ។ សួរថា ការចោទមានភូមិ ៥ គឺអ្វីខ្លះ ។ ឆ្លើយថា ការចោទមានភូមិ ៥ នេះគឺពោលត្រូវតាមកាល មិនពោលខុសកាល ១ ពោលពាក្យពិត មិនពោលពាក្យដែលមិនពិត ១ ពោលពាក្យផ្អែមល្ហែម មិនពោលពាក្យទ្រគោះ ១ ពោលពាក្យប្រកបដោយប្រយោជន៍ មិនពោលពាក្យដែលមិនប្រកបដោយប្រយោជន៍ ១ ពោលដោយមេត្តាចិត្ត មិនពោលដោយសេចក្តីស្អប់ ១ ។ សួរថា បុគ្គលចោទដោយអាការ ២ គឺអ្វីខ្លះ ។ ឆ្លើយថា បុគ្គលចោទដោយអាការ ២ នេះ គឺ ចោទដោយកាយ ១ ចោទដោយវាចា ១ ។

ចោទនាកណ្ឌំ ចោទកចុទិតកាទីនំ បដិបត្តិ

(១៦៣) ចោទកេន កថំ បដិបជ្ជិតព្វំ ចុទិតកេន កថំ បដិបជ្ជិតព្វំ សង្ឃេន កថំ បដិបជ្ជិតព្វំ អនុវិជ្ជកេន កថំ បដិបជ្ជិតព្វំ ។ ចោទកេន កថំ បដិបជ្ជិតព្វន្តិ ។ ចោទកេន បញ្ចសុ ធម្មេសុ បតិដ្ឋាយ បរោ ចោទេតព្វោ កាលេន វក្ខាមិ នោ អកាលេន ភូតេន វក្ខាមិ នោ អភូតេន សណ្ហេន វក្ខាមិ នោ ផរុសេន អត្ថសញ្ហិតេន វក្ខាមិ នោ អនត្ថសញ្ហិតេន មេត្តចិត្តោ វក្ខាមិ នោ ទោសន្តរោតិ ។ ចោទកេន ឯវំ បដិបជ្ជិតព្វំ ។ ចុទិតកេន កថំ បដិបជ្ជិតព្វន្តិ ។ ចុទិតកេន ទ្វីសុ ធម្មេសុ បតិដ្ឋាតព្វំ សច្ចេ ច អកុប្បេ ច ។ ចុទិតកេន ឯវំ បដិបជ្ជិតព្វំ ។ សង្ឃេន កថំ បដិបជ្ជិតព្វន្តិ ។ សង្ឃេន ឱតិណ្ណានោតិណ្ណំ ជានិតព្វំ ។

ចោទនាកណ្ឌ សេចក្តីប្រតិបត្តិរបស់អ្នកចោទនឹងអ្នកជាប់ចោទជាដើម

[១៦៣] សួរថា អ្នកចោទត្រូវប្រតិបត្តិដូចម្តេច អ្នកជាប់ចោទត្រូវប្រតិបត្តិដូចម្តេច សង្ឃត្រូវប្រតិបត្តិដូចម្តេច វិន័យធរត្រូវប្រតិបត្តិដូចម្តេច ៗ ត្រង់ពាក្យសួរថា អ្នកចោទត្រូវប្រតិបត្តិដូចម្តេច ៗ ឆ្លើយថា អ្នកចោទត្រូវតាំងនៅក្នុងធម៌ ៥ យ៉ាង ទើបចោទអ្នកដទៃបាន គឺតាំងចិត្តថា អាត្មាអញនឹងនិយាយត្រូវតាមកាល មិននិយាយខុសកាល ១ នឹងនិយាយពាក្យពិត មិននិយាយពាក្យដែលមិនពិត ១ នឹងនិយាយពាក្យផ្អែមល្ហែម មិននិយាយពាក្យទ្រគោះ ១ នឹងនិយាយពាក្យប្រកបដោយប្រយោជន៍ មិននិយាយពាក្យឥតប្រយោជន៍ ១ នឹងនិយាយដោយមេត្តាចិត្ត មិននិយាយដោយសេចក្តីស្អប់ ១ ៗ អ្នកចោទត្រូវប្រតិបត្តិយ៉ាងនេះ ៗ ត្រង់ពាក្យសួរថា អ្នកជាប់ចោទត្រូវប្រតិបត្តិដូចម្តេច ៗ ឆ្លើយថា អ្នកជាប់ចោទត្រូវតាំងនៅក្នុងធម៌ ២ យ៉ាង គឺក្នុងសច្ចវាចា ១ ក្នុងអកុប្បធម៌ គឺសេចក្តីមិនក្រោធចំពោះអ្នកចោទ ចំពោះវិន័យធរ ចំពោះសង្ឃ ១ ៗ អ្នកជាប់ចោទត្រូវប្រតិបត្តិយ៉ាងនេះ ៗ ត្រង់ពាក្យសួរថា សង្ឃត្រូវប្រតិបត្តិដូចម្តេច ៗ ឆ្លើយថា សង្ឃត្រូវដឹងពាក្យដែលទាក់ទងរកគ្នា នឹងពាក្យដែលមិនទាក់ទងរកគ្នា គឺដឹងពាក្យខាងដើមនឹងពាក្យខាងចុងរបស់អ្នកចោទមានប៉ុណ្ណេះ របស់អ្នកជាប់ចោទមានប៉ុណ្ណេះជាដើម ៗ

សង្ឃេន ឯវំ បដិបជ្ជិតព្វំ ។ អនុវិជ្ជកេន កថំ បដិ-បជ្ជិតព្វន្តិ ។ អនុវិជ្ជកេន យេន ធម្មេន យេន វិនយេន យេន សត្ថុសាសនេន តំ អធិករណំ វូប-សម្មតិ តថា តំ អធិករណំ វូបសមេតព្វំ ។ អនុវិជ្ជកេន ឯវំ បដិបជ្ជិតព្វំ ។

(១៦៤) ឧបោសថោ កិមត្ថាយ
បវារណា កិស្ស ការណា
បរិវាសោ កិមត្ថាយ
មូលាយ បដិកស្សនា កិស្ស ការណា
មានត្តំ កិមត្ថាយ
អព្ភានំ កិស្ស ការណា ។
ឧបោសថោ សមគ្គត្ថាយ
វិសុទ្ធត្ថាយ បវារណា
បរិវាសោ មានត្តត្ថាយ
មូលាយ បដិកស្សនា និគ្គហត្ថាយ
មានត្តំ អព្ភានត្ថាយ
វិសុទ្ធត្ថាយ អព្ភានំ ។

សង្ឃត្រូវប្រតិបត្តិយ៉ាងនេះ ៗ ត្រង់ពាក្យសួរថា វិន័យធរត្រូវប្រតិបត្តិដូចម្តេច ៗ ឆ្លើយថា អធិករណ៍នោះតែងរម្ងាប់បានដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាណា វិន័យធរត្រូវរមាប់អធិករណ៍នោះឯង ដោយធម៌នោះ ៗ ចុះ ៗ វិន័យធរត្រូវប្រតិបត្តិយ៉ាងនេះឯង ៗ

(១៦៨) សួរថា ការធ្វើឧបោសថ ដើម្បីប្រយោជន៍អ្វី ធ្វើបវារណា ដើម្បីអ្វី ធ្វើបរិវាស ដើម្បីប្រយោជន៍អ្វី ធ្វើការទាញភិក្ខុមកដាក់ក្នុងមូលាបត្តិ ដើម្បីអ្វី ការប្រព្រឹត្តិមានត្ត ដើម្បីប្រយោជន៍អ្វី ធ្វើអព្ភានកម្ម ដើម្បីអ្វី ៗ ឆ្លើយថា ធ្វើឧបោសថ ដើម្បីប្រយោជន៍ឲ្យសង្ឃព្រមព្រៀងគ្នា ធ្វើបវារណា ដើម្បីប្រយោជន៍ឲ្យសង្ឃស្អាតដោយវិសេស ធ្វើបរិវាស ដើម្បីប្រយោជន៍ដល់មានត្ត ធ្វើការទាញភិក្ខុមកដាក់ក្នុងមូលាបត្តិ ដើម្បីប្រយោជន៍នឹងសង្កត់សង្កិន (នូវបរិវាសិកភិក្ខុឲ្យរាងចាល) ការប្រព្រឹត្តិមានត្ត ដើម្បីប្រយោជន៍ដល់អព្ភានកម្ម ធ្វើអព្ភានកម្ម ដើម្បីប្រយោជន៍នឹងឲ្យភិក្ខុនោះស្អាតបរិសុទ្ធ ៗ

ចោទនាកណ្ឌំ ចោទកស្ស អត្តជ្ឈាបនំ

ឆន្ទា ទោសា ភយា មោហា
ថេរេ ច បរិភាសតិ
កាយស្ស ភេទា ទុប្បញ្ញោ
ខតោ ឧបហតិន្ទ្រិយោ
និរយំ គច្ឆតិ ទុម្មេធោ
ន ច សិក្ខាយ គារវោ ។
ន ចាមិសំបិ[១] និស្សាយ
ន ច និស្សាយ បុគ្គលំ
ឧភោ ឯតេ វិវជ្ជេត្វា
យថា ធម្មោ តថា ករេ ។
កោធនោ ឧបនាហី ច
ចណ្ឌោ ច បរិភាសកោ
អនាបត្តិយា អាបត្តីតិ រោបេតិ
តាទិសោ ចោទកោ ឈាបេតិ អត្តានំ ។
ឧបកណ្ណកំ ជប្បេតិ[២] ជិម្ហំ បេក្ខតិ
វីតិហរតិ កុម្មគ្គំ បដិសេវតិ

---

១ ឱ. ម. ន ប អាមិសំ ។ ២ ឱ. ម. ជប្បតិ ។

ចោទនាកណ្ឌ ការដុតខ្លួនឯងរបស់អ្នកចោទ

បុគ្គលណា ពោលមើលងាយពួកភិក្ខុជាថេរៈ ព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាច ឬ ព្រោះវង្វេង បុគ្គលនោះឈ្មោះថាជាអ្នកឥតប្រាជ្ញា ជាអ្នកបៀតបៀនខ្លួនឯង ផ្តាច់បង់ឥន្ទ្រិយ (មានសទ្ធិន្ទ្រិយជាដើម) ជាអ្នកឥតប្រាជ្ញា មិនមានសេចក្តីគោរពក្នុងសិក្ខា លុះទំលាយកាយទៅ តែងទៅកាន់នរក ៗ (ព្រោះហេតុនោះ) វិន័យធរ ត្រូវវៀរហេតុទាំងពីរនេះ គឺ កុំអាស្រ័យអាមិសៈ ១ កុំអាស្រ័យបុគ្គល(១) ១ ត្រូវតែវិនិច្ឆ័យសេចក្តីតាមសមគួរដល់ធម៌ ៗ ភិក្ខុដែលមានសេចក្តីក្រោធខឹង ចងសេចក្តីក្រោធទុក កាចអាក្រក់ ពោលតិះដៀល លើកអនាបត្តិថាជាអាបត្តិវិញ អ្នកចោទដូច្នោះឈ្មោះថា ដុតខ្លួនឯង ៗ ភិក្ខុឱនខ្សឹបទៀបត្រចៀកស្វែងរកតែទោស ធ្វើការវិ-និច្ឆ័យឲ្យសាបសូន្យ សេពគប់តែផ្លូវដែលខុស ៗ គឺប្រកាស

---

១ អដ្ឋកថាពន្យល់សេចក្តីថា ភិក្ខុជាវិន័យធរមិនត្រូវលុះដោយអគតិ មានឆន្ទាគតិជាដើមទេ គឺកុំយល់មុខថា លោកនេះជាឧបជ្ឈាយ៍ ជាអាចារ្យ របស់អញជាដើម ។

វិនយបិដកេ បរិវារោ

អនាបត្តិយា អាបត្តីតិ ទីបេតិ
តាទិសោ ធោនកោ ឈាបេតិ អត្តានំ
អកាលេន ចោទេតិ អភូតេន
ផរុសេន អនត្ថសញ្ហិតេន
ទោសន្តរោ ចោទេតិ នោ មេត្តចិត្តោ
អនាបត្តិយា អាបត្តីតិ ទីបេតិ
តាទិសោ ធោនកោ ឈាបេតិ អត្តានំ ។
ធម្មាធម្មំ ន ជានាតិ
ធម្មាធម្មស្ស អកោវិទោ
អនាបត្តិយា អាបត្តីតិ ទីបេតិ
តាទិសោ ធោនកោ ឈាបេតិ អត្តានំ ។
វិនយាវិនយំ ន ជានាតិ
វិនយាវិនយស្ស អកោវិទោ
អនាបត្តិយា អាបត្តីតិ ទីបេតិ
តាទិសោ ធោនកោ ឈាបេតិ អត្តានំ ។
ភាសិតាភាសិតំ ន ជានាតិ
ភាសិតាភាសិតស្ស អកោវិទោ

នូវអាបត្តិ លើកនូវអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះក៏ឈ្មោះថាដុតខ្លួនឯង បុគ្គលអ្នកចោទដោយមិនត្រូវតាមកាល ដោយពាក្យមិនពិត ដោយពាក្យគ្រោះ ដោយពាក្យឥតប្រយោជន៍ ចោទដោយស្អប់ មិនចោទដោយមេត្តាចិត្ត លើកនូវអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះក៏ឈ្មោះថា ដុតខ្លួនឯង ។ បុគ្គលមិនដឹងធម៌និងអធម៌ មិនឈ្វេងយល់ធម៌និងអធម៌ លើកនូវអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះក៏ឈ្មោះថា ដុតខ្លួនឯង ។ បុគ្គលមិនដឹងវិន័យនិងអវិន័យ មិនឈ្វេងយល់វិន័យនិងអវិន័យ លើកនូវអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថាដុតខ្លួនឯង ។ បុគ្គលមិនដឹងភាសិតនិងអភាសិត មិនឈ្វេងយល់ភាសិតនិង

ចោទនាកណ្ឌំ ចោទកស្ស អត្តជ្ឈាបនំ

អនាបត្តិយា អាបត្តីតិ ទីបេតិ

តាទិសោ ចោទកោ ឈាបេតិ អត្តានំ ។

អាចិណ្ណាចិណ្ណំ ន ជានាតិ

អាចិណ្ណាចិណ្ណស្ស អកោវិទោ

អនាបត្តិយា អាបត្តីតិ ទីបេតិ

តាទិសោ ចោទកោ ឈាបេតិ អត្តានំ ។

បញ្ញត្តាបញ្ញត្តំ ន ជានាតិ

បញ្ញត្តាបញ្ញត្តស្ស អកោវិទោ

អនាបត្តិយា អាបត្តីតិ ទីបេតិ

តាទិសោ ចោទកោ ឈាបេតិ អត្តានំ ។

អាបត្តានាបត្តឹ ន ជានាតិ

អាបត្តានាបត្តិយា អកោវិទោ

អនាបត្តិយា អាបត្តីតិ ទីបេតិ

តាទិសោ ចោទកោ ឈាបេតិ អត្តានំ ។

លហុកគរុកំ ន ជានាតិ

អភាសិត លើកនូវអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថាដុតខ្លួនឯង ៗ បុគ្គលមិនដឹងកិច្ចវត្តដែលអ្នកប្រាជ្ញសន្សំនឹងមិនសន្សំ មិនឈ្វេងយល់កិច្ចវត្តដែលអ្នកប្រាជ្ញសន្សំនឹងមិនសន្សំ លើកអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះឈ្មោះថាដុតខ្លួនឯង ៗ បុគ្គលមិនដឹងសិក្ខាបទ ដែលព្រះមានព្រះភាគបញ្ញត្តនឹងមិនបានបញ្ញត្ត មិនឈ្វេងយល់សិក្ខាបទ ដែលព្រះមានព្រះភាគបញ្ញត្តនឹងមិនបានបញ្ញត្ត លើកអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះឈ្មោះថាដុតខ្លួនឯង ៗ បុគ្គលមិនដឹងនូវអាបត្តិនឹងអនាបត្តិ មិនឈ្វេងយល់ដល់អាបត្តិនឹងអនាបត្តិ លើកអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះឈ្មោះថាដុតខ្លួនឯង ៗ បុគ្គលមិនដឹងលហុកាបត្តិ នឹងគរុកាបត្តិ

លហុកគរុកស្ស អកោវិទោ
អនាបត្តិយា អាបត្តីតិ រោបេតិ
តាទិសោ ថោនកោ ឈាបេតិ អត្តានំ ។
សាវសេសានវសេសំ ន ជានាតិ
សាវសេសានវសេសស្ស អកោវិទោ
អនាបត្តិយា អាបត្តីតិ រោបេតិ
តាទិសោ ថោនកោ ឈាបេតិ អត្តានំ ។
ទុដ្ឋុល្លាទុដ្ឋុល្លំ ន ជានាតិ
ទុដ្ឋុល្លាទុដ្ឋុល្លស្ស អកោវិទោ
អនាបត្តិយា អាបត្តីតិ រោបេតិ
តាទិសោ ថោនកោ ឈាបេតិ អត្តានំ ។
បុព្វាបរំ ន ជានាតិ
បុព្វាបរស្ស អកោវិទោ
អនាបត្តិយា អាបត្តីតិ រោបេតិ
តាទិសោ ថោនកោ ឈាបេតិ អត្តានំ ។
អនុសន្ធិវចនបថំ ន ជានាតិ

មិនឃើញយល់លហុកាបត្តិនឹងគរុកាបត្តិ លើកនូវអនាបត្តិថា ជាអាបត្តិ អ្នកចោទដូច្នោះឈ្មោះថាដុតខ្លួនឯង ។ បុគ្គលមិនដឹងនូវសាវសេសាបត្តិ នឹងអនវសេសាបត្តិ មិនឃើញយល់ដល់សាវសេសាបត្តិ នឹងអនវសេសាបត្តិ លើកអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះឈ្មោះថាដុតខ្លួនឯង ។ បុគ្គលមិនដឹងនូវទុដ្ឋុល្លាបត្តិនឹងអទុដ្ឋុល្លាបត្តិ មិនឃើញយល់ដល់ទុដ្ឋុល្លាបត្តិនឹងអទុដ្ឋុល្លាបត្តិ លើកនូវអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះឈ្មោះថាដុតខ្លួនឯង ។ បុគ្គលមិនដឹងពាក្យខាងដើមនឹងពាក្យខាងចុង មិនឃើញយល់ពាក្យខាងដើមនឹងពាក្យខាងចុង លើកនូវអនាបត្តិថាជាអាបត្តិ អ្នកចោទដូច្នោះឈ្មោះថា ដុតខ្លួនឯង ។ បុគ្គលមិនដឹងគន្លងនៃពាក្យតគ្នា

អនុសន្ធិវចនបថស្ស អកោវិទោ

អនាបត្តិយា អាបត្តីតិ ទីបេតិ

តាទិសោ ចោទកោ ឈាបេតិ អត្តានន្តិ ។

ចោទនាកណ្ឌំ និដ្ឋិតំ ។

តស្សុទ្ទានំ

(១៦៥) ចោទនា អនុវិជ្ជញ្ច[១]

អាទិ មូលេនុបោសថោ

គតិ ចោទនកណ្ឌម្ហិ

សាសនំ បតិដ្ឋាបយន្តិ ។

---

១ ឧ. អនុវិជ្ជា ច ។

ចោទនាកណ្ឌ ឧទ្ទានគាថា

មិនឈ្វេងយល់គន្លងនៃពាក្យគត្ថា លើកនូវអនាបត្តិថាជាអាបត្តិ

អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង ។

ចប់ ចោទនាកណ្ឌ ។

ឧទ្ទាន គឺបញ្ជីរឿងនៃចោទនាកណ្ឌនោះ ដូច្នេះ

[១៦៥] និយាយអំពីអ្នកចោទនឹងវិន័យធរ ១ ការចោទមាន

អ្វីជាខាងដើម និងមានមូលប៉ុន្មាន ១ សួរថាការធ្វើទោសថ

ដើម្បីប្រយោជន៍អ្វី ១ ដំណើរក្នុងចោទនាកណ្ឌ (នេះ) ជា

គ្រឿងញុំាងសាសនាឲ្យឋិតថេរ ។

ចូឡសង្គាមំ

(១៦៦) សង្គាមាវចរេន ភិក្ខុនា សង្ឃំ ឧបសង្ក-
មន្តេន នីចចិត្តេន សង្ឃោ ឧបសង្កមិតព្វោ រជោហ-
រណសមេន ចិត្តេន អាសនកុសលេន ភវិតព្វំ និសជ្ជ-
កុសលេន ថេរេ ភិក្ខូ អនុបខជ្ជន្តេន នវេ ភិក្ខូ
អាសនេន អប្បដិពាហន្តេន យថាបដិរូបេ អាសនេ
និសីទិតព្វំ អនានាកថិកេន ភវិតព្វំ អតិរច្ឆានកថិ-
កេន សាមំ វា ធម្មោ ភាសិតព្វោ បរោ វា អជ្ឈេ-
សិតព្វោ អរិយោ វា តុណ្ហីភាវោ នាតិមញ្ញិតព្វោ ។
សង្ឃេន អនុមតេន បុគ្គលេន អនុវិជ្ជកេន អនុវិជ្ជិតុ-
កាមេន ន ឧបជ្ឈាយោ បុច្ឆិតព្វោ ន អាចរិយោ

ចូឡសង្គាម

[១៦៦] ភិក្ខុអ្នកចូលកាន់សង្គ្រាម(១) កាលបើចូលទៅរកជំនុំសង្ឃ គប្បីបន្ទាបបន្ទន់ចិត្ត ចូលទៅរកសង្ឃ គប្បីជាអ្នកមានចិត្តស្មើដោយកំ-ណាត់សំពត់សម្រាប់ជូតនូវធូលី គប្បីជាអ្នកឈ្លាសក្នុងអាសនៈ ជាអ្នកឈ្លាសក្នុងការអង្គុយ កុំអង្គុយប្រៀតបៀតពួកភិក្ខុចាស់ កុំឃាត់អាសនៈពួកភិក្ខុខ្ចី គប្បីអង្គុយលើអាសនៈតាមសមគួរ គប្បីជាអ្នកមិនពោលពាក្យឥតប្រយោជន៍ផ្សេងៗ កុំពោលពាក្យតិរច្ឆានកថា គប្បីសំដែងធម៌ដោយខ្លួនឯងផង គប្បីនិមន្តភិក្ខុដទៃឲ្យសំដែងផង កុំមើលងាយព្រះអរិយៈដែលមានសភាពជាអ្នកស្ងប់ស្ងៀមផង ។ ភិក្ខុជាវិន័យធរដែលសង្ឃបានអនុម័ត(២) ហើយមានប្រាថ្នានឹងវិនិច្ឆ័យសេចក្តី មិនត្រូវសួររកឧបជ្ឈាយ៍ មិនត្រូវសួរ

---

១ ការប្រជុំសង្ឃដើម្បីរម្ងាប់ ឬវិនិច្ឆ័យ នូវអធិករណ៍ លោកហៅថា សង្គ្រាម ។ ដូចពួកវជ្ជីបុត្តកភិក្ខុ ក្នុងនគរវេសាលី ដែលជាសត្រូវដល់ខ្លួនផង ដល់សាសនាផង នាំគ្នាសំដែងខុសធម៌ខុសវិន័យ ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ។ ភិក្ខុណាសង្កត់សង្កិនលទ្ធិរបស់ពួកវជ្ជីបុត្ត ដែលជាសត្រូវទាំងនោះ នឹងចូលទៅក្នុងទីនោះ ហើយធ្វើសេចក្តីវិនិច្ឆ័យឲ្យដាច់ស្រេចដោយបំភ្លឺនូវវាទៈរបស់ខ្លួន ភិក្ខុនោះឈ្មោះថាជាអ្នកចូលទៅកាន់សង្គ្រាម ដូចជាព្រះយសត្ថេរ (អដ្ឋកថា) ។ ២ យល់តាមឬយល់ព្រម ពាក្យនេះជាពាក្យផ្លាស់ប្តូរគ្នា នឹងពាក្យអនុញ្ញាត ។

បុច្ឆិតព្វោ ន សទ្ធិវិហារិកោ បុច្ឆិតព្វោ ន អន្តេវាសិកោ បុច្ឆិតព្វោ ន សមានុបជ្ឈាយកោ បុច្ឆិតព្វោ ន សមានាចរិយកោ បុច្ឆិតព្វោ ន ជាតិ បុច្ឆិតព្វា ន នាមំ បុច្ឆិតព្វំ ន គោត្តំ បុច្ឆិតព្វំ ន អាគមោ បុច្ឆិតព្វោ ន កុលបទេសោ បុច្ឆិតព្វោ ន ជាតិភូមិ បុច្ឆិតព្វា ។ កិំការណា ។ អត្រស្ស បេមំ វា ទោសោ វា បេមេ វា សតិ ទោសេ វា សតិ ឆន្ទាបិ គច្ឆេយ្យ ទោសាបិ គច្ឆេយ្យ មោហាបិ គច្ឆេយ្យ ភយាបិ គច្ឆេយ្យ ។ សង្ឃេន អនុមតេន បុគ្គលេន អនុវិជ្ជកេន អនុវិជ្ជិតុកាមេន សង្ឃគរុកេន ភវិតព្វំ នោ បុគ្គលគរុកេន សទ្ធម្មគរុកេន ភវិតព្វំ នោ អាមិសគរុកេន អត្ថវសិកេន ភវិតព្វំ នោ បរិសកប្បិយេន កាលេន អនុវិជ្ជិតព្វំ នោ អកាលេន ភូតេន អនុវិជ្ជិតព្វំ នោ អភូតេន សណ្ហេន អនុវិជ្ជិតព្វំ នោ

គេអាចារ្យ មិនត្រូវសួរគេសទ្ធិវិហារិក មិនត្រូវសួរគេអន្តេវាសិក មិនត្រូវសួរគេបុគ្គលដែលមានឧបជ្ឈាយ៍ស្មើគ្នា មិនត្រូវសួរគេបុគ្គលដែលមានអាចារ្យស្មើគ្នា មិនត្រូវសួរគេជាតិ (មានក្សត្រិយ៍ជាដើម) មិនត្រូវសួរគេនាម មិនត្រូវសួរគេគោត្រ មិនត្រូវសួរគេអាគម (វិជ្ជាបំណេះថា លោកចេះពោលនិកាយ មានទីឃនិកាយជាដើម) មិនត្រូវសួរគេត្រកូលនិងប្រទេស មិនត្រូវសួរគេជាតិភូមិ (ស្រុកកំណើត) ។ ព្រោះហេតុអ្វី (បានជាមិនត្រូវឲ្យសួរដូច្នេះ) ។ (ព្រោះថា) សេចក្ដីស្រឡាញ់ក្ដី សេចក្ដីស្អប់ក្ដី នឹងមានដល់បុគ្គលជាវិន័យធរនោះ កាលបើមានសេចក្ដីស្រឡាញ់ និងសេចក្ដីស្អប់ហើយ (វិន័យធរនោះ) មុខជាលំអៀងព្រោះស្រឡាញ់ ឬលំអៀងព្រោះស្អប់ លំអៀងព្រោះវង្វេង ឬក៏លំអៀងព្រោះខ្លាច (មិនខាន) ។ ភិក្ខុជាវិន័យធរដែលសង្ឃបានអនុម័តហើយ មានប្រាថ្នានឹងវិនិច្ឆ័យសេចក្ដី ត្រូវមានចិត្តធ្ងន់ក្នុងសង្ឃ កុំធ្ងន់ទៅក្នុងបុគ្គល ត្រូវមានចិត្តធ្ងន់ក្នុងព្រះសទ្ធម្ម កុំធ្ងន់ទៅក្នុងអាមិសៈ ជាអ្នកលុះក្នុងអំណាចនៃប្រយោជន៍ មិនត្រូវបណ្ដែតបណ្ដោយតាមសេចក្ដីគាប់ចិត្តបរិសទ្យ គប្បីវិនិច្ឆ័យសេចក្ដីតាមកាល កុំវិនិច្ឆ័យសេចក្ដីឲ្យខុសកាល ត្រូវវិនិច្ឆ័យសេចក្ដីដោយពាក្យពិត កុំវិនិច្ឆ័យដោយពាក្យមិនពិត ត្រូវវិនិច្ឆ័យសេចក្ដីដោយពាក្យផ្អែមល្ហែម កុំវិនិច្ឆ័យ

ផរុសេន អត្តសញ្ញិតេន អនុវិជ្ជិតព្វំ នោ អនត្តសញ្ញិ-
តេន មេត្តចិត្តេន អនុវិជ្ជិតព្វំ នោ ទោសន្តរេន ន ឧ-
បកណ្ណកជប្បិនា ភវិតព្វំ ន ជិម្ហំ បេក្ខិតព្វំ ន អក្ខិំ
និក្ខណិតព្វំ ន ភមុកំ ឧក្ខិបិតព្វំ ន សីសំ ឧក្ខិបិតព្វំ
ន ហត្ថវិការោ កាតព្វោ ន ហត្ថមុទ្ទា ទស្សេតព្វា
អាសនកុសលេន ភវិតព្វំ និសជ្ជកុសលេន យុគមត្តំ
បេក្ខន្តេន អត្ថំ អនុវិធិយន្តេន សកេ អាសនេ និសីទិ-
តព្វំ ន ច អាសនា វុដ្ឋាតព្វំ ន វីតិហាតព្វំ ន កុម្មគ្គោ
សេវិតព្វោ ន ភាហាវិក្ខេបកំ (១) ភណិតព្វំ អតុរិតេន
ភវិតព្វំ អសាហសិកេន អចណ្ឌិកតេន ភវិតព្វំ វច-
នក្ខមេន មេត្តចិត្តេន ភវិតព្វំ ហិតានុកម្បិនា កា-
រុណិកេន ភវិតព្វំ ហិតបរិសក្កិនា អសម្ផប្បលាបិនា
ភវិតព្វំ បរិយន្តភាណិនា អវេរវសិកេន ភវិតព្វំ អនសុ-
រុត្តេ អត្តា បរិគ្គហេតព្វោ បរោ បរិគ្គហេតព្វោ
ចោទកោ បរិគ្គហេតព្វោ ចុទិតកោ បរិគ្គហេតព្វោ

---

១ ឱ. ម. ពាហាវិក្ខេបកំ ។

សេចក្តីដោយពាក្យទ្រគោះ ត្រូវវិនិច្ឆ័យសេចក្តីដោយពាក្យដែលមានប្រយោជន៍ កុំវិនិច្ឆ័យសេចក្តីដោយពាក្យឥតប្រយោជន៍ ត្រូវវិនិច្ឆ័យសេចក្តីដោយមេត្តាចិត្ត កុំវិនិច្ឆ័យសេចក្តីដោយសំអប់ កុំនិយាយខ្សឹបដិតត្រចៀក កុំស្វែងរកតែទោសខុស កុំមិចភ្នែក កុំញាក់ចិញ្ចើម កុំងក់ក្បាល កុំធ្វើវិការៈផ្សេង ៗ ដោយដៃ កុំបង្ហាញដៃទទេ ត្រូវឈ្លាសក្នុងអាសនៈ ឈ្លាសក្នុងការអង្គុយ គប្បីសំឡឹងមើលត្រឹមតែមួយជួរនឹម ត្រូវពិចារណាសេចក្តីសិនហើយសឹមអង្គុយលើអាសនៈរបស់ខ្លួន កុំក្រោកចាកអាសនៈ កុំធ្វើការវិនិច្ឆ័យឲ្យសាបសូន្យ កុំសេពគប់ផ្លូវខុស គឺកុំប្រកាសអាបត្តិ កុំនិយាយសំដីបោះបោក កុំនិយាយរួសរាន់ពេក កុំនិយាយហ៊ើសហួស កុំកាចអាក្រក់ ត្រូវចេះអត់ធ្មត់ ត្រូវមានមេត្តាចិត្ត មានចិត្តអនុគ្រោះចំពោះប្រយោជន៍ ត្រូវមានចិត្តប្រកបដោយករុណា ស្វែងរកនូវប្រយោជន៍ កុំពោលពាក្យពេយពាយ ត្រូវពោលពាក្យឲ្យមានទីបំផុត កុំលុះអំណាចនៃពៀរ កុំពោលពាក្យអសុរស ត្រូវស្ទង់មើលខ្លួន (ថាអាត្មាអញអាចនឹងវិនិច្ឆ័យសេចក្តីបានឬទេ) ត្រូវស្ទង់មើលបុគ្គលដទៃ (ថាបរិសទ្យនេះអាចសុខចិត្តដោយសេចក្តីអៀនខ្មាសដែរឬទេ) ត្រូវស្ទង់មើលបុគ្គលអ្នកចោទ (ថាអ្នកចោទនេះប្រកបដោយធម៌ឬទេ) ត្រូវស្ទង់មើលអ្នកជាប់ចោទ

ចូឡសង្គាមំ អនុវិជ្ជកស្ស បដិបត្តិ

អធម្មចោទកោ បរិគ្គហេតព្វោ អធម្មចុទិតកោ បរិគ្គហេតព្វោ ធម្មចោទកោ បរិគ្គហេតព្វោ ធម្មចុទិតកោ បរិគ្គហេតព្វោ វុត្តំ អហាបេន្តេន អវុត្តំ អប្បកាសេន្តេន ឱតិណ្ណានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា បរេ បដិបុច្ឆិត្វា យថាបដិញ្ញាយ ការេតព្វោ វេធោ បហាសេតព្វោ[១] ភីរុ អស្សាសេតព្វោ ចណ្ឌោ និសេធេតព្វោ អសុចិ វិភាវេតព្វោ[២] ឧជុមទ្ទវេន ន ឆន្ទាគតិ គន្តព្វា[៣] ន ទោសាគតិ គន្តព្វា ន មោហាគតិ គន្តព្វា ន ភយាគតិ គន្តព្វា[៤] មជ្ឈត្តេន ភវិតព្វំ ធម្មេសុ ច បុគ្គលេសុ ច ។ ឯវញ្ច បន អនុវិជ្ជកោ អនុវិជ្ជមានោ សត្ថុ ចេវ សាសនករោ ហោតិ វិញ្ញូនំ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។

---

១ ឱ. ប. មន្ទោ ហាសេតព្វោ ។ វេធោ បហាសេតព្វោតិ មន្ទោ មោមូហោ បគ្គណ្ហិតព្វោតិ អដ្ឋកថា ។ ២ ម. ភាវេតព្វោ ។ ៣–៤ ម. ន ឆន្ទាគតឹ គន្តព្វំ ។ប។ ន ភយាគតឹ គន្តព្វំ ។

ត្រូវស្ទង់មើលអ្នកចោទមិនត្រូវតាមធម៌ ត្រូវស្ទង់មើលអ្នកជាប់ចោទមិនត្រូវតាមធម៌ ត្រូវស្ទង់មើលអ្នកចោទត្រូវតាមធម៌ ត្រូវស្ទង់មើលអ្នកជាប់ចោទត្រូវតាមធម៌ កុំបំបាត់ពាក្យអ្នកចោទ នឹងអ្នកជាប់ចោទ ដែលនិយាយមកហើយ កុំប្រកាសផ្សាយពាក្យដែលអ្នកចោទ នឹងអ្នកជាប់ចោទមិនទាន់បាននិយាយ ត្រូវរៀនបទនឹងព្យញ្ជនៈដែលទាក់ទងគ្នា ឲ្យបេះចាំល្អ ហើយសួរបុគ្គលដទៃសិន សឹមវិនិច្ឆ័យសេចក្តីតាមពាក្យប្តេជ្ញា ត្រូវធ្វើអ្នកមានបញ្ញាទន់ឲ្យរីករាយ ត្រូវធ្វើអ្នកដែលមានសេចក្តីភិតភ័យឲ្យស្រួលចិត្ត ត្រូវគំរាមបុគ្គលដែលកាច ត្រូវឲ្យបុគ្គលដែលជាអលជ្ជីសំដែងអាបត្តិចេញ ត្រូវមានចិត្តត្រង់ មានចិត្តទន់ កុំលុះឆន្ទាគតិ កុំលុះទោសាគតិ កុំលុះមោហាគតិ កុំលុះភយាគតិ ត្រូវជាអ្នកមានខ្លួនតាំងនៅជាកណ្តាលចំពោះធម៌ផង ចំពោះបុគ្គលផង ៗ កាលបើវិន័យធរបានវិនិច្ឆ័យតាមទំនងយ៉ាងនេះហើយ ឈ្មោះថាជាអ្នកធ្វើសាសនារបស់ព្រះសាស្តា (ឲ្យរុងរឿង) ផង ឈ្មោះថាជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ដែលជាអ្នកចេះដឹងផង ៗ

(១៦៧) សុត្តំ សំសន្ទនត្ថាយ ឱបម្មំ និទស្សនត្ថាយ អត្ថោ វិញ្ញាបនត្ថាយ បដិបុច្ឆា ឋបនត្ថាយ ឱកាសកម្មំ ចោទនត្ថាយ ចោទនា សារណត្ថាយ សារណា សវចនីយត្ថាយ សវចនីយំ បលិពោធត្ថាយ បលិពោធោ វិនិច្ឆយត្ថាយ វិនិច្ឆយោ សន្តីរណត្ថាយ សន្តីរណា ឋានាឋានគមនត្ថាយ ឋានាឋានគមនំ ទុម្មង្កូនំ បុគ្គលានំ និគ្គហត្ថាយ បេសលានំ ភិក្ខូនំ សម្បគ្គហត្ថាយ[១] សង្ឃោ សម្បរិគ្គហសម្បដិច្ឆនត្ថាយ សង្ឃេន អនុមតា បុគ្គលា បច្ចេកដ្ឋាយិនោ អវិសំវាទនដ្ឋាយិនោ ។ វិនយោ សំវរត្ថាយ សំវរោ

១ សង្គហត្ថាយាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

វិនយបិដក បរិវារៈ

[១៦៧] សុត្តៈ គឺឧភតោវិភង្គ (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍នឹងប្រៀបធៀប (នូវអាបត្តិ និងអនាបត្តិ) សេចក្តីឧបមា (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍នឹងពន្យល់សេចក្តីឲ្យច្បាស់ អត្ថ (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍នឹងឲ្យដឹងច្បាស់ បដិបុច្ឆា (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍នឹងដាក់ទុក (នូវបុគ្គល) ឱកាសកម្ម (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍ដល់ការចោទ ការចោទ (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍នឹងរំលឹក (នូវទោសតូចនិងទោសធំ) ការរំលឹកទោស ដើម្បីប្រយោជន៍នឹងធ្វើ (បុគ្គលនោះ) ឲ្យមានមាត់ពាក្យ អំពើដែលធ្វើឲ្យមានមាត់ពាក្យ ដើម្បីប្រយោជន៍ដល់ការកន្លំ ការកន្លំ ដើម្បីប្រយោជន៍នឹងដាក់ចប់ទុកនូវការវិនិច្ឆ័យសេចក្តី ការវិនិច្ឆ័យ ដើម្បីប្រយោជន៍ពិចារណា (នូវទោសតូចនិងទោសធំ) ការពិចារណា ដើម្បីប្រយោជន៍នឹងដឹងនូវហេតុគួរនិងមិនគួរ (ដឹងអាបត្តិ និងអនាបត្តិ គរុកាបត្តិ និងលហុកាបត្តិ) ការដឹងនូវហេតុគួរនិងមិនគួរ ដើម្បីប្រយោជន៍សង្កត់សង្កិនពួកបុគ្គល ដែលមិនមានសេចក្តីអៀនខ្មាស និងដើម្បីប្រយោជន៍លើកដំកើងនូវពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ជំនុំសង្ឃ ដើម្បីប្រយោជន៍ទទួលនូវការវិនិច្ឆ័យ បុគ្គល គឺពួកភិក្ខុដែលសង្ឃអនុញ្ញាតហើយ គួរដល់តំណែងជាធំតាមចំណែក និងគួរដល់តំណែងជាអ្នកពោលពាក្យពិតៗ វិន័យ ដើម្បីប្រយោជន៍ដល់សេចក្តីសង្រួម សេចក្តីសង្រួម ដើម្បី

អវិប្បដិសារត្ថាយ អវិប្បដិសារោ បាមុជ្ជត្ថាយ បាមុជ្ជំ

បីតត្ថាយ បីតិ បស្សទ្ធត្ថាយ បស្សទ្ធិ សុខត្ថាយ សុខំ

សមាធត្ថាយ សមាធិ យថាភូតញាណទស្សនត្ថាយ

យថាភូតញាណទស្សនំ និព្ពិទត្ថាយ និព្ពិទា វិរាគត្ថាយ

វិរាគោ វិមុត្តត្ថាយ វិមុត្តិ វិមុត្តិញាណទស្សនត្ថាយ

វិមុត្តិញាណទស្សនំ អនុបាទាបរិនិព្ពានត្ថាយ ។ ឯតទត្ថា

កថា ឯតទត្ថា មន្តនា ឯតទត្ថា ឧបនិសា ឯតទត្ថំ

សោតាវធានំ យទិទំ អនុបាទា ចិត្តស្ស វិមោក្ខោតិ ។

ប្រយោជន៍ដល់សេចក្ដីមិនក្ដៅក្រហាយចិត្ត សេចក្ដីមិនក្ដៅក្រហាយចិត្ត ដើម្បីប្រយោជន៍ដល់បាមុជ្ជៈ គឺសេចក្ដីរីករាយទន់ បាមុជ្ជៈដើម្បីប្រយោជន៍ដល់បីតិ គឺសេចក្ដីរីករាយដ៏ក្លា បីតិ ដើម្បីប្រយោជន៍ដល់បស្សទ្ធិ គឺសេចក្ដីស្ងប់រម្ងាប់ បស្សទ្ធិ ដើម្បីប្រយោជន៍ដល់សុខៈ សុខៈ ដើម្បីប្រយោជន៍ដល់សមាធិ សមាធិ ដើម្បីប្រយោជន៍ដល់យថាភូតញ្ញាណទស្សនៈ គឺតរុណវិបស្សនា (វិបស្សនាទន់ខ្ចី) យថាភូតញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់និព្វិទា គឺពលវវិបស្សនា (វិបស្សនាមានកំឡាំង) និព្វិទា ដើម្បីប្រយោជន៍ដល់វិរាគៈ គឺអរិយមគ្គ វិរាគៈ ដើម្បីប្រយោជន៍ដល់វិមុត្តិ គឺអរហត្តផល វិមុត្តិ ដើម្បីប្រយោជន៍ដល់វិមុត្តិញ្ញាណទស្សនៈ គឺបច្ចវេក្ខណញ្ញាណ វិមុត្តិញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន គឺរំលត់មិនឲ្យមានបច្ច័យជាគ្រឿងប្រកាន់តទៅ ។ ព្រះអរហត្តផល ឬព្រះនិព្វានជាគ្រឿងរួចចាកសេចក្ដីសៅហ្មងនៃចិត្ត ព្រោះមិនមានឧបាទានជាគ្រឿងប្រកាន់ណា ការពោលនូវព្រះវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វាននុ៎ះជាប្រយោជន៍ ការប្រឹក្សានូវវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វាននុ៎ះជាប្រយោជន៍ ការពិចារណានូវវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វាននុ៎ះជាប្រយោជន៍ ការប្រុងស្ដាប់នូវវិន័យ ក៏មានព្រះអរហត្តផល ឬព្រះនិព្វាននុ៎ះជាប្រយោជន៍ ។

[១៦៨] អនុយោគវត្តំ និសាមយ(១)
កុសលេន ពុទ្ធិមតា កតំ
សុវុត្តំ សិក្ខាបទានុលោមិកំ
គតឹ ន នាសេន្តោ សម្បរាយិកំ
វត្ថុំ វិបត្តឹ អាបត្តឹ
និទានំ អាការអកោវិទោ(២)
បុព្វាបរំ ន ជានាតិ
កតាកតំ សមេន ច
កម្មញ្ច អធិករណញ្ច
សមថេ ចាបិ អកោវិទោ
រត្តោ ទុដ្ឋោ ច មូឡ្ហោ ច
ភយា មោហា(៣) ច គច្ឆតិ
ន ច សញ្ញត្តិកុសលោ
និជ្ឈត្តិយា ច អកោវិទោ
លទ្ធបក្ខោ អហិរិកោ
កណ្ហកម្មោ អនាទរោ

---

១ និសាមេថាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ម. និទានា ការអកោវិទោ
៣ ឱ. ម. សម្មោហា ។

[១៦៨] បុរសអ្នកពិចារណានូវវត្ថុដែលគួរប្រព្រឹត្តតាម ដែលអនុលោមតាមនូវសិក្ខាបទ ដែលព្រះលោកនាថជាអ្នកប្រាជ្ញ មានបញ្ញាវាងវៃនាំមកដាក់ទុក និងបញ្ញត្តទុកដោយប្រពៃ ធ្វើដំណើររបស់ខ្លួនដែលប្រព្រឹត្តទៅក្នុងបរលោកកុំឲ្យវិនាស ភិក្ខុណា មិនស្គាល់វត្ថុផង មិនស្គាល់វិបត្តិផង មិនស្គាល់អាបត្តិផង មិនស្គាល់និទានផង មិនឈ្លាសក្នុងអាការៈ គឺហេតុនិងមិនមែនហេតុផង មិនស្គាល់ពាក្យខាងដើមនិងពាក្យខាងចុងផង មិនស្គាល់កម្មគួរធ្វើនិងមិនគួរធ្វើដោយស្មើផង មិនស្គាល់កម្មផង មិនស្គាល់អធិករណ៍ផង មិនឈ្លាសក្នុងសមថៈផង ជាអ្នកត្រេកអរស៊ប់ជាដើមផង ជាអ្នកប្រទូស្តផង ជាអ្នកល្ងង់ផង លំអៀងព្រោះខ្លាចផង ព្រោះភ្លេចស្មារតីផង មិនឈ្លាសក្នុងការប្រកាស ឲ្យអ្នកដទៃយល់ព្រមផង មិនឈ្លាសក្នុងការពិចារណា នូវហេតុនិងមិនមែនហេតុផង តែងជាអ្នកបានបក្ខពួក (ស្មើនឹងខ្លួន) ជាអ្នកមិនមានសេចក្តីខ្មាស ប្រកបដោយកម្មខ្មៅ មិនអើពើ (ក្នុងធម៌និងបុគ្គល)

ចូឡសង្គាមំ សប្បដិក្ខោ

ស វេ(១) តាទិសោ ភិក្ខុ
អប្បដិក្ខោតិ វុច្ចតិ ។
វត្ថុំ វិបត្តឹ អាបត្តឹ
និទានំ អាការកោវិទោ
បុព្វាបរំ បជានាតិ
កតាកតំ សមេន ច
កម្មញ្ច អធិករណញ្ច
សមថេ ចាបិ កោវិទោ
អរត្តោ អទុដ្ឋោ អមូឡ្ហោ ច
ភយា មោហា ន គច្ឆតិ
សញ្ញត្តិយា ច កុសលោ
និជ្ឈត្តិយា ច កោវិទោ
លទ្ធបក្ខោ ហិរិមនោ
សុក្កកម្មោ សគារវោ
ស វេ តាទិសោ ភិក្ខុ
សប្បដិក្ខោតិ វុច្ចតីតិ ។

ចូឡសង្គាមំ និដ្ឋិតំ ។

---

១ ម. សបេ ។

ចូឡសង្គាម ភិក្ខុដែលបណ្ឌិតគប្បីរាប់រក

ភិក្ខុបែបនោះលោកហៅថាបុគ្គលដែលបណ្ឌិតលែងរាប់រក ។

ភិក្ខុណាស្គាល់វត្ថុ ស្គាល់វិបត្តិ ស្គាល់អាបត្តិ ស្គាល់និទាន ឈ្លាសក្នុងអាការ ដឹងច្បាស់នូវពាក្យខាងដើមនិងពាក្យខាងចុង ដឹងនូវកម្មដែលគួរធ្វើ និងមិនគួរធ្វើ ដោយស្មើ ដឹងកម្មផង ដឹងអធិករណ៍ផង ឈ្លាសក្នុងសមថៈផង មានចិត្តមិនបានត្រេកអរ មិនបានប្រទូស្ត មិនបានវង្វេង មិនលំអៀងព្រោះខ្លាច មិនលំអៀងព្រោះវង្វេងស្មារតី ឈ្លាសក្នុងការពន្យលឲ្យអ្នកដទៃយល់ ឈ្លាសក្នុងការពិចារណាមើលហេតុនិងមិនមែនហេតុ តែងជាអ្នកបានបក្ខពួក (ស្មើនិងខ្លួន) ជាអ្នកមានចិត្តខ្មាសបាប ប្រកបដោយកម្មស ប្រកបដោយសេចក្ដីគោរព ភិក្ខុបែបនោះឯង លោកហៅថាបុគ្គលដែលបណ្ឌិតគប្បីរាប់រក ។

ចប់ ចូឡសង្គាម ។

តស្សុទ្ទានំ

[១៦៩] នីចចិត្តេន បុច្ឆេយ្យ

គរុ សេវ្យ ន បុគ្គលេ

សុត្តំ សំសន្ទនត្ថាយ

វិនយាទុគ្គហេន ច

ឧទ្ទានំ ចូឡសង្គាមេ

ឯកុទ្ទេសំ ឥទំ កាតន្តិ ។

ឧទ្ទាន គឺបញ្ជីរឿងនៃចូឡសង្គ្រាមនោះ ដូច្នេះ

(១៦៩) និយាយអំពីភិក្ខុចូលទៅកាន់សង្គ្រាមត្រូវបន្ទាបបន្ទន់ចិត្ត ១ វិន័យធរដែលសង្ឃបានអនុញ្ញាតហើយ មិនត្រូវសួររកឧបជ្ឈាយ៍ជាដើម ១ វិន័យធរត្រូវមានចិត្តធ្ងន់ក្នុងសង្ឃ មិនត្រូវមានចិត្តធ្ងន់ក្នុងបុគ្គល ១ សុត្តៈប្រព្រឹត្តទៅដើម្បីប្រយោជន៍នឹងប្រៀបធៀបនូវអាបត្តិ នឹងអនាបត្តិជាដើម ១ ឧទ្ទានក្នុងចូឡសង្គ្រាមនេះ មានឧទ្ទេសតែមួយ លោកសំដែងទុកមកដោយសេចក្តីអនុគ្រោះដល់វិន័យ ។

មហាសង្គាមំ

(១៧០) សង្គាមាវចរេន ភិក្ខុនា សង្ឃេ វោហរន្តេន វត្ថុ ជានិតព្វំ វិបត្តិ ជានិតព្វា អាបត្តិ ជានិតព្វា និទានំ ជានិតព្វំ អាការោ ជានិតព្វោ បុព្វាបរំ ជានិតព្វំ កតាកតំ ជានិតព្វំ កម្មំ ជានិតព្វំ អធិករណំ ជានិតព្វំ សមថោ ជានិតព្វោ ន ឆន្ទាគតិ គន្តព្វា[១] ន ទោសាគតិ គន្តព្វា[២] ន មោហាគតិ គន្តព្វា[៣] ន ភយាគតិ គន្តព្វា[៤] សញ្ញាបនីយេ ឋានេ សញ្ញាបេតព្វំ និជ្ឈាបនីយេ ឋានេ និជ្ឈាបេតព្វំ បេក្ខនីយេ ឋានេ បេក្ខិតព្វំ បសាទនីយេ ឋានេ បសាទេតព្វំ លទ្ធបក្ខោម្ហីតិ បរេ បក្ខោ[៥] នាវជានិតព្វោ ពហុស្សុតោម្ហីតិ អប្បស្សុតោ នាវជានិតព្វោ ថេរតរោម្ហីតិ នវកតរោ នាវជានិតព្វោ អសម្បត្តំ ន ព្យាហារិតព្វំ សម្បត្តំ ធម្មតោ វិនយតោ ន បរិហាបេតព្វំ យេន ធម្មេន យេន វិនយេន យេន សត្ថុសាសនេន តំ អធិករណំ វូបសម្មតិ តថា តំ អធិករណំ វូបសមេតព្វំ ។

១-២-៣-៤ ម. ន ឆន្ទាគតឹ គន្តព្វំ ន ទោសាគតឹ គន្តព្វំ ន មោហាគតឹ គន្តព្វំ ន ភយាគតឹ គន្តព្វំ ។ ៥ ឱ. ម. បរបក្ខោ ។

មហាសង្គាម

(១៧០) ភិក្ខុអ្នកចូលទៅកាន់សង្គ្រាម កាលបើនិយាយ ក្នុងជំនុំសង្ឃ ត្រូវស្គាល់វត្ថុ ស្គាល់វិបត្តិ ស្គាល់អាបត្តិ ស្គាល់និទាន ស្គាល់អាការ ស្គាល់ពាក្យខាងដើមនឹងពាក្យខាងចុង ស្គាល់កម្មដែលគួរធ្វើនឹងមិនគួរធ្វើ ស្គាល់កម្ម ស្គាល់អធិករណ៍ ស្គាល់សមថៈ កុំលុះឆន្ទាគតិ កុំលុះទោសាគតិ កុំលុះមោហាគតិ កុំលុះភយាគតិ ត្រូវពន្យល់អ្នកដទៃឲ្យយល់ព្រមក្នុងទីដែលគួរឲ្យយល់ ត្រូវពិចារណាហេតុនិងមិនមែនហេតុ ក្នុងទីដែលគួរពិចារណា សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ត្រូវញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរឲ្យជ្រះថ្លា កុំគប្បីមើលងាយពួកជនដទៃដោយគិតថា អាត្មាអញបានបក្ខពួកហើយ កុំមើលងាយអ្នកចេះដឹងតិចដោយគិតថា អាត្មាអញជាអ្នកចេះដឹងច្រើន កុំមើលងាយភិក្ខុខ្ចីដោយគិតថា អាត្មាអញជាថេរៈចាស់ជាង កុំពោលនូវហេតុដែលមិនទាន់មកដល់ កុំញុំាងហេតុដែលមកដល់ហើយ ឲ្យវិនាស ចាកធម៌ ចាកវិន័យ អធិករណ៍ណារម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាណា គប្បីរម្ងាប់អធិករណ៍នោះ ដោយធម៌ជាដើមនោះៗ ចុះ ។

(១៧១) វត្ថុ ជានិតព្វន្តិ អដ្ឋបារាជិកានំ(១) វត្ថុ ជានិតព្វំ តេវីសសង្ឃាទិសេសានំ វត្ថុ ជានិតព្វំ ទ្វេអនិយតានំ វត្ថុ ជានិតព្វំ ទ្វេចត្តាឡីសនិស្សគ្គិយានំ(២) វត្ថុ ជានិតព្វំ អដ្ឋាសីតិសតបាចិត្តិយានំ(៣) វត្ថុ ជានិតព្វំ ទ្វាទសបាដិទេសនីយានំ វត្ថុ ជានិតព្វំ ទុក្កដានំ វត្ថុ ជានិតព្វំ ទុព្ភាសិតានំ វត្ថុ ជានិតព្វំ ។

(១៧២) វិបត្តិ ជានិតព្វាតិ សីលវិបត្តិ ជានិតព្វា អាចារវិបត្តិ ជានិតព្វា ទិដ្ឋិវិបត្តិ ជានិតព្វា អាជីវវិបត្តិ ជានិតព្វា ។

(១៧៣) អាបត្តិ ជានិតព្វាតិ បារាជិកាបត្តិ ជានិតព្វា សង្ឃាទិសេសាបត្តិ ជានិតព្វា ថុល្លច្ចយាបត្តិ ជានិតព្វា បាចិត្តិយាបត្តិ ជានិតព្វា បាដិទេសនីយាបត្តិ ជានិតព្វា ទុក្កដាបត្តិ ជានិតព្វា ទុព្ភាសិតាបត្តិ ជានិតព្វា ។

---

១ សព្វត្ថ អដ្ឋន្នំ បារាជិកានន្តិ ទិស្សតិ ។ ២ ឱ. ម. ទ្វេចត្តារីសនិស្សគ្គិយានំ ។ ៣ ម. អដ្ឋាសីតិសតំ បាចិត្តិយានំ ។

(១៧១) ពាក្យថា ត្រូវស្គាល់វត្ថុ គឺត្រូវស្គាល់វត្ថុនៃបារាជិក ៨ ស្គាល់វត្ថុនៃសង្ឃាទិសេស ២៣ ស្គាល់វត្ថុនៃអនិយតៈ ២ ស្គាល់វត្ថុនៃនិស្សគ្គិយៈ ៤២ ស្គាល់វត្ថុនៃបាចិត្តិយៈ ១៨៨ ស្គាល់វត្ថុនៃបាដិទេសនីយៈ ១២ ស្គាល់វត្ថុនៃទុក្កដទាំងឡាយ ស្គាល់វត្ថុនៃទុព្ភាសិតទាំងឡាយ ។

(១៧២) ពាក្យថា ត្រូវស្គាល់វិបត្តិ គឺត្រូវស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិ ស្គាល់អាជីវវិបត្តិ ។

(១៧៣) ពាក្យថា ត្រូវស្គាល់អាបត្តិ គឺត្រូវស្គាល់អាបត្តិបារាជិក ស្គាល់អាបត្តិសង្ឃាទិសេស ស្គាល់អាបត្តិថុល្លច្ច័យ ស្គាល់អាបត្តិបាចិត្តិយៈ ស្គាល់អាបត្តិបាដិទេសនីយៈ ស្គាល់អាបត្តិទុក្កដ ស្គាល់អាបត្តិទុព្ភាសិត

(១៧៤) និទានំ ជានិតព្វន្តិ អដ្ឋបារាជិកានំ និ-
ទានំ ជានិតព្វំ តេវីសសង្ឃាទិសេសានំ និទានំ ជានិតព្វំ
ទ្វេអនិយតានំ និទានំ ជានិតព្វំ ទ្វេចត្តាឡីសនិស្សគ្គិ-
យានំ និទានំ ជានិតព្វំ អដ្ឋាសីតិសតបាចិត្តិយានំ និ-
ទានំ ជានិតព្វំ ទ្វាទសបាដិទេសនីយានំ និទានំ ជានិ-
តព្វំ ទុក្កដានំ និទានំ ជានិតព្វំ ទុព្ភាសិតានំ និទានំ
ជានិតព្វំ ។

(១៧៥) អាការោ ជានិតព្វោតិ សង្ឃោ អាការ-
តោ ជានិតព្វោ គណោ អាការតោ ជានិតព្វោ បុគ្គលោ
អាការតោ ជានិតព្វោ ចោទកោ អាការតោ ជានិតព្វោ
ចុទិតកោ អាការតោ ជានិតព្វោ ។ សង្ឃោ អាកា-
រតោ ជានិតព្វោតិ បដិពលោ នុ ខោ អយំ សង្ឃោ
ឥមំ អធិករណំ វូបសមេតុំ ធម្មេន វិនយេន សត្ថុ-
សាសនេន ឧទាហុ នោតិ ឯវំ សង្ឃោ អាការតោ
ជានិតព្វោ ។ គណោ អាការតោ ជានិតព្វោតិ
បដិពលោ នុ ខោ អយំ គណោ ឥមំ អធិករណំ
វូបសមេតុំ ធម្មេន វិនយេន សត្ថុសាសនេន ឧទាហុ

(១៧៤) ពាក្យថា ត្រូវស្គាល់និទានៈ គឺត្រូវស្គាល់និទានរបស់បារាជិកទាំង ៨ ស្គាល់និទានរបស់សង្ឃាទិសេសទាំង ២៣ ស្គាល់និទានរបស់អនិយតៈទាំង ២ ស្គាល់និទានរបស់និស្សគ្គិយៈទាំង ៤២ ស្គាល់និទានរបស់បាចិត្តិយៈទាំង ១៨៨ ស្គាល់និទានរបស់បាដិទេសនីយៈទាំង ១២ ស្គាល់និទានរបស់ទុក្កដទាំងឡាយ ស្គាល់និទានរបស់ទុព្ភាសិតទាំងឡាយ ។

(១៧៥) ពាក្យថា ត្រូវស្គាល់អាការ គឺត្រូវស្គាល់សង្ឃដោយអាការ ស្គាល់គណៈដោយអាការ ស្គាល់បុគ្គលដោយអាការ ស្គាល់អ្នកចោទដោយអាការ ស្គាល់អ្នកជាប់ចោទដោយអាការ ។ ពាក្យថាត្រូវស្គាល់សង្ឃដោយអាការ គឺត្រូវស្គាល់សង្ឃដោយអាការយ៉ាងនេះថា សង្ឃនេះអាចនឹងរម្ងាប់អធិករណ៍នេះតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ឬមិនអាចរម្ងាប់បានទេ ។ ពាក្យថា ត្រូវស្គាល់គណៈដោយអាការ គឺស្គាល់គណៈដោយអាការយ៉ាងនេះថា គណៈនេះអាចនឹងរម្ងាប់អធិករណ៍នេះតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ឬ

នោតិ ឯវំ គណោ អាការតោ ជានិតព្វោ ។ បុគ្គលោ អាការតោ ជានិតព្វោតិ បឋមោ នុ ខោ អយំ បុគ្គលោ ឥមំ អធិករណំ វូបសមេតុំ ធម្មេន វិនយេន សត្ថុសាសនេន ឧទាហុ នោតិ ឯវំ បុគ្គលោ អាការតោ ជានិតព្វោ ។ ចោទកោ អាការតោ ជានិតព្វោតិ កច្ចិ នុ ខោ អយមាយស្មា បញ្ចសុ ធម្មេសុ បតិដ្ឋាយ បរំ ចោទេតិ ឧទាហុ នោតិ ឯវំ ចោទកោ អាការតោ ជានិតព្វោ ។ ចុទិតកោ អាការតោ ជានិតព្វោតិ កច្ចិ នុ ខោ អយមាយស្មា ទ្វីសុ ធម្មេសុ បតិដ្ឋិតោ សច្ចេ ច អកុប្បេ ច ឧទាហុ នោតិ ឯវំ ចុទិតកោ អាការតោ ជានិតព្វោ ។

(១៧៦) បុញ្ញាបរំ ជានិតព្វន្តិ កច្ចិ នុ ខោ អយមាយស្មា វត្ថុតោ វា វត្ថុំ សង្កមតិ វិបត្តិតោ វា វិបត្តឹ សង្កមតិ អាបត្តិតោ វា អាបត្តឹ សង្កមតិ អវជានិត្វា វា បដិជានាតិ បដិជានិត្វា វា អវជានាតិ អញ្ញេន វា អញ្ញំ បដិចរតិ ឧទាហុ នោតិ ឯវំ បុញ្ញាបរំ ជានិតព្វំ ។

មិនអាចរម្ងាប់បាន ។ ពាក្យថា ត្រូវស្គាល់បុគ្គលដោយអាការ គឺស្គាល់បុគ្គលដោយអាការយ៉ាងនេះថា បុគ្គលនេះអាចនឹងរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ឬមិនអាចរម្ងាប់បានទេ ។ ពាក្យថា ត្រូវស្គាល់អ្នកចោទដោយអាការ គឺស្គាល់អ្នកចោទដោយអាការយ៉ាងនេះថា លោកដ៏មានអាយុនេះ តាំងលំនៅក្នុងធម៌ទាំង ៥ ទើបចោទបុគ្គលដទៃ ឬមិនបានតាំងលំនៅទេ ។ ពាក្យថា ស្គាល់អ្នកជាប់ចោទ ដោយអាការ គឺស្គាល់អ្នកជាប់ចោទដោយអាការយ៉ាងនេះថា លោកដ៏មានអាយុនេះ តាំងលំនៅក្នុងធម៌ទាំងពីរ គឺ សច្ចវាចា ១ អកុប្បធម៌ ១ ឬមិនបានតាំងលំនៅទេ ។

(១៧៦) ពាក្យថា ត្រូវស្គាល់ពាក្យខាងដើមនិងពាក្យខាងចុង គឺត្រូវស្គាល់ពាក្យខាងដើមនិងពាក្យខាងចុងយ៉ាងនេះថា លោកដ៏មានអាយុនេះកន្លងនូវវត្ថុដោយវត្ថុផង កន្លងនូវវិបត្តិដោយវិបត្តិផង កន្លងនូវអាបត្តិដោយអាបត្តិផង គេបកែហើយប្តេជ្ញាផង ប្តេជ្ញាហើយគេបកែផង បំពាននូវពាក្យដទៃ ដោយពាក្យដទៃផង ឬមិនបានកន្លងគេបកែបំពានទេ ។

(១៧៧) កតាកតំ ជានិតព្វន្តិ មេថុនធម្មោ ជានិតព្វោ មេថុនធម្មស្ស អនុលោមំ ជានិតព្វំ មេថុនធម្មស្ស បុព្វភាគោ ជានិតព្វោ ។ មេថុនធម្មោ ជានិតព្វោតិ ទ្វយំទ្វយសមាបត្តិ[១] ជានិតព្វា ។ មេថុនធម្មស្ស អនុលោម ជានិតព្វន្តិ ភិក្ខុ អត្តនោ មុខេន បរស្ស អង្គជាតំ គណ្ហាតិ ។ មេថុនធម្មស្ស បុព្វភាគោ ជានិតព្វោតិ វណ្ណោ អវណ្ណោ[២] កាយសំសគ្គោ ទុដ្ឋុល្លវាចា អត្តកាមបារិចរិយា វណ្ណមនុប្បទានំ[៣] ។

(១៧៨) កម្មំ ជានិតព្វន្តិ សោឡស កម្មានិ ជានិតព្វានិ ចត្តារិ អបលោកនកម្មានិ ជានិតព្វានិ ចត្តារិ ញត្តិកម្មានិ ជានិតព្វានិ ចត្តារិ ញត្តិទុតិយកម្មានិ ជានិតព្វានិ ចត្តារិ ញត្តិចតុត្ថកម្មានិ ជានិតព្វានិ ។

---

១ ឱ. ម. ទ្វយំទ្វយសមាបត្តិ ។ ២ ឱ. វណ្ណាវណ្ណោ ។ ម. វណ្ណាវណ្ណា ។ ៣ ឱ. ធនមនុប្បទានំ ។ ម. វចនមនុប្បទានំ ។

[១៧៧] ពាក្យថា ត្រូវស្គាល់កម្មដែលគួរធ្វើនិងមិនគួរធ្វើ គឺត្រូវស្គាល់មេថុនធម្ម ស្គាល់អនុលោមរបស់មេថុនធម្ម ស្គាល់បុព្វភាគ (ចំណែកខាងដើម) របស់មេថុនធម្ម ។ ពាក្យថា ត្រូវស្គាល់មេថុនធម្ម គឺត្រូវស្គាល់ការជួបប្រសព្វរបស់ជនពីរ ៗ នាក់ ។ ពាក្យថា ត្រូវស្គាល់អនុលោមរបស់មេថុនធម្ម គឺបានដល់កិច្ចបៀមអង្គជាតរបស់អ្នកដទៃដោយមាត់របស់ខ្លួន ។ ពាក្យថា ត្រូវស្គាល់បុព្វភាគរបស់មេថុនធម្ម គឺស្គាល់ទឹកសុក្កៈមានពណ៌ និងមិនមានពណ៌ ការចាប់ពាល់កាយស្ត្រី និយាយពាក្យអាក្រក់ចំពោះទ្វារមគ្គស្ត្រី និយាយល្បួងស្ត្រី ឲ្យបម្រើខ្លួនដោយកាម និយាយដឹកនាំបុរសនិងស្ត្រីឲ្យបានគ្នាជាប្តីប្រពន្ធ (សិក្ខាបទទាំង ៩ នេះជាបុព្វភាគរបស់មេថុនធម្ម) ។

[១៧៨] ពាក្យថា ត្រូវស្គាល់កម្ម គឺត្រូវស្គាល់កម្ម ១៦ យ៉ាង គឺ ស្គាល់អបលោកនកម្ម ៤ ស្គាល់ញត្តិកម្ម ៤ ស្គាល់ញត្តិទុតិយកម្ម ៤ ស្គាល់ញត្តិចតុត្ថកម្ម ៤ ។

(១៧៩) អធិករណំ ជានិតព្វន្តិ ចត្តារិ អធិករណានិ ជានិតព្វានិ វិវាទាធិករណំ ជានិតព្វំ អនុវាទាធិករណំ ជានិតព្វំ អាបត្តាធិករណំ ជានិតព្វំ កិច្ចាធិករណំ ជានិតព្វំ ។

(១៨០) សមថោ ជានិតព្វោតិ សត្ត សមថា ជានិតព្វា សម្មុខាវិនយោ ជានិតព្វោ សតិវិនយោ ជានិតព្វោ អមូឡ្ហវិនយោ ជានិតព្វោ បដិញ្ញាតករណំ ជានិតព្វំ យេភុយ្យសិកា ជានិតព្វា តស្សបាបិយសិកា ជានិតព្វា តិណវត្ថារកោ ជានិតព្វោ ។

(១៨១) ន ឆន្ទាគតិ គន្តព្វាតិ[១] ឆន្ទាគតឹ គច្ឆន្តោ កថំ ឆន្ទាគតឹ គច្ឆតិ ។ ឥធេកច្ចោ អយំ មេ ឧបជ្ឈាយោ វា អាចរិយោ វា សទ្ធិវិហារិកោ វា អន្តេវាសិកោ វា សមានុបជ្ឈាយកោ វា សមានាចរិយកោ វា សន្ទិដ្ឋោ វា សម្ភត្តោ វា ញាតិសាលោហិតោ វាតិ តស្សានុកម្បាយ តស្សានុរក្ខាយ អធម្មំ ធម្មោតិ ទីបេតិ

១ ម. ន ឆន្ទាគតឹ គន្តព្វន្តិ ។

(១៧៩) ពាក្យថា ត្រូវស្គាល់អធិករណ៍ គឺត្រូវស្គាល់អធិករណ៍ទាំង ៤ យ៉ាង គឺស្គាល់វិវាទាធិករណ៍ ១ ស្គាល់អនុវាទាធិករណ៍ ១ ស្គាល់អាបត្តាធិករណ៍ ១ ស្គាល់កិច្ចាធិករណ៍ ១ ។

(១៨០) ពាក្យថា ត្រូវស្គាល់សមថៈ គឺត្រូវស្គាល់សមថៈ ៧ យ៉ាង គឺស្គាល់សម្មុខាវិន័យ ១ ស្គាល់សតិវិន័យ ១ ស្គាល់អមូឡ្ហវិន័យ ១ ស្គាល់បដិញ្ញាតករណៈ ១ ស្គាល់យេភុយ្យសិកា ១ ស្គាល់តស្សបាបិយសិកា ១ ស្គាល់តិណវត្ថារកៈ ១ ។

(១៨១) ពាក្យថា កុំលុះឆន្ទាគតិ សេចក្តីថា ភិក្ខុដែលលុះឆន្ទាគតិ តើលុះឆន្ទាគតិដូចម្តេច ។ ភិក្ខុជាវិន័យធរពួកខ្លះ ក្នុងសាសនានេះ យោគយល់ថា បុគ្គលនេះជាឧបជ្ឈាយ៍ ឬអាចារ្យ ជាសទ្ធិវិហារិក ឬអន្តេវាសិក ជាភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នា ឬភិក្ខុដែលមានអាចារ្យស្មើគ្នា ជាមិត្តធ្លាប់ឃើញគ្នាមក ៗ ឬជាមិត្តធ្លាប់ស្និទ្ធស្នាលគ្នាមាំ ពួកនោះជាញាតិសាលោហិតរបស់អាត្មាអញ ដូច្នេះហើយក៏សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌

ធម្មំ អធម្មោតិ ទីបេតិ អធម្មំ ធម្មោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេតិ ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេតិ អនាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេតិ អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេតិ អប្បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេតិ បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេតិ អនាបត្តិំ អាបត្តីតិ ទីបេតិ អាបត្តិំ អនាបត្តីតិ ទីបេតិ លហុកំ អាបត្តិំ គរុកា អាបត្តីតិ ទីបេតិ គរុកំ អាបត្តិំ លហុកា អាបត្តីតិ ទីបេតិ សាវសេសំ អាបត្តិំ អនវសេសា អាបត្តីតិ ទីបេតិ អនវសេសំ អាបត្តិំ សាវសេសា អាបត្តីតិ ទីបេតិ ទុដ្ឋុល្លំ អាបត្តិំ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ អទុដ្ឋុល្លំ អាបត្តិំ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ ឥមេហិ អដ្ឋារសហិ វត្ថូហិ ជញ្ញាតិ គច្ឆេ

មហាសង្គាម ការសំដែងនូវធម៌ថាមិនមែនធម៌ជាដើម

សំដែងនូវធម៌ ថាមិនមែនជាធម៌ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ សំដែងនូវវិន័យ ថាមិនមែនជាវិន័យ សំដែងនូវពាក្យដែលព្រះតថាគតមិនបានសំដែងមិនបានពោល ថាជាពាក្យដែលព្រះតថាគតបានសំដែងបានពោល សំដែងនូវពាក្យដែលព្រះតថាគត បានសំដែងបានពោល ថាជាពាក្យដែលព្រះតថាគត មិនបានសំដែងមិនបានពោល សំដែងនូវកិច្ចវត្តដែលព្រះតថាគតមិនបានសន្សំមក ថាព្រះតថាគតធ្លាប់សន្សំមក សំដែងនូវកិច្ចវត្តដែលព្រះតថាគតធ្លាប់សន្សំមក ថាព្រះតថាគតមិនបានសន្សំមក សំដែងនូវសិក្ខាបទដែលព្រះតថាគតមិនបានបញ្ញត្ត ថាព្រះតថាគតបានបញ្ញត្ត សំដែងនូវសិក្ខាបទដែលព្រះតថាគតបានបញ្ញត្ត ថាព្រះតថាគតមិនបានបញ្ញត្ត សំដែងនូវអនាបត្តិ ថាជាអាបត្តិ សំដែងនូវអាបត្តិ ថាជាអនាបត្តិ សំដែងនូវលហុកាបត្តិ ថាជាគរុកាបត្តិ សំដែងនូវគរុកាបត្តិ ថាជាលហុកាបត្តិ សំដែងនូវសាវសេសាបត្តិ ថាជាអនវសេសាបត្តិ សំដែងនូវអនវសេសាបត្តិ ថាជាសាវសេសាបត្តិ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ដូច្នេះព្រោះអនុគ្រោះដល់បុគ្គលនោះ ៗ ព្រោះកិរិយាក្យាដល់បុគ្គលនោះ ៗ ភិក្ខុជាវិន័យធរ កាលដែលលុះឆន្ទាគតិដោយវត្ថុទាំងឡាយ ១៨ ប្រការនេះ

ពហុជនាហិតាយ បដិបន្នោ ហោតិ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ឥមេហិ អដ្ឋារសហិ វត្ថូហិ ឆន្ទាគតឹ គច្ឆន្តោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ ច[1] វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ឆន្ទាគតឹ គច្ឆន្តោ ឯវំ ឆន្ទាគតឹ គច្ឆតិ ។

(១៨២) ន ទោសាគតិ គន្តព្វាតិ ទោសាគតឹ គច្ឆន្តោ កថំ ទោសាគតឹ គច្ឆតិ ។ ឥធេកច្ចោ អនត្ថំ មេ អចរីតិ អាឃាតំ ពន្ធតិ អនត្ថំ មេ ចរតីតិ អាឃាតំ ពន្ធតិ អនត្ថំ មេ ចរិស្សតីតិ អាឃាតំ ពន្ធតិ បិយស្ស មេ មនាបស្ស អនត្ថំ អចរិ អនត្ថំ ចរតិ អនត្ថំ ចរិស្សតីតិ

---

១ ឱ. ម. បោត្ថកេសុ ចសទ្ទោ ន ទិស្សតិ ។

ក៏ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនជាសុខដល់ជនច្រើនគ្នា ដើម្បីមិនមែនជាសេចក្ដីចំរើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ ដល់ទេវតានឹងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរ កាលបើលុះឆន្ទាគតិដោយវត្ថុទាំង ១៨ ប្រការនេះ ក៏ឈ្មោះថារក្សាខ្លួន ដែលមានកុសលធម៌ជីកគាស់រំលើងចោលចេញផង ឈ្មោះថាជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្ដីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថារង៍នូវអកុសលកម្មដ៏ច្រើនផង ភិក្ខុជាវិន័យធរ កាលបើលុះឆន្ទាគតិ ក៏រមែងលុះទៅខាងឆន្ទាគតិ ដោយអាការយ៉ាងនេះ ។

(១៨២) ពាក្យថា កុំលុះទោសាគតិ សេចក្ដីថា កាលដែលភិក្ខុជាវិន័យធរ លុះទោសាគតិ តើលុះទោសាគតិដូចម្ដេច ។ ភិក្ខុជាវិន័យធរពួកខ្លះក្នុងសាសនានេះ ចងគំនុំថា (បុគ្គលនេះ) បានប្រព្រឹត្តធ្វើនូវសេចក្ដីវិនាសដល់អាត្មាអញ ចងគំនុំថា (បុគ្គលនេះ) កំពុងតែប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍ដល់អាត្មាអញ ចងគំនុំថា (បុគ្គលនេះ) មុខជានឹងប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍ដល់អាត្មាអញ ចងគំនុំថា (បុគ្គលនេះ) បានប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍ កំពុងប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍ មុខជានឹងប្រព្រឹត្តធ្វើនូវកម្ម មិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់

អាឃាតំ ពន្ធតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរិ អត្ថំ ចរតិ អត្ថំ ចរិស្សតីតិ អាឃាតំ ពន្ធតិ ឥមេហិ នវហិ អាឃាតវត្ថូហិ អាឃាតោ បដិឃាតោ កុទ្ធោ កោធជាតិ-កោ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ អទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ ឥមេហិ អដ្ឋារសហិ វត្ថូហិ ទោសាគតឹ គច្ឆន្តោ ពហុជនាហិតាយ បដិបន្នោ ហោតិ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ឥមេហិ អដ្ឋារសហិ វត្ថូហិ ទោសាគតឹ គច្ឆន្តោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ ច វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ទោសាគតឹ គច្ឆន្តោ ឯវំ ទោសាគតឹ គច្ឆតិ ។

ជាទីគាប់ចិត្តរបស់អាត្មាអញ បងំគំនុំថា (បុគ្គលនេះ)បានប្រព្រឹត្តធ្វើនូវកម្មជាប្រយោជន៍ កំពុងប្រព្រឹត្តធ្វើនូវកម្មជាប្រយោជន៍ មុខជានឹងប្រព្រឹត្តធ្វើនូវកម្មជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ភិក្ខុជាវិន័យធរកាលបើបងំគំនុំខឹង មានសេចក្ដីក្រេវក្រោធគ្របសង្កត់ដោយអាឃាតវត្ថុទាំង៩ប្រការនេះហើយ រមែងសម្ដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌ ។ល។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុជាវិន័យធរ កាលបើលុះទោសាគតិដោយវត្ថុទាំង ១៨ ប្រការនេះ ក៏ឈ្មោះថាប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនមែនជាសុខដល់ជនច្រើនគ្នា ដើម្បីសេចក្ដីមិនចំរើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរកាលបើលុះទៅខាងទោសាគតិដោយវត្ថុទាំង ១៨ ប្រការនេះ ក៏ឈ្មោះថារក្សាខ្លួន ដែលខ្លួនមានកុសលធម៌ជីកគាស់រំលើងចោលហើយផង ឈ្មោះថាជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្ដីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថារងនូវអកុសលកម្មច្រើនផង ភិក្ខុជាវិន័យធរកាលបើលុះទៅខាងទោសាគតិ ក៏រមែងលុះទៅខាងទោសាគតិ ដោយអាការយ៉ាងនេះ ។

(១៨៣) ៖ មោហាគតិ គន្តព្វាតិ មោហាគតឹ គច្ឆន្តោ កថំ មោហាគតឹ គច្ឆតិ ។ រត្តោ រាគវសេន គច្ឆតិ ទុដ្ឋោ ទោសវសេន គច្ឆតិ មូឡ្ហោ មោហវសេន គច្ឆតិ បរាមដ្ឋោ ទិដ្ឋិវសេន គច្ឆតិ មូឡ្ហោ សម្មូឡ្ហោ មោហាភិភូតោ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ អទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ ឥមេហិ អដ្ឋារសហិ វត្ថូហិ មោហាគតឹ គច្ឆន្តោ ពហុជនាហិតាយ បដិបន្នោ ហោតិ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ឥមេហិ អដ្ឋារសហិ វត្ថូហិ មោហាគតឹ គច្ឆន្តោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ ច

វិនយបិដក បរិវារៈ

(១៨៣) ពាក្យថា កុំគប្បីលំអៀងដោយមោហាគតិ សេចក្តីថា ភិក្ខុជាវិន័យធរ កាលដែលលំអៀងដោយមោហាគតិ តើលំអៀងដោយមោហាគតិដូចម្តេច ។ ភិក្ខុជាវិន័យធរមានចិត្តត្រេកអរ លុះដោយអំណាចរាគៈ មានចិត្តប្រទូស្តលុះដោយអំណាចទោសៈ មានសេចក្តីវង្វេងលុះដោយអំណាចមោហៈ មានទិដ្ឋិជាគ្រឿងស្ទាបអង្អែល លុះដោយអំណាចទិដ្ឋិ វង្វេងកាន់កាំងស្មារតី ត្រូវមោហៈគ្របសង្កត់ ក៏សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌ ។ បេ ។ សំដែងទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ កាលបើភិក្ខុជាវិន័យធរលំអៀងដោយមោហាគតិ ដោយវត្ថុ ១៨ ប្រការនេះ ក៏ឈ្មោះថាប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនមែនជាសុខដល់ជនច្រើនគ្នា ដើម្បីសេចក្តីមិនចំរើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរកាលបើលំអៀងដោយមោហាគតិដោយវត្ថុទាំង ១៨ ប្រការនេះ ក៏ឈ្មោះថារក្សាខ្លួន ដែលខ្លួនមានកុសលធម៌ជីករំលើងចោលហើយផង ឈ្មោះថាជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់

វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ មោហាគតឹ គច្ឆន្តោ ឯវំ មោហាគតឹ គច្ឆតិ ។

[១៨៤] ៖ ភយាគតិ គន្តព្វាតិ ភយាគតឹ គច្ឆន្តោ កថំ ភយាគតឹ គច្ឆតិ ។ ឥធេកច្ចោ អយំ វិសមនិស្សិតោ ច គហននិស្សិតោ ច ពលវនិស្សិតោ ច កក្ខឡោ ផរុសោ ជីវិតន្តរាយំ វា ព្រហ្មចរិយន្តរាយំ វា ករិស្សតីតិ តស្ស ភយា ភីតោ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ អទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ ឥមេហិ អដ្ឋារសហិ វត្ថូហិ ភយាគតឹ គច្ឆន្តោ ពហុជនាហិតាយ បដិបន្នោ ហោតិ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ឥមេហិ អដ្ឋារសហិ វត្ថូហិ ភយាគតឹ គច្ឆន្តោ

អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថារេងនូវអកុសលកម្មដ៏ច្រើនផង ភិក្ខុជាវិនយធរ កាលលំអៀងដោយមោហាគតិ រមែងលំអៀងដោយមោហាគតិ ដោយអាការយ៉ាងនេះ ។

(១៨៤) ពាក្យថា កុំលំអៀងដោយភយាគតិ សេចក្ដីថា ភិក្ខុដែលលំអៀងដោយភយាគតិ តើលំអៀងដោយភយាគតិដូចម្ដេច ។ ភិក្ខុជាវិនយធរពួកខ្លះ ក្នុងសាសនានេះគិតថាបុគ្គលនេះ អាស្រ័យនូវកម្មមានកាយកម្មជាដើមមិនស្មើក្ដី អាស្រ័យនូវព្រៃស្បាតគីមិច្ឆាទិដ្ឋិនិងអន្តគ្គាហិកទិដ្ឋិក្ដី អាស្រ័យនូវភិក្ខុមានកំឡាំងក្ដី ជាអ្នករឹងរូសអាក្រក់ នឹងធ្វើនូវសេចក្ដីអន្តរាយដល់ជីវិតក្ដី នូវសេចក្ដីអន្តរាយដល់ព្រហ្មចរិយៈក្ដី ហើយតក់ស្លុត ព្រោះខ្លាចបុគ្គលនោះ ក៏សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌ ។ បេ ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ កាលបើភិក្ខុជាវិនយធរលំអៀងដោយភយាគតិ ដោយវត្ថុទាំង ១៨ ប្រការនេះ ក៏ឈ្មោះថាប្រតិបត្តិ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនជាសុខដល់ជនច្រើនគ្នា ដើម្បីសេចក្ដីមិនចំរើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ភិក្ខុជាវិនយធរ កាលបើលំអៀងដោយភយាគតិដោយវត្ថុទាំង ១៨ ប្រការនេះ ក៏ឈ្មោះថា

ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ ច វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ភយាគតឹ គច្ឆន្តោ ឯវំ ភយាគតឹ គច្ឆតិ ។

(១៨៥) ឆន្ទា ទោសា ភយា មោហា

យោ ធម្មំ អតិវត្តតិ

និហីយតិ តស្ស យសោ

កាឡបក្ខេវ ចន្ទិមាតិ ។

(១៨៦) កថំ ន ឆន្ទាគតឹ គច្ឆតិ ។ អធម្មំ អធម្មោតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ ធម្មំ ធម្មោតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ អវិនយំ អវិនយោតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ វិនយំ វិនយោតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ អភាសិតំ អលបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ ភាសិតំ

រក្សានូវខ្លួនដែលមានកុសលធម៌ជីកគាស់រលើងចោលហើយផង ឈ្មោះថាជាបុគ្គលប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថាផ្សំនូវអកុសលកម្មច្រើនផង ភិក្ខុជាវិន័យ-ធរ កាលដែលលំអៀងដោយភយាគតិ រមែងលំអៀងដោយភយាគតិ ដោយអាការយ៉ាងនេះ ។

[១៨៥] បុគ្គលណាប្រព្រឹត្តកន្លងនូវធម៌ ព្រោះសេចក្តីស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាច ព្រោះវង្វេង យសសក្តិរបស់បុគ្គលនោះឯង រមែងសាបសូន្យទៅ ដូចព្រះចន្ទក្នុងកាឡប័ក្ខ គឺខាងរនោច ។

(១៨៦) ភិក្ខុជាវិន័យធរមិនលំអៀងដោយឆន្ទាគតិតើដូចម្តេច ។ ភិក្ខុជាវិន័យធរកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវសភាវៈមិនមែនវិន័យ ថាមិនមែនវិន័យ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវវិន័យ ថាជាវិន័យ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវពាក្យដែលព្រះតថាគតមិនបានសំដែង មិនបានពោល ថាជាពាក្យដែលព្រះតថាគតមិនបានសំដែង មិនបានពោល ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ

មហាសង្គាមំ ឆន្ទាគតិអគមធំ

លបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ អនាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ អាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ អបញ្ញត្តំ តថាគតេន អបញ្ញត្តំ តថាគតេនាតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ អនាបត្តឹ អនាបត្តីតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ អាបត្តឹ អាបត្តីតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ លហុកំ អាបត្តឹ លហុកា អាបត្តីតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ គរុកំ អាបត្តឹ គរុកា អាបត្តីតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ សាវសេសំ អាបត្តឹ សាវសេសា អាបត្តីតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ អនវសេសំ អាបត្តឹ អនវសេសា អាបត្តីតិ ទីបេន្តោ ន ឆន្ទាគតឹ គច្ឆតិ ទុដ្ឋុល្លំ អាបត្តឹ

មហាសង្គាម សេចក្តីមិនលំអៀងដោយឆន្ទាគតិ

កាលសំដែងនូវពាក្យដែលព្រះតថាគតបានសំដែង បានពោល ថាជាពាក្យដែលព្រះតថាគតបានសំដែង បានពោល ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវកិច្ចវត្តដែលព្រះតថាគតមិនបានសន្សំមក ថាជាកិច្ចវត្តដែលព្រះតថាគតមិនបានសន្សំមក ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវកិច្ចវត្តដែលព្រះតថាគតបានសន្សំមក ថាជាកិច្ចវត្តដែលព្រះតថាគតបានសន្សំមក ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវសិក្ខាបទដែលព្រះតថាគត មិនបានបញ្ញត្ត ថា ព្រះតថាគតមិនបានបញ្ញត្ត ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវសិក្ខាបទដែលព្រះតថាគតទ្រង់បញ្ញត្ត ថាព្រះតថាគតទ្រង់បញ្ញត្ត ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវអនាបត្តិ ថាជាអនាបត្តិ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវអាបត្តិ ថាជាអាបត្តិ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវលហុកាបត្តិ ថាជាលហុកាបត្តិ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវគរុកាបត្តិ ថាជាគរុកាបត្តិ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវសាវសេសាបត្តិ ថាជាសាវសេសាបត្តិ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវអនវសេសាបត្តិ ថាជាអនវសេសាបត្តិ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ

ទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ ច ឆន្ទាគតិំ គច្ឆតិ អទុដ្ឋុល្លំ អាបត្តិំ អទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ ច ឆន្ទាគតិំ គច្ឆតិ ឯវំ ច ឆន្ទាគតិំ គច្ឆតិ ។

(១៨៧) កថំ ច ទោសាគតិំ គច្ឆតិ អធម្មំ អធម្មោតិ ទីបេន្តោ ច ទោសាគតិំ គច្ឆតិ ធម្មំ ធម្មោតិ ទីបេន្តោ ច ទោសាគតិំ គច្ឆតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តិំ ទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ ច ទោសាគតិំ គច្ឆតិ អទុដ្ឋុល្លំ អាបត្តិំ អទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ ច ទោសាគតិំ គច្ឆតិ ឯវំ ច ទោសាគតិំ គច្ឆតិ ។

(១៨៨) កថំ ច មោហាគតិំ គច្ឆតិ ។ អធម្មំ អធម្មោតិ ទីបេន្តោ ច មោហាគតិំ គច្ឆតិ ធម្មំ ធម្មោតិ ទីបេន្តោ ច មោហាគតិំ គច្ឆតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តិំ ទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ ច មោហាគតិំ គច្ឆតិ អទុដ្ឋុល្លំ អាបត្តិំ អទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ ច មោហាគតិំ គច្ឆតិ ឯវំ ច មោហាគតិំ គច្ឆតិ ។

ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថាមិនលំអៀងដោយឆន្ទាគតិ ភិក្ខុមិនលំអៀងដោយឆន្ទាគតិ ដោយអាការយ៉ាងនេះ ។

(១៨៧) ភិក្ខុជាវិន័យធរមិនលំអៀងដោយទោសាគតិ តើដូចម្តេច ។ ភិក្ខុកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថាមិនលំអៀងដោយទោសាគតិ កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថាមិនលំអៀងដោយទោសាគតិ ។ បេ ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថាមិនលំអៀងដោយទោសាគតិ កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថាមិនលំអៀងដោយទោសាគតិ ភិក្ខុមិនលំអៀងដោយទោសាគតិ ដោយអាការយ៉ាងនេះ ។

(១៨៨) ភិក្ខុជាវិន័យធរមិនលំអៀងដោយមោហាគតិតើដូចម្តេច ។ ភិក្ខុកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថាមិនលំអៀងដោយមោហាគតិ សំដែងនូវធម៌ ថាជាធម៌ ឈ្មោះថាមិនលំអៀងដោយមោហាគតិ ។ បេ ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថាមិនលំអៀងដោយមោហាគតិ កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថាមិនលំអៀងដោយមោហាគតិ ភិក្ខុមិនលំអៀងដោយមោហាគតិ ដោយអាការយ៉ាងនេះ ។

មហាសង្គាមំ ភយាគតិអគមនាទយោ

(១៨៩) កថំ ន ភយាគតឹ គច្ឆតិ ។ អធម្មំ អធម្មោតិ ទីបេន្តោ ន ភយាគតឹ គច្ឆតិ ធម្មំ ធម្មោតិ ទីបេន្តោ ន ភយាគតឹ គច្ឆតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ ន ភយាគតឹ គច្ឆតិ អទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ ន ភយាគតឹ គច្ឆតិ ឯវំ ន ភយាគតឹ គច្ឆតិ ។

(១៩០) ឆន្ទា ទោសា ភយា មោហា
យោ ធម្មំ នាតិវត្តតិ
អាបូរតិ តស្ស យសោ
សុក្កបក្ខេវ ចន្ទិមា ។

(១៩១) កថំ សញ្ញាបនីយេ ឋានេ សញ្ញាបេតិ ។ អធម្មំ អធម្មោតិ ទីបេន្តោ សញ្ញាបនីយេ ឋានេ សញ្ញាបេតិ ធម្មំ ធម្មោតិ ទីបេន្តោ សញ្ញាបនីយេ ឋានេ សញ្ញាបេតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ សញ្ញាបនីយេ ឋានេ សញ្ញាបេតិ

(១៨៩) ភិក្ខុជាវិន័យធរមិនលំអៀងដោយភយាគតិតើដូចម្តេច ។ ភិក្ខុកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថាមិនលំអៀងដោយភយាគតិ កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថាមិនលំអៀងដោយភយាគតិ ។បេ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថាមិនលំអៀងដោយភយាគតិ កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថាមិនលំអៀងដោយភយាគតិ ភិក្ខុមិនលំអៀងដោយភយាគតិ ដោយអាការយ៉ាងនេះ ។

(១៩០) បុគ្គលណា មិនប្រព្រឹត្តកន្លងនូវធម៌ ព្រោះសេចក្តីស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាច ព្រោះវង្វេង យសសក្តិ
របស់បុគ្គលនោះឯង រមែងពេញបរិបូណ៌ ដូចព្រះចន្ទក្នុង
សុក្កបក្ខ គឺបំណកខាងខ្នើត ។

(១៩១) សួរថា ភិក្ខុជាវិន័យធរពន្យល់ក្នុងទីដែលគួរពន្យល់នោះ តើដូចម្តេច ។ ឆ្លើយថា ភិក្ខុជាវិន័យធរ កាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថាពន្យល់ក្នុងទីដែលគួរពន្យល់ កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថាពន្យល់ក្នុងទីដែលគួរពន្យល់ ។បេ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថាពន្យល់ក្នុងទីដែលគួរពន្យល់

អទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ សញ្ញាបនីយេ ឋានេ សញ្ញាបេតិ ឯវំ សញ្ញាបនីយេ ឋានេ សញ្ញាបេតិ ។

(១៩២) កថំ និជ្ឈាបនីយេ ឋានេ និជ្ឈាបេតិ ។ អធម្មំ អធម្មោតិ ទីបេន្តោ និជ្ឈាបនីយេ ឋានេ និជ្ឈាបេតិ ធម្មំ ធម្មោតិ ទីបេន្តោ និជ្ឈាបនីយេ ឋានេ និជ្ឈាបេតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ និជ្ឈាបនីយេ ឋានេ និជ្ឈាបេតិ អទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ និជ្ឈាបនីយេ ឋានេ និជ្ឈាបេតិ ឯវំ និជ្ឈាបនីយេ ឋានេ និជ្ឈាបេតិ ។

(១៩៣) កថំ បេក្ខនីយេ ឋានេ បេក្ខតិ ។ អធម្មំ អធម្មោតិ ទីបេន្តោ បេក្ខនីយេ ឋានេ បេក្ខតិ ធម្មំ ធម្មោតិ ទីបេន្តោ បេក្ខនីយេ ឋានេ បេក្ខតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេន្តោ បេក្ខនីយេ ឋានេ បេក្ខតិ អទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ

កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថាពន្យល់ក្នុងទីដែលគួរពន្យល់ ភិក្ខុជាវិន័យធរពន្យល់ក្នុងទីដែលគួរពន្យល់ ដោយអាការយ៉ាងនេះ ។

(១៩២) សួរថា ភិក្ខុជាវិន័យធរពិចារណាក្នុងទីដែលគួរពិចារណា តើដូចម្តេច ។ ឆ្លើយថា ភិក្ខុជាវិន័យធរកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថាពិចារណាក្នុងទីដែលគួរពិចារណា កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថាពិចារណាក្នុងទីដែលគួរពិចារណា ។ បេ ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថាពិចារណា ក្នុងទីដែលគួរពិចារណា កាលសំដែងនូវអទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថាពិចារណា ក្នុងទីដែលគួរពិចារណា ភិក្ខុពិចារណាក្នុងទីដែលគួរពិចារណា ដោយអាការយ៉ាងនេះ ។

(១៩៣) សួរថា ភិក្ខុសំឡឹងមើលក្នុងទីគួរសំឡឹង តើដូចម្តេច ។ ឆ្លើយថា ភិក្ខុកាលសំដែងឡើងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថាសំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថាសំឡឹងមើល ក្នុងទីដែលគួរសំឡឹងមើល ។ បេ ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថាសំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា

ទីបេត្វា បេក្ខនីយេ ឋានេ បេក្ខតិ ឯវំ បេក្ខនីយេ ឋានេ បេក្ខតិ ។

(១៩៦) កថំ បសាទនីយេ ឋានេ បសាទេតិ ។ អធម្មំ អធម្មោតិ ទីបេត្វា បសាទនីយេ ឋានេ បសាទេតិ ធម្មំ ធម្មោតិ ទីបេត្វា បសាទនីយេ ឋានេ បសាទេតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លាបត្តីតិ ទីបេត្វា បសាទនីយេ ឋានេ បសាទេតិ អទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លាបត្តីតិ ទីបេត្វា បសាទនីយេ ឋានេ បសា-ទេតិ ឯវំ បសាទនីយេ ឋានេ បសាទេតិ ។

(១៩៨) កថំ សង្ឃបក្ខម្ហីតិ បរំ បក្ខំ[១] អវជានា-តិ ។ ឥធេកច្ចោ សង្ឃបក្ខោ ហោតិ សង្ឃបរិភាគោ បក្ខភ ញ្ញាតិកោ អយំ អសង្ឃបក្ខោ អសង្ឃបរិភាគោ ន បក្ខភ ន ញ្ញាតិកោតិ តស្ស អវជានន្តោ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា

---

១ ឱ. ម. បរបក្ខំ ។

សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ភិក្ខុសំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ដោយអាការយ៉ាងនេះ ។

(១៩៨) សួរថា ភិក្ខុញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា តើដូចម្តេច ។ ឆ្លើយថា ភិក្ខុកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថាញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថាញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា ។ បេ ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថាញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថាញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា ភិក្ខុញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា ដោយអាការយ៉ាងនេះ ។

(១៩៩) សួរថា ភិក្ខុមើលងាយនូវពួកភិក្ខុដទៃដោយគិតថា អាត្មាអញបានបក្ខពួកហើយ តើដូចម្តេច ។ ឆ្លើយថា ភិក្ខុពួកមួយក្នុងសាសនានេះ ជាអ្នកបានបក្ខពួក បានបរិវារ មានបក្ខពួក មានញាតិ ហើយមើលងាយបុគ្គលនោះថា បុគ្គលនេះមិនបានបក្ខពួក មិនបានបរិវារ គ្មានបក្ខពួក គ្មានញាតិទេ ក៏សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌ ។ បេ ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ

អាបត្តីតិ ទីបេតិ អទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ ឯវំ លទ្ធបក្ខោម្ហីតិ បរំ បក្ខំ អវជានាតិ ។

(១៩៦) កថំ ពហុស្សុតោម្ហីតិ អប្បស្សុតំ អវជានាតិ ។ ឥធេកច្ចោ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ អយំ អប្បស្សុតោ អប្បាគមោ អប្បធរោតិ តស្ស អវជានន្តោ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ អទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ ឯវំ ពហុស្សុតោម្ហីតិ អប្បស្សុតំ អវជានាតិ ។

(១៩៧) កថំ ថេរតរោម្ហីតិ នវកតរំ អវជានាតិ ។ ឥធេកច្ចោ ថេរោ ហោតិ រត្តញ្ញូ ចិរបព្វជិតោ អយំ នវកោ អប្បញ្ញាតោ អប្បស្សុតោ អប្បកតញ្ញូ ឥមស្ស វចនំ អកតំ ករិស្សតីតិ តស្ស អវជានន្តោ

សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុមើលងាយនូវបក្ខពួកដទៃ ដោយគិតថា អាត្មាអញបានបក្ខពួក ដោយអាការយ៉ាងនេះ ។

[១៩៦] សួរថា ភិក្ខុមើលងាយនូវបុគ្គលដែលចេះដឹងតិច ដោយគិតថា អាត្មាអញជាអ្នកចេះដឹងច្រើន តើដូចម្ដេច ។ ឆ្លើយថា ភិក្ខុពួកមួយក្នុងសាសនានេះ ជាអ្នកចេះដឹងច្រើន ចាំនូវសុតៈ សន្សំនូវសុតៈ រមែងមើលងាយបុគ្គលអ្នកចេះដឹងតិចនោះថា បុគ្គលនេះស្ដាប់តិច ជាអ្នកចេះដឹងនិកាយតិច ចាំតិច គឺសំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌ ។ បេ ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លា-បត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុមើលងាយនូវបុគ្គលដែលចេះដឹងតិច ដោយគិតថា អាត្មាអញជាអ្នកចេះដឹងច្រើន ដោយអាការយ៉ាងនេះ ។

[១៩] សួរថា ភិក្ខុមើលងាយភិក្ខុដែលខ្ចីជាង ដោយគិតថា អាត្មាអញជាថេរៈចាស់ជាង តើដូចម្ដេច ។ ឆ្លើយថា ភិក្ខុពួកមួយក្នុងសាសនានេះ ជាថេរៈ ជាអ្នកដឹងរាត្រី (វស្ស) បួសមកជាយូរហើយ រមែងមើលងាយភិក្ខុខ្ចីនោះថា ភិក្ខុនេះនៅខ្ចីមិនសូវល្បីល្បាញ ជាអ្នកចេះដឹងតិច មិនចេះច្បាប់ទម្លាប់ អាត្មាអញនឹងមិនធ្វើតាមពាក្យរបស់ភិក្ខុនេះទេ ដូច្នេះក៏

អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ អទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ ឃរំ ថេរតេហម្ហិតិ នេវកា-តំ អវជានាតិ ។

(១៩៨) អសម្បត្តំ ន ព្យាហរិតព្វន្តិ អនោតិណ្ណំ ភាសំ(១) ន ឱតារេតព្វំ ។ សម្បត្តំ ធម្មតោ វិនយតោ ន បរិហាបេតព្វន្តិ យំ អត្ថាយ សង្ឃោ សន្និបតិតោ ហោតិ តំ អត្ថំ ធម្មតោ វិនយតោ ន បរិហាបេតព្វំ ។

(១៩៩) យេន ធម្មេនាតិ ភូតេន វត្ថុនា ។ យេន វិនយេនាតិ ចោទេត្វា សារេត្វា ។ យេន សត្ថុសាសនេនាតិ ញត្តិសម្បទាយ អនុស្សាវនសម្បទាយ ។ យេន ធម្មេន យេន វិនយេន យេន សត្ថុសាសនេន តំ អធិករណំ វូបសម្មតិ តថា តំ អធិករណំ វូបសមេតព្វន្តិ អនុវិជ្ជកេន ចោទកោ បុច្ឆិតព្វោ យំ ខោ ត្វំ អាវុសោ ឥមស្ស ភិក្ខុនោ បវារណំ ឋបេសិ កិម្ហិ នំ

---

១ ឱ. ម. ភារំ ។

សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌ ។ បេ ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុមើលងាយភិក្ខុខ្ចីជាន់ដោយគិតថា អាត្មាអញជាថេរៈចាស់ជាន់ ដោយអាការយ៉ាងនេះ ។

(១៩៨) ពាក្យថា កុំពោលនូវហេតុដែលមិនទាន់មកដល់ គឺកុំនិយាយនូវពាក្យដែលមិនទាន់ធ្លាក់ដល់មក ។ ពាក្យថា កុំគប្បីញុំាងហេតុដែលដល់មកហើយឲ្យសាបសូន្យចាកធម៌ ចាកវិន័យ គឺបានដល់សង្ឃដែលប្រជុំគ្នាដើម្បីសេចក្តីណា កុំគប្បីញុំាងសេចក្តីនោះឲ្យសាបសូន្យចាកធម៌ ចាកវិន័យឡើយ ។

(១៩៩) ពាក្យថា ដោយធម៌ណា គឺដោយវត្ថុដែលពិតប្រាកដ ។ ពាក្យថា ដោយវិន័យណា គឺដះតៀនក្រើនរំលឹក ។ ពាក្យថា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាណា គឺដោយញត្តិសម្បទានិងអនុស្សាវនសម្បទា ។ ពាក្យថា អធិករណ៍រម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាណា គប្បីរម្ងាប់អធិករណ៍នោះ ដោយធម៌នោះៗ សេចក្តីថា វិន័យធរគប្បីសួរអ្នកចោទថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនោះ ដោយហេតុណា

ឋបេសិ សីលវិបត្តិយា ឋបេសិ អាចារវិបត្តិយា ឋបេ-
សិ ទិដ្ឋិវិបត្តិយា ឋបេសីតិ ។ សោ ចេ ឯវំ វទេយ្យ
សីលវិបត្តិយា វា ឋបេមិ អាចារវិបត្តិយា វា ឋបេមិ
ទិដ្ឋិវិបត្តិយា វា ឋបេមីតិ ។ សោ ឯវមស្ស វចនីយោ ជា-
នាសិ បនាយស្មា សីលវិបត្តឹ ជានាសិ អាចារវិបត្តឹ ជា-
នាសិ ទិដ្ឋិវិបត្តិន្តិ ។ សោ ចេ ឯវំ វទេយ្យ ជានាមិ ខោ
អហំ អាវុសោ សីលវិបត្តឹ ជានាមិ អាចារវិបត្តឹ ជានាមិ
ទិដ្ឋិវិបត្តិន្តិ ។ សោ ឯវមស្ស វចនីយោ កតមា បនា-
វុសោ សីលវិបត្តិ កតមា អាចារវិបត្តិ កតមា ទិដ្ឋិ-
វិបត្តីតិ ។ សោ ចេ ឯវំ វទេយ្យ ចត្តារិ បារាជិកានិ
តេរស សង្ឃាទិសេសា អយំ សីលវិបត្តិ ថុល្លច្ចយំ
បាចិត្តិយំ បាដិទេសនីយំ ទុក្កដំ ទុព្ភាសិតំ អយំ
អាចារវិបត្តិ មិច្ឆាទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ អយំ ទិដ្ឋិវិ-
បត្តីតិ ។ សោ ឯវមស្ស វចនីយោ យំ ត្វំ អាវុសោ
ឥមស្ស ភិក្ខុនោ បវារណំ ឋបេសិ ទិដ្ឋេន ឋបេសិ
សុតេន ឋបេសិ បរិសង្កាយ ឋបេសីតិ ។ សោ ចេ
ឯវំ វទេយ្យ ទិដ្ឋេន វា ឋបេមិ សុតេន វា ឋបេមិ

លោកឃាត់បវារណានោះដោយហេតុអ្វី លោកឃាត់ដោយសីលវិបត្តិ ឬឃាត់ដោយអាចារវិបត្តិ ឬក៏ឃាត់ដោយទិដ្ឋិវិបត្តិ ។ បើអ្នកចោទនោះនិយាយយ៉ាងនេះថា ខ្ញុំឃាត់ដោយសីលវិបត្តិផង ឃាត់ដោយអាចារវិបត្តិផង ឃាត់ដោយទិដ្ឋិវិបត្តិផង ។ វិន័យធរត្រូវនិយាយនឹងភិក្ខុអ្នកចោទនោះយ៉ាងនេះថា ចុះលោកដ៏មានអាយុស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរឬ ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរ ។ វិន័យធរត្រូវសួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ ចុះសីលវិបត្តិដូចម្តេច អាចារវិបត្តិដូចម្តេច ទិដ្ឋិវិបត្តិដូចម្តេច ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា បារាជិក ៤ សង្ឃាទិសេស ១៣ នេះហៅថាសីលវិបត្តិ ថុល្លច្ច័យ បាចិត្តិយៈ បាដិទេសនីយៈ ទុក្កដ ទុព្ភាសិត នេះហៅថាអាចារវិបត្តិ មិច្ឆាទិដ្ឋិ និងអន្តគ្គាហិកាទិដ្ឋិ នេះហៅថា ទិដ្ឋិវិបត្តិ ។ វិន័យធរត្រូវសួរភិក្ខុអ្នកចោទយ៉ាងនេះថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនេះ ដោយហេតុណា លោកឃាត់ដោយបានឃើញ ឬឃាត់ដោយបានឮ ឬក៏ឃាត់ដោយបានរង្កៀស ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ខ្ញុំឃាត់ដោយបានឃើញផង ឃាត់ដោយបានឮផង

បរិសង្កាយ វា ឋបេមីតិ ។ សោ ឯវមស្ស វចនីយោ យំ ខោ ត្វំ អាវុសោ ឥមស្ស ភិក្ខុនោ ទិដ្ឋេន បារាជិកំ ឋបេសិ កិន្តេ ទិដ្ឋំ កិន្តិ តេ ទិដ្ឋំ កទា តេ ទិដ្ឋំ កត្ថ តេ ទិដ្ឋំ បារាជិកំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ សង្ឃាទិសេសំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ថុល្លច្ចយំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ បាចិត្តិយំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ បាដិទេសនីយំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ទុក្កដំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ទុព្ភាសិតំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ កត្ថ ច ត្វំ អហោសិ កត្ថ ចាយំ ភិក្ខុ អហោសិ កិញ្ច(១) ត្វំ ករោសិ កិញ្ចាយំ ភិក្ខុ ករោតីតិ ។ សោ ចេ ឯវំ វទេយ្យ ន ខោ អហំ អាវុសោ ឥមស្ស ភិក្ខុនោ ទិដ្ឋេន បារាជិកំ ឋបេមិ អបិច សុតេន បារាជិកំ ឋបេមីតិ ។ សោ ឯវមស្ស វចនីយោ យំ ខោ ត្វំ អាវុសោ ឥមស្ស ភិក្ខុនោ សុតេន បារាជិកំ ឋបេសិ កិន្តេ សុតំ កិន្តិ តេ សុតំ កទា តេ សុតំ កត្ថ តេ សុតំ បារាជិកំ អជ្ឈាបន្នោតិ សុតំ សង្ឃាទិសេសំ អជ្ឈាបន្នោតិ សុតំ ថុល្លច្ចយំ អជ្ឈាបន្នោតិ សុតំ បាចិត្តិយំ

---

១ ម. កិញ្ចិ ។

ឃាត់ដោយបានរង្កៀសផង ។ វិន័យធរត្រូវសួរភិក្ខុអ្នកចោទយ៉ាងនេះថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនេះដោយបានឃើញ ដោយហេតុណា លោកបានឃើញដូចម្តេចខ្លះ លោកបានឃើញអំពីហេតុដូចម្តេច លោកបានឃើញពីកាលណា លោកបានឃើញក្នុងទីណា កាលភិក្ខុនេះត្រូវអាបត្តិបារាជិក លោកបានឃើញដែរឬ កាលត្រូវសង្ឃាទិសេស លោកបានឃើញដែរឬ កាលត្រូវថុល្លច្ច័យ លោកបានឃើញដែរឬ កាលត្រូវបាចិត្តិយៈ លោកបានឃើញដែរឬ កាលត្រូវបាដិទេសនីយៈ លោកបានឃើញដែរឬ កាលត្រូវទុក្កដ លោកបានឃើញដែរឬ កាលត្រូវទុព្ភាសិត លោកបានឃើញដែរឬ ចុះលោកនៅក្នុងទីណា ចំណែកភិក្ខុនេះនៅត្រង់ទីណា លោកកំពុងធ្វើអ្វី ភិក្ខុនេះកំពុងធ្វើអ្វី ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនបានឃាត់បវារណារបស់ភិក្ខុនេះ ដោយបានឃើញទេ ខ្ញុំឃាត់បវារណាដោយគ្រាន់តែបានឮទេ ។ វិន័យធរត្រូវសួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ អ្នកឃាត់បវារណារបស់ភិក្ខុនេះ ដោយបានឮដោយហេតុណា លោកបានឮដូចម្តេចខ្លះ លោកបានឮដោយហេតុដូចម្តេច លោកបានឮពីកាលណា លោកបានឮក្នុងទីណា លោកបានឮថាភិក្ខុនេះត្រូវបារាជិក ,ឬលោកបានឮថាភិក្ខុនេះត្រូវសង្ឃាទិសេស លោកបានឮថាភិក្ខុនេះត្រូវថុល្លច្ច័យ

អជ្ឈាបន្នោតិ សុតំ បាដិទេសនីយំ អជ្ឈាបន្នោតិ សុតំ ទុក្កដំ អជ្ឈាបន្នោតិ សុតំ ទុព្ភាសិតំ អជ្ឈាបន្នោតិ សុតំ ភិក្ខុស្ស សុតំ ភិក្ខុនិយា សុតំ សិក្ខមានាយ សុតំ សាមណេរស្ស សុតំ សាមណេរិយា សុតំ ឧបាសកស្ស សុតំ ឧបាសិកាយ សុតំ រាជូនំ សុតំ រាជមហាមត្តានំ សុតំ តិត្ថិយានំ សុតំ តិត្ថិយសាវកានំ សុតន្តិ ។ សោ ចេ ឯវំ វទេយ្យ ន ខោ អហំ អាវុសោ ឥមស្ស ភិក្ខុនោ សុតេន បករណំ ឋបេមិ អបិច បរិសង្កាយ បករណំ ឋបេមីតិ ។ សោ ឯវមស្ស វចនីយោ យំ ខោ ត្វំ អាវុសោ ឥមស្ស ភិក្ខុនោ បរិសង្កាយ បករណំ ឋបេសិ កឹ បរិសង្កសិ កិន្តិ បរិសង្កសិ កាន បរិសង្កសិ កត្ថ បរិសង្កសិ បារាជិកំ អជ្ឈាបន្នោតិ បរិសង្កសិ សង្ឃាទិសេសំ អជ្ឈាបន្នោតិ បរិសង្កសិ ថុល្លច្ចយំ អជ្ឈាបន្នោតិ បរិសង្កសិ បាចិត្តិយ អជ្ឈាបន្នោតិ បរិសង្កសិ បាដិទេសនីយំ អជ្ឈាបន្នោតិ បរិសង្កសិ

លោកបានឮថា ភិក្ខុនេះត្រូវបាចិត្តិយៈ លោកបានឮថា ភិក្ខុនេះត្រូវបាដិទេសនីយៈ លោកបានឮថា ភិក្ខុនេះត្រូវទុក្កដ លោកបានឮថា ភិក្ខុនេះត្រូវទុព្ភាសិត លោកបានឮពាក្យភិក្ខុ លោកបានឮពាក្យភិក្ខុនី លោកបានឮពាក្យសិក្ខមានា លោកបានឮពាក្យសាមណេរ លោកបានឮពាក្យសាមណេរី លោកបានឮពាក្យឧបាសក លោកបានឮពាក្យឧបាសិកា លោកបានឮព្រះបន្ទូលនៃពួកស្តេច លោកបានឮពាក្យនៃពួករាជមហាមាត្រ លោកបានឮពាក្យនៃពួកតិរ្ថិយ ឬបានឮពាក្យនៃពួកសាវ័ករបស់តិរ្ថិយ ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនបានឃាត់បវារណារបស់ភិក្ខុនេះ ដោយបានឮទេ ខ្ញុំឃាត់បវារណាដោយគ្រាន់តែរង្កៀសទេ ។ វិន័យធរត្រូវសួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនេះ ដោយរង្កៀសដោយហេតុណា លោករង្កៀសដោយហេតុដូចម្តេចខ្លះ លោករង្កៀសអំពីហេតុដូចម្តេច លោករង្កៀសពីកាលណា លោករង្កៀសក្នុងទីណា លោករង្កៀសថា ភិក្ខុនេះត្រូវបារាជិក ឬលោករង្កៀសថា ភិក្ខុនេះត្រូវសង្ឃាទិសេស លោករង្កៀសថា ភិក្ខុនេះត្រូវថុល្លច្ច័យ លោករង្កៀសថា ភិក្ខុនេះត្រូវបាចិត្តិយៈ លោករង្កៀសថា ភិក្ខុនេះត្រូវបាដិទេសនីយៈ លោករង្កៀសថា ភិក្ខុនេះ

ទុក្កដំ អជ្ឈាបន្នោតិ បរិសុទ្ធោសិ ទុព្ភាសិតំ អជ្ឈាបន្នោតិ បរិសុទ្ធោសិ ភិក្ខុស្ស សុត្វា បរិសុទ្ធោសិ ភិក្ខុនិយា សុត្វា បរិសុទ្ធោសិ សិក្ខមានាយ សុត្វា បរិសុទ្ធោសិ សាមណេរស្ស សុត្វា បរិសុទ្ធោសិ សាមណេរិយា សុត្វា បរិសុទ្ធោសិ ឧបាសកស្ស សុត្វា បរិសុទ្ធោសិ ឧបាសិកា-យ សុត្វា បរិសុទ្ធោសិ រាជូនំ សុត្វា បរិសុទ្ធោសិ រាជម-ហាមត្តានំ សុត្វា បរិសុទ្ធោសិ តិត្ថិយានំ សុត្វា បរិសុទ្ធោសិ តិត្ថិយសាវកានំ សុត្វា បរិសុទ្ធោសីតិ ។

(២០០) ទិដ្ឋំ ទិដ្ឋេន សមេតិ
ទិដ្ឋេន សំសន្ទតេ ទិដ្ឋំ
ទិដ្ឋំ បដិច្ច ន ឧបេតិ
អសុទ្ធបរិសង្កិតោ
សោ បុគ្គលោ បដិញ្ញាយ
កាតព្វា[1] តេន បវារណា

---

១ ម. ការេតព្វោ ។

ត្រូវទុក្កដ លោករង្កៀសថា ភិក្ខុនេះត្រូវទុព្ភាសិត លោករង្កៀសព្រោះពាក្យភិក្ខុ លោករង្កៀសព្រោះពាក្យភិក្ខុនី លោករង្កៀសព្រោះពាក្យសិក្ខមានា លោករង្កៀសព្រោះពាក្យសាមណេរ លោករង្កៀសព្រោះពាក្យសាមណេរី លោករង្កៀសព្រោះពាក្យឧបាសក លោករង្កៀសព្រោះពាក្យឧបាសិកា លោករង្កៀសព្រោះព្រះបន្ទូលនៃពួកស្តេច លោករង្កៀសព្រោះពាក្យនៃពួកមហាមាត្ររបស់ស្តេច លោករង្កៀសព្រោះពាក្យនៃពួកតិរ្ថិយ ឬលោករង្កៀសព្រោះពាក្យពួកសាវ័កនៃតិរ្ថិយ ។

[៤០០] ហេតុដែលអ្នកចោទបានឃើញ សមដោយហេតុដែលបានឃើញមែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានឃើញ ដោយហេតុដែលបានឃើញ (នោះ) ភិក្ខុអ្នកជាប់ចោទមិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យនូវហេតុដែលអ្នកចោទបានឃើញនៅឡើយទេ ឈ្មោះថាអ្នកចោទមានសេចក្តីរង្កៀសមិនបរិសុទ្ធ (រង្កៀសគ្មានមូល) វិន័យធរគប្បីវិនិច្ឆ័យតាមពាក្យប្តឹងរបស់បុគ្គល គឺភិក្ខុជាអ្នកជាប់ចោទនោះ ហើយធ្វើបវារណាជាមួយនឹងភិក្ខុនោះចុះ ។

សុតំ សុតេន សមេតិ
សុតេន សំសន្ទតេ សុតំ
សុតំ បដិច្ច ន ឧបេតិ
អសុទ្ធបរិសង្កិតោ
សោ បុគ្គលោ បដិញ្ញាយ
កាតព្វា(១) តេន បវារណា ។
មុតំ មុតេន សមេតិ
មុតេន សំសន្ទតេ មុតំ
មុតំ បដិច្ច ន ឧបេតិ
អសុទ្ធបរិសង្កិតោ
សោ បុគ្គលោ បដិញ្ញាយ
កាតព្វា(២) តេន បវារណាតិ

១-២ ម. កាតព្វោ ។

ហេតុដែលអ្នកចោទបានឮ សមដោយហេតុដែលបានឮមែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានឮ ដោយហេតុដែលបានឮ (នោះ) ភិក្ខុអ្នកជាប់ចោទនោះ មិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យនូវហេតុដែលអ្នកចោទបានឮទៅឡើយទេ ឈ្មោះថាអ្នកចោទមានសេចក្តីជ្រៀសមិនបរិសុទ្ធ វិន័យធរគប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញារបស់បុគ្គល គឺភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើបវារណា ជាមួយនឹងភិក្ខុនោះចុះ ។ ហេតុដែលអ្នកចោទបានប៉ះពាល់ សមដោយហេតុដែលបានប៉ះពាល់មែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានប៉ះពាល់ ដោយហេតុដែលបានប៉ះពាល់ (នោះ) ភិក្ខុអ្នកជាប់ចោទនោះមិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យនូវហេតុដែលអ្នកចោទបានប៉ះពាល់ទៅឡើយទេ ឈ្មោះថាអ្នកចោទមានសេចក្តីជ្រៀសមិនបរិសុទ្ធ វិន័យធរគប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញារបស់បុគ្គលគឺភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើបវារណា ជាមួយនឹងភិក្ខុនោះចុះ ។

[២០១] កិន្តេ ទិដ្ឋន្តិ កតមា បុច្ឆា កិន្តិ តេ ទិដ្ឋន្តិ កតមា បុច្ឆា កទា តេ ទិដ្ឋន្តិ កតមា បុច្ឆា កត្ថ តេ ទិដ្ឋន្តិ កតមា បុច្ឆា ។

[២០២] កិន្តេ ទិដ្ឋន្តិ វត្ថុបុច្ឆា វិបត្តិបុច្ឆា អាបត្តិបុច្ឆា អជ្ឈាចារបុច្ឆា ។ វត្ថុបុច្ឆាតិ អដ្ឋបារាជិកានំ(១) វត្ថុបុច្ឆា តេរសសង្ឃាទិសេសានំ វត្ថុបុច្ឆា ទ្វេអនិយតានំ វត្ថុបុច្ឆា ទ្វេចត្តាឡីសនិស្សគ្គិយានំ វត្ថុបុច្ឆា អដ្ឋាសីតិសតបាចិត្តិយានំ វត្ថុបុច្ឆា ទ្វាទសបាដិទេសនីយានំ វត្ថុបុច្ឆា ទុក្កដានំ វត្ថុបុច្ឆា ទុព្ភាសិតានំ វត្ថុបុច្ឆា ។ វិបត្តិបុច្ឆាតិ សីលវិបត្តិបុច្ឆា អាចារវិបត្តិបុច្ឆា ទិដ្ឋិវិបត្តិបុច្ឆា អាជីវវិបត្តិបុច្ឆា ។ អាបត្តិបុច្ឆាតិ បារាជិកាបត្តិបុច្ឆា សង្ឃាទិសេសាបត្តិបុច្ឆា ថុល្លច្ចយាបត្តិបុច្ឆា បាចិត្តិយាបត្តិបុច្ឆា បាដិទេសនីយាបត្តិបុច្ឆា ទុក្កដាបត្តិបុច្ឆា ទុព្ភាសិតាបត្តិបុច្ឆា ។ អជ្ឈាចារបុច្ឆាតិ ទ្វយទ្វយសមាបត្តិបុច្ឆា ។

---

១ សព្វត្ថ អដ្ឋន្នំ បារាជិកានន្តិ ទិស្សតិ ។

[២០១] ត្រង់ពាក្យថា អ្នកបានឃើញដូចម្តេច គឺបានដល់ពាក្យសួរថាដូចម្តេច ត្រង់ពាក្យថា អ្នកបានឃើញអំពីហេតុដូចម្តេច គឺបានដល់ពាក្យសួរថាដូចម្តេច ត្រង់ពាក្យថា អ្នកបានឃើញពីកាលណា គឺបានដល់ពាក្យសួរថាដូចម្តេច ត្រង់ពាក្យថា អ្នកបានឃើញក្នុងទីណា គឺបានដល់ពាក្យសួរថាដូចម្តេច ៗ

[២០២] ត្រង់ពាក្យដែលថាបានឃើញដូចម្តេច គឺបានដល់វត្ថុបុច្ឆា ១ វិបត្តិបុច្ឆា ១ អាបត្តិបុច្ឆា ១ អជ្ឈាចារបុច្ឆា ១ ៗ ត្រង់ពាក្យថាវត្ថុបុច្ឆា គឺបានដល់ពាក្យសួរអំពីវត្ថុនៃបារាជិក ៨ សួរវត្ថុនៃសង្ឃាទិសេស ២៣ សួរវត្ថុនៃអនិយត ២ សួរវត្ថុនៃនិស្សគ្គិយៈ ៤២ សួរវត្ថុនៃបាចិត្តិយៈ ១៨៨ សួរវត្ថុនៃបាដិទេសនីយៈ ១២ សួរវត្ថុនៃទុក្កដទាំងឡាយ សួរវត្ថុនៃទុព្ភាសិតទាំងឡាយ ៗ ត្រង់ពាក្យថា វិបត្តិបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីសីលវិបត្តិ សួរអំពីអាចារវិបត្តិ សួរអំពីទិដ្ឋិវិបត្តិ សួរអំពីអាជីវវិបត្តិ ៗ ត្រង់ពាក្យថា អាបត្តិបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីអាបត្តិបារាជិក សួរអំពីអាបត្តិសង្ឃាទិសេស សួរអំពីអាបត្តិថុល្លច្ច័យ សួរអំពីអាបត្តិបាចិត្តិយៈ សួរអំពីអាបត្តិបាដិទេសនីយៈ សួរអំពីអាបត្តិទុក្កដ សួរអំពីអាបត្តិទុព្ភាសិត ៗ ត្រង់ពាក្យថា អជ្ឈាចារបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីការប្រសព្វរបស់ជនពីរ ៗ នាក់ ៗ

(២០៣) កតិ តេ ទិដ្ឋិ វត្ថុបុច្ឆា ឥរិយាបថបុច្ឆា អាការបុច្ឆា វិប្បការបុច្ឆា ។ វត្ថុបុច្ឆាតិ ទីឃំ វា រស្សំ វា កណ្ហំ វា ឱទាតំ វា ។ ឥរិយាបថបុច្ឆាតិ គច្ឆន្តំ វា ឋិតំ វា និសិន្នំ វា និបន្នំ វា ។ អាការបុច្ឆាតិ គិហិលិង្គេ វា តិត្ថិយលិង្គេ វា បព្វជិតលិង្គេ វា ។ វិប្បការបុច្ឆាតិ គច្ឆន្តំ វា ឋិតំ វា និសិន្នំ វា និបន្នំ វា ។

(២០៤) កតា តេ ទិដ្ឋិ កាលបុច្ឆា សមយបុច្ឆា ទិវសបុច្ឆា ឧតុបុច្ឆា ។ កាលបុច្ឆាតិ បុព្វណ្ហកាលេ វា មជ្ឈន្តិកកាលេ វា សាយណ្ហកាលេ វា ។ សមយបុច្ឆាតិ បុព្វណ្ហសមយេ វា មជ្ឈន្តិកសមយេ វា សាយណ្ហសមយេ វា ។ ទិវសបុច្ឆាតិ បុរេភត្តំ វា បច្ឆាភត្តំ វា រត្តិំ វា ទិវា វា កាឡេ វា ជុណ្ហេ វា ។ ឧតុបុច្ឆាតិ ហេមន្តេ វា គិម្ហេ វា វស្សេ វា ។

(៤០៣) ត្រង់ពាក្យថា លោកបានឃើញអំពីហេតុដូចម្តេច គឺបានដល់លិង្គបុច្ឆា ១ ឥរិយាបថបុច្ឆា ១ អាការបុច្ឆា ១ វិប្បការបុច្ឆា ១ ។ ត្រង់ពាក្យថា លិង្គបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភេទខ្ពស់ ឬទាប ខ្មៅ ឬស ។ ត្រង់ពាក្យថា ឥរិយាបថបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីបុគ្គលដើរ ឬឈរ អង្គុយ ឬដេក ។ ត្រង់ពាក្យថា អាការបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភេទគ្រហស្ថ ឬភេទតិត្ថិយ ឬភេទបព្វជិត ។ ត្រង់ពាក្យថា វិប្បការបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីបុគ្គលកំពុងដើរ ឬឈរ កំពុងអង្គុយ ឬដេក ។

(៤០៤) ត្រង់ពាក្យថា លោកបានឃើញពីកាលណា គឺបានដល់កាលបុច្ឆា ១ សមយបុច្ឆា ១ ទិវសបុច្ឆា ១ ឧតុបុច្ឆា ១ ។ ត្រង់ពាក្យថា កាលបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីពេលព្រឹក ឬពេលថ្ងៃត្រង់ ឬថ្ងៃរសៀល ។ ត្រង់ពាក្យថា សមយបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីសម័យព្រឹក ឬសម័យថ្ងៃត្រង់ ឬក៏សម័យថ្ងៃរសៀល ។ ត្រង់ពាក្យថា ទិវសបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីវេលាមុនភត្ត វេលាក្រោយភត្ត វេលាយប់ វេលាថ្ងៃ ខាងរនោច ឬខ្នើត ។ ត្រង់ពាក្យថា ឧតុបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីហេមន្តរដូវ គិម្ហរដូវ ឬវស្សានរដូវ ។

[២០៥] កត្ថ តេ ទិដ្ឋន្តិ ឋានបុច្ឆា ភូមិបុច្ឆា ឱកាសបុច្ឆា បទេសបុច្ឆា ។ ឋានបុច្ឆាតិ ភូមិយោ វា បថវិយោ វា ធរណិយោ វា ជគតិយោ វា ។ ភូមិបុច្ឆាតិ ភូមិយោ វា បព្វតេ វា បាសាណេ វា បាសាទេ វា ។ ឱកាសបុច្ឆាតិ បុរត្ថិមេ វា ឱកាសេ បច្ឆិមេ វា ឱកាសេ ឧត្តរេ វា ឱកាសេ ទក្ខិណេ វា ឱកាសេ ។ បទេសបុច្ឆាតិ បុរត្ថិមេ វា បទេសេ បច្ឆិមេ វា បទេសេ ឧត្តរេ វា បទេសេ ទក្ខិណេ វា បទេសេតិ ។

មហាសង្គាមំ និដ្ឋិតំ ។

តស្សុទ្ទានំ

[២០៦] វត្ថុ និទានំ អាការោ
បុព្វាបរំ កតាកតំ
កម្មាធិករណញ្ចេវ
សមថា ឆន្ទគាមិ ច
ទោសា មោហា ភយា ចេវ

[២០៥] ត្រង់ពាក្យថា លោកបានឃើញក្នុងទីណា គឺបានដល់ ឋានបុច្ឆា ១ ភូមិបុច្ឆា ១ ឱកាសបុច្ឆា ១ បទេសបុច្ឆា ១ ។ ត្រង់ពាក្យថា ឋានបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភូមិ ប្រថពី ធរណី ឬផែនដី ។ ត្រង់ពាក្យថា ភូមិបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភូមិ ភ្នំ ថ្ម ឬប្រាសាទ ។ ត្រង់ពាក្យថា ឱកាសបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីឱកាសខាងកើត ឱកាសខាងលិច ឱកាសខាងជើង ឱកាសខាងត្បូង ។ ត្រង់ពាក្យថា បទេសបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីប្រទេសខាងកើត ឬប្រទេសខាងលិច ប្រទេសខាងជើង ឬប្រទេសខាងត្បូង ។

ចប់ មហាសង្គាម ។

ឧទ្ទានគឺបញ្ជីរឿងនៃមហាសង្គាមនោះ ដូច្នេះ

[២០៦] និយាយអំពីកិច្ចត្រូវស្គាល់វត្ថុ ១ ស្គាល់និទាន ១ ស្គាល់អាការ ១ ស្គាល់ពាក្យខាងដើមនិងពាក្យខាងចុង ១ ស្គាល់កម្មដែលគួរធ្វើ និងមិនគួរធ្វើ ១ ស្គាល់កម្ម ១ ស្គាល់អធិករណ៍ ១ ស្គាល់សមថៈ ១ មិនលំអៀងទៅខាងឆន្ទាគតិ ១ ទោសាគតិ ១ មោហាគតិ ១ ភយាគតិ ១

សញ្ញា និជ្ឈាបនេន ច

បេក្ខា បសាទេ បក្ខាម្ហិ

សុតថេរតរេន ច

អសម្បត្តញ្ច សម្បត្តំ

ធម្មេន វិនយេន ច

សត្ថុស្ស សាសនោបិ

មហាសង្គាមញ្ញាបជាតិ ។

ពន្យល់បុគ្គលដទៃឲ្យយល់ក្នុងទីដែលគួរពន្យល់ ១ ពិចារ-ណាក្នុងទីដែលគួរពិចារណា ១ សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ១ ញុំាងបរិសទ្យឲ្យជ្រះថ្លាក្នុងទីគួរជ្រះថ្លា ១ មើលងាយពួកដទៃដោយគិតថា អាត្មាអញបានបក្ខពួក ១ អាត្មាអញជាអ្នកចេះដឹងច្រើន ១ អាត្មាអញជាថេរៈ ១ ពោលហេតុដែលមិនទាន់មកដល់ ១ កុំញុំាងហេតុដែលមកដល់ហើយឲ្យសាបសូន្យ ១ រម្ងាប់អធិករណ៍ដោយធម៌ ដោយវិន័យ ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ១ ក្នុងមហា-សង្គាម បណ្ឌិតគប្បីដឹងថា (មានសេចក្តី) ប៉ុណ្ណោះឯង ។

កឋិនភេទ

(២០៧) កស្ស កឋិនំ អនត្ថតំ កស្ស កឋិនំ អត្ថតំ កតិន្នំ កឋិនំ អនត្ថតំ កតិន្នំ កឋិនំ អត្ថតំ ។

(២០៨) កស្ស កឋិនំ អនត្ថតន្តិ ទ្វិន្នំ បុគ្គលានំ អនត្ថតំ ហោតិ កឋិនំ អនត្ថារកស្ស ច អននុមោទកកស្ស ច ឥមេសំ ទ្វិន្នំ បុគ្គលានំ អនត្ថតំ ហោតិ កឋិនំ ។

(២០៩) កស្ស កឋិនំ អត្ថតន្តិ ទ្វិន្នំ បុគ្គលានំ អត្ថតំ ហោតិ កឋិនំ អត្ថារកស្ស ច អនុមោទកស្ស ច ឥមេសំ ទ្វិន្នំ បុគ្គលានំ អត្ថតំ ហោតិ កឋិនំ ។

(២១០) កតិន្នំ កឋិនំ អនត្ថតន្តិ ចតុវីសតិយា អាការេហិ អនត្ថតំ ហោតិ កឋិនំ ន ឧល្លិខិតមត្តេន អត្ថតំ ហោតិ កឋិនំ ន ធោវនមត្តេន អត្ថតំ ហោតិ

កឋិនភេទ

(២០៧) បុគ្គលដូចម្តេចដែលឈ្មោះថាមិនបានក្រាលកឋិន បុគ្គលដូចម្តេចដែលឈ្មោះថាបានក្រាលកឋិន កឋិនដែលភិក្ខុក្រាលមិនឡើងដោយអាការដូចម្តេច កឋិនដែលភិក្ខុក្រាលឡើងដោយអាការដូចម្តេច ។

(២០៨) ពាក្យថា បុគ្គលដូចម្តេចដែលឈ្មោះថាមិនបានក្រាលកឋិននោះ សេចក្តីថា បុគ្គលពីរពួកដែលឈ្មោះថាមិនបានក្រាលកឋិន គឺបុគ្គលមិនបានក្រាល ១ មិនបានអនុមោទនា ១ បុគ្គលទាំង ២ ពួកនេះ ឈ្មោះថាមិនបានក្រាលកឋិនទេ ។

(២០៩) ពាក្យថា បុគ្គលដូចម្តេចដែលឈ្មោះថាបានក្រាលកឋិននោះ សេចក្តីថា បុគ្គល ២ ពួកដែលឈ្មោះថាបានក្រាលកឋិន គឺបុគ្គលដែលបានក្រាល ១ បានអនុមោទនា ១ បុគ្គលទាំង ២ ពួកនេះឈ្មោះថាបានក្រាលកឋិន ។

(២១០) ពាក្យថា កឋិនដែលភិក្ខុក្រាលមិនឡើងដោយអាការដូចម្តេចនោះ សេចក្តីថា កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការ ២៤ គឺ សំពត់ដែលគ្រាន់តែវាស់ទទឹងបណ្តោយ ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលគ្រាន់តែលាង ក្រាលមិនឡើងជាកឋិន ១ សំពត់ដែល

កឋិនំ ន ចីវរវិចារណមត្តេន អត្ថតំ ហោតិ កឋិនំ
ន ឆេទនមត្តេន អត្ថតំ ហោតិ កឋិនំ ន ពន្ធនមត្តេន
អត្ថតំ ហោតិ កឋិនំ ន ឱវដ្ដិកករណមត្តេន អត្ថតំ
ហោតិ កឋិនំ ន កណ្ឌុសករណមត្តេន អត្ថតំ ហោតិ
កឋិនំ ន ទឡ្ហីកម្មករណមត្តេន អត្ថតំ ហោតិ កឋិនំ
ន អនុវាតករណមត្តេន អត្ថតំ ហោតិ កឋិនំ ន បរិ-
ភណ្ឌករណមត្តេន អត្ថតំ ហោតិ កឋិនំ ន ឱវទ្ធេយ្យ-
ករណមត្តេន អត្ថតំ ហោតិ កឋិនំ ន កម្ពលមទ្ទន-
មត្តេន អត្ថតំ ហោតិ កឋិនំ ន និមិត្តកតេន អត្ថតំ
ហោតិ កឋិនំ ន បរិកថាកតេន អត្ថតំ ហោតិ ក-
ឋិនំ ន កុក្កុកតេន អត្ថតំ ហោតិ កឋិនំ ន សន្និ-
ធិកតេន អត្ថតំ ហោតិ កឋិនំ ន និស្សគ្គិយេន អត្ថ-
តំ ហោតិ កឋិនំ ន អកប្បកតេន អត្ថតំ ហោតិ
កឋិនំ ន អញ្ញត្រ សង្ឃាដិយា អត្ថតំ ហោតិ កឋិនំ
ន អញ្ញត្រ ឧត្តរាសង្គេន អត្ថតំ ហោតិ កឋិនំ

គ្រាន់តែបាត់បែងលៃលកជាចីវរ ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលគ្រាន់តែកាត់ ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលគ្រាន់តែដានភ្ជាប់គ្នា ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលគ្រាន់តែដេរ (មានដេរបណ្ដោយជាដើម) ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលគ្រាន់តែដាក់ក្ខុំ ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលគ្រាន់តែថែមសំពត់ឲ្យមាំ ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលគ្រាន់តែប្រក់អនុវាតមួយជាន់ (ពីខាងក្រៅ) ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលគ្រាន់តែធ្វើជាអនុវាតមួយជាន់ (ពីខាងក្នុង) ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលគ្រាន់តែដេរគួបគ្នា ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលគ្រាន់តែជ្រលក់ម្ដង មានពណ៌ដូចក្អកដី ឬដូចស្លឹកឈើទុំ ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលបានមកដោយធ្វើនិមិត្ត ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលបានមកដោយនិយាយបញ្ឆោះបញ្ជូលគេ ក្រាលមិនឡើងជាក-ឋិន ១ សំពត់ដែលខ្ចីគេ ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលធ្វើសន្និធិគឺមិនបានធ្វើឲ្យស្រេចក្នុងថ្ងៃនោះ ក្រាលមិនឡើងជាកឋិន ១ សំពត់ជានិស្សគ្គិយៈ (ទុកឲ្យកន្លងរាត្រី) ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលមិនបានធ្វើពិន្ទុកប្ប ក្រាលមិនឡើងជាកឋិន ១ វៀរចាកសង្ឃាដិ ក្រាលមិនឡើងជាកឋិន ១ វៀរចាកចីពរ ក្រាលមិនឡើងជាកឋិន ១ វៀរចាក

ន អញ្ញត្រ អន្តរវាសកេន អត្ថតំ ហោតិ កឋិនំ ន អញ្ញត្រ បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន អត្ថតំ ហោតិ កឋិនំ ន អញ្ញត្រ បុគ្គលស្ស អត្ថារា អត្ថតំ ហោតិ កឋិនំ ន សម្មា ចេ[១] អត្ថតំ ហោតិ កឋិនំ តញ្ចេ និស្សីមដ្ឋោ អនុមោទតិ ។ ឯវម្បិ អនត្ថតំ ហោតិ កឋិនំ ។

[២១១] និមិត្តកម្មំ នាម និមិត្តំ ករោតិ ឥមិនា ទុស្សេន កឋិនំ អត្ថរិស្សាមីតិ ។ បរិកថា នាម បរិកថំ ករោតិ ឥមាយ បរិកថាយ កឋិនទុស្សំ និព្វត្តេស្សាមីតិ ។ កុក្កុកតំ នាម អនាទិយទានំ វុច្ចតិ ។ សន្និធិ នាម ទ្វេ សន្និធិយោ ករណសន្និធិ ច និចយសន្និធិ ច ។ និស្សគ្គិយំ នាម ករិយមានេ អរុណំ ឧដ្ឋិយតិ ។ ឥមេហិ ចតុវីសតិយា អាការេហិ អនត្ថតំ ហោតិ កឋិនំ ។

---

១ ម. កឋិនំ សម្មា ចេ ។

ស្បង់ ក្រាលមិនឡើងជាកឋិន ១ វៀរចាកសំពត់ជាបញ្ចខណ្ឌ ឬលើស ពីបញ្ចខណ្ឌឡើងទៅ ដែលបានកាត់ដាច់ត្រឹមត្រូវធ្វើឲ្យមានមណ្ឌលល្អក្នុងថ្ងៃនោះ ក្រាលមិនឡើងជាកឋិន ១ វៀរចាកបុគ្គលអ្នកក្រាល ក៏ក្រាលមិនឡើងជាកឋិន ១ សំពត់ដែលបុគ្គលក្រាលត្រឹមត្រូវហើយ តែបើភិក្ខុទៅក្រៅសីមាអនុមោទនា កឋិននោះក៏មិនឡើងជាកឋិន ១ ។ កឋិនដែលក្រាលមិនឡើង ដោយអាការយ៉ាងនេះឯង ។

(២១១) ភិក្ខុធ្វើនិមិត្តថា អាត្មាអញក្រាលកឋិនដោយសំពត់នេះ ដូច្នេះ ហៅថា ធ្វើនិមិត្ត ។ ភិក្ខុធ្វើនូវការនិយាយបញ្ចុះបញ្ចូលដោយគិតថា អាត្មាអញនឹងឲ្យសំពត់កឋិនកើតឡើង ដោយការនិយាយបញ្ចុះបញ្ចូលដូច្នេះ ហៅថា ការនិយាយបញ្ចុះបញ្ចូល ។ សំពត់ដែលគេមិនបានឲ្យដាច់ហៅថា សំពត់ខ្ចីគេ ។ សន្និធិ មាន ២ យ៉ាងគឺ ករណសន្និធិ មិនធ្វើឲ្យស្រេចក្នុងថ្ងៃនោះ (ទុកធ្វើទៅក្នុងថ្ងៃខាងមុខ ៗ តទៅទៀត) ១ និចយសន្និធិ ទុកធ្វើដល់ថ្ងៃស្អែកជាកំណត់ ១ ហៅថា សន្និធិ ។ កាលបើភិក្ខុកំពុងធ្វើ (សំពត់នោះ) អរុណក៏រះឡើង ហៅថា សំពត់ជានិស្សគ្គិយៈ ។ កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការ ២៤ នេះឯង ។

[២០២] កិន្តិ កឋិនំ អត្ថតន្តិ សត្តរសហិ អាការេហិ អត្ថតំ ហោតិ កឋិនំ អហតេន អត្ថតំ ហោតិ កឋិនំ អហតកប្បេន អត្ថតំ ហោតិ កឋិនំ បិលោតិកាយ អត្ថតំ ហោតិ កឋិនំ បំសុកូលេន អត្ថតំ ហោតិ កឋិនំ បាបណិកេន អត្ថតំ ហោតិ កឋិនំ អនិមិត្តកតេន អត្ថតំ ហោតិ កឋិនំ អបរិកថាកតេន អត្ថតំ ហោតិ កឋិនំ អកុក្កុកតេន អត្ថតំ ហោតិ កឋិនំ អសន្និធិកតេន អត្ថតំ ហោតិ កឋិនំ អនិស្សគ្គិយេន អត្ថតំ ហោតិ កឋិនំ កប្បកតេន អត្ថតំ ហោតិ កឋិនំ សង្ឃាដិយា អត្ថតំ ហោតិ កឋិនំ ឧត្តរាសង្គេន អត្ថតំ ហោតិ កឋិនំ អន្តរវាសកេន អត្ថតំ ហោតិ កឋិនំ បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន អត្ថតំ ហោតិ កឋិនំ បុគ្គលស្ស អត្ថារា អត្ថតំ ហោតិ កឋិនំ សម្មា ចេ អត្ថតំ ហោតិ កឋិនំ តញ្ចេ សីមដ្ឋោ អនុមោទតិ ។ ឯវម្បិ អត្ថតំ ហោតិ កឋិនំ ។ ឥមេហិ សត្តរសហិ អាការេហិ អត្ថតំ ហោតិ កឋិនំ ។

[៦១៤] ត្រង់ពាក្យថា កឋិនដែលភិក្ខុក្រាលឡើង ដោយអាការដូចម្តេចនោះ សេចក្តីថា កឋិនដែលភិក្ខុក្រាលឡើងដោយអាការ ១៧ គឺ សំពត់ថ្មីសុទ្ធ ក្រាលឡើងជាកឋិន ១ សំពត់ដំទុំ ក្រាលឡើងជាកឋិន ១ សំពត់ចាស់ ក្រាលឡើងជាកឋិន ១ សំពត់បង្សុកូល ក្រាលឡើងជាកឋិន ១ សំពត់ដែលធ្លាក់ទៀបកនផ្សារ ក្រាលឡើងជាកឋិន ១ សំពត់ដែលបានមកដោយមិនបានធ្វើនិមិត្ត ក្រាលឡើងជាកឋិន ១ សំពត់ដែលបានមកដោយមិនបាននិយាយបញ្ចុះបញ្ចូល ក្រាលឡើងជាកឋិន ១ សំពត់ដែលមិនបានខ្ចីគេ ក្រាលឡើងជាកឋិន ១ សំពត់ដែលមិនបានធ្វើឲ្យជាសន្និធិ ក្រាលឡើងជាកឋិន ១ សំពត់ដែលមិនមែនជានិស្សគ្គិយៈ ក្រាលឡើងជាកឋិន ១ សំពត់ដែលបានធ្វើពិន្ទុកប្បក្រាលឡើងជាកឋិន ១ សង្ឃាដិ ក្រាលឡើងជាកឋិន ១ ចីពរ ក្រាលឡើងជាកឋិន ១ ស្បង់ ក្រាលឡើងជាកឋិន ១ ចីវរជាបញ្ចក្ខន្ធ ឬ លើសពីបញ្ចក្ខន្ធឡើងទៅ ដែលបានកាត់ដាច់ត្រឹមត្រូវធ្វើឲ្យមានមណ្ឌលល្អក្នុងថ្ងៃនោះ ក្រាលឡើងជាកឋិន ១ បុគ្គលទើបក្រាលឡើងជាកឋិន ១ សំពត់ដែលបុគ្គលក្រាលឲ្យត្រឹមត្រូវ (តាមច្បាប់) ទាំងភិក្ខុនៅក្នុងសីមាអនុមោទនា កឋិននោះទើបឡើងជាកឋិន ១ កឋិនដែលភិក្ខុក្រាលឡើងដោយអាការយ៉ាងនេះឯង ។ កឋិនដែលភិក្ខុក្រាលឡើង ដោយអាការទាំង ១៧ នេះ ។

កឋិនភេទំ អដ្ឋមាតិកាទយោ បណ្ណរសធម្មា

(២១៣) សហ កឋិនស្ស អត្ថារា កតិ ធម្មា ជាយន្តិ ។ សហ កឋិនស្ស អត្ថារា បណ្ណរស ធម្មា ជាយន្តិ អដ្ឋ មាតិកា ទ្វេ បលិពោធា បញ្ច អានិសំសា ។ សហ កឋិនស្ស អត្ថារា ឥមេ បណ្ណរស ធម្មា ជាយន្តិ ។

(២១៤) បយោគស្ស កតមេ ធម្មា អនន្តរប្បច្ចយេន បច្ចយោ សមនន្តរប្បច្ចយេន បច្ចយោ និស្សយប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ។ បុព្វករណស្ស ។ បេ ។ បច្ចុទ្ធារស្ស អធិដ្ឋានស្ស អត្ថារស្ស មាតិកានញ្ច បលិពោធានញ្ច វត្ថុស្ស កតមេ ធម្មា អនន្តរប្បច្ចយេន បច្ចយោ សមនន្តរប្បច្ចយេន បច្ចយោ និស្សយប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ។

កបិនភេទ ធម៌ ១៨ ប្រការមានមាតិកា ៨ ជាដើម

(៤១៣) ធម៌ប៉ុន្មានយ៉ាង ដែលកើតជាមួយនឹងការក្រោលកបិន ។ ធម៌ ១៥ យ៉ាង ដែលកើតជាមួយនឹងការក្រោលកបិន គឺ មាតិកា ៨ បលិពោធ ២ អានិសង្ស ៥ ។ ធម៌ទាំង ១៥ នេះឯង ដែលកើតទៀនជាមួយនឹងការក្រោលកបិន ។

ឧបសង្កមន្តេន បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា សង្ឃោ ឧបសង្កមិតព្វោ ។ កតមេ បញ្ច ។ សង្គាមាវចរេនុ- បាលិ ភិក្ខុនា សង្ឃំ ឧបសង្កមន្តេន នីចចិត្តេន សង្ឃោ ឧបសង្កមិតព្វោ រជោហរណសមេន ចិត្តេន អាសនកុ- សលេន ភវិតព្វំ និសជ្ជកុសលេន ថេរេ ភិក្ខូ អនុប- ខជ្ជន្តេន នវេ ភិក្ខូ អាសនេន អប្បដិពាហន្តេន យថា- បដិរូបេ អាសនេ និសីទិតព្វំ អនានាកថិកេន ភវិតព្វំ អតិរច្ឆានកថិកេន សាមំ វា ធម្មោ ភាសិតព្វោ បរោ វា អជ្ឈេសិតព្វោ អរិយោ វា តុណ្ហីភាវោ នាតិមញ្ញិ- តព្វោ សចេ ឧបាលិ សង្ឃោ សមគ្គករណីយានិ កម្មា- និ ករោតិ តត្រ ចេ ឧបាលិ ភិក្ខុនោ នក្ខមតិ[១] អបិ ទិដ្ឋាវិកម្មំ កត្វា ឧបេតព្វា សាមគ្គី ។ តំ កិស្ស ហេតុ ។ មាហំ សង្ឃេន នានត្តោ អស្សន្តិ ។ សង្គា- មាវចរេនុបាលិ ភិក្ខុនា សង្ឃំ ឧបសង្កមន្តេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា សង្ឃោ ឧបសង្ក- មិតព្វោតិ ។

---

១ ភិក្ខុនោ សង្ឃបដិមានំ នក្ខមតីតិបិ កត្ថចិ បោត្ថកេ ទិស្សតិ ។

តំកល់ធម៌ ៥ យ៉ាងទុកក្នុងសន្តានហើយសឹមចូលទៅរកសង្ឃ ។ ធម៌ ៥ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុជាអ្នកចូលទៅកាន់សង្គ្រាម កាលបើចូលទៅរកសង្ឃ ត្រូវមានចិត្តទន់ទេនសឹមចូលទៅរកសង្ឃ គប្បីជាអ្នកមានចិត្តស្មើដោយសំពត់សម្រាប់ជូតធូលី ជាអ្នកឈ្លាសក្នុងអាសនៈ ឈ្លាសក្នុងការអង្គុយ ១ មិនត្រូវចូលទៅប្រៀតប្រៀតពួកភិក្ខុជាថេរៈ មិនត្រូវឃាត់អាសនៈពួកភិក្ខុខ្ចី អង្គុយលើអាសនៈតាមសមគួរ ១ មិនត្រូវជាអ្នកនិយាយពាក្យផ្តេសផ្តាស មិនត្រូវនិយាយតិរច្ឆានកថា ១ ត្រូវពោលធម៌ដោយខ្លួនឯង ឬ អារាធនាអ្នកដទៃឲ្យពោលធម៌ ១ មិនត្រូវមើលងាយព្រះអរិយបុគ្គលដែលលោកគន់ស្ងៀម ១ ម្នាលឧបាលិ បើសង្ឃធ្វើកម្មទាំងឡាយ ដែលសង្ឃគប្បីធ្វើដោយសេចក្តីព្រមព្រៀងគ្នា ម្នាលឧបាលិ បើមានភិក្ខុមិនគាប់ចិត្តនឹងកម្មនោះ ភិក្ខុនោះត្រូវធ្វើទិដ្ឋិឲ្យប្រាស់ប្រាកដសឹមដំកល់សាមគ្គី ។ សេចក្តីនោះតើព្រោះហេតុអ្វី ។ ព្រោះថាភិក្ខុនោះត្រូវតំកល់សាមគ្គីដោយគិតថា អាត្មាអញមិនត្រូវមានខ្លួនបែកអំពីសង្ឃទេ ។ ម្នាលឧបាលិ ភិក្ខុជាអ្នកចូលទៅកាន់សង្គ្រាម កាលបើចូលទៅរកសង្ឃ ត្រូវតំកល់ធម៌ទាំង ៥ នេះ ក្នុងសន្តានសិនសឹមចូលទៅរកសង្ឃ

(២៥០) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតោ ភិក្ខុ សង្ឃេ វោហារន្តោ ពហុជនាកន្តោ ច ហោតិ ពហុ-ជនាមនាបោ ច ពហុជនារុចិតោ ចាតិ។ បញ្ចហុបា-លិ អង្គេហិ សមន្នាគតោ ភិក្ខុ សង្ឃេ វោហារន្តោ ពហុជនាកន្តោ ច ហោតិ ពហុជនាមនាបោ ច ពហុ ជនារុចិតោ ច។ កតមេហិ បញ្ចហិ។ ឧស្សិតមន្តី ច ហោតិ និស្សិតជប្បី ច ន ច ភាសានុសន្ធិកុសលោ ហោតិ ន យថាធម្មេ យថាវិនយេ យថាបត្តិយា ចោ-ទេតា ហោតិ ន យថាធម្មេ យថាវិនយេ យថាបត្តិយា ការេតា ហោតិ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេ-ហិ សមន្នាគតោ ភិក្ខុ សង្ឃេ វោហារន្តោ ពហុជនា-កន្តោ ច ហោតិ ពហុជនាមនាបោ ច ពហុជនារុ-ចិតោ ច។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ សង្ឃេ វោហារន្តោ ពហុជនកន្តោ ច ហោតិ ពហុជនមនាបោ ច ពហុជនរុចិតោ ច។ កតមេហិ បញ្ចហិ។ ន ឧស្សិតមន្តី ច ហោតិ ន និស្សិតជប្បី

ឧបាលិបញ្ចកៈ អង្គ ៥ របស់ភិក្ខុដែលនិយាយក្នុងកណ្តាលជំនុំសង្ឃ

(២៥០) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន ពោលក្នុងកណ្តាលជំនុំសង្ឃ នាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំមិនឲ្យជនច្រើនគ្នាបូលចិត្តផង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ពោលក្នុងកណ្តាលជំនុំសង្ឃ នាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំមិនឲ្យជនច្រើនគ្នាបូលចិត្តផង ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុជាអ្នកនិយាយពាក្យប្រកបដោយលោភៈជាដើម ១ ជាអ្នកពោលអាងអ្នកដទៃ ១ ជាអ្នកមិនឈ្លាសក្នុងកាសាទឹងវិនិច្ឆ័យ ១ ជាអ្នកមិនចោទភិក្ខុផងគ្នាឲ្យសមគួរតាមធម៌ សមគួរតាមវិន័យ សមគួរតាមអាបត្តិ ១ ជាអ្នកមិនកាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ នេះឯងនិយាយកណ្តាលជំនុំសង្ឃ តែងនាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំមិនឲ្យជនច្រើនគ្នាបូលចិត្តផង ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ កាលនិយាយកណ្តាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំឲ្យជនច្រើនគ្នាបូលចិត្តផង ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុជាអ្នកមិននិយាយពាក្យប្រកបដោយលោភៈជាដើម ១ មិនពោលអាងអ្នកដទៃ ១

ច ភាសានុសន្ធិកុសលោ ច ហោតិ យថាធម្មេ-
យថាវិនយេ យថាបត្តិយោ ចោទេតា ហោតិ យថា-
ធម្មេ យថាវិនយេ យថាបត្តិយោ ការេតា ហោតិ ។
ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ
ភិក្ខុ សង្ឃេ វោហារន្តោ ពហុជនកន្តោ ច ហោតិ
ពហុជនមនាបោ ច ពហុជនរុចិតោ ច ។ អបរេហិបិ
ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ សង្ឃេ
វោហារន្តោ ពហុជនាកន្តោ ច ហោតិ ពហុជនាមនាបោ
ច ពហុជនារុចិតោ ច ។ កតមេហិ បញ្ចហិ ។ ឧស្សា-
ទេតា ហោតិ អបសាទេតា ហោតិ អធម្មំ គណ្ហាតិ
ធម្មំ បដិពាហតិ សម្ផំ ពហុំ ភាសតិ ។ ឥមេហិ
ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ សង្ឃេ
វោហារន្តោ ពហុជនាកន្តោ ច ហោតិ ពហុជនាមនាបោ
ច ពហុជនារុចិតោ ច ។ បញ្ចហុបាលិ អង្គេហិ ស-
មន្នាគតោ ភិក្ខុ សង្ឃេ វោហារន្តោ ពហុជនកន្តោ ច
ហោតិ ពហុជនមនាបោ ច ពហុជនរុចិតោ ច ។
កតមេហិ បញ្ចហិ ។ ន ឧស្សាទេតា ហោតិ ន

ជាអ្នកឈ្លាសក្នុងការសានឹងវិនិច្ឆ័យ ១ ជាអ្នកចោទកិច្ចផងគ្នាឲ្យសមគួរតាមធម៌ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ ជាអ្នកកាត់សេចក្ដីឲ្យសមគួរតាមធម៌ឲ្យសមគួរតាមវិន័យឲ្យសមគួរតាមអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង កាលនិយាយក្នុងកណ្ដាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត កាលនិយាយក្នុងជំនុំសង្ឃ ក៏តែងនាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាពេញចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង ។ អង្គ៥តើដូចម្ដេច ។ គឺភិក្ខុជាអ្នកអួតអាងសរសើរលើកបុគ្គលដទៃ ១ ជាអ្នកផ្ចាញ់ផ្ចាល់គេ ១ ប្រកាន់យកហេតុដែលមិនមែនជានិយ្យានិកធម៌ ១ ឃាត់ហេតុដែលជានិយ្យានិកធម៌ ១ និយាយពាក្យច្រើនឥតប្រយោជន៍ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង កាលនិយាយក្នុងកណ្ដាលជំនុំសង្ឃ តែងនាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាពេញចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ កាលនិយាយក្នុងកណ្ដាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាពេញចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង ។ អង្គ ៥ តើដូចម្ដេច ។ គឺភិក្ខុជាអ្នកមិនអួតអាងសរសើរលើកបុគ្គលដទៃ ១

ឧបាលិបញ្ចកំ សង្ឃេ វោហរន្តស្ស បញ្ចង្គានិ

អបសាទេតា ហោតិ ធម្មំ គណ្ហាតិ អធម្មំ បដិពាហតិ សម្ផញ្ច ន ពហុំ ភាសតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ សង្ឃេ វោហរន្តោ ពហុជនកន្តោ ច ហោតិ ពហុជនមនាបោ ច ពហុ-ជនរុចិតោ ច ។ អបរេហិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ សង្ឃេ វោហរន្តោ ពហុជនកន្តោ ច ហោតិ ពហុជនមនាបោ ច ពហុជនរុចិតោ ច ។ កតមេហិ បញ្ចហិ ។ បសយ្ហ វត្តា ហោតិ អនោ-កាសកម្មំ ការេត្វា វត្តា ហោតិ ន យថាធម្មេ យថាវិនយេ យថាបត្តិយា ចោទេតា ហោតិ ន យ-ថាធម្មេ យថាវិនយេ យថាបត្តិយា ការេតា ហោតិ ន យថាទិដ្ឋិយា ព្យាកតា ហោតិ ។ ឥមេហិ ខោ ឧបា-លិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ សង្ឃេ វោហ-រន្តោ ពហុជនអកន្តោ ច ហោតិ ពហុជនអមនាបោ ច ពហុជនអរុចិតោ ច ។ បញ្ចហុបាលិ អង្គេហិ សមន្នាគ-តោ ភិក្ខុ សង្ឃេ វោហរន្តោ ពហុជនកន្តោ ច ហោតិ

ជាអ្នកមិនផ្ចាញ់ផ្ចាល់គេ ១ កាន់យកហេតុដែលជានិយ្យានិកធម៌ ១ ឃាត់ហេតុមិនមែនជានិយ្យានិកធម៌ ១ មិននិយាយពាក្យដែលឥតប្រយោជន៍ដោយច្រើន ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ នេះឯង កាលនិយាយក្នុងកណ្ដាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាពេញចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ ដទៃទៀត កាលនិយាយក្នុងកណ្ដាលជំនុំសង្ឃ តែងនាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាពេញចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង ។ អង្គ ៩ តើដូចម្ដេច ។ គឺភិក្ខុជាអ្នកនិយាយសង្កត់សង្កិន (ព្រោះអាស្រ័យមានះ) ១ មិនបានសូមឱកាសជាមុន ក៏ស្រាប់តែនិយាយ ១ មិនចោទភិក្ខុដទៃឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ មិនកាត់សេចក្ដីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ មិនព្យាករដោយសមគួរ តាមសេចក្ដីយល់របស់ខ្លួន ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ នេះឯង កាលនិយាយក្នុងកណ្ដាល ជំនុំសង្ឃ តែងនាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាពេញចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ កាលនិយាយក្នុងកណ្ដាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង

ពហុជនមនាបោ ច ពហុជនរុចិតោ ច ។ កតមេហិ បញ្ចហិ ។ ន បសយ្ហ វត្តា[១] ហោតិ ឱកាសកម្មំ ការាបេត្វា វត្តា[២] យថាធម្មេ យថាវិនយេ យថាបត្តិយា ចោទេតា ហោតិ យថាធម្មេ យថាវិនយេ យថាបត្តិយា ការេតា ហោតិ យថាទិដ្ឋិយា ព្យាករតា ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ សង្ឃេ វោហរន្តោ ពហុជនកន្តោ ច ហោតិ ពហុជនមនាបោ ច ពហុជនរុចិតោ ចាតិ ។

(២៥១) កតិ នុ ខោ ភន្តេ អានិសំសា វិនយបរិយត្តិយាតិ ។ បញ្ចិមេ ឧបាលិ អានិសំសា វិនយបរិយត្តិយា ។ កតមេ បញ្ច ។ អត្តនោ សីលក្ខន្ធោ សុគុត្តោ ហោតិ សុរក្ខិតោ កុក្កុច្ចបកតានំ បដិសរណំ ហោតិ វិសារទោ សង្ឃមជ្ឈេ វោហរតិ បច្ចត្ថិកេ សហធម្មេន សុនិគ្គហិតំ និគ្គណ្ហាតិ សទ្ធម្មដ្ឋិតិយា បដិបន្នោ ហោតិ ។ ឥមេ ខោ ឧបាលិ បញ្ចានិសំសា វិនយបរិយត្តិយាតិ ។

នប្បដិប្បស្សម្ភនវគ្គោ ទុតិយោ ។

១-២ ឱ. ម. បវត្តា ។

នាំឲ្យជនច្រើនគ្នាពេញចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុជាអ្នកពុំបាននិយាយសង្កត់សង្កិន (ព្រោះអាស្រ័យមានៈ) ១ បានសូមឱកាសជាមុនទើបនិយាយ ១ ចោទភិក្ខុផងគ្នាឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ កាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ ព្យាករណ៍តាមសេចក្តីយល់របស់ខ្លួន ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង កាលនិយាយក្នុងកណ្តាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាពេញចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង ។

(២៥១) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន អានិសង្សនៃការរៀនវិន័យ មានប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ អានិសង្សនៃការរៀនវិន័យ មាន៥ ។ អានិសង្ស ៥ តើដូចម្តេច ។ គឺភិក្ខុជាអ្នកបេះគ្រប់គ្រងរក្សាសីលក្ខន្ធរបស់ខ្លួនដោយប្រពៃ ១ រមែងបានជាទីពឹងនៃពួកជន ដែលមានសេចក្តីសង្ស័យ ១ ជាអ្នកក្លៀវក្លានិយាយកណ្តាលជំនុំសង្ឃ ១ ជាអ្នកសង្កត់សង្កិននូវពួកសត្រូវដោយសហធម៌បាន ដោយងាយ ១ ជាអ្នកប្រតិបត្តិដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ ១ ។ ម្នាលឧបាលិ អានិសង្សនៃការរៀនវិន័យ មាន ៥ នេះឯង ។

ចប់ នប្បតិប្បស្សម្ភនវគ្គ ទី ២ ។

តស្សុទ្ទានំ

[២៥២] អាបន្នោ យោ យេ វណ្ណញ្ច[1]
អកវឌ្ឍី សង្គាមេន ច
ឧស្សិតា ឧស្សាទេតា ច
បសយ្ហ បរិយត្តិយោតិ ។

[២៥៣] កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វន្តិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ អាបត្តឹ ន ជានាតិ អាបត្តិសមុដ្ឋានំ ន ជានាតិ អាបត្តិយា បយោគំ ន ជានាតិ អាបត្តិយា វូបសមំ ន ជានាតិ ន អាបត្តិយា វិនិច្ឆយកុសលោ ហោតិ[2] ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ អាបត្តឹ ជានាតិ អាបត្តិសមុដ្ឋានំ ជានាតិ អាបត្តិយា បយោគំ ជា-

---

១ ម. វណ្ណា ច ។ ២ ឱ. អាបត្តិយា ន វិនិច្ឆយកុសលោ ហោតិ ។

ឧទ្ទានគឺបញ្ជីរឿងនៃបដិប្បស្សម្ភនវគ្គទី ២ នោះដូច្នេះ

(៤៥២) និយាយអំពីភិក្ខុត្រូវអាបត្តិ ១ សង្ឃធ្វើកម្មភិក្ខុនោះចំពោះអាបត្តិណា ១ ភិក្ខុពោលតិះដៀលព្រះពុទ្ធជាដើម ១ មិនខ្មាសបាប ១ ចូលទៅកាន់សង្គ្រាម ១ និយាយពាក្យប្រកបដោយលោភៈជាដើម ១ អួតអាងសរសើរលើកបុគ្គលដទៃ ១ ពោលពាក្យសង្កត់សង្កិន ១ អានិសង្សនៃការរៀនវិន័យ ១ ។

(៤៥៣) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលមិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ ។ អង្គ ៥ តើដូចម្តេច ។ គឺមិនស្គាល់អាបត្តិ ១ មិនស្គាល់សមុដ្ឋាននៃអាបត្តិ ១ មិនស្គាល់ប្រយោគរបស់អាបត្តិ ១ មិនស្គាល់ការរម្ងាប់អាបត្តិ ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុស្គាល់អាបត្តិ ១ ស្គាល់សមុដ្ឋាននៃអាបត្តិ ១ ស្គាល់ប្រយោគរបស់អាបត្តិ ១

នាតិ អាបត្តិយា វូបសមំ ជានាតិ អាបត្តិយា វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ អធិករណំ ន ជានាតិ អធិករណសមុដ្ឋានំ ន ជានាតិ អធិករណស្ស បយោគំ ន ជានាតិ អធិករណស្ស វូបសមំ ន ជានាតិ ន អធិករណស្ស វិនិច្ឆយកុសលោ ហោតិ[១] ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ អធិករណំ ជានាតិ អធិករណសមុដ្ឋានំ ជានាតិ អធិករណស្ស បយោគំ ជានាតិ អធិករណស្ស វូបសមំ ជានាតិ អធិករណស្ស វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។

១ . ម. អធិករណស្ស ន វិនិច្ឆយកុសលោ ហោតិ ។

ស្គាល់ការរម្ងាប់អាបត្តិ ១ ឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ ។ អង្គ ៥ តើដូចម្តេច ។ ភិក្ខុមិនស្គាល់អធិករណ៍ ១ មិនស្គាល់សមុដ្ឋាននៃអធិករណ៍ ១ មិនស្គាល់ប្រយោគរបស់អធិករណ៍ ១ មិនស្គាល់ការរម្ងាប់អធិករណ៍ ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុស្គាល់អធិករណ៍ ១ ស្គាល់សមុដ្ឋាននៃអធិករណ៍ ១ ស្គាល់ប្រយោគរបស់អធិករណ៍ ១ ស្គាល់ការរម្ងាប់អធិករណ៍ ១ ឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។

អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃោ ន វោហារិតព្វោ ។ កតមេហិ បញ្ចហិ ។ បសយ្ហ វត្តា(១) ហោតិ អនោកាសកម្មំ ការេត្វា វត្តា(២) ហោតិ ន យថាធម្មេ យថាវិនយេ យថា-បត្តិយា ចោទេតា ហោតិ ន យថាធម្មេ យថាវិនយេ យថាបត្តិយា ការេតា ហោតិ ន យថាទិដ្ឋិយា ព្យាកតា ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេ-ហិ សមន្នាគតេន ភិក្ខុនា សង្ឃោ ន វោហារិតព្វោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃោ វោហារិតព្វោ ។ កតមេហិ បញ្ចហិ ។ ន បសយ្ហ វត្តា ហោតិ ឱកាសកម្មំ ការេត្វា វត្តា ហោតិ យថាធម្មេ យថាវិនយេ យថាបត្តិយា ចោទេតា ហោតិ យថាធម្មេ យថាវិនយេ យថាបត្តិយា ការេតា ហោតិ យថាទិដ្ឋិ-យា ព្យាកតា ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ច-ហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃោ វោហារិតព្វោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា

១–២ ឱ. ម. បវត្តា ។

ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដោយឡែកទៀត ក៏មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃដែរ ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុជាអ្នកនិយាយសង្កត់សង្កិនគេ ១ មិនសូមឱកាសជាមុន ស្រាប់តែនិយាយ ១ មិនចោទភិក្ខុផងគ្នាឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ មិនកាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសម-គួរតាមអាបត្តិ ១ មិនព្យាករតាមសេចក្តីយល់របស់ខ្លួន ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុជាអ្នកមិនពោលសង្កត់សង្កិនគេ ១ បានសូមឱកាសជាមុនហើយ ទើបនិយាយ ១ ចោទភិក្ខុផងគ្នាឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ កាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ ជាអ្នកព្យាករតាមសេចក្តីយល់របស់ខ្លួន ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត

សង្ឃេ ន ភាសិតព្វំ ។ កតមេហិ បញ្ចហិ ។ អាបត្តានាបត្តឹ ន ជានាតិ លហុកគរុកំ អាបត្តឹ ន ជានាតិ សាវសេសានវសេសំ អាបត្តឹ ន ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ន ជានាតិ សប្បដិកម្មអប្បដិកម្មំ[១] អាបត្តឹ ន ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន ភាសិតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ភាសិតព្វំ ។ កតមេហិ បញ្ចហិ ។ អាបត្តានាបត្តឹ ជានាតិ លហុកគរុកំ អាបត្តឹ ជានាតិ សាវសេសានវសេសំ អាបត្តឹ ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ជានាតិ សប្បដិកម្មអប្បដិកម្មំ អាបត្តឹ ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ភាសិតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន ភាសិតព្វំ ។ កតមេហិ បញ្ចហិ ។ កម្មំ ន ជានាតិ កម្មស្ស ករណំ ន ជានាតិ

---

១ ឧ. ម. សប្បដិកម្មំ អប្បដិកម្មំ ។

ក៏មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃដែរ ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនស្គាល់អាបត្តិនិងអនាបត្តិ ១ មិនស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ មិនស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ មិនស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១ មិនស្គាល់សប្បដិកម្មាបត្តិ[១] និងអប្បដិកម្មាបត្តិ[២] ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុស្គាល់អាបត្តិនិងអនាបត្តិ ១ ស្គាល់លហុកាបត្តិនិងគរុកាបត្តិ ១ ស្គាល់សាវសេសាបត្តិនិងអនវសេសាបត្តិ ១ ស្គាល់ទុដ្ឋុល្លាបត្តិនិងអទុដ្ឋុល្លាបត្តិ ១ ស្គាល់សប្បដិកម្មាបត្តិនិងអប្បដិកម្មាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនស្គាល់កម្ម (៧ ប្រការ[៣] មានតជ្ជនីយកម្មជាដើម) ១ មិនស្គាល់ការធ្វើកម្ម ១

---

១ សប្បដិកម្មាបត្តិ ប្រែថា អាបត្តិដែលនៅកែបាននៅឡើយ បានដល់អាបត្តិ៦កង តាំងពីសង្ឃាទិសេស រៀងដល់ទុព្ភាសិត ។ ២ អប្បដិកម្មាបត្តិ ប្រែថា អាបត្តិកែមិនបាន គឺបានដល់អាបត្តិបារាជិក ។ ៣ កម្ម ៧ យ៉ាង គឺ តជ្ជនីយកម្ម ១ និយស្សកម្ម ១ បព្វាជនីយកម្ម ១ បដិសារណីយកម្ម ១ ឧក្ខេបនីយកម្ម ១ បត្តនិក្កុជ្ជនកម្ម ១ បត្តឧក្កុជ្ជនកម្ម ១ រួមជា ៧ យ៉ាង

ឧបាលិបញ្ចកំ កម្មំ ជានាតិអាទីនិ បញ្ចង្គានិ

កម្មស្ស វត្ថុំ ន ជានាតិ កម្មស្ស វត្តំ ន ជានាតិ កម្មស្ស វូបសមំ ន ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ កម្មំ ជានាតិ កម្មស្ស ករណំ ជានាតិ កម្មស្ស វត្ថុំ ជានាតិ កម្មស្ស វត្តំ ជានាតិ កម្មស្ស វូបសមំ ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ វត្ថុំ ន ជានាតិ និទានំ ន ជានាតិ បញ្ញត្តឹ ន ជានាតិ បទបច្ចាភដ្ឋំ ន ជានាតិ អនុសន្ធិវចនបថំ ន ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។

មិនស្គាល់វត្ថុរបស់កម្ម ១ មិនស្គាល់វត្តរបស់កម្ម ១ មិនស្គាល់ការរម្ងាប់របស់កម្ម ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃឡើយ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃបាន ។ អង្គ ៥ តើដូចម្ដេច ។ គឺភិក្ខុស្គាល់កម្ម ១ ស្គាល់ការធ្វើកម្ម ១ ស្គាល់វត្ថុរបស់កម្ម ១ ស្គាល់វត្តរបស់កម្ម ១ ស្គាល់ការរម្ងាប់របស់កម្ម ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃឡើយ ។ អង្គ ៥ តើដូចម្ដេច ។ គឺភិក្ខុមិនស្គាល់វត្ថុ(នៃអាបត្តិទាំង៧) ១ មិនស្គាល់និទាន គឺរឿងដែលទ្រង់បញ្ញត្តសិក្ខាបទ១ មិនស្គាល់បញ្ញត្តិ ១ មិនស្គាល់សេចក្ដីខាងចុងខាងដើមបទ (១) ១ មិនស្គាល់គន្លងពាក្យដែលជាប់គ្នា ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃឡើយ ។

---

១ អដ្ឋកថា ថា មិនស្គាល់សេចក្ដីខាងចុងនឹងខាងដើមបទនោះ គឺដូចជាគេធ្លាប់សូត្រថា ពុទ្ធោ ភគវា ត្រឡប់ជាសូត្រ ភគវា ពុទ្ធោ ដូច្នេះវិញ ។

បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ វត្ថុំ ជានាតិ និទានំ ជានាតិ បញ្ញត្តឹ ជានាតិ បទបច្ឆាភដ្ឋំ ជានាតិ អនុសន្ធិវចនបថំ ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ អលជ្ជី ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ លជ្ជី ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។

ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃបាន ។ អង្គ ៥ តើដូចម្ដេច ។ គឺភិក្ខុស្គាល់វត្ថុ ១ ស្គាល់និទាន ១ ស្គាល់បញ្ញត្តិ ១ ស្គាល់សេចក្ដីខាងចុងនិងខាងដើមបទ ១ ស្គាល់គន្លងពាក្យដែលជាប់គ្នា ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃដែរ ។ អង្គ៥តើដូចម្ដេច ។ គឺភិក្ខុលំអៀងទៅខាងឆន្ទាគតិ ១ លំអៀងទៅខាងទោសាគតិ ១ លំអៀងទៅខាងមោហាគតិ ១ លំអៀងទៅខាងភយាគតិ ១ មិនខ្មាសបាប១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃឡើយ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃបាន ។ អង្គ ៥ តើដូចម្ដេច ។ គឺភិក្ខុមិនលំអៀងទៅខាងឆន្ទាគតិ ១ មិនលំអៀងទៅខាងទោសាគតិ ១ មិនលំអៀងទៅខាងមោហាគតិ ១ មិនលំអៀងទៅខាងភយាគតិ ១ មានសេចក្ដីខ្មាសបាប ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃបាន ។

អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហាតព្វំ ។ កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ អកុសលោ ច ហោតិ វិនយេ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហាតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហាតព្វំ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ កុសលោ ច ហោតិ វិនយេ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហាតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហាតព្វំ ។ កតមេហិ បញ្ចហិ ។ ញត្តឹ ន ជានាតិ ញត្តិយា ករណំ ន ជានាតិ ញត្តិយា អនុស្សាវនំ ន ជានាតិ ញត្តិយា សមថំ ន ជានាតិ ញត្តិយា វូបសមំ ន ជានាតិ ។

ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនគួរនិយាយក្នុងកណ្តាលជំនុំសង្ឃ ។ អង្គ៥តើដូចម្តេច ។ គឺភិក្ខុលំអៀងទៅខាងឆន្ទាគតិ១ លំអៀងទៅខាងទោសាគតិ ១ លំអៀងទៅខាងមោហាគតិ ១ លំអៀងទៅខាងភយាគតិ ១ មិនឈ្លាសក្នុងវិន័យ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនគួរនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួរនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនលំអៀងទៅខាងឆន្ទាគតិ ១ មិនលំអៀងទៅខាងទោសាគតិ ១ មិនលំអៀងទៅខាងមោហាគតិ ១ មិនលំអៀងទៅខាងភយាគតិ ១ ជាអ្នកឈ្លាសក្នុងវិន័យ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ នេះឯង ទើបគួរនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនគួរនិយាយក្នុងកណ្តាលជំនុំសង្ឃដែរ ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនស្គាល់ញត្តិ១ មិនស្គាល់ការធ្វើដោយញត្តិ១ មិនស្គាល់វិធីសូត្រដោយញត្តិ១ មិនស្គាល់សមថៈដោយញត្តិ ១ មិនស្គាល់ការរម្ងាប់ដោយញត្តិ ១ ។

ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្ពំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្ពំ ។ កតមេហិ បញ្ចហិ ។ ញត្តឹ ជានាតិ ញត្តិយា ករណំ ជានាតិ ញត្តិយា អនុស្សាវនំ ជានាតិ ញត្តិយា សមថំ ជានាតិ ញត្តិយា វូបសមំ ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្ពំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្ពំ ។ កតមេហិ បញ្ចហិ ។ សុត្តំ ន ជានាតិ សុត្តានុលោមំ ន ជានាតិ វិនយំ ន ជានាតិ វិនយានុលោមំ ន ជានាតិ ន ឋានាឋានកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្ពំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្ពំ ។ កតមេហិ បញ្ចហិ ។ សុត្តំ

ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។ អង្គ៥តើដូចម្តេច ។ គឺភិក្ខុស្គាល់ញត្តិ ១ ស្គាល់ការធ្វើដោយញត្តិ ១ ស្គាល់វិធីសូត្រដោយញត្តិ ១ ស្គាល់សមថៈដោយញត្តិ១ស្គាល់ការរម្ងាប់ដោយញត្តិ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃដែរ ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនចេះសុត្តៈ គឺឧភតោវិភង្គ ១ មិនចេះសុត្តានុលោម គឺ មហាបទេសទាំងបួន ១ មិនចេះវិន័យ គឺ ខន្ធកៈនិងបរិវារៈ ១ មិនចេះវិនយានុលោម គឺ មហាបទេសទាំងបួន ១ មិនឈ្លាសក្នុងហេតុដែលគួរនិងមិនគួរ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុចេះសុត្តៈ ១

ជានាតិ សុត្តានុលោមំ ជានាតិ វិនយំ ជានាតិ វិនយានុលោមំ ជានាតិ ឋានាឋានកុសលោ ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ ធម្មំ ន ជានាតិ ធម្មានុលោមំ ន ជានាតិ វិនយំ ន ជានាតិ វិនយានុលោមំ ន ជានាតិ ន ច បុព្វាបរកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ ន វោហរិតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វំ ។ កតមេហិ បញ្ចហិ ។ ធម្មំ ជានាតិ ធម្មានុលោមំ ជានាតិ វិនយំ ជានាតិ វិនយានុលោមំ ជានាតិ បុព្វាបរកុសលោ ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វោហរិតព្វន្តិ ។

វោហារវគ្គោ តតិយោ ។

បេះសុត្តានុលោម ១ បេះវិន័យ ១ បេះវិនយានុលោម ១ ឈ្លាសក្នុង ហេតុដែលគួរនឹងមិនគួរ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយ អង្គ ៩ នេះឯង ទើបត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃបាន ។ ម្នាល ឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ ដទៃទៀត ក៏មិនត្រូវនិយាយក្នុង កណ្ដាលជំនុំសង្ឃដែរ ។ អង្គ ៩ តើដូចម្ដេច ។ គឺភិក្ខុមិនបេះធម៌ ១ មិន បេះធម្មានុលោម គឺមហាបទេសបួនខាងព្រះសូត្រ ១ មិនបេះវិន័យ ១ មិន បេះវិនយានុលោម ១ មិនឈ្លាសក្នុងពាក្យខាងដើមនឹងពាក្យខាងចុង ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ នេះឯង មិនត្រូវនិយាយក្នុង កណ្ដាលជំនុំសង្ឃឡើយ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៩ទើប ត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃបាន ។ អង្គ ៩ តើដូចម្ដេច ។ គឺភិក្ខុបេះ ធម៌ ១ បេះធម្មានុលោម ១ បេះវិន័យ ១ បេះវិនយានុលោម ១ ឈ្លាស ក្នុងពាក្យខាងដើមនឹងពាក្យខាងចុង ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកប ដោយអង្គ ៩ នេះឯង ទើបត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃបាន ។

ចប់ វោហារវគ្គ ទី៣ ។

តស្សុទ្ទានំ

(២៥៤) អាបត្តិ អធិករណំ

បញ្ហាបត្តិជាននា

កម្មំ វត្ថុំ អលជ្ជី ច

អកុសលោ ច ញត្តិយា

សុត្តំ ន ជានាតិ ធម្មំ

តតិយោ វគ្គសង្គហោតិ ។

(២៥៥) កតិ នុ ខោ ភន្តេ អធម្មិកា ទិដ្ឋាវិកម្មាតិ ។ បញ្ចិមេ ឧបាលិ អធម្មិកា ទិដ្ឋាវិកម្មា ។ កតមេ បញ្ច ។ អនាបត្តិយា ទិដ្ឋឹ អាវិករោតិ អទេសនាគាមិនិយា អាបត្តិយា ទិដ្ឋឹ អាវិករោតិ ទេសិតាយ អាបត្តិយា ទិដ្ឋឹ អាវិករោតិ ចតូហិ បញ្ចហិ ទិដ្ឋឹ អាវិករោតិ មនោមានសេន ទិដ្ឋឹ អាវិករោតិ ។ ឥមេ ខោ ឧបាលិ បញ្ច

ឧទ្ទាន គឺបញ្ជីរឿងនៃវោហារវគ្គទី ៣ នោះដូច្នេះ

(២៩៤) និយាយអំពីភិក្ខុមិនស្គាល់អាបត្តិ ១ មិនស្គាល់អធិករណ៍ ១ និយាយសង្កត់សង្កិនគេ ១ ស្គាល់អាបត្តិ ១ មិនស្គាល់កម្ម ១ មិនស្គាល់វត្ថុ ១ មិនខ្មាសបាប ១ មិនឈ្លាស ១ មិនដឹងញត្តិ ១ មិនចេះសុត្តៈ ១ មិនចេះធម៌ ១ (ទាំងនេះ)សង្គ្រោះដោយវោហារវគ្គទី ៣ ។

(២៩៥) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការប្រាប់សេចក្ដីយល់ឃើញ (ការសំដែងអាបត្តិ) មិនប្រកបដោយធម៌ មានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ការប្រាប់សេចក្ដីយល់ឃើញមិនប្រកបដោយធម៌នេះ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុប្រាប់សេចក្ដីយល់ឃើញ ដោយមិនមានអាបត្តិ ១ ប្រាប់សេចក្ដីយល់ឃើញដោយអាបត្តិ មិនមែនជាទេសនាគាមិនី ១ ប្រាប់សេចក្ដីយល់ឃើញដោយអាបត្តិ ដែលសំដែងហើយ ១ ប្រាប់សេចក្ដីយល់ឃើញជាមួយនឹងភិក្ខុ ៤ រូប ឬ ៥ រូប ១ ប្រាប់សេចក្ដីយល់ឃើញដោយគិតតែក្នុងចិត្ត (សំដែងអាបត្តិដោយមិនបញ្ចេញវចីភេទ)១ ។ ម្នាលឧបាលិ

អដ្ឋកថា ថា ដូចភិក្ខុ ៤ រូប ឬ ៥ រូប សុទ្ធតែជាអ្នកធ្វើឲ្យជាក់ច្បាស់នូវអាបត្តិដូចគ្នាហើយ ក៏សំដែងទាំង ៤ រូប ឬ ៥ រូបនោះ ក្នុងវេលាមួយជាមួយគ្នាតែម្ដងមិនបានទេ ។ ដីកា ថាបើភិក្ខុត្រឹម ២ រូប ឬ ៣ រូប សំដែងជាមួយគ្នាបាន តែច្រើនជាងនោះមិនបាន ។

អធម្មិកា ទិដ្ឋាវិកម្មា ។ បញ្ចិមេ ឧបាលិ ធម្មិកា ទិដ្ឋាវិកម្មា ។ កតមេ បញ្ច ។ អាបត្តិយា ទិដ្ឋឹ អាវិ-ករោតិ ទេសនាគាមិនិយា អាបត្តិយា ទិដ្ឋឹ អាវិករោតិ អទេសិតាយ អាបត្តិយា ទិដ្ឋឹ អាវិករោតិ ន ចតូហិ បញ្ចហិ ទិដ្ឋឹ អាវិករោតិ ន មនោមានសេន ទិដ្ឋឹ អាវិ-ករោតិ ។ ឥមេ ខោ ឧបាលិ បញ្ច ធម្មិកា ទិដ្ឋាវិ-កម្មា ។ អបរេបិ ឧបាលិ បញ្ច អធម្មិកា ទិដ្ឋាវិកម្មា ។ កតមេ បញ្ច ។ នានាសំវាសកស្ស សន្តិកេ ទិដ្ឋឹ អាវិករោតិ នានាសីមាយ ឋិតស្ស សន្តិកេ ទិដ្ឋឹ អាវិករោតិ អបកតត្តស្ស សន្តិកេ ទិដ្ឋឹ អាវិករោតិ

ការប្រាប់សេចក្ដីយល់ឃើញ មិនប្រកបដោយធម៌ មាន ៥ យ៉ាងនេះឯង ។ ម្នាលឧបាលិ ការប្រាប់សេចក្ដីយល់ឃើញ ប្រកបដោយធម៌នេះ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុប្រាប់សេចក្ដីយល់ឃើញ ដោយមានអាបត្តិ ១ ប្រាប់សេចក្ដីយល់ឃើញដោយអាបត្តិ ជាទេសនាគាមិនី ១ ប្រាប់សេចក្ដីយល់ឃើញដោយអាបត្តិ ដែលមិនទាន់សំដែង ១ ប្រាប់សេចក្ដីយល់ឃើញ មិនមែនជាមួយនឹងភិក្ខុ ៤ រូប ឬ ៥ រូប ១ ប្រាប់សេចក្ដីយល់ឃើញ ដោយមិនបានគិតតែក្នុងចិត្ត ១ ។ ម្នាលឧបាលិ ការប្រាប់សេចក្ដីយល់ឃើញ ប្រកបដោយធម៌ មាន ៥ យ៉ាងនេះឯង ។ ម្នាលឧបាលិ ការប្រាប់សេចក្ដីយល់ឃើញ មិនប្រកបដោយធម៌ មាន ៥ យ៉ាងដទៃទៀត ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុប្រាប់សេចក្ដីយល់ឃើញ ក្នុងសំណាក់ភិក្ខុ មានសំវាសផ្សេងគ្នា ១ ប្រាប់សេចក្ដីយល់ឃើញ ក្នុងសំណាក់ភិក្ខុដែលឋិតនៅ ក្នុងសីមាផ្សេងគ្នា(១) ១ ប្រាប់សេចក្ដីយល់ឃើញ ក្នុងសំណាក់ភិក្ខុមិនមែនជាបកតត្ត ១

---

១ អដ្ឋកថាពន្យល់ថា ត្រង់ពាក្យថា ប្រាប់សេចក្ដីយល់ឃើញក្នុងសំណាក់ភិក្ខុដែលឋិតនៅក្នុងសីមាផ្សេងគ្នា នោះ គឺ ភិក្ខុសំដែងអាបត្តិក្នុងសំណាក់ភិក្ខុ ដែលមានសំវាសស្មើគ្នា តែនៅក្នុងសីមាផ្សេងគ្នា ដូចជាភិក្ខុឋិតនៅក្នុងមាឡកសីមាគឺខណ្ឌសីមា សំដែងក្នុងសំណាក់ភិក្ខុ ឋិតនៅក្នុងសីមន្តរិកក៏ ភិក្ខុឋិតនៅក្នុងសីមន្តរិកសំដែងក្នុងសំណាក់ភិក្ខុ ឋិតនៅក្នុងអវិប្បវាសសីមា គឺ មហាសីមាក្ដី មិនគួរទេ ។

ចតូហិ បញ្ចហិ ទិដ្ឋឹ អាវិករោតិ មនោមានសេន ទិដ្ឋឹ អាវិករោតិ ។ ឥមេ ខោ ឧបាលិ បញ្ច អធម្មិកា ទិដ្ឋាវិកម្មា ។ បញ្ចិមេ ឧបាលិ ធម្មិកា ទិដ្ឋាវិកម្មា ។ កតមេ បញ្ច ។ សមានសំវាសកស្ស សន្តិកេ ទិដ្ឋឹ អាវិករោតិ សមានសីមាយ ឋិតស្ស សន្តិកេ ទិដ្ឋឹ អាវិករោតិ បកតត្តស្ស សន្តិកេ ទិដ្ឋឹ អាវិករោតិ ន ចតូហិ បញ្ចហិ ទិដ្ឋឹ អាវិករោតិ ន មនោមានសេន ទិដ្ឋឹ អាវិករោតិ ។ ឥមេ ខោ ឧបាលិ បញ្ច ធម្មិកា ទិដ្ឋាវិកម្មាតិ ។

[២៥៦] កតិ នុ ខោ ភន្តេ អធម្មិកា បដិគ្គហាតិ ។ បញ្ចិមេ ឧបាលិ អធម្មិកា បដិគ្គហា ។ កតមេ បញ្ច ។ កាយេន ទីយមានំ កាយេន អប្បដិគ្គហិតំ កាយេន ទីយមានំ កាយប្បដិពទ្ធេន អប្បដិគ្គហិតំ កាយប្បដិពទ្ធេន ទីយមានំ កាយេន អប្បដិគ្គហិតំ កាយប្បដិពទ្ធេន ទីយមានំ កាយប្បដិពទ្ធេន អប្បដិគ្គហិតំ

ប្រាប់សេចក្តីយល់ឃើញជាមួយនឹងភិក្ខុ ៤ រូប ឬ ៥ រូប ១ ប្រាប់សេចក្តីយល់ឃើញដោយគិតតែក្នុងចិត្ត ១ ។ ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញមិនប្រកបដោយធម៌ មាន ៥ យ៉ាងនេះឯង ។ ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញ ប្រកបដោយធម៌នេះ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុមានសំវាសស្មើគ្នា ១ ប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុដែលឋិតនៅក្នុងសីមាជាមួយគ្នា ១ ប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុជាបកតត្ត ១ ប្រាប់សេចក្តីយល់ឃើញ មិនមែនជាមួយនឹងភិក្ខុ ៤ រូប ឬ ៥ រូប ១ ប្រាប់សេចក្តីយល់ឃើញ ដោយមិនគិតតែក្នុងចិត្ត ១ ។ ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញ ប្រកបដោយធម៌ មាន ៥ យ៉ាងនេះឯង ។

(៤៩៦) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការទទួលប្រគេនមិនប្រកបដោយធម៌ មានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ការទទួលប្រគេន មិនប្រកបដោយធម៌នេះ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺគេប្រគេនវត្ថុដោយកាយ ភិក្ខុមិនបានទទួលដោយកាយ ១ គេប្រគេនវត្ថុដោយកាយ ភិក្ខុមិនបានទទួលដោយវត្ថុជាប់នឹងកាយ ១ គេប្រគេនដោយវត្ថុជាប់នឹងកាយ ភិក្ខុមិនបានទទួលដោយកាយ ១ គេប្រគេនវត្ថុដោយវត្ថុជាប់នឹងកាយ ភិក្ខុមិនបានទទួល

និស្សគ្គិយេន ទីយមានំ កាយេន វា កាយបដិពទ្ធេន វា អប្បដិគ្គហិតំ ។ ឥមេ ខោ ឧបាលិ បញ្ច អធម្មិកា បដិគ្គហា ។ បញ្ចិមេ ឧបាលិ ធម្មិកា បដិគ្គហា ។ កតមេ បញ្ច ។ កាយេន ទីយមានំ កាយេន បដិគ្គហិតំ កាយេន ទីយមានំ កាយបដិពទ្ធេន បដិគ្គហិតំ កាយបដិពទ្ធេន ទីយមានំ កាយេន បដិគ្គហិតំ កាយបដិពទ្ធេន ទីយមានំ កាយបដិពទ្ធេន បដិគ្គហិតំ និស្សគ្គិយេន ទីយមានំ កាយេន វា កាយបដិពទ្ធេន វា បដិគ្គហិតំ ។ ឥមេ ខោ ឧបាលិ បញ្ច ធម្មិកា បដិគ្គហាតិ ។

(២៥៧) កតិ នុ ខោ ភន្តេ អនតិរិត្តាតិ ។ បញ្ចិមេ ឧបាលិ អនតិរិត្តា ។ កតមេ បញ្ច ។ អកប្បិយកតំ ហោតិ អប្បដិគ្គហិតកតំ ហោតិ អនុច្ចារិតកតំ ហោតិ

ដោយវត្ថុជាប់នឹងកាយ ១ គេប្រគេនវត្ថុដោយបោះមកឲ្យ ភិក្ខុមិនបានទទួលដោយកាយ ឬដោយវត្ថុជាប់នឹងកាយ ១ ។ ម្នាលឧបាលិ ការទទួលប្រគេនមិនប្រកបដោយធម៌ មាន ៥ យ៉ាងនេះឯង ។ ម្នាលឧបាលិ ការទទួល-ប្រគេន ប្រកបដោយធម៌នេះ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺគេប្រគេនវត្ថុដោយកាយ ភិក្ខុបានទទួលដោយកាយ ១ គេប្រគេនវត្ថុដោយកាយ ភិក្ខុបានទទួលដោយវត្ថុជាប់នឹងកាយ ១ គេប្រគេនវត្ថុដោយវត្ថុជាប់នឹងកាយ ភិក្ខុបានទទួលដោយកាយ ១ គេប្រគេនវត្ថុដោយវត្ថុជាប់នឹងកាយ ភិក្ខុបានទទួលដោយវត្ថុជាប់នឹងកាយ ១ គេប្រគេនវត្ថុដោយបោះឲ្យមក ភិក្ខុបានទទួលដោយកាយ ឬដោយវត្ថុជាប់នឹងកាយ ១ ។ ម្នាលឧបាលិ ការទទួលប្រគេនប្រកបដោយធម៌ មាន ៥ យ៉ាងនេះឯង ។

(២៥៧) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន អនតិរិត្តភោជន (ភោជនដែលភិក្ខុមិនបានធ្វើវិនយកម្ម) មានប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ អនតិរិត្តភោជននេះ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺវត្ថុដែលមិនគួរធ្វើវិនយកម្ម ១ វត្ថុដែលភិក្ខុមិនបានទទួលប្រគេនយកទៅធ្វើវិនយកម្ម ១ វត្ថុដែលភិក្ខុដទៃ មិនបានលើក

អហត្ថបាសេ កតំ ហោតិ អលមេតំ សព្វន្តិ អវុត្តំ ហោតិ ។ ឥមេ ខោ ឧបាលិ បញ្ច អនតិរិត្តា ។ បញ្ចិមេ ឧបាលិ អតិរិត្តា ។ កតមេ បញ្ច ។ កប្បិយកតំ ហោតិ បដិគ្គហិតកតំ ហោតិ ឧច្ចារិតកតំ ហោតិ ហត្ថបាសេ កតំ ហោតិ អលមេតំ សព្វន្តិ វុត្តំ ហោតិ ។ ឥមេ ខោ ឧបាលិ បញ្ច អតិរិត្តាតិ ។

(២៩៨) កតីហិ នុ ខោ ភន្តេ អាការេហិ បវារណា បញ្ញាយតីតិ ។ បញ្ចហុបាលិ អាការេហិ បវារណា បញ្ញាយតិ ។ កតមេហិ បញ្ចហិ ។ អសនំ បញ្ញាយតិ ភោជនំ បញ្ញាយតិ ហត្ថបាសេ ឋិតោ អភិហរតិ បដិក្ខេបោ បញ្ញាយតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហាការេហិ បវារណា បញ្ញាយតីតិ ។

ឡើងធ្វើវិនយកម្ម ១ វត្ថុដែលភិក្ខុមិនបានឋិតនៅក្នុងហត្ថបាសធ្វើវិនយកម្ម ១ វត្ថុដែលភិក្ខុមិនបាននិយាយថា របស់ទាំងអស់នេះគួរ ១ ៗ ម្នាលឧបាលិ អនតិរិត្តភោជន មាន ៥ យ៉ាងនេះឯង ។ ម្នាលឧបាលិ អតិរិត្តភោជន (ភោជនដែលភិក្ខុបានធ្វើវិនយកម្ម) នេះ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺវត្ថុដែលគួរធ្វើវិនយកម្ម ១ វត្ថុដែលភិក្ខុបានទទួលប្រគេនយកទៅធ្វើវិនយកម្ម ១ វត្ថុដែលភិក្ខុបានលើកឡើងធ្វើវិនយកម្ម ១ វត្ថុដែលភិក្ខុឋិតនៅក្នុងហត្ថបាសធ្វើវិនយកម្ម ១ វត្ថុដែលភិក្ខុនិយាយថា របស់ទាំងអស់នេះគួរ ១ ៗ ម្នាលឧបាលិ អតិរិត្តភោជន មាន ៥ យ៉ាងនេះឯង ។

[២៥៨] ព្រះឧបាលិទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការហាមភោជនប្រាកដដោយអាការប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ការហាមភោជនប្រាកដដោយអាការ ៥ យ៉ាង ។ អាការ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺការកំពុងឆាន់ប្រាកដ ១ ភោជនប្រាកដ ១ បុគ្គលឋិតនៅក្នុងហត្ថបាស ១ បង្អោនមកប្រគេន ១ ការហាមឃាត់ប្រាកដ ១ ៗ ម្នាលឧបាលិ ការហាមភោជនប្រាកដ ដោយអាការ ៥ យ៉ាង នេះឯង ។

(២៥៩) កតិ នុ ខោ ភន្តេ អធម្មិកា បដិញ្ញាតករណាតិ ។ បញ្ចិមេ ឧបាលិ អធម្មិកា បដិញ្ញាតករណា ។ កតមេ បញ្ច ។ ភិក្ខុ បារាជិកំ អជ្ឈាបន្នោ ហោតិ បារាជិកេន ចោទិយមានោ សង្ឃាទិសេសំ អជ្ឈាបន្នោ បដិជានាតិ តំ សង្ឃោ សង្ឃាទិសេសេន ការេតិ អធម្មិកំ បដិញ្ញាតករណំ ភិក្ខុ បារាជិកំ អជ្ឈាបន្នោ ហោតិ បារាជិកេន ចោទិយមានោ បាចិត្តិយំ បាដិទេសនីយំ ទុក្កដំ អជ្ឈាបន្នោ បដិជានាតិ តំ សង្ឃោ ទុក្កដេន ការេតិ អធម្មិកំ បដិញ្ញាតករណំ ភិក្ខុ សង្ឃាទិសេសំ បាចិត្តិយំ បាដិទេសនីយំ ទុក្កដំ អជ្ឈាបន្នោ ហោតិ ទុក្កដេន ចោទិយមានោ បារាជិកំ អជ្ឈាបន្នោ បដិជានាតិ តំ សង្ឃោ បារាជិកេន ការេតិ អធម្មិកំ បដិញ្ញាតករណំ ភិក្ខុ ទុក្កដំ អជ្ឈាបន្នោ ហោតិ ទុក្កដេន ចោទិយមានោ សង្ឃាទិសេសំ បាចិត្តិយំ បាដិទេសនីយំ អជ្ឈាបន្នោ បដិជានាតិ តំ សង្ឃោ បាដិទេសនីយេន ការេតិ អធម្មិកំ បដិញ្ញាតករណំ ។ ឥមេ ខោ

(២៤៩) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន បដិញ្ញាតករណៈ (ការកាត់អាបត្តិតាមប្តេជ្ញា) មិនប្រកបដោយធម៌មានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ បដិញ្ញាតករណៈ មិនប្រកបដោយធម៌នេះ មាន ៤ យ៉ាង ។ ៤ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកត្រូវបារាជិក ហើយគេចោទដោយបារាជិក តែប្តេជ្ញាថាត្រូវសង្ឃាទិសេសទៅវិញ សង្ឃក៏កាត់សេចក្តីភិក្ខុនោះដោយសង្ឃាទិសេស (នេះ) ជាបដិញ្ញាតករណៈមិនប្រកបដោយធម៌ ភិក្ខុជាអ្នកត្រូវបារាជិក ហើយគេចោទដោយអាបត្តិបារាជិក តែប្តេជ្ញាថាត្រូវបាចិត្តិយៈ ឬ បាដិទេសនីយៈ ឬ ទុក្កដទៅវិញ សង្ឃកាត់សេចក្តីភិក្ខុនោះដោយទុក្កដ (នេះ) ជាបដិញ្ញាតករណៈមិនប្រកបដោយធម៌ ភិក្ខុជាអ្នកត្រូវអាបត្តិសង្ឃាទិសេស ឬ បាចិត្តិយៈ ឬ បាដិទេសនីយៈ ឬទុក្កដ ហើយគេចោទដោយទុក្កដ តែប្តេជ្ញាថាត្រូវបារាជិកទៅវិញ សង្ឃបានកាត់សេចក្តីភិក្ខុនោះដោយបារាជិក (នេះ) ជាបដិញ្ញាតករណៈ មិនប្រកបដោយធម៌ ភិក្ខុជាអ្នកត្រូវទុក្កដ ហើយគេចោទដោយទុក្កដ តែប្តេជ្ញាថាត្រូវសង្ឃាទិសេស ឬ បាចិត្តិយៈ ឬ បាដិទេសនីយៈទៅវិញ សង្ឃបានកាត់សេចក្តីភិក្ខុនោះដោយបាដិទេសនីយៈ (នេះ) ជាបដិញ្ញាតករណៈ មិនប្រកបដោយធម៌ ។ ម្នាលឧបាលិ

ឧបាលិ បញ្ច អធម្មិកា បដិញ្ញាតករណា ។ បញ្ចិមេ ឧបាលិ ធម្មិកា បដិញ្ញាតករណា ។ កតមេ បញ្ច ។ ភិក្ខុ បារាជិកំ អជ្ឈាបន្នោ ហោតិ បារាជិកេន ចោទិយមានោ បារាជិកំ អជ្ឈាបន្នោ បដិជានាតិ តំ សង្ឃោ បារាជិកេន ការេតិ ធម្មិកំ បដិញ្ញាតករណំ ភិក្ខុ សង្ឃាទិសេសំ បាចិត្តិយំ បាដិទេសនីយំ ទុក្កដំ អជ្ឈាបន្នោ ហោតិ ទុក្កដេន ចោទិយមានោ ទុក្កដំ អជ្ឈាបន្នោ បដិជានាតិ តំ សង្ឃោ ទុក្កដេន ការេតិ ធម្មិកំ បដិញ្ញាតករណំ ។ ឥមេ ខោ ឧបាលិ បញ្ច ធម្មិកា បដិញ្ញាតករណាតិ ។

[២៦០] កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសកម្មំ ការាបេន្តស្ស នាលំ ឱកាសកម្មំ កាតុន្តិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសកម្មំ ការាបេន្តស្ស នាលំ ឱកាសកម្មំ កាតុំ ។ កតមេហិ បញ្ចហិ ។ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច

បដិញ្ញាតករណៈមិនប្រកបដោយធម៌ មាន ៤ យ៉ាង នេះឯង ។ ម្នាលឧបាលិ បដិញ្ញាតករណៈ ប្រកបដោយធម៌នេះ មាន ៤ យ៉ាង ។ ៤ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកត្រូវបារាជិក ហើយគេចោទដោយបារាជិក ក៏ប្តេជ្ញាថាត្រូវបារាជិកមែន សង្ឃបានកាត់សេចក្តីភិក្ខុដោយបារាជិក (នេះ) ជាបដិញ្ញាតករណៈប្រកបដោយធម៌ ភិក្ខុជាអ្នកត្រូវសង្ឃាទិសេស ឬបាចិត្តិយៈ ឬ បាដិទេសនីយៈ ឬទុក្កដ ហើយគេចោទដោយទុក្កដ ក៏ប្តេជ្ញាថាត្រូវទុក្កដមែន សង្ឃក៏បានកាត់សេចក្តីភិក្ខុនោះដោយទុក្កដ (នេះ) ជាបដិញ្ញាតករណៈប្រកបដោយធម៌ ។ ម្នាលឧបាលិ បដិញ្ញាតករណៈប្រកបដោយធម៌ មាន ៤ យ៉ាងនេះឯង ។

(៤៦០) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន កាលបើសូមឧកាសកម្ម (ដើម្បីចោទ) មិនគួរភិក្ខុដទៃបើកឧកាសកម្មឡើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៤ កាលបើសូមឧកាសកម្ម មិនគួរភិក្ខុដទៃបើកឧកាសកម្មឡើយ ។ អង្គ ៤ គឺអ្វីខ្លះ ។ គឺភិក្ខុមិនមានសេចក្តីខ្មាសបាប ១ ជាភិក្ខុល្ងង់ ១ ជាភិក្ខុមិនមែនជាបកតត្ត ១ ជាភិក្ខុនិយាយ

ចាវនាធិប្បាយោ វត្តា ហោតិ នោ វុឌ្ឍាធិប្បាយោ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសកម្មំ ការាបេន្តស្ស នាលំ ឱកាសកម្មំ កាតុំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសកម្មំ ការាបេន្តស្ស អលំ ឱកាសកម្មំ កាតុំ ។ កតមេហិ បញ្ចហិ ។ លជ្ជី ច ហោតិ បណ្ឌិតោ ច បកតត្តោ ច វុឌ្ឍាធិប្បាយោ វត្តា ហោតិ នោ ចាវនាធិប្បាយោ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសកម្មំ ការាបេន្តស្ស អលំ ឱកាសកម្មំ កាតុន្តិ ។

(២៦១) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធិំ វិនយោ ន សាកច្ឆាតព្វោតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធិំ វិនយោ ន សាកច្ឆាតព្វោ ។ កតមេហិ បញ្ចហិ ។ វត្ថុំ ន ជានាតិ និទានំ ន ជានាតិ បញ្ញត្តិំ ន ជានាតិ បទបច្ឆាភដ្ឋំ ន ជានាតិ អនុសន្ធិវចនបថំ ន ជានាតិ ។ ឥមេហិ ខោ

ដោយប្រាថ្នាដើម្បីឲ្យភិក្ខុដទៃឃាត (ចាកសាសនា)១ មិនប្រាថ្នានឹងចេញចាកអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង កាលបើសូមឧកាសកម្ម មិនគួរភិក្ខុដទៃបើកឧកាសកម្មឲ្យទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ កាលបើសូមឧកាសកម្ម ទើបគួរភិក្ខុដទៃបើកឧកាសកម្មឲ្យ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមានសេចក្ដីខ្មាសបាប ១ ជាបណ្ឌិត ១ ជាភិក្ខុបកតត្ត ១ ជាភិក្ខុនិយាយដោយប្រាថ្នាឲ្យភិក្ខុដទៃចេញចាកអាបត្តិ ១ មិនប្រាថ្នាឲ្យភិក្ខុដទៃឃាត (ចាកសាសនា)១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ នេះឯង កាលបើសូមឧកាសកម្ម ទើបគួរភិក្ខុដទៃបើកឧកាសកម្មឲ្យបាន ។

(៤៦១) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលភិក្ខុដទៃមិនគួរសាកច្ឆាវិន័យជាមួយផង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ភិក្ខុដទៃមិនគួរសាកច្ឆាវិន័យជាមួយផងទេ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនដឹងវត្ថុ ១ មិនដឹងនិទាន ១ មិនដឹងបញ្ញត្តិ ១ មិនដឹងបទបាលិក្រោយមុខ ១ មិនដឹងគន្លងពាក្យដែលជាប់គ្នា ១ ។ ម្នាលឧបាលិ

ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វិនយោ ន សាកច្ឆាតព្វោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វិនយោ សាកច្ឆាតព្វោ ។ កតមេហិ បញ្ចហិ ។ វត្ថុំ ជានាតិ និទានំ ជានាតិ បញ្ញត្តឹ ជានាតិ បទបច្ចាភដ្ឋំ ជានាតិ អនុសន្ធិវចនបថំ ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សង្ឃេ វិនយោ សាកច្ឆាតព្វោតិ ។

(២៦២) កតិ នុ ខោ ភន្តេ បញ្ហាបុច្ឆាតិ ។ បញ្ចិមា ឧបាលិ បញ្ហាបុច្ឆា ។ កតមា បញ្ច ។ មន្ទត្តា មោមូហត្តា បញ្ហំ បុច្ឆតិ បាបិច្ឆោ ឥច្ឆាបកតោ បញ្ហំ បុច្ឆតិ បរិភវា បញ្ហំ បុច្ឆតិ អញ្ញាតុកាមោ បញ្ហំ បុច្ឆតិ សចេ មេ បញ្ហំ បុដ្ឋោ សម្មទេវ ព្យាករិស្សតិ ឥច្ចេតំ កុសលំ នោ ចេ មេ បញ្ហំ បុដ្ឋោ សម្មទេវ ព្យាករិស្សតិ អហមស្ស សម្មទេវ ព្យាករិស្សាមីតិ បញ្ហំ បុច្ឆតិ ។ ឥមា ខោ ឧបាលិ បញ្ច បញ្ហាបុច្ឆាតិ ។ កតិ

ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនគួរភិក្ខុដទៃសាកច្ឆាជាមួយផងទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួរភិក្ខុដទៃសាកច្ឆាវិន័យជាមួយផងបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងវត្ថុ ១ ដឹងនិទាន ១ ដឹងបញ្ញត្តិ ១ ដឹងបទបាលីក្រោយមុន ១ ដឹងគន្លងពាក្យដែលជាប់តគ្នា ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង គួរភិក្ខុដទៃសាកច្ឆាវិន័យជាមួយផងបាន ។

(៤៦៤) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការសួរប្រស្នា មានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ការសួរប្រស្នានេះ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺបុគ្គលសួរប្រស្នាដោយសេចក្តីល្ងង់វង្វេង ១ បុគ្គលមានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ សួរប្រស្នា ១ បុគ្គលសួរប្រស្នាដោយសេចក្តីមើលងាយគេ ១ បុគ្គលសួរប្រស្នាដោយសេចក្តីចង់ដឹងច្បាស់ ១ បុគ្គលសួរប្រស្នាដោយគិតថា បើអាត្មាអញសួរប្រស្នាទៅហើយ គេអាចនឹងដោះស្រាយឲ្យច្បាស់លាស់បាន នេះក៏ជាការស្រួល បើអាត្មាអញសួរប្រស្នាទៅហើយ គេមិនអាចនឹងដោះស្រាយឲ្យច្បាស់លាស់បានទេ អាត្មាអញនឹងដោះស្រាយឲ្យច្បាស់លាស់ ដល់បុគ្គលនោះវិញ ១ ។ ម្នាលឧបាលិ ការសួរប្រស្នា មាន ៥ យ៉ាងនេះឯង ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា

នុ ខោ ភន្តេ អញ្ញព្យាករណាតិ ។ បញ្ចិមេ ឧបាលិ
អញ្ញព្យាករណា ។ កតមេ បញ្ច ។ មន្ទត្តា មោមូហត្តា
អញ្ញំ ព្យាករោតិ បាបិច្ឆោ ឥច្ឆាបកតោ អញ្ញំ ព្យាក-
រោតិ ឧម្មាទា ចិត្តក្ខេបា អញ្ញំ ព្យាករោតិ អធិមា-
នេន អញ្ញំ ព្យាករោតិ សម្មា អញ្ញំ ព្យាករោតិ ។
ឥមេ ខោ ឧបាលិ បញ្ច អញ្ញព្យាករណាតិ ។

(២៦៣) កតិ នុ ខោ ភន្តេ វិសុទ្ធិយោតិ ។ បញ្ចិមា
ឧបាលិ វិសុទ្ធិយោ ។ កតមា បញ្ច ។ និទានំ ឧទ្ទិ-
សិត្វា អវសេសំ សុតេន សាវេតព្វំ អយំ បឋមា វិសុទ្ធិ ។
និទានំ ឧទ្ទិសិត្វា ចត្តារិ បារាជិកានិ ឧទ្ទិសិត្វា អ-
វសេសំ សុតេន សាវេតព្វំ អយំ ទុតិយា វិសុទ្ធិ ។ និទានំ
ឧទ្ទិសិត្វា ចត្តារិ បារាជិកានិ ឧទ្ទិសិត្វា តេរស សង្ឃា-
ទិសេសេ ឧទ្ទិសិត្វា អវសេសំ សុតេន សាវេតព្វំ អយំ
តតិយា វិសុទ្ធិ ។ និទានំ ឧទ្ទិសិត្វា ចត្តារិ បារាជិកានិ
ឧទ្ទិសិត្វា តេរស សង្ឃាទិសេសេ ឧទ្ទិសិត្វា ទ្វេ
អនិយតេ ឧទ្ទិសិត្វា អវសេសំ សុតេន សាវេតព្វំ

បពិត្រព្រះអង្គដ៏ចំរើន ការប្រាប់អរហត្តផល មានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ការប្រាប់អរហត្តផលនេះ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុប្រាប់អរហត្តផល ព្រោះសេចក្ដីល្ងង់វង្វេង ១ ភិក្ខុមានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីប្រាថ្នាគ្របសង្កត់ប្រាប់អរហត្តផល ១ ភិក្ខុប្រាប់អរហត្តផល ដោយឆ្កួតអណ្ដែតអណ្ដូងចិត្ត ១ ភិក្ខុប្រាប់អរហត្តផល ដោយសេចក្ដីស្មានខុស ១ ភិក្ខុប្រាប់អរហត្តផលដែលពិតត្រង់ ១ ។ ម្នាលឧបាលិ ការប្រាប់អរហត្តផល មាន ៥ យ៉ាងនេះឯង ។

(២៦៣) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន វិសុទ្ធិមានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ វិសុទ្ធិនេះ មាន ៥ យ៉ាង ។ វិសុទ្ធិ៥យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុត្រូវសំដែងនូវនិទាន ហើយសូត្រនូវឧទ្ទេសដ៏សេស ដោយសុតបទ នេះជាវិសុទ្ធិ ទី ១ ។ ភិក្ខុសំដែងនូវនិទាន ហើយត្រូវសំដែងបារាជិកទាំង ៤ ហើយសូត្រនូវឧទ្ទេសដ៏សេស ដោយសុតបទ នេះជាវិសុទ្ធិ ទី ២ ។ ភិក្ខុសំដែងនូវនិទានហើយ សំដែងនូវបារាជិកទាំង ៤ សំដែងនូវសង្ឃាទិសេសទាំង១៣ ហើយសូត្រនូវឧទ្ទេសដ៏សេស ដោយសុតបទ នេះជាវិសុទ្ធិ ទី ៣ ។ ភិក្ខុសំដែងនូវនិទាន សំដែងនូវបារាជិកទាំង ៤ សំដែងនូវសង្ឃាទិសេសទាំង ១៣ សំដែងនូវអនិយតទាំង ២ ហើយសូត្រនូវឧទ្ទេសដ៏សេស ដោយសុតបទ

អយំ ចតុត្ថា វិសុទ្ធិ ។ វិត្ថារេនេវ បញ្ចមី ។ ឥមា ខោ ឧបាលិ បញ្ច វិសុទ្ធិយោតិ ។

(២៦៤) កតិ នុ ខោ ភន្តេ ភោជនានិ ។ បញ្ចិមេ ឧបាលិ ភោជនា ។ កតមេ បញ្ច ។ ឱទនោ កុម្មា-សោ សត្តុ មច្ឆោ មំសំ ។ ឥមេ ខោ ឧបាលិ បញ្ច ភោជនានិ ។

ទិដ្ឋាវិកម្មវគ្គោ ចតុត្ថោ ។

តស្សុទ្ទានំ

(២៦៥) ទិដ្ឋាវិកម្មា អបរេ
បដិគ្គហោ អតិរិត្តា
បវារណា បដិញ្ញាតំ
ឱកាសំ សាកច្ឆេន ច
បញ្ហំ អញ្ញព្យាករណា
វិសុទ្ធិ ចាបិ ភោជនាតិ ។

នេះជាវិសុទ្ធិ ទី ៤ ។ វិសុទ្ធិ ទី ៥ ភិក្ខុត្រូវសំដែងដោយពិស្ដារ ។ ម្នាលឧបាលិ វិសុទ្ធិ មាន ៥ យ៉ាងនេះឯង ។

(២៦៤) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភោជនមានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភោជននេះមាន ៥ យ៉ាង ។ ភោជន ៥ យ៉ាង គឺអ្វីខ្លះ ។ គឺបាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ម្នាលឧបាលិ ភោជនមាន ៥ យ៉ាងនេះឯង ។

ចប់ ទិដ្ឋាវិកម្មវគ្គ ទី ៤ ។

ឧទ្ទាន គឺបញ្ជីរឿងនៃទិដ្ឋាវិកម្មវគ្គនោះ ដូច្នេះ

(២៦៥) និយាយអំពីសេចក្ដីយល់ឃើញ (សំដែងអាបត្តិ) ១ សេចក្ដីយល់ឃើញដទៃទៀត ១ ទទួលប្រគេន ១ អតិរិត្ត-ភោជន ១ ការហាមភោជន ១ កាត់អាបត្តិតាមបច្ចា ១ ការសូមឱកាស ១ សាកច្ឆាវិន័យ ១ សួរប្រស្នា ១ ប្រាប់អរហត្តផល ១ វិសុទ្ធិ ១ ភោជន ១ ។

[៤៦៦] ចោទកេន ភន្តេ ភិក្ខុនា បរំ ចោទេតុកាមេន កតិ ធម្មេ អជ្ឈត្តំ បច្ចវេក្ខិត្វា បរោ ចោទេតព្វោតិ ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន បញ្ច ធម្មេ អជ្ឈត្តំ បច្ចវេក្ខិត្វា បរោ ចោទេតព្វោ ។ កតមេ បញ្ច ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ បរិសុទ្ធកាយសមាចារោ នុ ខោម្ហិ បរិសុទ្ធេនម្ហិ(១) កាយសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ នោ ចេ ឧបាលិ ភិក្ខុ បរិសុទ្ធកាយសមាចារោ ហោតិ បរិសុទ្ធេន កាយសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា កាយិកំ សិក្ខស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។ បុន ចបរំ ឧបាលិ ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ បរិសុទ្ធវចីសមាចារោ នុ ខោម្ហិ បរិសុទ្ធេនម្ហិ វចីសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន

---

១ បរិសុទ្ធេន ។

(២៦៦) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ប៉ុន្មានយ៉ាង ទុកក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ ៥ យ៉ាង ទុកក្នុងខ្លួន ហើយសឹមចោទភិក្ខុដទៃ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញជាអ្នកមានកាយសមាចារបរិសុទ្ធហើយឬ អាត្មាអញប្រកបដោយកាយសមាចារបរិសុទ្ធ មិនដុះដាល មិនមានហេតុគួរឲ្យគេចាប់ថ្នាក់បាន ធម៌នុ៎ះ មានដល់អាត្មាអញដែរឬ ឬក៏មិនមានទេ ។ ម្នាលឧបាលិ បើភិក្ខុមិនមានកាយសមាចារបរិសុទ្ធ មិនប្រកបដោយកាយសមាចារបរិសុទ្ធ មិនប្រកបដោយកាយសមាចារមិនដុះដាល មិនប្រកបដោយកាយសមាចារដែលមិនមានហេតុគួរឲ្យគេចាប់ថ្នាក់បានទេ គង់មានអ្នកផងនិយាយដះតៀនភិក្ខុនោះបានថា នែលោកមានអាយុ ចូរលោកសិក្សាកាយកម្មសិន រមែងមានអ្នកផងនិយាយដះតៀនដល់ភិក្ខុនោះដូច្នេះ ១ ។ ម្នាលឧបាលិ អង្គដទៃទៀត គឺភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញជាអ្នកមានវចីសមាចារបរិសុទ្ធហើយឬ អាត្មាអញប្រកបដោយវចីសមាចារបរិសុទ្ធ មិនដុះដាល មិនមានហេតុគួរឲ្យគេចាប់ថ្នាក់បាន

សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ នោ ចេ ឧបាលិ ភិក្ខុ បរិសុទ្ធវចីសមាចារោ ហោតិ បរិសុទ្ធេន វចីសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា វាចសិកំ សិក្ខស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។ បុន ចបរំ ឧបាលិ ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ មេត្តំ នុ ខោ មេ ចិត្តំ បច្ចុបដ្ឋិតំ ស-ព្រហ្មចារីសុ អនាឃាតំ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ នោ ចេ ឧបាលិ ភិក្ខុនោ មេត្តំ ចិត្តំ(១) បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អនាឃាតំ តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា សព្រហ្មចារីសុ មេត្តំ ចិត្តំ ឧបដ្ឋាបេហីតិ ឥតិស្ស ភវន្តិ វត្តារោ ។ បុន ចបរំ ឧបាលិ ចោទកេន ភិក្ខុនា បរំ ចោទេ-តុកាមេន ឯវំ បច្ចវេក្ខិតព្វំ ពហុស្សុតោ នុ ខោម្ហិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្-ល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា

---

១ ឱ. មេត្តចិត្ត ។

ធម៌នុ៎ះមានដល់អាត្មាអញដែរឬ ឬក៏មិនមានទេ ។ ម្នាលឧបាលិ បើភិក្ខុមិនមានវចីសមាចារបរិសុទ្ធ មិនប្រកបដោយវចីសមាចារបរិសុទ្ធ មិនប្រកបដោយវចីសមាចារមិនធ្លុះធ្លាយ មិនប្រកបដោយវចីសមាចារមិនមានហេតុគួរឲ្យគេចាប់ថ្នាក់បាន គង់មានអ្នកផងនិយាយដះតៀនភិក្ខុនោះថា លោកមានអាយុ ចូរលោកសិក្សាវចីកម្មសិន រមែងមានអ្នកផងនិយាយដះតៀនដល់ភិក្ខុនោះដូច្នេះ១ ។ ម្នាលឧបាលិ អង្គដទៃទៀត គឺភិក្ខុអ្នកចោទ ប៉ន៍នឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា ចិត្តរបស់អាត្មាអញប្រកបដោយមេត្តាតម្កល់ចំពោះ មិនមានគំនុំក្នុងពួកសព្រហ្មចារីបុគ្គល ធម៌នុ៎ះមានដល់អាត្មាអញដែរឬ ឬក៏មិនមានទេ ។ ម្នាលឧបាលិ បើចិត្តប្រកបដោយមេត្តាតម្កល់ចំពោះ ជាចិត្តមិនមានគំនុំក្នុងពួកសព្រហ្មចារីបុគ្គល មិនមានដល់ភិក្ខុនោះទេ គង់មានអ្នកផងនិយាយដះតៀនភិក្ខុនោះថា នែលោកមានអាយុ ចូរលោកតាំងមេត្តាចិត្ត ក្នុងពួកសព្រហ្មចារីបុគ្គលសិន រមែងមានអ្នកផងនិយាយដះតៀនដល់ភិក្ខុនោះដូច្នេះ ១ ។ ម្នាលឧបាលិ អង្គដទៃទៀត គឺ ភិក្ខុអ្នកចោទ ប៉ន៍នឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញជាពហុស្សុត ជាអ្នកទ្រទ្រង់ពុទ្ធវចនៈ ជាអ្នកសន្សំពុទ្ធវចនៈហើយឬ ធម៌ទាំងឡាយណា មានពីរោះដើមបទ ពីរោះកណ្តាលបទ ពីរោះចុងបទ

សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មច-
រិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា(១)
ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្ប-
ដិវិទ្ធា សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ
នោតិ ។ នោ ចេ ឧបាលិ ភិក្ខុ ពហុស្សុតោ
ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិ-
កល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា
សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ
អភិវទន្តិ តថារូបាស្ស ធម្មា ន ពហុស្សុតា ហោន្តិ ធតា
វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា
តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា អាគមំ បរិយា-
បុណស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។ បុន ចបរំ ឧបាលិ
ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិ-
តព្វំ ឧភយានិ ខោ មេ បាតិមោក្ខានិ វិត្ថារេន
ស្វាគតានិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ
អនុព្យញ្ជនសោ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ

---

១ ឯត្ថន្តរេ ហោន្តីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ប្រកាសព្រហ្មចរិយៈដ៏បរិសុទ្ធបរិបូណ៌សព្វគ្រប់ ទាំងអត្ថទាំងព្យញ្ជនៈ ធម៌ទាំងឡាយមានសភាពដូច្នោះ អាត្មាអញបានស្ដាប់ច្រើន បានទ្រទ្រង់ ចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ យល់ធ្លុះធ្លាយដោយទិដ្ឋិ គឺបញ្ញា ធម៌នុ៎ះមានដល់អាត្មាអញដែរឬ ឬក៏មិនមានទេ ។ ម្នាលឧបាលិ បើភិក្ខុមិនមែនជាពហុស្សុត អ្នកទ្រទ្រង់នូវបទៈ អ្នកសន្សំនូវបទៈទេ ធម៌ទាំងឡាយណា ដែលមានពីរោះដើមបទ ពីរោះកណ្ដាលបទ ពីរោះចុងបទ ប្រកាសព្រហ្មចរិយៈដ៏បរិសុទ្ធបរិបូណ៌សព្វគ្រប់ ទាំងអត្ថទាំងព្យញ្ជនៈ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះមិនបានស្ដាប់ច្រើន មិនទ្រទ្រង់ មិនចាំស្ទាត់រត់មាត់ មិនចូលចិត្តច្បាស់លាស់ មិនយល់ធ្លុះធ្លាយដោយទិដ្ឋិគឺបញ្ញាទេ គង់មានអ្នកផងនិយាយដាស់តឿនភិក្ខុនោះថា នែលោកមានអាយុ ចូរលោករៀនគម្ពីរនិកាយសិន រមែងមានអ្នកផងនិយាយដាស់តឿនដល់ភិក្ខុនោះដូច្នោះ ១ ។ ម្នាលឧបាលិ ក្រៅអំពីនេះទៀត គឺភិក្ខុអ្នកចោទ បំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា បាតិមោក្ខទាំងពីរ អាត្មាអញបានស្ដាប់ដោយពិស្ដារល្អ បានចែកបទភាជនៈដោយប្រពៃ បានចាំស្ទាត់រត់មាត់ដោយប្រពៃ បានកាត់សេចក្ដីដោយល្អ តាមសុត្តៈ គឺខន្ធកៈនិងបរិវារៈ តាមអនុព្យញ្ជនៈ គឺអក្ខរៈនិងបទ ធម៌នុ៎ះមានដល់អាត្មាអញដែរឬ

នោតិ ។ នោ ចេ ឧបាលិ ភិក្ខុនោ ឧភយានិ បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ ឥទំ បនាវុសោ កត្ថ វុត្តំ ភគវតាតិ ឥតិ បុដ្ឋោ ន សម្បាទេតិ[១] តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា វិនយំ បរិយាបុណស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ បច្ចវេក្ខិត្វា បរោ ចោទេតព្វោតិ ។

(២៦៧) ចោទកេន ភន្តេ ភិក្ខុនា បរំ ចោទេតុកាមេន កតិ ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរោ ចោទេតព្វោតិ ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរោ ចោទេតព្វោ ។ កតមេ បញ្ច ។ កាលេន វក្ខាមិ នោ អកាលេន

១ ម. ន សម្បាយតិ ។

ឬក៏មិនមានទេ ។ ម្នាលឧបាលិ បើបាតិមោក្ខទាំងពីរ ភិក្ខុមិនបានចេះចាំដោយពិស្តារ មិនបានចែកបទភាជនៈដោយល្អ មិនបានចាំស្ទាត់រត់មាត់ដោយល្អ មិនបានកាត់សេចក្តីដោយល្អ តាមសុត្តៈនឹងអនុព្យញ្ជនៈទេ កាលបើមានគេសួរថា នែលោកមានអាយុ ចុះពាក្យនេះព្រះមានព្រះភាគទ្រង់សំដែងក្នុងទីណា ភិក្ខុនោះឆ្លើយមិនរួច គង់មានអ្នកផងនិយាយដេះតឿនភិក្ខុនោះថា នែលោកមានអាយុ ចូរលោករៀនវិន័យសិន រមែងមានអ្នកផងនិយាយដេះតឿន ដល់ភិក្ខុនោះដូច្នេះ ១ ។ ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ ៥ យ៉ាងនេះក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន ។

(២៦៧) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវតាំងធម៌ប៉ុន្មានយ៉ាង ក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវតាំងធម៌ ៥ យ៉ាងក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន ។ ធម៌ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុត្រូវតាំងក្នុងដូច្នេះថា អាត្មាអញនឹងនិយាយក្នុងកាលគួរ មិននិយាយក្នុងកាលមិនគួរ ១

ភូតេន វក្ខាមិ នោ អភូតេន សណ្ហេន វក្ខាមិ នោ ផរុសេន អត្ថសញ្ហិតេន វក្ខាមិ នោ អនត្ថសញ្ហិតេន មេត្តចិត្តោ វក្ខាមិ នោ ទោសន្តរោតិ ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរោ ចោទេតព្វោតិ ។

(២៦៨) ចោទកេន ភន្តេ ភិក្ខុនា បរំ ចោទេតុកាមេន កតិ ធម្មេ អជ្ឈត្តំ មនសិករិត្វា បរោ ចោទេតព្វោតិ ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន បញ្ច ធម្មេ អជ្ឈត្តំ មនសិករិត្វា បរោ ចោទេតព្វោ ។ កតមេ បញ្ច ។ ការុញ្ញតា ហិតេសិតា អនុកម្បិតា អាបត្តិវុដ្ឋានតា វិនយបុរេក្ខារតា ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ មនសិករិត្វា បរោ ចោទេតព្វោតិ ។

អាត្មាអញនឹងនិយាយពាក្យពិត មិននិយាយពាក្យមិនពិត ១ អាត្មាអញនឹងនិយាយពាក្យផ្អែមល្ហែម មិននិយាយពាក្យគ្រគោះ ១ អាត្មាអញនឹងនិយាយពាក្យប្រកបដោយប្រយោជន៍ មិននិយាយពាក្យឥតប្រយោជន៍ ១ អាត្មាអញនឹងមានចិត្តប្រកបដោយមេត្តាទើបនិយាយ មិននិយាយទៅតាំងចិត្តប្រកបដោយសេចក្តីប្រទូស្ត ១ ។ ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវតាំងធម៌ ៥ យ៉ាងនេះឯងទុកក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន ។

(២៦៨) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌ប៉ុន្មានយ៉ាងក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌ ៥ យ៉ាងក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីករុណា ១ ការស្វែងរកប្រយោជន៍ ១ សេចក្តីអនុគ្រោះ ១ ការចេញចាកអាបត្តិ ១ សេចក្តីប្រុងប៉ងក្នុងវិន័យ ១ ។ ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌ ៥ យ៉ាងនេះឯង ទុកក្នុងខ្លួនហើយទើបចោទភិក្ខុដទៃបាន ។

(៥៦៩) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសកម្មំ ការាបេន្តស្ស នាលំ ឱកាសកម្មំ កាតុន្តិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសកម្មំ ការាបេន្តស្ស នាលំ ឱកាសកម្មំ កាតុំ ។ កតមេហិ បញ្ចហិ ។ អបរិសុទ្ធកាយសមាចារោ ហោតិ អបរិសុទ្ធវចីសមាចារោ ហោតិ អបរិសុទ្ធាជីវោ ហោតិ ពាលោ ហោតិ អព្យត្តោ នបដិពលោ អនុយុញ្ជិយមានោ អនុយោគំ ទាតុំ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសកម្មំ ការាបេន្តស្ស នាលំ ឱកាសកម្មំ កាតុំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសកម្មំ ការាបេន្តស្ស អលំ ឱកាសកម្មំ កាតុំ ។ កតមេហិ បញ្ចហិ ។ បរិសុទ្ធកាយសមាចារោ ហោតិ បរិសុទ្ធវចីសមាចារោ ហោតិ បរិសុទ្ធាជីវោ ហោតិ បណ្ឌិតោ ហោតិ ព្យត្តោ បដិពលោ អនុយុញ្ជិយមានោ

(៦៦៩) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន កាលបើសូមឧកាសកម្ម ក៏មិនគួរភិក្ខុដទៃបើកឧកាសកម្មឲ្យ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ កាលបើសូមឧកាសកម្ម ក៏មិនគួរភិក្ខុដទៃបើកឧកាសកម្មឲ្យ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមានកាយសមាចារមិនបរិសុទ្ធ ១ មានវចីសមាចារមិនបរិសុទ្ធ ១ មានអាជីវៈមិនបរិសុទ្ធ ១ ជាភិក្ខុល្ងង់មិនឈ្លាសវៃ ១ កាលបើគេសាកសួរ ក៏មិនអាចនឹងឲ្យគេសាកសួរ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ នេះឯង កាលបើសូមឧកាសកម្ម ក៏មិនគួរភិក្ខុដទៃបើកឧកាសកម្មឲ្យ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ កាលបើសូមឧកាសកម្ម ក៏គួរភិក្ខុដទៃ បើកឧកាសកម្មឲ្យបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមានកាយសមាចារបរិសុទ្ធ ១ មានវចីសមាចារបរិសុទ្ធ ១ មានអាជីវៈបរិសុទ្ធ ១ ជាបណ្ឌិតឈ្លាសវៃ ១ កាលបើគេសាកសួរ ក៏អាច

អនុយោគំ ទាតុំ ។ កតមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ឱកាសកម្មំ ការាបេន្តស្ស អលំ ឱកាសកម្មំ កាតុន្តិ ។

(២៧០) អត្តាទានំ អាទាតុកាមេន ភន្តេ ភិក្ខុនា កតីហិ អង្គេហិ សមន្នាគតំ អត្តាទានំ អាទាតព្វន្តិ ។ អត្តាទានំ អាទាតុកាមេនុបាលិ ភិក្ខុនា បញ្ចហង្គេហិ សមន្នាគតំ អត្តាទានំ អាទាតព្វំ ។ កតមេហិ បញ្ចហិ ។ អត្តាទានំ អាទាតុកាមេនុបាលិ ភិក្ខុនា ឯវំ បច្ចវេក្ខិតព្វំ យំ ខោ អហំ ឥមំ អត្តាទានំ អាទាតុកាមោ កាលោ នុ ខោ ឥមំ អត្តាទានំ អាទាតុំ ឧទាហុ នោតិ ។ សចេ ឧបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អកាលោ ឥមំ អត្តាទានំ អាទាតុំ នោ កាលោតិ ន តំ ឧបាលិ អត្តាទានំ អាទាតព្វំ ។ សចេ បនុបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ កាលោ ឥមំ អត្តាទានំ អាទាតុំ នោ អកាលោតិ

ឲ្យគេសាកសួរបាន ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង កាលបើសូមឱកាសកម្ម ក៏គួរភិក្ខុដទៃបើកឱកាសកម្មឲ្យបាន ។

(២៧០) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រាថ្នានឹងកាន់យកនូវអត្តាទាន ត្រូវកាន់យកនូវអត្តាទាន ដែលប្រកបដោយអង្គប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រាថ្នានឹងកាន់យកនូវអត្តាទាន ត្រូវកាន់យកនូវអត្តាទាន ដែលប្រកបដោយអង្គ ៥ ។ អង្គ៥ គឺអ្វីខ្លះ ។ ម្នាលឧបាលិ ភិក្ខុប្រាថ្នានឹងកាន់យកនូវអត្តាទាន ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញប្រាថ្នានឹងកាន់យកនូវអត្តាទាននេះ ក្នុងកាលណា កាលនោះ ជាកាលគួរនឹងកាន់យកនូវអត្តាទាននេះ ឬមិនគួរទេ ។ ម្នាលឧបាលិ បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា កាលនេះជាកាលមិនគួរនឹងកាន់យកនូវអត្តាទាននេះ កាលនេះ មិនមែនជាកាលគួរទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ ។ ម្នាលឧបាលិ ម្យ៉ាងទៀត បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា កាលនេះជាកាលគួរនឹងកាន់យកនូវអត្តាទាននេះ កាលនេះមិនមែនជាកាលមិនគួរទេ ម្នាល

---

១ អដ្ឋកថា នឹងដីកាបាតិមោក្ខវិបទក្ខទក: ពន្យល់ថា ភិក្ខុមានប្រាថ្នាដើម្បីជម្រះសាសនាឲ្យស្អាតល្អ ហើយការយកនូវអធិករណ៍ណាមួយដោយខ្លួនឯង ដើម្បីចោទភិក្ខុដទៃ អធិករណ៍នោះ ហៅថា អត្តាទាន ។

តេនុបាលិ ភិក្ខុនា ឧត្តរិ បច្ចវេក្ខិតព្ពំ យំ ខោ អហំ ឥមំ អត្តាទានំ អាទាតុកាមោ ភូតំ នុ ខោ ឥទំ អត្តាទានំ ឧទាហុ នោតិ ។ សចេ ឧបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អភូតំ ឥទំ អត្តាទានំ នោ ភូតន្តិ ន តំ ឧបាលិ អត្តាទានំ អាទាតព្ពំ ។ សចេ បនុបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ភូតំ ឥទំ អត្តាទានំ នោ អភូតន្តិ តេនុបាលិ ភិក្ខុនា ឧត្តរិ បច្ចវេក្ខិតព្ពំ យំ ខោ អហំ ឥមំ អត្តាទានំ អាទាតុកាមោ អត្ថសញ្ហិតំ នុ ខោ ឥទំ អត្តាទានំ ឧទាហុ នោតិ ។ សចេ ឧបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អនត្ថសញ្ហិតំ ឥទំ អត្តាទានំ នោ អត្ថសញ្ហិតន្តិ ន តំ ឧបាលិ អត្តាទានំ អាទាតព្ពំ ។ សចេ បនុបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អត្ថសញ្ហិតំ ឥទំ អត្តាទានំ នោ អនត្ថសញ្ហិតន្តិ តេនុបាលិ ភិក្ខុនា ឧត្តរិ បច្ចវេក្ខិតព្ពំ ឥមំ ខោ អហំ អត្តាទានំ អាទិយមានោ លភិស្សាមិ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ ធម្មតោ វិនយតោ បក្ខេ ឧទាហុ នោតិ ។ សចេ ឧបាលិ

ឧបាលិ ភិក្ខុនោះត្រូវពិចារណាតទៅទៀតថា អាត្មាអញប្រាថ្នានឹងកាន់យកនូវអត្តាទានណា អត្តាទាននេះជារឿងពិតមែន ឬមិនពិតទេ ។ ម្នាលឧបាលិ បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អត្តាទាននេះជារឿងមិនពិត មិនមែនជារឿងពិតទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ ។ ម្នាលឧបាលិ ម្យ៉ាងទៀត បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អត្តាទាននេះជារឿងពិត មិនមែនជារឿងមិនពិតទេ ម្នាលឧបាលិ ភិក្ខុនោះត្រូវពិចារណាតទៅទៀតថា អាត្មាអញប្រាថ្នានឹងកាន់យកនូវអត្តាទានណា អត្តាទាននេះប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ទេ ។ ម្នាលឧបាលិ បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អត្តាទាននេះឥតប្រយោជន៍ អត្តាទាននេះមិនមែនប្រកបដោយប្រយោជន៍ទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ ។ ម្នាលឧបាលិ ម្យ៉ាងទៀត បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អត្តាទាននេះប្រកបដោយប្រយោជន៍ អត្តាទាននេះមិនមែនឥតប្រយោជន៍ទេ ម្នាលឧបាលិ ភិក្ខុនោះត្រូវពិចារណាតទៅទៀតថា កាលបើអាត្មាអញកាន់យកនូវអត្តាទាននេះ នឹងបានភិក្ខុដែលជាសន្ទិដ្ឋមិត្រ (មិត្រគ្រាន់តែធ្លាប់ឃើញគ្នា) នឹងជាសម្ភត្តមិត្រ (មិត្តស្និទ្ធស្នាលគ្នាមាំមួន) មកជាបក្ខពួក តាមធម៌ តាមវិន័យ ឬមិនបានទេ ។ ម្នាលឧបាលិ បើ

ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ឥមំ ខោ អហំ អត្តាទានំ អាទិយមានោ ន លភិស្សាមិ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ ធម្មតោ វិនយតោ បក្ខេតិ ន តំ ឧបាលិ អត្តាទានំ អាទាតព្វំ ។ សចេ បនុបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ឥមំ ខោ អហំ អត្តាទានំ អាទិយមានោ លភិស្សាមិ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ ធម្មតោ វិនយតោ បក្ខេតិ តេនុបាលិ ភិក្ខុនា ឧត្តរឹ បច្ចវេក្ខិតព្វំ ឥមំ ខោ មេ អត្តាទានំ អាទិយតោ ភវិស្សតិ សង្ឃស្ស តតោនិទានំ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ ឧទាហុ នោតិ ។ សចេ ឧបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ឥមំ ខោ មេ អត្តាទានំ អាទិយតោ ភវិស្សតិ សង្ឃស្ស តតោនិទានំ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណន្តិ ន តំ ឧបាលិ

ភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា កាលបើអាត្មាអញកាន់យកនូវអត្តាទាននេះ មុខជានឹងមិនបានភិក្ខុដែលជាសន្ទិដ្ឋមិត្រនឹងជាសម្ភត្តមិត្រ មកជាបក្ខពួក តាមធម៌ តាមវិន័យទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ ។ ម្នាលឧបាលិ មួយទៀត បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា កាលបើអាត្មាអញកាន់យកនូវអត្តាទាននេះ មុខជានឹងបានភិក្ខុជាសន្ទិដ្ឋមិត្រនឹងជាសម្ភត្តមិត្រ មកជាបក្ខពួកតាមធម៌ តាមវិន័យ ម្នាលឧបាលិ ភិក្ខុនោះ ត្រូវពិចារណាតទៅទៀតថា កាលបើអាត្មាអញកាន់យកនូវអត្តាទាននេះ ការបង្កហេតុ ជម្លោះ ទាស់ទែង វិវាទ ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់នៃសង្ឃ អំពើផ្សេងៗរបស់សង្ឃ មានអត្តាទាននោះជាហេតុ នឹងមានដល់សង្ឃ ឬមិនមានទេ ។ ម្នាលឧបាលិ បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា កាលបើអាត្មាអញកាន់យកនូវអត្តាទាននេះ ការបង្កហេតុ ជម្លោះ ទាស់ទែង វិវាទ ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់នៃសង្ឃ អំពើផ្សេង ៗនៃសង្ឃ មានអត្តាទាននោះជាហេតុ នឹងមានដល់សង្ឃមិនខាន ម្នាលឧបាលិ

អត្តាទានំ អាទាតព្វំ ។ សចេ បនុបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ន ខោ មេ អត្តាទានំ អាទិយតោ ន ភវិស្សតិ សង្ឃស្ស តតោនិទានំ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណន្តិ អាទាតព្វំ តំ ឧបាលិ អត្តាទានំ ។ ឯវំ បញ្ចង្គសមន្នាគតំ ខោ ឧបាលិ អត្តាទានំ អាទិន្នំ បច្ឆាបិ អវិប្បដិសារករំ ភវិស្សតីតិ ។

(២៧១) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតោ ភិក្ខុ អធិករណជាតានំ ភិក្ខូនំ ពហូបការោ(១) ហោតីតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ អធិករណជាតានំ ភិក្ខូនំ ពហូបការោ ហោតិ ។ កតមេហិ បញ្ចហិ ។ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា

១ ពហុការោ ។

ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះទេ ។ ម្នាលឧបាលិ ម្យ៉ាងទៀត បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា កាលបើអាត្មាអញកាន់យកនូវអត្តាទាននេះ ការបង្កហេតុ ជម្លោះ ទាស់ទែង វិវាទ ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់នៃសង្ឃ អំពើផ្សេង ៗ នៃសង្ឃ មានអត្តាទាននោះជាហេតុ នឹងមិនមានដល់សង្ឃទេ ម្នាលឧបាលិ ភិក្ខុត្រូវកាន់យកនូវអត្តាទាននោះចុះ ។ ម្នាលឧបាលិ អត្តាទានប្រកបដោយអង្គ ៥ យ៉ាងនេះឯង ដែលភិក្ខុកាន់យកហើយ ជាធម្មជាតមិនធ្វើឲ្យក្ដៅក្រហាយ ក្នុងកាលជាខាងក្រោយ ។

(៦៧១) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ទើបឈ្មោះថាជាអ្នកមានឧបការៈច្រើនដល់ភិក្ខុដែលកើតអធិករណ៍ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបឈ្មោះថាជាអ្នកមានឧបការៈច្រើន ដល់ភិក្ខុដែលកើតអធិករណ៍ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺ ភិក្ខុជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ធម៌ទាំងឡាយណា ដែល

អាទិកល្យាណោ មជ្ឈេកល្យាណោ បរិយោសានកល្យាណោ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ វិនយេ ខោ បន ឋិតោ ហោតិ អសំហីរោ បដិពលោ ហោតិ ឧភោ អត្ថបច្ចត្ថិកេ អស្សាសេតុំ សញ្ញាបេតុំ និជ្ឈាបេតុំ បេក្ខេតុំ បសាទេតុំ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ អធិករណជាតានំ ភិក្ខូនំ ពហូបការោ ហោតិ ។

អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ អធិករណជាតានំ ភិក្ខូនំ ពហូបការោ ហោតិ ។ កតមេហិ បញ្ចហិ ។ បរិសុទ្ធកាយសមាចារោ ហោតិ បរិសុទ្ធវចីសមាចារោ ហោតិ បរិសុទ្ធាជីវោ ហោតិ បណ្ឌិតោ ហោតិ ព្យត្តោ បដិពលោ អនុយុញ្ជិយមានោ អនុយោគំ ទាតុំ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ

មានពីរោះដើមបទ ពីរោះកណ្តាលបទ ពីរោះចុងបទ ប្រកាសព្រហ្ម-ចរិយៈដ៏បរិសុទ្ធ បរិបូណ៌សព្វគ្រប់ ទាំងអត្ថទាំងព្យញ្ជនៈ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះក៏បានរៀនដឹងច្រើន បានទ្រទ្រង់ចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ យល់ជ្រាលជ្រៅដោយទិដ្ឋិ គឺបញ្ញា ១ ភិក្ខុនោះបានរៀនចាំបាតិមោក្ខទាំងពីរដោយពិស្តារ ចែកបទភាជនៈដោយត្រឹមត្រូវបាន ចាំស្ទាត់រត់មាត់ដោយប្រពៃ កាត់សេចក្តីបានស្រួលតាមសុត្តៈនឹងអនុព្យញ្ជនៈ ១ ជាអ្នកតាំងមាំក្នុងវិន័យ មិនរំកើប(១) អាចលួងលោមពន្យល់ដល់ជនទាំងពីរខាង ដែលមានសេចក្តីទាស់ទែងគ្នា ដោយអត្ថនឹងពិចារណា ឲ្យគ្រឡេកមើល ឲ្យជ្រះថ្លាបាន ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបឈ្មោះថាជាអ្នកមានឧបការៈច្រើន ដល់ពួកភិក្ខុដែលកើតអធិករណ៍ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏ឈ្មោះថាជាអ្នកមានឧបការៈច្រើនដល់ភិក្ខុដែលកើតអធិករណ៍ដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺ ភិក្ខុមានកាយសមាចារបរិសុទ្ធ ១ មានវចីសមាចារបរិសុទ្ធ ១ មានអាជីវៈបរិ-សុទ្ធ ១ ជាបណ្ឌិតឈ្លាសវៃ ១ កាលបើគេសាកសួរ ក៏អាចឲ្យគេសាកសួរបាន ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង

---

១ អដ្ឋកថា ថា មិនលះបង់លទ្ធិរបស់ខ្លួន ដោយត្រឹមតែពាក្យអ្នកដទៃ ។

សមន្នាគតោ ភិក្ខុ អធិករណជាតានំ ភិក្ខូនំ ពហុ-បការោ ហោតិ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ អធិករណជាតានំ ភិក្ខូនំ ពហុ-បការោ ហោតិ ។ កតមេហិ បញ្ចហិ ។ វត្ថុំ ជានាតិ និទានំ ជានាតិ បញ្ញត្តឹ ជានាតិ បទបច្ចាភដ្ឋំ ជានាតិ អនុសន្ធិវចនបថំ ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ច-ហង្គេហិ សមន្នាគតោ ភិក្ខុ អធិករណជាតានំ ភិក្ខូនំ ពហុបការោ ហោតីតិ ។

(២៧២) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នា-គតេន ភិក្ខុនា នានុយុញ្ជិតព្វន្តិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា នានុយុញ្ជិតព្វំ ។ កត-មេហិ បញ្ចហិ ។ សុត្តំ ន ជានាតិ សុត្តានុលោមំ ន ជានាតិ វិនយំ ន ជានាតិ វិនយានុលោមំ ន ជា-នាតិ ន ច ឋានាឋានកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា

ទើបឈ្មោះថាជាអ្នកមានឧបការៈច្រើន ដល់ពួកភិក្ខុ ដែលកើតអធិករណ៍ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ក៏ឈ្មោះថាជាអ្នកមានឧបការៈច្រើន ដល់ពួកភិក្ខុដែលកើតអធិករណ៍ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងវត្ថុ ១ ដឹងនិទាន ១ ដឹងបញ្ញត្តិ ១ ដឹងបទបាលីក្រោយមុន ១ ដឹងគន្លងពាក្យដែលជាប់តគ្នា ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបឈ្មោះថាជាអ្នកមានឧបការៈច្រើន ដល់ភិក្ខុដែលកើតអធិករណ៍ ។

[៤៧២] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលភិក្ខុមិនត្រូវសាកសួរ[១] ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ភិក្ខុផងគ្នាមិនត្រូវសាកសួរទេ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនដឹងសុត្តៈ (ឧភតោវិភង្គ) ១ មិនដឹងសុត្តានុលោម (មហាបទេសបួនខាងព្រះសូត្រ) ១ មិនដឹងវិន័យ (ខន្ធកៈនិងបរិវារៈ) ១ មិនដឹងវិនយានុលោម (មហាបទេសបួនខាងវិន័យ) ១ ជាអ្នកមិនឈ្លាសក្នុងហេតុ និងមិនមែនហេតុ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គទាំង ៥ នេះឯង ភិក្ខុមិនត្រូវសាក

---

១ សំដៅយកការពិនិត្យដេញដោល ពិនិត្យរករឿងឲ្យឃើញពិតឬទេ ។

នានុយុញ្ជិតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា អនុយុញ្ជិតព្វំ ។ កតមេហិ បញ្ចហិ ។ សុត្តំ ជានាតិ សុត្តានុលោមំ ជានាតិ វិនយំ ជានាតិ វិនយានុលោមំ ជានាតិ ឋានាឋានកុសលោ ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា អនុយុញ្ជិតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា នានុយុញ្ជិតព្វំ ។ កតមេហិ បញ្ចហិ ។ ធម្មំ ន ជានាតិ ធម្មានុលោមំ ន ជានាតិ វិនយំ ន ជានាតិ វិនយានុលោមំ ន ជានាតិ ន ច បុព្វាបរកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា នានុយុញ្ជិតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា អនុយុញ្ជិតព្វំ ។ កតមេហិ បញ្ចហិ ។ ធម្មំ ជានាតិ ធម្មានុលោមំ ជានាតិ វិនយំ ជានាតិ វិនយានុលោមំ ជានាតិ បុព្វាបរកុសលោ ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា អនុយុញ្ជិតព្វំ ។ អបរេហិបិ ឧបាលិ បញ្ច-

សួរទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ភិក្ខុផងគ្នាគួរសាកសួរបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងសូត្រៈ ១ ដឹងសុត្តានុលោម ១ ដឹងវិន័យ ១ ដឹងវិនយានុលោម ១ ជាអ្នកឈ្លាសក្នុងហេតុនិងមិនមែនហេតុ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង ៥ នេះឯង ទើបភិក្ខុគួរសាកសួរបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ដទៃទៀត គឺភិក្ខុមិនត្រូវសាកសួរទេ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនដឹងធម៌ គឺសុត្តន្តបិដកនិងអភិធម្មបិដក ១ មិនដឹងធម្មានុលោម (មហាបទេសបួនខាងព្រះសូត្រ) ១ មិនដឹងវិន័យ ១ មិនដឹងវិនយានុលោម ១ ជាអ្នកមិនឈ្លាសក្នុងពាក្យខាងដើមនិងពាក្យខាងចុង ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង ៥ នេះឯង ភិក្ខុមិនត្រូវសាកសួរទេ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង ៥ ទើបភិក្ខុគួរសាកសួរបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងធម៌ ១ ដឹងធម្មានុលោម ១ ដឹងវិន័យ ១ ដឹងវិនយានុលោម ១ ជាអ្នកឈ្លាសក្នុងពាក្យខាងដើមនិងពាក្យខាងចុង ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង ៥ នេះឯង ទើបភិក្ខុគួរសាកសួរបាន ។ ម្នាលឧបាលិ

ហង្គេហិ សមន្នាគតេន ភិក្ខុនា នានុយុញ្ជិតព្វំ ។ ក-
តមេហិ បញ្ចហិ ។ វត្ថុំ ន ជានាតិ និទានំ ន ជានាតិ
បញ្ញត្តឹ ន ជានាតិ បទបច្ចាភដ្ឋំ ន ជានាតិ អនុសន្ធិ-
វចនបថំ ន ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ច-
ហង្គេហិ សមន្នាគតេន ភិក្ខុនា នានុយុញ្ជិតព្វំ ។
បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា អនុ-
យុញ្ជិតព្វំ ។ កតមេហិ បញ្ចហិ ។ វត្ថុំ ជានាតិ
និទានំ ជានាតិ បញ្ញត្តឹ ជានាតិ បទបច្ចាភដ្ឋំ ជានាតិ
អនុសន្ធិវចនបថំ ជានាតិ ។ ឥមេហិ ខោ ឧបាលិ
បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា អនុយុញ្ជិតព្វំ ។
អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុ-
នា នានុយុញ្ជិតព្វំ ។ កតមេហិ បញ្ចហិ ។ អាបត្តឹ
ន ជានាតិ អាបត្តិសមុដ្ឋានំ ន ជានាតិ អាបត្តិយា
បយោគំ ន ជានាតិ អាបត្តិយា វូបសមំ ន ជានាតិ
ន អាបត្តិយា វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ
ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា នា-
នុយុញ្ជិតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន

ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ក៏ភិក្ខុមិនត្រូវសាកសួរទេ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនដឹងវត្ថុ ១ មិនដឹងនិទាន ១ មិនដឹងបញ្ញត្តិ ១ មិនដឹងបទបាលីក្រោយមុន ១ មិនដឹងគន្លងពាក្យដែលជាប់គ្នា ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង ភិក្ខុមិនត្រូវសាកសួរទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គទាំង ៥ ទើបភិក្ខុគួរសាកសួរបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងវត្ថុ ១ ដឹងនិទាន ១ ដឹងបញ្ញត្តិ ១ ដឹងបទបាលីក្រោយមុន ១ ដឹងគន្លងពាក្យដែលជាប់គ្នា ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង ៥ នេះឯង ទើបគួរសាកសួរបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ក៏ភិក្ខុមិនត្រូវសាកសួរទេ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនដឹងអាបត្តិ ១ មិនដឹងសមុដ្ឋាននៃអាបត្តិ ១ មិនដឹងប្រយោគនៃអាបត្តិ ១ មិនដឹងសេចក្តីរម្ងាប់នៃអាបត្តិ ១ ជាអ្នកមិនឈ្លាស ក្នុងការវិនិច្ឆ័យអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង ៥ នេះឯង ភិក្ខុមិនត្រូវសាកសួរទេ ។ ម្នាលឧបាលិ ភិក្ខុ

ឧបាលិបញ្ចកំ អនុយុញ្ជិតព្វនានុយុញ្ជិតព្វភិក្ខុនោ បញ្ចង្គានិ

ភិក្ខុនា អនុយុញ្ជិតព្វំ ។ កតមេហិ បញ្ចហិ ។ អាបត្តឹ ជានាតិ អាបត្តិសមុដ្ឋានំ ជានាតិ អាបត្តិយា បយោគំ ជានាតិ អាបត្តិយា វូបសមំ ជានាតិ អាបត្តិយា វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា អនុយុញ្ជិតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា នានុយុញ្ជិតព្វំ ។ កតមេហិ បញ្ចហិ ។ អធិករណំ ន ជានាតិ អធិករណសមុដ្ឋានំ ន ជានាតិ អធិករណស្ស បយោគំ ន ជានាតិ អធិករណស្ស វូបសមំ ន ជានាតិ ន អធិករណស្ស វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា នានុយុញ្ជិតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា អនុយុញ្ជិតព្វំ ។ កតមេហិ បញ្ចហិ ។ អធិករណំ ជានាតិ អធិករណសមុដ្ឋានំ

ប្រកបដោយអង្គ ៥ ទើបគួរសាកសួរបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងអាបត្តិ ១ ដឹងសមុដ្ឋាននៃអាបត្តិ ១ ដឹងប្រយោគនៃអាបត្តិ ១ ដឹងសេចក្តីរម្ងាប់នៃអាបត្តិ ១ អ្នកឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង ៥ នេះឯង ទើបគួរសាកសួរបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុមិនត្រូវសាកសួរទេ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនដឹងអធិករណ៍ ១ មិនដឹងសមុដ្ឋាននៃអធិករណ៍ ១ មិនដឹងប្រយោគនៃអធិករណ៍ ១ មិនដឹងសេចក្តីរម្ងាប់នៃអធិករណ៍ ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង ៥ នេះឯង ភិក្ខុមិនត្រូវសាកសួរទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួរសាកសួរបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងអធិករណ៍ ១ ដឹងសមុដ្ឋាននៃអធិករណ៍ ១

ជានាតិ អធិករណស្ស បយោគំ ជានាតិ អធិករ-ណស្ស វូបសមំ ជានាតិ អធិករណស្ស វិនិច្ឆយកុ-សលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា អនុយុញ្ជិតព្វំ ។

អត្តាទានវគ្គោ បញ្ចមោ ។

តស្សុទ្ទានំ

(២៧៣) បរិសុទ្ធញ្ច កាលេន
ការុញ្ញំ ឱកាសេន ច
អត្តាទានំ អធិករណំ
អបរេហិបិ វត្ថុញ្ច
សុត្តំ ធម្មំ បុន វត្ថុញ្ច
អាបត្តិ អធិករណេន ចាតិ ។

(២៧៤) កតិ នុ ខោ ភន្តេ អារញ្ញកាតិ ។ បញ្ចិមេ ឧបាលិ អារញ្ញកា ។ កតមេ បញ្ច ។ មន្ទត្តា មោមូ-ហត្តា អារញ្ញកោ ហោតិ បាបិច្ឆោ ឥច្ឆាបកតោ អា-រញ្ញកោ ហោតិ ឧម្មាទា ចិត្តក្ខេបា អារញ្ញកោ ហោតិ

ជំនុំប្រយោគនៃអធិករណ៍ ១ ជំនុំសេចក្ដីរម្ងាប់នៃអធិករណ៍ ១ អ្នកឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង ៥ នេះឯង ទើបគួរសាកសួរបាន ។

ចប់ អត្តាទានវគ្គ ទី ៥ ។

ឧទ្ទានគឺបញ្ជីរឿង នៃអត្តាទានវគ្គនោះដូច្នេះ

[៤៧៣] និយាយអំពីភិក្ខុអ្នកចោទមានកាយសមាចារដ៏ដើមបរិសុទ្ធ ១ ភិក្ខុអ្នកចោទនិយាយក្នុងកាលគួរ ១ ភិក្ខុអ្នកចោទប្រកបដោយសេចក្ដីករុណា ១ ភិក្ខុសូមឱកាស ១ ភិក្ខុគួរកាន់យកនូវអត្តាទាន ១ ភិក្ខុមានឧបការៈដល់ភិក្ខុដែលកើតអធិករណ៍ ១ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ១ ភិក្ខុដឹងវត្ថុ ១ សូត្រ ១ ធម៌ ១ វត្ថុដទៃទៀត ១ អាបត្តិ ១ អធិករណ៍ ១ ។

[៤៧៤] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ មានប៉ុន្មានពួក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ មាន ៥ ពួក ។ ៥ ពួក គឺអ្វីខ្លះ ។ គឺភិក្ខុអ្នកកាន់អារញ្ញកធុតង្គ ព្រោះល្ងង់វង្វេង ១ ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ មានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីប្រាថ្នាគ្របសង្កត់ ១ ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ ព្រោះឆ្កួត ព្រោះរាយមាយចិត្ត ១

ឧបាលិបញ្ចកំ បញ្ចារញ្ញកាទយោ

វណ្ណិតោ[1] ពុទ្ធេហិ ពុទ្ធសាវកេហីតិ អារញ្ញកោ ហោតិ អបិច អប្បិច្ឆតញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមត្ថិតញ្ញេវ និស្សាយ អារញ្ញកោ ហោតិ ។ ឥមេ ខោ ឧបាលិ បញ្ច អារញ្ញកាតិ ។ កតិ នុ ខោ ភន្តេ បិណ្ឌបាតិកាតិ ។បេ។ កតិ នុ ខោ ភន្តេ បំសុកូលិកាតិ ។ កតិ នុ ខោ ភន្តេ រុក្ខមូលិកាតិ ។ កតិ នុ ខោ ភន្តេ សោសានិកាតិ ។ កតិ នុ ខោ ភន្តេ អព្ភោកាសិកាតិ ។ កតិ នុ ខោ ភន្តេ តេចីវរិកាតិ ។ កតិ នុ ខោ ភន្តេ សបទានចារិកាតិ ។ កតិ នុ ខោ ភន្តេ នេសជ្ជិកាតិ ។ កតិ នុ ខោ ភន្តេ យថាសន្ថតិកាតិ ។ កតិ នុ ខោ ភន្តេ ឯកាសនិកាតិ ។ កតិ នុ ខោ ភន្តេ

---

១ ឱ. ម. វណ្ណិតំ ។

ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ ដោយគិតថា ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ ព្រះពុទ្ធនឹងពួកពុទ្ធសាវ័កតែងសរសើរ១ ភិក្ខុជាអ្នកកាន់អារញ្ញកធុតង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិចផង ព្រោះអាស្រ័យសេចក្តីសន្តោសផង ព្រោះអាស្រ័យការដុសខាត់ចិត្តផង ព្រោះអាស្រ័យសេចក្តីស្ងាត់ផង ព្រោះអាស្រ័យសេចក្តីប្រតិបត្តិ ដែលមានប្រយោជន៍ផង១ ។ ម្នាលឧបាលិ ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ មាន ៥ ពួកនេះឯង ។ ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់បិណ្ឌបាតិកធុតង្គមានប៉ុន្មានពួក ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់បំសុកូលិកធុតង្គ មានប៉ុន្មានពួក ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់រុក្ខមូលិកធុតង្គ មានប៉ុន្មានពួក ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់សោសានិកធុតង្គ មានប៉ុន្មានពួក ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់អព្ភោកាសិកធុតង្គ មានប៉ុន្មានពួក ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់តេចីវរិកធុតង្គ មានប៉ុន្មានពួក ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់សបទានចារិកធុតង្គ មានប៉ុន្មានពួក ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់នេសជ្ជិកធុតង្គ មានប៉ុន្មានពួក ។ បពិត្រព្រះង្គដ៏ចំរើន ភិក្ខុអ្នកកាន់យថាសន្ថតិកធុតង្គ មានប៉ុន្មានពួក ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់ឯកាសនិកធុតង្គ មានប៉ុន្មានពួក ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់

ខលុបច្ឆាភត្តិកាតិ ។ កតិ នុ ខោ ភន្តេ បត្តបិណ្ឌិកាតិ ។ បញ្ចិមេ ឧបាលិ បត្តបិណ្ឌិកា ។ កតមេ បញ្ច ។ មន្ទត្តា មោមូហត្តា បត្តបិណ្ឌិកោ ហោតិ បាបិច្ឆោ ឥច្ឆាបកតោ បត្តបិណ្ឌិកោ ហោតិ ឧម្មាទា ចិត្តក្ខេបា បត្តបិណ្ឌិកោ ហោតិ វណ្ណិតោ ពុទ្ធេហិ ពុទ្ធសាវកេហីតិ បត្តបិណ្ឌិកោ ហោតិ អបិច អប្បិច្ឆញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមត្ថិតញ្ញេវ និស្សាយ បត្តបិណ្ឌិកោ ហោតិ ។ ឥមេ ខោ ឧបាលិ បញ្ច បត្តបិណ្ឌិកាតិ ។

ធុតង្គវគ្គោ ឆដ្ឋោ ។

តស្សុទ្ទានំ

[២៧៤] អារញ្ញកោ បិណ្ឌិបំសុ[1]

រុក្ខសុសានបញ្ចមំ

---

១ ឱ. ម. បិណ្ឌិបំសុ ។

ខលុបច្ឆាភត្តិកធុតង្គ មានប៉ុន្មានពួក ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ មានប៉ុន្មានពួក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ មាន ៥ ពួក ។ ៥ ពួក គឺអ្វីខ្លះ ។ គឺភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ ព្រោះសេចក្ដីល្ងង់វង្វេង ១ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ មានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីប្រាថ្នាគ្របសង្កត់ ១ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ ព្រោះឆ្កួត ព្រោះរាយមាយចិត្ត ១ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ ដោយគិតថា ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ ព្រះពុទ្ធនឹងពួកសាវ័កនៃព្រះពុទ្ធតែងសរសើរ១ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ ព្រោះអាស្រ័យសេចក្ដីប្រាថ្នាតិចផង ព្រោះអាស្រ័យសេចក្ដីសន្ដោសផង ព្រោះអាស្រ័យការផុសខាត់ចិត្តផង ព្រោះអាស្រ័យសេចក្ដីស្ងាត់ផង ព្រោះអាស្រ័យសេចក្ដីប្រតិបត្តិដែលមានប្រយោជន៍នេះផង ១ ។ ម្នាលឧបាលិ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ មាន ៥ ពួកនេះឯង ។

ចប់ ធុតង្គវគ្គ ទី ៦ ។

ឧទ្ទានគឺបញ្ជីរឿងនៃធុតង្គវគ្គ នោះដូច្នេះ

(២៧៥) និយាយអំពីភិក្ខុកាន់អារញ្ញកធុតង្គ១ ភិក្ខុកាន់បិណ្ឌបាតិកធុតង្គ ១ ភិក្ខុកាន់បំសុកូលិកធុតង្គ ១ ភិក្ខុកាន់រុក្ខមូលិកធុតង្គ ១ ភិក្ខុកាន់សោសានិកធុតង្គ ១ ជាគំរប់ ៥ ភិក្ខុកាន់

អញ្ញេតេ ចីវរញ្ចេវ

សរបនានេន សង្ឃិកា

សរន្ទតេ កាសនញ្ចេវ

ខលុបច្ឆាបត្តបិណ្ឌិកាតិ ។

(២៧៦) កតិ នុ ខោ ភន្តេ មុសាវាទាតិ ។ បញ្ចិមេ ឧបាលិ មុសាវាទា ។ កតមេ បញ្ច ។ អត្ថិ មុសាវាទោ បារាជិកគាមី អត្ថិ មុសាវាទោ សង្ឃាទិសេសគាមី អត្ថិ មុសាវាទោ ថុល្លច្ចយគាមី អត្ថិ មុសាវាទោ បាចិត្តិយគាមី អត្ថិ មុសាវាទោ ទុក្កដគាមី ។ ឥមេ ខោ ឧបាលិ បញ្ច មុសាវាទាតិ ។

(២៧៧) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ សង្ឃមជ្ឈេ ឧបោសថំ វា បវារណំ វា ឋបេន្តស្ស អលំ ភិក្ខុ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន ឧបោសថោ វា បវារណា វា កាតព្វាតិ ។ បញ្ចហុបាលិ អង្គេហិ

អព្ភោកាសិកធុតង្គ ១ ភិក្ខុកាន់តេចីវរិកធុតង្គ ១ ភិក្ខុកាន់សបទានចារិកធុតង្គ ១ ភិក្ខុកាន់នេសជ្ជិកធុតង្គ ១ ភិក្ខុកាន់យថាសន្ថតិកធុតង្គ ១ ភិក្ខុកាន់ឯកាសនិកធុតង្គ ១ ភិក្ខុកាន់ខលុបច្ឆាភត្តិកធុតង្គ ១ ភិក្ខុកាន់បត្តបិណ្ឌិកធុតង្គ ១ ។

(២៧៦) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន មុសាវាទ មានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ មុសាវាទនេះមាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមុសាវាទ ដល់នូវបារាជិកក៏មាន មុសាវាទ ដល់នូវសង្ឃាទិសេសក៏មាន មុសាវាទ ដល់នូវថុល្លច្ច័យក៏មាន មុសាវាទ ដល់នូវបាចិត្តិយៈក៏មាន មុសាវាទ ដល់នូវទុក្កដក៏មាន ។ ម្នាលឧបាលិ មុសាវាទ មាន ៥ យ៉ាងនេះឯង ។

(២៧៧) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន កាលបើបញ្ឈប់នូវឧបោសថ ឬបវារណាក្នុងកណ្តាលជំនុំសង្ឃ សង្ឃគប្បីសង្កត់សង្កិនថា ម្នាលភិក្ខុ ណ្ហើយលោក កុំបង្កហេតុ កុំធ្វើជម្លោះ កុំទាស់ទែង កុំវិវាទគ្នាឡើយ ដូច្នេះហើយសឹមធ្វើឧបោសថ ឬបវារណា ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ

សមន្នាគតស្ស ភិក្ខុនោ សង្ឃមជ្ឈេ ឧបោសថំ វា បវារណា វា ឋបេន្តស្ស អលំ ភិក្ខុ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន ឧបោសថោ វា បវារណា វា កាតព្វា ។ កតមេហិ បញ្ចហិ ។ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ចាវនាធិប្បាយោ វត្តា ហោតិ នោ វុដ្ឋានាធិប្បាយោ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ សង្ឃមជ្ឈេ ឧបោសថំ វា បវារណំ វា ឋបេន្តស្ស អលំ ភិក្ខុ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន ឧបោសថោ វា បវារណា វា កាតព្វា ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ សង្ឃមជ្ឈេ ឧបោសថំ វា បវារណំ វា ឋបេន្តស្ស អលំ ភិក្ខុ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន ឧបោសថោ វា បវារណា វា កាតព្វា ។ កតមេហិ បញ្ចហិ ។ អបរិសុទ្ធកាយសមាចារោ ហោតិ អបរិសុទ្ធវចីសមាចារោ ហោតិ អបរិសុទ្ធាជីវោ ហោតិ ពាលោ ហោតិ អព្យត្តោ

ភិក្ខុប្រកបដោយអង្គ ៨ កាលបើបញ្ឈប់នូវឧបោសថ ឬបវារណាក្នុងកណ្ដាលជំនុំសង្ឃ សង្ឃគប្បីសង្កត់សង្កិនថា ម្នាលភិក្ខុ ណ្ហើយលោក កុំបង្កហេតុ កុំធ្វើជម្លោះ កុំទាស់ទែង កុំវិវាទគ្នាឡើយ ដូច្នេះហើយសឹមធ្វើឧបោសថ ឬបវារណា ។ អង្គ៨ គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកមិនខ្លាសបាប ១ ជាមនុស្សល្ងង់ ១ មិនមែនជាបកតត្ត ១ ជាអ្នកនិយាយដោយបំណងនឹងឲ្យភិក្ខុដទៃឃ្លាត (ចាកសាសនា)១ ជាអ្នកមិនប្រាថ្នានឹងចេញចាកអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៨ នេះឯង កាលបើបញ្ឈប់នូវឧបោសថ ឬបវារណាក្នុងកណ្ដាលជំនុំសង្ឃ សង្ឃគប្បីសង្កត់សង្កិនថា ម្នាលភិក្ខុ ហើយលោក កុំបង្កហេតុ កុំធ្វើជម្លោះ កុំទាស់ទែង កុំវិវាទគ្នាឡើយ ដូច្នេះហើយសឹមធ្វើឧបោសថ ឬបវារណា ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៨ ដទៃទៀត កាលបើបញ្ឈប់នូវឧបោសថ ឬបវារណាក្នុងកណ្ដាលជំនុំសង្ឃ សង្ឃគប្បីសង្កត់សង្កិនថា ម្នាលភិក្ខុ ណ្ហើយលោក កុំបង្កហេតុ កុំធ្វើជម្លោះ កុំទាស់ទែង កុំវិវាទគ្នាឡើយ ដូច្នេះហើយសឹមធ្វើឧបោសថ ឬបវារណា ។ អង្គ ៨ គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកមានកាយសមាចារមិនបរិសុទ្ធ ១ មានវចីសមាចារមិនបរិសុទ្ធ ១ មានអាជីវៈមិនបរិសុទ្ធ ១ ជាមនុស្សល្ងង់មិនឈ្លាសវៃ ១

ភណ្ឌនការកោ ហោតិ កលហការកោ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ សង្ឃមជ្ឈេ ឱភាសជំ វា បការណំ វា ឋបេន្តស្ស អលំ ភិក្ខុ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន ឱភាសជោ វា បការណា វា កាតព្វាតិ ។

[២៧៨] កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អនុយោគោ ន ទាតព្វោតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អនុយោគោ ន ទាតព្វោ ។ កតមេហិ បញ្ចហិ ។ អាបត្តានាបត្តឹ ន ជានាតិ លហុកគរុកំ អាបត្តឹ ន ជានាតិ សាវសេសានាវសេសំ អាបត្តឹ ន ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ន ជានាតិ សប្បដិកម្មអប្បដិកម្មំ អាបត្តឹ ន ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អនុយោគោ ន ទាតព្វោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អនុយោគោ ទាតព្វោ ។ កតមេហិ បញ្ចហិ ។ អាបត្តានាបត្តឹ ជានាតិ លហុ-

ជាអ្នកធ្វើការបន្តហេតុ ធ្វើជម្លោះ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ នេះឯង កាលបើបញ្ញត្តិនូវឧបោសថ ឬបវារណាក្នុងកណ្តាលជំនុំសង្ឃ សង្ឃគប្បីសង្កត់សង្កិនថា ម្នាលភិក្ខុ ណើយលោកកុំបន្តហេតុ កុំធ្វើជម្លោះ កុំទាស់ទែង កុំវិវាទគ្នាឡើយ ដូច្នេះហើយសឹមធ្វើឧបោសថ ឬបវារណា ។

(២៧៨) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃមិនត្រូវឲ្យការសាកសួរដល់ភិក្ខុ ដែលប្រកបដោយអង្គប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ សង្ឃមិនត្រូវឲ្យការសាកសួរ ដល់ភិក្ខុ ដែលប្រកបដោយអង្គ ៥ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនដឹងអាបត្តិនឹងអនាបត្តិ ១ មិនដឹងអាបត្តិស្រាលនឹងធ្ងន់ ១ មិនដឹងសាវសេសាបត្តិនឹងអនវសេសាបត្តិ ១ មិនដឹងទុដ្ឋុល្លាបត្តិនឹងអទុដ្ឋុល្លាបត្តិ ១ មិនដឹងសប្បដិកម្មាបត្តិ[1] នឹងអប្បដិកម្មាបត្តិ[2] ១ ។ ម្នាលឧបាលិ សង្ឃមិនត្រូវឲ្យការសាកសួរដល់ភិក្ខុ ដែលប្រកបដោយអង្គ ៥ នេះឯង ។ ម្នាលឧបាលិ សង្ឃត្រូវឲ្យការសាកសួរដល់ភិក្ខុ ដែលប្រកបដោយអង្គ ៥ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងនូវអាបត្តិនឹងអនាបត្តិ ១ ដឹងនូវអាបត្តិស្រាល

---

១ ប្រែថា អាបត្តិដែលកែត្រឡប់ដោយវុដ្ឋានវិធីនឹងទេសនាវិធីបាន ។ ២ ប្រែថា អាបត្តិដែលកែត្រឡប់មិនបាន គឺបារាជិកាបត្តិ ។

កគរុកំ អាបត្តឹ ជានាតិ សាវសេសានវសេសំ អាបត្តឹ ជានាតិ ទុដ្ឋុល្លាទុដ្ឋុល្លំ អាបត្តឹ ជានាតិ សប្បដិកម្មា-អប្បដិកម្មំ អាបត្តឹ ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អនុយោគោ ទាតព្វោតិ ។

[២៧៩] កតីហិ នុ ខោ ភន្តេ អាការេហិ ភិក្ខុ អាបត្តឹ អាបជ្ជតីតិ ។ បញ្ចហុបាលិ អាការេហិ ភិក្ខុ អាបត្តឹ អាបជ្ជតិ ។ កតមេហិ បញ្ចហិ ។ អលជ្ជិតា អញ្ញាណតា កុក្កុច្ចបកតតា អកប្បិយេ កប្បិយសញ្ញិតា កប្បិយេ អកប្បិយសញ្ញិតា ។ ឥមេហិ ខោ ឧបាលិ បញ្ចហាការេហិ ភិក្ខុ អាបត្តឹ អាបជ្ជតិ ។ អបរេហិបិ ឧបាលិ បញ្ចហាការេហិ ភិក្ខុ អាបត្តឹ អាបជ្ជតិ ។ កតមេហិ បញ្ចហិ ។ អទស្សនេន អស្សវនេន បសុត្តតា តថាសញ្ញី(១) សតិសម្មោសា ។ ឥមេហិ ខោ ឧបាលិ បញ្ចហាការេហិ ភិក្ខុ អាបត្តឹ អាបជ្ជតីតិ ។

---

១ តថាសញ្ញិតាតិ បាឋោ យុត្តតរោ ។

នឹងធ្ងន់១ ដឹងនូវសាវសេសាបត្តិនឹងអនវសេសាបត្តិ១ ដឹងនូវទុដ្ឋុល្លាបត្តិនឹងអទុដ្ឋុល្លាបត្តិ ១ ដឹងនូវសប្បដិកម្មាបត្តិនឹងអប្បដិកម្មាបត្តិ១ ។ ម្នាលឧបាលិ សង្ឃត្រូវឲ្យការសាកសួរដល់ភិក្ខុ ដែលប្រកបដោយអង្គ ៥ នេះឯង ។

(២៧៩) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុត្រូវអាបត្តិ ដោយអាការប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុត្រូវអាបត្តិ ដោយអាការ ៥ ។ អាការ ៥ អ្វីខ្លះ ។ គឺភិក្ខុត្រូវអាបត្តិ ដោយសេចក្តីមិនខ្មាសបាប ១ ដោយមិនស្គាល់អាបត្តិ ១ ដោយសង្ស័យហើយចេះតែធ្វើទៅ ១ ដោយសំគាល់ថាគួរ ក្នុងរបស់ដែលមិនគួរ ១ ដោយសំគាល់ថាមិនគួរ ក្នុងរបស់ដែលគួរ ១ ។ ម្នាលឧបាលិ ភិក្ខុត្រូវអាបត្តិ ដោយអាការ៥ នេះឯង ។ ម្នាលឧបាលិ ភិក្ខុត្រូវអាបត្តិ ដោយអាការ ៥ ដទៃទៀត ។ អាការ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុត្រូវអាបត្តិ ដោយអាការមិនឃើញ(១)១ ត្រូវដោយអាការមិនឮ(២)១ ត្រូវដោយដេកលក់(៣)១ ត្រូវដោយខ្លួនសំគាល់ពិត(៤)១ ត្រូវដោយភ្លេចស្មារតី(៥)១ ម្នាលឧបាលិ ភិក្ខុត្រូវអាបត្តិ ដោយអាការ៥នេះឯង ។

---

១ អដ្ឋកថា ថា ភិក្ខុសង្ស័យ ហើយធ្វើលើកម្មមិនគួរ ដោយមិនបានជួបវិន័យធរ ។ ២ ធ្វើកម្មមិនគួរ ព្រោះមិនសួរឬមិនប្រុងស្តាប់ពាក្យវិន័យធរ ដែលអធិប្បាយពីកម្មគួរនឹងមិនគួរដល់ភិក្ខុដទៃ ។ ៣ ត្រូវអាបត្តិដោយដេកលក់ តាមសិក្ខាបទដែលហាមការដេករួមនឹងសាមណេរជាដើម ។ ៤ របស់មិនគួរ តែភិក្ខុសំគាល់ថាជាក់ជាគួរ ។ ៥ ត្រូវដោយឲ្យរាត្រី១កន្លងទៅជាដើម។

ឧបាលិបញ្ចកំ បញ្ចវេរា បញ្ចវេរមណិយោ

(២៨០) កតិ នុ ខោ ភន្តេ វេរាតិ ។ បញ្ចិមេ ឧបាលិ វេរា ។ កតមេ បញ្ច ។ បាណាតិបាតោ អទិន្នាទានំ កាមេសុមិច្ឆាចារោ មុសាវាទោ សុរាមេរយមជ្ជប្បមាទដ្ឋានំ ។ ឥមេ ខោ ឧបាលិ បញ្ច វេរាតិ ។

(២៨១) កតិ នុ ខោ ភន្តេ វេរមណិយោតិ ។ បញ្ចិមា ឧបាលិ វេរមណិយោ ។ កតមា បញ្ច ។ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុមិច្ឆាចារា វេរមណី មុសាវាទា វេរមណី សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី ។ ឥមា ខោ ឧបាលិ បញ្ច វេរមណិយោតិ ។

ឧបាលិបញ្ចកៈ ពៀរមាន ៥ យ៉ាង កិរិយាវៀរមាន ៥ យ៉ាង

[៤៨០] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ពៀរមានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ពៀរនេះមាន ៥ យ៉ាង ។ ពៀរ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺការញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះឲ្យវិនាស ១ ការកាន់យកទ្រព្យដែលគេមិនឲ្យ ១ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ការនិយាយកុហក ១ ហេតុជាទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកទឹកស្រវឹង គឺសុរានឹងមេរ័យ ១ ម្នាលឧបាលិ ពៀរមាន ៥ យ៉ាងនេះឯង ។

[៤៨១] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន កិរិយាវៀរ មានប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កិរិយាវៀរមាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកិរិយាវៀរចាកការញុំាងសត្វមានជីវិតឲ្យវិនាស ១ កិរិយាវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ១ កិរិយាវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ កិរិយាវៀរចាកការនិយាយកុហក ១ កិរិយាវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកទឹកស្រវឹងគឺសុរានឹងមេរ័យ ១ ។ ម្នាលឧបាលិ កិរិយាវៀរមាន ៥ យ៉ាងនេះឯង ។

(២៨២) កតិ នុ ខោ ភន្តេ ព្យសនានិ ។ បញ្ចិមានិ ឧបាលិ ព្យសនានិ ។ កតមានិ បញ្ច ។ ញាតិព្យសនំ ភោគព្យសនំ រោគព្យសនំ សីលព្យសនំ ទិដ្ឋិព្យសនំ ។ ឥមានិ ខោ ឧបាលិ បញ្ច ព្យសនានីតិ ។

(២៨៣) កតិ នុ ខោ ភន្តេ សម្បទាតិ ។ បញ្ចិមា ឧបាលិ សម្បទា ។ កតមា បញ្ច ។ ញាតិសម្បទា ភោគសម្បទា អារោគ្យសម្បទា សីលសម្បទា ទិដ្ឋិសម្បទា ។ ឥមា ខោ ឧបាលិ បញ្ច សម្បទាតិ ។

មុសាវាទវគ្គោ សត្តមោ ។

(២៨២) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សេចក្តីវិនាស មានប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ សេចក្តីវិនាស មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីវិនាសញាតិ ១ សេចក្តីវិនាសភោគសម្បត្តិ ១ សេចក្តីវិនាសព្រោះរោគ ១ សេចក្តីវិនាសសីល ១ សេចក្តីវិនាសព្រោះទិដ្ឋិ ១ ។ ម្នាលឧបាលិ សេចក្តីវិនាស មាន ៥ យ៉ាងនេះឯង ។

(២៨៣) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សម្បទា គឺសេចក្តីបរិបូណ៌ មានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ សេចក្តីបរិបូណ៌ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីបរិបូណ៌ដោយញាតិ ១ សេចក្តីបរិបូណ៌ដោយភោគសម្បត្តិ ១ សេចក្តីបរិបូណ៌ដោយអាការមិនមានរោគ ១ សេចក្តីបរិបូណ៌ដោយសីល ១ សេចក្តីបរិបូណ៌ដោយទិដ្ឋិត្រូវ ១ ។ ម្នាលឧបាលិ សេចក្តីបរិបូណ៌មាន ៥ យ៉ាងនេះឯង ។

ចប់ មុសាវាទវគ្គ ទី ៣ ។

តស្សុទ្ទានំ

(២៨៤) មុសាវាទោ ច ឱមទ្ទិ
អបរេហិ អនុយោគោ ច
អាបត្តិញ្ច អបរេហិ
វេរ វេរមណីបិ ច
ព្យសនំ សម្បទា ចេវ
សត្តមោ វគ្គសង្គហោតិ ។

(២៨៥) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ ភិក្ខុនីសង្ឃេន កម្មំ កាតព្វន្តិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ ភិក្ខុនីសង្ឃេន កម្មំ កាតព្វំ អវន្ទិយោ សោ ភិក្ខុ ភិក្ខុនីសង្ឃេន ។ កតមេហិ បញ្ចហិ ។ វិវរិត្វា កាយំ ភិក្ខុនីនំ ទស្សេតិ ឩរុំ ទស្សេតិ អង្គជាតំ ទស្សេតិ ឧភោ អំសកូដេ ទស្សេតិ ឱភាសតិ គិហី សម្បយោជេតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ភិក្ខុនីសង្ឃេន កម្មំ កាតព្វំ អវន្ទិយោ សោ ភិក្ខុ ភិក្ខុនីសង្ឃេន ។

ឧបាលិបញ្ចកៈ ឧទ្ទានគាថា ភិក្ខុនីសង្ឃត្រូវធ្វើកម្មដល់ភិក្ខុ

ឧទ្ទាន គឺបញ្ជីរឿងនៃមុសាវាទវគ្គនោះ ដូច្នេះ

[២៨៨] និយាយអំពីមុសាវាទ ១ អំពីសង្ឃត្រូវសង្កត់សង្កិនភិក្ខុ ១ អំពីភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ១ អំពីការសាកសួរ ១ អំពីភិក្ខុត្រូវអាបត្តិ ១ អំពីភិក្ខុត្រូវអាបត្តិដោយអាការ ៥ ដទៃទៀត ១ អំពីពៀរ ១ អំពីកិរិយាវៀរ ១ អំពីសេចក្តីវិនាស ១ អំពីសេចក្តីបរិបូណ៌ ១ (នេះ) ជាសង្គហវត្ថុទីប្រាំពីរ ។

[២៨៩] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលភិក្ខុនីសង្ឃត្រូវធ្វើកម្ម ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដែលភិក្ខុនីសង្ឃត្រូវធ្វើកម្ម គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុបើកកាយបង្ហាញពួកភិក្ខុនី ១ បើកភ្លៅបង្ហាញ ១ បើកអង្គជាតបង្ហាញ ១ បើកចង្កូយស្មាទាំងសងខាងបង្ហាញ ១ និយាយល្បួងឬផ្សំផ្គុំនឹងគ្រហស្ថ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង ដែលភិក្ខុនីសង្ឃត្រូវធ្វើកម្ម គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ ។

អបរេហិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ភិក្ខុនីសង្ឃេនេវ កម្មំ កាតព្វំ អវន្ទិយោ សោ ភិក្ខុ ភិក្ខុនីសង្ឃេន ។ កតមេហិ បញ្ចហិ ។ ភិក្ខុនីនំ អវណ្ណាយ បរិសក្កតិ ភិក្ខុនីនំ អនត្ថាយ បរិសក្កតិ ភិក្ខុនីនំ អនាវាសាយ បរិសក្កតិ ភិក្ខុនិយោ អក្កោសតិ បរិភាសតិ ភិក្ខូ ភិក្ខុនីហិ ភេទេតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ភិក្ខុនីសង្ឃេនេវ កម្មំ កាតព្វំ អវន្ទិយោ សោ ភិក្ខុ ភិក្ខុនីសង្ឃេន ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ភិក្ខុនីសង្ឃេនេវ កម្មំ កាតព្វំ អវន្ទិយោ សោ ភិក្ខុ ភិក្ខុនីសង្ឃេន ។ កតមេហិ បញ្ចហិ ។ ភិក្ខុនីនំ អវណ្ណាយ បរិសក្កតិ ភិក្ខុនីនំ អនត្ថាយ បរិសក្កតិ ភិក្ខុនីនំ អនាវាសាយ បរិសក្កតិ ភិក្ខុនិយោ អក្កោសតិ បរិភាសតិ ភិក្ខូ ភិក្ខុនីហិ សម្បយោជេតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ ភិក្ខុនីសង្ឃេនេវ កម្មំ កាតព្វំ អវន្ទិយោ សោ ភិក្ខុ ភិក្ខុនីសង្ឃេនាតិ ។

ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ភិក្ខុនីសង្ឃក៏ត្រូវធ្វើកម្មដែរ គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុព្យាយាមដើម្បីមិនឲ្យបានលាភដល់ពួកភិក្ខុនី ១ ព្យាយាមដើម្បីមិនឲ្យមានប្រយោជន៍ដល់ពួកភិក្ខុនី ១ ព្យាយាមដើម្បីមិនឲ្យមានទីលំនៅដល់ពួកភិក្ខុនី ១ ជេរគំរាមភិក្ខុនីទាំងឡាយ ១ ឲ្យពួកភិក្ខុបែកបាកពួកភិក្ខុនី ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង ដែលភិក្ខុនី-សង្ឃត្រូវធ្វើកម្ម គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ភិក្ខុនីសង្ឃត្រូវធ្វើកម្មដែរ គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុព្យាយាមដើម្បីមិនឲ្យមានលាភដល់ពួកភិក្ខុនី ១ ព្យាយាមដើម្បីមិនឲ្យមានប្រយោជន៍ដល់ពួកភិក្ខុនី ១ ព្យាយាមដើម្បីមិនឲ្យមានទីលំនៅដល់ភិក្ខុនី ១ ជេរគំរាមភិក្ខុនីទាំងឡាយ ១ ផ្សំផ្គុំពួកភិក្ខុនឹងពួកភិក្ខុនី ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង ដែលភិក្ខុនីសង្ឃត្រូវធ្វើកម្ម គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ ។

(២៨៦) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតាយ ភិក្ខុនិយា កម្មំ កាតព្វន្តិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតាយ ភិក្ខុនិយា កម្មំ កាតព្វំ ។ កតមេហិ បញ្ចហិ ។ វិវរិត្វា កាយំ ភិក្ខូនំ ទស្សេតិ ឩរុំ ទស្សេតិ អង្គជាតំ ទស្សេតិ ឧភោ អំសកូដេ ទស្សេតិ ឱភាសតិ គិហី សម្បយោជេតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតាយ ភិក្ខុនិយា កម្មំ កាតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតាយ ភិក្ខុនិយា កម្មំ កាតព្វំ ។ កតមេហិ បញ្ចហិ ។ ភិក្ខូនំ អលាភាយ បរិសក្កតិ ភិក្ខូនំ អនត្ថាយ បរិសក្កតិ ភិក្ខូនំ អនាវាសាយ បរិសក្កតិ ភិក្ខូ អក្កោសតិ បរិភាសតិ ភិក្ខុនិយោ ភិក្ខូហិ ភេទេតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចកង្គេហិ សមន្នាគតាយ ភិក្ខុនិយា កម្មំ កាតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតាយ ភិក្ខុនិយា កម្មំ កាតព្វំ ។ កតមេហិ បញ្ចហិ ។ ភិក្ខូនំ អលាភាយ បរិសក្កតិ ភិក្ខូនំ អនត្ថាយ បរិសក្កតិ ភិក្ខូនំ អនាវាសាយ បរិសក្កតិ

(២៨៦) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ ៥ ។ អង្គ ៥ អ្វីខ្លះ ។ គឺភិក្ខុដែលបើកកាយ បង្ហាញពួកភិក្ខុ ១ បើកភ្លៅបង្ហាញ ១ បើកអង្គជាតបង្ហាញ ១ បើកបង្កួយស្មាទាំងសងខាងបង្ហាញ ១ និយាយល្បួង ឬផ្សំផ្គុំនឹងគ្រហស្ថ ១ ។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ ៥ នេះឯង ។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ ៥ ដទៃទៀត ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុព្យាយាមដើម្បីមិនឲ្យមានលាភ ដល់ពួកភិក្ខុ ១ ព្យាយាមដើម្បីមិនឲ្យមានប្រយោជន៍ ដល់ពួកភិក្ខុ ១ ព្យាយាមដើម្បីមិនឲ្យមានទីលំនៅ ដល់ពួកភិក្ខុ ១ ជេរគំរាមភិក្ខុទាំងឡាយ ១ ធ្វើពួកភិក្ខុឲ្យបែកបាក់ពួកភិក្ខុ ១ ។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ ៥ ដទៃទៀត ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុព្យាយាមដើម្បីមិនឲ្យមានលាភដល់ភិក្ខុ ១ ព្យាយាមដើម្បីមិនឲ្យមានប្រយោជន៍ដល់ពួកភិក្ខុ ១ ព្យាយាមដើម្បីមិនឲ្យមានទីលំនៅ ដល់ពួកភិក្ខុ ១

ភិក្ខូ អក្កោសតិ បរិភាសតិ ភិក្ខុនិយោ ភិក្ខូហិ សម្បយោជេតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតាយ ភិក្ខុនិយា កម្មំ កាតព្វន្តិ ។

(២៨៧) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន ឋបេតព្វោតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន ឋបេតព្វោ ។ កតមេហិ បញ្ចហិ ។ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ចាវនាធិប្បាយោ វត្តា ហោតិ នោ វុឌ្ឍនាធិប្បាយោ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន ឋបេតព្វោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន ឋបេតព្វោ ។ កតមេហិ បញ្ចហិ ។ អបរិសុទ្ធកាយសមាចារោ ហោតិ អបរិសុទ្ធវចីសមាចារោ ហោតិ អបរិសុទ្ធាជីវោ ហោតិ ពាលោ ហោតិ អព្យត្តោ ន បដិពលោ អនុយុញ្ជិយមានោ អនុយោគ ទាតុំ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ

ជេរគំរាមភិក្ខុ ១ ផ្សំផ្គុំពួកភិក្ខុនឹងពួកភិក្ខុ ១ ។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ ៥ នេះឯង ។

(៤៨៧) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុទាំងឡាយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ មិនត្រូវបញ្ឈប់ នូវឱវាទដល់ភិក្ខុទាំងឡាយទេ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនមានសេចក្តីខ្មាស ១ ជាមនុស្សល្ងង់ ១ មិនមែនជាបកតត្ត ១ ជាអ្នកនិយាយប៉ងញុំាងភិក្ខុដទៃឲ្យឃ្លាតចាក (សាសនា) ១ មិនប្រាថ្នានឹងចេញចាកអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវបញ្ឈប់នូវឱវាទដល់ភិក្ខុទាំងឡាយទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុទាំងឡាយដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមានកាយសមាចារមិនបរិសុទ្ធ ១ មានវចីសមាចារមិនបរិសុទ្ធ ១ មានអាជីវៈមិនបរិសុទ្ធ ១ ជាមនុស្សល្ងង់មិនឈ្លាសវៃ ១ កាលបើគេសាកសួរ ក៏មិនអាចនឹងឲ្យគេសាកសួរ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង

ឧបាលិបញ្ចកំ ភិក្ខុនីនំ ឱវាទោ ន ឋបេតព្វោ

ឋបេតព្វោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន ឋបេតព្វោ ។ កតមេហិ បញ្ចហិ ។ កាយិកេន អនាចារេន សមន្នាគតោ ហោតិ វាចសិកេន អនាចារេន សមន្នាគតោ ហោតិ កាយិកវាចសិកេន អនាចារេន សមន្នាគតោ ហោតិ ភិក្ខុនីនំ អក្កោសកបរិភាសកោ ហោតិ ភិក្ខុនីហិ សទ្ធឹ សំសដ្ឋោ វិហរតិ អននុលោមិកេន សំសគ្គេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន ឋបេតព្វោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន ឋបេតព្វោ ។ កតមេហិ បញ្ចហិ ។ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច ភណ្ឌនការកោ ច ហោតិ កលហការកោ សិក្ខាយ ច ន បរិបូរការី ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន ឋបេតព្វោតិ ។

មិនត្រូវបញ្ឈប់នូវឱវាទដល់ភិក្ខុនីទាំងឡាយទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនត្រូវបញ្ឈប់នូវឱវាទដល់ភិក្ខុនីទាំងឡាយដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុប្រកបដោយអនាចារខាងផ្លូវកាយ ១ ប្រកបដោយអនាចារខាងផ្លូវវាចា ១ ប្រកបដោយអនាចារទាំងផ្លូវកាយទាំងផ្លូវវាចា ១ ជេរគំរាមពួកភិក្ខុនី ១ នៅច្រឡូកច្រឡំនឹងពួកភិក្ខុនី ដោយសេចក្តីច្រឡូកច្រឡំមិនសមគួរ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយទេ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនមានសេចក្តីខ្មាស ១ ជាមនុស្សល្ងង់ ១ មិនមែនជាបកតត្ត ១ ជាអ្នកធ្វើនូវការបង្កហេតុ ធ្វើនូវជម្លោះ ១ ជាអ្នកមិនធ្វើនូវសិក្ខាឲ្យបរិបូណ៌ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយទេ ។

[៦៨៨] កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន គហេតព្វោតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន គហេតព្វោ ។ កតមេហិ បញ្ចហិ ។ កាយិកេន អនាចារេន សមន្នាគតោ ហោតិ វាចសិកេន អនាចារេន សមន្នាគតោ ហោតិ កាយិកវាចសិកេន អនាចារេន សមន្នាគតោ ហោតិ ភិក្ខុនីនំ អក្កោសកបរិភាសកោ ហោតិ ភិក្ខុនីហិ សទ្ធឹ សំសដ្ឋោ វិហរតិ អននុលោមិកេន សំសគ្គេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន គហេតព្វោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន គហេតព្វោ ។ កតមេហិ បញ្ចហិ ។ អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច គមិកោ វា ហោតិ គិលានោ វា ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា ភិក្ខុនីនំ ឱវាទោ ន គហេតព្វោតិ ។

(៤៨៨) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលមិនត្រូវឲ្យពួកភិក្ខុនីកាន់យកឱវាទ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដែលមិនត្រូវឲ្យពួកភិក្ខុនីកាន់យកឱវាទ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុប្រកបដោយអនាចារខាងផ្លូវកាយ ១ ប្រកបដោយអនាចារខាងផ្លូវវាចា ១ ប្រកបដោយអនាចារទាំងផ្លូវកាយទាំងផ្លូវវាចា ១ ជាអ្នកជេរគំរាមពួកភិក្ខុនី ១ ជាអ្នកនៅច្របូកច្របល់នឹងពួកភិក្ខុនី ដោយសេចក្តីច្របូកច្របល់មិនសមគួរ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវឲ្យពួកភិក្ខុនីកាន់យកឱវាទ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏មិនត្រូវឲ្យពួកភិក្ខុនីកាន់យកឱវាទដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនមានសេចក្តីខ្មាស ១ ជាមនុស្សពាល ១ មិនមែនជាបកតត្ត ១ ជាអ្នកដំណើរ ១ ជាអ្នកមានជម្ងឺ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវឲ្យពួកភិក្ខុនីកាន់យកឱវាទ ។

[២៨៩] កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ ន សាកច្ឆាតព្វន្តិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ ន សាកច្ឆាតព្វោ ។ កតមេហិ បញ្ចហិ ។ ន អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ ន អសេក្ខេន សមាធិក្ខន្ធេន សមន្នាគតោ ហោតិ ន អសេក្ខេន បញ្ញាខន្ធេន[១] សមន្នាគតោ ហោតិ ន អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតោ ហោតិ ន អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ ន សាកច្ឆាតព្វោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ សាកច្ឆាតព្វោ ។ កតមេហិ បញ្ចហិ ។ អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន សមាធិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន បញ្ញាខន្ធេន[២] សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ។

១-២ បញ្ញាក្ខន្ធេនាតិ សំយោគោ សក្កដភាសានុសារេន កតោ យេភុយ្យេន ទិស្សតិ ។

(៦៨៩) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន កិច្ចមិនត្រូវសាកច្ឆាជាមួយនឹងកិច្ច ដែលប្រកបដោយអង្គប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កិច្ចមិនត្រូវសាកច្ឆាជាមួយនឹងកិច្ចដែលប្រកបដោយអង្គ ៥ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺកិច្ចមិនប្រកបដោយសីលក្ខន្ធ ជារបស់អសេក្ខបុគ្គល ១ មិនប្រកបដោយសមាធិក្ខន្ធ ជារបស់អសេក្ខបុគ្គល ១ មិនប្រកបដោយបញ្ញាខន្ធ ជារបស់អសេក្ខបុគ្គល ១ មិនប្រកបដោយវិមុត្តិក្ខន្ធ ជារបស់អសេក្ខបុគ្គល ១ មិនប្រកបដោយវិមុត្តិញាណទស្សនក្ខន្ធ ជារបស់អសេក្ខបុគ្គល ១ ។ ម្នាលឧបាលិ កិច្ចមិនត្រូវសាកច្ឆាជាមួយនឹងកិច្ច ដែលប្រកបដោយអង្គ ៥ នេះឯង ។ ម្នាលឧបាលិ កិច្ចត្រូវសាកច្ឆាជាមួយនឹងកិច្ច ដែលប្រកបដោយអង្គ ៥ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺកិច្ចប្រកបដោយសីលក្ខន្ធ ជារបស់អសេក្ខបុគ្គល ១ ប្រកបដោយសមាធិក្ខន្ធ ជារបស់អសេក្ខបុគ្គល ១ ប្រកបដោយបញ្ញាខន្ធ ជារបស់អសេក្ខបុគ្គល ១ ប្រកបដោយវិមុត្តិក្ខន្ធ ជារបស់អសេក្ខបុគ្គល ១ ប្រកបដោយវិមុត្តិញាណទស្សនក្ខន្ធ ជារបស់អសេក្ខបុគ្គល ១ ។

ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ សាកច្ឆាតព្វំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ ន សាកច្ឆាតព្វំ ។ កតមេហិ បញ្ចហិ ។ ន អត្ថប្បដិសម្ភិទាបត្តោ ហោតិ ន ធម្មប្បដិសម្ភិទាបត្តោ ហោតិ ន និរុត្តិប្បដិសម្ភិទាបត្តោ ហោតិ ន បដិភាណប្បដិសម្ភិទាបត្តោ ហោតិ ន យថាវិមុត្តំ ចិត្តំ បច្ចវេក្ខតិ(១) ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ ន សាកច្ឆាតព្វំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ សាកច្ឆាតព្វំ ។ កតមេហិ បញ្ចហិ ។ អត្ថប្បដិសម្ភិទាបត្តោ ហោតិ ធម្មប្បដិសម្ភិទាបត្តោ ហោតិ និរុត្តិប្បដិសម្ភិទាបត្តោ ហោតិ បដិភាណប្បដិសម្ភិទាបត្តោ ហោតិ យថាវិមុត្តំ ចិត្តំ បច្ចវេក្ខតិ(២) ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតេន ភិក្ខុនា សទ្ធឹ សាកច្ឆាតព្វន្តិ ។

ភិក្ខុនីឱវាទវគ្គោ អដ្ឋមោ ។

១-២ ឱ. បច្ចវេក្ខតា ។

ម្នាលឧបាលិ ភិក្ខុត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ ៥ នេះឯង ។ ម្នាលឧបាលិ ភិក្ខុមិនត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ ៥ ដទៃទៀត ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនទាន់ដល់នូវអត្ថប្បដិសម្ភិទា (ការបែកធ្លាយក្នុងអដ្ឋកថា) ១ មិនទាន់ដល់នូវធម្មប្បដិសម្ភិទា (ការបែកធ្លាយក្នុងបាលី) ១ មិនទាន់ដល់នូវនិរុត្តិប្បដិសម្ភិទា (ការបែកធ្លាយក្នុងភាសា ឬដីកា) ១ មិនទាន់ដល់នូវបដិភាណប្បដិសម្ភិទា (ការបែកធ្លាយដោយសេចក្ដីឈ្លាសវៃ) ១ មិនពិចារណានូវចិត្ត ដែលរួចហើយតាមគតិលេសយ៉ាងណា ១ ។ ម្នាលឧបាលិ ភិក្ខុមិនត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ ៥ នេះឯង ។ ម្នាលឧបាលិ ភិក្ខុត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ ៥ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដល់នូវអត្ថប្បដិសម្ភិទា ១ ដល់នូវធម្មប្បដិសម្ភិទា ១ ដល់នូវនិរុត្តិប្បដិសម្ភិទា ១ ដល់នូវបដិភាណប្បដិសម្ភិទា ១ ពិចារណានូវចិត្តដែលរួចហើយតាមគតិលេសយ៉ាងណា ១ ។ ម្នាលឧបាលិ ភិក្ខុត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ ៥ នេះឯង ។

ចប់ ភិក្ខុនីឱវាទវគ្គ ទី ៨ ។

តស្សុទ្ទានំ

(២៩០) ភិក្ខុនីហេវ កាតព្វំ
អបរេហិ តថា ទុវេ
ភិក្ខុនីនំ តយោ កម្មា
ន ឋបេតព្វោ ទ្វេ ទុកា
ន គហេតព្វោ(១) ទ្វេ វុត្តា
សាកច្ឆាសុ ច ទ្វេ ទុកាតិ ។

(២៩១) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និតព្វោតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និ-តព្វោ ។ កតមេហិ បញ្ចហិ ។ ន អត្ថកុសលោ ហោតិ ន ធម្មកុសលោ ហោតិ ន និរុត្តិកុសលោ ហោតិ ន ព្យញ្ជនកុសលោ ហោតិ ន បុព្វាបរកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និតព្វោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។

១ ម. គហេតព្វា ។

ឧទ្ទាន គឺបញ្ជីរឿងនៃភិក្ខុនីឧបាលិវគ្គ នោះដូច្នេះ

(៦៩០) និយាយអំពីរឿងដែលភិក្ខុនីសង្ឃត្រូវធ្វើកម្ម ១ អំពីកម្មពីរយ៉ាង ដែលភិក្ខុនីសង្ឃត្រូវធ្វើដល់ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត១ អំពីកម្ម ៣ យ៉ាង ដែលសង្ឃត្រូវធ្វើដល់ពួកភិក្ខុនី១ អំពីភិក្ខុមិនត្រូវបញ្ឈប់ឧបោសថមាន៦ចុកៈ ១ អំពីភិក្ខុមិនត្រូវឲ្យកាន់យកឧបោសថមាន ៦ ចុកៈ ដែលព្រះមានភាគត្រាស់ហើយ ១ អំពីចុកៈ ៦ ក្នុងការនិយាយធម៌ ១ ។

(៦៩១) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលសង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្ម ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនឈ្លាសក្នុងអដ្ឋកថា ១ មិនឈ្លាសក្នុងបាលី ១ មិនឈ្លាសក្នុងភាសា១ មិនឈ្លាសក្នុងព្យញ្ជនៈ (មានសិថិលនិងធនិតជាដើម) ១ មិនឈ្លាសក្នុងពាក្យខាងដើមនិងខាងចុង ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន ។

---

១ ការជ្រើសរើសយកភិក្ខុអំពីសង្ឃ ដើម្បីរម្ងាប់អធិករណ៍ ដែលកើតឡើង ហៅថា ឧព្វាហិកាកម្ម ។

កតមេហិ បញ្ចហិ ។ អត្ថកុសលោ ហោតិ ធម្មកុសលោ ហោតិ និរុត្តិកុសលោ ហោតិ ព្យញ្ជនកុសលោ ហោតិ បុព្វាបរកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និតព្វោ ។ កតមេហិ បញ្ចហិ ។ កោធនោ ហោតិ កោធាភិភូតោ មក្ខី ហោតិ មក្ខាភិភូតោ បឡាសី ហោតិ បឡាសាភិភូតោ ឥស្សុកី ហោតិ ឥស្សាភិភូតោ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និតព្វោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ កតមេហិ បញ្ចហិ ។ ន កោធនោ ហោតិ ន កោធាភិភូតោ ន មក្ខី ហោតិ ន មក្ខាភិភូតោ ន បឡាសី ហោតិ ន បឡាសាភិភូតោ

អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុឈ្លាសក្នុងអដ្ឋកថា ១ ឈ្លាសក្នុងបាលី ១ ឈ្លាសក្នុងភាសា ១ ឈ្លាសក្នុងព្យញ្ជនៈ ១ ឈ្លាសក្នុងពាក្យខាងដើមនិងខាងចុង ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត សង្ឃក៏មិនត្រូវសន្មត ដោយឧព្វាហិកាកម្មដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកក្រោធ បណ្តាយឲ្យសេចក្តីក្រោធគ្របសង្កត់ ១ មានសេចក្តីលុបគុណ បណ្តាយឲ្យសេចក្តីលុបគុណគ្របសង្កត់ ១ មានសេចក្តីលើកខ្លួន បណ្តាយឲ្យសេចក្តីលើកខ្លួនគ្របសង្កត់ ១ មានសេចក្តីប្រណែន បណ្តាយឲ្យសេចក្តីប្រណែនគ្របសង្កត់ ១ មានសេចក្តីប្រកាន់ដោយទិដ្ឋិរបស់ខ្លួន មានសេចក្តីប្រកាន់មាំ លះបង់បានដោយកម្រ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ សង្ឃគប្បីសន្មត ដោយឧព្វាហិកាកម្មបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកមិនក្រោធ មិនបណ្តាយឲ្យសេចក្តីក្រោធគ្របសង្កត់ ១ ជាមនុស្សមិនមានសេចក្តីលុបគុណ មិនបណ្តាយឲ្យសេចក្តីលុបគុណគ្របសង្កត់ ១ ជាមនុស្សមិនមានសេចក្តីលើកខ្លួន មិនបណ្តាយឲ្យសេចក្តី

ន ឥស្សុកី ហោតិ ន ឥស្សាកិក្កោ អសន្ទិដ្ឋិបរាមាសី ហោតិ អនាធានគ្គាហី សុប្បដិនិស្សគ្គី ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និតព្វោ ។ កតមេហិ បញ្ចហិ ។ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបំ ជនេតិ អក្ខមោ ហោតិ អប្បទក្ខិណគ្គាហី អនុសាសនឹ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និតព្វោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ កតមេហិ បញ្ចហិ ។ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិត្ថីយតិ ន កោបំ ជនេតិ ខមោ ហោតិ បទក្ខិណគ្គាហី អនុសាសនឹ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និតព្វោ ។

លើកខ្លួនគ្រប់សង្កត់ ១ ជាមនុស្សមិនប្រណាំង មិនបណ្ដាយឲ្យសេចក្ដីប្រណាំងគ្រប់សង្កត់ ១ ជាមនុស្សមិនប្រកាន់ដោយទិដ្ឋិរបស់ខ្លួន មិនប្រកាន់មាំ លះបង់បានដោយងាយ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត សង្ឃក៏មិនត្រូវសន្មតដោយឧព្វាហិកាកម្មដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុតែងកក្រើករំពើក ១ តែងផ្ទួនសេចក្ដីព្យាបាទ ១ តែងបង្អៀតបង្អល់ដោយសេចក្ដីក្រោធ ១ តែងបណ្ដាលឲ្យកើតសេចក្ដីក្រោធ ១ មិនចេះអត់ធន់ មិនកាន់យកពាក្យប្រៀនប្រដៅដោយចំណែកខាងស្ដាំ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនកក្រើករំពើក ១ មិនផ្ទួនសេចក្ដីព្យាបាទ ១ មិនបង្អៀតបង្អល់ដោយសេចក្ដីក្រោធ ១ មិនបណ្ដាយឲ្យកើតសេចក្ដីក្រោធ ១ ចេះអត់ធន់ ជាអ្នកកាន់យកពាក្យប្រៀនប្រដៅដោយចំណែកខាងស្ដាំ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត សង្ឃក៏មិនត្រូវសន្មតដោយឧព្វាហិកាកម្មដែរ ។

កតមេហិ បញ្ចហិ ។ បសារេតា(១) ហោតិ នោ សារេ-
តា អនោកាសកម្មំ ការាបេត្វា វត្តា ហោតិ ន យ-
ថាធម្មេ យថាវិនយេ យថាបត្តិយា ចោទេតា ហោតិ ន
យថាធម្មេ យថាវិនយេ យថាបត្តិយា ការេតា ហោតិ
ន យថាទិដ្ឋិយា ព្យាកតា ហោតិ ។ ឥមេហិ ខោ ឧ-
បាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ
ន សម្មន្និតព្វោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគ-
តោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ កតមេហិ
បញ្ចហិ ។ សារេតា ហោតិ នោ បសារេតា ឱកាស-
កម្មំ ការាបេត្វា វត្តា ហោតិ យថាធម្មេ យថាវិនយេ
យថាបត្តិយា ចោទេតា ហោតិ យថាធម្មេ យថាវិនយេ
យថាបត្តិយា ការេតា ហោតិ យថាទិដ្ឋិយា ព្យាកតា
ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នា-
គតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ អបរេ-
ហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វា-
ហិកាយ ន សម្មន្និតព្វោ ។ កតមេហិ បញ្ចហិ ។
ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ

---

១ អបសារេតាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ អដ្ឋកថាយម្បិ ឯវំ ទិស្សតិ ។

អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកមិនឲ្យគេលើកឃើញ គឺបំភាន់បំប៉ាំងពាក្យអ្នកដើមចោទនឹងចម្លើយ មិនលើកស្មារតី ១ ជាអ្នកមិនសូមឱកាសកម្មសិន ហើយស្រាប់តែនិយាយ ១ ជាអ្នកមិនចោទតាមធម៌ តាមវិន័យ នឹងតាមអាបត្តិ ១ ជាអ្នកមិនកាត់សេចក្តីតាមធម៌ តាមវិន័យ នឹងតាមអាបត្តិ ១ ជាអ្នកមិនប្រាប់តាមសេចក្តីយល់ឃើញ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកឲ្យគេលើកឃើញ មិនបំភាន់គេ ១ ជាអ្នកសូមឱកាសកម្មសិន ហើយទើបនិយាយ ១ ជាអ្នកចោទតាមធម៌ តាមវិន័យ នឹងតាមអាបត្តិ ១ ជាអ្នកកាត់សេចក្តីតាមធម៌ តាមវិន័យ នឹងតាមអាបត្តិ១ ជាអ្នកប្រាប់តាមសេចក្តីយល់ឃើញ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត សង្ឃក៏មិនត្រូវសន្មតដោយឧព្វាហិកាកម្មដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុលុះឆន្ទាគតិ ១ លុះទោសាគតិ ១ លុះមោហាគតិ ១

ភយាគតឹ គច្ឆតិ អលជ្ជី ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និតព្វោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ លជ្ជី ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និតព្វោ ។ កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ អកុសលោ ច ហោតិ វិនយេ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ ន សម្មន្និតព្វោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ

លុះភយាគតិ ១ ជាអ្នកមិនមានសេចក្ដីខ្មាស ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ជាអ្នកមានសេចក្ដីអៀនខ្មាស ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត សង្ឃក៏មិនត្រូវសន្មតដោយឧព្វាហិកាកម្មដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុលុះឆន្ទាគតិ ១ លុះទោសាគតិ ១ លុះមោហាគតិ ១ លុះភយាគតិ ១ ជាអ្នកមិនឈ្លាសក្នុងវិន័យ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះ សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១

ន ភយាគតឹ គច្ឆតិ កុសលោ ច ហោតិ វិនយេ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោតិ ។

(២៩២) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតោ ភិក្ខុ ពាលោត្វេវ សង្ខំ គច្ឆតិ[១] ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ ពាលោត្វេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។ សុត្តំ ន ជានាតិ សុត្តានុលោមំ ន ជានាតិ វិនយំ ន ជានាតិ វិនយានុលោមំ ន ជានាតិ ន ច ឋានាឋានកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ពាលោត្វេវ សង្ខំ គច្ឆតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។ សុត្តំ ជានាតិ សុត្តានុលោមំ ជានាតិ វិនយំ ជានាតិ វិនយានុលោមំ ជានាតិ ឋានាឋានកុសលោ ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ បណ្ឌិ-

---

១ ឱ. ម. គច្ឆតីតិ ។

មិនលុះភយាគតិ ១ ជាអ្នកឈ្លាសក្នុងវិន័យ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង សង្ឃគប្បីបន្ទាត់ដោយឧព្វាហិកាកម្មបាន ។

(២៩២) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ទើបដល់នូវការរាប់ថាជាភិក្ខុពាលពិត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ទើបដល់នូវការរាប់ថាជាភិក្ខុពាលមែន ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនចេះសូត្រ ១ មិនចេះសុត្តានុលោម ១ មិនចេះវិន័យ ១ មិនចេះវិនយានុលោម ១ ជាអ្នកមិនឈ្លាសក្នុងហេតុដែលគួរនិងហេតុមិនគួរ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបដល់នូវការរាប់ថាជាភិក្ខុពាលពិត ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុចេះសូត្រ ១ ចេះសុត្តានុលោម ១ ចេះវិន័យ ១ ចេះវិនយានុលោម ១ ជាអ្នកឈ្លាសក្នុងហេតុដែលគួរនិងហេតុមិនគួរ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិត

តោ ត្វេវ សង្ខ្យំ គច្ឆតិ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ
សមន្នាគតោ ភិក្ខុ ពាលោ ត្វេវ សង្ខ្យំ គច្ឆតិ។ កតមេហិ
បញ្ចហិ។ ធម្មំ ន ជានាតិ ធម្មានុលោមំ ន ជានាតិ
វិនយំ ន ជានាតិ វិនយានុលោមំ ន ជានាតិ ន ច
បុព្វាបរកុសលោ ហោតិ។ ឥមេហិ ខោ ឧបាលិ បញ្ច-
ហង្គេហិ សមន្នាគតោ ភិក្ខុ ពាលោ ត្វេវ សង្ខ្យំ គច្ឆតិ។
បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ បណ្ឌិតោ ត្វេវ
សង្ខ្យំ គច្ឆតិ។ កតមេហិ បញ្ចហិ។ ធម្មំ ជានាតិ
ធម្មានុលោមំ ជានាតិ វិនយំ ជានាតិ វិនយានុលោមំ
ជានាតិ បុព្វាបរកុសលោ ច ហោតិ។ ឥមេហិ ខោ
ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ បណ្ឌិតោ ត្វេវ
សង្ខ្យំ គច្ឆតិ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ ស-
មន្នាគតោ ភិក្ខុ ពាលោ ត្វេវ សង្ខ្យំ គច្ឆតិ។ កតមេហិ
បញ្ចហិ។ វត្ថុំ ន ជានាតិ និទានំ ន ជានាតិ បញ្ញត្តិំ
ន ជានាតិ បទបច្ឆាភដ្ឋំ ន ជានាតិ អនុសន្ធិវចនបថំ
ន ជានាតិ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ

ពិត ៗ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏ដល់នូវការរាប់ថាជាភិក្ខុពាលដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនចេះធម៌ ១ មិនចេះធម្មានុលោម ១ មិនចេះវិន័យ ១ មិនចេះវិនយានុលោម ១ ជាអ្នកមិនឈ្លាស ក្នុងពាក្យខាងដើមនិងពាក្យខាងចុង ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបដល់នូវការរាប់ថាជាភិក្ខុពាលពិត ៗ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត ៗ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុចេះធម៌ ១ ចេះធម្មានុលោម ១ ចេះវិន័យ ១ ចេះវិនយានុលោម ១ ជាអ្នកឈ្លាសក្នុងពាក្យខាងដើមនិងពាក្យខាងចុង ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត ៗ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ដល់នូវការរាប់ថាជាភិក្ខុពាលពិត ៗ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនដឹងវត្ថុ ១ មិនដឹងនិទាន ១ មិនដឹងបញ្ញត្តិ ១ មិនដឹងបទបាលីក្រោយមុខ ១ មិនដឹងគន្ធ៌ពាក្យដែលជាប់គ្នា ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង

សមន្នាគតោ ភិក្ខុ ពាលោត្វេវ សង្ខំ គច្ឆតិ ។ បញ្ចហុ-
បាលិ អង្គេហិ សមន្នាគតោ ភិក្ខុ បណ្ឌិតោត្វេវ សង្ខំ
គច្ឆតិ ។ កតមេហិ បញ្ចហិ ។ វត្ថុំ ជានាតិ និទានំ
ជានាតិ បញ្ញត្តឹ ជានាតិ បទបច្ចាភដ្ឋំ ជានាតិ
អនុសន្ធិវចនបថំ ជានាតិ ។ ឥមេហិ ខោ ឧបាលិ
បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ បណ្ឌិតោត្វេវ សង្ខំ
គច្ឆតិ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ
ភិក្ខុ ពាលោត្វេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។
អាបត្តឹ ន ជានាតិ អាបត្តិសមុដ្ឋានំ ន ជានាតិ
អាបត្តិយា បយោគំ ន ជានាតិ អាបត្តិយា វូបសមំ
ន ជានាតិ ន អាបត្តិយា វិនិច្ឆយកុសលោ ហោតិ ។
ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ
ពាលោត្វេវ សង្ខំ គច្ឆតិ ។ បញ្ចហុបាលិ អង្គេហិ
សមន្នាគតោ ភិក្ខុ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ ។
កតមេហិ បញ្ចហិ ។ អាបត្តឹ ជានាតិ អាបត្តិសមុដ្ឋានំ
ជានាតិ អាបត្តិយា បយោគំ ជានាតិ អាបត្តិយា វូប-

ដល់នូវការរាប់ថាជាភិក្ខុពាលពិត ៗ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត ៗ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងវត្ថុ ១ ដឹងនិទាន ១ ដឹងបញ្ញត្តិ ១ ដឹងបទបាលីក្រោយមុន ១ ដឹងគន្លងពាក្យដែលជាប់គ្នា ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិតមែន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏ដល់នូវការរាប់ថាជាភិក្ខុពាលដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនដឹងអាបត្តិ ១ មិនដឹងសមុដ្ឋាននៃអាបត្តិ ១ មិនដឹងប្រយោគនៃអាបត្តិ ១ មិនដឹងសេចក្តីរម្ងាប់នៃអាបត្តិ ១ ជាអ្នកមិនឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ដល់នូវការរាប់ថាជាភិក្ខុពាលពិត ៗ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត ៗ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងអាបត្តិ ១ ដឹងសមុដ្ឋាននៃអាបត្តិ ១ ដឹងប្រយោគនៃអាបត្តិ ១ ដឹងសេចក្តីរម្ងាប់នៃអាបត្តិ ១ ជា

សមំ ជានាតិ អាបត្តិយោ វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ពាលោត្វេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។ អធិករណំ ន ជានាតិ អធិករណសមុដ្ឋានំ ន ជានាតិ អធិករណស្ស បយោគំ ន ជានាតិ អធិករណស្ស វូបសមំ ន ជានាតិ ន អធិករណស្ស វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ ពាលោត្វេវ សង្ខំ គច្ឆតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ បណ្ឌិតោត្វេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។ អធិករណំ ជានាតិ អធិករណសមុដ្ឋានំ ជានាតិ អធិករណស្ស បយោគំ ជានាតិ អធិករណស្ស វូបសមំ ជានាតិ អធិករណស្ស វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ បណ្ឌិតោត្វេវ សង្ខំ គច្ឆតីតិ ។

ឧព្វាហិកាវគ្គោ នវមោ(១) ។

---

១ សព្វត្ថ ឧព្វាហិកវគ្គោ និដ្ឋិតោ នវមោតិ ទិស្សតិ ។ ឥតោ បរំបិ តត្តវគ្គាវសានេ និដ្ឋិតោតិ វេបល្លេ លិខិយតិ ។

អ្នកឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត ក៏ដល់នូវការរាប់ថាជាភិក្ខុពាលដែរ ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុមិនដឹងអធិករណ៍ ១ មិនដឹងសមុដ្ឋាននៃអធិករណ៍ ១ មិនដឹងប្រយោគនៃអធិករណ៍ ១ មិនដឹងសេចក្តីរម្ងាប់នៃអធិករណ៍ ១ ជាអ្នកមិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ដល់នូវការរាប់ថាជាភិក្ខុពាលពិត ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺភិក្ខុដឹងអធិករណ៍ ១ ដឹងសមុដ្ឋាននៃអធិករណ៍ ១ ដឹងប្រយោគនៃអធិករណ៍ ១ ដឹងសេចក្តីរម្ងាប់នៃអធិករណ៍ ១ ជាអ្នកឈ្លាសក្នុងការវិនិច្ឆ័យនៃអធិក-ណ៍ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិតមែន ។

ចប់ឧព្វាហិកាវគ្គ ទី ៩ ។

តស្សុទ្ទានំ

[២៩៣] អនត្តកុសលោ ចេវ
កោធនោ កុប្បតី ច យោ
បសារេតា ជប្បតិ
ន កុសលោ តថេវ ច
សុត្តំ ធម្មញ្ច វត្ថុញ្ច
អាបត្តិ អធិករណំ
ទ្វេ ទ្វេ បកាសិតា សព្វេ
កណ្ហសុក្កំ វិជានថាតិ ។

[២៩៤] កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុន្តិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ អាបត្តឹ ន ជានាតិ អាបត្តិសមុដ្ឋានំ ន ជានាតិ អាបត្តិយា បយោគំ ន ជានាតិ អាបត្តិយា វូបសមំ ន ជានាតិ ន អាបត្តិយា វិនិច្ឆយកុសលោ(១) ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ច-

---

១ ឱ. ម. អាបត្តិយា ន វិនិច្ឆយកុសលោ ។

ឧទ្ទាន គឺបញ្ជីរឿងនៃឧព្វាហិកាវគ្គនោះ ដូច្នេះ

(៤៩៣) និយាយអំពីភិក្ខុមិនឈ្លាសក្នុងអដ្ឋកថា ១ ភិក្ខុជាអ្នកក្រោធ ១ ភិក្ខុតែងកក្រើករំពើក ១ ភិក្ខុជាអ្នកបំភាន់គេ ១ ភិក្ខុលុះឆន្ទាគតិ ១ ភិក្ខុមិនឈ្លាស ១ សុត្តៈ ១ ធម្មៈ ១ វត្ថុ ១ អាបត្តិ ១ អធិករណ៍ ១ ធម៌ទាំងអស់មានពីរ ៗ ដែលព្រះអង្គសំដែងហើយ អ្នកទាំងឡាយចូរដឹង ថាជាធម៌ខ្មៅនឹងស គឺមានអាក្រក់ មានល្អ ។

(៤៩៤) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន មិនគួររម្ងាប់អធិករណ៍បាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ មិនគួររម្ងាប់អធិករណ៍បាន ។ អង្គ ៥ នោះតើដូចម្តេច ។ គឺភិក្ខុមិនដឹងអាបត្តិ ១ មិនដឹងសមុដ្ឋាននៃអាបត្តិ ១ មិនដឹងប្រយោគនៃអាបត្តិ ១ មិនដឹងការរម្ងាប់អាបត្តិ ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុ

ឧបាលិបញ្ចកំ អលំបិ នាលំបិ អធិករណំ វូបសមេតុំ

ហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ អាបត្តឹ ជានាតិ អាបត្តិសមុដ្ឋានំ ជានាតិ អាបត្តិយា បយោគំ ជានាតិ អាបត្តិយា វូបសមំ ជានាតិ អាបត្តិយា វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ អធិករណំ ន ជានាតិ អធិករណសមុដ្ឋានំ ន ជានាតិ អធិករណស្ស បយោគំ ន ជានាតិ អធិករណស្ស វូបសមំ ន ជានាតិ ន អធិករណស្ស[១] វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ អធិករណំ

---

១ ឱ. ម. អធិករណស្ស ន ។

ប្រកបដោយអង្គ ៥ នេះឯង មិនគួររម្ងាប់អធិករណ៍ទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួររម្ងាប់អធិករណ៍បាន ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុដឹងអាបត្តិ ១ ដឹងសមុដ្ឋាននៃអាបត្តិ ១ ដឹងប្រយោគនៃអាបត្តិ ១ ដឹងកិរិយារម្ងាប់អាបត្តិ ១ ឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបគួររម្ងាប់អធិករណ៍បាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនដឹងអធិករណ៍ ១ មិនដឹងសមុដ្ឋាននៃអធិករណ៍ ១ មិនដឹងប្រយោគនៃអធិករណ៍ ១ មិនដឹងកិរិយារម្ងាប់អធិករណ៍ ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួររម្ងាប់អធិករណ៍ទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួររម្ងាប់អធិករណ៍បាន ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុ

ជានាតិ អធិករណសមុដ្ឋានំ ជានាតិ អធិករណស្ស បយោគំ ជានាតិ អធិករណស្ស វូបសមំ ជានាតិ អធិករណស្ស វិនិច្ឆយកុសលោ ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ អលជ្ជី ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ លជ្ជី ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។

ដឹងអធិករណ៍ ១ ដឹងសមុដ្ឋាននៃអធិករណ៍ ១ ដឹងប្រយោគនៃអធិករណ៍ ១ ដឹងកិរិយារម្ងាប់អធិករណ៍ ១ ឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបគួររម្ងាប់អធិករណ៍បាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ ។ អង្គ ៥ តើដូចម្ដេច ។ គឺភិក្ខុលំអៀងព្រោះសេចក្ដីស្រឡាញ់ ១ លំអៀងព្រោះសេចក្ដីស្អប់ ១ លំអៀងព្រោះសេចក្ដីល្ងង់ ១ លំអៀងព្រោះសេចក្ដីខ្លាច ១ ជាអ្នកឥតខ្មាស ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនគួររម្ងាប់អធិករណ៍ទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួររម្ងាប់អធិករណ៍បាន ។ អង្គ ៥ តើដូចម្ដេច ។ គឺភិក្ខុមិនលំអៀងព្រោះសេចក្ដីស្រឡាញ់ ១ មិនលំអៀងព្រោះសេចក្ដីស្អប់ ១ មិនលំអៀងព្រោះសេចក្ដីល្ងង់ ១ មិនលំអៀងព្រោះសេចក្ដីខ្លាច ១ ជាអ្នកមានខ្មាស ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបគួររម្ងាប់អធិករណ៍បាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ ។

កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ អប្បស្សុតោ ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ពហុស្សុតោ ច ហោតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ វត្ថុំ ន ជានាតិ និទានំ ន ជានាតិ បញ្ញត្តឹ ន ជានាតិ បទបច្ឆាភដ្ឋំ ន ជានាតិ អនុសន្ធិវចនបថំ ន ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ វត្ថុំ ជានាតិ

អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់ ១ លំអៀងព្រោះសេចក្តីស្អប់ ១ លំអៀងព្រោះសេចក្តីល្ងង់ ១ លំអៀងព្រោះសេចក្តីខ្លាច ១ ជាអ្នកចេះដឹងតិច ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ នេះឯង មិនគួររម្ងាប់អធិករណ៍ទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួររម្ងាប់អធិករណ៍បាន ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់ ១ មិនលំអៀងព្រោះសេចក្តីស្អប់ ១ មិនលំអៀងព្រោះសេចក្តីល្ងង់ ១ មិនលំអៀងព្រោះសេចក្តីខ្លាច ១ ជាអ្នកចេះដឹងច្រើន ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបគួររម្ងាប់អធិករណ៍បាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ ។ អង្គ៥ តើដូចម្តេច ។ គឺភិក្ខុមិនដឹងវត្ថុ ១ មិនដឹងនិទាន ១ មិនដឹងបញ្ញត្តិ ១ មិនដឹងបទខាងចុងនឹងបទខាងដើម ១ មិនដឹងគន្លងពាក្យដែលជាប់គ្នា ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនគួររម្ងាប់អធិ-ករណ៍ទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួររម្ងាប់អធិករណ៍បាន ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុដឹងវត្ថុ ១

ឋានំ ជានាតិ បញ្ញត្តឹ ជានាតិ បទបច្ចាភដ្ឋំ ជានាតិ
អនុសន្ធិវចនបថំ ជានាតិ ។ ឥមេហិ ខោ ឧបាលិ
បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ
វូបសមេតុំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សម-
ន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ កត-
មេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ
មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ អកុសលោ ច
ហោតិ វិនយេ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ
សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។
បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិ-
ករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទា-
គតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ
ន ភយាគតឹ គច្ឆតិ កុសលោ ច ហោតិ វិនយេ ។
ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ
អលំ អធិករណំ វូបសមេតុំ ។ អបរេហិបិ ឧបាលិ
បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ
វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ

ដឹងនិទាន ១ ដឹងបញ្ញត្តិ ១ ដឹងបទខាងចុងនឹងបទខាងដើម ១ ដឹងគន្លងពាក្យដែលជាប់តគ្នា ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ នេះឯង ទើបគួររម្ងាប់អធិករណ៍បាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ ។ អង្គ ៩ តើដូចម្តេច ។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់ ១ លំអៀងព្រោះសេចក្តីស្អប់ ១ លំអៀងព្រោះសេចក្តីល្ងង់ ១ លំអៀងព្រោះសេចក្តីខ្លាច ១ ជាអ្នកមិនឈ្លាសក្នុងវិន័យ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ នេះឯង មិនគួររម្ងាប់អធិករណ៍ទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ ទើបគួររម្ងាប់អធិករណ៍បាន ។ អង្គ ៩ តើដូចម្តេច ។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់ ១ មិនលំអៀងព្រោះសេចក្តីស្អប់ ១ មិនលំអៀងព្រោះសេចក្តីល្ងង់ ១ មិនលំអៀងព្រោះសេចក្តីខ្លាច ១ ជាអ្នកឈ្លាសក្នុងវិន័យ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ នេះឯង ទើបគួររម្ងាប់អធិករណ៍បាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៩ ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ ។ អង្គ ៩ តើដូចម្តេច ។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់ ១

ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ បុគ្គលគរុ ហោតិ នោ សង្ឃគរុ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ សង្ឃគរុ ហោតិ នោ បុគ្គលគរុ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ អាមិសគរុ ហោតិ នោ សទ្ធម្មគរុ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ នាលំ អធិករណំ វូបសមេតុំ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។ កតមេហិ បញ្ចហិ ។

លំអៀងព្រោះសេចក្តីស្អប់១ លំអៀងព្រោះសេចក្តីល្ងង់ ១ លំអៀងព្រោះសេចក្តីខ្លាច ១ ជាអ្នកមានចិត្តជន់កន្លងបុគ្គល មិនជន់កន្លងសង្ឃ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនគួរនឹងរម្ងាប់អធិករណ៍ទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ទើបគួរនឹងរម្ងាប់អធិក-រណ៍បាន ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់១ មិនលំអៀងព្រោះសេចក្តីស្អប់១ មិនលំអៀងព្រោះសេចក្តីល្ងង់១ មិនលំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកមានចិត្តជន់កន្លងសង្ឃ មិនជន់កន្លងបុគ្គល ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបគួរនឹងរម្ងាប់អធិករណ៍បាន ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀតមិនគួរនឹងរម្ងាប់អធិករណ៍ទេ ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់១ លំអៀងព្រោះសេចក្តីស្អប់ ១ លំអៀងព្រោះសេចក្តីល្ងង់១ លំអៀងព្រោះសេចក្តីខ្លាច ១ ជាអ្នកមានចិត្តជន់កន្លងអាមិសៈ មិនជន់កន្លងព្រះសទ្ធម្ម១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ នេះឯង មិនគួរនឹងរម្ងាប់អធិករណ៍ទេ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួរនឹងរម្ងាប់អធិករណ៍បាន ។ អង្គ ៥ តើដូចម្តេច ។

ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ សទ្ធម្មគរុ ហោតិ នោ អាមិសគរុ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ អលំ អធិករណំ វូបសមេតុំ ។

[២៩៨] កតីហិ នុ ខោ ភន្តេ អាការេហិ សង្ឃោ ភិជ្ជតីតិ ។ បញ្ចហុបាលិ អាការេហិ សង្ឃោ ភិជ្ជតិ ។ កតមេហិ បញ្ចហិ ។ កម្មេន ឧទ្ទេសេន វោហារន្តោ (១) អនុស្សាវនេន សលាកគ្គាហេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហាការេហិ សង្ឃោ ភិជ្ជតីតិ ។

---

១ វោហារេនាតិ បាឋោ យុត្តតរោ មញ្ញេ ។

គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់ ១ មិនលំអៀងព្រោះសេចក្តីស្អប់ ១ មិនលំអៀងព្រោះសេចក្តីល្ងង់ ១ មិនលំអៀងព្រោះសេចក្តីខ្លាច ១ ជាអ្នកមានចិត្តធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងអាមិសៈ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ទើបគួរដើម្បីរម្ងាប់អធិករណ៍បាន ។

[២៩៥] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃបែកគ្នាដោយអាការប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ សង្ឃបែកគ្នាដោយអាការ ៥ ។ អាការ ៥ តើដូចម្តេច ។ គឺដោយកម្ម (មានអបលោកនកម្មជាដើម) ១ ដោយឧទ្ទេស (មាននិទានុទ្ទេសជាដើម) ១ ដោយសំដែងភេទករវត្ថុ ១៨ យ៉ាង ១ ដោយអនុស្សាវនៈ គឺសូត្របញ្ចាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន[១] ១ ដោយប្រគល់ស្លាក[២] ១ ។ ម្នាលឧបាលិ សង្ឃបែកគ្នាដោយអាការ ៥ យ៉ាងនេះឯង ។

---

១ អដ្ឋកថា ថាភិក្ខុអ្នកបំបែកសង្ឃសូត្របញ្ចាក់ដោយពាក្យថ្លីថ្លេះជាដើមថា លោកទាំងឡាយចូរដឹងចុះ ខ្ញុំនេះជាអ្នកចេញចាកត្រកូលខ្ពង់ខ្ពស់មកបួស ហើយជាពហុស្សូតផង សូមលោកគ្រប់រូបទុកចិត្តចុះថា ខ្ញុំមិនមែននាំឲ្យលោកគ្រប់រូបកាន់ខុសធម៌វិន័យទេ មួយទៀតខ្ញុំមិនមែនសំគាល់អវីចិនរកថាត្រជាក់ដូចជាផ្កាឧប្បលខៀវទេ ខ្ញុំមិនមែនជាមិនខ្លាចអបាយនោះទេ ។ បើតាមដីកាថា សូត្របញ្ចាក់ពាក្យខ្លួនដល់ភិក្ខុដែលខ្លួនត្រូវបំបែក ។ ២ អដ្ឋកថា ថាលុះសូត្របញ្ចាក់យ៉ាងនេះហើយក៏ញ៉ាំងចិត្តភិក្ខុទាំងនោះឲ្យជឿស៊ប់មិនឲ្យងាកបែរត្រឡប់វិញបានហើយក៏ប្រគល់ស្លាកឲ្យទៅថា លោកទាំងឡាយចូរយកស្លាកនេះទៅចុះ ។ ឯអាការទាំង ៥ នេះត្រង់អាការទី ១ ទី ២ ជាសំខាន់ក្នុងការបំបែកសង្ឃនេះ ចំណែកឯអាការទី ៣ ទី ៤ ទី ៥ គ្រាន់តែជាបុព្វភាគទេ ។

ឧបាលិបញ្ចកំ សង្ឃរាជិ សង្ឃភេទោ

[២៨៦] សង្ឃរាជីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ កិត្តាវតា ច បន សង្ឃរាជិ ចេវ ហោតិ សង្ឃភេទោ ចាតិ ។ បញ្ញត្តំ ឧបាលិ មយា អាគន្តុកានំ ភិក្ខូនំ អាគន្តុកវត្តំ ឯវំ សុប្បញ្ញត្តេ ខោ ឧបាលិ មយា សិក្ខាបទេ អាគន្តុកា ភិក្ខូ អាគន្តុកវត្តេ ន វត្តន្តិ ឯវម្បិ ខោ ឧបាលិ សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ ។ បញ្ញត្តំ ឧបាលិ មយា អាវាសិកានំ ភិក្ខូនំ អាវាសិកវត្តំ ឯវំ សុប្បញ្ញត្តេ ខោ ឧបាលិ មយា សិក្ខាបទេ អាវាសិកា ភិក្ខូ អាវាសិកវត្តេ ន វត្តន្តិ ឯវម្បិ ខោ ឧបាលិ សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ ។ បញ្ញត្តំ ឧបាលិ មយា ភិក្ខូនំ ភត្តគ្គេ ភត្តគ្គវត្តំ យថាវុឌ្ឍំ យថារត្តំ យថាបដិរូបំ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ ឯវំ សុប្បញ្ញត្តេ ខោ ឧបាលិ មយា សិក្ខាបទេ នវា ភិក្ខូ ភត្តគ្គេ ថេរានំ ភិក្ខូនំ អាសនំ បដិពាហន្តិ ឯវម្បិ

(៤៩៦) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គត្រាស់ថាការប្រេះឆានៃសង្ឃ បពិត្រព្រះអង្គដ៏ចំរើន ការប្រេះឆានៃសង្ឃ តែមិនទាន់បែកធ្លាយនៃសង្ឃតើដូចម្តេច ម្យ៉ាងទៀតការប្រេះឆានៃសង្ឃផង ការបែកធ្លាយនៃសង្ឃផងដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ តថាគតបានបញ្ញត្តអាគន្តុកវត្តនេះ ដល់ពួកភិក្ខុជាអាគន្តុកៈ ម្នាលឧបាលិ កាលបើសិក្ខាបទដែលតថាគតបានបញ្ញត្ត ដោយប្រពៃយ៉ាងនេះ ហើយ ពួកភិក្ខុជាអាគន្តុកៈមិនបានប្រព្រឹត្តក្នុងអាគន្តុកវត្ត ម្នាលឧបាលិ យ៉ាងនេះហើយហៅថា ការប្រេះឆានៃសង្ឃ តែមិនទាន់ហៅថា បែកធ្លាយនៃសង្ឃទេ ។ ម្នាលឧបាលិ តថាគតបានបញ្ញត្តអាវាសិកវត្តនេះដល់អាវាសិកភិក្ខុ ម្នាលឧបាលិ កាលបើសិក្ខាបទដែលតថាគតបានបញ្ញត្តដោយប្រពៃយ៉ាងនេះ ពួកអាវាសិកភិក្ខុមិនប្រព្រឹត្តក្នុងអាវាសិកវត្តទេ ម្នាលឧបាលិ យ៉ាងនេះហើយហៅថា ការប្រេះឆានៃសង្ឃ តែមិនទាន់ហៅថាបែកធ្លាយនៃសង្ឃ ។ ម្នាលឧបាលិ តថាគតបានបញ្ញត្តភត្តគ្គវត្តនេះក្នុងរោងភត្តដល់ពួកភិក្ខុ តាមលំដាប់ចាស់ខ្ចី តាមលំដាប់រាត្រី ឬលំដាប់នៃថេរៈ តាមកិច្ចដ៏សមគួរ តាមអាសនៈខ្ពស់ តាមទឹកថ្លោង តាមចង្ហាន់ថ្លោង ម្នាលឧបាលិ កាលបើសិក្ខា-បទដែលតថាគតបានបញ្ញត្តដោយប្រពៃយ៉ាងនេះហើយ ពួកភិក្ខុថ្មី ហាមឃាត់អាសនៈដល់ពួកភិក្ខុជាថេរៈក្នុងរោងភត្ត ម្នាលឧបាលិ យ៉ាងនេះហើយ

ខោ ឧបាលិ សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ ។ បញ្ញត្តំ ឧបាលិ មយា ភិក្ខូនំ សេនាសនេ សេនាសនវត្តំ យថាវុឌ្ឍំ យថារត្តំ យថាបដិរូបំ ឯវំ សុបញ្ញត្តេ ខោ ឧបាលិ មយា សិក្ខាបទេ ឯកោ ភិក្ខុ ថេកនំ ភិក្ខូនំ សេនាសនំ បដិពាហតិ ឯវម្បិ ខោ ឧបាលិ សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ ។ បញ្ញត្តំ ឧបាលិ មយា ភិក្ខូនំ អន្តោសីមាយ ឯកំ ឧបោសថ ឯកំ បវារណា ឯកំ សង្ឃកម្មំ ឯកំ កម្មាកម្មំ ឯវំ សុបញ្ញត្តេ ខោ ឧបាលិ មយា សិក្ខាបទេ តត្ថេវ អន្តោសីមាយ អាវេណិភាវំ ករិត្វា គណំ ពន្ធិត្វា អាវេណិ(១) ឧបោសថំ ករោន្តិ អាវេណិ(២) បវារណំ ករោន្តិ អាវេណិ(៣) សង្ឃកម្មំ ករោន្តិ អាវេណិ(៤) កម្មាកម្មានិ ករោន្តិ ឯវម្បិ ខោ ឧបាលិ សង្ឃរាជិ ចេវ ហោតិ សង្ឃភេទោ ចាតិ ។

អធិករណវូបសមវគ្គោ ទសមោ ។

១-២-៣-៤ ម. អាវេណី ។

ឈ្មោះថាការប្រេះឆានៃសង្ឃ តែមិនទាន់ហៅថា បែកធ្លាយនៃសង្ឃទេ ។ ម្នាលឧបាលិ តថាគតបានបញ្ញត្តសេនាសនវត្តនេះ គឺសេនាសនៈដល់ភិក្ខុតាមលំដាប់ចាស់ខ្ចី តាមលំដាប់រាត្រី តាមកិច្ចដ៏សមគួរ ម្នាលឧបាលិ កាលបើសិក្ខាបទដែលតថាគត បានបញ្ញត្តដោយប្រពៃ យ៉ាងនេះហើយ ហើយពួកភិក្ខុថ្មីក៏ហាមឃាត់សេនាសនៈដល់ពួកភិក្ខុជាថេរៈ ម្នាលឧបាលិ យ៉ាងនេះឈ្មោះថា ការប្រេះឆានៃសង្ឃ តែមិនទាន់ហៅថាបែកធ្លាយនៃសង្ឃទេ ។ ម្នាលឧបាលិ តថាគតបានបញ្ញត្តឧបោសថជាមួយគ្នា បវារណាជាមួយគ្នា សង្ឃកម្មជាមួយគ្នា កម្មតូចកម្មធំជាមួយគ្នានេះខាងក្នុងសីមាដល់ភិក្ខុទាំងឡាយហើយ ម្នាលឧបាលិ កាលបើសិក្ខាបទដែលតថាគតបានបញ្ញត្តដោយប្រពៃយ៉ាងនេះហើយ ភិក្ខុទាំងឡាយក៏ធ្វើសេចក្តីកំណត់ផ្សេងគ្នា ចងគ្នាជាពួក ធ្វើឧបោសថផ្សេងគ្នា ធ្វើបវារណាផ្សេងគ្នា ធ្វើសង្ឃកម្មផ្សេងគ្នា ធ្វើកម្មតូចកម្មធំផ្សេងគ្នា ខាងក្នុងសីមានោះ ម្នាលឧបាលិ យ៉ាងនេះហើយឈ្មោះថា ការប្រេះឆានៃសង្ឃផង ឈ្មោះថាការបែកធ្លាយនៃសង្ឃផង ។

ចប់ អធិករណវូបសមវគ្គ ជាគំរប់ ១០ ។

តស្សុទ្ទានំ

(២៩៧) អាបត្តិ អធិករណំ
ឆន្ទា អប្បស្សុតេន ច
វត្ថុញ្ច អកុសលោ ច
បុគ្គលោ អាមិសេន ច
ភិន្ទតិ សង្ឃរាជិ ច
សង្ឃភេទោ តថេវ ចាតិ ។

(២៩៨) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ វិនិធាយ ទិដ្ឋឹ កម្មេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ

ឧទ្ទានគឺបញ្ជីរឿងនៃអធិករណវូបសមវគ្គនោះដូច្នេះ

(៦៩៧) និយាយអំពីអាបត្តិ ១ អធិករណ៍ ១ ការលំអៀងដោយស្រឡាញ់ ១ ភិក្ខុបេះដឹងតិច ១ វគ្គ ១ ភិក្ខុមិនឈ្លាស ១ មានចិត្តជន់ក្នុងបុគ្គល ១ ជន់ក្នុងអាមិសៈ ១ សង្ឃបែកគ្នា ១ ការប្រេះឆានៃសង្ឃ ១ ការបែកធ្លាយនៃសង្ឃ ១ ។

(៦៩៨) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ អង្គ ៥ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះសំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ បិទបាំងទិដ្ឋិហើយធ្វើសង្ឃកម្មផ្សេងគ្នា ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង ឈ្មោះថាជាអ្នកបំបែកសង្ឃ តែង

អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ វិនិធាយ ទិដ្ឋឹ ឧទ្ទេសេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ វិនិធាយ ទិដ្ឋឹ វោហារេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ

ទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ អង្គ ៥ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ បិទបាំងទិដ្ឋិហើយសំដែងបាតិមោក្ខ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ អង្គ ៥ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនជាធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ បិទបាំងទិដ្ឋិហើយសំដែង (ភេទករវត្ថុ ១៨ យ៉ាង) ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង

អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហាការេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ វិនិធាយ ទិដ្ឋឹ អនុស្សាវនេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហាការេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហាការេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ វិនិធាយ ទិដ្ឋឹ សលាកគ្គាហេន ។

ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ អង្គ ៥ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ បិទបាំងទិដ្ឋិហើយសូត្របញ្ចាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ អង្គ ៥ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ បិទបាំងទិដ្ឋិប្រកាសស្លាក ១ ។

ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ វិនិធាយ ទិដ្ឋឹ កម្មេន ។ បេ ។ វិនិធាយ ទិដ្ឋឹ ឧទ្ទេសេន ។ វិនិធាយ ទិដ្ឋឹ វោហារេន ។ វិនិធាយ ទិដ្ឋឹ អនុស្សាវនេន ។ វិនិធាយ ទិដ្ឋឹ សលាកគ្គាហេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ

ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៩ នេះឯង ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៩ ដទៃទៀត ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ អង្គ ៩ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ បិទបាំងសេចក្តីពេញចិត្តហើយធ្វើសង្ឃកម្មផ្សេងគ្នា ១ ។ បេ ។ បិទបាំងសេចក្តីពេញចិត្តហើយសំដែងបាតិមោក្ខ ។ បិទបាំងសេចក្តីពេញចិត្តហើយ សំដែងភេទករវត្ថុ ១៨ យ៉ាង ។ បិទបាំងសេចក្តីពេញចិត្តហើយ សូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន ។ បិទបាំងសេចក្តីពេញចិត្តហើយប្រគល់ស្លាក ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៩ នេះឯង ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៩ ដទៃទៀត ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ អង្គ ៩ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ

អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ វិនិធាយ ទិដ្ឋឹ កម្មេន ៗ បេ ៗ វិនិធាយ ទិដ្ឋឹ ឧទ្ទេសេន ៗ វិនិធាយ ទិដ្ឋឹ វោហរន្តោ ៗ វិនិធាយ ទិដ្ឋឹ អនុស្សាវនេន ៗ វិនិធាយ ទិដ្ឋឹ សលាកគ្គាហេន ៗ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ៗ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ៗ កតមេហិ បញ្ចហិ ៗ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ វិនិធាយ សញ្ញំ កម្មេន ៗ បេ ៗ វិនិធាយ សញ្ញំ ឧទ្ទេសេន ៗ វិនិធាយ សញ្ញំ វោហរន្តោ ៗ វិនិធាយ សញ្ញំ អនុស្សាវនេន ៗ វិនិធាយ

ឧបាលិបញ្ចកៈ ភិក្ខុអ្នកបំបែកសង្ឃតែងទៅកើតក្នុងអបាយ ក្នុងនរក

សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ បិទបាំងសេចក្ដីគាប់ចិត្តហើយធ្វើសង្ឃកម្មផ្សេងគ្នា ១ ។ បេ ។ បិទបាំងសេចក្ដីគាប់ចិត្តហើយសំដែងបាតិមោក្ខ ។ បិទបាំងសេចក្ដីគាប់ចិត្តហើយសំដែងភេទករវត្ថុ ១៨ យ៉ាង ។ បិទបាំងសេចក្ដីគាប់ចិត្តហើយសូត្របញ្ចាក់អំពីសេចក្ដីស្មោះត្រង់របស់ខ្លួន ។ បិទបាំងសេចក្ដីគាប់ចិត្តហើយប្រគល់ស្លាក ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ ដទៃទៀត ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ អង្គ ៥ តើដូចម្ដេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនជាវិន័យ ១ បិទបាំងសញ្ញាហើយធ្វើសង្ឃកម្មផ្សេងគ្នា ១ ។ បេ ។ បិទបាំងសញ្ញាហើយសំដែងបាតិមោក្ខ ។ បិទបាំងសញ្ញាហើយសំដែងភេទករវត្ថុ ១៨ យ៉ាង ។ បិទបាំងសញ្ញាហើយសូត្របញ្ចាក់អំពីសេចក្ដីស្មោះត្រង់របស់ខ្លួន ។ បិទបាំងសញ្ញា

សញ្ញំ សលាកគ្គាហេន ។ នវហិ ខោ ឧបាលិ បញ្ច-ហង្គេហិ សមន្នាគតោ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។

សង្ឃភេទវគ្គោ(១) ឯកាទសមោ ។

តស្សុទ្ទានំ

(២៩៩) វិនិធាយ ទិដ្ឋី កម្មេន
ឧទ្ទេសេន វោហារេន ច
អនុស្សាវនេ សលាកេន
បញ្ចេតេ ទិដ្ឋិនិស្សិតា ។
ខន្តិ រុចិ ច សញ្ញា ច
តយោ តេ បញ្ចធា នយាតិ ។

(៣០០) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នា-គតោ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ សង្ឃភេទកោ ន អាបាយិកោ ន

១ ឱ. ម. សង្ឃភេទកវគ្គោ និដ្ឋិតោ ។

ហើយប្រគល់ស្លាក ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៤ នេះឯង ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។

ចប់ សង្ឃភេទវគ្គ ជាគំរប់១១ ។

ឧទ្ទាន គឺបញ្ជីរឿងនៃសង្ឃភេទវគ្គនោះ ដូច្នេះ

(២៩៩) និយាយអំពីបិទបាំងទិដ្ឋិហើយធ្វើសង្ឃកម្មផ្សេងគ្នា ១ សំដែងបាតិមោក្ខ ១ សំដែងភេទករវត្ថុ ១៨ យ៉ាង ១ សូត្របញ្ចាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន ១ ប្រគល់ស្លាក ១ អាការទាំង ៤ នេះអាស្រ័យនូវទិដ្ឋិ ។ សេចក្តីពេញចិត្ត ១ សេចក្តីគាប់ចិត្ត ១ សញ្ញា ១ ធម៌ទាំង ៣ យ៉ាងនោះមានន័យ ៤ប្រការដូចគ្នាដែរ ។

(៣០០) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គប៉ុន្មាន មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៤ មិន

នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អវិនិធាយ ទិដ្ឋឹ កម្មេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អវិនិធាយ ទិដ្ឋឹ ឧទ្ទេសេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេ-កិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នា-

កំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ។ អង្គ ៨ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ មិនបិទបាំងទិដ្ឋិហើយធ្វើសង្ឃកម្មផ្សេងគ្នា ១ ៗ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៨ នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៨ ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ។ អង្គ ៨ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនជាវិន័យ ១ មិនបិទបាំងទិដ្ឋិ ហើយសំដែងបាតិមោក្ខ ១ ៗ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃប្រកបដោយអង្គ ៨ នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៨ ដទៃទៀត

គតោ សង្ឃភេទកោ ច អាបាយិកោ ច នេរយិកោ ច កប្បដ្ឋោ ច អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អវិនិធាយ ទិដ្ឋឹ វោហារេន្តោ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ ច អាបាយិកោ ច នេរយិកោ ច កប្បដ្ឋោ ច អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ ច អាបាយិកោ ច នេរ-យិកោ ច កប្បដ្ឋោ ច អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អវិនិធាយ ទិដ្ឋឹ អនុស្សាវេតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ ច អាបាយិកោ ច នេរយិកោ

មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតទៅអស់មួយកប្ប ទៅកែខ្លួនបាន ។ អង្គ ៩ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនជាវិន័យ ១ មិនបិទបាំងទិដ្ឋិ ហើយសំដែងភេទករវត្ថុ ១៨ យ៉ាង ១ ។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៩ នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតទៅអស់មួយកប្ប ទៅកែខ្លួនបាន ។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៩ ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតទៅអស់មួយកប្ប ទៅកែខ្លួនបាន ។ អង្គ ៩ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនជាធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ មិនបិទបាំងទិដ្ឋិហើយសូត្របញ្ចាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន ១ ។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃប្រកបដោយអង្គ ៩ នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក

ច កប្បដ្ឋោ ច អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហាការេហិ សមន្នាគតោ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អវិនិធា [illegible] ទិដ្ឋឹ សលាកគ្គាហេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហាការេហិ សមន្នាគតោ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហាការេហិ សមន្នាគតោ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អវិនិធាយ ទិដ្ឋឹ កម្មេន ។ បេ ។ អវិនិធាយ ទិដ្ឋឹ ឧទ្ទេសេន ។ អវិនិធាយ ទិដ្ឋឹ វោហរន្តោ ។

មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ៗ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៥ ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ៗ អង្គ ៥ តើដូចម្តេច ៗ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ មិនបិទបាំងទិដ្ឋិហើយប្រគល់ស្លាក ១ ៗ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃប្រកបដោយអង្គ ៥ នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ៗ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៥ ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ៗ អង្គ ៥ តើដូចម្តេច ៗ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ មិនបិទបាំងសេចក្តីពេញចិត្តហើយធ្វើសង្ឃកម្មផ្សេងគ្នា ១ ។បេ។ មិនបិទបាំងសេចក្តីគាប់ចិត្តហើយសំដែងបាតិមោក្ខ ៗ មិនបិទបាំងសេចក្តីគាប់ចិត្តហើយសំដែងភេទករវត្ថុ ១៨ យ៉ាង

អវិនិធាយ ទិដ្ឋឹ អនុស្សាវនេន ។ អវិនិធាយ ទិដ្ឋឹ សលាកគ្គាហេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។ អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អវិនិធាយ រុចឹ កម្មេន ។ បេ ។ អវិនិធាយ រុចឹ ឧទ្ទេសេន ។ អវិនិធាយ រុចឹ វោហរន្តោ ។ អវិនិធាយ រុចឹ អនុស្សាវនេន ។ អវិនិធាយ រុចឹ សលាកគ្គាហេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។

មិនបិទបាំងសេចក្តីគាប់ចិត្តហើយសូត្របញ្ញាត់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន ។ មិនបិទបាំងសេចក្តីពេញចិត្តហើយប្រគល់ស្លាក ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៨ នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃប្រកបដោយអង្គ ៨ ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ។ អង្គ ៨ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈ មិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យថាមិនមែនវិន័យ ១ មិនបិទបាំងសេចក្តីគាប់ចិត្តហើយធ្វើសង្ឃកម្មផ្សេងគ្នា ១ ។ បេ ។ មិនបិទបាំងសេចក្តីគាប់ចិត្តហើយសំដែងបាតិមោក្ខ ។ មិនបិទបាំងសេចក្តីគាប់ចិត្តហើយសំដែងភេទករវត្ថុ ១៨ យ៉ាង ។ មិនបិទបាំងសេចក្តីគាប់ចិត្តហើយសូត្របញ្ញាត់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន ។ មិនបិទបាំងសេចក្តីគាប់ចិត្តហើយប្រគល់ស្លាក ។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៨ នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន

អបរេហិបិ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃ-ភេទកោ ច អាបាយិកោ ច នេរយិកោ ច កប្បដ្ឋោ ច អតេកិច្ឆោ ។ កតមេហិ បញ្ចហិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អវិនិធាយ សញ្ញំ កម្មេន ។ បេ ។ អវិនិធាយ សញ្ញំ ឧទ្ទេសេន ។ អវិនិធាយ សញ្ញំ វោហារេន ។ អវិនិធាយ សញ្ញំ អនុស្សាវនេន ។ អវិនិធាយ សញ្ញំ សលាកគ្គាហេន ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សង្ឃ-ភេទកោ ច អាបាយិកោ ច នេរយិកោ ច កប្បដ្ឋោ ច អតេកិច្ឆោតិ ។

ទុតិយសង្ឃភេទវគ្គោ(១) ទ្វាទសមោ ។

តស្សុទ្ទានំ

[៣០១] អវិនិធាយ ទិដ្ឋិ កម្មេន
ឧទ្ទេសេន វោហារេន ច

---

១ ឱ. ម. ទុតិយសង្ឃភេទកវគ្គោ និដ្ឋិតោ ។

ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៥ ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ។ អង្គ ៥ តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ ១ សំដែងនូវធម៌ថាមិនមែនធម៌ ១ សំដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ ១ មិនបិទបាំងសញ្ញាហើយ ធ្វើសង្ឃកម្មផ្សេងគ្នា ១ ។ បេ ។ មិនបិទបាំងសញ្ញាហើយសំដែងបាតិមោក្ខ ។ មិនបិទបាំងសញ្ញាហើយសំដែងភេទករវត្ថុ ១៨ យ៉ាង ។ មិនបិទបាំងសញ្ញាហើយសូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន ។ មិនបិទបាំងសញ្ញាហើយប្រគល់ស្លាក ។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ ៥ នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន ។

ចប់ ទុតិយសង្ឃភេទវគ្គ ជាគំរប់ ១២ ។

ឧទ្ទាន គឺបញ្ជីរឿងនៃសង្ឃភេទវគ្គនោះដូច្នេះ

[៣០១] និយាយអំពីមិនបិទបាំងទិដ្ឋិហើយធ្វើសង្ឃកម្មផ្សេងគ្នា ១ សំដែងបាតិមោក្ខ ១ សំដែងភេទករវត្ថុ ១៨ យ៉ាង ១

អនុស្សាវនេ សលាកេន
បញ្ចេតេ ទិដ្ឋិនិស្សិតា ។
ខន្តិ រុចិ ច សញ្ញា ច[1]
តយោ តេ បញ្ចធា នយាតិ ។
ហេដ្ឋិមេ កណ្ហបក្ខម្ហិ
សមវីសតិ វិធី យថា
តថេវ សុក្កបក្ខម្ហិ
សមវីសតិ ឋានថាតិ ។

(៣០២) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ សង្ឃិកំ បុគ្គលិកាបរិភោគេន បរិភុញ្ជតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ

---

១ ម. ខន្តី រុចី ច សញ្ញញ្ច ។

សូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន ១ ប្រគល់ស្លាក ១ អាការទាំង ៥ នេះអាស្រ័យនូវទិដ្ឋិ ៗ សេចក្តីពេញចិត្ត ១ សេចក្តីគាប់ចិត្ត ១ សញ្ញា ១ ធម៌ទាំង ៣ យ៉ាងនោះមានន័យ ៥ ប្រការដូចគ្នាដែរ ៗ វិធី ២០ គត់ ក្នុងចំណែកខាងអាក្រក់ មានក្នុងខាងក្រោម (ខាងដើម) យ៉ាងណា អ្នកទាំងឡាយ ចូរដឹងនូវវិធី ២០ គត់ ក្នុងចំណែកខាងល្អ ក៏យ៉ាងនោះដែរ ៗ

(៣០២) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន អាវាសិកភិក្ខុ គឺភិក្ខុដែលនៅក្នុងអាវាសប្រកបដោយអង្គប៉ុន្មាន រមែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ អាវាសិកភិក្ខុដែលប្រកបដោយអង្គ ៥ រមែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ៗ អង្គ ៥ តើដូចម្តេច ៗ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់ ១ លំអៀងព្រោះសេចក្តីស្អប់ ១ លំអៀងព្រោះសេចក្តីលង់ ១ លំអៀងព្រោះសេចក្តីខ្លាច ១ ប្រើប្រាស់នូវវត្ថុជារបស់សង្ឃដោយការប្រើប្រាស់ដូចជារបស់បុគ្គល ១ ៗ ម្នាលឧបាលិ អាវាសិកភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង រមែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅ

និក្ខិត្តោ ឯវំ និរយេ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ សង្ឃិកំ ន បុគ្គលិកបរិភោគេន បរិភុញ្ជតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។

(៣០៣) កតិ នុ ខោ ភន្តេ អធម្មិកា វិនយព្យាករណាតិ ។ បញ្ចិមេ ឧបាលិ អធម្មិកា វិនយព្យាករណា ។ កតមេ បញ្ច ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ បរិណាមេតិ ធម្មំ អធម្មោតិ បរិណាមេតិ អវិនយំ វិនយោតិ បរិណាមេតិ វិនយំ អវិនយោតិ បរិណាមេតិ អប្បញ្ញត្តំ បញ្ញាបេតិ បញ្ញត្តំ សមុច្ឆិន្ទតិ ។ ឥមេ ខោ ឧបាលិ បញ្ច អធម្មិកា វិនយព្យាករណា ។ បញ្ចិមេ ឧបាលិ ធម្មិកា វិនយព្យាករណា ។

ទំលាក់ ។ ម្នាលឧបាលិ អាវាសិកភិក្ខុដែលប្រកបដោយអង្គ ៥ រមែងទៅកើតក្នុងនរក ហាក់ដូចជា គេនាំយកទៅដាក់ទុក ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនពិចារណាហើយ មិនពិសោធហើយ ... មិនលំអៀងព្រោះសេចក្តីស្រឡាញ់ ១ មិនលំអៀងព្រោះសេចក្តីស្អប់ ១ មិនលំអៀងព្រោះសេចក្តីវង្វេង ១ មិនលំអៀងព្រោះសេចក្តីខ្លាច ១ មិនប្រើប្រាស់វត្ថុជារបស់សង្ឃ ដោយការប្រើប្រាស់ដូចជារបស់បុគ្គល ១ ។ ម្នាលឧបាលិ អាវាសិកភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដាក់ទុក ។

(៣០៣) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការដោះស្រាយវិន័យមិនប្រកបដោយធម៌មានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ការដោះស្រាយវិន័យមិនប្រកបដោយធម៌មាន ៥ យ៉ាងនេះ ។ ៥ យ៉ាង តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ បង្អាន[1] នូវសភាវៈមិនមែនធម៌ថាជាធម៌ ១ បង្អាននូវធម៌ថាមិនមែនជាធម៌ ១ បង្អាននូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ បង្អាននូវវិន័យថាមិនមែនជាវិន័យ ១ បញ្ញត្តនូវសិក្ខាបទដែលតថាគតមិនបានបញ្ញត្ត ចាំងដកសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ១ ។ ម្នាលឧបាលិ ការដោះស្រាយវិន័យមិនប្រកបដោយធម៌មាន ៥ យ៉ាងនេះឯង ។ ម្នាលឧបាលិ ការដោះស្រាយវិន័យដែលប្រកបដោយធម៌មាន ៥ យ៉ាងនេះ ។

---

១ អដ្ឋកថាថា កំពត់ សំដែង និយាយ ។

កតមេ បញ្ច ។ ឥធុបាលិ ភិក្ខុ អធម្មំ អធម្មោតិ បរិណាមេតិ ធម្មំ ធម្មោតិ បរិណាមេតិ អវិនយំ អវិនយោតិ បរិណាមេតិ វិនយំ វិនយោតិ បរិណាមេតិ អប្បញ្ញត្តំ ន បញ្ញាបេតិ បញ្ញត្តំ ន សមុច្ឆិន្ទតិ ។ ឥមេ ខោ ឧបាលិ បញ្ច ធម្មិកា វិនយព្យាករណាតិ ។

(៣០៤) កតីហិ នុ ខោ ភន្តេ អង្គេហិ សមន្នាគតោ ភត្តុទ្ទេសកោ យថាភតំ និក្ខិត្តោ ឯវំ និរយេតិ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ ភត្តុទ្ទេសកោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ឧទ្ទិដ្ឋានុទ្ទិដ្ឋំ ន ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភត្តុទ្ទេសកោ

៤ យ៉ាង តើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ បង្អោននូវសភាវៈមិនមែនធម៌ថាមិនមែនធម៌១ បង្អោននូវធម៌ថាជាធម៌ ១ បង្អោននូវសភាវៈមិនមែនវិន័យថាមិនមែនវិន័យ ១ បង្អោននូវវិន័យថាជាវិន័យ ១ មិនបញ្ញត្តនូវសិក្ខាបទដែលតថាគតមិនបានបញ្ញត្ត ទាំងមិនដកសិក្ខាបទដែលតថាគតបានបញ្ញត្តហើយ ១ ។ ម្នាលឧបាលិ ការដោះស្រាយវិន័យដែលប្រកបដោយធម៌មាន៤ យ៉ាងនេះឯង ។

[៣០៤] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលជាភត្តុទ្ទេសក៍[១] (អ្នកសំដែងភត្ត) ប្រកបដោយអង្គប៉ុន្មាន រមែងធ្លាក់ទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលជាភត្តុទ្ទេសក៍ប្រកបដោយអង្គ ៤ រមែងធ្លាក់ទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់ ។ អង្គ ៤ តើដូចម្តេច ។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់ ១ លំអៀងព្រោះសេចក្តីស្អប់ ១ លំអៀងព្រោះសេចក្តីវង្វេង ១ លំអៀងព្រោះសេចក្តីខ្លាច ១ មិនដឹងនូវភត្តដែលខ្លួនបានសំដែងហើយ ទាំងមិនទាន់បានសំដែង[២] ១ ។ ម្នាលឧបាលិ ភិក្ខុដែលជាភត្តុទ្ទេសក៍ប្រកបដោយអង្គ៤នេះឯង រមែងធ្លាក់ចុះទៅក្នុងនរក ហាក់ដូច

---

១ ភិក្ខុអ្នកចាត់ភិក្ខុសង្ឃក្នុងការទទួលភត្ត (មេបញ្ជី) ។ ២ មិនដឹងនូវភត្តដែលខ្លួនគួរសំដែងនឹងមិនគួរសំដែង ។

យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ បញ្ចហុបាលិ អង្គេហិ
សមន្នាគតោ ភត្តុទ្ទេសកោ យថាភតំ និក្ខិត្តោ ឯវំ
សគ្គេ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ
ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយា-
គតឹ គច្ឆតិ ឧទ្ទិដ្ឋានុទ្ទិដ្ឋំ ជានាតិ ។ ឥមេហិ ខោ
ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ ភត្តុទ្ទេសកោ យ-
ថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។ កតីហិ នុ ខោ
ភន្តេ អង្គេហិ សមន្នាគតោ សេនាសនបញ្ញាបកោ
។បេ។ ភណ្ឌាគារិកោ ចីវរប្បដិគ្គាហកោ ចីវរភាជកោ
យាគុភាជកោ ផលភាជកោ ខជ្ជភាជកោ អប្បមត្ត-
កវិស្សជ្ជកោ សាដិយគ្គាហាបកោ បត្តគ្គាហាបកោ
អារាមិកបេសកោ សាមណេរបេសកោ យថាភតំ
និក្ខិត្តោ ឯវំ និរយេតិ ។ បញ្ចហុបាលិ អង្គេហិ ស-
មន្នាគតោ សាមណេរបេសកោ យថាភតំ និក្ខិត្តោ ឯវំ
និរយេ ។ កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ
ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ

ជាគេនាំយកទៅទំលាក់ ។ ម្នាលឧបាលិ ភិក្ខុដែលជាភត្តុទ្ទេសក៍ប្រកបដោយអង្គ ៥ រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដំកល់ទុក ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់ ១ មិនលំអៀងព្រោះសេចក្តីស្អប់ ១ មិនលំអៀងព្រោះសេចក្តីល្ងង់ ១ មិនលំអៀងព្រោះសេចក្តីខ្លាច ១ ដឹងនូវភត្តដែលខ្លួនបានសំដែងហើយ ទាំងមិនទាន់បានសំដែង ១ ។ ម្នាលឧបាលិ ភិក្ខុដែលជាភត្តុទ្ទេសក៍ប្រកបដោយអង្គ ៥ នេះឯង រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដំកល់ទុក ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុអ្នកក្រាលសេនាសនៈ ។ បេ ។ ភិក្ខុអ្នករក្សាឃ្លាំង ភិក្ខុអ្នកទទួលចីវរ ភិក្ខុអ្នកចែកចីវរ ភិក្ខុអ្នកចែកបបរ ភិក្ខុអ្នកចែកផ្លែឈើ ភិក្ខុអ្នកចែកបង្អែម ភិក្ខុអ្នកលះបង់នូវរបស់បន្តិចបន្តួច ភិក្ខុអ្នកប្រគល់សាដក ភិក្ខុអ្នកប្រគល់បាត្រ ភិក្ខុអ្នកប្រើនូវអារាមិកជនគឺញោមវត្ត ភិក្ខុអ្នកប្រើសាមណេរ ប្រកបដោយអង្គប៉ុន្មាន រមែងធ្លាក់ទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកប្រើសាមណេរប្រកបដោយអង្គ ៥ រមែងធ្លាក់ទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់ ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់ ១ លំអៀងព្រោះសេចក្តីស្អប់ ១ លំអៀងព្រោះសេចក្តីល្ងង់ ១ លំអៀងព្រោះសេចក្តីខ្លាច ១ មិនដឹង

បេសិតាបេសិតំ ន ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សាមណេរបេសកោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ បញ្ចហុបាលិ អង្គេហិ សមន្នាគតោ សាមណេរបេសកោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ បេសិតាបេសិតំ ជានាតិ ។ ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ សមន្នាគតោ សាមណេរបេសកោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

អាវាសិកវគ្គោ តេរសមោ ។

តស្សុទ្ទានំ

[៣០៥] អាវាសិកព្យាករណា

ភត្តសេនាសនានិ ច

ភណ្ឌាចីវរគ្គាហោ ច

ចីវរស្ស ច ភាជកោ

នូវសាមណេរដែលខ្លួនបានប្រើ តាំងមិនទាន់បានប្រើ[1] ១ ។ ម្នាលឧបាលិ ភិក្ខុអ្នកប្រើសាមណេរប្រកបដោយអង្គ ៥ នេះឯង រមែងធ្លាក់ទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់ ។ ម្នាលឧបាលិ ភិក្ខុអ្នកប្រើសាមណេរ ប្រកបដោយអង្គ ៥ រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដំកល់ទុក ។ អង្គ ៥ តើដូចម្តេច ។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់ ១ មិនលំអៀងព្រោះសេចក្តីស្អប់ ១ មិនលំអៀងព្រោះសេចក្តីវង្វេង ១ មិនលំអៀងព្រោះសេចក្តីខ្លាច ១ ដឹងនូវសាមណេរដែលខ្លួនបានប្រើ តាំងមិនទាន់បានប្រើ ១ ។ ម្នាលឧបាលិ ភិក្ខុអ្នកប្រើសាមណេរប្រកបដោយអង្គ ៥ នេះឯង រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដំកល់ទុក ។

ចប់ អាពាសិកវគ្គ ជាគំរប់ ១៣ ។

ឧទ្ទានគឺបញ្ជីរឿងនៃអាវាសិកវគ្គនោះដូច្នេះ

(៣០៥) និយាយអំពីអាវាសិកភិក្ខុ ១ ការដោះស្រាយវិន័យ ១ ភិក្ខុជាភត្តុទ្ទេសក៍ ១ ភិក្ខុអ្នកក្រាលសេនាសនៈ ១ ភិក្ខុអ្នករក្សាឃ្លាំង ១ ភិក្ខុអ្នកទទួលចីវរ ១ ភិក្ខុអ្នកចែកចីវរ ១ ចែក

---

[1] មិនដឹងនូវសាមណេរដែលគួរប្រើនឹងមិនគួរប្រើ ។

យាគុ ផលំ ១ដ្ឋកញ្ចុ

អប្បសាទិយត្តាហាកោ

បត្តអាភមិតា ចេវ(១)

សាមណោរេន បេសកោតិ

(៣០៦) កតិ នុ ខោ ភន្តេ អានិសំសា កឋិនត្ថារេតិ ។ បញ្ចិមេ ឧបាលិ អានិសំសា កឋិនត្ថារេ ។ កតមេ បញ្ច ។ អនាមន្តចារោ អសមាទានចារោ គណភោជនំ យាវទត្ថចីវរំ យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ ។ ឥមេ ខោ ឧបាលិ បញ្ច អានិសំសា កឋិនត្ថារេតិ ។

(៣០៧) កតិ នុ ខោ ភន្តេ អាទីនវា មុដ្ឋស្សតិស្ស អសម្បជានស្ស និទ្ទំ ឱក្កមតោតិ(២) ។ បញ្ចិមេ ឧបាលិ អាទីនវា មុដ្ឋស្សតិស្ស អសម្បជានស្ស និទ្ទំ ឱក្កមតោ ។ កតមេ បញ្ច ។ ទុក្ខំ សុបតិ ទុក្ខំ បដិពុជ្ឈតិ បាបកំ សុបិនំ បស្សតិ ទេវតា ន រក្ខន្តិ អសុចិ មុច្ចតិ ។ ឥមេ ខោ ឧបាលិ បញ្ច អាទីនវា

១ ម. បត្តោ អាភមិកោ ចេវ ។ ២ ឧ. ម. ឧក្កមយតោតិ ។

បបរ ១ បែកផ្លែឈើ ១ បែកបង្អែម ១ ភិក្ខុអ្នកលះបង់នូវវត្តបដិបទ្ធប ១ ភិក្ខុអ្នកប្រគល់សាដក ១ ភិក្ខុអ្នកប្រគល់បាត្រ ១ ភិក្ខុអ្នកប្រើអារាមិកជន ១ ភិក្ខុអ្នកប្រើសាមណេរ ១ ។

(៣០៦) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន អានិសង្សក្នុងការក្រាលកឋិនមានប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ អានិសង្សក្នុងការក្រាលកឋិនមាន ៥ ។ អានិសង្ស ៥ យ៉ាង តើដូចម្តេច ។ គឺការត្រាច់ទៅដោយមិនបាច់លាភិក្ខុផងគ្នា[១] ១ ការត្រាច់ទៅដោយមិនបាច់យកត្រៃចីវរឲ្យគ្រប់ទាំង ៣ ទៅក៏បាន ១ ឆាន់គណភោជនបាន ១ ប្រើប្រាស់អតិរេកចីវរបាន តាមសេចក្តីត្រូវការ ១ ចីវរលាភ ដែលកើតឡើងក្នុងទីអាវាសនោះនឹងបានដល់ភិក្ខុទាំងនោះ ១ ។ ម្នាលឧបាលិ អានិសង្សក្នុងការក្រាលកឋិនមាន ៥ យ៉ាងនេះឯង ។

(៣០៧) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ទោសរបស់ភិក្ខុអ្នកភ្លេចស្មារតី មិនដឹងខ្លួន ដេកលក់ មានប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ទោសរបស់ភិក្ខុអ្នកភ្លេចស្មារតី មិនដឹងខ្លួន ដេកលក់នេះ មាន ៥ ។ ទោស ៥ យ៉ាង ដូចម្តេច ។ គឺដេកលក់ជាទុក្ខ ១ ភ្ញាក់ឡើងក៏ជាទុក្ខ ១ យល់សប្តិឃើញមិនល្អ ១ ទេវតាមិនរក្សា ១ អសុចិឃ្លាតចេញ ១ ។ ម្នាលឧបាលិ ទោសរបស់ភិក្ខុ

---

១ ចំពោះតែចារិត្តសិក្ខាបទប៉ុណ្ណោះ ។

មុដ្ឋស្សតិស្ស អសម្បជានស្ស និទ្ទំ ឱក្កមតោ(១) ។ បញ្ចិមេ ឧបាលិ អានិសំសា ឧបដ្ឋិតស្សតិស្ស សម្បជានស្ស និទ្ទំ ឱក្កមតោ(២) ។ កតមេ បញ្ច ។ សុខំ សុបតិ សុខំ បដិពុជ្ឈតិ ន បាបកំ សុបិនំ បស្សតិ ទេវតា រក្ខន្តិ អសុចិ ន មុច្ចតិ ។ ឥមេ ខោ ឧបាលិ បញ្ច អានិសំសា ឧបដ្ឋិតស្សតិស្ស សម្បជានស្ស និទ្ទំ ឱក្កមតោតិ(៣) ។

(៣០៨) កតិ នុ ខោ ភន្តេ អវន្ទិយាតិ(៤) ។ បញ្ចិមេ ឧបាលិ អវន្ទិយា ។ កតមេ បញ្ច ។ អន្តរឃរំ បវិដ្ឋោ អវន្ទិយោ រច្ឆគតោ អវន្ទិយោ ឱតមសិកោ អវន្ទិយោ អសមន្នាហរន្តោ អវន្ទិយោ សុត្តោ អវន្ទិយោ ។ ឥមេ ខោ ឧបាលិ បញ្ច អវន្ទិយា ។ អបរេបិ ឧបាលិ បញ្ច អវន្ទិយា ។ កតមេ បញ្ច ។ យាគុបានេ អវន្ទិយោ

១-២-៣ ឱ. ម. ឧក្កមយតោ ។ ៤ អវន្ទិយាតិបិ បាឋោ ។ ឯវំ សព្វត្ថ ។

អ្នកភ្លេចស្មារតី មិនដឹងខ្លួន ដេកលក់ មាន ៥ យ៉ាងនេះឯង ។ ម្នាលឧបាលិ អានិសង្សរបស់ភិក្ខុអ្នកមានសតិតាំងខ្ជាប់ ដឹងខ្លួន ដេកលក មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង តើដូចម្ដេច ។ គឺដេកលក់ជាសុខ ១ ភ្ញាក់ឡើងក៏ជាសុខ ១ មិនយល់សប្តិឃើញអាក្រក់ ១ ទេវតារក្សា ១ អសុចិមិនឃ្លាតចេញ ១ ។ ម្នាលឧបាលិ អានិសង្សរបស់ភិក្ខុអ្នកមានសតិតាំងខ្ជាប់ ដឹងខ្លួន ដេកលក់ មាន ៥ យ៉ាងនេះឯង ។

(៣០៨) ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គលដែលភិក្ខុមិនគួរសំពះមានប៉ុន្មានពួក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ បុគ្គលដែលភិក្ខុមិនគួរសំពះមាន ៥ ពួក ។ បុគ្គល ៥ ពួក តើដូចម្ដេច ។ គឺភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះមិនគួរភិក្ខុសំពះ ១ កំពុងដើរតាមច្រកផ្លូវមិនគួរសំពះ ១ នៅក្នុងទីងងឹតមិនគួរសំពះ ១ ភិក្ខុដែលកំពុងខ្វល់ខ្វាយដោយការងារមិនបានអើពើនឹងការសំពះមិនគួរសំពះ ១ កំពុងដេកលក់មិនគួរសំពះ ១ ។ ម្នាលឧបាលិ បុគ្គល ៥ ពួកនេះឯង ភិក្ខុមិនគួរសំពះទេ ។ ម្នាលឧបាលិ បុគ្គល ៥ ពួកដទៃទៀត ភិក្ខុមិនគួរសំពះ ។ បុគ្គល ៥ ពួក តើដូចម្ដេច ។ គឺភិក្ខុកំពុងឆាន់បបរមិនគួរសំពះ ១

ឧបាលិបញ្ចកំ អបរេ បញ្ច អវន្ទិយា

ភត្តគ្គេ អវន្ទិយោ ឯកាវត្តោ អវន្ទិយោ អញ្ញាវិហិតោ អវន្ទិយោ និបន្នោ អវន្ទិយោ ។ ឥមេ ខោ ឧបាលិ បញ្ច អវន្ទិយា ។ អបរេបិ ឧបាលិ បញ្ច អវន្ទិយា ។ កតមេ បញ្ច ។ ខាទន្តោ អវន្ទិយោ ភុញ្ជន្តោ អវន្ទិយោ ឧច្ចារំ ករោន្តោ អវន្ទិយោ បស្សាវំ ករោន្តោ អវន្ទិយោ ឧក្ខិត្តកោ អវន្ទិយោ ។ ឥមេ ខោ ឧបាលិ បញ្ច អវន្ទិយា ។ អបរេបិ ឧបាលិ បញ្ច អវន្ទិយា ។ កតមេ បញ្ច ។ បុរេ ឧបសម្បន្នេន បច្ឆា ឧបសម្បន្នោ អវន្ទិយោ អនុបសម្បន្នោ អវន្ទិយោ នានាសំវាសកោ វុឌ្ឍតរោ អធម្មវាទី អវន្ទិយោ មាតុគាមោ អវន្ទិយោ បណ្ឌកោ អវន្ទិយោ ។ ឥមេ ខោ ឧបាលិ បញ្ច អវន្ទិយា ។ អបរេបិ ឧបាលិ បញ្ច អវន្ទិយា ។ កតមេ បញ្ច ។ បារិវាសិកោ អវន្ទិយោ មូលាយ បដិកស្សនារហោ អវន្ទិយោ មានត្តារហោ អវន្ទិយោ

ឧបាលិបញ្ចកៈ បុគ្គល៥ពួកដទៃទៀតដែលមិនគួរសំពះ

នៅក្នុងរោងភត្តមិនគួរសំពះ ១ ភិក្ខុងាកទៅក្នុងទីម្ខាង គឺបុគ្គលមានពៀរនឹងគ្នាជាវិសភាគបុគ្គលមិនគួរសំពះ ១ ភិក្ខុបញ្ជូនចិត្តទៅកាន់អារម្មណ៍ដទៃ គឺកំពុងគិតហេតុដទៃមិនគួរសំពះ ១ ភិក្ខុអាក្រាតមិនគួរសំពះ ១ ។ ម្នាលឧបាលិ បុគ្គល ៥ ពួកនេះឯង មិនគួរសំពះឡើយ ។ ម្នាលឧបាលិ បុគ្គល ៥ ពួកដទៃទៀត មិនគួរសំពះ ។ បុគ្គល ៥ ពួកតើដូចម្តេច ។ គឺភិក្ខុកំពុងឆាន់បង្អែមមិនគួរសំពះ ១ កំពុងឆាន់បំអាបមិនគួរសំពះ ១ កំពុងបន្ទោបង់ឧច្ចារៈមិនគួរសំពះ ១ កំពុងបន្ទោបង់បស្សាវៈមិនគួរសំពះ ១ ភិក្ខុដែលសង្ឃលើកវត្តមិនគួរសំពះ ១ ។ ម្នាលឧបាលិ បុគ្គល ៥ ពួកនេះឯង មិនគួរសំពះឡើយ ។ ម្នាលឧបាលិ បុគ្គល ៥ ពួកដទៃទៀត មិនគួរសំពះ ។ បុគ្គល ៥ ពួកតើដូចម្តេច ។ គឺភិក្ខុដែលបានឧបសម្បទាក្រោយ ភិក្ខុដែលបានឧបសម្បទាមុនមិនគួរសំពះ ១ អនុបសម្បន្ន ភិក្ខុមិនគួរសំពះ ១ ភិក្ខុមានសំវាសផ្សេងគ្នា ទោះបីចាស់ជាងតែជាអធម្មវាទី ភិក្ខុមិនគួរសំពះ ១ មាតុគ្រាមភិក្ខុមិនគួរសំពះ ១ បណ្ឌកៈ ភិក្ខុមិនគួរសំពះ ១ ។ ម្នាលឧបាលិ បុគ្គល ៥ ពួកនេះឯង មិនគួរសំពះឡើយ ។ ម្នាលឧបាលិ បុគ្គល ៥ ពួកដទៃទៀត ក៏មិនគួរសំពះ ។ បុគ្គល ៥ ពួកតើដូចម្តេច ។ គឺភិក្ខុដែលកំពុងនៅបរិវាសមិនគួរសំពះ ១ ភិក្ខុដែលគួរនឹងទាញមកដាក់ក្នុងមូលាបត្តិមិនគួរសំពះ ១ ភិក្ខុគួរដល់មានត្តមិនគួរសំពះ ១

មានត្តចារិកោ អវន្ទិយោ អព្ភានារហោ អវន្ទិយោ ។ ឥមេ ខោ ឧបាលិ បញ្ច អវន្ទិយាតិ ។

(១០៩) កតិ នុ ខោ ភន្តេ វន្ទិយាតិ ។ បញ្ចិមេ ឧបាលិ វន្ទិយា ។ កតមេ បញ្ច ។ បច្ឆា ឧបសម្បន្នេន បុរេ ឧបសម្បន្នោ វន្ទិយោ នានាសំវាសកោ វុឌ្ឍតរោ ធម្មវាទី វន្ទិយោ អាចរិយោ វន្ទិយោ ឧបជ្ឈាយោ វន្ទិយោ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ តថាគតោ អរហំ សម្មាសម្ពុទ្ធោ វន្ទិយោ ។ ឥមេ ខោ ឧបាលិ បញ្ច វន្ទិយាតិ ។

(១១០) នវកតរេន ភន្តេ ភិក្ខុនា វុឌ្ឍតរស្ស ភិក្ខុនោ បាទេ វន្ទន្តេន កតិ ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បាទា វន្ទិតព្វាតិ ។ នវកតរេនុបាលិ ភិក្ខុនា វុឌ្ឍតរស្ស ភិក្ខុនោ បាទេ វន្ទន្តេន បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា

ភិក្ខុកំពុងប្រព្រឹត្តមានត្តមិនគួរសំពះ ១ ភិក្ខុគួរដល់អព្ភានកម្ម មិនគួរសំពះ ១ ។ ម្នាលឧបាលិ បុគ្គល ៥ ពួកនេះឯង មិនគួរសំពះឡើយ ។

[៣០៩] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គលដែលគួរសំពះ មានប៉ុន្មានពួក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ បុគ្គលដែលគួរសំពះមាន ៥ ពួក ។ បុគ្គល ៥ ពួកតើដូចម្តេច ។ គឺភិក្ខុដែលបានឧបសម្បទាមុន ភិក្ខុដែលបានឧបសម្បទាក្រោយគួរសំពះ ១ ភិក្ខុដែលមានសំវាសផ្សេងគ្នា ដែលចាស់ជាង ហើយជាធម្មវាទីគួរសំពះ ១ ភិក្ខុជាអាចារ្យ គួរសំពះ ១ ភិក្ខុជាឧបជ្ឈាយ៍ គួរសំពះ ១ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ភិក្ខុគួរថ្វាយបង្គំ ១ ។ ម្នាលឧបាលិ បុគ្គល ៥ ពួកនេះឯង ភិក្ខុគួរសំពះ ។

[៣១០] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុខ្ចីជាង កាលនឹងថ្វាយបង្គំបាទាភិក្ខុចាស់ជាង ត្រូវដំកល់ធម៌ប៉ុន្មានយ៉ាងទុកខាងក្នុង ទើបថ្វាយបង្គំចំពោះបាទា ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុខ្ចីជាង កាលនឹងថ្វាយបង្គំបាទាភិក្ខុចាស់ជាង ត្រូវដំកល់ធម៌ ៥

ឧបាលិបញ្ចកំ ឧទ្ទានគាថា

បាទា វន្ទិតព្វា ។ កតមេ បញ្ច ។ នវកតរេនុបាលិ ភិក្ខុនា វុឌ្ឍតរស្ស ភិក្ខុនោ បាទេ វន្ទន្តេន ឯកំសំ ឧត្តរាសង្គំ ករិត្វា អញ្ជលឹ បគ្គហេត្វា ឧភោហិ បាណិតលេហិ បាទានិ បរិសម្ពាហន្តេន បេមញ្ច គារវញ្ច ឧបដ្ឋាបេត្វា បាទា វន្ទិតព្វា ។ នវកតរេនុបាលិ ភិក្ខុនា វុឌ្ឍតរស្ស ភិក្ខុនោ បាទេ វន្ទន្តេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បាទា វន្ទិតព្វាតិ ។

កឋិនត្ថារវគ្គោ ចុទ្ទសមោ ។

តស្សុទ្ទានំ

[១១] កឋិនត្ថារារហា ច
អន្តរាយោ ឧបាហនេ
បុរេ ច បារិវាសិ ច
វន្ទេយ្យា វន្ទិតព្វកន្តិ ។

ឧបាលិបញ្ចកំ និដ្ឋិតំ ។

យ៉ាងទុកខាងក្នុង ទើបថ្វាយបង្គំចំពោះបាទា ។ ធម៌ ៥ យ៉ាងតើដូចម្តេច ។ ម្នាលឧបាលិ ភិក្ខុខ្ចីជាង កាលនឹងថ្វាយបង្គំបាទាភិក្ខុចាស់ជាង ត្រូវធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ១ ផ្គងអញ្ជលី ១ ប្របាច់បាទាដោយបាតដៃទាំងគូ ១ ដំកល់សេចក្តីស្រឡាញ់ទុក ១ សេចក្តីគោរព ១ ទើបថ្វាយបង្គំចំពោះបាទាបាន ។ ម្នាលឧបាលិ ភិក្ខុខ្ចីជាង កាលនឹងថ្វាយបង្គំបាទាភិក្ខុចាស់ជាង ត្រូវដំកល់ធម៌ ៥ យ៉ាងនេះឯងទុកខាងក្នុង ទើបថ្វាយបង្គំចំពោះបាទា ។

ចប់ កឋិនត្ថារវគ្គ ជាគំរប់ ១៤ ។

ឧទ្ទាន គឺបញ្ជីរឿងនៃកឋិនត្ថារវគ្គនោះដូច្នេះ

(៣១១) និយាយអំពីអានិសង្សក្រាលកឋិន ១ ទោសរបស់ភិក្ខុភ្លេចស្មារតីដេកលក់ ១ ភិក្ខុកំពុងចូលទៅក្នុងចន្លោះផ្ទះមិនគួរសំពះ ១ ភិក្ខុកំពុងឆាន់បបរមិនគួរសំពះ ១ ភិក្ខុកំពុងឆាន់បង្អែមនឹងចំអាបមិនគួរសំពះ ១ ភិក្ខុបួសមុនមិនគួរសំពះភិក្ខុបួសក្រោយ ១ ភិក្ខុកំពុងនៅបរិវាសមិនគួរសំពះ ១ បុគ្គលដែលគួរសំពះ ១ ភិក្ខុខ្ចីជាងគួរថ្វាយបង្គំបាទាភិក្ខុចាស់ជាង ១ ។

ចប់ ឧបាលិបញ្ចកៈ តែប៉ុណ្ណេះ ។

ទេសំ វត្ថានំ ឧទ្ទានំ

(៣១២) អនិស្សិតេន កម្មញ្ច

វោហារាវិកម្មេន ច

ចោទនា ច ចុទក្កា ច

មុសា ភិក្ខុនិមេវ ច

ឧព្ពាហិកាធិករណំ

ភេទកា បញ្ចមា បុរេ

អាវាសិកា កឋិនញ្ច

ចុទ្ទសា សុប្បកាសិតាតិ ។

ឧទ្ទានគឺបញ្ជាំរឿងនៃវគ្គទាំងនោះដូច្នេះ

(៣១២) និយាយអំពីអនិស្សិតវគ្គ ១ កម្មនប្បដិប្បស្សម្ភន–វគ្គ ១ វោហារវគ្គ ១ ទិដ្ឋាវិកម្មវគ្គ ១ ចោទនាកណ្ឌវគ្គ ១ ធុតង្គវគ្គ ១ មុសាវាទវគ្គ១ ភិក្ខុនោវាទវគ្គ១ ឧព្ភាហិកាវគ្គ ១ អធិករណវូបសមវគ្គ ១ សង្ឃភេទវគ្គមានធម៌ ៤ យ៉ាង ១ ទុតិយសង្ឃភេទវគ្គមានធម៌ ៤ យ៉ាងដូចមុន ១ អាវាសិក–វគ្គ ១ កឋិនត្ថារវគ្គ ១ រួមទាំងអស់ត្រូវជា ១៤ វគ្គ ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសទុកមកហើយដោយល្អ ។

សមុដ្ឋានំ

(៣១៣) អត្ថាបត្តិ អចិត្តកោ អាបជ្ជតិ សចិត្តកោ វុដ្ឋាតិ អត្ថាបត្តិ សចិត្តកោ អាបជ្ជតិ អចិត្តកោ វុដ្ឋាតិ អត្ថាបត្តិ អចិត្តកោ អាបជ្ជតិ អចិត្តកោ វុដ្ឋាតិ អត្ថាបត្តិ អចិត្តកោ អាបជ្ជតិ សចិត្តកោ វុដ្ឋាតិ ។ អត្ថាបត្តិ កុសលចិត្តោ អាបជ្ជតិ កុសលចិត្តោ វុដ្ឋាតិ អត្ថាបត្តិ កុសលចិត្តោ អាបជ្ជតិ អកុសលចិត្តោ វុដ្ឋាតិ អត្ថាបត្តិ កុសលចិត្តោ អាបជ្ជតិ អព្យាកតចិត្តោ វុដ្ឋាតិ អត្ថាបត្តិ អកុសលចិត្តោ អាបជ្ជតិ កុសលចិត្តោ វុដ្ឋាតិ អត្ថាបត្តិ អកុសលចិត្តោ អាបជ្ជតិ អកុសលចិត្តោ វុដ្ឋាតិ អត្ថាបត្តិ អកុសលចិត្តោ អាបជ្ជតិ អព្យាកតចិត្តោ វុដ្ឋាតិ ។ អត្ថាបត្តិ អព្យាកតចិត្តោ អាបជ្ជតិ កុសលចិត្តោ

សមុដ្ឋាន

[៣១៣] អាបត្តិដែលភិក្ខុមិនមានចិត្តគិតហើយត្រូវ មានចិត្តគិតហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានចិត្តគិតហើយត្រូវ មិនមានចិត្តគិតហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមិនមានចិត្តគិតហើយត្រូវ មិនមានចិត្តគិតហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានចិត្តគិតហើយត្រូវ មានចិត្តគិតហើយចេញចាកអាបត្តិនោះក៏មាន ។ អាបត្តិដែលភិក្ខុមានកុសលចិត្តហើយត្រូវ មានកុសលចិត្តហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានកុសលចិត្តហើយត្រូវ មានអកុសលចិត្តហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានកុសលចិត្តហើយត្រូវ មានអព្យាកតចិត្តហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានអកុសលចិត្តហើយត្រូវ មានកុសលចិត្តហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានអកុសលចិត្តហើយត្រូវ មានអកុសលចិត្តហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានអកុសលចិត្តហើយត្រូវ មានអព្យាកតចិត្តហើយ ចេញចាកអាបត្តិនោះក៏មាន ។ អាបត្តិដែលភិក្ខុមានអព្យាកតចិត្តហើយត្រូវ មានកុសលចិត្ត

វុដ្ឋាតិ អនាបត្តិ អព្យាកតចិត្តោ អាបជ្ជតិ អកុសលចិត្តោ វុដ្ឋាតិ អនាបត្តិ អព្យាកតចិត្តោ អាបជ្ជតិ អព្យាកតចិត្តោ វុដ្ឋាតិ ។

(៣១៤) បឋមំ បារាជិកំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បឋមំ បារាជិកំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ទុតិយំ បារាជិកំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ទុតិយំ បារាជិកំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ តតិយំ បារាជិកំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ តតិយំ បារាជិកំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាច-

ហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានអព្យាកតចិត្តហើយត្រូវ មានអកុសលចិត្តហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានអព្យាកតចិត្តហើយត្រូវ មានអព្យាកតចិត្តហើយចេញចាកអាបត្តិនោះក៏មាន ។

(៣១៤) បឋមបារាជិកតាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ បឋមបារាជិកតាំងឡើងអំពីសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនតាំងឡើងអំពីវាចា ។ ទុតិយបារាជិកតាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ ទុតិយបារាជិកតាំងឡើងអំពីសមុដ្ឋាន ៣ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ។ តតិយបារាជិកតាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ តតិយបារាជិកតាំងឡើងអំពីសមុដ្ឋាន ៣ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចា

តោ ច ចិត្តតោ ច សមុដ្ឋាតិ ។ ចតុត្ថំ បារាជិកំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ចតុត្ថំ បារាជិកំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

ចត្តារោ បារាជិកា និដ្ឋិតា ។

(៣១៨) ឧបក្កមិត្វា អសុចិំ មោចេន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ឧបក្កមិត្វា អសុចិំ មោចេន្តស្ស សង្ឃាទិសេសោ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ មាតុគ្គាមេន សទ្ធិំ កាយសំសគ្គំ សមាបជ្ជន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ មាតុគ្គាមេន សទ្ធិំ កាយសំសគ្គំ សមាបជ្ជន្តស្ស សង្ឃាទិសេសោ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។

នឹងចិត្តក៏មាន ៗ ចតុត្ថបារាជិកតាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ៗ ចតុត្ថ-បារាជិកតាំងឡើងអំពីសមុដ្ឋាន ៣ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ៗ

ចប់ បារាជិក ៤ ។

(៣១៥) អាបត្តិសង្ឃាទិសេសរបស់ភិក្ខុដែលព្យាយាមធ្វើអសុចិឲ្យឃ្លាតចេញ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ៗ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុដែលព្យាយាមធ្វើអសុចិឲ្យឃ្លាតចេញ តាំងឡើងអំពីសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចា ៗ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុ ដែលដល់ព្រមនូវកាយសំសគ្គៈ មួយអន្លើដោយមាតុគ្រាម តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ៗ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុដែលដល់ព្រមនូវកាយសំសគ្គៈ មួយអន្លើដោយមាតុគ្រាម តាំងឡើងអំពីសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចា ៗ

មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសន្តស្ស សង្ឃាទិសេសោ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ មាតុគ្គាមស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ មាតុគ្គាមស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសន្តស្ស សង្ឃាទិសេសោ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។បេ។ សញ្ចរិត្តំ សមាបជ្ជន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ សញ្ចរិត្តំ សមាបជ្ជន្តស្ស សង្ឃាទិសេសោ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ សិយា វាចតោ សមុដ្ឋាតិ ន កាយតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ

អាបត្តិសង្ឃាទិសេសរបស់ភិក្ខុ ដែលពោលល្បួងមាតុគ្រាម ដោយវាចាអាក្រក់ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុ ដែលពោលល្បួងមាតុគ្រាមដោយវាចាអាក្រក់ តាំងឡើងអំពីសមុដ្ឋាន ៣ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុ ដែលពោលសរសើរការបម្រើដោយកាម ដើម្បីខ្លួនក្នុងសំណាក់នៃមាតុគ្រាម តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុ ដែលពោលសរសើរការបម្រើដោយកាម ដើម្បីខ្លួនក្នុងសំណាក់នៃមាតុគ្រាម តាំងឡើងអំពីសមុដ្ឋាន ៣ ។ បេ ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុ ដែលប្រព្រឹត្តជីកនាំ (បុរសស្ត្រីឲ្យបានគ្នាជាប្តីប្រពន្ធ) តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុ ដែលប្រព្រឹត្តជីកនាំ តាំងឡើងអំពីសមុដ្ឋាន ៦ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចានឹងចិត្តក៏មាន តាំងឡើងអំពីវាចា មិនបានតាំងឡើងអំពីកាយនឹងចិត្តក៏មាន តាំងឡើងអំពីកាយនឹងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនឹងចិត្ត

សមុដ្ឋានំ តេរស សង្ឃាទិសេសា

ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ សញ្ញាចិកាយ កុដឹ ការាបេន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ សញ្ញាចិកាយ កុដឹ ការាបេន្តស្ស សង្ឃាទិសេសោ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។ មហល្លកំ វិហារំ ការាបេន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ មហល្លកំ វិហារំ ការាបេន្តស្ស សង្ឃាទិសេសោ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។ ភិក្ខុំ អមូលកេន បារាជិកេន ធម្មេន អនុទ្ធំសេន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ភិក្ខុំ អមូលកេន បារាជិកេន ធម្មេន អនុទ្ធំសេន្តស្ស សង្ឃាទិសេសោ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។ ភិក្ខុំ អញ្ញភាគិយស្ស អធិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

សមុដ្ឋាន សង្ឃាទិសេស ១៣

មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុដែលឲ្យគេធ្វើកុដិ ដោយសូមគ្រឿងឧបករណ៍អំពីគេមកដោយខ្លួនឯង តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុដែលឲ្យគេធ្វើកុដិ ដោយសូមគ្រឿងឧបករណ៍អំពីគេមកដោយខ្លួនឯង តាំងឡើងអំពីសមុដ្ឋាន ៦ ។ បេ ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុដែលឲ្យគេធ្វើវិហារធំ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុដែលឲ្យគេធ្វើវិហារធំ តាំងឡើងអំពីសមុដ្ឋាន ៦ ។ បេ ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុ ដែលចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិកមិនមានមូល តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុដែលចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិកមិនមានមូល តាំងឡើងអំពីសមុដ្ឋាន ៣ ។ បេ ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុ ដែលកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ ជាចំណែកដទៃមកជាគ្រឿងអាង ហើយចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិក តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។

ភិក្ខុំ អញ្ញភាគិយស្ស អធិករណស្ស កញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេន្តស្ស សង្ឃាទិសេសោ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។ សង្ឃភេទកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ សង្ឃភេទកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ ភេទានុវត្តកានំ ភិក្ខូនំ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តានំ សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ភេទានុវត្តកានំ ភិក្ខូនំ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តានំ សង្ឃាទិសេសោ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

អាបត្តិសង្ឃាទិសេសរបស់ភិក្ខុ ដែលកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ជាចំណែកដទៃមកជាគ្រឿងកាន់ ហើយចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិក តាំងឡើងអំពីសមុដ្ឋាន ៣ ។ បេ ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុជាអ្នកទំលាយសង្ឃ ដែលសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុជាអ្នកទំលាយសង្ឃ ដែលសង្ឃសូត្រសមនុភាសនកម្ម ជាគំរប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនឹងវាចានឹងចិត្ត ។ អាបត្តិសង្ឃាទិសេស របស់ពួកភិក្ខុដែលប្រព្រឹត្តតាមភិក្ខុ ជាអ្នកទំលាយសង្ឃ ដែលសង្ឃសូត្រសមនុភាសនកម្ម ជាគំរប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អាបត្តិសង្ឃាទិសេសរបស់ពួកភិក្ខុដែលប្រព្រឹត្តតាមភិក្ខុ ជាអ្នកទំលាយសង្ឃ ដែលសង្ឃសូត្រសមនុភាសនកម្ម ជាគំរប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនឹងវាចានឹងចិត្ត ។

ទុព្វចស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិសជ្ជន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ទុព្វចស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ កុលទូសកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ កុលទូសកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

តេរស សង្ឃាទិសេសា និដ្ឋិតា ។

(៣១៦) ។ បេ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស ទុក្កដំ កតីហិ

អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលគេប្រដៅក្រ ដែលសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុដែលគេប្រដៅក្រដែលសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនឹងវាចានឹងចិត្ត ។ អាបត្តិសង្ឃាទិសេសរបស់ភិក្ខុដែលទ្រុស្តត្រកូល ដែលសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលទ្រុស្តត្រកូលដែលសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់ ៣ ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋាន ១ គឺតាំងឡើង អំពីកាយនឹងវាចានឹងចិត្ត ។

ចប់ សង្ឃាទិសេស ១៣ ។

(៣១៦) ។ បេ ។ អាបត្តិទុក្កដរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើបន្ទោបង់ ៖ ឧច្ចារៈក្តី បស្សាវៈក្តី ស្តោះទឹកមាត់ក្តីក្នុងទឹក តាំងឡើងអំពី

សមុដ្ឋានេហិ សមុដ្ឋាតិ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស ទុក្កដំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។

សេខិយា និដ្ឋិតា ។

(៣១៧) ចត្តារោ បារាជិកា កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចត្តារោ បារាជិកា តីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។

(៣១៨) តេរស សង្ឃាទិសេសា កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ តេរស សង្ឃាទិសេសា ឆហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ សិយា វាចតោ សមុដ្ឋហន្តិ

សមុដ្ឋានប៉ុន្មាន ។ អាបត្តិទុក្កដរបស់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើពើ បន្ទាបង់ឧច្ចារៈក្តី បស្សាវៈក្តី ស្តោះទឹកមាត់ក្តី ក្នុងទឹក តាំងឡើងអំពីសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចា ។

ចប់ សេខិយៈ ។

(៣១៧) បារាជិកទាំង ៤ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ បារាជិកទាំង ៤ តាំងឡើងអំពីសមុដ្ឋាន ៣ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ។

(៣១៨) សង្ឃាទិសេសទាំង ១៣ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ សង្ឃាទិសេសទាំង ១៣ តាំងឡើងអំពីសមុដ្ឋាន ៦ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចានឹងចិត្តក៏មាន តាំងឡើងអំពីវាចា មិនបានតាំង

ន កាយតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋហន្តិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។

(៣១៩) ទ្វេ អនិយតា កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ទ្វេ អនិយតា តីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។

(៣២០) តឹស និស្សគ្គិយា បាចិត្តិយា កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ តឹស និស្សគ្គិយា បាចិត្តិយា ឆហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ សិយា វាចតោ សមុដ្ឋហន្តិ ន កាយតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋហន្តិ

ឡើងអំពីកាយនឹងចិត្តក៏មាន តាំងឡើងអំពីកាយនឹងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ។

(៣១៩) អនិយតៈទាំង ២ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ អនិយតៈទាំង ២ តាំងឡើងអំពីសមុដ្ឋាន ៣ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ។

(៣២០) និស្សគ្គិយបាចិត្តិយៈទាំង ៣០ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ និស្សគ្គិយបាចិត្តិយៈទាំង ៣០ តាំងឡើងអំពីសមុដ្ឋាន ៦ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចានឹងចិត្តក៏មាន តាំងឡើងអំពីវាចា មិនបានតាំងឡើងអំពីកាយនឹងចិត្តក៏មាន តាំងឡើងអំពីកាយនឹងវាចា

ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។

(៣២១) ទ្វេ នវុតិ បាចិត្តិយា កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ទ្វេនវុតិ បាចិត្តិយា ឆហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ សិយា វាចតោ សមុដ្ឋហន្តិ ន កាយតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋហន្តិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។

(៣២២) ចត្តារោ បាដិទេសនីយា កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចត្តារោ បាដិទេសនីយា ចតូហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ

មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ។

[៣២១] បាចិត្តិយៈតាំង ៩២ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ បាចិត្តិយៈតាំង ៩២ តាំងឡើងអំពីសមុដ្ឋាន ៦ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចានឹងចិត្តក៏មាន តាំងឡើងអំពីវាចា មិនបានតាំងឡើងអំពីកាយនឹងចិត្តក៏មាន តាំងឡើងអំពីកាយនឹងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ។

[៣២២] បាដិទេសនីយៈតាំង ៤ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ បាដិទេសនីយៈតាំង ៤ តាំងឡើងអំពីសមុដ្ឋាន ៤ គឺតាំងឡើងអំពីកាយ

សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋហន្តិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។

(៣២៣) បញ្ចសត្តតិ សេក្ខិយា កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ បញ្ចសត្តតិ សេក្ខិយា តីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តីតិ ។

សមុដ្ឋានំ និដ្ឋិតំ ។

តស្សុទ្ទានំ

(៣២៤) អចិត្តកុសលា ចេវ[(១)]
សមុដ្ឋានញ្ច សព្វថា
យថាធម្មេន ញាយេន
សមុដ្ឋានំ វិជានថាតិ ។

---

១ ខ ម. អចិត្តកុសលោ ចេវ ។

មិនបានតាំងឡើងអំពីវាចានឹងចិត្តក៏មាន តាំងឡើងអំពីកាយនឹងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ។

(៣៦៣) សេក្ខិយៈទាំង ៧៥ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន ។ សេក្ខិយៈទាំង ៧៥ តាំងឡើងអំពីសមុដ្ឋាន ៣ គឺតាំងឡើងអំពីកាយនឹងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានឹងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនឹងវាចានឹងចិត្តក៏មាន ។

ចប់ សមុដ្ឋាន តែប៉ុណ្ណេះ ។

ឧទ្ទានគឺបញ្ជីរឿងនៃសមុដ្ឋាននោះដូច្នេះ

(៣៦៤) និយាយអំពីអាបត្តិដែលភិក្ខុមិនមានចិត្តគិត ១ មានកុសលចិត្ត ១ និយាយអំពីសមុដ្ឋាននៃអាបត្តិទាំងអស់ ១ អ្នកទាំងឡាយចូរដឹងសមុដ្ឋានដោយបញ្ញាដ៏សមគួរដល់អាបត្តិចុះ ។

ទុតិយគាថាសង្គណិកំ

(៣២៥) កតិ អាបត្តិយោ កាយិកា
កតិ វាចសិកា កតា
ឆាទេន្តស្ស កតិ អាបត្តិយោ
កតិ សំសគ្គបច្ចយា ។
ឆ អាបត្តិយោ កាយិកា
ឆ វាចសិកា កតា
ឆាទេន្តស្ស តិស្សោ អាបត្តិយោ
បញ្ច សំសគ្គបច្ចយា ។

(៣២៦) អរុណុគ្គេ កតិ អាបត្តិយោ
កតិ យាវតតិយកា
កតេត្ថ អដ្ឋវត្ថុកា
កតីហិ សព្វសង្គហោ ។
អរុណុគ្គេ តិស្សោ អាបត្តិយោ
ទ្វេ យាវតតិយកា
ឯកេត្ថ អដ្ឋវត្ថុកា
ឯកេន សព្វសង្គហោ ។

ទុតិយគាថាសង្គណិកៈ

(៣២៥) សួរថា អាបត្តិដែលតាំងឡើងអំពីកាយមានប៉ុន្មាន អាបត្តិដែលតាំងឡើង អំពីវាចាមានប៉ុន្មាន អាបត្តិប៉ុន្មានមានដល់ឧបសម្បន្នដែលបិទបាំងទោសទុក អាបត្តិប៉ុន្មានដែលត្រូវព្រោះបច្ច័យគឺការប៉ះពាល់នូវកាយ ។ ឆ្លើយថា អាបត្តិដែលតាំងឡើងអំពីកាយមាន ៦ អាបត្តិដែលតាំងឡើងអំពីវាចាមាន ៦ អាបត្តិ ៣ មានដល់ឧបសម្បន្នដែលបិទបាំងទោសទុក អាបត្តិ ៥ ដែលត្រូវព្រោះបច្ច័យគឺការប៉ះពាល់នូវកាយ ។

(៣២៦) អាបត្តិដែលត្រូវក្នុងវេលាអរុណរះឡើង មានប៉ុន្មាន អាបត្តិដែលត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគំរប់ ៣ ដង មានប៉ុន្មាន អាបត្តិដែលត្រូវព្រោះបំពេញនូវវត្ថុគ្រប់ទាំង ៨ មានប៉ុន្មាន ក្នុងសាសនានេះ ការសង្គ្រោះទាំងអស់ដោយឧទ្ទេសប៉ុន្មាន ។ អាបត្តិដែលត្រូវក្នុងវេលាអរុណរះឡើងមាន ៣ អាបត្តិដែលត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគំរប់ ៣ ដង មាន ២ អាបត្តិដែលត្រូវព្រោះបំពេញនូវវត្ថុឲ្យគ្រប់ទាំង ៨ មានតែ ១ ក្នុងសាសនានេះ ការសង្គ្រោះទាំងអស់ដោយឧទ្ទេសតែ ១ គឺនិទានុទ្ទេស ។

ទុតិយគាថាសង្គណិកំ វិនយមូលាទិបុច្ឆាវិស្សជ្ជនា

(៣២៧) វិនយស្ស កតិ មូលានិ
យានិ ពុទ្ធេន បញ្ញត្តា
វិនយគរុកា កតិ វុត្តា
ទុដ្ឋុល្លច្ឆាទនា កតិ ។
វិនយស្ស ទ្វេ មូលានិ
យានិ ពុទ្ធេន បញ្ញត្តា
វិនយគរុកា ទ្វេ វុត្តា
ទ្វេ ទុដ្ឋុល្លច្ឆាទនា ។

(៣២៨) គាមន្តរេ កតិ អាបត្តិយោ
កតិ នទីបារបច្ចយា
កតិ មំសេសុ ថុល្លច្ចយំ
កតិ មំសេសុ ទុក្កដំ ។
គាមន្តរេ ចតស្សោ អាបត្តិយោ
ចតស្សោ នទីបារបច្ចយា
ឯកមំសេ ថុល្លច្ចយំ
នវមំសេសុ ទុក្កដំ ។

ទុតិយគាថាសង្គណិកៈ បុច្ឆាវិស្សជ្ជនាអំពីមូលនៃវិន័យជាដើម

[៣៦៧] មូលរបស់វិន័យមានប៉ុន្មាន ដែលព្រះពុទ្ធទ្រង់បញ្ញត្តទុកមក គរុកាបត្តិក្នុងវិន័យមានប៉ុន្មាន ដែលព្រះអង្គទ្រង់ត្រាស់ទុកមក អាបត្តិដែលត្រូវព្រោះបិទបាំងទុដ្ឋុល្លាបត្តិមានប៉ុន្មាន ។ មូលរបស់វិន័យមាន ២ ដែលព្រះពុទ្ធទ្រង់បញ្ញត្តទុកមក គរុកាបត្តិក្នុងវិន័យមាន ២ ដែលព្រះអង្គទ្រង់ត្រាស់ទុកមក ដែលត្រូវព្រោះបិទបាំងទុដ្ឋុល្លាបត្តិមាន២[1] ។

[៣៦៨] អាបត្តិប៉ុន្មាន ដែលត្រូវក្នុងចន្លោះផ្ទះ អាបត្តិប៉ុន្មាន ដែលត្រូវព្រោះឆ្លងទៅកាន់ត្រើយស្ទឹង ជាបច្ច័យ សាច់ប៉ុន្មានប្រការ ដែលភិក្ខុឆាន់ត្រូវថុល្លច្ច័យ សាច់ប៉ុន្មានប្រការ ដែលភិក្ខុឆាន់ត្រូវទុក្កដ ។ អាបត្តិ ៤ ដែលត្រូវក្នុងចន្លោះផ្ទះ អាបត្តិ ៤ ដែលត្រូវព្រោះឆ្លងទៅកាន់ត្រើយស្ទឹង ជាបច្ច័យ សាច់មនុស្សតែម្យ៉ាងដែលឆាន់ត្រូវអាបត្តិថុល្លច្ច័យ សាច់ ៩ ប្រការ ដែលភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ ។

---

១ អដ្ឋកថា អាបត្តិ ២ នោះគឺអាបត្តិបារាជិក របស់ភិក្ខុនីដែលត្រូវព្រោះខ្លួនបិទបាំងទោសភិក្ខុនីផងគ្នា ១ អាបត្តិបាចិត្តិយៈរបស់ភិក្ខុដែលត្រូវព្រោះខ្លួនបិទបាំងអាបត្តិសង្ឃាទិសេសនៃភិក្ខុផងគ្នា ១ ។

(៣២៩) កតិ វាចសិកា រត្តី
កតិ វាចសិកា ទិវា
ទទមានស្ស កតិ អាបត្តិយោ
បដិគ្គណ្ហន្តស្ស កិត្តកា ។
ទ្វេ វាចសិកា រត្តី
ទ្វេ វាចសិកា ទិវា
ទទមានស្ស តិស្សោ អាបត្តិយោ
ចត្តារោ ច បដិគ្គហោ ។

(៣៣០) កតិ ទេសនាគាមិនិយោ
កតិ សប្បដិកម្មា កតា
កតេត្ថ អប្បដិកម្មា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា ។
បញ្ច ទេសនាគាមិនិយោ
ឆ សប្បដិកម្មា កតា
ឯកេត្ថ អប្បដិកម្មា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា ។

(៣២៩) អាបត្តិប៉ុន្មានដែលតាំងឡើងអំពីវាចា ហើយត្រូវតែក្នុងរាត្រី អាបត្តិប៉ុន្មានដែលតាំងឡើងអំពីវាចា ហើយត្រូវតែក្នុងវេលាថ្ងៃ អាបត្តិប៉ុន្មានមានដល់ឧបសម្បន្នដែលឲ្យ អាបត្តិប៉ុន្មានមានដល់ឧបសម្បន្នដែលទទួល ។ អាបត្តិ ២ ប្រកបដោយវាចាហើយត្រូវតែក្នុងរាត្រី អាបត្តិ ២ ដែលតាំងឡើងអំពីវាចាហើយត្រូវតែក្នុងវេលាថ្ងៃ អាបត្តិ ៣ មានដល់ឧប-សម្បន្នដែលឲ្យ អាបត្តិ ៤ មានដល់ឧបសម្បន្នដែលទទួល ។

(៣៣០) អាបត្តិប៉ុន្មានដែលជាទេសនាគាមិនី អាបត្តិប៉ុន្មានដែលជាសប្បដិកម្ម(១) ក្នុងសាសនានេះ មានអាបត្តិប៉ុន្មានដែលព្រះពុទ្ធជាអាទិច្ចវង្សទ្រង់ត្រាស់ថាជាអប្បដិកម្ម(២) ក្នុងសាសនានេះ ។ អាបត្តិដែលជាទេសនាគាមិនីមាន ៥ អាបត្តិដែលជាសប្បដិកម្មមាន ៦ អាបត្តិ ១ ដែលព្រះពុទ្ធជាអាទិច្ច-វង្សទ្រង់ត្រាស់ថាជាអប្បដិកម្ម ក្នុងសាសនានេះ ។

---

១ អដ្ឋកថា ថា សប្បដិកម្ម ប្រែថា អាបត្តិដែលកែបាន បានដល់អាបត្តិ ៦ កង ទាំងពីសង្ឃាទិសេស រហូតដល់ទុព្ភាសិត ។ ២ អប្បដិកម្ម ប្រែថា អាបត្តិកែលែងបាន បានដល់បារាជិក ៤ ឬទាំង ៨ ។

(៣៣១) វិនយគរុកា កតិ វុត្តា
កាយវាចសិកានិ ច
កតិ វិកាលេ ធញ្ញរសា(១)
កតិ ញត្តិចតុត្ថេន សម្មុតិ ។
វិនយគរុកា ទ្វេ វុត្តា
កាយវាចសិកានិ ច
ឯកោ វិកាលេ ធញ្ញរសោ
ឯកា ញត្តិចតុត្ថេន សម្មុតិ ។

(៣៣២) បារាជិកា កាយិកា កតិ
កតិ សំវាសកភូមិយោ(២)
កតីនញ្ច រត្តិច្ឆេទោ
បញ្ញត្តា ទ្វង្គុលា កតិ ។
បារាជិកា កាយិកា ទ្វេ
ទ្វេ សំវាសកភូមិយោ(៣)
ទ្វិន្នញ្ច រត្តិច្ឆេទោ
បញ្ញត្តា ទ្វង្គុលា ទុវេ ។

---

១ ម. ធញ្ញរសោ ។ ២-៣ ឱ. សំវាសភូមិយោ ។

ទុតិយគាថាសង្គណិកៈ បុច្ឆាវិស្សជ្ជនាអំពីគរុកាបត្តិជាដើម

(៣៣១) អាបត្តិប៉ុន្មាន ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថាជាគរុកាបត្តិក្នុងវិន័យ សិក្ខាបទប៉ុន្មាន ដែលតាំងឡើងអំពីកាយនឹងវាចា សេស្រូវប៉ុន្មានដែលគួរឆាន់បានក្នុងវេលាវិកាល ការសន្មតិដោយញត្តិចតុត្ថកម្មវាចា មានប៉ុន្មាន ៕ អាបត្តិ ២ យ៉ាងដែលព្រះពុទ្ធជាអាទិច្ចវង្សទ្រង់ត្រាស់ថាជាគរុកាបត្តិក្នុងវិន័យ សិក្ខាបទទាំងអស់សុទ្ធតែតាំងឡើងអំពីកាយនឹងវាចា សេស្រូវតែ១គឺថ្នាំឈ្មោះលោណសោចិរកៈ[1]ដែលគួរឆាន់បានក្នុងវេលាវិកាល ការសន្មតិដោយញត្តិចតុត្ថកម្មវាចាមានតែ១ ៕

(៣៣២) អាបត្តិបារាជិក ដែលតាំងឡើងអំពីកាយមានប៉ុន្មាន ភូមិនៃសំវាសមានប៉ុន្មាន រាត្រីដាច់មានដល់ភិក្ខុប៉ុន្មានពួក ព្រះអង្គបញ្ញត្តខាតត្រឹមពីរធ្នាប់ មានប៉ុន្មានសិក្ខាបទ ៕ អាបត្តិបារាជិកដែលតាំងឡើងអំពីកាយមាន ២ ភូមិនៃសំវាសមាន ២ រាត្រីដាច់មានដល់ភិក្ខុ ២ ពួក (ភិក្ខុកំពុងនៅបរិវាស ១ ប្រព្រឹត្តមានត្ត ១) ព្រះអង្គទ្រង់បញ្ញត្តខាតត្រឹមពីរធ្នាប់ មាន២ សិក្ខាបទ[2] ៕

---

១ អដ្ឋកថា ថា ត្រូវមើលនយលក្ខណៈក្នុងសៀវភៅទី ៧ ក្នុងភេសជ្ជក្ខន្ធកៈទំព័រ ២៥៦ ៕

២ ព្រះអង្គ ទ្រង់បញ្ញត្តមិនឲ្យភិក្ខុនីយកម្រាមដៃលាងអង្គជាតឲ្យហួសជាង២ធ្នាំងម្រាមដៃឡើងទៅ អនុញ្ញាតត្រឹមតែ ២ ធ្នាំងដៃ១ទ្រង់បញ្ញត្តមិនឲ្យទុកសក់វែងហួសជាង ២ ធ្នាប់ឡើងទៅ ១ ៕

(៣៣៣) កតត្ថានំ វធិត្វាន

កតីហិ សង្វេជ្យា កិជ្ជតិ

កេត្ថ បឋមាបត្តិកា

ញត្តិយា ការណា កតិ ។

ទេ្វ អត្ថានំ វធិត្វាន

ទ្វីហិ សង្វេជ្យា កិជ្ជតិ

ទេ្វត្ថ បឋមាបត្តិកា

ញត្តិយា ការណា ទុវេ ។

(៣៣៤) ឆាណាតិឆាតេ កតិ អាបត្តិយោ

ភចា ឆាភជិកា កតិ

ឱកាសជា កតិ វុត្តា

សញ្ចរិត្តេន ភ កតិ ។

ឆាណាតិឆាតេ តិស្សោ អាបត្តិយោ

ភចា ឆាភជិកា តយោ

ឱកាសជា តយោ វុត្តា

សញ្ចរិត្តេន ភ តយោ ។

(៣៣៣) ភិក្ខុនី វាយខ្លួនឯង ត្រូវអាបត្តិប៉ុន្មាន សង្ស័យបែក គ្នាដោយអាការប៉ុន្មាន អាបត្តិដែលត្រូវជាជំពូកក្នុងវិន័យនេះ មានប៉ុន្មាន ការចេញត្តិមានប៉ុន្មាន ។ ភិក្ខុនី វាយខ្លួនឯង ត្រូវអាបត្តិ ២ សង្ស័យបែកគ្នាដោយអាការ ២ អាបត្តិដែលត្រូវ ជាជំពូកក្នុងវិន័យនេះមាន ២ ការចេញត្តិមាន ២ ។

(៣៣៤) ក្នុងបាណាតិបាតមានអាបត្តិប៉ុន្មាន អាបត្តិបារាជិក ដែលតាំងឡើងអំពីវាចាមានប៉ុន្មាន អាបត្តិដែលភិក្ខុនិយាយ ល្បួងមាតុគ្រាមដោយពាក្យអាក្រក់មានប៉ុន្មាន អាបត្តិប៉ុន្មាន ដែលភិក្ខុត្រូវព្រោះការដឹកនាំបុរសនឹងស្ត្រី ឲ្យបានគ្នាជាប្តី ប្រពន្ធ ។ ក្នុងបាណាតិបាតមានអាបត្តិ ៣ អាបត្តិបារាជិកដែល តាំងឡើងអំពីវាចាមាន ៣ អាបត្តិដែលភិក្ខុនិយាយល្បួងមាតុ-គ្រាមដោយពាក្យអាក្រក់មាន ៣ អាបត្តិ ៣ ត្រូវ(ព្រោះការ ដឹកនាំបុរសនឹងស្ត្រីឲ្យបានគ្នាជាប្តីប្រពន្ធ) ។

ទុតិយគាថាសង្គណិកំ តិបុគ្គលាទិបុច្ឆាវិស្សជ្ជនា

(៣៣៥) កតិ បុគ្គលា ន ឧបសម្បាទេតព្វា
កតី កម្មាន(១) សង្គហា
នាសិតកា កតិ វុត្តា
កតីនំ ឯកវាចិកា ។

តយោ បុគ្គលា ន ឧបសម្បាទេតព្វា
តយោ កម្មាន(២) សង្គហា
នាសិតកា តយោ វុត្តា
តិណ្ណន្នំ ឯកវាចិកា ។

(៣៣៦) អទិន្នាទានេ កតិ អាបត្តិយោ
កតិ មេថុនប្បច្ចយា
ឆិន្ទន្តស្ស កតិ អាបត្តិយោ
កតិ ឆឌ្ឌិតប្បច្ចយា ។

អទិន្នាទានេ តិស្សោ អាបត្តិយោ
ចតស្សោ មេថុនប្បច្ចយា
ឆិន្ទន្តស្ស តិស្សោ អាបត្តិយោ
បញ្ច ឆឌ្ឌិតប្បច្ចយា ។

១-២ ឱ. ម. កម្មានិ ។

[៣៣៥] បុគ្គលដែលមិនត្រូវឲ្យឧបសម្បទា មានប៉ុន្មានពួក ការសង្គ្រោះកម្មមានប៉ុន្មាន បុគ្គលដែលព្រះអង្គទ្រង់ត្រាស់ថា ត្រូវឲ្យវិនាសមានប៉ុន្មាន ជនប៉ុន្មានពួកដែលត្រូវសូត្រកម្មវាចាតែមួយបាន ។ បុគ្គលដែលមិនត្រូវឲ្យឧបសម្បទាមាន ៣ ពួក ការសង្គ្រោះកម្មមាន ៣ បុគ្គលដែលព្រះអង្គទ្រង់ត្រាស់ថាត្រូវឲ្យវិនាសមាន ៣ ពួក ជន ៣ ពួក ដែលត្រូវសូត្រកម្មវាចាតែមួយបាន ។

[៣៣៦] ភិក្ខុអទិន្នាទានមានអាបត្តិប៉ុន្មាន អាបត្តិព្រោះមេថុនជាបច្ច័យមានប៉ុន្មាន អាបត្តិប៉ុន្មានមានដល់ភិក្ខុដែលកាត់ អាបត្តិប៉ុន្មានដែលភិក្ខុត្រូវព្រោះពោលជាបច្ច័យ ។ ភិក្ខុអទិន្នាទានមានអាបត្តិ ៣ អាបត្តិព្រោះមេថុនជាបច្ច័យមាន ៤ អាបត្តិ ៣ មានដល់ភិក្ខុដែលកាត់ អាបត្តិ ៥ ដែលភិក្ខុត្រូវព្រោះពោលជាបច្ច័យ ។

(៣៣៧) ភិក្ខុនោវាទកវគ្គស្មឹ
បាចិត្តិយេន ទុក្កដា
កតេត្ថ នវកា វុត្តា
កតិនំ ចីវរេន ច ។
ភិក្ខុនោវាទកវគ្គស្មឹ
បាចិត្តិយេន ទុក្កដា កតា
ចតុរេត្ថ នវកា វុត្តា
ទ្វិន្នំ ចីវរេន ច ។

(៣៣៨) ភិក្ខុនីនញ្ច អក្ខាតា
បាដិទេសនីយា កតិ
ភុញ្ជន្តាមកធញ្ញេន
បាចិត្តិយេន ទុក្កដា កតិ ។
ភិក្ខុនីនញ្ច អក្ខាតា
អដ្ឋ បាដិទេសនីយា កតា
ភុញ្ជន្តាមកធញ្ញេន
បាចិត្តិយេន ទុក្កដា កតា ។

(៣៣៧) ក្នុងភិក្ខុនោវាទកវគ្គ មានអាបត្តិទុក្កដលាយ
ដោយអាបត្តិបាចិត្តិយៈដែរឬទេ នវកៈក្នុងបឋមសិក្ខាបទនេះ
ព្រះមានព្រះភាគទ្រង់ត្រាស់ថា មានប៉ុន្មាន អាបត្តិដែលត្រូវ
ព្រោះបវារមានដល់ភិក្ខុប៉ុន្មានពួក ។ ក្នុងភិក្ខុនោវាទកវគ្គក៏
មានអាបត្តិទុក្កដលាយដោយអាបត្តិបាចិត្តិយៈដែរ ក្នុងបឋម-
សិក្ខាបទនេះមាននវកៈ ៤ ដែលព្រះអង្គទ្រង់ត្រាស់ទុកមក
ហើយ អាបត្តិដែលត្រូវព្រោះបវារមានដល់ភិក្ខុពីរពួក ។

(៣៣៨) អាបត្តិបាដិទេសនីយៈរបស់ភិក្ខុនីព្រះអង្គទ្រង់ត្រាស់
ថាមានប៉ុន្មាន អាបត្តិទុក្កដលាយដោយអាបត្តិបាចិត្តិយៈព្រោះ
សូមស្រូវស្រស់យកមកឆាន់មានដែរឬទេ ។ អាបត្តិបាដិ-
ទេសនីយៈរបស់ភិក្ខុនីព្រះអង្គទ្រង់ត្រាស់ថាមាន ៨ អាបត្តិ
ទុក្កដលាយដោយអាបត្តិបាចិត្តិយៈ ព្រោះសូមស្រូវស្រស់យក
មកឆាន់ក៏មានដែរ ។

[១៧៩] គច្ឆន្តស្ស កតិ អាបតិយោ
ឋិតស្ស ចាបិ កិត្តកា
និសិន្នស្ស កតិ អាបត្តិយោ
និបន្នស្សាបិ កិត្តកា[1] ។
គច្ឆន្តស្ស ចតស្សោ អាបត្តិយោ
ឋិតស្ស ចាបិ តត្តកា[2]
និសិន្នស្ស ចតស្សោ អាបត្តិយោ
និបន្នស្សាបិ តត្តកា[3] ។

[១៨០] កតិ បាចិត្តិយានិ សព្វានិ នានាវត្ថុកានិ
អបុព្វំ អចរិម អាបជ្ជេយ្យ ឯកតោ ។
បញ្ច បាចិត្តិយានិ សព្វានិ នានាវត្ថុកានិ
អបុព្វំ អចរិមំ អាបជ្ជេយ្យ ឯកតោ ។

---

១ ឱ. កិត្តិកា ។ ២–៣ តត្តិកា ។

ទុតិយគាថាសង្គណិកៈ បុច្ឆាវិស្សជ្ជនាអំពីអាបត្តិជាចិត្តិយៈ

(៣៣៩) អាបត្តិប៉ុន្មានមានដល់ភិក្ខុដែលដើរ អាបត្តិប៉ុន្មានមានដល់ភិក្ខុដែលឈរ អាបត្តិប៉ុន្មានមានដល់ភិក្ខុដែលអង្គុយ អាបត្តិប៉ុន្មានមានដល់ភិក្ខុដែលដេក ។ អាបត្តិ ៤ មានដល់ភិក្ខុដែលដើរ ឯភិក្ខុដែលឈរក៏មានអាបត្តិប៉ុណ្ណោះដែរ អាបត្តិ ៤ មានដល់ភិក្ខុដែលអង្គុយ ឯភិក្ខុដែលដេកក៏មានអាបត្តិប៉ុណ្ណោះដែរ ។

(៣៤០) ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នាក្នុងខណៈមួយមិនមុនមិនក្រោយ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ ៩ ដែលមានវត្ថុផ្សេងៗគ្នា ក្នុងខណៈមួយ មិនមុន មិនក្រោយ ។

(៣៤១) កតិ អាបត្តិយោ សព្វានិ នានាវត្ថុកានិ

អបុព្វំ អចរិមំ អាបជ្ជេយ្យ ឯកតោ ។

នវ អាបត្តិយោ សព្វានិ នានាវត្ថុកានិ

អបុព្វំ អចរិមំ អាបជ្ជេយ្យ ឯកតោ ។

(៣៤២) កតិ អាបត្តិយោ សព្វានិ នានាវត្ថុកានិ

កតិវាចាយ ទេសេយ្យ វុត្តា អាទិច្ចពន្ធុនា ។

បញ្ច អាបត្តិយោ សព្វានិ នានាវត្ថុកានិ

ឯកវាចាយ ទេសេយ្យ វុត្តា អាទិច្ចពន្ធុនា ។

(៣៨១) ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នា ក្នុងខណៈមួយ មិនមុន មិនក្រោយ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ ៩ ដែលមានវត្ថុផ្សេងៗគ្នា ក្នុងខណៈមួយ មិនមុន មិនក្រោយ ។

(៣៨២) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរសំដែងដោយវាចាប៉ុន្មានដងបាន ។ ព្រះពុទ្ធជាអាទិច្ចវង្សទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ ៩ ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរសំដែងដោយវាចាតែម្ដងបាន ។

ទុតិយគាថាសង្គណិកំ បាចិត្តិយបុច្ឆាវិស្សជ្ជនា

(៣៤៣) កតិ បាចិត្តិយានិ សព្វានិ នានាវត្ថុកានិ

កតិវាចាយ ទេសេយ្យ វុត្តា អាទិច្ចពន្ធុនា ។

នវ បាចិត្តិយានិ សព្វានិ នានាវត្ថុកានិ

ឯកវាចាយ ទេសេយ្យ វុត្តា អាទិច្ចពន្ធុនា ។

(៣៤៤) កតិ បាចិត្តិយានិ សព្វានិ នានាវត្ថុកានិ

កិញ្ចិ កិត្តេត្វា ទេសេយ្យ វុត្តា អាទិច្ចពន្ធុនា ។

បញ្ច បាចិត្តិយានិ សព្វានិ នានាវត្ថុកានិ

វត្ថុំ កិត្តេត្វា ទេសេយ្យ វុត្តា អាទិច្ចពន្ធុនា ។

ទុតិយគាថាសង្គណិកៈ បុច្ឆាវិស្សជ្ជនាអំពីអាបត្តិបាចិត្តិយៈ

(៣៤៣) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរសំដែងដោយវាចាប៉ុន្មានដងបាន ។ ព្រះពុទ្ធជាអា–ទិច្ចវង្សទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំង–អស់ ៩ ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរសំដែង ដោយវាចាតែមួយដងបាន ។

(៣៤៤) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មានដែលមានវត្ថុផ្សេង ៗ គ្នា ហើយគួរប្រាប់អ្វី ទើបសំដែងបាន ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់៥ ដែលមានវត្ថុផ្សេងៗគ្នាហើយគួរប្រាប់វត្ថុទើបសំដែងបាន ។

(៣៨៥) កតិ បាចិត្តិយានិ សព្វានិ នានាវត្ថុកានិ

កិញ្ច កត្វា ទេសេយ្យ វុត្តា អាទិច្ចពន្ធុនា ។

នវ បាចិត្តិយានិ សព្វានិ នានាវត្ថុកានិ

វត្ថុំ កត្វា ទេសេយ្យ វុត្តា អាទិច្ចពន្ធុនា ។

(៣៨៦) យាវតតិយកេ កតិ អាបត្តិយោ

កតិ វោហារបច្ចយា

ខាទន្តស្ស កតិ អាបត្តិយោ

កតិ ភោជនបច្ចយា ។

យាវតតិយកេ តិស្សោ អាបត្តិយោ

ឆ វោហារបច្ចយា

ខាទន្តស្ស តិស្សោ អាបត្តិយោ

បញ្ច ភោជនបច្ចយា ។

(៣៨៥) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរប្រាប់អ្វីទើបសំដែងបាន ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ ៩ ដែលមានវត្ថុផ្សេង ៗ គ្នា ហើយគួរប្រាប់វត្ថុទើបសំដែងបាន ។

(៣៨៦) អាបត្តិប៉ុន្មានយ៉ាងដែលត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគំរប់៣ ផង អាបត្តិប៉ុន្មាន ដែលត្រូវព្រោះពោលជាបច្ច័យ អាបត្តិប៉ុន្មានដែលត្រូវព្រោះទំពាស៊ី (សាច់) អាបត្តិប៉ុន្មានដែលត្រូវព្រោះភោជនជាបច្ច័យ ។ អាបត្តិ ៣ ដែលត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគំរប់ ៣ ផង អាបត្តិ ៦ ដែលត្រូវព្រោះពោលជាបច្ច័យ ។ អាបត្តិ ៣ ដែលត្រូវព្រោះទំពាស៊ី (សាច់) អាបត្តិ៩ ដែលត្រូវព្រោះភោជនជាបច្ច័យ ៕

ទុតិយគាថាសង្គណិកំ យាវតតិយាទិបញ្ហាវិស្សជ្ជនា

(៣៤៧) សព្វា យាវតតិយា
កតិ ឋានានិ គច្ឆន្តិ
កតីនញ្ចេវ អាបត្តិ
កតីនំ អធិករណេន ច ។
សព្វា យាវតតិយកា
បញ្ច ឋានានិ គច្ឆន្តិ
បញ្ចន្នញ្ចេវ អាបត្តិ
បញ្ចន្នំ អធិករណេន ច ។

(៣៤៨) កតីនំ វិនិច្ឆយោ ហោតិ
កតីនំ វូបសមេន ច
កតីនញ្ចេវ អនាបត្តិ
កតីហិ ឋានេហិ សោភតិ ។
បញ្ចន្នំ វិនិច្ឆយោ ហោតិ
បញ្ចន្នំ វូបសមេន ច
បញ្ចន្នញ្ចេវ អនាបត្តិ
តីហិ ឋានេហិ សោភតិ ។

(៣៤៧) យាវតតិយកាបត្តិទាំងអស់ រមែងដល់នូវស្ថានប៉ុន្មាន មួយទៀត អាបត្តិមានដល់បុគ្គលប៉ុន្មានពួក អធិករណ៍មានដល់បុគ្គលប៉ុន្មានពួក ។ យាវតតិយកាបត្តិទាំងអស់ រមែងដល់នូវស្ថាន ៤ អាបត្តិមានដល់បុគ្គល ៤ ពួក អធិករណ៍មានដល់បុគ្គល ៤ ពួក ។

(៣៤៨) ការវិនិច្ឆ័យមានដល់បុគ្គលប៉ុន្មានពួក ការរម្ងាប់អធិករណ៍មានដល់បុគ្គលប៉ុន្មានពួក អនាបត្តិមានដល់បុគ្គលប៉ុន្មានពួក បុគ្គលរុងរឿងដោយស្ថានប៉ុន្មានយ៉ាង ។ ការវិនិច្ឆ័យមានដល់បុគ្គល ៤ ពួក ការរម្ងាប់អធិករណ៍មានដល់បុគ្គល ៤ ពួក អនាបត្តិមានដល់បុគ្គល ៤ ពួក បុគ្គលរុងរឿងដោយស្ថាន ៣ យ៉ាង ។

(៣៤៩) កតិ កាយិកា រត្តិ
កតិ កាយិកា ទិវា
និជ្ឈន្តស្ស កតិ អាបត្តិ
កតិ បិណ្ឌបាតបច្ចយា ។
ទ្វេ កាយិកា រត្តិ
ទ្វេ កាយិកា ទិវា
និជ្ឈន្តស្ស ឯកា អាបត្តិ
ឯកា បិណ្ឌបាតបច្ចយា ។

(៣៥០) កតានិសំសេ សម្បស្សំ
បរេសំ សទ្ធាយ ទេសយេ[១]
ឧក្ខិត្តកា កតិ វុត្តា
កតិ សម្មាបវត្តនា[២] ។
អដ្ឋានិសំសេ សម្បស្សំ
បរេសំ សទ្ធាយ ទេសយេ
ឧក្ខិត្តកា តយោ វុត្តា
តេចត្តាឡីស សម្មាវត្តនា ។

---
១ ឧ. ទេសេយ្យ ។ ២ ឧ. ម. សម្មាវត្តនា ។

(៣៨៩) អាបត្តិដែលតាំងឡើងអំពីកាយ ហើយត្រូវតែក្នុងរាត្រីមានប៉ុន្មាន អាបត្តិដែលតាំងឡើងអំពីកាយ ហើយត្រូវតែក្នុងវេលាថ្ងៃមានប៉ុន្មាន អាបត្តិប៉ុន្មានដែលត្រូវព្រោះគយគន់ អាបត្តិប៉ុន្មានដែលត្រូវព្រោះបិណ្ឌបាតជាបច្ច័យ ។ អាបត្តិដែលតាំងឡើងអំពីកាយ ហើយត្រូវតែក្នុងវេលារាត្រីមាន ២ អាបត្តិ ដែលតាំងឡើងអំពីកាយ ហើយត្រូវតែក្នុងវេលាថ្ងៃមាន ២ អាបត្តិតែ ១ ដែលត្រូវព្រោះគយគន់ (មើលអង្គជាតមាតុគ្រាមដោយតម្រេក) អាបត្តិតែ ១ ដែលត្រូវព្រោះបិណ្ឌបាតជាបច្ច័យ[1] ។

(៣៩០) ភិក្ខុឃើញអានិសង្ស ប៉ុន្មាន ទើបសំដែងធម៌ដល់អ្នកដទៃដោយសទ្ធា ឧក្ខិត្តកភិក្ខុ (ភិក្ខុដែលសង្ឃលើកវត្ត) ព្រះមានព្រះភាគត្រាស់ថាមានប៉ុន្មាន ការប្រព្រឹត្តិវត្តដោយប្រពៃមានប៉ុន្មាន ។ ភិក្ខុឃើញអានិសង្ស ៨ យ៉ាង ទើបសំដែងធម៌ ដល់អ្នកដទៃដោយសទ្ធា ឧក្ខិត្តកភិក្ខុព្រះមានព្រះភាគទ្រង់ត្រាស់ថាមាន ៣ ពួក ការប្រព្រឹត្តិវត្តដោយប្រពៃមាន ៤៣ ។

---

១ អដ្ឋកថា ថា អាបត្តិតែ ១ ដែលត្រូវព្រោះបិណ្ឌបាតជាបច្ច័យនោះគឺ ភិក្ខុសំឡឹងមើលមុខស្ត្រីដែលប្រគេនចង្ហាន់ត្រូវទុក្កដ ។ ដោយហោចទៅសូម្បីតែសំឡឹងមើលមុខសាមណេរដែលកំពុងប្រគេនបបរ ឬម្ហូបក្រៀមក៏ត្រូវទុក្កដដែរ ។ ប៉ុន្តែក្នុងកុរុន្ទីលោកកែក្នុងបទថា អាបត្តិតែ ១ ដែលត្រូវព្រោះបិណ្ឌបាតជាបច្ច័យនោះ គឺភិក្ខុឆាន់បិណ្ឌបាតដែលភិក្ខុនីបាត់បែងត្រូវបាចិត្តិយៈ។ (ពាក្យក្នុងកុរុន្ទីនេះ ត្រូវគ្នានឹងបរិបាចនសិក្ខាបទ ក្នុងមហាវិភង្គ) ។

ទុតិយគាថាសង្គណិកំ មុសាវាទបុច្ឆាវិស្សជ្ជនា

(៣៨១) កតិហានេ មុសាវាទោ
កតិ បរមន្តិ វុច្ចតិ
កតិ ចាបិ ទេសនីយា
កតីនំ ទេសនាយ ច ។
បញ្ចហានេ មុសាវាទោ
ចុទ្ទស បរមន្តិ វុច្ចតិ
ទ្វាទស ចាបិ ទេសនីយា
ចតុន្នំ ទេសនាយ ច ។

(៣៨២) កតង្គិកោ មុសាវាទោ
កតិ ឧបោសថង្គានិ
កតិ ទូតេយ្យង្គានិ
កតិ តិត្ថិយវត្តនា ។
អដ្ឋង្គិកោ មុសាវាទោ
អដ្ឋ ឧបោសថង្គានិ
អដ្ឋ ទូតេយ្យង្គានិ
អដ្ឋ តិត្ថិយវត្តនា ។

ទុតិយគាថាសង្គណិកៈ បុច្ឆាវិស្សជ្ជនាអំពីមុសាវាទជាដើម

(៣៩១) មុសាវាទដល់នូវស្ថានប៉ុន្មាន ព្រះមានព្រះភាគទ្រង់ត្រាស់ថា អាបត្តិប៉ុន្មានដែលមានកំណត់ថ្ងៃ អាបត្តិបាដិទេស-នីយៈមានប៉ុន្មាន មួយទៀត បុគ្គលប៉ុន្មានពួកដែលគួរសំដែងទោស ។ មុសាវាទដល់នូវស្ថាន ៩ យ៉ាង ព្រះមានព្រះភាគទ្រង់ត្រាស់ថា អាបត្តិដែលមានកំណត់ថ្ងៃ (នោះ) មាន ១៤ អាបត្តិបាដិទេសនីយៈ មាន ១២ (ដោយរួមទាំងភិក្ខុ ភិក្ខុនី) បុគ្គល ៤ ពួកដែលគួរសំដែងទោស ។

(៣៩២) មុសាវាទប្រកបដោយអង្គប៉ុន្មាន ឧបោសថមានអង្គប៉ុន្មាន អង្គរបស់ភិក្ខុដែលគួរដល់នូវទូតកម្មមានប៉ុន្មាន ការប្រព្រឹត្តតិត្ថិយវត្តមានប៉ុន្មាន ។ មុសាវាទប្រកបដោយអង្គ ៨ ឧបោសថប្រកបដោយអង្គ ៨ អង្គរបស់ភិក្ខុដែលគួរដល់នូវទូតកម្មមាន ៨ ការប្រព្រឹត្តតិត្ថិយវត្តមាន ៨ ប្រការ ។

(៣៨៣) កតិវាចិកា ឧបសម្បទា
កតីនំ បច្ចុដ្ឋាតព្វំ
កតីនំ អាសនំ ទាតព្វំ
ភិក្ខុនោវាទកោ កតីហិ ៗ
អដ្ឋវាចិកា ឧបសម្បទា
អដ្ឋន្នំ បច្ចុដ្ឋាតព្វំ
អដ្ឋន្នំ អាសនំ ទាតព្វំ
ភិក្ខុនោវាទកោ អដ្ឋហិ ៗ

(៣៨៤) កតីនំ ឆេជ្ជ ហោតិ
កតីនំ ថុល្លច្ចយំ
កតីនញ្ចេវ អនាបត្តិ
សព្វេសំ ឯកវត្ថុកា ៗ
ឯកស្ស ឆេជ្ជំ ហោតិ
ចតុន្នំ ថុល្លច្ចយំ
ចតុន្នញ្ចេវ អនាបត្តិ
សព្វេសំ ឯកវត្ថុកា ៗ

(៣៩៣) ឧបសម្បទា (របស់ភិក្ខុនី) ប្រកបដោយកម្មវាចាប៉ុន្មាន ភិក្ខុនីត្រូវក្រោកទទួលចំពោះភិក្ខុនីប៉ុន្មានពួក ត្រូវឲ្យអាសនៈដល់ភិក្ខុនីប៉ុន្មានពួក ភិក្ខុប្រកបដោយអង្គប៉ុន្មាន ទើបគួរប្រដៅភិក្ខុនីបាន ។ ឧបសម្បទា (របស់ភិក្ខុនី) ប្រកបដោយកម្មវាចា ៨ ភិក្ខុនីត្រូវក្រោកទទួលចំពោះភិក្ខុនី ៨ ពួក ត្រូវឲ្យអាសនៈដល់ភិក្ខុនី ៨ ពួក ភិក្ខុប្រកបដោយអង្គ ៨ ទើបគួរប្រដៅភិក្ខុនីបាន ។

(៣៩៤) ឆេជ្ជវត្ថុ (វត្ថុជាហេតុឲ្យដាច់ចាកភិក្ខុភាវៈ) មានដល់បុគ្គលប៉ុន្មានពួក អាបត្តិថុល្លច្ច័យមានដល់បុគ្គលប៉ុន្មានពួក អនាបត្តិមានដល់បុគ្គលប៉ុន្មានពួក អាបត្តិនិងអនាបត្តិទាំងអស់ (នេះ) មានវត្ថុតែមួយទេឬ ។ ឆេជ្ជវត្ថុមានដល់បុគ្គល ១ ពួក អាបត្តិថុល្លច្ច័យមានដល់បុគ្គល ៤ ពួក អនាបត្តិមានដល់បុគ្គល ៤ ពួក អាបត្តិនិងអនាបត្តិទាំងអស់ (នេះ) មានវត្ថុតែ ១ ។

ទុតិយគាថាសង្គណិកំ អាឃាតវត្ថុអាទិបុច្ឆាវិស្សជ្ជនា

(៣៥៥) កតិ អាឃាតវត្ថូនិ
កតីហិ សង្ឃោ ភិជ្ជតិ
កតេត្ថ បឋមាបត្តិកា
ញត្តិយោ ករណា កតិ ។
ទស អាឃាតវត្ថូនិ
ទសហិ សង្ឃោ ភិជ្ជតិ
ទសេត្ថ បឋមាបត្តិកា
ញត្តិយោ ករណា ទស ។

(៣៥៦) កតិ បុគ្គលោ នាភិវាទេតព្វា
អញ្ជលិសាមិចេន ច
កតីនំ ទុក្កដំ ហោតិ
កតិ ចីវរធារណា ។
ទស បុគ្គលា នាភិវាទេតព្វា
អញ្ជលិសាមិចេន ច
ទសន្នំ ទុក្កដំ ហោតិ
ទស ចីវរធារណា ។

(៣៩៥) អាឃាតវត្ថុ (វត្ថុជាហេតុឲ្យកើតចិត្តគុំគួន) មានប៉ុន្មាន សង្ឃប្រែកគ្នាដោយភិក្ខុប៉ុន្មានរូប ក្នុងវិន័យនេះ បឋមាបត្តិកាបត្តិមានប៉ុន្មាន កិច្ចដែលធ្វើដោយញត្តិមានប៉ុន្មាន ។

អាឃាតវត្ថុមាន ៩ យ៉ាង សង្ឃប្រែកគ្នាដោយភិក្ខុ ៩ រូប ក្នុងវិន័យនេះ បឋមាបត្តិកាបត្តិមាន ៩ យ៉ាង កិច្ចដែលធ្វើដោយញត្តិមាន ៩ យ៉ាង ។

(៣៩៦) បុគ្គលដែលមិនគួរអភិវាទ និងបុគ្គលដែលមិនគួរធ្វើអញ្ជលីកម្មនិងសាមីចិកម្មមានប៉ុន្មានពួក អាបត្តិទុក្កដមានដល់បុគ្គលប៉ុន្មានពួក ការទុកអតិរេកចីវរបានប៉ុន្មានថ្ងៃ ។

បុគ្គលដែលមិនគួរអភិវាទ និងបុគ្គលដែលមិនគួរធ្វើអញ្ជលីកម្ម និងសាមីចិកម្មមាន ១០ ពួក អាបត្តិទុក្កដមានដល់បុគ្គល ១០ ពួក ការទុកអតិរេកចីវរបានត្រឹម ១០ ថ្ងៃ ។

(១៥៧) កតីនំ វស្សំ វុត្តានំ

នានត្តំ ឥធ ចីវរំ

កតីនំ សង្ឃេ នានត្តំ

កតីនញ្ចេវ ន នានត្តំ ។

បញ្ចន្នំ វស្សំ វុត្តានំ

នានត្តំ ឥធ ចីវរំ

សត្តន្នំ សង្ឃេ នានត្តំ

សោឡសន្នំ ន នានត្តំ ។

(១៥៨) កតិសតំ រត្តិសតំ

អាបត្តី ឆាទយិត្វាន

កតិ រត្តិយោ វសិត្វាន

មុច្ចេយ្យ បារិវាសិកោ ។

ទសសតំ រត្តិសតំ

អាបត្តី ឆាទយិត្វាន

ទស រត្តិយោ វសិត្វាន

មុច្ចេយ្យ បារិវាសិកោ ។

(៣៨៧) ក្នុងសាសនានេះ បុគ្គលត្រូវឲ្យចីវរដល់បុគ្គលប៉ុន្មានពួកដែលនៅចាំវស្សារួចហើយ កាលបើមានអ្នកទទួលដ៏សមគួរ ហើយបុគ្គលត្រូវឲ្យចីវរដល់បុគ្គលប៉ុន្មានពួក មិនត្រូវឲ្យដល់បុគ្គលប៉ុន្មានពួក ។ ក្នុងសាសនានេះ បុគ្គលត្រូវឲ្យចីវរដល់បុគ្គល ៨ ពួក[១] ដែលនៅចាំវស្សារួចហើយ កាលបើមានបុគ្គលអ្នកទទួលដ៏សមគួរ បុគ្គលត្រូវឲ្យចីវរដល់បុគ្គល ៧ ពួក មិនត្រូវឲ្យដល់បុគ្គល ១៦ ពួកទេ ។

(៣៨៨) ភិក្ខុបិទបាំងអាបត្តិអស់មួយរយរាត្រី ត្រូវជាប៉ុន្មានរយអាបត្តិ ហើយចូលបរិវាសនៅប៉ុន្មានរាត្រី ទើបរួច (ចាកអាបត្តិ) បាន ។ ភិក្ខុបិទបាំងអាបត្តិអស់មួយរយរាត្រី ត្រូវជាមួយពាន់[២] អាបត្តិ ហើយចូលបរិវាសនៅ ១០ រាត្រី ទើបរួច (ចាកអាបត្តិនោះ) បាន ។

---

១ អដ្ឋកថា ថា សហធម្មិកទាំង ៨ ។ ២ រាត្រីទី ១ ភិក្ខុត្រូវអាបត្តិមួយរយ ហើយក៏បិទបាំងទុកអស់ ១០ រាត្រី លុះដល់ថ្ងៃទី១១ ទើបត្រូវអាបត្តិមួយរយ ១ លើកទៀត ហើយក៏បិទបាំងទុកអស់១០រាត្រី ទើបត្រូវអាបត្តិមួយរយ១លើកទៀត ត្រូវនឹងបិទបាំងយ៉ាងនេះដរាបដល់ ១០ លើករួមរាត្រីទាំងអស់ មួយរយរាត្រី រួមអាបត្តិជា ១ ពាន់ ។

ទុតិយគាថាសង្គណិកំ កម្មទោសាទិបុច្ឆាវិស្សជ្ជនា

(៣៥៩) កតិ កម្មទោសា វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

ចម្បាយំ វិនយវត្ថុស្មឹ

សព្វេ(១) អធម្មិកា កតិ ។

ទ្វាទស កម្មទោសា វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

ចម្បាយំ វិនយវត្ថុស្មឹ

សព្វេ(២) អធម្មិកា កតា ។

(៣៦០) កតិ កម្មសម្បត្តិយោ វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

ចម្បាយំ វិនយវត្ថុស្មឹ

សព្វេវ ធម្មិកា កតិ ។

ចតស្សោ កម្មសម្បត្តិយោ វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

ចម្បាយំ វិនយវត្ថុស្មឹ

សព្វេវ ធម្មិកា កតា ។

១-២ ឱ. ម. សព្វេវ ។

(៣៥៩) ទោសរបស់កម្មមានប៉ុន្មាន ដែលព្រះពុទ្ធជាអាទិច្ច–
វង្ស ទ្រង់ត្រាស់ក្នុងវិនយវត្ថុ ក្នុងនគរចម្បា កម្មទាំងអស់
(នោះ) ឈ្មោះថាមិនប្រកបដោយធម៌ឬអ្វី ។ ទោសរបស់កម្ម
(មានអបលោកនកម្មជាដើម) មាន ១៦ ដែលព្រះពុទ្ធជាអា–
ទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិនយវត្ថុ ក្នុងនគរចម្បា កម្មទាំងអស់
(នោះ) ឈ្មោះថា មិនប្រកបដោយធម៌មែនហើយ ។

(៣៦) សម្បត្តិរបស់កម្ម មានប៉ុន្មាន ដែលព្រះពុទ្ធជាអា–
ទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិនយវត្ថុ ក្នុងនគរចម្បា កម្មទាំងអស់
(នោះ) ឈ្មោះថា ប្រកបដោយធម៌ឬអ្វី ។ សម្បត្តិរបស់កម្ម
មាន ៤ ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិនយវត្ថុ
ក្នុងនគរចម្បា កម្មទាំងអស់ (នោះ) ឈ្មោះថា ប្រកបដោយ
ធម៌មែនហើយ ។

(៣៦១) កតិ កម្មានិ វុត្តានិ
ពុទ្ធេនាទិច្ចពន្ធុនា
ចម្បាយំ វិនយវត្ថុស្មឹ
ធម្មិកា អធម្មិកា កតិ ។
ឆ កម្មានិ វុត្តានិ
ពុទ្ធេនាទិច្ចពន្ធុនា
ចម្បាយំ វិនយវត្ថុស្មឹ
ឯកេត្ថ ធម្មិកា វុត្តា
បញ្ច អធម្មិកា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា ។

(៣៦២) កតិ កម្មានិ វុត្តានិ
ពុទ្ធេនាទិច្ចពន្ធុនា
ចម្បាយំ វិនយវត្ថុស្មឹ
ធម្មិកា អធម្មិកា កតិ ។
ចត្តារិ កម្មានិ វុត្តានិ
ពុទ្ធេនាទិច្ចពន្ធុនា
ចម្បាយំ វិនយវត្ថុស្មឹ

(៣៦១) កម្មមានប៉ុន្មាន ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិនយវត្ថុ ក្នុងនគរចម្បា (កម្មនោះ) ប្រកបដោយធម៌មានប៉ុន្មាន មិនប្រកបដោយធម៌មានប៉ុន្មាន ។ កម្មមាន ៦ ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិនយវត្ថុ ក្នុងនគរចម្បា បណ្ដាកម្មទាំង៦នេះ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ប្រកបដោយធម៌មានតែ ១ ពួក មិនប្រកបដោយធម៌មាន ៥ ។

(៣៦២) កម្មមានប៉ុន្មាន ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិនយវត្ថុ ក្នុងនគរចម្បា (កម្មនោះ) ប្រកបដោយធម៌មានប៉ុន្មានមិនប្រកបដោយធម៌មានប៉ុន្មាន ។ កម្ម ៤ ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិនយវត្ថុ ក្នុងនគរចម្បា

ឯកេត្ថ ធម្មិកា កតា
ទ្វយោ អធម្មិកា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា ។

(៣៦៣) យំ ទេសិតំ[១] អនន្តជិនេន តាទិនា–
អាបត្តិក្ខន្ធានិ វិវេកទស្សិនា
កតេត្ថ សម្មតិ វិនា សមថេហិ
បុច្ឆាមិ តំ ព្រូហិ វិភង្គកោវិទ ។
យំ ទេសិតំ[២] អនន្តជិនេន តាទិនា
អាបត្តិក្ខន្ធានិ វិវេកទស្សិនា
ឯកេត្ថ សម្មតិ វិនា សមថេហិ
ឯតន្តេ អក្ខាមិ វិភង្គកោវិទ ។

(៣៦៤) កតិ អាបាយិកា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោម តេ

១–២ ឱ. ម. ទេសិតា ។

បណ្ដាកម្មទាំង ៤ នេះ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ប្រកបដោយធម៌មានតែ ១ ពួក មិនប្រកបដោយធម៌មាន ៣ ។

(៣៦៣) ព្រះមានព្រះភាគទ្រង់បាននូវព្រះនិព្វាន ប្រកបដោយតាទិគុណ ទ្រង់ឃើញនូវវិវេកធម៌ បានសំដែងនូវកងនៃអាបត្តិ ទាំងឡាយណា បណ្ដាកងនៃអាបត្តិទាំងនុ៎ះ កងនៃអាបត្តិប៉ុន្មាន ដែលមិនរម្ងាប់ដោយសមថៈទាំងឡាយ បពិត្រលោកអ្នកឈ្លាសវៃក្នុងវិគ្គ ខ្ញុំសូមសួរនូវកងនៃអាបត្តិនោះ សូមលោកឆ្លើយមក ។ ព្រះមានព្រះភាគទ្រង់បាននូវព្រះនិព្វាន ប្រកបដោយតាទិគុណ ទ្រង់ឃើញនូវវិវេតធម៌ បានសំដែងនូវកងនៃអាបត្តិណា បណ្ដាកងនៃអាបត្តិទាំងនុ៎ះ មានតែកងអាបត្តិ ១ គឺបារាជិក ដែលមិនរម្ងាប់ដោយសមថៈទាំងឡាយទេ បពិត្រលោកអ្នកឈ្លាសវៃក្នុងវិគ្គ ខ្ញុំប្រាប់នូវកងនៃអាបត្តិនុ៎ះចំពោះលោក ។

(៣៦៤) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បុគ្គលប៉ុន្មានពួក ដែលទៅកើតក្នុងអបាយ ខ្ញុំនឹងតាំងស្ដាប់ នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។

វិនយបិដកេ បរិវារេ

ឆឡេនិយ្យសតា វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

អាបាយិកា នេរយិកា

កប្បដ្ឋា សង្ឃភេទកា

វិនយំ បដិជានន្តស្ស

វិសយានិ សុណោហិ មេ ។

(៣៦៨) កតិ អាបាយិកា វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

វិនយំ បដិជានន្តស្ស

វិសយានិ សុណោម តេ ។

អដ្ឋារស អាបាយិកា វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

វិនយំ បដិជានន្តស្ស

វិសយានិ សុណោហិ មេ ។

ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បុគ្គល ១៤៤ ពួក[១] ដែលបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប ចូរលោកស្ដាប់វិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

(៣៦៤) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បុគ្គលប៉ុន្មានពួក ដែលមិនកើតក្នុងអបាយ ខ្ញុំនឹងចាំស្ដាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បុគ្គល ១៨ ពួកដែលមិនទៅកើតក្នុងអបាយ ចូរអ្នកស្ដាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

---

១ អដ្ឋកថា ថា បុគ្គល ១៤៤ ពួកនោះ គឺយកបុគ្គល ៨ ពួកទៅគុណនឹងភេទករវត្ថុ ១៨ យ៉ាង ត្រូវជា ១៤៤ ពួក ។ ទី ១ គឺភិក្ខុសំដែងនូវអធម៌ថាជាធម៌មាន ៨ យ៉ាងទៀត គឺបុគ្គលយល់ឃើញក្នុងអធម៌នោះថាជាអធម៌មែន យល់ឃើញក្នុងការបំបែកថាជាអធម៌ដែរ ១ យល់ឃើញក្នុងអធម៌នោះថាជាអធម៌មែន តែយល់ឃើញ ក្នុងការបំបែកថាជាធម៌ទៅវិញ ១ យល់ឃើញក្នុងអធម៌នោះថាជាអធម៌មែន តែសង្ស័យក្នុងការបំបែក ១ យល់ឃើញក្នុងអធម៌នោះថាជាធម៌ទៅវិញ តែយល់ឃើញក្នុងការបំបែកថាជាអធម៌ ១ យល់ឃើញក្នុងអធម៌នោះថាជាធម៌ទៅវិញ តែសង្ស័យក្នុងការបំបែក ១ សង្ស័យក្នុងអធម៌នោះ យល់ឃើញក្នុងការបំបែកថាជាអធម៌មែន ១ សង្ស័យក្នុងអធម៌នោះ យល់ឃើញក្នុងការបំបែកថាជាធម៌ទៅវិញ ១ សង្ស័យក្នុងអធម៌នោះ នឹងសង្ស័យក្នុងការបំបែក ១ ។ នេះជាបុគ្គលពួកទី ១ ឯបុគ្គលពួកទី២រហូតដល់១៤៤នោះ ក៏មានសេចក្ដីប្រហែលៗគ្នាដែរ (សេចក្ដីពិស្ដារមានក្នុងសង្ឃភេទក្ខន្ធកៈ) ។

ទុតិយគាថាសង្គណិកំ អដ្ឋកាទិបុច្ឆាវិស្សជ្ជនា

(៣៦៦) កតិ អដ្ឋកា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោម តេ ។
អដ្ឋារសដ្ឋកា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោហិ មេ ។

(៣៦៧) កតិ កម្មានិ វុត្តានិ
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោម តេ ។
សោឡស កម្មានិ វុត្តានិ
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោហិ មេ ។

[៣៦៦] ធម៌ទាំង ៨ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់សំដែងប៉ុន្មានលើក ខ្ញុំនឹងចាំស្ដាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ធម៌ទាំង ៨ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់សំដែងមាន ១៨ លើក ចូរអ្នកស្ដាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

[៣៦៧] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្ដាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមាន ១៦ យ៉ាង ចូរអ្នកស្ដាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

(៣៦៨) កតិ កម្មទោសា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោម តេ ។
ទ្វាទស កម្មទោសា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោហិ មេ ។

(៣៦៩) កតិ កម្មសម្បត្តិយោ វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោម តេ ។
ចតស្សោ កម្មសម្បត្តិយោ វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោហិ មេ ។

(៣៦៨) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ទោសរបស់កម្មមានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ទោសរបស់កម្មមាន ១៤ យ៉ាង ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

(៣៦៩) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សម្បត្តិរបស់កម្មមានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សម្បត្តិរបស់កម្មមាន ៤ យ៉ាង ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

(៣៧០) កតិ កម្មានិ វុត្តានិ
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោម តេ ។
ឆ កម្មានិ វុត្តានិ
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោហិ មេ ។

(៣៧១) កតិ កម្មានិ វុត្តានិ
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោម តេ ។
ចត្តារិ កម្មានិ វុត្តានិ
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោហិ មេ ។

ទុតិយគាថាសង្គណិកៈ បុច្ឆាវិស្សជ្ជនាអំពីកម្ម

[៣៧០] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមានប៉ុន្មានយ៉ាង ខ្ញុំទើងតាំងស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមាន ៦ យ៉ាង ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

[៣៧១] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមានប៉ុន្មានយ៉ាង ខ្ញុំទើងតាំងស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមាន ៤ យ៉ាង ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

(១៧២) កតិ ឆាកដិកា វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

វិនយំ បដិជានន្តស្ស

វិសយានិ សុណោម តេ ។

អដ្ឋ ឆាកដិកា វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

វិនយំ បដិជានន្តស្ស

វិសយានិ សុណោហិ មេ ។

(១៧៣) កតិ សង្ឃាទិសេសា វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

វិនយំ បដិជានន្តស្ស

វិសយានិ សុណោម តេ ។

តេរស សង្ឃាទិសេសា វុត្តា

ពុទ្ធេនាទិច្ចពន្ធុនា

វិនយំ បដិជានន្តស្ស

វិសយានិ សុណោហិ មេ ។

[៣៧២] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បាចិត្តិយាបត្តិ មានប៉ុន្មាន ខ្ញុំនឹងចាំស្ដាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បាចិត្តិយាបត្តិមាន ៨ ចូរអ្នកស្ដាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

[៣៧៣] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សង្ឃាទិសេសាបត្តិ មានប៉ុន្មាន ខ្ញុំនឹងចាំស្ដាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សង្ឃាទិសេសាបត្តិ មាន ២៣ ចូរអ្នកស្ដាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

ទុតិយគាថាសង្គណិកំ អនិយតាទិបុច្ឆាវិស្សជ្ជនា

(៣៧៤) កតិ អនិយតា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិនយានិ សុណោម តេ ។
ទ្វេ អនិយតា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិនយានិ សុណោហិ មេ ។

(៣៧៥) កតិ និស្សគ្គិយា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិនយានិ សុណោម តេ ។
ទ្វេចត្តាឡីស និស្សគ្គិយា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិនយានិ សុណោហិ មេ ។

ទុតិយគាថាសង្គណិកៈ បុច្ឆាវិស្សជ្ជនាអំពីអនិយតៈជាដើម

(៣៧៨) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា អនិយតៈមានប៉ុន្មាន ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា អនិយតៈមាន ២ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

(៣៧៩) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា និស្សគ្គិយៈមានប៉ុន្មាន ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា និស្សគ្គិយៈមាន ៤២ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

វិនយបិដកេ បរិវារេ

(១៧៦) កតិ អាបត្តិយោ វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោម តេ ។
អដ្ឋាសីតិសតំ អាបត្តិយោ វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោហិ មេ ។

(១៧៧) កតិ បាដិទេសនីយា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោម តេ ។
ទ្វាទស បាដិទេសនីយា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិសយានិ សុណោហិ មេ ។

(៣៧៦) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បាចិត្តិយាបត្តិ មានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បាចិត្តិយាបត្តិមាន ១៨៨ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

(៣៧៧) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បាដិទេសនីយាបត្តិមានប៉ុន្មាន ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បាដិទេសនីយាបត្តិមាន ១២ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។

ទុតិយគាថាសង្គណិកំ សេក្ខិយបុច្ឆាវិស្សជ្ជនា

(៣៧៨) កតិ សេក្ខិយា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិនយានិ សុណោម តេ ។
បញ្ចសត្តតិ សេក្ខិយា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
វិនយំ បដិជានន្តស្ស
វិនយានិ សុណោហិ មេ ។
យាវ សុបុច្ឆិតំ តយា
តាវ សុវិស្សជ្ជិតំ មយា
បុច្ឆាវិស្សជ្ជនាយ វា
នត្ថិ កិញ្ចិ អសុត្តកន្តិ ។

ទុតិយគាថាសង្គណិកំ និដ្ឋិតំ ។

ទុតិយគាថាសង្គណិកៈ បញ្ហាវិស្សជ្ជនាអំពីសេក្ខិយៈ

(៣៧៨) ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សេក្ខិយៈ មានប៉ុន្មាន ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នកដែលជាអ្នកជ្រាបច្បាស់នូវវិន័យ ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សេក្ខិយៈមាន ៧៥ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ ។ ពាក្យដែលអ្នកសួរមកដោយប្រពៃត្រឹមណា ខ្ញុំក៏បានវិស្សជ្ជនាដោយប្រពៃត្រឹមនោះហើយ ពាក្យបន្តិចបន្តួចដែលមិនមែនជាខ្សែបន្ទាត់ មិនមានក្នុងពាក្យបុច្ឆាវិស្សជ្ជនានេះឡើយ ។

ចប់ ទុតិយគាថាសង្គណិកៈ ។

សេទមោចកគាថា

[៣៧៩] អសំវាសោ ភិក្ខូហិ(១) ភិក្ខុនីហិ ច
សម្ភោគោ ឯកច្ចោ តហឹ ន លព្ភតិ
អវិប្បវាសេន អនាបត្តិ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

[៣៨០] អវិស្សជ្ជិតំ(២) អវេភង្គិយំ បញ្ចវុត្តា មហេសិនា
វិស្សជ្ជន្តស្ស បរិភុញ្ជន្តស្ស អនាបត្តិ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

[៣៨១] ទស បុគ្គលេ ន វទាមិ ឯកាទស វិវជ្ជិយ
វុឌ្ឍំ វន្ទន្តស្ស អាបត្តិ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

---

១ ឱ. ម. ភិក្ខូហិ ច ។ ២ ឱ. អវិស្សជ្ជិយំ ។ ម. អវិស្សជ្ជិកំ អវេភង្គិកំ ។

សេទមោចនគាថា

(៣៧៩) ពួកភិក្ខុក្តី ពួកភិក្ខុនីក្តី មិនមានសំវាស(១) សម្ភោគ ពួកមួយ គឺពួកភិក្ខុ ឬពួកភិក្ខុនី មិនបានក្នុងបុគ្គលនោះទេ(២) ការនៅរួមមិនត្រូវអាបត្តិ(៣) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៨០) ព្រះមានព្រភាគជាមហាឥសី (ទ្រង់ស្វែងរកនូវប្រយោជន៍ដ៏ប្រសើរ) ទ្រង់ត្រាស់ថា របស់ ៥ យ៉ាង មិនត្រូវលះ មិនត្រូវចែក តែកាលបើភិក្ខុលះនឹងប្រើប្រាស់មិនត្រូវអាបត្តិ(៤) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៨១) យើងមិនបានពោលចំពោះអវន្ទិយបុគ្គលទាំង ១០ ពួកទេ ទាំងអភព្វបុគ្គល ១១ មានបណ្ឌកជាដើម ក៏លើកលែងដែរ តែភិក្ខុសំពះភិក្ខុបាស(៥) ត្រូវអាបត្តិ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ ពួកភិក្ខុក្តី ភិក្ខុនីក្តីដែលត្រូវបារាជិក ឬមិនមែនជាបកតត្ត ឈ្មោះថាមិនមានសំវាសគឺធ្វើឧបោសថជាដើមជាមួយនឹងសង្ឃមិនបានទេ ។ ២ ការបម្រើមានផ្តល់ទឹកជាដើមពួកមាតុគ្រាមធ្វើដល់ភិក្ខុមិនបាន លើកតែមាតាបង្កើត ឯភិក្ខុនីក៏ដូចគ្នាដែរ ។ ៣ សេចក្តីនេះចំពោះភិក្ខុនីដែលនៅជាមួយនឹងកូនប្រុសរបស់ខ្លួន ក្នុងទីប្រក់ទីបាំងជាមួយគ្នាបាន ។ ៤ មានក្នុងគរុភណ្ឌវិនិច្ឆ័យក្នុងសេនាសនក្ខន្ធកៈចុល្លវគ្គ ។ ៥ គឺភិក្ខុថ្វាយបង្គំភិក្ខុអាក្រាត ។

សេទមោចនគាថា សិក្ខាយ អសាធារណាទិបញ្ហា

(៣៨២) ន ឧក្ខិត្តកោ ន ច បន ធារិវាសិកោ

ន សង្ឃភិន្ទោ ន ច បន បក្ខសង្កន្តោ

សមានវាសកភូមិយា ឋិតោ

កថំ នុ សិក្ខាយ អសាធារណោ សិយា

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៣៨៣) ឧបេតិ ធម្មំ បរិបុច្ឆមានោ

កុសលំ អត្ថុបសញ្ហិតំ

ន ជីវតិ ន មតោ ន និព្វុតោ ។

តំ បុគ្គលំ កតមំ វទន្តិ ពុទ្ធា

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៣៨៤) ឧព្ភក្ខកេ ន វទាមិ

អធោនាភី វិវជ្ជិយ

សេទមោចនគាថា ប្រស្នាសួរអំពីភិក្ខុមិនសាធារណៈដោយសិក្ខាជាដើម

(៣៨២) ភិក្ខុមិនមែនជាភិក្ខុដែលសង្ឃលើកវត្ត ទាំងមិនមែនជាភិក្ខុដែលនៅបរិវាស មិនមែនជាអ្នកទំលាយសង្ឃ ទាំងមិនមែនជាអ្នកចូលពួកតិរ្ថិយ (ភិក្ខុនោះ) ឋិតនៅក្នុងភូមិនៃសមានសំវាសកៈ (ភូមិរបស់ភិក្ខុមានសំវាសស្មើគ្នា) តែភិក្ខុនោះមិនសាធារណៈដោយសិក្ខា[1] ដូចម្តេច ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៨៣) មានបុគ្គលដែលចូលទៅសាកសួរធម៌ជាកុសលប្រកបដោយប្រយោជន៍ បុគ្គលនោះទឹងថារស់នៅក៏មិនមែន ទឹងថាស្លាប់ក៏មិនមែន ទឹងថានិព្វានក៏មិនមែន ។ ព្រះពុទ្ធទាំងឡាយត្រាស់ហៅបុគ្គលនោះថា ដូចម្តេចទៅវិញ[2] ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៨៤) បើមិនបានពោលចំពោះអវយវៈតាំងពីដងកាបិតឡើងទៅទេ ទាំងអវយវៈតាំងពីផ្ចិតចុះមកក្រោម ក៏លើកលែង

---

១ អដ្ឋកថា សំដៅយកភិក្ខុដែលធ្លាប់ធ្វើជាខ្មាន់ព្រះកេសជាដើម ឯភិក្ខុបែបនេះព្រះអង្គទ្រង់បញ្ញត្តមិនឲ្យរក្សាកាំបិតកោរទុកទេ ។ ២ បុគ្គលមានសភាពយាងនេះគឺសំដៅយកពុទ្ធនិមិត្ត ។

មេថុនធម្មប្បច្ចយា

កាជំ ឆាភជិតោ សិយា

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៣៨៥) ភិក្ខុ សញ្ញាចិកាយ កុដឹ ការេតិ

អទេសិតវត្ថុកំ បមាណាតិក្កន្តំ

សារម្ភំ អបរិក្កមនំ អនាបត្តិ

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៣៨៦) ភិក្ខុ សញ្ញាចិកាយ កុដឹ ការេតិ

ទេសិតវត្ថុកំ បមាណិកំ

អនារម្ភំ សបរិក្កមនំ អាបត្តិ

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

ដែរ តែហេតុដូចម្តេចបានជាភិក្ខុត្រូវអាបត្តិបារាជិក ព្រោះមេថុនធម្ម[១]ជាបច្ច័យ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃបានគិតមកហើយ ។

(៣៨៥) ភិក្ខុធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេមកដោយខ្លួនឯង ឥតមានពួកភិក្ខុសំដែងទីឲ្យ ធ្វើឲ្យកន្លងហួសប្រមាណ មានហេតុចាស់ មិនមានទីឧបចារៈ តែភិក្ខុនោះមិនត្រូវអាបត្តិ[២] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៨៦) ភិក្ខុធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេមកដោយខ្លួនឯង ដែលមានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ មិនមានហេតុចាស់ មានទីឧបចារៈ តែភិក្ខុនោះត្រូវអាបត្តិ[៣] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ អដ្ឋិកឋា ឋា សាកសពដែលគ្មានក្បាល មានតែភ្នែកនឹងមាត់ជុះត្រង់ទ្រូង ហើយភិក្ខុទៅសេពមេថុនធម្មនឹងទ្វារមាត់ត្រូវបារាជិក ។ ២ ព្រោះកុដិនោះភិក្ខុធ្វើប្រកដោយស្មៅ បានជាមិនត្រូវអាបត្តិ ។ ៣ សំដៅយកកុដិដែលភិក្ខុធ្វើដោយដីសុទ្ធ (កុដិការសិក្ខាបទទី ៦) ។

សេទមោចនគាថា គរុកាបត្តាទិបញ្ហា

(៣៨៧) ន កាយិកំ កិញ្ចិ បយោគមាចរេ
ន ចាបិ វាចាយ បរេ ភណេយ្យ
អាបជ្ជេយ្យ គរុកំ ឆេជ្ជវត្ថុំ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៣៨៨) ន កាយិកំ វាចសិកញ្ច កិញ្ចិ
មនសាបិ សន្តោ ន ករេយ្យ បាបំ
សោ នាសិតោ កិន្តិ សុនាសិតោ ភវេ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៣៨៩) អនាលបន្តោ មនុជេន កេនចិ
វាចាគិរំ នោ ច បរេ ភណេយ្យ
អាបជ្ជេយ្យ វាចសិកំ ន កាយិកំ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

សេខមោចនគាថា ប្រស្នាសួរអំពីការត្រូវគរុកាបត្តិជាដើម

(៣៨៧) ឧបសម្បន្ន មិនបានប្រព្រឹត្តប្រយោគអ្វីមួយ ប្រកបដោយកាយ ទាំងមិនបានពោលនឹងអ្នកដទៃ ដោយវាចា តែឧបសម្បន្ននោះត្រូវគរុកាបត្តិ ជាវត្ថុដាច់ចាកភិក្ខុភាវៈ(១) ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៨៨) បុគ្គលមានចិត្តស្ងប់រម្ងាប់ មិនបានធ្វើបាបបន្តិចបន្តួចដោយកាយក្តី វាចាក្តី ចិត្តក្តី បុគ្គលនោះ សង្ឃត្រូវឲ្យវិនាសចេញ ចុះធ្វើដូចម្តេច ទើបឈ្មោះថា ឲ្យវិនាសចេញដោយស្រួល(២) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៨៩) ភិក្ខុកាលមិនចរចានឹងមនុស្សណាមួយ មួយទៀត កាលនឹងបញ្ចេញវាចា ក៏មិនបានពោលចំពោះអ្នកដទៃឡើយ តែភិក្ខុ (នោះ) ត្រឡប់ត្រូវអាបត្តិប្រកបដោយវាចា(៣) មិនត្រូវអាបត្តិប្រកបដោយកាយ ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ អដ្ឋកថា សំដៅយកភិក្ខុនីដែលជួយបិទបាំងទោសភិក្ខុនីផងគ្នា ។ ២ គឺបុគ្គលដែលជាអភព្វបុគ្គល ១១ ពួកកូលមកបួស ទោះបីឥតប្រព្រឹត្តអាក្រក់សោះក៏ត្រូវតែឲ្យវិនាសគឺបណ្តេញចេញ ។ ៣ គឺភិក្ខុដែលអង្គុយស្តាប់ព្រះបាតិមោក្ខ កាលបើគេសួរចំពោះអាបត្តិមានពាក្យថា បើលោកមានអាបត្តិ ចូរប្រាប់ដោយច្បាស់លាស់មក ឯភិក្ខុនោះទុកជាមានអាបត្តិ កុំនៅតែស្ងៀមយ៉ាងនោះ ត្រូវសម្បជានមុសាវាទ ព្រោះស្ងៀម ។

(៣៩០) សិក្ខាបទា ពុទ្ធវរេន វណ្ណិតា

សង្ឃាទិសេសា ចតុរោ ភវេយ្យុំ

អាបជ្ជេយ្យ ឯកបយោគេន សព្វេ

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៣៩១) ឧភោ ឯកតោ ឧបសម្បន្នា

ឧភិន្នំ ហត្ថតោ ចីវរំ បដិគ្គណ្ហេយ្យ

សិយា អាបត្តិយោ នានា

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

[៣៩០] សិក្ខាបទទាំងឡាយដែលព្រះពុទ្ធដ៏ប្រសើរ ទ្រង់ពណ៌នាទុកថា សង្ឃាទិសេស ៤ សិក្ខាបទ ភិក្ខុនីត្រូវអាបត្តិទាំងអស់នោះ ដោយប្រយោគតែមួយ [១] ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

[៣៩១] ភិក្ខុនីពីររូបបានឧបសម្បទាក្នុងទីជាមួយគ្នា ភិក្ខុទទួលចីវរអំពីដៃនៃភិក្ខុនីទាំងពីររូប ត្រូវអាបត្តិផ្សេងៗ គ្នា [២] ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ អដ្ឋកថា ថា ភិក្ខុនីមួយរូបចេញពីស្រុករបស់ខ្លួនក្នុងបច្ចូសសម័យ គ្រាន់តែដល់ទៅត្រើយស្ទឹង អរុណក៏រះឡើង ភិក្ខុនីនោះត្រូវអាបត្តិ ៤ គឺ ១ ត្រូវព្រោះនៅប្រាសចាកភត្រី ២ ត្រូវព្រោះទៅកាន់ចន្លោះស្រុក ៣ ត្រូវព្រោះឆ្លងស្ទឹង ៤ ត្រូវព្រោះនៅប្រាសចាកគណៈ ទាំង ៤ នេះត្រូវដោយប្រយោគតែ ១ ។ ២ ភិក្ខុទទួលចីវរអំពីដៃភិក្ខុនីដែលបានឧសម្បទាតែខាងសំណាក់ភិក្ខុនីត្រូវបាចិត្តិយៈ ទទួលចីវរអំពីដៃភិក្ខុនីដែលបានឧបសម្បទាតែខាងសំណាក់ភិក្ខុនី ត្រូវទុក្កដ ។

សេទមោចនគាថា គរុភណ្ឌាវហារាទិបញ្ហា

(១៩២) ចតុរោ ជនា សំវិធាយ គរុភណ្ឌំ អវាហរុំ[១]
តយោ បារាជិកា ឯកោ ន បារាជិកោ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(១៩៣) ឥត្ថី ច អព្ភន្តរេ សិយា
ភិក្ខុ ច ពាហិរេ សិយា
ឆិទ្ទំ តស្មឹ ឃរេ នត្ថិ
មេថុនធម្មប្បច្ចយា
កថំ បារាជិកោ សិយា
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

---

១ ឱ. ម. អវាហរុំ ។

សេទមោចនគាថា ប្រស្នាសួរអំពីការលួចគរុភណ្ឌជាដើម

[៣៩២] ជន គឺភិក្ខុ ៤ រូប បបួលគ្នាលួចគរុភណ្ឌ ឯភិក្ខុ ៣ រូបត្រូវអាបត្តិបារាជិក ភិក្ខុ ១ រូបមិនត្រូវអាបត្តិបារាជិកទេ (១) ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

[៣៩៣] ស្រីនៅខាងក្នុង ភិក្ខុនៅខាងក្រៅ ក្នុងផ្ទះនោះឥតប្រហោងសោះ ដូចម្ដេចបានជាភិក្ខុត្រូវអាបត្តិបារាជិក (២) ព្រោះសេពមេថុនធម្មជាបច្ច័យ ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ ជន ៤ នាក់ គឺអាចារ្យ១ រូប កូនសិស្ស៣ រូបប្រាថ្នានឹងលួចយកគរុភណ្ឌចំនួន៦មាសក ចំណែកអាចារ្យបង្គាប់កូនសិស្សទាំង ៣ រូបថា អ្នកទាំងអស់គ្នាចូរយក ១ មាសក ៗ ម្នាក់ ៗ ចំណែកខាងខ្ញុំឯងយក ៣ មាសក ឯកូនសិស្សទី ១ និយាយថា លោកអាចារ្យចូរយក៣មាសកចុះ លោកឯណោះយក ១ មាសក លោកឯណោះទៀតយក ១ មាសក ឯខ្លួនខ្ញុំក៏យក១ មាសកដែរ កូនសិស្សទី ២ ទី ៣ ក៏និយាយដូចកូនសិស្សទី១ កូនសិស្សទាំង ៣ រូបត្រូវអាបត្តិបារាជិកទាំងអស់គ្នា លោកចារ្យត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ កូនសិស្សទាំង ៣ រូប បានជាត្រូវអាបត្តិបារាជិក ព្រោះបង្គាប់ឲ្យគេយកដល់ ៥ មាសក តែក្នុងអាណត្តិកបយោគ ១ ឯអាចារ្យដែលជាអ្នកបង្គាប់ឲ្យសិស្សយកមួយ ៗ មាសកម្នាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ ជាអាណត្តិកបយោគ ដែលយកចំពោះខ្លួន ៣ មាសកនោះ ក៏ត្រូវអាបត្តិថុល្លច្ច័យដែរ តែជាសាហត្ថិកបយោគ ។ ឯសាហត្ថិកបយោគនឹងអាណត្តិកបយោគនេះ រាប់បញ្ចូលគ្នាមិនបានទេ ដូចជាភិក្ខុលួចដោយសាហត្ថិកបយោគ ៣ មាសក លួចដោយអាណត្តិកបយោគ ៣ មាសក ត្រូវជា ៣ មាសកពីរដង ភិក្ខុនោះត្រូវទោសតែត្រឹមអាបត្តិថុល្លច្ច័យ ព្រោះក្នុងបយោគមួយ ៗ មិនគ្រប់ចំនួន ៥ មាសក ។ បើលួចដោយសាហត្ថិកៈ ១ មាសក លួចដោយអាណត្តិកៈ៥មាសក ទើបត្រូវអាបត្តិបារាជិក ព្រោះក្នុងអាណត្តិកបយោគ ១ នោះគ្រប់ចំនួន ៥ មាសក ។ ឯលួចដោយសាហត្ថិកបយោគ ១ មាសកនោះត្រូវតែត្រឹមអាបត្តិទុក្កដ ។ ២ បានជាត្រូវបារាជិក ព្រោះផ្ទះក្នុងទីនេះលោកសំដៅយកសំពត់ទេ ព្រោះថាភិក្ខុអាចប្រព្រឹត្តធ្វើមេថុនធម្មទាំងសំពត់បាន ។

[៣៩៤] តេលំ មធុ ផាណិតញ្ចាបិ សប្បឹ
សាមំ គហេត្វាន និក្ខិបេយ្យ
អវីតិវត្តេ សត្តាហេ
សតិ បច្ចយេ បរិភុញ្ជន្តស្ស អាបត្តិ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

[៣៩៥] និស្សគ្គិយេន អាបត្តិ
សុទ្ធកេន បាចិត្តិយំ
អាបជ្ជន្តស្ស(១) ឯកតោ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

[៣៩៦] ភិក្ខូ សិយា វីសតិយា សមាគតា
កម្មំ ករេយ្យុំ សមគ្គសញ្ញិនោ
ភិក្ខុ សិយា ទ្វាទសយោជនេ ឋិតោ
កម្មញ្ច តំ កុប្បេយ្យ វគ្គបច្ចយា
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

---

១ អាបជ្ជេយ្យាតិបិ កត្ថចិ បោត្ថកេ ទិស្សតិ ។

(៣៩៤) ឧបសម្បន្ន ទទួលប្រេង ទឹកឃ្មុំ ទឹកអំពៅ នឹងទឹកដោះពាវ ហើយទុកដាក់ដោយខ្លួនឯង ទុកជាមិនទាន់កន្លង ៧ ថ្ងៃនៅឡើយ កាលបើមានបច្ច័យហើយឆាន់ត្រូវអាបត្តិ(១) ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៩៥) ភិក្ខុត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ នឹងសុទ្ធកបា-ចិត្តិយៈក្នុងខណៈជាមួយគ្នា(២) ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៩៦) ភិក្ខុ ២០ រូបមកប្រជុំគ្នា មានសេចក្តីសំគាល់ថាព្រមព្រៀងគ្នាហើយធ្វើសង្ឃកម្មទៅ មានភិក្ខុ ១ រូបឋិតនៅក្នុងទីឆ្ងាយមានប្រមាណ ១២ យោជន៍ក៏មាន ចុះហេតុដូចម្តេចបានជាសង្ឃកម្មនោះកម្រើក(៣) ព្រោះបច្ច័យគឺកម្មនោះជាពួកប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ ភិក្ខុនីបើគ្មានជម្ងឺហើយសូមភេសជ្ជៈមានប្រេងជាដើមយកមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ បើសូមបានមកមិនទាន់បានឆាន់នៅឡើយហើយភេទក៏ក្លាយជាភិក្ខុទៅ ឯភេសជ្ជៈនោះទុកជាមិនទាន់កន្លងហួស ៧ ថ្ងៃ បើភិក្ខុនោះយកមកឆាន់ក៏នៅតែត្រូវអាបត្តិបាដិទេសនីយៈដែរ ។ ២ ភិក្ខុបង្អោនចីវរជាសង្ឃលាភពីរ គឺចីវរ ១ ដើម្បីខ្លួនត្រូវនិស្សគ្គិយបាចិត្តិយ ចីវរ ១ ទៀតដើម្បីបុគ្គលដទៃវិញ ត្រូវបាចិត្តិយៈ ។ ៣ អដ្ឋកថា ថា កម្មនេះបានជាកម្រើក ព្រោះភិក្ខុដែលនៅចម្ងាយ ១២ យោជន៍នោះ ឋិតនៅក្នុងគាមសីមាជាមួយគ្នា ។

សេទមោចនគាថា គរុកាបត្តិអាទិបញ្ហា

[៣៩៧] បទវីតិហារមត្តេន វាចាយ ភណិតេន ច
សព្វានិ គរុកានិ សប្បដិកម្មានិ
ចតុសដ្ឋី អាបត្តិយោ អាបជ្ជេយ្យ ឯកតោ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

[៣៩៨] និវត្ថោ អន្តរវាសកេន
ទិគុណំ សង្ឃាដឹ បារុតោ
សព្វានិ តានិ និស្សគ្គិយានិ ហោន្តិ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

[៣៩៩] ន ចាបិ ញត្តិ ន ច បន កម្មវាចា
ន ចេហិភិក្ខូតិ ជិនោ អវោច
សរណគមនម្បិ ន តស្ស អត្ថិ
ឧបសម្បទា ចស្ស អកុប្បា
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

សេទមោចនគាថា ប្រស្នាសួរអំពីគរុកាបត្តិជាដើម

(៣៩៧) ភិក្ខុត្រូវគរុកាបត្តិទាំងអស់ ៦៤ ជាអាបត្តិដែលខ្លួនតែបាន ក្នុងខណៈជាមួយគ្នា ដោយគ្រាន់តែឈានជំហានទៅនឹងពោលដោយវាចា[1] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៩៨) ភិក្ខុស្លៀកស្បង់ គ្រងសង្ឃាដីមានជាន់ពីរ តែចីវរទាំងអស់នោះជានិស្សគ្គិយៈ[2] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៣៩៩) ញត្តិ (របស់បុគ្គលនោះ) ក៏មិនមាន ទាំងកម្មវាចាសោតក៏មិនមាន សូម្បីព្រះជិនស្រីក៏មិនបានត្រាស់ហៅថា ឯហិភិក្ខុ ទេ ម្យ៉ាងទៀត សរណគមន៍ របស់បុគ្គលនោះក៏មិនមាន (ចុះហេតុអ្វីបានជា) ឧបសម្បទា របស់បុគ្គលនោះមិនកម្រើក[3] (គឺបានឧបសម្បទាពេញបរិបូណ៌) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ អដ្ឋកថា ថា សំដៅយកភិក្ខុដែលទទួលពាក្យបណ្តាំរបស់បុរសទៅប្រាប់ដំណឹងដល់ពួកស្ត្រីចំនួន ៦៤ នាក់ ដើម្បីឲ្យបានជាប្រពន្ធរបស់បុរសនោះ បានជាត្រូវគរុកាបត្តិដល់ ៦៤ តាមចំនួនស្រីទាំងនោះ ។ ២ សំដៅយកចីវរដែលភិក្ខុប្រើភិក្ខុនីឲ្យលាង ។ ៣ សំដៅយកឧបសម្បទារបស់នាងមហាបជាបតី ដែលគ្រាន់តែទទួលគរុធម៌ ៨ ប្រការ មិនបាច់តាំងញត្តិ នឹងសូត្រកម្មវាចា ក៏បានឡើងជាភិក្ខុនីភាវៈ (ហៅថាអដ្ឋគរុធម្មប្បដិគ្គហណឧបសម្បទា) ។

(៨០០) ឥត្ថឹ ហនេ ន មាតរំ
បុរិសញ្ច ន បិតរំ ហនេ
ហនេយ្យ អនរិយំ មន្ទោ
តេន ចានន្តរំ ផុសេ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៨០១) ឥត្ថឹ ហនេ ច មាតរំ
បុរិសញ្ច បិតរំ ហនេ
មាតរំ បិតរំ ហន្ត្វា
ន តេនានន្តរំ ផុសេ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៨០២) អចោទយិត្វា អសារយិត្វា
អសម្មុខីភូតស្ស ករេយ្យ កម្មំ
កតញ្ច កម្មំ សុកតំ ភវេយ្យ
ការកោ ច សង្ឃោ អនាបត្តិកោ សិយា
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤០០) បុគ្គលលួចសម្លាប់ស្ត្រីមិនមែនជាមាតា សម្លាប់បុរសមិនមែនជាបិតា សម្លាប់បុគ្គលមិនមែនជាព្រះអរិយៈ បុគ្គលនោះត្រូវអនន្តរិយកម្ម ព្រោះការសម្លាប់នោះ[១] ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៤០១) បុគ្គលសម្លាប់ស្ត្រីដែលជាមាតាពិត សម្លាប់បុរសដែលជាបិតាពិត លុះសម្លាប់មាតាបិតាហើយក៏មិនត្រូវអនន្តរិយកម្ម ព្រោះការសម្លាប់នោះ[២] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៤០២) ភិក្ខុមិនបានចោទ មិនបានរំលឹក ហើយធ្វើកម្មដល់បុគ្គលដែលមាននៅក្នុងទីចំពោះមុខ កម្មដែលភិក្ខុធ្វើនោះឈ្មោះថា ធ្វើប្រពៃហើយ ទាំងការកសង្ឃក៏មិនត្រូវអាបត្តិ[៣] ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ អដ្ឋកថាថា បុគ្គលនោះគឺជាមាតានឹងបិតាពិត គ្រាន់តែមាតាក្លាយភេទជាបិតា បិតាក្លាយភេទជាមាតាវិញ សម្លាប់បុគ្គលមិនមែនជាព្រះអរិយៈនោះ គឺសម្លាប់មាតានឹងបិតា ។ ២ សំដៅយកកូនជាមនុស្ស មាតានឹងបិតាជាសត្វតិរច្ឆាន បើសម្លាប់មាតានឹងបិតាជាសត្វតិរច្ឆានយ៉ាងនេះ មិនត្រូវអនន្តរិយកម្មទេ ។ ៣ សំដៅយក ទូតេន ឧបសម្បទា ដែលព្រះអង្គទ្រង់អនុញ្ញាតឲ្យនាងអឌ្ឍកាសីគណិកាព្រោះនាងនោះចង់មកបួសក្នុងសំណាក់ព្រះអង្គ តែមកមិនរួចព្រោះពួកបុរសចាំស្កាត់ពាក់កណ្ដាលផ្លូវ បានជាព្រះអង្គទ្រង់អនុញ្ញាតឲ្យឧបសម្បទាដោយទូតបាន ។

សេទមោចនគាថា សម្មុខីភូតស្ស កម្មករណាទិបញ្ហា

(៤០៣) ចោទយិត្វា សារយិត្វា

សម្មុខីភូតស្ស ករេយ្យ កម្មំ

កតញ្ច កម្មំ អកតំ ករេយ្យ

ការកោ ច សង្ឃោ សាបត្តិកោ សិយា

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤០៤) ឆិន្ទន្តស្ស អាបត្តិ ឆិន្ទន្តស្ស អនាបត្តិ

ឆាទេន្តស្ស អាបត្តិ ឆាទេន្តស្ស អនាបត្តិ

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤០៥) សច្ចំ ភណន្តោ គរុកំ

មុសា ច លហុ ភាសតោ

មុសា ភណន្តោ គរុកំ

សច្ចញ្ច លហុ ភាសតោ

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

សេទមោចនគាថា ប្រស្នាសួរអំពីការធ្វើកម្មដល់បុគ្គលដែលនៅចំពោះមុខជាដើម

[៤០៧] ភិក្ខុបានចោទ បានរំលឹក ហើយធ្វើកម្មដល់បុគ្គល ដែលមាននៅក្នុងទីចំពោះមុខ ឯកម្មដែលភិក្ខុនោះធ្វើហើយ ឈ្មោះថា មិនបានធ្វើទៅវិញ ទាំងការកសង្ឃក៏ត្រូវអាបត្តិ(១) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

[៤០៨] ភិក្ខុកាត់ ត្រូវអាបត្តិក៏មាន(២) ភិក្ខុកាត់ មិនត្រូវអាបត្តិក៏មាន(៣) ភិក្ខុបិទបាំង ត្រូវអាបត្តិក៏មាន(៤) ភិក្ខុបិទបាំង មិនត្រូវអាបត្តិក៏មាន(៥) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

[៤០៩] ភិក្ខុពោលពាក្យពិត ត្រូវគរុកាបត្តិក៏មាន(៦) ពោលពាក្យកុហក ត្រូវលហុកាបត្តិក៏មាន(៧) ពោលពាក្យកុហក ត្រូវគរុកាបត្តិក៏មាន(៨) ពោលពាក្យពិត ត្រូវលហុកាបត្តិក៏មាន(៩) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ អដ្ឋកថា ថាសំដៅយកភិក្ខុឲ្យឧបសម្បទា ដល់អភព្វបុគ្គលមានបណ្ឌកជាដើម ។
២ កាត់វត្ថុមានដើមឈើជាដើម ។ ៣ កាត់ក្រចក ឬកាត់សក់ ។ ៤ បិទបាំងអាបត្តិទុក ។
៥ បិទបាំងទីលំនៅមានផ្ទះជាដើម ។ ៦ ភិក្ខុពោលពាក្យចំពោះទ្វារមគ្គជាដើមរបស់ស្រី ។
៧ ពោលសម្បជានមុសាវាទ ។ ៨ ពោលប្រាប់ឧត្តរិមនុស្សធម្ម ។ ៩ ប្រាប់ឧត្តរិមនុស្សធម្ម ដែលមានក្នុងសន្តានពិត ដល់អនុបសម្បន្ន ។

(៨០៦) អចិន្តិតំ រជនាយ រត្តំ
កប្បកតំបិ សន្តំ
បរិភុញ្ជន្តស្ស អាបត្តិ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៨០៧) អត្ថង្គតេ សុរិយេ ភិក្ខុ មំសានិ ខាទតិ
ន ឧម្មត្តកោ ន ច បន ខិត្តចិត្តោ
ន ចាបិ សោ វេទនដ្ដោ ភវេយ្យ
ន ចស្ស ហោតិ អាបត្តិ
សោ ច ធម្មោ សុគតេន ទេសិតោ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៨០៨) ន រត្តចិត្តោ ន ច បន ថេយ្យចិត្តោ
ន ចាបិ សោ បរំ មរណាយ ចេតយិ
សលាកំ ទេន្តស្ស ហោតិ ឆេជ្ជំ
បដិគ្គណ្ហន្តស្ស ថុល្លច្ចយំ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤០៦) ចីវរភិក្ខុបានអធិដ្ឋាន បានជ្រលក់ដោយគ្រឿងជ្រលក់ បានធ្វើពិន្ទុកប្បៈ ត្រឹមត្រូវហើយ តែភិក្ខុនោះប្រើប្រាស់ត្រូវអាបត្តិ[1] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៤០៧) កាលបើព្រះអាទិត្យអស្តង្គតហើយ ភិក្ខុឆាន់សាច់ ភិក្ខុនោះ មិនមែនជាភិក្ខុឆ្កួត ទាំងមិនមែនជាភិក្ខុមានចិត្តរវើរវាយ ទាំងមិនមែនជាភិក្ខុមានវេទនាគ្របសង្កត់ តែភិក្ខុនោះមិនត្រូវអាបត្តិ[2] ទាំងធម៌នោះសោត ក៏ព្រះសុគតទ្រង់បានសំដែងហើយ ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៤០៨) ភិក្ខុនោះមិនមានតម្រេក មិនមានថេយ្យចិត្ត ទាំងមិនបានគិតដើម្បីសម្លាប់អ្នកដទៃ កាលភិក្ខុនោះឲ្យស្លាក រមែងដាច់ចាកភិក្ខុភាវៈ[3] ភិក្ខុអ្នកទទួលស្លាក ត្រូវថុល្លច្ច័យ[4] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ អដ្ឋកថា ថា ចីវរដែលជានិស្សគ្គិយ ភិក្ខុមិនលះបង់ជាវិនយកម្មសិនហើយប្រើប្រាស់ ។
២ សំដៅយករោមន្ថកភិក្ខុ គឺភិក្ខុជាអ្នកទំពាអៀង ព្រះអង្គទ្រង់អនុញ្ញាតឲ្យទំពាអៀងបាន ព្រោះភិក្ខុនោះធ្លាប់យោនយកកំណើតជាគោ (មានក្នុងខុទ្ទកវត្ថុក្ខន្ធកៈទី ៥ ចុល្លវគ្គ) ។
៣ សំដៅយកភិក្ខុអ្នកបំបែកសង្ឃ កាលភិក្ខុនោះចែកស្លាកឲ្យពួកភិក្ខុដែលចូលដៃនឹងខ្លួន ត្រូវអាបត្តិបារាជិក ។ ៤ ឯភិក្ខុដែលប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃនោះ ត្រូវថុល្លច្ច័យ ។

សេទមោចនគាថា អារញ្ញកាទិបញ្ហា

(៤០៩) ន ចាបិ អារញ្ញកំ សាសង្កសម្មតំ
ន ចាបិ សង្ឃេន សម្មុតិ ទិន្នា
ន ចស្ស កឋិនំ អត្ថតំ តត្ថេវ ចីវរំ
និក្ខិបិត្វា គច្ឆេយ្យ អឌ្ឍយោជនំ
តស្សេវ អរុណំ ឧគ្គច្ឆន្តស្ស អាបត្តិ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤១០) កាយិកានិ ន វាចសិកានិ
សព្វានិ នានាវត្ថុកានិ
អបុព្វំ អចរិមំ(១) អាបជ្ជេយ្យ ឯកតោ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤១១) វាចសិកានិ ន កាយិកានិ
សព្វានិ នានាវត្ថុកានិ
អបុព្វំ អចរិមំ(២) អាបជ្ជេយ្យ ឯកតោ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

១–២ អបរិមន្តិបិ កត្ថចិ បោត្ថកេសុ ទិស្សតិ ។

សេទមោចនគាថា ប្រស្នាសួរអំពីសេនាសនៈនៅក្នុងព្រៃជាដើម

[៤០៩] ទីនោះមិនមែនជាសេនាសនៈនៅក្នុងព្រៃ ដែលគេសន្មតថាប្រកបដោយសេចក្ដីរង្កៀសទេ ទាំងសង្ឃក៏មិនបានឲ្យសម្មតិ ទាំងភិក្ខុនោះ ក៏មិនបានក្រាលកឋិន (បើភិក្ខុនោះ) ទុកចីវរក្នុងទីនោះ ហើយទៅកាន់ទីមានប្រមាណកន្លះយោជន៍ លុះអរុណរះឡើង ភិក្ខុនោះក៏មិនត្រូវអាបត្តិឡើយ(១) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

[៤១០] ភិក្ខុត្រូវអាបត្តិទាំងពួង មានវត្ថុផ្សេង ៗ គ្នា ប្រកបដោយកាយ មិនប្រកបដោយវាចា ក្នុងខណៈជាមួយគ្នា មិនមុនមិនក្រោយ(២) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

[៤១១] ភិក្ខុត្រូវអាបត្តិទាំងពួង មានវត្ថុផ្សេង ៗ គ្នា ប្រកបដោយវាចា មិនប្រកបដោយកាយ ក្នុងខណៈជាមួយគ្នា មិនមុនមិនក្រោយ(៣) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

---

១ អដ្ឋកថា ថាបានជាមិនត្រូវអាបត្តិ ព្រោះភិក្ខុនោះទៅនៅអាស្រ័យក្រោមម្លប់ឈើរបស់ត្រកូល ១មានមែកធំហើយវែងចំនួន ១ យោជន៍ ឬ២យោជន៍ ទោះបីភិក្ខុនោះទុកដាក់ចីវរក្រោមម្លប់ឈើនោះហើយដើរទៅចម្ងាយកន្លះយោជន៍ ហើយអរុណរះឡើងក៏មិនត្រូវអាបត្តិ ដ្បិតមិនផុតពីម្លប់នៅឡើយ ។ ២ សំដៅយកភិក្ខុដែលចាប់សក់ ឬស្ទាបដៃជាដើម របស់ស្ត្រីច្រើននាក់ក្នុងវេលាជាមួយគ្នា ។ ៣ គឺភិក្ខុពោលពាក្យអាក្រក់ចំពោះទ្វារមគ្គជាដើមរបស់ស្ត្រីច្រើននាក់ក្នុងវេលាជាមួយគ្នា ។

[៤១២] តិស្សិត្ថិយោ មេថុនំ តំ ន សេវេ
តយោ បុរិសេ តយោ ច អនរិយបណ្ឌកេ
ន ចាចរេ មេថុនំ ព្យញ្ជនស្មឹ
ឆេជ្ជា សិយា មេថុនប្បច្ចយា
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

[៤១៣] មាតរំ ចីវរំ យាចេ
នោ ច សង្ឃស្ស បរិណតំ
កេនស្ស ហោតិ អាបត្តិ
អនាបត្តិ ច ញាតកេ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

[៤១៤] កុទ្ធោ អារាធកោ ហោតិ
កុទ្ធោ ហោតិ គរហិយោ
អថ កោ នាម សោ ធម្មោ
យេន កុទ្ធោ បសំសិយោ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤១២) ឧបសម្បន្ន មិនសេពមេថុននឹងស្រី ៣ ពួកនោះ នឹងបុរស ៣ ពួក មួយទៀត មិនសេពមេថុននឹងអនរិយជន គឺឧភតោព្យញ្ជនក ៣ ពួក នឹងបណ្ឌក ៣ ពួក មួយទៀតមិនបានប្រព្រឹត្តមេថុនក្នុងព្យញ្ជនៈ គឺដោយអំណាចនៃអនុលោមបារាជិកសោះឡើយ តែឧបសម្បន្ននោះ ត្រូវឆេជ្ជវត្ថុ ព្រោះមេថុនធម្មជាបច្ច័យ(១) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៤១៣) ភិក្ខុសូមចីវរនឹងមាតា តែមិនមែនជាចីវរ ដែលមាតាបង្អោនទៅដើម្បីសង្ឃ ភិក្ខុនោះត្រូវអាបត្តិ ព្រោះហេតុអ្វី(២) មួយទៀត ភិក្ខុមិនត្រូវអាបត្តិ ព្រោះសូមចីវរនឹងពួកញាតិ ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៤១៤) បុគ្គលក្រោធខឹងហើយត្រឡប់ទៅជាត្រេកអរវិញ(៣) បុគ្គលក្រោធខឹងហើយគួរនឹងតិះដៀល (៤) បុគ្គលក្រោធខឹងហើយគួរនឹងសរសើរ ដោយធម៌ណា ធម៌នោះតើឈ្មោះដូចម្តេច ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ

---

១ អដ្ឋកថា ថា សំដៅយកអដ្ឋវត្ថុកបារាជិករបស់ភិក្ខុនី ។ ២ សំដៅយកភិក្ខុសូមសំពត់វស្សិក-សាដិកអំពីមាតាក្នុងបិដ្ឋិសម័យ គឺសម័យខាងខ្នងរដូវ រាប់តាំងអំពី ១ រោចខែកត្តិក រហូតដល់ ១៥ កើតខែជេស្ឋ ។ ៣ បានដល់ពួកតិរ្ថិយ៍ដែលកំពុងបំពេញវត្ត កាលបើឮគេសរសើរគុណពួកតិរ្ថិយ៍ ទុកជាខឹងហើយក៏ត្រឡប់ទៅជាត្រេកអរវិញ ។ ៤ កាលបើគេសរសើរគុណព្រះរតនត្រ័យ បើបុគ្គលណាខឹង បុគ្គលនោះឈ្មោះថា គួរនឹងតិះដៀល ។

សេទមោចនគាថា តុណ្ឌាភាធកាទិបញ្ហា

(៤១៥) តុណ្ឌា អាភជកោ ហោតិ
តុណ្ឌា ហោតិ គរហិយោ
អថ កោ ណាម សោ ធម្មោ
យេន តុណ្ឌា គរហិយោ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤១៦) សង្ឃាទិសេសំ ថុល្លច្ចយំ
បាចិត្តិយំ បាដិទេសនីយំ
ទុក្កដំ អាបជ្ជេយ្យ ឯកតោ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤១៧) ឧភោ បរិបុណ្ណវីសតិវស្សា ឧភិន្នំ
ឯកុបជ្ឈាយោ ឯកាចរិយោ ឯកា កម្មវាចា

(៤១៥) បុគ្គលដែលត្រេកអរ ហើយក៏ត្រេកអរថែមទៀត បុគ្គលដែលត្រេកអរហើយ តែគួរនឹងតិះដៀល បុគ្គលដែលត្រេកអរហើយ តែគួរនឹងតិះដៀល ដោយធម៌ណា ធម៌នោះ តើឈ្មោះដូចម្តេច ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៤១៦) ឧបសម្បន្ន ត្រូវអាបត្តិសង្ឃាទិសេស (លាយដោយអាបត្តិ) ថុល្លច្ច័យៈ បាចិត្តិយៈ បាដិទេសនីយៈនិងទុក្កដក្នុងខណៈជាមួយគ្នា[១] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៤១៧) កុលបុត្រ ២ រូបមានឆ្នាំ ២០ គ្រប់គ្រាន់ហើយ ឯកុលបុត្រទាំង ២ រូបនោះ សឹងមានឧបជ្ឈាយ៍ជាមួយគ្នា អាចារ្យ ជាមួយគ្នា កម្មវាចា ជាមួយគ្នា តែកុលបុត្រមួយរូបជា

១ អដ្ឋកថា ថា ភិក្ខុនីមានតម្រេកទទួលបិណ្ឌបាតអំពីដៃបុរសដែលមានតម្រេកដែរ យកមកលាយគ្នានឹងសាច់មនុស្ស, ខ្ទឹម, បណីតភោជន នឹងសាច់ជាអកប្បិយៈដ៏សេស ហើយយកមកឆាន់ ត្រូវអាបត្តិទាំងនោះ គឺត្រូវថុល្លច្ច័យ ព្រោះឆាន់សាច់មនុស្ស ត្រូវបាចិត្តិយៈ ព្រោះឆាន់ខ្ទឹម ត្រូវបាដិទេសនីយៈ ព្រោះឆាន់បណីតភោជនមានទឹកដោះរាជាដើម ត្រូវទុក្កដ ព្រោះឆាន់សាច់ជាអកប្បិយៈដ៏សេស បានជាត្រូវអាបត្តិទាំងនោះជាមួយគ្នា ព្រោះយករបស់ទាំងអស់នេះមកលាយចូលគ្នាហើយឆាន់ ។

ឯកោ ឧបសម្បន្នោ ឯកោ អនុបសម្បន្នោ

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤១៨) អកប្បកតំ នាបិ[១] រជនាយ រត្តំ

តេន និវត្ថោ យេន កាមំ វជេយ្យ

ន ចស្ស ហោតិ អាបត្តិ

សោ ច ធម្មោ សុគតេន ទេសិតោ

បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤១៩) ន ទេតិ ន បដិគ្គណ្ហាតិ

បដិគ្គហោ តេន ន វិជ្ជតិ

អាបជ្ជតិ គរុកំ ន លហុកំ

---

១ ឱ. ម. នា ។

ឧបសម្បន្ន គឺបានឡើងជាភិក្ខុ មួយរូបទៀត ជាអនុបសម្បន្ន[១] គឺនៅជាសាមណេរ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៨១៨) សំពត់ដែលភិក្ខុមិនបានធ្វើពិន្ទុកប្ប ទាំងមិនបានជ្រលក់ដោយគ្រឿងជ្រលក់ ភិក្ខុស្លៀកពាក់សំពត់នោះហើយ ដើរទៅដោយគួរតាមប្រាថ្នា ភិក្ខុនោះមិនត្រូវអាបត្តិ[២] ទាំងធម៌នោះសោតក៏ព្រះសុគតទ្រង់សំដែងហើយ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៨១៩) ឧបសម្បន្ន១ មិនបានឲ្យ ឧបសម្បន្ន១ មិនបានទទួល ព្រោះហេតុនោះ ការទទួលមិនមានទេ តែឧបសម្បន្ននោះ ត្រូវគរុកាបត្តិ[៣] មិនមែនជាលហុកាបត្តិ កាលដែល

---

១ អដ្ឋកថា ថា សាមណេរមានឫទ្ធិ ហោះទៅឯអាកាស ឬមុជជ្រែកទៅអង្គុយក្នុងផែនដីសូម្បីប៉ុនចុងចំរៀកសក់ក៏មិនឡើងឧបសម្បទាជាភិក្ខុឡើយ ម្យ៉ាងទៀតចំណែកខាងសង្ឃបើឋិតនៅឯអាកាសក៏កម្មនោះកម្រើកដែរ ។ ២ ភិក្ខុដែលចោរដណ្ដើមយកចីវរ ទុកជាស្លៀកពាក់សំពត់យ៉ាងនោះក៏មិនត្រូវអាបត្តិ ។ ៣ ភិក្ខុជាអ្នកបញ្ជូនក៏មិនឲ្យ ភិក្ខុនីដែលត្រូវគេបញ្ជូនក៏មិនបានទទួលអំពីដៃភិក្ខុនីដែលជាអ្នកបញ្ជូននោះ តែភិក្ខុនីជាអ្នកបញ្ជូនត្រូវអាបត្តិសង្ឃាទិសេសក្នុងពេលដែលភិក្ខុនីត្រូវគេបញ្ជូនបានទទួលបិណ្ឌបាតអំពីដៃបុរសដែលមានសេចក្ដីត្រេកអរ តាមពិតនោះគឺត្រូវក្នុងពេលដែលភិក្ខុនីត្រូវគេបញ្ជូនបរិភោគរួចជាស្រេច ។ មានពិស្ដារក្នុងភិក្ខុនីវិភង្គ បច្ឆេកភាគទី ៨ ត្រង់សង្ឃាទិសេសសិក្ខាបទទី ៦ ទំព័រ ៦៤ អដ្ឋកថាក៏មានដូចគ្នា ។

សេទមោចនគាថា អកានាប្បដិគ្គហាទិបញ្ហា

តញ្ច បរិភោគបច្ចយា
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤២០) ន នេតិ នប្បដិគ្គណ្ហាតិ
បដិគ្គហោ តេន ន វិជ្ជតិ
អាបជ្ជតិ លហុកំ ន គរុកំ
តញ្ច បរិភោគបច្ចយា
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

(៤២១) អាបជ្ជតិ គរុកំ សាវសេសំ
ឆាទេតិ អនាទរិយំ បដិច្ច
ន ភិក្ខុនី នោ ច ផុសេយ្យវជ្ជំ
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

សេទមោចនគាថា និដ្ឋិតា ។

សេទមោចនគាថា ប្រស្នាសួរអំពីការមិនបានឲ្យ និងមិនបានទទួលជាដើម

ដឹងត្រូវអាបត្តិនោះ ក៏ត្រូវព្រោះការបរិភោគ ជាបច្ច័យ ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៨២០) ឧបសម្បន្ន ១ មិនបានឲ្យ ឧបសម្បន្ន១ មិនបានទទួល ព្រោះហេតុនោះ ការទទួលមិនមានទេ តែឧបសម្បន្ននោះ ត្រូវលហុកាបត្តិ(១) មិនមែនជាគរុកាបត្តិទេ កាលដែលត្រូវអាបត្តិនោះ ក៏ត្រូវព្រោះការបរិភោគ ជាបច្ច័យ ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

(៨២១) ឧបសម្បន្នមិនមែនជាភិក្ខុនី ត្រូវគរុកាបត្តិ ជាសាវសេសាបត្តិ ហើយបិទបាំងទុក ព្រោះអាស្រ័យសេចក្តីមិនអើពើ(២) តែមិនត្រូវទោស ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

ចប់ សេទមោចនគាថា ។

---

១ ត្រង់គាថាទី ២ នេះ គឺភិក្ខុនោះឯដែល បានជាត្រូវលហុកាបត្តិ ព្រោះវត្ថុនោះជាទឹកនិងឈើស្ទន់ ឯកិច្ចដែលត្រូវអាបត្តិនោះ មានវិធីដូចគ្នានឹងគាថាទី ១ ។ ២ សំដៅយកឧក្ខិត្តកភិក្ខុ គឺភិក្ខុដែលសង្ឃលើកវត្ត ព្រោះភិក្ខុនោះមិនត្រូវមានវិនយកម្មជាមួយនឹងសង្ឃទេ ព្រោះហេតុនោះបានជាត្រូវអាបត្តិសង្ឃាទិសេស ហើយបិទបាំងទុកមិនត្រូវទោសព្រោះបិទបាំង ។

តស្សុទ្ទានំ

(៨២២) អសំវាសោ អវិស្សជ្ជិ

ទស ច អនុទ្ទិដ្ឋតោ

ឧបេតិ ធម្មំ ឧព្ភក្ខំ (១)

តតោ សញ្ញាចិកា ច ទ្វេ

ន កាយិកញ្ច គរុកំ

ន កាយិកំ សុភាសិតំ (២)

អភាវបត្តោ សិក្ខា ច

ឧភោ ច ចតុរោ ជនា

ឥត្ថី តេវញ្ច និស្សគ្គិ

ភិក្ខូ ច បទវីតិយោ

និវត្តោ ច ន ច ញត្តិ

ន មាតរំ បិតរំ ហនេ

អចោទយិត្វា ចោទយិត្វា

---

១ ឧ. ម. ឧព្ភក្ខកំ ។ ២ ន វាចសិកំ ។

វិនយបិដក បរិវារៈ

ឧទ្ទានគឺបញ្ជីរឿងនៃសេទមោចនគាថានោះដូច្នេះ

(៨៨២) និយាយអំពីមិនមានសំវាស ១ គរុកណ្ឌ ៥ ដែលភិក្ខុលះមិនបាន ១ អវន្ទិយបុគ្គល ១០ ពួក ១ ភិក្ខុដែលសង្ឃមិនបានលើកវត្ត ១ បុគ្គលដែលចូលទៅសាកសួរធម៌ ១ អវយវៈត្រឹមដងកាំបិតទៅលើ ១ ភិក្ខុធ្វើកុដិដោយការសូមគ្រឿងឧបករណ៍គេមកដោយខ្លួនឯងមាន ២ ប្រស្នា ១ ភិក្ខុប្រព្រឹត្តប្រយោគមិនប្រកបដោយកាយត្រូវគរុកាបត្តិ ១ ភិក្ខុមិនធ្វើបាបប្រកបដោយកាយ ដែលសង្ឃត្រូវឲ្យវិនាសដោយល្អ ១ ភិក្ខុមិនបរាជ ១ សិក្ខាដែលព្រះអង្គទ្រង់សំដែង ១ ភិក្ខុទាំងពីររូបបានឧបសម្បទាជាមួយគ្នា ១ ជនគឺភិក្ខុ ៤ រូប បបួលគ្នាទៅលួចគរុកណ្ឌ ១ ស្រីនៅក្នុង ភិក្ខុនៅក្រៅ ១ ភិក្ខុទទួលប្រេងជាដើម ១ ភិក្ខុត្រូវអាបត្តិនិស្សគ្គិយៈនឹងបាចិត្តិយៈក្នុងខណៈជាមួយ ១ ភិក្ខុ ២០ រូប មកប្រជុំគ្នា ១ ភិក្ខុត្រូវគរុកាបត្តិដោយគ្រាន់តែឈានជំហាន ១ ភិក្ខុស្លៀកស្បង់ជាដើម ១ ឧបសម្បទាមិនមានញត្តិជាដើម ១ បុគ្គលសម្លាប់មាតាបិតាតែមិនត្រូវអនន្តរិយកម្ម ១ ភិក្ខុមិនបានទោទ ១ ភិក្ខុបានទោទ ១

សេទមោចនគាថា ឧទ្ទានគាថា

ឆិន្នន្តំ សព្វមេវ ច
អធិដ្ឋិតញ្ញត្តន្តេ
ន រត្តំ ន ចារញ្ញកំ
កាយិកា វាចសិកា ច [1]
តិស្សិត្ថី ចាបិ មាតរំ
កុទ្ធោ អារាធកោ តុដ្ឋោ
សង្ឃាទិសេសកា [2] ឧភោ
អកប្បកតំ ន ទេតិ
ន ទេតាបជ្ជតេ [3] គរុំ
សេទមោចនិកា គាថា
បញ្ហា វិញ្ញូវិភាវិតាតិ ។

---

១ ឱ. កាយិកវាចសិកា ។ ២ សង្ឃាទិសេសា ច ។ ម. សង្ឃាទិសេសា ច ។
៣ ឱ. ម. ន ទេតាបជ្ជតិ ។

សេទមោចនគាថា ឧទ្ទានគាថា

ភិក្ខុកាត់ ១ ភិក្ខុពោលពាក្យពិត ១ ចីវរដែលភិក្ខុបានអធិដ្ឋានហើយ ១ ភិក្ខុឆាន់សាច់ក្នុងវេលាព្រះអាទិត្យអស្តង្គត ១ ភិក្ខុមិនមានចិត្តត្រេកអរ ១ ទីសេនាសនៈដែលមិនបានតាំងនៅក្នុងព្រៃ ១ ភិក្ខុត្រូវអាបត្តិមិនប្រកបដោយកាយ ប្រកបតែដោយវាចា ១ ស្រី ៣ ពួក ១ ភិក្ខុសូមចីវរនឹងមាតា ១ បុគ្គលក្រោធខឹងហើយត្រឡប់ជាត្រេកអរ ១ បុគ្គលត្រេកអរហើយក៏ត្រេកអរថែមទៀត ១ ឧបសម្បន្នត្រូវអាបត្តិសង្ឃាទិសេសជាដើម ១ កុលបុត្រ ២ រូប ១ សំពត់ដែលភិក្ខុមិនបានធ្វើពិន្ទុកប្បជាដើម ១ ឧបសម្បន្នមួយរូបមិនបានឲ្យ ១ ឧបសម្បន្នមួយរូបបានឲ្យ ១ ឧបសម្បន្នត្រូវគរុកាបត្តិ ១ ចប់សេទមោចនិកាគាថា ប្រស្នាដែលលោកអ្នកប្រាជ្ញ បានសំដែងឲ្យច្បាស់លាស់ហើយ ។

បញ្ចវគ្គ

(៤៦៣) ចត្តារិ កម្មានិ អបលោកនកម្មំ ញត្តិកម្មំ ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ។ ឥមានិ ចត្តារិ កម្មានិ កតីហាការេហិ វិបជ្ជន្តិ ។ ឥមានិ ចត្តារិ កម្មានិ បញ្ចហាការេហិ វិបជ្ជន្តិ វត្ថុតោ វា ញត្តិតោ វា អនុស្សាវនតោ វា សីមតោ វា បរិសតោ វា ។

(៤៦៤) កថំ វត្ថុតោ កម្មានិ វិបជ្ជន្តិ ។ សម្មុខា ករណីយំ កម្មំ អសម្មុខា ករោតិ វត្ថុវិបន្នំ អធម្មកម្មំ ។ បដិបុច្ឆា ករណីយំ កម្មំ អប្បដិបុច្ឆា ករោតិ វត្ថុវិបន្នំ អធម្មកម្មំ ។ បដិញ្ញាយ ករណីយំ កម្មំ អប្បដិញ្ញាយ ករោតិ វត្ថុវិបន្នំ អធម្មកម្មំ ។ សតិវិនយារហស្ស អមូឡ្ហវិនយំ ទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ អមូឡ្ហវិនយារហស្ស តស្សបាបិយសិកាកម្មំ ករោតិ វត្ថុវិបន្នំ អធម្មកម្មំ ។ តស្សបាបិយសិកាកម្មារហស្ស តជ្ជនីយកម្មំ ករោតិ វត្ថុវិបន្នំ អធម្មកម្មំ ។ តជ្ជនីយកម្មារហស្ស និយស្សកម្មំ ករោតិ វត្ថុវិបន្នំ អធម្មកម្មំ ។ និយស្សកម្មារហស្ស បព្វាជនីយកម្មំ ករោតិ វត្ថុវិបន្នំ អធម្មកម្មំ ។

បញ្ចវគ្គ

(៤៦៣) កម្ម ៤ យ៉ាង គឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ ញត្តិចតុត្ថកម្ម ១ ។ កម្មទាំង ៤ នេះ តែងវិបត្តិព្រោះអាការប៉ុន្មាន ។ កម្មទាំង ៤ នេះ តែងវិបត្តិព្រោះអាការ ៥ គឺ វត្ថុ ១ ញត្តិ ១ អនុស្សាវនៈ ១ សីមា ១ បរិសទ្យ ១ ។

(៤៦៤) កម្មវិបត្តិព្រោះវត្ថុដូចម្តេច ។ កម្មដែលសង្ឃត្រូវធ្វើចំពោះមុខ បែរជាធ្វើកំបាំងមុខទៅវិញ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ កម្មដែលសង្ឃត្រូវធ្វើដោយការសាកសួរ បែរជាធ្វើដោយការមិនសាកសួរវិញ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ កម្មដែលសង្ឃត្រូវធ្វើតាមពាក្យប្តេជ្ញា បែរជាធ្វើមិនតាមពាក្យប្តេជ្ញាវិញ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃឲ្យអមូឡ្ហវិន័យដល់ភិក្ខុគួរដល់សតិវិន័យ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុគួរដល់អមូឡ្ហវិន័យ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃធ្វើតជ្ជនីយកម្មដល់ភិក្ខុគួរដល់តស្សបាបិយសិកាកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃធ្វើនិយស្សកម្ម ដល់ភិក្ខុគួរដល់តជ្ជនីយកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃធ្វើបព្វាជនីយកម្ម ដល់ភិក្ខុគួរដល់និយស្សកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។

បព្វាជនីយកម្មារហស្ស បដិសារណីយកម្មំ ករោតិ វត្ថុវិបន្នំ អធម្មកម្មំ ។ បដិសារណីយកម្មារហស្ស ឧក្ខេបនីយកម្មំ ករោតិ វត្ថុវិបន្នំ អធម្មកម្មំ ។ ឧក្ខេបនីយកម្មារហស្ស បរិវាសំ ទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ បរិវាសារហំ មូលាយ បដិកស្សតិ វត្ថុវិបន្នំ អធម្មកម្មំ ។ មូលាយ បដិកស្សនារហស្ស មានត្តំ ទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ មានត្តារហំ អព្ភេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ អព្ភានារហំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ អនុបោសថេ ឧបោសថំ ករោតិ វត្ថុវិបន្នំ អធម្មកម្មំ ។ អបវារណាយ បវារេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ ឯវំ វត្ថុតោ កម្មានិ វិបជ្ជន្តិ ។

(៤៣៥) កថំ ញត្តិតោ កម្មានិ វិបជ្ជន្តិ ។ បញ្ចហាការេហិ ញត្តិតោ កម្មានិ វិបជ្ជន្តិ វត្ថុំ ន បរាមសតិ សង្ឃំ ន បរាមសតិ បុគ្គលំ ន បរាមសតិ ញត្តឹ ន បរាមសតិ បច្ឆា វា ញត្តឹ ឋបេតិ ។ ឥមេហិ បញ្ចហាការេហិ ញត្តិតោ កម្មានិ វិបជ្ជន្តិ ។

សង្ឃធ្វើបដិសារណីយកម្ម ដល់ភិក្ខុគួរដល់បព្វាជនីយកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុគួរដល់បដិសារណីយកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃឲ្យបរិវាស ដល់ភិក្ខុគួរដល់ឧក្ខេបនីយកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃទាញភិក្ខុគួរដល់បរិវាស មកដាក់ក្នុងមូលាបត្តិ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃឲ្យមានត្ត ដល់ភិក្ខុគួរដល់មូលាយបដិកស្សនៈ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃឲ្យអព្ភាន ដល់ភិក្ខុគួរដល់មានត្ត កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាងភិក្ខុគួរដល់អព្ភាន ឲ្យឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ១ សង្ឃធ្វើឧបោសថ ក្នុងថ្ងៃមិនមែនជាថ្ងៃឧបោសថ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃធ្វើបវារណា ក្នុងថ្ងៃមិនមែនជាថ្ងៃបវារណា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ កម្ម វិបត្តិព្រោះវត្ថុយ៉ាងនេះឯង ។

(៤២៥) កម្មទាំងឡាយ វិបត្តិព្រោះញត្តិដូចម្ដេច ។ កម្មទាំងឡាយ វិបត្តិព្រោះញត្តិ ដោយអាការ ៥ គឺភិក្ខុមិនសូត្របញ្ចេញឈ្មោះវត្ថុ គឺឧបសម្បទាបេក្ខៈ ១ មិនបញ្ចេញឈ្មោះសង្ឃ ១ មិនបញ្ចេញឈ្មោះបុគ្គល គឺឧបជ្ឈាយ៍ ១ មិនតាំងញត្តិ ១ ឬតាំងញត្តិខាងក្រោយកម្មវាចា ១ ។ កម្មទាំងឡាយ វិបត្តិព្រោះញត្តិ ដោយអាការ ៥ នេះឯង ។

(៨២៦) កថំ អនុស្សាវនតោ កម្មានិ វិបជ្ជន្តិ ។
បញ្ចហាការេហិ អនុស្សាវនតោ កម្មានិ វិបជ្ជន្តិ វត្ថុំ
ន បរាមសតិ សង្ឃំ ន បរាមសតិ បុគ្គលំ ន បរាមសតិ
សាវនំ ហាបេតិ អកាលេ វា សាវេតិ ។ ឥមេហិ បញ្ច-
ហាការេហិ អនុស្សាវនតោ កម្មានិ វិបជ្ជន្តិ ។

(៨២៧) កថំ សីមតោ កម្មានិ វិបជ្ជន្តិ ។ ឯកា-
ទសហាការេហិ សីមតោ កម្មានិ វិបជ្ជន្តិ អតិខុទ្ទកំ
សីមំ សម្មន្នតិ អតិមហតឹ សីមំ សម្មន្នតិ ខណ្ឌនិមិត្តំ
សីមំ សម្មន្នតិ ឆាយានិមិត្តំ សីមំ សម្មន្នតិ អនិមិត្តំ
សីមំ សម្មន្នតិ ពហិសីមេ ឋិតោ សីមំ សម្មន្នតិ នទិ-
យា សីមំ សម្មន្នតិ សមុទ្ទេ សីមំ សម្មន្នតិ ជាតស្ស-
រេ សីមំ សម្មន្នតិ សីមាយ សីមំ សម្ភិន្ទតិ សីមាយ
សីមំ អជ្ឈោត្ថរតិ ។ ឥមេហិ ឯកាទសហាការេហិ
សីមតោ កម្មានិ វិបជ្ជន្តិ ។

(៨២៨) កថំ បរិសតោ កម្មានិ វិបជ្ជន្តិ ។ ទ្វាទស-
ហាការេហិ បរិសតោ កម្មានិ វិបជ្ជន្តិ ចតុវគ្គករណេ

(៨២៦) កម្មទាំងឡាយ វិបត្តិព្រោះអនុស្សាវនៈដូចម្តេច ។ កម្មទាំងឡាយ វិបត្តិព្រោះអនុស្សាវនៈ ដោយអាការ ៥ គឺសូត្រមិនចេញឈ្មោះវត្ថុ ១ មិនចេញឈ្មោះសង្ឃ ១ មិនចេញឈ្មោះបុគ្គល ១ ធ្វើអនុស្សាវនវិធីឲ្យខូច ១ សូត្រក្នុងកាលមិនគួរ ១ ។ កម្មទាំងឡាយ វិបត្តិព្រោះអនុស្សាវនៈ ដោយអាការ ៥ នេះឯង ។

(៨២៧) កម្មទាំងឡាយ វិបត្តិព្រោះសីមាដូចម្តេច ។ កម្មទាំងឡាយ វិបត្តិព្រោះសីមា ដោយអាការ ១១ គឺសន្មតសីមាតូចពេក ១ សន្មតសីមាធំពេក ១ សន្មតសីមាមាននិមិត្តមិនតគ្នា ១ សន្មតសីមាយកស្រមោលជានិមិត្ត ១ សន្មតសីមាមិនមានអ្វីជានិមិត្ត ១ ឈរខាងក្រៅសីមាសន្មតសីមា ១ សន្មតសីមាក្នុងស្ទឹង ១ សន្មតសីមាក្នុងសមុទ្រ ១ សន្មតសីមាក្នុងជាតស្រះ ១ ចំណាយសីមាដោយសីមា ១ គ្របសីមាដោយសីមា ១ ។ កម្មទាំងឡាយ វិបត្តិព្រោះសីមាដោយអាការ ១១ នេះឯង ។

(៨២៨) កម្មទាំងឡាយ វិបត្តិព្រោះបរិសទ្យដូចម្តេច ។ កម្មទាំងឡាយ វិបត្តិព្រោះបរិសទ្យ ដោយអាការ ១២ គឺកម្មដែលសង្ឃធ្វើដោយ

កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អនាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ចតុវគ្គករណោ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ចតុវគ្គករណោ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ បញ្ចវគ្គករណោ កម្មេ ។ បេ ។ ទសវគ្គករណោ កម្មេ ។ បេ ។ វីសតិវគ្គករណោ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អនាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ វីសតិវគ្គករណោ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ វីសតិវគ្គករណោ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ

ចតុវគ្គ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះក៏មិនបានមក ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏មិនបាននាំមក ពួកភិក្ខុដែលមាននៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម ១ កម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះបានមកហើយតែឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈមិនបាននាំមក ទាំងពួកភិក្ខុដែលនៅក្នុងទីចំពោះមុខក៏ឃាត់ហាម ១ កម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះក៏បានមកហើយ ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏បាននាំមកហើយដែរ តែពួកភិក្ខុដែលនៅក្នុងទីចំពោះមុខក៏ឃាត់ហាម១កម្មដែលសង្ឃធ្វើដោយបញ្ចវគ្គ ។ បេ ។ កម្មដែលសង្ឃធ្វើដោយទសវគ្គ ។ បេ ។ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ពួកភិក្ខុមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះមិនបានមក ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏មិនបាននាំមក ទាំងពួកភិក្ខុដែលនៅក្នុងទីចំពោះមុខក៏ឃាត់ហាម ១ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះក៏បានមកហើយដែរ តែឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈមិនបាននាំមក ទាំងពួកភិក្ខុដែលនៅក្នុងទីចំពោះមុខក៏ឃាត់ហាម ១ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះក៏បានមក

ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ។ ឥមេហិ ទ្វាទសហាការេហិ បរិសតោ កម្មានិ វិបជ្ជន្តិ ។

[៤២៩] ចតុវគ្គករណេ កម្មេ ចត្តារោ ភិក្ខូ បកតត្តា កម្មប្បត្តា អវសេសា បកតត្តា ឆន្ទារហា យស្ស សង្ឃោ កម្មំ ករោតិ សោ នេវ កម្មប្បត្តោ នបិ[១] ឆន្ទារហោ អបិច កម្មារហោ ។ បញ្ចវគ្គករណេ កម្មេ បញ្ច ភិក្ខូ បកតត្តា កម្មប្បត្តា អវសេសា បកតត្តា ឆន្ទារហា យស្ស សង្ឃោ កម្មំ ករោតិ សោ នេវ កម្មប្បត្តោ នបិ ឆន្ទារហោ អបិច កម្មារហោ ។ ទសវគ្គករណេ កម្មេ ទស ភិក្ខូ បកតត្តា កម្មប្បត្តា អវសេសា បកតត្តា ឆន្ទារហា យស្ស សង្ឃោ កម្មំ ករោតិ សោ នេវ កម្មប្បត្តោ នបិ ឆន្ទារហោ អបិច កម្មារហោ ។ វីសតិវគ្គករណេ កម្មេ វីសតិ ភិក្ខូ បកតត្តា កម្មប្បត្តា អវសេសា បកតត្តា ឆន្ទារហា យស្ស សង្ឃោ កម្មំ ករោតិ សោ នេវ កម្មប្បត្តោ នបិ ឆន្ទារហោ អបិច កម្មារហោ ។

---
១ ឱ. ម. នាបិ ។

ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏បាននាំមកហើយដែរ តែពួកភិក្ខុដែលនៅក្នុងទីចំពោះមុខក៏ឃាត់ហាម ១ ។ កម្មទាំងឡាយ វិបត្តិព្រោះបរិសទ្យដោយអាការ ១២ នេះឯង ។

(៤២៩) កម្មសង្ឃធ្វើដោយចតុវគ្គ បានដល់ភិក្ខុ ៤ រូប ជាបកតត្តដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេសជាអ្នកគួរដល់ឆន្ទៈដែរ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះជាអ្នកមិនគួរដល់កម្ម ទាំងមិនគួរដល់ឆន្ទៈទេ តែជាជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ) ។ កម្មដែលសង្ឃធ្វើដោយបញ្ចវគ្គ បានដល់ភិក្ខុ ៥ រូប ជាបកតត្តដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេសជាអ្នកគួរដល់ឆន្ទៈ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះជាអ្នកមិនគួរដល់កម្មទាំងជាអ្នកមិនគួរដល់ឆន្ទៈ តែជាជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ) ។ កម្មដែលសង្ឃធ្វើដោយទសវគ្គ បានដល់ភិក្ខុ ១០ រូប ជាបកតត្តដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេសជាអ្នកគួរដល់ឆន្ទៈ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះជាអ្នកមិនគួរដល់កម្មជាអ្នកមិនគួរដល់ឆន្ទៈ តែជាជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ) ។ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ បានដល់ភិក្ខុ ២០ រូបជាបកតត្ត ដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេសគួរដល់ឆន្ទៈ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះជាអ្នកមិនគួរដល់កម្ម ទាំងជាអ្នកមិនគួរដល់ឆន្ទៈ តែជាជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ) ។

បញ្ច វគ្គា ចត្តារិ កម្មានិ វត្ថុវិបត្តិ

(៤៣០) ចត្តារិ កម្មានិ អបលោកនកម្មំ ញត្តិកម្មំ ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ។ ឥមានិ ចត្តារិ កម្មានិ កតីហាការេហិ វិបជ្ជន្តិ ។ ឥមានិ ចត្តារិ កម្មានិ បញ្ចហាការេហិ វិបជ្ជន្តិ វត្ថុតោ វា ញត្តិតោ វា អនុស្សាវនតោ វា សីមតោ វា បរិសតោ វា ។

(៤៣១) កថំ វត្ថុតោ កម្មានិ វិបជ្ជន្តិ ។ បណ្ឌកំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ ថេយ្យសំវាសកំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ តិត្ថិយបក្កន្តកំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ តិរច្ឆានគតំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ មាតុឃាតកំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ បិតុឃាតកំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ អរហន្តឃាតកំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ ភិក្ខុនីទូសកំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ សង្ឃភេទកំ ឧប-

បញ្ចុគ្គ កម្ម ៤ យ៉ាង នឹងវត្ថុវិបត្តិ

(៤៣០) កម្ម ៤ យ៉ាង គឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ ញត្តិចតុត្ថកម្ម ១ ។ កម្មទាំង ៤ នោះ តែងវិបត្តិព្រោះអាការប៉ុន្មាន ។ កម្មទាំង ៤ នេះ តែងវិបត្តិព្រោះអាការ ៥ គឺ វត្ថុ ១ ញត្តិ ១ អនុស្សាវនៈ ១ សីមា ១ បរិសទ្យ ១ ។

(៤៣១) កម្មទាំងឡាយវិបត្តិព្រោះវត្ថុដូចម្តេច ។ (កម្មទាំងឡាយវិបត្តិព្រោះវត្ថុនោះ) គឺសង្ឃញុំាងបណ្ឌកឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាងបុគ្គលជាថេយ្យសំវាស ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាងបុគ្គលដែលចូលពួកតិរ្ថិយ៍ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាងសត្វតិរច្ឆានឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាងមាតុឃាតកបុគ្គល (អ្នកសម្លាប់មាតា) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិជាអធម្មកម្ម ។ សង្ឃញុំាងបិតុឃាតកបុគ្គល (អ្នកសម្លាប់បិតា) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាងអរហន្តឃាតកបុគ្គល (អ្នកសម្លាប់ព្រះអរហន្ត) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាងភិក្ខុនីទូសកៈ (អ្នកប្រទូស្តភិក្ខុនី) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាងសង្ឃភេទកបុគ្គល (អ្នកបំបែកសង្ឃ)

សម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ លោហិតុប្បាទកំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ ឧភតោព្យញ្ជនកំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ ឩនវីសតិវស្សំ បុគ្គលំ ឧបសម្បាទេតិ វត្ថុវិបន្នំ អធម្មកម្មំ ។ ឥមេហិ វត្ថុតោ កម្មានិ វិបជ្ជន្តិ ។

(៤៣២) កតីហិ ញត្តិតោ កម្មានិ វិបជ្ជន្តិ ។ បញ្ចហាការេហិ ញត្តិតោ កម្មានិ វិបជ្ជន្តិ វត្ថុំ ន បរាមសតិ សង្ឃំ ន បរាមសតិ បុគ្គលំ ន បរាមសតិ ញត្តឹ ន បរាមសតិ បច្ឆា វា ញត្តឹ ឋបេតិ ។ ឥមេហិ បញ្ចហាការេហិ ញត្តិតោ កម្មានិ វិបជ្ជន្តិ ។

(៤៣៣) កតីហិ អនុស្សាវនតោ កម្មានិ វិបជ្ជន្តិ ។ បញ្ចហាការេហិ អនុស្សាវនតោ កម្មានិ វិបជ្ជន្តិ វត្ថុំ ន បរាមសតិ សង្ឃំ ន បរាមសតិ បុគ្គលំ ន បរាមសតិ សាវនំ ហាបេតិ អកាលេ វា សាវេតិ ។ ឥមេហិ បញ្ចហាការេហិ អនុស្សាវនតោ កម្មានិ វិបជ្ជន្តិ ។

ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាង លោហិតុប្បាទកបុគ្គល (អ្នកធ្វើព្រះលោហិតព្រះពុទ្ធឲ្យពុះពងឡើង) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាង ឧភតោព្យញ្ជនកបុគ្គលឲ្យទទួលឧបសម្បទា កម្មនេះ ចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ សង្ឃញុំាបុគ្គលមានឆ្នាំថយពី ២០ ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម ។ កម្មទាំងឡាយវិបត្តិព្រោះវត្ថុ យ៉ាងនេះឯង ។

(៤៣២) កម្មវិបត្តិព្រោះញត្តិដូចម្តេច ។ កម្មដែលវិបត្តិព្រោះញត្តិ ដោយអាការ៥ គឺភិក្ខុសូត្រមិនចេញឈ្មោះវត្ថុ ១ មិនចេញឈ្មោះសង្ឃ១ មិនចេញឈ្មោះបុគ្គល ១ មិនតាំងញត្តិ ១ ឬតាំងញត្តិក្រោយ (កម្មវាចា) ១ ។ កម្មវិបត្តិព្រោះញត្តិដោយអាការ ៥ នេះឯង ។

(៤៣៣) កម្មវិបត្តិព្រោះអនុស្សាវនៈដូចម្តេច ។ កម្មវិបត្តិព្រោះអនុស្សាវនៈដោយអាការ ៥ គឺភិក្ខុសូត្រមិនចេញឈ្មោះវត្ថុ ១ មិនចេញឈ្មោះសង្ឃ ១ មិនចេញឈ្មោះបុគ្គល ១ ធ្វើអនុស្សាវនវិធីឲ្យខូច ១ ឬសូត្រក្នុងកាលមិនគួរ ១ កម្មទាំងឡាយវិបត្តិព្រោះអនុស្សាវនៈ ដោយអាការ ៥ នេះឯង ។

បញ្ចវគ្គោ សីមាវិបត្តិ បរិសវិបត្តិ

(៤៣៤) កថំ សីមតោ កម្មានិ វិបជ្ជន្តិ ។ ឯកាទសហាការេហិ សីមតោ កម្មានិ វិបជ្ជន្តិ អតិខុទ្ទកំ សីមំ សម្មន្នតិ អតិមហតឹ សីមំ សម្មន្នតិ ខណ្ឌនិមិត្តំ សីមំ សម្មន្នតិ ឆាយានិមិត្តំ សីមំ សម្មន្នតិ អនិមិត្តំ សីមំ សម្មន្នតិ ពហិសីមេ ឋិតោ សីមំ សម្មន្នតិ នទិយា សីមំ សម្មន្នតិ សមុទ្ទេ សីមំ សម្មន្នតិ ជាតស្សរេ សីមំ សម្មន្នតិ សីមាយ សីមំ សម្ភិន្ទតិ សីមាយ សីមំ អជ្ឈោត្ថរតិ ។ ឥមេហិ ឯកាទសហាការេហិ សីមតោ កម្មានិ វិបជ្ជន្តិ ។

(៤៣៥) កថំ បរិសតោ កម្មានិ វិបជ្ជន្តិ ។ ទ្វាទសហាការេហិ បរិសតោ កម្មានិ វិបជ្ជន្តិ ។ ចតុវគ្គករណេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អនាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ចតុវគ្គករណេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ចតុវគ្គករណេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា

បញ្ចវគ្គ សីមាវិបត្តិនិងបរិសវិបត្តិ

(៤៣៨) កម្មវិបត្តិព្រោះសីមាដូចម្តេច ។ កម្មវិបត្តិព្រោះសីមា ដោយអាការ ១១ គឺសន្មតសីមាតូចពេក ១ សន្មតសីមាធំពេក ១ សន្មតសីមាមាននិមិត្តមិនតគ្នា ១ សន្មតសីមាយកស្រមោលជានិមិត្ត ១ សន្មតសីមាមិនមានអ្វីជានិមិត្ត ១ ឈរខាងក្រៅសីមាសន្មតសីមា ១ សន្មតសីមាក្នុងស្ទឹង ១ សន្មតសីមាក្នុងសមុទ្រ ១ សន្មតសីមាក្នុងជាតស្រះ ១ ទំលាយសីមាដោយសីមា ១ គ្របសីមាដោយសីមា ១ ។ កម្មទាំងឡាយវិបត្តិព្រោះសីមាដោយអាការ ១១ នេះឯង ។

(៤៣៩) កម្មទាំងឡាយវិបត្តិព្រោះបរិសទ្យដូចម្តេច ។ កម្មទាំងឡាយវិបត្តិព្រោះបរិសទ្យដោយអាការ១២ គឺកម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះមិនបានមក ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏មិនបាននាំមក ពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម ១ កម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះបានមកហើយ តែឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈមិនបាននាំមក ទាំងពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម ១ កម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះបានមកហើយ ទាំងឆន្ទៈរបស់ភិក្ខុ

ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ បញ្ចវគ្គករណេ កម្មេ ។ បេ ។ ទសវគ្គករណេ កម្មេ ។ បេ ។ វីសតិវគ្គករណេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អនាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ វីសតិវគ្គករណេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ វីសតិវគ្គករណេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ។ ឥមេហិ ទ្វាទសហាការេហិ បរិសតោ កម្មានិ វិបជ្ជន្តិ ។

(៨៣៦) អបលោកនកម្មំ កតិ ឋានានិ គច្ឆតិ ញត្តិកម្មំ កតិ ឋានានិ គច្ឆតិ ញត្តិទុតិយកម្មំ កតិ ឋានានិ គច្ឆតិ ញត្តិចតុត្ថកម្មំ កតិ ឋានានិ គច្ឆតិ ។

ដែលគួរដល់ឆន្ទៈ ក៏បាននាំមកហើយ តែពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម ១ កម្មដែលសង្ឃធ្វើដោយបញ្ចវគ្គ ។ បេ ។ កម្មដែលសង្ឃធ្វើដោយទសវគ្គ ។ បេ ។ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ភិក្ខុមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះមិនបានមក ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏មិនបាននាំមក ពួកភិក្ខុដែលនៅក្នុងទីចំពោះមុខក៏ឃាត់ហាម ១ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ភិក្ខុមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះក៏បានមកហើយ តែឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏មិនបាននាំមក ពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម ១ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ភិក្ខុមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះបានមកហើយ ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏បាននាំមកហើយ តែពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម ១ ។ កម្មទាំងឡាយវិបត្តិ ព្រោះបរិសទ្យដោយអាការ ១២ នេះឯង ។

(៤៣៦) អបលោកនកម្មដល់នូវឋានៈប៉ុន្មាន ញត្តិកម្មដល់នូវឋានៈប៉ុន្មាន ញត្តិទុតិយកម្មដល់នូវឋានៈប៉ុន្មាន ញត្តិចតុត្ថកម្មដល់នូវឋានៈប៉ុន្មាន ។

អបលោកនកម្មំ បញ្ច ឋានានិ គច្ឆតិ ញត្តិកម្មំ នវ ឋានានិ គច្ឆតិ ញត្តិទុតិយកម្មំ សត្ត ឋានានិ គច្ឆតិ ញត្តិចតុត្ថកម្មំ សត្ត ឋានានិ គច្ឆតិ ។

[៤៣៧] អបលោនកម្មំ កតមានិ បញ្ច ឋានានិ គច្ឆតិ ។ ឱសារណំ និស្សារណំ ភណ្ឌុកម្មំ ព្រហ្មទណ្ឌំ កម្មលក្ខណញ្ញេវ បញ្ចមំ ។ អបលោកនកម្មំ ឥមានិ បញ្ច ឋានានិ គច្ឆតិ ។

[៤៣៨] ញត្តិកម្មំ កតមានិ នវ ឋានានិ គច្ឆតិ ។ ឱសារណំ និស្សារណំ ឧបោសថំ បវារណំ សម្មតឹ ទានំ បដិគ្គហំ បច្ចុក្កឌ្ឍនំ កម្មលក្ខណញ្ញេវ នវមំ ។ ញត្តិកម្មំ ឥមានិ នវ ឋានានិ គច្ឆតិ ។

[៤៣៩] ញត្តិទុតិយកម្មំ កតមានិ សត្ត ឋានានិ គច្ឆតិ ។ ឱសារណំ និស្សារណំ សម្មតឹ ទានំ ឧទ្ធរណំ ទេសនំ កម្មលក្ខណញ្ញេវ សត្តមំ ។ ញត្តិទុតិយកម្មំ ឥមានិ សត្ត ឋានានិ គច្ឆតិ ។

[៤៤០] ញត្តិចតុត្ថកម្មំ កតមានិ សត្ត ឋានានិ គច្ឆតិ ។ ឱសារណំ និស្សារណំ សម្មតឹ ទានំ និគ្គហំ

អបលោកនកម្មដល់នូវឋានៈ ៥ ញត្តិកម្មដល់នូវឋានៈ ៩ ញត្តិទុតិយកម្មដល់នូវឋានៈ ៧ ញត្តិចតុត្ថកម្មដល់នូវឋានៈ ៧ ។

(៤៣៨) អបលោកនកម្មដល់នូវឋានៈ ៥ ដូចម្តេច ។ ឋានៈ ៥ គឺ ឱសារណា ១ និស្សារណា ១ ភណ្ឌុកម្ម ១ ព្រហ្មទណ្ឌ ១ ជាគំរប់ ៥ នឹងកម្មលក្ខណៈ ។ អបលោកនកម្មដល់នូវឋានៈ ៥ នេះឯង ។

(៤៣៨) ញត្តិកម្មដល់នូវឋានៈ ៩ ដូចម្តេច ។ ឋានៈ ៩ គឺ ឱសារណា ១ និស្សារណា ១ ឧបោសថ ១ បវារណា ១ សម្មតិ គឺសន្មតខ្លួនជាអ្នកសួរ ឆ្លើយ ឬសន្មតបុគ្គល សន្មតវត្ថុ ១ ការឲ្យបាត្រនឹងចីវរជាដើម ១ ការទទួលអាបត្តិ ១ ការបង្ខិតថ្ងៃបវារណាទៅខាងមុខ ១ ជាគំរប់ ៩ នឹងកម្មលក្ខណៈ ។ ញត្តិកម្មដល់នូវឋានៈទាំង ៩ នេះឯង ។

(៤៣៩) ញត្តិទុតិយកម្មដល់នូវឋានៈ ៧ ដូចម្តេច ។ ឋានៈ ៧ គឺ ឱសារណា ១ និស្សារណា ១ សម្មតិ ១ ការឲ្យបាត្រនឹងចីវរជាដើម ១ ការដោះកឋិន ១ ការសំដែង គឺសូត្រសំដែងទីដីសង់កុដិ វិហារជាដើម ១ ជាគំរប់ ៧ នឹងកម្មលក្ខណៈ ។ ញត្តិទុតិយកម្មដល់នូវឋានៈទាំង ៧ នេះឯង ។

(៤៤០) ញត្តិចតុត្ថកម្មដល់នូវឋានៈ ៧ ដូចម្តេច ។ ឋានៈ ៧ គឺឱសារណា ១ និស្សារណា ១ សម្មតិ ១ ការឲ្យបាត្រនឹងចីវរជាដើម ១ និគ្គហៈ

សមនុភាសនំ កម្មលក្ខណញ្ញេវ សត្តមំ ។ ញត្តិចតុត្ថកម្មំ ឥមានិ សត្ត ឋានានិ គច្ឆតិ ។

(៤៤១) ចតុវគ្គករណេ កម្មេ ចត្តារោ ភិក្ខូ បកតត្តា កម្មប្បត្តា អវសេសា បកតត្តា ឆន្ទារហា យស្ស សង្ឃោ កម្មំ ករោតិ សោ នេវ កម្មប្បត្តោ នបិ ឆន្ទារហោ អបិច កម្មារហោ ។ បញ្ចវគ្គករណេ កម្មេ ។បេ។ ទសវគ្គករណេ កម្មេ ។បេ។ វីសតិវគ្គករណេ កម្មេ វីសតិ ភិក្ខូ បកតត្តា កម្មប្បត្តា អវសេសា បកតត្តា ឆន្ទារហា យស្ស សង្ឃោ កម្មំ ករោតិ សោ នេវ កម្មប្បត្តោ នបិ ឆន្ទារហោ អបិច កម្មារហោ ។

កម្មវគ្គោ និដ្ឋិតោ បឋមោ ។

(៤៤២) ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន

គឺការសង្កត់សង្កិនដោយទាញមកដាក់ក្នុងមូលាបត្តិ ១ សមនុភាសនកម្ម ១ ជាគំរប់ ៧ នឹងកម្មលក្ខណៈ ។ ញត្តិចតុត្ថកម្មដល់នូវឋានៈទាំង ៧ នេះឯង ។

[៤៤១] កម្មដែលសង្ឃធ្វើដោយចតុវគ្គ បានដល់ភិក្ខុ ៤ រូបជាបកតត្ត ដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេសគួរដល់ឆន្ទៈ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះជាអ្នកមិនគួរដល់កម្ម ទាំងជាអ្នកមិនគួរដល់ឆន្ទៈ តែជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ) ។ កម្មដែលសង្ឃធ្វើដោយបញ្ចវគ្គ ។ បេ ។ កម្មដែលសង្ឃធ្វើដោយទសវគ្គ ។ បេ ។ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ បានដល់ភិក្ខុ ២០ រូបជាបកតត្ត ដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេសជាអ្នកគួរដល់ឆន្ទៈ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះជាអ្នកមិនគួរដល់កម្ម ទាំងជាអ្នកមិនគួរដល់ឆន្ទៈ តែថាជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ) ។

ចប់ កម្មវគ្គជាបឋម ។

[៤៤២] ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីសេចក្តីល្អដល់សង្ឃ ១ ដើម្បីសេចក្តីសប្បាយដល់សង្ឃ ១ ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាច

សាវកានំ សិក្ខាបទំ បញ្ញត្តំ ទុម្មង្កូនំ បុគ្គលានំ និគ្គ-
ហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ។ ឥមេ ទ្វេ
អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ
បញ្ញត្តំ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ
សិក្ខាបទំ បញ្ញត្តំ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ
សម្បរាយិកានំ អាសវានំ បដិឃាតាយ ។ ឥមេ ទ្វេ
អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ
បញ្ញត្តំ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ
សិក្ខាបទំ បញ្ញត្តំ ទិដ្ឋធម្មិកានំ វេរានំ សំវរាយ សម្ប-
រាយិកានំ វេរានំ បដិឃាតាយ ។ ឥមេ ទ្វេ អត្ថវសេ
បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។
ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ
បញ្ញត្តំ ទិដ្ឋធម្មិកានំ វជ្ជានំ សំវរាយ សម្បរាយិកានំ
វជ្ជានំ បដិឃាតាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថា-
គតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ ទ្វេ អត្ថវ-
សេ បដិច្ច តថាគតេន សាវកានំ សិកាបទំ បញ្ញត្តំ

ប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីសង្កត់សង្កិនពួកបុគ្គលដែលមិនមានអៀនខ្មាស ១ គឺដើម្បីនៅសប្បាយដល់ពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ១ ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺ បញ្ញត្តដើម្បីរក្សាអាសវៈទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមអាសវៈទាំងឡាយក្នុងបរលោក ១ ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីរក្សានូវពៀរក្នុងបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមនូវពៀរក្នុងបរលោក ១ ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័កព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ ប្រការ គឺ បញ្ញត្តដើម្បីរក្សាទោសក្នុងបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមទោសក្នុងបរលោក ១ ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ

ទិដ្ឋធម្មិកានំ ភយានំ សំវរាយ សម្បរាយិកានំ ភយានំ បដិឃាតាយ ។ បេ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ទិដ្ឋធម្មិកានំ អកុសលានំ ធម្មានំ សំវរាយ សម្បរាយិកានំ អកុសលានំ ធម្មានំ បដិឃាតាយ ។ បេ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ គិហីនំ អនុកម្បាយ បាបិច្ឆានំ បក្ខុបច្ឆេទាយ ។ បេ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ ។ បេ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ

គឺបញ្ញត្តដើម្បីរាំងនូវភ័យក្នុងបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមនូវភ័យ ក្នុងបរលោក ១ ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីរាំងអកុសលធម៌ក្នុងបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមអកុសលធម៌ក្នុងបរលោក ១ ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគតទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺដើម្បីអនុគ្រោះដល់ពួកគ្រហស្ថ ដើម្បីផ្តាច់ផ្តិលបក្ខពួករបស់បុគ្គលមានសេចក្តីប្រាថ្នាដ៏លាមក ១ ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគតទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីសេចក្តីជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លា ១ ដើម្បីញ៉ាំងជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ

សទ្ធម្មដ្ឋិតិយោ វិនយានុគ្គហាយ ។ ឥមេ ទេ្វ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តន្តិ ។

អត្ថវសវគ្គោ និដ្ឋិតោ ទុតិយោ ។

[៤៤៣] ទេ្វ អត្ថវសេ បដិច្ច តថាគតេន សាវកានំ បាតិមោក្ខំ បញ្ញត្តំ ។បេ។ បាតិមោក្ខុទ្ទេសោ បញ្ញត្តោ បាតិមោក្ខដ្ឋបនំ បញ្ញត្តំ បវារណា បញ្ញត្តា បវារណាដ្ឋបនំ បញ្ញត្តំ តជ្ជនីយកម្មំ បញ្ញត្តំ និយស្សកម្មំ បញ្ញត្តំ បព្វាជនីយកម្មំ បញ្ញត្តំ បដិសារណីយកម្មំ បញ្ញត្តំ ឧក្ខេបនីយកម្មំ បញ្ញត្តំ បរិវាសទានំ បញ្ញត្តំ មូលាយ បដិកស្សនា បញ្ញត្តា មានត្តទានំ បញ្ញត្តំ អព្ភានំ បញ្ញត្តំ ឱសារណីយំ បញ្ញត្តំ និស្សារណីយំ បញ្ញត្តំ ឧបសម្បទា បញ្ញត្តា អបលោកនកម្មំ បញ្ញត្តំ ញត្តិកម្មំ បញ្ញត្តំ ញត្តិទុតិយកម្មំ បញ្ញត្តំ ញត្តិចតុត្ថកម្មំ បញ្ញត្តន្តិ ។

បញ្ញត្តវគ្គោ និដ្ឋិតោ តតិយោ ។

[៤៤៤] អបញ្ញត្តេ បញ្ញត្តំ បញ្ញត្តេ អនុបញ្ញត្តំ សម្មុខាវិនយោ បញ្ញត្តោ សតិវិនយោ បញ្ញត្តោ អមូឡ្ហវិ-

គឺបញ្ញត្តដើម្បីញុំាងព្រះសទ្ធម្មឲ្យឋិតថេរ ១ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ១ ។ ព្រះតថាគតទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។

ចប់ អត្ថវសវគ្គ ជាគំរប់ ២ ។

[៤៤៣] ព្រះតថាគត ទ្រង់បញ្ញត្តបាតិមោក្ខដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ ។ បេ ។ ព្រះតថាគត ទ្រង់បញ្ញត្តបាតិមោក្ខុទ្ទេស បញ្ញត្តនូវការបញ្ឈប់បាតិមោក្ខ បញ្ញត្តបវារណា បញ្ញត្តនូវការបញ្ឈប់បវារណា បញ្ញត្តតជ្ជនីយកម្ម បញ្ញត្តនិយស្សកម្ម បញ្ញត្តបព្វាជនីយកម្ម បញ្ញត្តបដិសារណីយកម្ម បញ្ញត្តឧក្ខេបនីយកម្ម បញ្ញត្តការឲ្យបរិវាស បញ្ញត្តមូលាយបដិកស្សនៈ គឺការទាញភិក្ខុមកដាក់ក្នុងមូលាបត្តិ បញ្ញត្តការឲ្យមានត្ត បញ្ញត្តអព្ភាន បញ្ញត្តឱសារណីយកម្ម បញ្ញត្តនិស្សារណីយកម្ម បញ្ញត្តឧបសម្បទា បញ្ញត្តអបលោកនកម្ម បញ្ញត្តញត្តិកម្ម បញ្ញត្តញត្តិទុតិយកម្ម បញ្ញត្តញត្តិចតុត្ថកម្ម ។

ចប់ បញ្ញត្តិវគ្គ ជាគំរប់ ៣ ។

[៤៤៤] កាលសិក្ខាបទដែលអ្នកណាមួយ មិនទាន់បានបញ្ញត្តទុក ព្រះតថាគតទ្រង់បញ្ញត្តសិក្ខាបទឡើង សិក្ខាបទដែលព្រះអង្គបញ្ញត្តហើយ ទ្រង់បញ្ញត្តថែមទៀត ទ្រង់បញ្ញត្តសម្មុខាវិន័យ បញ្ញត្តសតិវិន័យ បញ្ញត្ត

នយោ បញ្ញត្តោ បដិញ្ញាតករណំ បញ្ញត្តំ យេភុយ្យសិកា បញ្ញត្តា តស្ស បាបិយសិកា បញ្ញត្តា តិណវត្ថារកោ បញ្ញត្តោ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ

អមូឡ្ហវិន័យ បញ្ញត្តបដិញ្ញាតករណៈ បញ្ញត្តយេភុយ្យសិកា បញ្ញត្តតស្ស-បាបិយសិកា បញ្ញត្តតិណវត្ថារកៈ (ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ) គឺដើម្បីសេចក្តីល្អដល់សង្ឃ ១ ដើម្បីសេចក្តីសប្បាយដល់សង្ឃ ១ ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័កព្រោះអា-ស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ៗ ព្រះតថាគតទ្រង់បញ្ញត្តតិ-ណវត្ថារកៈដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺ បញ្ញត្តដើម្បីសង្កត់សង្កិនពួកបុគ្គល ដែលមិនមានខ្មាស ១ ដើម្បីនៅសប្បាយដល់ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ១ ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីពារាំងអាសវៈ ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមអាសវៈទាំងឡាយក្នុងបរលោក ១ ៗ ព្រះតថាគតទ្រង់បញ្ញត្តតិវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បី

ទិដ្ឋធម្មិកានំ វេរានំ សំវរាយ សម្បរាយិកានំ វេរានំ បដិឃាតាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ទិដ្ឋធម្មិកានំ វជ្ជានំ សំវរាយ សម្បរាយិកានំ វជ្ជានំ បដិឃាតាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ទិដ្ឋធម្មិកានំ ភយានំ សំវរាយ សម្បរាយិកានំ ភយានំ បដិឃាតាយ ។ ឥមេ ទ្វេ អវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ទិដ្ឋធម្មិកានំ អកុសលានំ ធម្មានំ សំវរាយ សម្បរាយិកានំ អកុសលានំ ធម្មានំ បដិឃាតាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ តិណវត្ថារកោ បញ្ញត្តោ គិហីនំ អនុកម្បាយ

រាំងពៀរក្នុងបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមពៀរក្នុងបរលោក ១ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីរាំងទោសក្នុងបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមទោសក្នុងបរលោក ១ ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីរាំងភ័យក្នុងបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមភ័យក្នុងបរលោក ១ ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវ័កព្រោះអាស្រ័យអំណាចប្រយោជន៍ ២ប្រការនេះឯង ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរាំងអកុសលធម៌ក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមអកុសលធម៌ក្នុងបរលោក១ ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង ៗ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីអនុគ្រោះដល់ពួកគ្រហស្ថ ១

បាបិច្ឆានំ បក្ខុបច្ឆេទាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ ឥមេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តន្តិ ។

បញ្ញត្តវគ្គោ និដ្ឋិតោ បឋមោ ។

[៤៤៨] ទស សង្គហា វត្ថុសង្គហោ វិបត្តិសង្គហោ អាបត្តិសង្គហោ និទានសង្គហោ បុគ្គលសង្គហោ ខន្ធសង្គហោ សមុដ្ឋានសង្គហោ អធិករណសង្គហោ សមថសង្គហោ ។

ដើម្បីផ្តាច់ផ្តិលនូវបក្ខពួកនៃបុគ្គលមានសេចក្តីប្រាថ្នាដ៏លាមក ១ ។ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវកព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីសេចក្តីជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ១ ដើម្បីញុំាងពួកជនដែលជ្រះថ្លាស្រាប់ហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ។ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺបញ្ញត្តដើម្បីញុំាងព្រះសទ្ធម្មឲ្យឋិតថេរ ១ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ១ ។ ព្រះតថាគតទ្រង់បញ្ញត្តតិណវត្ថារកៈដល់ពួកសាវក ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការនេះឯង ។

ចប់ បញ្ញត្តវគ្គ ជាគំរប់ ៤ ។

(៤៤៩) សង្គហៈទាំងឡាយ ៩ គឺវត្ថុសង្គហៈ ១ វិបត្តិសង្គហៈ ១ អាបត្តិសង្គហៈ ១ និទានសង្គហៈ ១ បុគ្គលសង្គហៈ ១ ខន្ធសង្គហៈ ១ សមុដ្ឋានសង្គហៈ ១ អធិករណសង្គហៈ ១ សមថសង្គហៈ ១ ។

[៤៤៦] អធិករណេ សមុប្បន្នេ សចេ ឧភោ អត្ថប្បច្ចត្ថិកា[1] អាគច្ឆន្តិ ឧភិន្នម្បិ វត្ថុំ[2] អារោចាបេតព្វំ ឧភិន្នម្បិ វត្ថុំ អារោចាបេត្វា ឧភិន្នម្បិ បដិញ្ញា សោតព្វា ឧភិន្នម្បិ បដិញ្ញំ សុត្វា ឧភោបិ វត្តព្វា អម្ហាកំ ឥមស្មឹ អធិករណេ វូបសមិតេ[3] ឧភោបិ តុដ្ឋា ភវិស្សថាតិ សចេ អាហំសុ ឧភោបិ តុដ្ឋា ភវិស្សាមាតិ សង្ឃេន តំ អធិករណំ បដិច្ឆិតព្វំ ។ សចេ អលជ្ជុស្សន្នា ហោតិ បរិសា ឧព្វាហិកាយ វូបសមេតព្វំ ។ សចេ ពាលុស្សន្នា ហោតិ បរិសា វិនយធរោ បរិយេសិតព្វោ ។ យេន ធម្មេន យេន វិនយេន យេន សត្ថុសាសនេន តំ អធិករណំ វូបសម្មតិ តថា តំ អធិករណំ វូបសមេតព្វំ ។

[៤៤៧] វត្ថុំ[4] ជានិតព្វំ គោត្តំ ជានិតព្វំ នាមំ ជានិតព្វំ អាបត្តិ ជានិតព្វា ។ មេថុនធម្មោតិ វត្ថុញ្ចេវ[5] គោត្តញ្ច ។ បារាជិកន្តិ នាមញ្ចេវ អាបត្តិ ច ។ អទិន្នាទានន្តិ វត្ថុញ្ចេវ គោត្តញ្ច ។ បារាជិកន្តិ នាមញ្ចេវ

---

១ ឱ. ម. អត្ថប្បច្ចត្ថិកា។ ២ ឱ. ម. វត្ថុ ។ ៣ ម. វូបសមេថ ៤ ឱ. ម. វត្ថុ ។ ៥ ឱ. ម. វត្ថុ ចេវ ។

បញ្ចវគ្គ ត្រូវឲ្យប្រាប់រឿងរ៉ាវ ត្រូវដឹងវត្ថុជាដើម

(៤៤៦) កាល បើអធិករណ៍កើតឡើងហើយ បើភិក្ខុទាំងពីររូប ដែលជាសត្រូវនឹងគ្នាមកដល់ សង្ឃត្រូវឲ្យលោកទាំងពីររូប (នោះ) ប្រាប់រឿងរ៉ាវ លុះឲ្យលោកទាំងពីររូបប្រាប់រឿងរ៉ាវហើយ សង្ឃត្រូវស្តាប់ពាក្យប្តេជ្ញារបស់ភិក្ខុទាំងពីរ (នោះ) លុះស្តាប់ពាក្យប្តេជ្ញារបស់ពួកភិក្ខុទាំងពីររូប (នោះ) ហើយ សង្ឃត្រូវប្រាប់លោកទាំងពីររូប (នោះ) ថា កាលបើអធិករណ៍នេះយើងបានរម្ងាប់រួចហើយ លោកទាំងពីររូបនឹងត្រេកអរ (ឬទេ) បើភិក្ខុទាំងពីររូបពោលថា យើងទាំងពីររូបនឹងទទួលត្រេកអរ សង្ឃត្រូវទទួលអធិករណ៍នោះចុះ ។ បើបរិសទ្យជាពួកក្រាស់ដោយអលជ្ជី សង្ឃត្រូវរម្ងាប់អធិករណ៍នោះ ដោយឧព្វាហិកា គឺត្រូវអបលោកហើយសឹមសន្មត ឬសន្មតដោយទុតិយកម្មវាចា ។ បើបរិសទ្យជាពួកក្រាស់ដោយលជ្ជី សង្ឃត្រូវស្វែងរកវិន័យធរ ។ អធិករណ៍នោះតែងរម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាណា សង្ឃត្រូវរម្ងាប់អធិករណ៍នោះ តាមទំនងនោះចុះ ។

(៤៤៧) ភិក្ខុត្រូវស្គាល់វត្ថុ ត្រូវស្គាល់គោត្រ ត្រូវស្គាល់នាម ត្រូវស្គាល់អាបត្តិ ។ ត្រង់ពាក្យថា មេថុនធម្ម បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា បារាជិក បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា អទិន្នាទាន បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា បារាជិក បានដល់នាម

អាបត្តិ ច ។ មនុស្សវិគ្គហោតិ វត្ថុញ្ញេវ គោត្តញ្ច ។
បារាជិកន្តិ នាមញ្ញេវ អាបត្តិ ច ។ ឧត្តរិមនុស្សធម្មោតិ
វត្ថុញ្ញេវ គោត្តញ្ច ។ បារាជិកន្តិ នាមញ្ញេវ អាបត្តិ ច ។
សុក្កវិស្សដ្ឋីតិ វត្ថុញ្ញេវ គោត្តញ្ច ។ សង្ឃាទិសេសោតិ
នាមញ្ញេវ អាបត្តិ ច ។ កាយសំសគ្គោតិ វត្ថុញ្ញេវ
គោត្តញ្ច ។ សង្ឃាទិសេសោតិ នាមញ្ញេវ អាបត្តិ ច ។
ទុដ្ឋុល្លវាចាតិ វត្ថុញ្ញេវ គោត្តញ្ច ។ សង្ឃាទិសេសោតិ
នាមញ្ញេវ អាបត្តិ ច ។ អត្តកាមន្តិ វត្ថុញ្ញេវ គោត្តញ្ច ។
សង្ឃាទិសេសោតិ នាមញ្ញេវ អាបត្តិ ច ។ សញ្ចរិត្តន្តិ
វត្ថុញ្ញេវ គោត្តញ្ច ។ សង្ឃាទិសេសោតិ នាមញ្ញេវ អា-
បត្តិ ច ។ សញ្ញាចិកាយ កុដឹ ការាបនន្តិ វត្ថុញ្ញេវ
គោត្តញ្ច ។ សង្ឃាទិសេសោតិ នាមញ្ញេវ អាបត្តិ ច ។
មហល្លកំ វិហារំ ការាបនន្តិ វត្ថុញ្ញេវ គោត្តញ្ច ។ សង្ឃា-
ទិសេសោតិ នាមញ្ញេវ អាបត្តិ ច ។ ភិក្ខុំ អមូលកេន
បារាជិកេន ធម្មេន អនុទ្ធំសនន្តិ វត្ថុញ្ញេវ គោត្តញ្ច ។

ផង អាបត្តិផង ។ ត្រង់ពាក្យថា មនុស្សវិគ្គហៈ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា បារាជិក បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា ឧត្តរិមនុស្សធម្ម បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា បារាជិក បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា សុក្កវិសដ្ឋិ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា កាយសំសគ្គៈ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា ទុដ្ឋុល្លវាចៈ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា អត្តកាមៈ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា សញ្ចរិត្តៈ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា ភិក្ខុធ្វើកុដិដោយការសូមគ្រឿងឧបករណ៍គេមកដោយខ្លួនឯង បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា ភិក្ខុឲ្យគេធ្វើកុដិធំ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា ភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិកមិនមានមូល បានដល់វត្ថុផង គោត្រផង ។

បញ្ច វគ្គា នាមញ្ចេវ អាបត្តិ ជាតិអាទីនិ

សង្ឃាទិសេសោតិ នាមញ្ចេវ អាបត្តិ ច ។ ភិក្ខុំ អញ្ញ-
ភាគិយស្ស អធិករណស្ស កញ្ចិ ទេសំ លេសមត្តំ
ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសនន្តិ វត្ថុញ្ចេវ
គោត្តញ្ច ។ សង្ឃាទិសេសោតិ នាមញ្ចេវ អាបត្តិ ច ។
សង្ឃភេទកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនា-
យ នប្បដិនិស្សជ្ជនន្តិ វត្ថុញ្ចេវ គោត្តញ្ច ។ សង្ឃាទិសេ-
សោតិ នាមញ្ចេវ អាបត្តិ ច ។ ភេទកានុវត្តកានំ ភិក្ខូ-
នំ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនន្តិ
វត្ថុញ្ចេវ គោត្តញ្ច ។ សង្ឃាទិសេសោតិ នាមញ្ចេវ អាបត្តិ
ច ។ ទុព្ពចស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ
នប្បដិនិស្សជ្ជនន្តិ វត្ថុញ្ចេវ គោត្តញ្ច ។ សង្ឃាទិសេសោ-
តិ នាមញ្ចេវ អាបត្តិ ច ។ កុលទូសកស្ស ភិក្ខុនោ
យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជនន្តិ វត្ថុញ្ចេវ
គោត្តញ្ច ។ សង្ឃាទិសេសោតិ នាមញ្ចេវ អាបត្តិ ច

បញ្ញវត្ត នាមផង អាបត្តិផង ជាដើម

ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា ភិក្ខុអាស្រ័យនូវគ្រឿងអាងបន្តិចបន្តួចនៃអធិករណ៍ ជាចំណែកដទៃឡើយជាលេសហើយចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិក បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យ ភិក្ខុបំបែកសង្ឃ សង្ឃបានសូត្រសមនុភាសនវិធីជាគំរប់ ៣ ដងហើយនៅតែមិនលះបង់ (ទិដ្ឋិអាក្រក់នោះ) ចេញ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា ពួកភិក្ខុជាអ្នកប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃ សង្ឃបានសូត្រសមនុភាសនវិធីជាគំរប់ ៣ ដងហើយ នៅតែមិនលះបង់ (ទិដ្ឋិអាក្រក់នោះ) ចេញ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា ភិក្ខុដែលគេប្រដៅបានដោយក្រ សង្ឃបានសូត្រសមនុភាសនវិធីជាគំរប់ ៣ ដងហើយ នៅតែមិនលះបង់ (ទិដ្ឋិអាក្រក់នោះ ចេញ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង ។ ត្រង់ពាក្យថា ភិក្ខុអ្នកប្រទូស្តត្រកូល សង្ឃបានសូត្រសមនុភាសនវិធីជាគំរប់ ៣ ដងហើយនៅតែមិនលះបង់ (ទិដ្ឋិអាក្រក់នោះ) ចេញ បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង

។ បេ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណន្តិ វត្ថុញ្ចេវ គោត្តញ្ច ។ ទុក្កដន្តិ នាមញ្ចេវ អាបត្តិ ចាតិ ។

នវសង្គហវគ្គោ និដ្ឋិតោ បញ្ចមោ ។

តស្សុទ្ទានំ

[៤៤៨] អបលោកនំ ញត្តិ ច[១]
ទុតិយំ ចតុត្ថេន ច
វត្ថុ ញត្តិ អនុស្សាវនំ
សីមាបរិសមេវ ច
សម្មុខា បដិបុច្ឆា ច
បដិញ្ញា វិនយារហោ
វត្ថុសង្ឃបុគ្គលញ្ច
ញត្តី បច្ឆា ញត្តី បុរេ

---

១ ឱ. អបលោកនញ្ញត្តិ ច ។

។ បេ ។ ត្រង់ពាក្យថា ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោបង់ទុច្ចារៈក្តី បស្សាវៈក្តី ស្តោះទឹកមាត់ក្តី ក្នុងទឹក បានដល់វត្ថុផង គោត្រផង ។ ត្រង់ពាក្យថា ទុក្កដ បានដល់នាមផង អាបត្តិផង ។

ចប់ នវសង្គហវគ្គ ជាគំរប់ ៨ ។

ឧទ្ទាន គឺបញ្ជីរឿងនៃបញ្ចវគ្គនោះដូច្នេះ

(៤៤៨) (និយាយពីកម្ម ៤ យ៉ាង) គឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ ញត្តិចតុត្ថកម្ម ១ (និងវិបត្តិ ៥ យ៉ាង) គឺវត្ថុវិបត្តិ ១ ញត្តិវិបត្តិ ១ អនុស្សាវនវិបត្តិ ១ សីមាវិបត្តិ ១ បរិសវិបត្តិ ១ (ឯវត្ថុវិបត្តិនោះ) គឺសង្ឃត្រូវធ្វើកម្មក្នុងទីចំពោះមុខ តែធ្វើក្នុងទីកំបាំងមុខវិញ សង្ឃគួរសាកសួរ តែធ្វើមិនសាកសួរវិញ សង្ឃគួរធ្វើកម្មតាមប្តេជ្ញា តែធ្វើមិនតាមពាក្យប្តេជ្ញាវិញ សង្ឃធ្វើកម្មដល់ភិក្ខុដែលគួរដល់សតិវិន័យ (ជាដើមញត្តិវិបត្តិនោះ) គឺសូត្រញត្តិមិនចេញឈ្មោះវត្ថុ ១ មិនចេញឈ្មោះសង្ឃ ១ មិនចេញឈ្មោះបុគ្គល១ មិនតាំងញត្តិ ១ ឬតាំងញត្តិក្រោយកម្មវាចា ១ (អនុស្សាវន-

បញ្ចវគ្គោ ឧទ្ទានគាថា

វត្ថុសង្ឃបុគ្គលញ្ច
សាវនំ ច អក្កោសិតំ (១)
អតិខុទ្ទា (២) មហន្តា ច
ខណ្ឌាដ្ឋាយានិមិត្តកា
ពហិនទីសមុទ្ទេ ច
ជាតស្សរេ ច ភិន្ទតិ
អជ្ឈោត្ថរតិ សីមាយ
ចតុប្បញ្ចវគ្គិកា
ទស វីសតិវគ្គា ច
អនាហដា ច អាហដា
កម្មប្បត្តា ឆន្ទារហា
កម្មារហា ច បុគ្គលា
អបលោកនំ បញ្ញត្តានំ
ញត្តិ ច នវ ហានិកា
ញត្តិទុតិយំ សត្តដ្ឋានំ
ចតុត្ថា សត្ត ហានិកា
សុទ្ធ ជាសុ (៣) ទុម្មង្គុលំ

---

១ ឱ. ម. សាវនំ អកោសេន ច ។ ២ ឱ. ម. អតិខុទ្ទកា ។ ៣ ឱ. ម. ឆាសុ ច ។

វិបត្តិនោះ) គឺសូត្រមិនបញ្ចេញឈ្មោះវត្ថុ ១ មិនបញ្ចេញឈ្មោះសង្ឃ ១ មិនបញ្ចេញឈ្មោះបុគ្គល ១ ធ្វើអនុស្សាវនាវិធីឲ្យខូច ១ សូត្រក្នុងកាលមិនគួរ ១ (សីមាវិបត្តិនោះ) គឺសីមាតូចពេក ១ សីមាធំពេក ១ សីមាមាននិមិត្តមិនតគ្នា ១ យកស្រមោលជានិមិត្ត ១ សីមាមិនមានអ្វីជានិមិត្ត ១ ឈរខាងក្រៅសីមាសន្មត ១ សន្មតសីមាក្នុងស្ទឹង ១ សន្មតសីមាក្នុងសមុទ្រ ១ សន្មតសីមាក្នុងជាតស្រះ ១ ចំលាយសីមា ដោយសីមា ១ គ្របសីមាដោយសីមា ១ (បរិសវិបត្តិនោះ) គឺកម្មដែលសង្ឃធ្វើដោយចតុវគ្គក្តី បញ្ចវគ្គក្តី ទសវគ្គក្តី វីសតិវគ្គក្តី ភិក្ខុទាំងឡាយជាអ្នកគួរដល់កម្មមិនបានមក ទាំងមិនបាននាំឆន្ទៈមក១ ភិក្ខុទាំងឡាយជាអ្នកគួរដល់កម្មបានមកហើយ ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈក៏បាននាំមកហើយ តែថាជាបុគ្គលដែលគួរដល់កម្ម ១ អបលោកនកម្មដល់នូវឋានៈ ៥ ញត្តិកម្មដល់នូវឋានៈ ៩ ញត្តិទុតិយកម្មដល់នូវឋានៈ ៧ ញត្តិចតុត្ថកម្មដល់នូវឋានៈ ៧ ទ្រង់បញ្ញត្តដើម្បីសេចក្តីល្អដល់សង្ឃ ដើម្បីសេចក្តីសប្បាយដល់សង្ឃ ដើម្បីសង្កត់សង្កិនបុគ្គលដែលឥតខ្មាស

បេសលា ចាបិ អាសវា
វេរវជ្ជភយញ្ចេវ
អកុសលញ្ច គីហិនំ (១)
ចាបិដ្ឋា អប្បសន្នានំ
បសន្នាធម្មឋបនា
វិនយានុគ្គហា ចេវ
បាតិមោក្ខុទ្ទេសេន ច
បាតិមោក្ខញ្ច ឋបនា
បវារណញ្ច ឋបនំ
តជ្ជនីយា និយស្សញ្ច
បព្វាជប្បដិសារណី (២)
ឧក្ខេបនបរិវាសំ
មូលំ មានត្តព្ភានំ (៣)
ឱសារណំ និស្សារណំ
តថេវ ឧបសម្បទា
អបលោកនំ ញត្តិ ច (៤)

---

១ ឱ. ម. អកុសលំ គីហីនញ្ច ។ ២ ឱ. ម. បព្វាជនីយប្បដិសារណី ។
៣ ឱ. ប. មូលមានត្តអព្ភានំ ។ ៤ អបលោកនញ្ញត្តិ ច ។

ដើម្បីនៅសប្បាយ ដល់ពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ដើម្បីកំពិននូវអាសវធម៌ ដើម្បីឃាត់ហាមនូវអាសវធម៌ ដើម្បីកំពិនពៀរ ទោស ភ័យ អកុសលធម៌ ដើម្បីអនុគ្រោះដល់ពួកគ្រហស្ថ ដើម្បីផ្តាច់ផ្តិលនូវបក្សពួកនៃបុគ្គល ដែលមានសេចក្តីប្រាថ្នាលាមក ដើម្បីសេចក្តីជ្រះថ្លានៃពួកជនដែលមិនទាន់ជ្រះថ្លា ដើម្បីធ្វើជនដែលជ្រះថ្លាស្រាប់ហើយឲ្យរឹតតែជ្រះថ្លាឡើង ដើម្បីធ្វើព្រះសទ្ធម្មឲ្យឋិតថេរ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ទ្រង់បញ្ញត្តបាតិមោក្ខ បាតិមោក្ខុទ្ទេស ការបញ្ឈប់បាតិមោក្ខ បវារណា ការបញ្ឈប់នូវបវារណា តជ្ជនីយ-កម្ម និយស្សកម្ម បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេ-បនីយកម្ម ការឲ្យបរិវាស មូលាយបដិកស្សនៈ គឺការទាញភិក្ខុមកដាក់ក្នុងមូលាបត្តិ ការឲ្យមានត្ត អព្ភានកម្ម ឧសារណា-កម្ម និស្សារណាកម្ម ឧបសម្បទាកម្ម អបលោកនកម្ម ញត្តិកម្ម

បញ្ចវគ្គ ឧទ្ទានគាថា

ទុតិយញ្ច ចតុត្ថកំ
អប្បញ្ញត្តេ ទុប្បញ្ញត្តំ
សម្មុខាវិនយោ សតិ
អមូឡ្ហបដិយេភុយ្យ
បាបិយតិណវត្ថារកំ
វត្ថុំ (១) វិបត្តិ អាបត្តិ
និទានំ បុគ្គលេន ច
ខន្ធា ចេវ សមុដ្ឋានា
អធិករណមេវ ច
សមថា សង្គហា ចេវ
នាមា អាបត្តិកា (២) ចាតិ ។

បរិវារោ និដ្ឋិតោ ។

---

១ ឱ. ម. វត្ថុ ។ ២ នាមអាបត្តិកា ។

បញ្ចវគ្គ ឧទ្ទានគាថា

ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម កាលសិក្ខាបទដែលអ្នកណាមួយមិនទាន់បញ្ញត្តទុក ព្រះអង្គទ្រង់បញ្ញត្តឡើង សិក្ខាបទដែលព្រះអង្គបញ្ញត្តហើយ ទ្រង់បញ្ញត្តថែមទៀត ទ្រង់បញ្ញត្តសម្មុខាវិន័យ សតិវិន័យ អមូឡ្ហវិន័យះ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា តិណវត្ថារកៈ សង្គហៈ ៩ យ៉ាង គឺវត្ថុសង្គហៈ វិបត្តិសង្គហៈ អាបត្តិសង្គហៈ និទានសង្គហៈ បុគ្គលសង្គហៈ ខន្ធសង្គហៈ សមុដ្ឋានសង្គហៈ អធិករណសង្គហៈ សមថសង្គហៈ (ម្យ៉ាងទៀត) ភិក្ខុត្រូវស្គាល់នាម ១ ត្រូវស្គាល់អាបត្តិ ១ ។

ចប់ បរិវារៈតែប៉ុណ្ណេះ ។

បរិយោសានគាថា

(៤៤៩) បុញ្ញាចរិយមក្ខញ្ញុ
បុច្ឆិត្វា វ តហឹ តហឹ
ឌីបងាមោ មហាបញ្ញោ
សុតងកោ វិចក្ខណោ
ឥមំ វិត្ថារសង្ខេបំ
សជ្ឈាមគ្គេន មជ្ឈិមេ
ចិន្តយិត្វា លិខាបេសិ
សិស្សកានំ សុខាវហំ ៕
បរិភាវន្តិ យំ វុត្តំ
សត្វំ វត្ថុំ សលក្ខណំ
អត្ថំ អត្ថេន សទ្ធម្មេ
ធម្មំ ធម្មេន បញ្ញត្តេ
សាសនំ បរិភាវេសិ
ជម្ពុទីបំវ សាគរេ ។
បរិភាវំ អជានន្តោ
កុតោ ធម្មវិនិច្ឆយំ ។

បរិយោសានគាថា

(៨៨៩) មហាអ្នកប្រាជ្ញមាននាមថា ទីប: ជាអ្នកទ្រទ្រង់សុត: គឺព្រះត្រៃបិដក មានប្រាជ្ញាជាគ្រឿងពិចារណា បានសាកសួរផ្លូវនៃអាចារ្យជាន់ដើម ក្នុងបាលីបទេសនោះៗ ហើយគិតឲ្យចារិកសេចក្តីពិស្តារនឹងសង្ខេបនេះ ដែលជាហេតុនាំមកឲ្យបានសេចក្តីស្រួលងាយ ដល់ពួកសិស្សានុសិស្សទុកក្នុងមជ្ឈិមបទេសតាមផ្លូវស្វាធ្យាយ ៗ វត្ថុណាដែលបានពោលថាបរិហារ: ដូច្នេះ វត្ថុទាំងអស់នោះប្រកបដោយលក្ខណៈ កាលបើព្រះសទ្ធម្មដែលព្រះពុទ្ធ បញ្ញត្តនូវអត្ថដ៏សមគួរ តាមអត្ថហើយ ទ្រង់បញ្ញត្តនូវធម៌ដ៏សមគួរ តាមធម៌ហើយ តែងលោមពោមអមសាសនា ដូចសាគរដែលព័ទ្ធជុំវិញជម្ពូទ្វីប ។ កាលបើកុល-បុត្រមិនចេះបរិហារ:ហើយ នឹងចេះវិនិច្ឆ័យធម៌អាចដូចម្ដេចកើតៗ

បរិយោសានគាថា បញ្ចមា

វិបត្តិ វត្ថុ បញ្ញត្តិ
អនុប្បញ្ញត្តិ បុគ្គលោ
ឯកតោ ឧភតោ ចេវ
លោកបណ្ណត្តិវជ្ជតោ
យស្ស ជាយតិ វិមតិ
បរិហារេន ឆិជ្ជតិ
ចក្កវត្តិ មហាសេនេ
មិគមជ្ឈេវ កេសរី
រវិ រំសិបរិកិណ្ណោ
ចន្ទោ តារគណេ យថា
ព្រហ្មា ព្រហ្មបរិសាយ
គណមជ្ឈេវ នាយកោ ។
ឯវំ សទ្ធម្មវិនយោ
បរិហារេន សោភតីតិ ។

បរិយោសានគាថា សេចក្ដីឧបមា ៥ យ៉ាង

សេចក្ដីសង្ស័យអាបត្តិក្ដី វត្ថុក្ដី បញ្ញត្តិក្ដី អនុប្បញ្ញត្តិក្ដី បុគ្គលក្ដី ឯកតោបញ្ញត្តិក្ដី ឧភតោបញ្ញត្តិក្ដី លោកវជ្ជៈក្ដី បណ្ណត្តិវជ្ជៈក្ដី កើតឡើងដល់កុលបុត្រណា កុលបុត្រនោះនឹងកាត់សេចក្ដីសង្ស័យបានដោយបរិហារៈ ស្ដេចចក្រតែងល្អរុងរឿងក្នុងកណ្ដាលទីប្រជុំមហាសេនា កេសររាជសីហ៍ល្អរុងរឿងក្នុងកណ្ដាលហ្វូងម្រឹគ ព្រះអាទិត្យមានរស្មីភ្លឺច្បាស់ (ល្អរុងរឿងលើអាកាស) ព្រះចន្ទល្អរុងរឿងក្នុងកណ្ដាលពពួកផ្កាយ ព្រហ្ម ជានាយក តែងល្អរុងរឿងក្នុងកណ្ដាលពួកនៃព្រហ្មជាបរិសទ្យ យ៉ាងណាមិញ ព្រះសទ្ធម្មនឹងព្រះវិន័យក៏ល្អរុងរឿង ដោយបរិហារៈយ៉ាងនោះដែរ ។

វិរុទ្ធាវិរុទ្ធបត្តំ

វិរុទ្ធបាឋោ	អវិរុទ្ធបាឋោ	អង្កេ	បន្តិលេខាយំ
វិស្សជ្ជិសំ	វិសជ្ជិស្សំ	១	៤
ឯកតរិកំ	ឯកុត្តរិកំ	១១	១
"	"	១៥	"
លទ្ធិនោចនយាបតិ	លទ្ធី នោ ច យាបតិ	១៦	៨
ឯកតរិកំ	ឯកុត្តរិកំ	២៧	១
គិលានោ–	គិលានោ	២៩	១៥
បារិវាសិកស្ស	បារិវាសិកស្ស	៣០	៦
ឯកុត្តរិកេ	ឯកុត្តរិកំ	៣៣	១
"	"	៣៥	"
សមនាគតស្ស	សមន្នាគតស្ស	៣៦	១៨
"	"	៣៧	"
ព្រហ្មចារី	ព្រហ្មចារី	៣៨	"
ឯកុត្តរិកេ	ឯកុត្តរិកំ	៣៩	១
ទុដ្ឋុល្លាទុដ្ឋុលំ	ទុដ្ឋុល្លាទុដ្ឋុល្លំ	៦៤	១៨
អនាគតតា	អនាគតត្តា	៧៧	១៧
បេសញ្ញា	បេសុញ្ញា	១០២	"
បគ្គលាទយោ	បុគ្គលាទយោ	១០៣	១
បញ្ញាត្តា	បញ្ញត្តា	១១៩	១៨
អធំករណំ	អធិករណំ	១៤២	៣
អាបត្តិ	អាបត្តី	១៤៧	១០
តតិយ	តតិយំ	១៥២	១៣
កិច្ចាធិករណា	កិច្ចាធិករណំ	១៥៥	៧

វិរុទ្ធាវិរុទ្ធបត្តំ

វិរុទ្ធបាឋ	អវិរុទ្ធបាឋ	អង្ក	បង្តិលេខាយំ
អាបត្តិយោ	អាបត្តិយា	១៥៥	១៥
អាបត្តាធិករណំ	អាបត្តាធិករណំ ។	១៥៨	៣
អម្ហូឡ្ហវិនយោ	អម្ហូឡ្ហវិនយោ	១៥៩	១៥
រុត្ត	រុត្តេន	១៩២	៥
បន្តនា	មន្តនា	១៩៥	៨
ទេ្វបតារីសេ	ទេ្វបត្តារីសេ	២០០	១៦
គនពូទិ	គន្ធពូទ្ធិ	២០៤	១៧
អាបតិតិ	អាបត្តីតិ	២១៦	២
គសេ	គស្សេ	"	១៤
ទេសនីយ	ទេសនីយំ	២១៩	៨
ជាភដិក	ជាភដិកំ	២១៩	១៧
ជាចិត្តិយ	ជាចិត្តិយំ	២២០	១៥
កំនេ	កំន្តេ	២២៣	១
ទុក្កដាបតិ	ទុក្កដាបត្តិ	"	១៤
និស្សយប្បច្ចយេ	និស្សយប្បច្ចយេ	២៣២	៣
បុព្វករណ	បុព្វករណំ	២៣៤	១១
វត្ថុ	វត្ថុ—	២៣៨	៣
បិវរេ	ចីវរេ	២៤៦	១៥
និភោជេ ន	និភោជេន	២៥២	"
សមពោបិ	សម្មពោបិ	២៦២	១២

វិរុទ្ធាវិរុទ្ធបត្តំ

វិរុទ្ធបាឋោ	អវិរុទ្ធបាឋោ	អង្កេ	បន្តិលេខាយំ
ឧបសង	ឧបសង្គ–	២៦៤	១៦
យថាធម្មេ–	យថាធម្មេ	២៦៦	២
បញ្ចង្គានី	បញ្ចង្គានិ	២៦៧	១
វគ្គ( )	វគ្គ(១)	២៧១	៤
ឧកា កម្មំ	ឧកាសកម្មំ	២៩៤	៦
កល្យា	កល្យា–	២៩៩	២
សមនាគតស្ស	សមន្នាគតស្ស	៣១៣	១១
ឧញ្ញហិកាវត្ថោ	ឧញ្ញហិកាវត្ថោ	៣២៩	១៨
វិនយំ	វិនយំ	៣៤៣	១៣
អវិនិធា	អវិនិធាយ	៣៤៧	៧
អាបច្ចតិ	អាបជ្ជតិ	៣៦១	៦
តតិយ	តតិយំ	៣៦២	១៣
ឋាភនិក	ឋាភនិកំ	"	១៤
សមនុភាសនា	សមនុភាសនា–	៣៦៦	៨
អាបតិយោ	អាបត្តិយោ	៣៧៩	២
បិណ្ឌិបាតប្បច្ចយា	បិណ្ឌបាតប្បច្ចយា	៣៨៤	៥
ពាទិនា–	ពាទិនា	៣៩១	"
វិនយបិដក	វិនយបិដកេ	៤០៤	១
អាបជ្ជិន្តស្ស	អាបជ្ជន្តស្ស	៤០៦	៩
អនុស្សាវនគោ	អនុស្សាវនកោ	៤១៨	៦
ឧបោសថ	ឧបោសថំ	៤១៩	១០
(៤៣៥)	(៤២៥)	"	១៣

សន្លឹកប្រាប់ពាក្យខុស-ត្រូវ

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
អាបត្តិក៏មាន	អាបត្តិ	១៣	៨
ប់បិល	អំបិល	១៩	១០
វៈនិយ	វិន័យ	២៣	២
ឯកតរិកៈ	ឯកុត្តរិកៈ	២៧	១
ជាភ–	ជាធិ–	២៤	៥
ឯកត្តរីកៈ	ឯកុត្តរិក	២៧	១
មិននមែន	មិនមែន	៣៧	១០
អាបតិ	អាបត្តិ	៤៥	១
សទ្ធិវិហារីក	សទ្ធិវិហារិក	៤៩	១២
នៅខាក្រៅ	នៅខាងក្រៅ	៥២	៦
ជាតិមោខ	ជាតិមោក្ខ	៥៧	៥
អាបត្ត	អាបត្តិ	"	៩
របស់ជាតិដទៃ	របស់ជនដទៃ	៦១	១៥
របស់ជាតិ	របស់ជន	"	១៦
ជាតិដទៃ	ជនដទៃ	៦២	៣
"	"	"	៤
និស្ស័យទ	និស្ស័យទេ	៦៩	២
(៩)	(៦៩)	៧៣	៩
គោខាយិ	គោខាយិត	៧៤	១០
ឆកៈ	ឆក្កៈ	៨០	១៥

សន្លឹកប្រាប់ពាក្យខុស-ត្រូវ

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
នាះ	នោះ	៨៥	១៨
សតកៈ	សត្តកៈ	៨៧	១
ប្រជ្ញា	ប្រាជ្ញា	៨៨	២
ក្នុងង	ក្នុង	"	៦
ប្រជ្ញា	ប្រាជ្ញា	"	១១
ម្រេច	សម្រេច	"	១៥
ប្រម្ហូស	ប្រម្ហូស១	៨៩	១២
ឯកុតរិកៈ	ឯកុត្តរិកៈ	៩១	១
របស	របស់	៩២	១៦
ជាតិជិវៃ	ជិនជិវៃ	៩៦	៤
"	"	"	៥
"	"	"	១៩
"	"	"	១២
ឯកុតរិតៈ	ឯកុត្តរិកៈ	៩៩	១
ភប់អានថា	ភប់ថា	៩៩	៥
សុប្តិ	សប្ត	១០៤	៣
ទវិពា	ទេវិពា	"	៤
ខន–	ខុន–	១២៣	១៧
ក្តិ	ក្តី	២២៥	៩
សមុខា	សម្មុខា–	១៣៤	៤

សន្លឹកប្រាប់ពាក្យខុស-ត្រូវ

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
នវ	នូវ	១៤៥	១៣
មួយទ	មួយទេ	១៥៤	៦
បុគល	បុគ្គល	"	១៦
ឈាភដិក	ឈាភដិក	១៥៦	១៣
អាធីរិបតិ	អាធីរិបត្តិ	១៧៦	៩
យ៉ាងរេះហ៊ា	យ៉ាងនេះហ៊ា	១៧៨	៣
អកទោទ	អ្នកទោទ	១៨៣	២
បតិបត្តិ	ប្រតិបតិ	"	៤
វិន្ទ័យ	វិន័យ	១៨៤	"
រមាប់	រម្យាប់	"	៤
ដាយ	ដោយ	១៩១	១៧
ពល់	ពន្យល់	២០៣	"
(១៩)	(១៩៧)	២១៦	១៣
ំពី	អំពី	២២៤	៨
មិឈាន	មិនឈាន	២២៩	១១
ដិល	ដែល	២៣០	៦
"	"	២៣២	១៦
បត្វករណៈ	បុត្វករណៈ	"	"
សាល់	ស្គាល់	២៦៩	១៨
ព្រះអង	ព្រះអង្គ	២៧៨	១០

សន្ទឹកប្រាប់ពាក្យខុស-ត្រូវ

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
៥រូប១	៥រូប១(១)	២៧៨	១៥
អដ្ឋកថា	១អដ្ឋកថា	"	១៧
សទ្ធា	សុទ្ធា	"	"
សីមនរិកកី	សីមន្តរិកក្តី	២៧៩	១៨
លំណាក់	សំណាក់	"	"
ប្ដេជា	ប្ដេជ្ញា	២៨៣	៣
សាកចា	សាកច្ឆា	២៨៥	១៤
ដេល	ដែល	"	១៦
បកប	ប្រកប	២៩៣	៤
អត្តាទាន	អត្តាទាន(១)	២៩៥	៥
ដិល	ដែល	៣០០	៦
ភែិក្ខុ	ភិក្ខុ	"	៩
ពីកម	ពីកម្ម	៣១០	១៧
ដិលគេ	ដែលគេ	៣១១	៥
គសាកសួរ	គេសាកសួរ	៣១៦	១៥
ឧព្វាហិកាកម្ម	ឧព្វាហិកាកម្ម(១)	៣២១	១០
ដាយ	ដោយ	៣២៦	៦
អដ្ឋថា	អដ្ឋកថា	៣៣៦	១៧
កែខ្លួបាន	កែខ្លួនបាន	៣៤៥	១១
ហីយ	ហើយ	"	១៥

សន្លឹកប្រាប់ពាក្យខុស-ត្រូវ

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
អតី	អំពី	៣៦៤	៨
ផើង្ស	ផ្សើង	៣៨២	៣
(៣៦)	(៣៦០)	៣៨៩	៨
ជាដេម	ជាដើម	៤០០	១៦
បន្ទោះស្រក	បន្ទោះស្រុក	៤០៤	១១
ភិក្ខុនីត្រូវបាចិត្តិយះ	ភិក្ខុត្រូវបាចិត្តិយះ	"	១៣
លោកចារ្យ	លោកអាចារ្យ	៤០៥	១៤
ភេត	ភេទ	៤០៦	១៥
មកហើយ	មកហើយ ។	៤១២	១៦
បណីកោធន	បណីតកោធន	៤១៣	១៧
សង្ឃភេទ	សង្ឃទេ	៤១៥	១៦
ញ៉ាំបុគ្គល	ញ៉ាំងបុគ្គល	៤២៤	៦
(៤៣៨)	(៤៣៧)	៤២៧	៤
រឹងរិត	រឹងរឹត	៤៣០	១៥

សន្លឹកចង្អុលប្រាប់មាតិកា

ខន្ធកបុច្ឆា

លេខទំព័រ

បុច្ឆាវិស្សជ្ជនា អំពីឧបសម្បទាខន្ធកៈជាដើម ១
អំពីចីវរសញ្ញត្តៈជាដើម ៣
អំពីសេនាសនក្ខន្ធកៈជាដើម ៥
ឧទ្ទានគាថា ៧

ឯកុត្តរិកៈ

ឯកកៈ (ពួកមួយៗ ត្រូវស្គាល់ធម៌ដែលធ្វើឲ្យត្រូវអាបត្តិជាដើម) ៩
ឧទ្ទានគាថា. ១១
ទុកៈ(ពួក ពីរៗ)អាបត្តិដែលប្រកបនឹងគ្រឿងបរិក្ខារជាដើម ១៣
អាបត្តិជាភាគិកទាំងពីរចំណែកជាដើម ១៥
ការហាមឃាត់មានពីរយ៉ាងជាដើម ១៧
ការមិនអើពើមានពីរយ៉ាងជាដើម ១៩
បុគ្គលពីរពួកជាដើម. ២១
ឧទ្ទានគាថា ២៣
តិកៈ (ពួកបីៗ) វត្ថុជាគ្រឿងចោទមាន ៣យ៉ាងជាដើម ២៧
ការបិទបាំងមាន ៣ យ៉ាងជាដើម ២៩
ការធ្វើកម្មមានតជ្ជនីយកម្មជាដើម ៣១
ការធ្វើកម្មមានឧក្ខេបនីយកម្មជាដើម ៣៣
កិច្ចមានការឲ្យឧបសម្បទាជាដើម ៣៥
មានភិក្ខុមិនមានខ្មាសជាដើម ៣៧
មូលនៃកុសល ៣ ជាដើម. ៣៩

ឯកុត្តរិកៈ

	លេខទំព័រ
ឧទ្ទានគាថា	៤១
ចតុក្កៈ (ពួកបួន ៗ) ការត្រូវនឹងការចេញចាកអាបត្តិជាដើម	៤៣
បរិភោគ ៤ ជាដើម	៤៧
សេចក្តីផ្សេងគ្នាដោយវត្ថុជាដើម	៤៩
ការត្រូវអាបត្តិតែក្នុងកាលមិនត្រូវក្នុងវិកាលជាដើម	៥១
ការមិនលុះអគតិទាំង ៤ ជាដើម	៥៣
ឧទ្ទានគាថា	៥៥
បញ្ចកៈ (ពួកប្រាំ ៗ) អាបត្តិមាន ៥ យ៉ាងជាដើម	៥៧
សំពត់បំសុកូល ៥ យ៉ាងជាដើម	៥៩
អង្គ ៥ របស់វិន័យធរ	៦១
អង្គ ៥ របស់ភិក្ខុមិនត្រូវនៅដោយឥតនិស្ស័យនឹងគួរនៅដោយឥតនិស្ស័យ	៦៣
អង្គ៥របស់ភិក្ខុនីដែលឥតនិស្ស័យនឹងមិនត្រូវនៅដោយឥតនិស្ស័យ	៦៩
អានិសង្ស ៥ ប្រការនឹងទោស ៥ ប្រការ	៧១
អានិសង្ស ៥ ប្រការ របស់ភិក្ខុអ្នកទ្រទ្រង់វិន័យ	៧៣
ឧទ្ទានគាថា	៧៥
ឆក្កៈ (ពួកប្រាំមួយ ៗ) អង្គ ៦ របស់ឧបជ្ឈាយ៍	៧៧
ឧទ្ទានគាថា	៨១
សត្តកៈ (ពួកប្រាំពីរ ៗ) អង្គ ៧ របស់ភិក្ខុជាវិន័យធរ	៨៣
អសទ្ធម្ម ៧ នឹងព្រះសទ្ធម្ម ៧	៨៩
អដ្ឋកៈ (ពួកប្រាំបី ៗ) អានិសង្ស ៨ ប្រការជាដើម	៩១

ឯកុត្តរិកៈ

លេខទំព័រ

នវកៈ (ពួកប្រាំបួនៗ) អាឃាតវត្ថុទាំង ៩ ជាដើម ៩៣

ទសកៈ (ពួកដប់ ៗ) វត្ថុជាទីកើតគំនុំទាំង១០ជាដើម. ៩៥

អង្គ ១០ របស់វិន័យធរ ៩៧

អង្គ ១០ ជាដើមរបស់ភិក្ខុដែលសង្ឃគួរសន្មតដោយឧព្វាហិកាកម្ម ៩៩

ឧទ្ទានគាថា ១០១

ឯកាទសកៈ (ពួកដប់មួយៗ) បុគ្គល ១១ ជាដើម ១០៣

ឧទ្ទានគាថា ១០៥

បុច្ឆាវិស្សជ្ជនាអំពីឧបោសថកម្មជាដើម

កម្មមានឧបោសថកម្មជាដើម ១០៧

ការសន្មតិភិក្ខុឲ្យជាអ្នកប្រដៅភិក្ខុនីជាដើម ១០៩

បករណៈសំដែងអំពីអំណាចប្រយោជន៍

មហាវគ្គ អំណាចនៃប្រយោជន៍ ១០ យ៉ាង. ១១៦

ឧទ្ទានគាថា. ១១៧

គាថាសង្គណិកៈ

បញ្ហាព្យាករណ៍ ១១៩

ការទ្រង់ព្យាករណ៍អាបត្តិមានអាបត្តិជាយាវតតិយកាជាដើម ១២៥

ការទ្រង់ព្យាករណ៍បុគ្គល ១១ រូបជាដើម ១២៧

ការទ្រង់ព្យាករណ៍សិក្ខាបទ ២២០ . . . . ១២៩

ការទ្រង់ព្យាករណ៍សិក្ខាបទដែលជាអសាធារណៈ ១៣១

សេចក្តីឧបមានៃបារាជិក ៨ ជាដើម ១៣៣

គាថាសង្គណិកៈ

លេខទំព័រ

អាបត្តិមានអាបត្តិសង្ឃាទិសេសជាដើម ១៣៥
អាបត្តិជាធិទេសនីយៈ ជាតារវ្ហៈ ១៣៧
សេក្ខិយសិក្ខាបទ ១៣៩

អធិករណភេទ

ការបាននូវការសើរើ ១០ យ៉ាងជាដើម ១៤៣
អធិករណៈមានកិច្ចាធិករណៈជាដើម ១៤៥
អាបត្តិនឹងអនាបត្តិនៃវិវាទាធិករណៈ ១៤៧
ការត្រូវអាបត្តិព្រោះអធិករណៈ ជាបច្ច័យ. ១៤៩
ការត្រូវអាបត្តិព្រោះបច្ច័យនៃអធិករណៈ ១៥០
សេចក្ដីអធិប្បាយនៃអធិករណៈមានវិវាទាធិករណៈជាដើម ១៥៥
សេចក្ដីអធិប្បាយនៃអធិករណៈមានអាបត្តាធិករណៈជាដើម ១៥៧
សំដែងអំពីពាក្យថា សតិវិន័យមានក្នុងទំណាងខ្លះជាដើម ១៥៩
សំដែងអំពីហេតុនៃសមថៈទាំង ៧ ជាដើម ១៦១
សំដែងអំពីអត្ថផ្សេង ៗ នៃសមថៈទាំង ៧ ជាដើម ១៦៥
អនុវាទាធិករណៈ ១៦៧
កិច្ចាធិករណៈ ១៦៩

គាថាសង្គណិកៈ ជាដំណាមក

បុច្ឆាវិស្សជ្ជនាអំពីអលជ្ជីបុគ្គលជាដើម ១៧៣
បុច្ឆាវិស្សជ្ជនាអំពីអ្នកចោទត្រូវតាមធម៌ជាដើម ១៧៥

ពោទនាកណ្ឌ

លេខទំព័រ

ការសាកសួរ របស់ភិក្ខុជាវិន័យធរ ១៧៩
សេចក្ដីប្រតិបត្តិ របស់ភិក្ខុជាវិន័យធរ ១៨១
សេចក្ដីប្រតិបត្តិរបស់អ្នកចោទនឹងអ្នកជាប់ចោទជាដើម ១៨៣
ការរិះគន់ខ្លួនឯងរបស់អ្នកជាប់ចោទ ១៨៥
ឧទ្ទានគាថា ១៨៩

ចូឡសង្គ្រាម

សេចក្ដីប្រតិបត្តិ របស់ភិក្ខុជាវិន័យធរ ១៩១
សេចក្ដីប្រតិបត្តិ ដើម្បីប្រយោជន៍មិនឲ្យក្ដៅក្រហាយចិត្តជាដើម. . . . ១៩៥
ភិក្ខុដែលបណ្ឌិតគប្បីរកប់រក ១៩៧

មហាសង្គ្រាម

ពាក្យថា ត្រូវស្គាល់និទានជាដើម ២០១
ពាក្យថា ត្រូវស្គាល់កម្មដែលគួរធ្វើនឹងមិនគួរធ្វើជាដើម. ២០៣
ការសំដែងនូវធម៌ថា មិនមែនធម៌ជាដើម ២០៥
ភិក្ខុជាវិន័យធរមិនត្រូវលំអៀងដោយទោសាគតិ ២០៧
ភិក្ខុជាវិន័យធរមិនត្រូវលំអៀងដោយភយាគតិ ២០៩
សេចក្ដីមិនលំអៀងដោយឆន្ទាគតិ ២១១
ការមិនលំអៀងដោយភយាគតិជាដើម ២១៣
ទីដែលគួរជ្រះថ្លាជាដើម ២១៥
សំដែងអំពីពាក្យថា មិនត្រូវពោលនូវហេតុដែលមិនទាន់មកដល់ជាដើម. ២១៧
សេចក្ដីប្រតិបត្តិ របស់ភិក្ខុជាវិន័យធរ ២១៩
ការចែកពាក្យមានពាក្យថា អ្នកបានឃើញនូវម្ដេចជាដើម ២២៣
ពាក្យថា លោកបានឃើញក្នុងទីណានឹងឧទ្ទានគាថា ២២៥

កឋិនភេទ

លេខទំព័រ

កម្មមានការធ្វើនិមិត្តជាដើម ២២៩
ធម៌ ១៥ ប្រការមានមាតិកា ៨ ជាដើម ២៣១
បច្ច័យមានអនន្តរប្បច្ច័យជាដើម ២៣៣
កិច្ចមានបុព្វករណៈជាដើមមានបយោគជាដើមធមជាដើម ២៣៥
កិច្ចមានបុព្វករណៈជាដើម លោកសង្គ្រោះដោយធម៌ ៧ យ៉ាង . . . ២៣៧
ការក្រាលកឋិនរបស់បុគ្គល ៣ ពួក ២៣៩
ការចែកពាក្យមានពាក្យថា ភិក្ខុគប្បីស្គាល់កឋិនជាដើម ២៤១
វិធីក្រាលកឋិន ២៤៣
បញ្ហាព្យាករណ៍អំពីបលិពោធក្នុងមាតិកាទាំង ៨ . . . . ២៤៥
ការដោះកឋិន និងឧទ្ទានគាថា ២៥១

ឧបាលិបញ្ចកៈ

សំដែងអំពីពាក្យថា ភិក្ខុមិនត្រូវឲ្យឧបសម្បទាជាដើម ២៥៥
អង្គ ៥ របស់ភិក្ខុដែលសង្ឃត្រូវធ្វើកម្ម ២៥៩
ឧទ្ទានគាថា ២៦១
ធម៌ ៥ ប្រការ របស់ភិក្ខុដែលចូលទៅកាន់សង្គ្រាម ២៦៣
អង្គ ៥ របស់ភិក្ខុដែលនិយាយក្នុងកណ្ដាលជំនុំសង្ឃ ២៦៥
ឧទ្ទានគាថា និងអង្គ ៥ មានមិនស្គាល់អាបត្តិជាដើម ២៦៩
អង្គ ៥ មាននិយាយសង្កត់សង្កិនគេជាដើម ២៧១
អង្គ ៥ មានស្គាល់កម្មជាដើម ២៧៣
អង្គ ៥ មានលំអៀងដោយឆន្ទាគតិជាដើម ២៧៥
អង្គ ៥ មានមិនចេះធម៌ជាដើម ២៧៧

ឧបាលិបញ្ចកៈ

លេខទំព័រ

ការប្រាប់សេចក្ដីយល់ឃើញដែលប្រកបដោយធម៌និងមិនប្រកបដោយធម៌ ២៧៩
ការទទួលប្រគេនប្រកបដោយធម៌ ៥ យ៉ាងនិងអនតិរិត្តភោជន ៥ យ៉ាង . ២៨១
បដិញ្ញាតករណៈដែលមិនប្រកបដោយធម៌មាន ៥ យ៉ាង ២៨៣
ភិក្ខុមិនគួរសាកសួរវិន័យជាមួយនឹងភិក្ខុ ២៨៥
សុទ្ធិមាន ៥ យ៉ាង ២៨៧
ភិក្ខុអ្នកចោទត្រូវពិចារណាធម៌ ៥ យ៉ាងទុកក្នុងខ្លួន ២៨៩
ភិក្ខុអ្នកចោទត្រូវធ្វើទុកក្នុងចិត្តនូវធម៌ ៥ យ៉ាងក្នុងខ្លួន. ២៩៣
ភិក្ខុត្រូវកាន់យកអត្តាទានដែលប្រកបដោយអង្គ ៥ . . . . ២៩៥
ភិក្ខុដែលមានឧបការៈច្រើនដល់ពួកភិក្ខុដែលកើតអធិករណ៍. ២៩៧
អង្គ ៥ របស់ភិក្ខុដែលមិនគួរសាកសួរនឹងគួរសាកសួរ ៣០១
ភិក្ខុអ្នកកាន់អារញ្ញកធុតង្គមាន ៥ ពួកជាដើម ៣០៥
មុសាវាទមាន ៥ យ៉ាងជាដើម ៣០៧
សង្ឃមិនត្រូវឲ្យការសាកសួរដល់ភិក្ខុប្រកបដោយអង្គ ៥ . . . . . . ៣០៩
ពៀរមាន ៥ យ៉ាង កិរិយាវៀរមាន ៥ យ៉ាង ៣១១
ឧទ្ទានគាថា ភិក្ខុនីសង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ៣១៣
សង្ឃត្រូវធ្វើកម្មដល់ភិក្ខុនីដែលប្រកបដោយអង្គ ៥ . . . . ៣១៥
ភិក្ខុមិនត្រូវឃាត់ឧបោសថដល់ភិក្ខុនីទាំងឡាយ. ៣១៧
ភិក្ខុមិនត្រូវសាកច្ឆាជាមួយនឹងភិក្ខុដែលប្រកបដោយអង្គ ៥ . . . . . ៣១៩
ឧទ្ទានគាថា សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្ម. ៣២១
ភិក្ខុប្រកបដោយអង្គ ៥ សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្ម . . . ៣២៣
សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មក៏មាន មិនគប្បីសន្មតក៏មាន . . . ៣២៥
ភារៈនៃភិក្ខុជាពាលនឹងជាបណ្ឌិត. ៣២៧
ភិក្ខុអាចរម្ងាប់អធិករណ៍បានក៏មាន មិនអាចក៏មាន ៣៣១

ឧបាលិបញ្ចកៈ

លេខទំព័រ

ការប្រេះធានៃសង្ឃនឹងការបែកធ្លាយនៃសង្ឃ ៣៣៧
ឧទ្ទានគាថា នឹងភិក្ខុបំបែកសង្ឃតែងទៅកើតក្នុងអបាយ ៣៣៩
ភិក្ខុអ្នកបំបែកសង្ឃតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ៣៤១
ឧទ្ទានគាថា ៣៤៩
ការដោះស្រាយវិន័យមិនប្រកបដោយធម៌មាន ៥ យ៉ាង ៣៥១
អង្គ ៥ របស់ភិក្ខុមានភិក្ខុជាភត្តុទ្ទេសកៈជាដើម ៣៥៣
អានិសង្សនៃការក្រាលកឋិននឹងទោសរបស់ភិក្ខុភ្លេចស្មារតី ៣៥៥
បុគ្គល ៥ ពួកដទៃទៀតដែលមិនគួរសំពះ ៣៥៧
ឧទ្ទានគាថា ៣៥៩

សមុដ្ឋាន

សង្ឃាទិសេស ១៣ . . . . ៣៦៣
សង្ឃាទិសេស១៣ នឹងសេក្ខិយៈ ៣៦៧
អនិយតៈ ២ នឹងនិស្សគ្គិយបាចិត្តិយៈ ៣០ . . . . ៣៦៩
សេក្ខិយៈ ៧៥ នឹងឧទ្ទានគាថា ៣៧១

ទុតិយគាថាសង្គណិកៈ

បុច្ឆាវិស្សជ្ជនា	អំពី មូលនៃវិន័យជាដើម	៣៧៣
	គរុកាបត្តិជាដើម	៣៧៥
	បុគ្គល ៣ ពួកជាដើម	៣៧៧
	អាបត្តិបាចិត្តិយៈ	៣៧៩

ទុតិយគាថាសង្គណិកៈ

លេខទំព័រ

បុញ្ញាវិស្សជ្ជនា អំពី យាវតតិយាបត្តិជាដើម ៣៨៣
មុសាវាទជាដើម ៣៨៥
អាឃាតវត្ថុជាដើម ៣៨៧
ទោសរបស់កម្មជាដើម ៣៨៩
កងនៃអាបត្តិជាដើម ៣៩១
ធម៌ទាំង ៨ ជាដើម ៣៩៣
កម្ម ៣៩៥
អនិយតៈជាដើម ៣៩៧
សេក្ខិយៈ ៣៩៩

សេទមោចនគាថា

ប្រស្នាសួរ អំពី ភិក្ខុដែលមិនសាធារណៈដោយសិក្ខាជាដើម . . . ៤០១
ការត្រូវគរុកាបត្តិជាដើម ៤០៣
ការលួចគរុភណ្ឌជាដើម ៤០៥
គរុកាបត្តិជាដើម ៤០៧
ការធ្វើកម្មដល់បុគ្គលដែលនៅចំពោះមុខជាដើម ៤០៩
សេនាសនៈនៅក្នុងព្រៃជាដើម ៤១១
បុគ្គលត្រេកអរហើយត្រេកអរថែមទៀតជាដើម ៤១៣
ការមិនបានឲ្យនឹងមិនបានទទួលជាដើម ៤១៥
ឧទ្ទានគាថា ៤១៧

បញ្ចវគ្គ

	លេខទំព័រ
វត្ថុវិបត្តិ និងញត្តិវិបត្តិ	៤១៩
បរិសវិបត្តិ	៤២១
កម្ម ៤ យ៉ាង និងវត្ថុវិបត្តិ	៤២៣
សីមាវិបត្តិ និងបរិសវិបត្តិ	៤២៥
កម្មទាំងឡាយមានអបលោកនកម្មជាដើម	៤២៧
ទ្រង់បញ្ញត្តសិក្ខាបទ ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ . .	៤២៩
ទ្រង់បញ្ញត្តបាតិមោក្ខ ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ . .	៤៣១
ទ្រង់បញ្ញត្តតិណវត្ថារកៈ ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ .	៤៣៣
ត្រូវឲ្យប្រាប់រឿងក៏ ត្រូវនឹងវត្ថុជាដើម	៤៣៥
នាមផង អាបត្តិផងជាដើម	៤៣៧
ឧទ្ទានគាថា	៤៣៩

បរិយោសានគាថា

សេចក្តីឧបមា ៥ យ៉ាង	៤៤៣

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ ៖

Printing costs were met through the gift of

Namuno-Kai　Kyoshi Nakajima・Shun Sakai
1-31-1 Ikegami, Ohta-ku, Tokyo　Japan

この本は次の方によって復刻されました。

南無の会　中島教之・阪井　舜
〒146 東京都大田区池上1-31-1
☎03-3754-6194

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 13 (of 110 volumes total)
"VINAYA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

トリピタカ（南伝大蔵経）全110巻・第13巻ヴィナヤピタカ（律部）

発　　行：プノンペン仏教研究所
復刻救援：カンボジア版トリピタカ（南伝大蔵経）復刻救援委員会
発　　行：1994年12月8日

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE